ចំណេះដឹងជាមូលដ្ឋាន

អំពី

សភាជាន់ខ្ពស់

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

គ.ស ២០១១

ស្វែងយល់

ចំណេះដឹងជាមូលដ្ឋាន

អំ ពី

សភាជាន់ខ្ពស់

ឈ្មោះរបស់សភាជាន់ខ្ពស់

ការកកើត ឃ្មបានសភាជាន់ខ្ពស់

ចំនួនសមាជិក ការរៀបចំ និងការឃ្មាក្រឹត្តនៅរបស់សភាជាន់ខ្ពស់

អាណត្តិ សមាសភាព

ការផ្លាស់ប្តូរជាវ៉ៃក សម៉ឃឃ្មជុំ ភាពមិនអាចរៃលាយបាន

ភាពជាតំណាង ធំនាក់ធំនងជាមូយដ្ឋសភានិងអង្គការនីតិឃ្មតិបត្តិ

ណែនាំនិងឲ្យបត្តម្ពដោយ :ឯកឲ្យត្តម អ៊ឹ សារ៉ឌ្ឋ អត្តលេខាធិការឃ្មាក្រឌ្ឋសភា

សឃ្ឋលនិងរៀបរៀងដោយ :ឯកឲ្យត្តម ឥម លី អត្តនាយកនងនៃអត្តនាយកដ្ឋានវ្ជបាលនិងហិរញ្ញវត្ថុ

ពិនិត្យនិងផ្ទៀងផ្ទាត់ដោយ: ឯកឲ្យត្តម ឡោក ធាយ អត្តនាយកនៃអត្តនាយកដ្ឋានវ្ជបាលនិងហិរញ្ញវត្ថុ

ចាយកុំព្យូធ៍ និងរចនាឃ្មបដោយ :ឈោក លី រដ្ឋា បុគ្គលិកនាយកដ្ឋានព៍ត៌មានវិទ្យា

ឆ.ស ២០១១

មាតិកា

មរិយាយ	ឥណ្ឌិ
អារម្ភកថា	១
គាគឥ១ ឥឌ្ឋគាពរូមនៃសគាជាន់ខ្ពស់	
១-ឈ្មោះរបស់សភាជាន់ខ្ពស់	២
២-របៀបបង្កើត	៤
៣-ចំនួនសមាជិក	៦
៤-អាណត្តិ	៦
៥-ការផ្ទាស់ប្តូរជាផ្ទែក	៧
៦-ភាពមិនអាចរំលាយបាន	៧
៧-ភាពជាតំណាង	៧
៨-ប្រធានសភាជាន់ខ្ពស់	៨
៩-ការរៀបចំ និងការប្រព្រឹត្តទៅរបស់សភាជាន់ខ្ពស់	៨
គាគឥ២ សគាជាន់ខ្ពស់នៃបណ្ណាវ្ឋ	
អាហ្ហហ្ហានីស្ថាន	៩
អាហ្ហ្រីកខាងត្បូង	១៨
អាល់ហ្សេរី	២៥
អាល់ឡឺមីង់	៣១
អង់ទីហ្ហា និងបាប៊ូដា	៣៩
អាហ្ហ្ហ្រង់ទីន	៤៣
អូស្ត្រាលី	៥១
អូទ្រីស	៥៦

បាហាម៉ាស	៦២
បារ៉ែន	៦៦
បារបាត	៧១
ប៊ីយេឡូរុស្ស៊ី	៧៥
បែលហ្ស៊ិក	៧៦
ប៊ីលីស៍	៨២
ប្ចលីវី	៨៤
ប្ចស្ន៊ី ហេហ្សេកូវីន	៥០
ប្ចតស្វាណា	៥៤
ប្រេស៊ីល	៥៨
ប៊ូរុនឌ៊ី	១០៦
កម្ពុជា	១២២
កាណាដា	១២៥
ឈីលី	១២៥
កូឡុំប៊ី	១៣៥
កុងហ្គោ(Brazzaville)	១៤៤
កុងហ្គោ(សាធារណរដ្ឋប្រជាធិបតេយ្យ)	១៥២
អេហ្ស៊ីប	១៥៥
អេត្យូពី	១៦៤
បារាំង	១៦៥
ហ្គាបុង	១៧៨
ហ្ស្រ៊ីណាដ	១៨៧
ហាយទី	១៥២

ឥណ្ឌា	១៩៨
ឥណ្ឌូណេស៊ី	២០២
អៀរឡង់	២០៥
អ៊ីតាលី	២០៨
ហ្សាម៉ាអ៊ិក	២១៤
ជប៉ុន	២១៩
ហ៊ូកដានី	២២៣
កាហ៊ូ៉ាក់ស្ថាន	២២៩
ឡឺសូថូ	២៣៧
លីបេរីយ៉ា	២៤១
ម៉ាដាកាស្ការ	២៤៨
ម៉ាឡេស៊ី	២៥៧
ម៉ារ៉ុក	២៦១
ម៉ូរីតានី	២៦៨
ម៉ាឡាវ	២៧៧
ម៉ារ៉ាហ្គាយ	២៨៣
ហុលឡង់	២៩១
ហ្វីលីពីន	២៩៥
ប៉ូឡូញ	៣០២
ម៉ាតីស្ថាន	៣០៧
ម៉ិកស៊ិក	៣០៩
ណាមីប៊ី	៣១២
សាធារណរដ្ឋដូមីនីកែន	៣១៥

សាធារណរដ្ឋឆែក	៣២០
រូម៉ានី	៣២៦
ចក្រភពអង់គ្លេស	៣៣៤
រុស្សុី	៣៤២
ហ្វ៉ាន់ដា	៣៥០
សាំង លូស៊ី	៣៥៩
សេណេហ្គាល់	៣៦៤
ស្លូវេនី	៣៦៨
ស៊ូដង់	៣៧
ស្វីស	៣៧៩
ស្វាស៊ីលែន	៣៨១
តាស៊ីតីស្ថាន	៣៨៣
ទ្រីណីតេ និងតូបាកូ	៣៨៥
ទុយនីស៊ី	៣៩០
អ្លូរហ្គាយ	៣៩៦
យេម៉ែន	៤០៧
ហ្សុីមបាវៃ	៤០៨
ហ្វីដហ្សុី	៤១០
ប៊ូតីណាហ្វាសូ	៤១៥
ក្រូអាស៊ី	៤២០
ត្យៀហ្គីស្ថាន	៤២៤
ម៉ាឡាវី	៤២៨
ណេប៉ាល់	៤៣០

ហុលឡង់ ៤៣៦
ឆាត ៤៤០
យូហ្គោស្លាវី ៤៤៧

-ចម់-

អារម្ភកថា

សៀវភៅនេះរៀបចំឡើងក្នុងគោលបំណងរួមចំណែកបង្កើននូវចំណេះដឹងជាមូលដ្ឋានអំពីព្រឹទ្ធសភា ដល់មន្ត្រីរាជការរបស់សភានិងជួយដល់អ្នកអាន ជាអាទិ៍ មន្ត្រីរាជការ សិស្ស និស្សិត ដែលចង់យល់ដឹង អំពីព្រឹទ្ធសភានៃប្រទេសនានាដែលមានភាពប្លែក១ត្នា និងមានការវិវត្តប្រែប្រួល ឱ្យងាយស្រួលយល់អំពីចំណុចមួយចំនួនទាក់ទងនឹងការកកើត ការរៀបចំ ការប្រព្រឹត្តទៅ តួនាទី ភារកិច្ច សិទ្ធិ អំណាចរបស់ព្រឹទ្ធសភានិងទំនាក់ទំនងរវាងព្រឹទ្ធសភា រដ្ឋសភា និងរដ្ឋាភិបាលនៃប្រទេសនីមួយ១ ។ ខ្លឹមសារសង្ខេបនេះផ្ទែកតាមឯកសារព្រឹទ្ធសភាពិភពលោក ។

ប៉ុន្តែខ្លឹមសារនានាដែលមានចែងពិតជាមិនបានល្អិតល្អន់គ្រប់ជ្រុងជ្រោយឡើយ និងនៅមានការខ្វះខាតជាច្រើនទៀត ទាំងពាក្យពេចន៍បកប្រែពីភាសាបរទេស ទាំងអក្ខរាវិរុទ្ធ ទាំងការតាក់តែងឃ្លាប្រយោត ។ល ។ ម្យ៉ាងទៀត ការខ្វះខាតខ្លះទៀតបណ្តាលមកពីការច្នើបច្ចុប្បន្នភាពមិនបានគ្រប់ជ្រុងជ្រោយទៅតាមការវិវត្តិនៃសភាមួយចំនួននៅតាមតំបន់នានា ។

ខ្ញុំសូមមិត្តអ្នកអានមេត្តាអភ័យទោសចំពោះកំហុសឆ្គងទាំងឡាយនេះ ហើយរង់ចាំទទួលដោយពេញចិត្តជានិច្ចនូវមតិជួយកែតម្រូវទាំងឡាយពីមិត្តអ្នកអានគ្រប់រូប ។

ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះឯកឧត្តម អ៊ុ សារីទ្ធ អត្តលេខាធិការព្រឹទ្ធសភាដែលបានជួយអភិវឌ្ឍសមត្ថភាពយើងខ្ញុំតតឈប់ឈរ និងបានណែនាំ ព្រមទាំងផ្តល់ឱកាសឱ្យខ្ញុំរៀបចំសៀវភៅនេះឡើងតាំងពីដើមរហូតដល់ចប់ ។

ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម ឡោក ឆាយ អត្តនាយកនៃអត្តនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុនៃអត្តលេខាធិការដ្ឋានព្រឹទ្ធសភា ដែលបានជួយត្រួតពិនិត្យលើការរៀបចំឯកសារនេះ ។

សូមឱ្យសៀវភៅនេះបានជាប្រយោជន៍ដល់ការអភិវឌ្ឍន៍ព្រឹទ្ធសភាកម្ពុជាតរៀងទៅ ។

ភ្នំពេញ ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០១១

ភាគទី១

ទិដ្ឋភាពរួមនៃសភាជាន់ខ្ពស់

តាមការសិក្សាអំពីសភាជាន់ខ្ពស់ជាច្រើនកន្លងមកនេះពុំមានឃើញមានអ្វីជាកំរូ សម្រាប់ការបង្កើតការប្រៀប ធំនិងការប្រព្រឹត្តទៅនៃសភាទាំងនេះទេ ។ លក្ខណៈប្លែកៗគ្នាអាស្រ័យ ទៅតាមរដ្ឋនីមួយៗជ្រើសរើសយក ដោយយោលទៅតាមស្ថានភាពនយោបាយ សេដ្ឋកិច្ច សង្គម ភូមិសាស្ត្រនិងប្រវត្តិសាស្ត្រផ្សេងៗខ្លួន ហើយសភាជាន់ខ្ពស់តែងមានការប្រែប្រួលពីតំណាក់មួយទៅតំណាក់កាលមួយដោយឥតឈប់ឈរ ។

១. ឈ្មោះរបស់សភាជាន់ខ្ពស់

សភាជាន់ខ្ពស់ (la Chambre haute) ជាឈ្មោះដែលគេឱ្យទៅសភាទី២ ។ រដ្ឋសភា គេហៅថាសភាជាន់ទាប (la Chambre basse) ។ សភាជាន់ខ្ពស់កើតឡើងតាមរបៀបផ្សេងៗគ្នា ឯសភាជាន់ទាបកើតចេញពីការបោះឆ្នោតជាសកល ចំពោះរដ្ឋ ដែលប្រកាន់របបប្រជាធិបតេយ្យ ។

ក្នុងរដ្ឋនីមួយៗដែលប្រកាន់របបសភាពីរ សភាជាន់ខ្ពស់របស់ខ្លួនមានឈ្មោះប្លែកៗគ្នាទោះ បីជាមានរដ្ឋចំនួនច្រើនបានប្រើឈ្មោះព្រឹទ្ធសភា (le Sénat) ក៏ដោយ ។

ក្រៅពីហៅព្រឹទ្ធសភាសភាជាន់ខ្ពស់ នៅមានហៅថា **ក្រុមប្រឹក្សា** (Conseil) ដូចជា ក្រុមប្រឹក្សាជាតិ (Conseil national) ក្រុមប្រឹក្សាជាតិនៃបណ្តារដ្ឋ (Conseil national des Etats) ក្រុមប្រឹក្សាសហព័ន្ធ (Conseil fédéral) ក្រុមប្រឹក្សានៃបណ្តារដ្ឋ (Conseil des Etats) ឬហៅថាសភា (Chambre) ដូចជាសភានៃបណ្តាប្រជាជន (Chambre des Peuples) សភានៃបណ្តាប្រធាន (Chambre des Chefs) សភានៃបណ្តាទីប្រឹក្សា (Chambre des Conseillers) សភានៃបណ្តាសាធារណរដ្ឋ ។ល ។

រដ្ឋដែលប្រើឈ្មោះ**ព្រឹទ្ធសភា**មានជាអាទិ៍ : អង់ទីហ្គានិងបាប៊ីយដា (Antigua-et-Barbuda) អាហ្សង់ទីន(Argentine) អូស្ត្រាលី(Australie) បាហាម៉ាស (Bahamas) បាបាត (Barbade) បែលហ្សិក(Belgique) បឺលីហ្ស(Belize) ប្រេស៊ីល(Brésil) បូលីវី (Bolivie) ប៊ីរុនឌី(Burundi) កម្ពុជា(Cambodge) កាណាដា(Canada) ស៊ីលី (Chili) កូឡុំបី(Colombi) កុងហ្គោ -ប្រាសាវ៊ីល(Congo-Brasaville) កុងហ្គោ -សាធារណរដ្ឋ ប្រជាធិបតេយ្យ (Congo-République démocratique) អេស្ប៉ាញ (Espagne) សហ រដ្ឋអាមេរិក (Etats-Unis d'Amérique) ហ្ជិដហ្ស៊ី-កោះ (Fidji-Ile) បារាំង(France) ហ្គាបុង(Gabon) ហ្ជ្រឺណាត (Grenade) ហៃទី(Haïti) អៀឡង់(Irlande) អ៊ីតាលី (Italie) ហ្សាម៉ាអ៊ីក (Jamaïque) ហ្ស៉ីរដានី (Jordanie) កាហ្សាក់ស្តាន (Kazakhstan) ឡីហ្សុថូ (Lesotho) លីបេរីយ៉ា (Liberia) ម៉ាដាហ្គាស្គា(*Madagascar*) ម៉ាឡេស៊ី (Malaisie) ម៉ូរីតានី (Moritanie) ម៉ិកស៊ិក (Mexique) នីហ្សេរីយ៉ា(Nigéria) ប៉ាឡាវ(Palaos) ប៉ារ៉ាហ្គាយ(Paraguay) ហ្ជីលីពីន (Philippines) ប៉ូឡូញ (Pologne) សាធារណរដ្ឋដូមីនីកែន (République Dominicaine) រូម៉ានី (Roumanie) សាំងលូស៊ីល (Sainte-Lucile) សេណេហ្គាល (Sénégal) ស្វាស៊ីឡែន (Swaziland) ឆែក-សាធារណរដ្ឋ(Tchèque-République) ថៃឡង់ (Thailande) ទ្រីនីតេ និង តូបាហ្គោ (Trinité-et-Tobago) អ៊ីយរុយហ្គាយ(Uruguay) ហ្ស៊ីមបាវៃ (Zimbawé) ។

រដ្ឋដែលប្រើឈ្មោះ**ក្រុមប្រឹក្សា**(Conseil) មានជាអាទិ៍: អាហ្ជ្រិកខាងត្បូង(Afrique du Sud) ក្រុមប្រឹក្សាជាតិនៃបណ្តាខេត្ត (Conseil national des provinces) អាល់ហ្សេរី (Algérie) ក្រុមប្រឹក្សាប្រជាជាតិ (Conseil de la Nation) អាឡឺម៉ង់(Allemagne) ក្រុម ប្រឹក្សាសហព័ន្ធ (Conseil fédéral) អូទ្រីស(Autriche) ក្រុមប្រឹក្សាសហព័ន្ធ (Conseil fédéral) បារ៉ែន (**Barène**) ក្រុមប្រឹក្សាពិគ្រោះយោបល់(Conseil consultatif) បេឡារុស្ស៊ី (Biélorussie) ក្រុមប្រឹក្សាសាធារណរដ្ឋ(Conseilde République) អេត្យូពី (Ethiopie) ក្រុមប្រឹក្សាសហព័ន្ធ (Conseil de la Fédération) ឥណ្ឌា(Inde) ក្រុមប្រឹក្សានៃបណ្តារដ្ឋ (Conseil des Etats) ណាមីប៊ី(Namibie) ក្រុមប្រឹក្សាជាតិ (Conseil national) ណេប៉ាល់ (Népal) ក្រុមប្រឹក្សា (Conseil national) រុស្ស៊ី(Russie) ក្រុមប្រឹក្សាសហព័ន្ធ (Conseil de la

Fédération) រ្វាន់ដា(Rwanda) ក្រុមប្រឹក្សាជាតិ (Conseil national) ស្លូវេនី (Slovénie) ក្រុមប្រឹក្សាជាតិ (Conseil national) ស៊ូដង់(Soudan) ក្រុមប្រឹក្សានៃបណ្តារដ្ឋ(Conseil des Etats) ស្វីស(Suisse) ក្រុមប្រឹក្សានៃបណ្តារដ្ឋ(Conseil des Etats) យ៉ាម៉ែន(Yémén) ក្រុមប្រឹក្សាជូរ៉ា(Conseil de la Choura) ។ល។ និង ។ល។

រដ្ឋដែលប្រើឈ្មោះ**សភា** (Chambre) មានជាអាទិ៍ : បូស្នីហេហ្ស ហ្គូវីន (Bosnie-Herzégovine) សភានៃបណ្តាប្រជាជន (Chambre des Peuples) បូតស្វាណា(Botswana) សភានៃបណ្តាប្រធាន (Chambre des Chefs) អ៊ីណូណេស៊ី (Indonésie) សភានៃតំណាងតំបន់ (*Chambre des présentants des régions*) ជប៉ុន(Japan) សភានៃបណ្តាទីប្រឹក្សា (Chambre des conseillers) ម៉ារ៉ុក(Maroc) សភាបណ្តាទីប្រឹក្សា (Chambre des Conseillers) ហូលឡង់(Pays-Bas) សភាទី១នៃបណ្តារដ្ឋធំ (Première Chambre de Etats Généraux) ចក្រភពអង់គ្លេស(Royaume-Uni) សភាអភិជន (Chambre des Lords) ទុយនីស៊ី(Tunésie) សភានៃបណ្តាទីប្រឹក្សា (Chambre des Conseillers) យូហ្គូស្លាវី(Yougoslavie) សភាបណ្តាសាធារណរដ្ឋ(Chambre des Républiques) ។ល។

២.អង្គការបង្កើត

ដោយសារភាពខ្លួកៗគ្នានៃប្រព័ន្ធនយោបាយ ប្រព័ន្ធច្បាប់ និងលទ្ធភាពដែលសមាសភាពនានានៅក្នុងរដ្ឋអាចទទួលយកបាន សភាជាន់ខ្ពស់ដែលហៅថាព្រឹទ្ធសភា ឬក្រុមប្រឹក្សានោះបានត្រូវបង្កើតឡើងលើមូលដ្ឋានរដ្ឋធម្មនុញ្ញ និងច្បាប់ ។

ការសិក្សាបានបង្ហាញថាសភាជាន់ខ្ពស់កើតជារូបភាពតាមរបៀបជាច្រើន ហើយបត់បែនទៅតាមតំណាក់កាលផ្សេងៗ អាស្រ័យតាមបរិដ្ឋាននយោបាយនិងសង្គម ហើយអាចសរុបមកមានរបៀបបីយ៉ាងគឺ (១)ចោះឆ្នោតជ្រើសតាំងទាំងស្រុង (២)ចោះឆ្នោតជងនិងតែងតាំងជង (៣)តែងតាំងទាំងស្រុង ។

ក-សភាជាន់ខ្ពស់ដែលកើតឡើងដោយការជ្រើសតាំងទាំងស្រុង

មានសភាជាន់ខ្ពស់ចំនួន៣៥ (ក្នុងចំណោមសភាជាន់ខ្ពស់ទាំងអស់៦៧) ដែលសមាជិក

ទាំងអស់ត្រូវបានជ្រើសតាំងដោយការបោះឆ្នោត ។ ការបោះឆ្នោតនេះមាន២យ៉ាង គឺការបោះឆ្នោតដោយផ្ទាល់(scrutin direct) និងការបោះឆ្នោតមិនផ្ទាល់ (scrutin indirect) ។

រដ្ឋដែលប្រើវិធីបោះឆ្នោតដោយផ្ទាល់មានជាអាទ៍ អូស្ត្រាលី ប្ចលីវី ជប៉ុន ម៉ិកស៊ិក ប៉ូឡូញ ប្រេស៊ីល ស្វ៊ីស សហរដ្ឋអាមេរិក ។ល ។ រដ្ឋដែលប្រើវិធីបោះឆ្នោតមិនផ្ទាល់ មានជាអាទ៍ អាហ្វ្រិកខាងត្បូង ហ្គាបុង រុស្ស៊ី ។ល ។ នៅអាហ្វ្រិកខាងត្បូង ការបោះឆ្នោតធ្វើឡើងដោយសភានីតិប្បញ្ញត្តិខេត្ត (assemblées législatives des provinces) ។

វិធីនេះត្រូវបានយកមកប្រើ នៅរដ្ឋជាច្រើនទៀតដូចជាអូទ្រីស និងអេត្យូពីជាដើម ។ ជាទូទៅ វិធីនេះច្រើនប្រើនៅតាមរដ្ឋដែលមានទម្រង់ជាសហព័ន្ធ ។

ហ្គាបុងបានប្រើវិធីបោះឆ្នោតដោយតំណាងសមូហភាពដែនដី (représentants des collectivities territoriales) ដូចគ្នានឹងម៉ូរីតានី បារាំង កម្ពុជា ។ រុស្ស៊ីប្រើវិធីឱ្យមានតំណាងអង្គនីតិប្រតិបត្តិ និងនីតិប្បញ្ញត្តិនៅក្នុងសភាជាន់ខ្ពស់ ។ នៅអាឡឺម៉ង់គឺជាតំណាងរដ្ឋាភិបាល តាមដែនដី ជ្រើសរើសដោយសភានីតិប្បញ្ញត្តិតាមតំបន់ ។

នៅមានតំរូមួយទៀតសំរាប់សហព័ន្ធ គឺប្រព័ន្ធចំរុះ ។ រដ្ឋពីរបានប្រើប្រព័ន្ធចំរុះគឺបោះឆ្នោតដោយផ្ទាល់ផង និងបោះឆ្នោតមិនផ្ទាល់ផង ។រដ្ឋទាំងពីរនោះគឺ អេស្ប៉ាញ និង បែលហ្ស៊ិក ។ នៅអេស្ប៉ាញ សមាជិកសភាជាន់ខ្ពស់២០៨រូប ត្រូវបានជ្រើសតាំងដោយ ការបោះឆ្នោតដោយផ្ទាល់ និង៤៥រូប ដោយការបោះឆ្នោតមិនផ្ទាល់ ។ នៅបែលហ្ស៊ិក ៤០រូបត្រូវបានជ្រើសតាំងដោយការបោះឆ្នោតដោយផ្ទាល់ និង២១រូប ដោយក្រុមប្រឹក្សាសហគមន៍ ហើយ១០រូបទៀតត្រូវបានជ្រើសតាំងដោយសមាជិក៦១រូបខាងលើ ។

ខ-ព្រឹទ្ធសភាដែលកើតពីការបោះឆ្នោតផងនិងតែងតាំងផង (វិធីចំរុះ)

រដ្ឋមួយចំនួន សមាជិកសភាជាន់ខ្ពស់មួយផ្ទែកត្រូវបានជ្រើសតាំង និងមួយផ្ទែកទៀតត្រូវបានតែងតាំង ។ចំពោះការជ្រើសតាំង រដ្ឋខ្លះដូចជាស៊ីលី ក្រូអាស៊ី អ៊ីតាលី ប្រើវិធីបោះឆ្នោតដោយផ្ទាល់ រដ្ឋជាច្រើនទៀតប្រើការបោះឆ្នោតមិនផ្ទាល់ ដូចជាអាល់ហ្ស៊ីរី អ្យៀរឡង់ កម្ពុជា កាហ្ស៊ាក់ស្ថាន ។ល ។ ទោះជាយ៉ាងណា ជាទូទៅសមាជិកជ្រើសតាំងតែងមានចំនួនច្រើនជាសមាជិកតែងតាំង (៥៦/១៤៤នៅអាល់ហ្ស៊ីរី ,៣៨/៤៧នៅស៊ីលី , ៤៥/៦០ នៅអ្យៀរឡង់ , ៣១៥/៣២៤ នៅអ៊ីតាលី ,៥៥/៦១ នៅកម្ពុជា ,៣២/៣៥ នៅកាហ្ស៊ាក់ស្ថាន) ។

គ-ព្រឹទ្ធសភាដែលកើតពីការតែងតាំងទាំងស្រុង

នៅរដ្ឋមួយចំនួន សមាជិកសភាជាន់ខ្ពស់ត្រូវបានតែងតាំងទាំងស្រុង ។ រដ្ឋទាំងនោះមាន ជាអាទិ៍ អាឡឺម៉ង់ អង់ទីហ្គានិងបាប៊ុយដា បាហាម៉ាស់ បារ៉ែន បាបាត បឺលី បូស្នី ហេហ្សេកូវីន កាណាដា ហ្គ្រីណាត ហ្សាម៉ាអ៊ិក ហ្ស៊រដានី ឡឺហ្សូថូ ចក្រភពអង់គ្លេស ទ្រីនីតេនិងតូបាហ្គោ យ៉េមែន ។

៣-ចំនួនសមាជិក

ចំនួនសមាជិកសភាជាន់ខ្ពស់មានការប្រែប្រួលច្រើន ឬ តិចទៅតាមស្ថានភាពរបស់រដ្ឋនីមួយៗ ។ សភាជាន់ខ្ពស់ភាគច្រើនមានសមាជិកមិនលើសពី១១០រូបឡើយ លើកលែងតែមួយចំនួនតូចដែលមានសមាជិកលើសពីនេះ ។ តាមចំនួនសមាជិក សភាជាន់ខ្ពស់ អាចត្រូវបានចែកជា៣ក្រុម ។

ទី១ជាក្រុមដែលមានសមាជិកក្រោម៣០រូប ។ ក្រុមនេះមានជាអាទិ៍បូលីវី ស៊ីលី ប៉ារ៉ា-ហ្គាយ ហ្វីលីពីន អ៊ូរុយ ហ្គាយ ។ល ។ សភាជាន់ខ្ពស់ដែលមានសមាជិកក្រោម ១៩នាក់ ភាគច្រើនជារដ្ឋនៅតំបន់ការ៉ាអ៊ីប (ផ្ទៃដីតូច ប្រជាជនតិច) ។

ទី២ ជាក្រុមដែលមានសមាជិកពី៤៩រូប ទៅ១០៩រូប ។ រដ្ឋទាំងនេះមានជាអាទិ៍ អាឡឺ-ម៉ង់ អូទ្រីស អៀរឡង់ ហុលឡង់ បែលហ្ស៊ិក ម៉ាឡេស៊ី កម្ពុជា ណេប៉ាល់ អូស្ត្រាលី កាណាដា សហរដ្ឋអាមេរិក ប្រេស៊ីល កូឡុំប៊ី អាហ្សង់ទីន ម៉ូរីតានី ហ្គាបុង អេត្យូពី នីហ្សេរីយ៉ា ក្រូអាស៊ី សាធារណរដ្ឋឆែក ប៉ូឡូញ ។ល ។

ទី៣ ជាក្រុមដែលមានសមាជិកលើសពី១០៩រូប មានជាអាទិ៍ ឥណ្ឌា អេស្ប៉ាញ ជប៉ុន ថៃឡង់ អេហ្ស៊ីប ម៉ារ៉ុក បារាំង អ៊ីតាលី និងចក្រភពអង់គ្លេស ។

៤-អាណត្តិ

ជាទូទៅសភាជាន់ខ្ពស់មានអាណត្តិពី៤ឆ្នាំទៅ៦ឆ្នាំ ។ មានសភាជាន់ខ្ពស់តែ៥ទេ ដែលមានអាណត្តិលើសពី៦ឆ្នាំ ។ សភាទាំង៥នោះមាននៅប្រេស៊ីល និង ស៊ីលី(៨ឆ្នាំ),បារាំង ម៉ារ៉ុក និងលីបេរីយ៉ា(៩ឆ្នាំ) ។ សភាជាន់ខ្ពស់ដែលមានអាណត្តិក្រោម៤ឆ្នាំមានតែ៣ទេ គឺនៅបុស្នីហេ-

ហ្ស៊ីកូវីន(២ឆ្នាំ) ប៊ូតីណាហ្វាសូ និង ម៉ាឡេស៊ី(៣ឆ្នាំ) ។ នៅចក្រភពអង់គ្លេស សមាជិកសភាជាន់ខ្ពស់ទាំងអស់ត្រូវតែងតាំងអស់មួយជីវិត ។នៅបូស្វាណា៨/១៥នៃសមាជិកសភាជាន់ខ្ពស់ត្រូវបានតែងតាំងតាមរបៀបតំណពូជ ។ នៅកាណាដា សមាជិកសភាជាន់ខ្ពស់ត្រូវបានតែងតាំងរហូតដល់អាយុ៧៥ឆ្នាំ ។ សភាជាន់ខ្ពស់៣ តីនៅអាឡឺម៉ង់ អូទ្រីស និងរុស្ស៊ី មានអាណត្តិប្រែប្រួលទៅតាមអាណត្តិរបស់អង្គអ្នកបោះឆ្នោត ។

៥-ការផ្លាស់ប្តូរថ្មីជាផ្នែកជាការធានានូវស្ថេរភាពរបស់សភា ។ មានប្រទេសជាច្រើនបានប្រើរបៀបនេះ ។ ប្រទេសទាំងនោះមាន ជាអាទ៍ អាហ្ស៊ង់ទីន អូស្ត្រាលី ប្រេស៊ីល ស៊ីលី អេហ្ស៊ីបបារាំង ហៃទី ឥណ្ឌា ម៉ារុំក ម៉ូរីតានី ណេប៉ាល់ ហ្វីលីពីន សាធារណរដ្ឋឆែក ។ល ។

៦-គាតមិនអាចរំលាយបាន

សភាជាន់ខ្ពស់ភាគច្រើនមិនអាចត្រូវរំលាយបានឡើយ នៅក្នុងអាណត្តិ ។ របៀបនេះ ជាការធានានូវស្ថេរភាព និងនិរន្តរភាពរបស់រដ្ឋ ។ មានរដ្ឋចំនួនតែ១៩ ប៉ុណ្ណោះដែលរដ្ឋធម្មនុញ្ញ បានចែងអំពីសិទ្ធិរំលាយសភាជាន់ខ្ពស់ ។ រដ្ឋទាំងនោះ មានជាអាទ៍ បែលហ្ស៊ីក អេស្ប៉ាញ អ៊ីតាលី ហុលឡង់ ជប៉ុន ម៉ារុំក កាហ្ស៊ាក់ស្ថាន ថៃឡង់ ណេប៉ាល់ អ៊ីរុហ្ពាយ ។ល ។

៧-គាតជាតំណាង

របបសភាពីរអនុញ្ញាតឱ្យមានភាពជាតំណាងនានានៃសមាសភាពរបស់សង្គម និងជាការធ្វើឱ្យមានប្រព័ន្ធសភាដែលមានតុល្យភាព ។

ក-ទំរង់តាមដែនដីរបស់រដ្ឋ

ក្រុមប្រឹក្សាជាតិបណ្ណាខេត្តនៃសាធារណរដ្ឋអាហ្វ្រិកខាងត្បូង ឬ ក្រុមប្រឹក្សាសហព័ន្ធរុស្ស៊ីជាឧទាហរណ៍នៃទម្រង់តាមដែនដី ។ ផ្សេងពីនេះ ក្រុមប្រឹក្សាសហព័ន្ធអេត្យូពី ជ្រើសតាំងដោយក្រុមប្រឹក្សាខេត្ត តំណាងប្រជាជាតិនានា សញ្ជាតិនានា ឬប្រជាពលរដ្ឋក្នុងប្រទេសឬ ព្រឹទ្ធ-សភាប្រេស៊ីលដែលជាតំណាងរដ្ឋនានាជាសមាជិករដ្ឋសហព័ន្ធ ។

មុខងារជាតំណាងសមូហភាពដែនដី ជាត្រីះរដ្ឋធម្មនុញ្ញរបស់សភាបារាំង ហើយក៏ជាត្រីះ
របស់ព្រឹទ្ធសភាហ្គាបុង កម្ពុជា និងម៉ូរីតានី ។

ខ-មុខរបរ ស្រទាប់សង្គម និងកម្លាំងសកម្មរបស់ជាតិ

ចំនួន២/៥នៃសមាជិកសភាក្រុមប្រឹក្សាម៉ារ៉ុកថ្មី ត្រូវបានជ្រើសរើសដោយសភាមុខរបរ (chambres professionelles) ។

៨-ប្រធានសភាជាន់ខ្ពស់

ប្រធានសភាជាន់ខ្ពស់ស្ថិតក្នុងឋានុក្រមទី២ឬទីពារបស់រដ្ឋ ហើយជាទូទៅប្រធានសភាជាន់ខ្ពស់ទទួលជាប្រមុខរដ្ឋស្ថីទី ក្នុងករណីដែលប្រមុខរដ្ឋមិនអាចបំពេញមុខងារបាន ។ យ៉ាងនេះបញ្ជាក់ថាជាការផ្តល់ឱ្យសភាជាន់ខ្ពស់ នូវតួនាទីធានានិរន្តរភាពនៃស្ថាប័នធម្មនុញ្ញ ។ រដ្ឋដែលប្រធានសភាជាន់ខ្ពស់ទទួលជាប្រមុខរដ្ឋ ក្នុងករណីដែលប្រមុខរដ្ឋមិនអាចបំពេញមុខងារបានមានជាអាទិ៍ អាល់ហ្សេរី អាឡឺម៉ង់ ប្ចលីវី កម្ពុជា ស៊ីលី បារាំង ហ្គាបុង អ៊ីតាលី កាហ្សាក់ស្ថាន ម៉ូរីតានី រូម៉ានី សាធារណរដ្ឋឆែក ។ នៅសហរដ្ឋអាមេរិក ឥណ្ឌា លីបេរី ប្រធានសភាជាន់ខ្ពស់ជាអនុប្រធានាធិបតី ។

ក្រៅពីនេះ ប្រធានសភាជាន់ខ្ពស់នៅមានមុខងារជាច្រើនទៀតក្នុងស្ថាប័នជាន់ខ្ពស់របស់រដ្ឋ ។

៩-ការរៀបចំ និងការប្រព្រឹត្តទៅរបស់សភាជាន់ខ្ពស់

សភាជាន់ខ្ពស់នានាមានការរៀបចំជាការិយាល័យអចិន្ត្រៃយ៍ និងមានចែកចេញជាគណៈកម្មការជំនាញនានាដែលមានកំណត់តួនាទី និងភារកិច្ចរៀងៗខ្លួន ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់សភាជាន់ខ្ពស់មានកំណត់នៅក្នុងបទដ្ឋានមួយ ។

ភាគទី២

សភាជាន់ខ្ពស់នៃបណ្ណារដ្ឋ

អាហ្វហ្គានីស្ថាន **មៃស្រាណូហ្ស៊ីហ្គា**

AFGANISTAN

រដ្ឋធម្មនុញ្ញថ្ងៃ១៤ មករា ២០០៤ បានបង្កើតសភាពីរ ។

ការបោះឆ្នោតនីតិប្បញ្ញត្តិដែលត្រូវធ្វើក្នុងពេល១ឆ្នាំ ក្រោយការបោះឆ្នោតជ្រើសរើសប្រធានាធិបតី ថ្ងៃ៩ខែតុលា២០០៤ បានប្រព្រឹត្តទៅនៅថ្ងៃ១៨ខែកញ្ញា ២០០៥ ។

ក្នុងរយៈពេលនេះអំណាចរបស់សភាបានផ្ទេរទៅឱ្យរដ្ឋាភិបាល ។ បទប្បញ្ញត្តិទាំងឡាយដែលបានអនុម័តរូចត្រូវដាក់ឆ្លងរដ្ឋសភានៅសម័យប្រជុំលើកទី១ ។

I-សមាសភាព

សមាជិកមានចំនួន១០២នាក់ ត្រូវជាពាដងនៃចំនួនខេត្តដែលមាន(៣៤) ។

មៃស្រាណូ ហ្ស៊ីហ្គា មានសមាជិកពាប្រភេទ:

១- តំណាងនៃក្រុមប្រឹក្សាខេត្តទាំង៣៤ ដែលជ្រើសរើសដោយការបោះមិនផ្ទាល់ (suffrage indirect) ។

២-តំណាងនៃក្រុមប្រឹក្សាស្រុក (districts)នៃខេត្តមួយ១ ដែលជ្រើសរើសដោយការបោះមិនផ្ទាល់ (suffrage indirect) ។

៣-សមាជិក៣៤នាក់ដែលតែងតាំងដោយប្រធានាធិបតី ។

ii-របបបោះឆ្នោត និងតែងតាំង

ប្រព័ន្ធ : ភាគច្រើន ពីរជុំ

អាណត្តិ :

-៤ឆ្នាំ ចំពោះសមាជិកដែលជ្រើសរើសដោយក្រុមប្រឹក្សាខេត្ត

-៣ឆ្នាំ ចំពោះសមាជិកដែលជ្រើសរើសដោយក្រុមប្រឹក្សាស្រុក

-៥ឆ្នាំ ចំពោះសមាជិកដែលតែងតាំងដោយប្រធានាធិបតី ។

អាយុ: ៣៥ឆ្នាំ ។

សមភាពរវាងបុរសនិងស្ត្រី : សមាជិកដែលតែងតាំងដោយប្រធានាធិបតីត្រូវមានពាក់កណ្តាលជាស្ត្រី ។

តំណាងជនជាតិភាគតិច : សមាជិក២នាក់ដែលតែងតាំងដោយប្រធានាធិបតីជាជនពិការ និង២នាក់ជាចរកជន (nomades-les Kuchi) ។

វិសមិតភាព:

-រវាងអាណត្តិជាសមាជិករដ្ឋសភា និងអាណត្តិជាសមាជិកព្រឹទ្ធសភា ។

-រវាងអាណត្តិជាសមាជិកព្រឹទ្ធសភា (mandat sénatorial) និងសមាជិកក្រុមប្រឹក្សាអ្នកបោះឆ្នោតមូលដ្ឋាន (membre du conseil local d'électeurs) ។

-រវាងអាណត្តិជាសមាជិកសភា (mandat parlementaire) និងមុខងារជារដ្ឋមន្ត្រី (fonction ministerielle) ។

បោះឆ្នោតលើកទី១ : ១៨ កញ្ញា ២០០៥ ។

តែងតាំងលើកទី១:ធ្នូ ២០០៥ ។

កំណត់ចំណាំ : ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាស្រុក (conseils de districts) មិនបានធ្វើនៅ ខែកញ្ញា ឆ្នាំ២០០៥ទេ ដោយសារមានបញ្ហាខ្លះ ។

រដ្ឋសភា នៅពេលបម្លែងឡើងនឹងដោះស្រាយបញ្ហាទាំងនេះ ។

ដើម្បីបំពេញអាសនៈ៣៤សំរាប់សមាជិកក្រុមប្រឹក្សាស្រុកម៉ៃស្រាណូបហ្ស៊ីហ្ក មានបន្ថែម

ពីលើសមាជិកតែងតាំង ៣៤នាក់ ឲ្យតំណាងក្រុមប្រឹក្សាខេត្ត២នាក់ក្នុងមួយខេត្ត ដែលត្រូវជា ៦៨នាក់ ។ ក្នុងចំណោមនេះ ពាក់កណ្តាល គឺ៣៤ នាក់ស្ថិតនៅក្នុងតំណែង រហូតដល់មានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាស្រុក ។

III-សម័យប្រជុំ

សម័យប្រជុំត្រូវគ្នានឹងសម័យប្រជុំរដ្ឋសភា ។

ក-សម័យប្រជុំសាមញ្ញ

មានពីរសម័យប្រជុំសាមញ្ញក្នុងមួយឆ្នាំ ។ ចំរៃវេលាសរុប៩ខែយ៉ាងច្រើន ។

ខ-សម័យប្រជុំវិសាមញ្ញ

ប្រធានាធិបតីកោះប្រជុំវិសាមញ្ញ ។

គ-ការពន្យារសម័យប្រជុំ

សម័យប្រជុំសាមញ្ញត្រូវបានពន្យារ ក្នុងករណីចាំបាច់ ។

ម្យ៉ាងទៀត បើការពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ ដែនការអភិវឌ្ឍន៍ ឬអត្ថបទដែលទាក់ទងនឹងសន្តិសុខសាធារណៈ ឬរណភាពដែនដី ឬឯករាជជាតិមិនទាន់ចប់ សម័យប្រជុំត្រូវបន្តដោយពេញច្បាប់ រហូតដល់ចប់សព្វគ្រប់ ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអង្គការនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-ឥទ្ធិពលផ្តួចផ្តើមធ្វើច្បាប់ និងការចុះក្នុងរបៀបវារៈ

សមាជិកមេ៉ស្រាណូហ្ស៊ីហ្ការ៉ាដូចជាសមាជិកវ៉ូឡ្ស៊ីស៊ីហ្ស៊ីហ្ការ៉ (តំណាងរាស្ត្រ) ឬរដ្ឋាភិបាលមានសិទ្ធិផ្តួចផ្តើមឥទ្ធិពលធ្វើច្បាប់លើកលែងតែវិស័យថវិកា និងហិរញ្ញវត្ថុដែលជាសិទ្ធិរបស់រដ្ឋាភិបាល ។ ក្នុងវិស័យយុត្តិធម៌ ឥទ្ធិពលផ្តួចផ្តើមជារបស់រដ្ឋាភិបាល និងពិនិត្យដោយតុលាការជាន់ខ្ពស់ ។

ម្យ៉ាងទៀត បើសេចក្តីស្នើច្បាប់ដែលស្នើឡើងដោយសមាជិក១០នាក់នៃសភាណាមួយ ហើយបានអនុម័តដោយសមាជិកមួយភាគប្រាំ សេចក្តីស្នើច្បាប់នោះអាចចុះក្នុងរបៀបវារៈរបស់ខ្លួន ។

២-សិទ្ធិធ្វើវិសោធនកម្ម

សមាជិកមេំស្រាណូ ហ្ស៊ីហ្ហា ចែកវំលែកជាមួយសមាជិក វ៉ូឡីស៊ីហ្ស៊ីហ្ហា នូវសិទ្ធិកែប្រែ ឬនិរាករណ៍ច្បាប់ក៏ដូចជាក្រិត្ស ។ ហេតុនេះសមាជិកមេំស្រាណូហ្ស៊ីហ្ហាមានសិទ្ធិធ្វើវិសោធនកម្ម ។

៣-នីតិវិធីធម្មតា

សមាជិកមេំស្រាណូហ្ស៊ីហ្ហា (សមាជិកព្រឹទ្ធសភា) មិនមានសិទ្ធិពេញលេញដូចសមាជិក វ៉ូឡីស៊ីហ្ស៊ីហ្ហា(អ្នកតំណាងរាស្ត្រ) ក្នុងនីតិវិធីធម្មតាឡើយ ។

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ធម្មតាជាកម្មវត្ថុនៃការពិនិត្យតែមួយលើកតត់ក្នុងសភាមួយ១ ។

សេចក្តីព្រាងទាំងនេះត្រូវតែបញ្ជូនជាលើកដំបូងមកសភាតំណាងរាស្ត្រ ។ សេចក្តីព្រាងទាំងនោះត្រូវបញ្ជូនទៅព្រឹទ្ធសភាបន្ទាប់ពីសភាតំណាងរាស្ត្រអនុម័តរួច ។ សភាជាន់ខ្ពស់មានរយៈពេល១៥ថ្ងៃ ដើម្បីបញ្ជាប់ការសម្រេចរបស់ខ្លួន ។

រឫៀបវារៈជាអាទិភាពនៃសភាទាំងពីរគឺ សេចក្តីព្រាងច្បាប់ដែលរដ្ឋាភិបាលស្នើសុំប្រកាសជាការប្រញ្ជាប់ ។

សភាមួយ១បង្កើតគណៈកម្មការនានាស្របតាមបទបញ្ជារបស់ខ្លួនដើម្បីពិនិត្យបញ្ជាដែលត្រូវពិភាក្សា ។

សេចក្តីសម្រេចទាំងឡាយត្រូវយកតាមមតិភាគច្រើន លើកលែងតែរដ្ឋធម្មនុញ្ញចែងខុសពីនេះ ។

ក្នុងករណីមិនឯកភាពគ្នារវាងសភាទាំងពីរ គណៈកម្មការចំរុះសមភាគីមួយត្រូវបានបង្កើតឡើងឱ្យទទួលបន្ទុករកការព្រមព្រៀងគ្នា ។បើសិនគណៈកម្មការចំរុះរកបានកិច្ចព្រមព្រៀងលើអត្ថបទមួយ អត្ថបទនោះត្រូវបានយកទៅប្រកាសឱ្យអនុវត្តដោយប្រធានាធិបតី ។

បើសិនគណៈកម្មការចំរុះមិនអាចរកការព្រមព្រៀងបាន សេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នោះត្រូវចាត់ទុកថាបានបដិសេធ ហើយសេចក្តីព្រាងនោះនឹងត្រឡប់មកសភាតំណាងរាស្ត្រនៅសម័យប្រជុំបន្ទាប់ ដែលលើកនេះត្រូវអនុម័តដោយសម្លេងភាគច្រើន២/៣ ។

៤-បញ្ញត្តិពិសេសក្នុងវិស័យថវិកា និងផែនការ

សិទ្ធិរបស់ព្រឹទ្ធសភាមិនស្មើនឹងសិទ្ធិរបស់សភាតំណាងរាស្ត្រទេ ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ថវិកាឬច្បាប់ហិរញ្ញវត្ថុ ។ ថវិកាជាតិនិងផែនការអភិវឌ្ឍន៍នានារបស់រដ្ឋាភិបាល ត្រូវតែបញ្ជូនមកសភាតំណាងរាស្ត្រ ហើយត្រូវសុំយោបល់ពីព្រឹទ្ធសភាដែលក្នុងករណីនេះគ្រាន់តែជាសភាពិគ្រោះយោបល់តែប៉ុណ្ណោះ ។

បើសិនជាថវិកាមិនបានអនុម័តមុនដើមឆ្នាំសារពើពន្ធទេ ថវិកាមុននៅតែយកមកអនុវត្ត បានរហូតដល់អនុម័តថវិកាថ្មីបាន ។

ម្យ៉ាងទៀត គណនីថវិកាឆ្នាំចាស់ត្រូវតែបញ្ជូនមកសភាទាំងពីរក្នុងរយៈពេល៦ខែក្រោយចប់ការិយបរិច្ឆេទ ។

៥-បញ្ញត្តិពិសេសក្នុងវិស័យបោះឆ្នោត

សេចក្តីស្នើកែប្រែច្បាប់បោះឆ្នោតមិនអាចចុះក្នុងរបៀបវារៈបានទេ ក្នុងឆ្នាំមុនមានការបោះឆ្នោត ។

៦-ក្រិត្យច្បាប់

ក្រិត្យច្បាប់ដែលចេញដោយរដ្ឋាភិបាលជាបណ្តោះអាសន្ន លើមូលដ្ឋានមាត្រា ១៦០នៃរដ្ឋធម្មនុញ្ញ គឺនៅពេលមុនការបង្កើតសភាជាតិ ដោយបោះឆ្នោតត្រូវតែបញ្ជូនទៅសុំការពិនិត្យពីសភា ក្រោយពេលដែលកើតសភាដែលបដិសេធជាយថាហេតុនូវក្រិត្យច្បាប់ទាំងនោះ ។

ម្យ៉ាងទៀត ក្នុងករណីព្យួរការងាររបស់សភាតំណាងរាស្ត្រ ដូចជានៅចន្លោះសម័យប្រជុំ រដ្ឋាភិបាលអាចអនុម័តបញ្ញត្តិច្បាប់ដែលមានលក្ខណៈប្រញាប់ក្នុងវិស័យផ្សេងពីថវិកា និងហិរញ្ញ-វត្ថុ ។

បញ្ញត្តិទាំងនេះត្រូវតែបញ្ជូនទៅសភាទាំងពីរក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីថ្ងៃដែលសភាចាប់ផ្តើមការងារ ។ ក្នុងករណីដែលសភាបដិសេធបញ្ញត្តិទាំងនេះត្រូវទុកជាមោឃៈ ។

ខ-ការត្រួតពិនិត្យសកម្មភាពរដ្ឋាភិបាល

១-សំណួរ

គណៈកម្មការរបស់សភាអាចសួររដ្ឋមន្ត្រីម្នាក់ៗ លើបញ្ហាជាក់លាក់ទាំងឡាយ ។ អ្នកដែលត្រូវសួរត្រូវផ្តល់ចម្លើយផ្ទាល់មាត់ ឬជាលាយលក្ខណ์អក្សរ ។

២-ការចូលរួមរបស់រដ្ឋមន្ត្រីក្នុងសម័យប្រជុំ

ព្រឹទ្ធសភាក៏ដូចជារដ្ឋសភា អាចស្នើសុំឱ្យរដ្ឋមន្ត្រីចូលរួមក្នុងសម័យប្រជុំ ។

៣-គណៈកម្មការអង្កេត

ព្រឹទ្ធសភាក៏ដូចជារដ្ឋសភាអាចបង្កើតគណៈកម្មការពិសេសក្រៅពីគណៈកម្មការអចិន្ត្រៃយ์នានា ដើម្បីពិនិត្យមើលសកម្មភាពរបស់រដ្ឋាភិបាល ឬអង្កេតសកម្មភាពរបស់រដ្ឋាភិបាល ។

គណៈកម្មការទាំងនេះ ត្រូវបង្កើតឡើងតាមសំណើពីសមាជិកចំនួនមួយភាគបី ។

៤-របាយការណ์ប្រចាំឆ្នាំអំពីការអនុវត្តថវិកា

រយៈពេល៦ខែក្រោយចប់ឆ្នាំសារពើពន្ធ រដ្ឋាភិបាលបង្ហាញសភាជាតិ គឺរដ្ឋសភា និង ព្រឹទ្ធសភានូវរបាយការណ์ អំពីការអនុវត្តថវិកាឆ្នាំចាស់ ។

៥-វិស័យអន្តរជាតិ

ព្រឹទ្ធសភាក៏ដូចជារដ្ឋសភាមានសមត្ថកិច្ចផ្តល់សច្ចាប័នលើសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិនានា ឬលប់ចោលសន្ធិសញ្ញាឬកិច្ចព្រមព្រៀងអន្តរជាតិណាមួយ ។

គ-ការយល់ព្រមលើការសម្រេចរបស់ប្រធានាធិបតី

តាមរដ្ឋធម្មនុញ្ញ សេចក្តីសម្រេចខ្លះរបស់ប្រធានាធិបតីត្រូវមានការយល់ព្រមពីសភាដើម្បីអាចអនុវត្តបាន ។

១-ការប្រកាសសង្គ្រាម ឬការសន្ធិដ្ឋានអំពីសន្តិភាព

ប្រធានាធិបតីប្រកាសសង្គ្រាម ឬសន្ធិដ្ឋានអំពីសន្តិភាព ដោយមានការយល់ព្រមពីសភា។

២-ប្រតិបត្តិការប្រដាប់អាវុធនៅក្រៅប្រទេស

ការបញ្ជូនកងកម្លាំងប្រដាប់អាវុធទៅក្រៅប្រទេស ត្រូវប្រកាសដោយប្រធានាធិបតី ដោយមានការយល់ព្រមពីសភា។

៣-ស្ថានភាពអាសន្ន

ការប្រកាស ឬការបញ្ចប់ភាពអាសន្នជាទូទៅ ឬមួយផ្នែកនៃប្រទេសធ្វើឡើងដោយ ប្រធានាធិបតី ដោយមានការយល់ព្រមពីសភា។

ស្ថានភាពដែលអាចប្រកាសភាពអាសន្នមាន : សង្គ្រាម ការតម្រាមនៃសង្គ្រាម ការបះ បោរធ្ងន់ធ្ងរ មហន្តរាយពីធម្មជាតិ ឬស្ថានភាពប្រហាក់ប្រហែល ដែលមិនអាចការពារឯករាជ្យ ជាតិ តាមបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ។

ការបន្តស្ថានភាពអាសន្នលើសពីពីរខែ ត្រូវតែមានការយល់ព្រមជាថ្មីពីសភា។

ក្នុងស្ថានភាពអាសន្ន ក្រោយការពិគ្រោះយោបល់ជាមួយប្រធានសភា(រដ្ឋសភានិងព្រឹទ្ធ-សភា) និងប្រធានតុលាការកំពូល ប្រធានាធិបតីអាចផ្ទេរសមត្ថកិច្ចរបស់សភាទៅឱ្យរដ្ឋាភិបាល។

ដូចគ្នានេះដែរ ដោយមានការយល់ព្រមពីប្រធានសភា និងពីតុលាការកំពូល ប្រធានាធិប តីអាចព្យួរ ឬបន្ថយសេរីភាពបុគ្គលរបស់ពលរដ្ឋ ដែលមានរៀបរាប់ក្នុងរដ្ឋធម្មនុញ្ញ(ភាពមិនអាច រំលោភលើរាងកាយ សិទ្ធិធ្វើបាតុកម្ម ការសម្ងាត់នៃការឆ្លងឆ្លើយ ភាពមិនអាចរំលោភលើលំនៅ ដ្ឋាន)។

បើអាណត្តិរបស់ប្រធានាធិបតី ឬរបស់សភាត្រូវចប់ក្នុងរយៈពេលនៃស្ថានភាពអាសន្ន អាណត្តិនេះអាចបន្តបាន ៤ខែ។

ក្នុងស្ថានភាពអាសន្ន រដ្ឋធម្មនុញ្ញមិនអាចធ្វើវិសោធនកម្មបានឡើយ។

V-បទឧក្រិដ្ឋនិងទណ្ឌ

ក-សមាសភាពការិយាល័យ

មុនចាប់ផ្តើមការងារ ព្រឹទ្ធសភាជ្រើសរើសប្រធានសំរាប់មួយនីតិកាល និងលេខាធិការពីរ រូបសំរាប់ពេលមួយឆ្នាំ ។ បទបញ្ជាផ្ទៃក្នុងដែលត្រូវអនុម័តនៅពេលខាងមុខនឹងអាចចែងអំពីតំណែងអនុប្រធាន ។

ខ-សម័យប្រជុំរួម

សភាតីរដ្ឋសភា និងព្រឹទ្ធសភាប្រជុំរួមគ្នា :

-ពេលបើកនីតិកាល ឬបើកសម័យប្រជុំប្រចាំឆ្នាំ ដោយប្រធានាធិបតី

-ពេលប្រធានាធិបតីយល់ថាចាំបាច់ ។

ក្នុងករណីនេះ ការប្រជុំត្រូវដឹកនាំដោយប្រធានរដ្ឋសភា ។

ត-សភាធំ(Grande assemblée-Loya Jirga)

សភាធំខុសគ្នាពីសភាទាំងពីរួមគ្នា ។

. សមាសភាព :

-សមាជិកនៃសភាទាំងពីរ

-ប្រធាននៃបណ្តាក្រុមប្រឹក្សាខេត្ត(Conseils des provinces) និងស្រុក(districts) ។

. សភាធំប្រជុំក្នុងករណីពា :

- ដើម្បីសម្រេចបញ្ជាដែលទាក់ទងនឹងឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី និងផលប្រយោជន៍ខ្ពស់របស់ជាតិ

- ដើម្បីកែប្រែរដ្ឋធម្មនុញ្ញ

- ដើម្បីដំណើរការផ្លូវច្បាប់ប្រឆាំងនឹងប្រធានាធិបតី អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើក្បត់ ឬឧក្រិដ្ឋ ។

ឃ-ការបញ្ជប់មុខងារប្រធានាធិបតី

. ការលាលែង :

ប្រធានាធិបតីអាចដាក់ពាក្យសុំលាលែងទៅសភា ។

. ស្ពីទី :

ក្នុងករណីមរណភាពព្រមគ្នានៃប្រធានាធិបតី និងអនុទាំងពីរ ប្រធានព្រឹទ្ធសភាទទួល

ជាប្រធានាធិបតីស្តីទី ។

. ការវិនិច្ឆ័យទោសប្រធានាធិបតី :

បើមានសំណើពីសមាជិករដ្ឋសភាចំនួនមួយភាគបី និងតាមការអនុម័តដោយសម្លេងពីរភាគបីរបស់រដ្ឋសភាសុំឱ្យចោទប្រកាន់ប្រធានាធិបតីអំពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ អំពើក្បត់ឬឧក្រិដ្ឋ សភាត្រូវសម្រេចលើការចោទប្រកាន់នោះតាមសម្លេងភាគច្រើនពីរភាគបី ។

បើមានការយល់ព្រមពីសភាធំ ប្រធានាធិបតីត្រូវទទួលការកាត់សេចក្តីពីតុលាការពិសេសមួយដែលមានប្រធានព្រឹទ្ធសភា សមាជិករដ្ឋសភាពីនាក់ និងសមាជិកតុលាការកំពូលពីនាក់ តែងតាំងដោយសភាធំ ។

ង-ការសើរើរដ្ឋធម្មនុញ្ញ

ការផ្តួចផ្តើមគំនិតសើរើរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់ប្រធានាធិបតី ដោយមានការយល់ព្រមពីសមាជិកសភា តាមសម្លេងភាគច្រើន ។

សេចក្តីព្រាងនៃការសើរើរដ្ឋធម្មនុញ្ញត្រូវរៀបចំដោយគណៈកម្មការមួយដែលមានសមាជិករដ្ឋាភិបាល សមាជិកសភា សមាជិកតុលាការកំពូល ដែលតែងតាំងដោយក្រឹត្យរបស់ប្រធានាធិ-បតី ។ សេចក្តីព្រាងនេះត្រូវអនុម័ត ដោយសភាធំតាមសម្លេងភាគច្រើន២ / ៣ ។

អាហ្វ្រិកខាងត្បូង ក្រុមប្រឹក្សាជាតិនៃបណ្តាខេត្ត

AFRIQUE DU SUD LE CONSEIL DES PROVINCES

សភានៃរដ្ឋបាលខេត្ត និងមូលដ្ឋានក្រុមប្រឹក្សាជាតិនៃបណ្តាខេត្តត្រូវបានបង្កើតឡើងដើម្បីឱ្យមានចំនាក់ចំនងខ្លាំងក្លាវាងសភា និងខេត្តទាំង៩ ។

I.សមាសភាព

គណៈប្រតិភូមួយដែលមានទីប្រឹក្សា១០នាក់សំរាប់ខេត្តមួយៗ ។ ទីប្រឹក្សាទាំងអស់មាន ៩០នាក់ ។

II.របបបោះឆ្នោត

ការបោះឆ្នោតធ្វើឡើងដោយមិនផ្ទាល់ (indirect) ។ គណបក្សនានាដែលមានតំណាងនៅសភានីមួយៗក្នុងចំណោមសភាខេត្តទាំង៩ចាត់សមាជិកត្រីទ្វសភា១០នាក់ លើមូលដ្ឋានអត្រាសម្លេងឆ្នោតដែលគណបក្សនីមួយៗបានទទួលក្នុងពេលបោះឆ្នោតខេត្ត ។

សមាជិក៦នាក់ជាប្រតិភូអចិន្ត្រៃយ៍ ហើយ៤នាក់ទៀតជាប្រតិភូពិសេសដែលចាត់តាំងចំពោះកិច្ច(adhoc)និងត្រូវបម្ចិលគ្នា (roulement) : ប្រធានអង្គការប្រតិបត្តិខេត្ត១នាក់ និងប្រតិភូពិសេសពីនាក់ ។

ដើម្បីបានជាប្រតិភូអចិន្ត្រៃយ៍ត្រូវជាអ្នកជាប់ឆ្នោតនៅសភាខេត្ត ។ កាលបើបានតែងតាំងជាប្រតិភូអចិន្ត្រៃយ៍ សមាជិកនេះត្រូវលាលែងពីសមាជិកនៃសភាមូលដ្ឋាន ។

អាណត្តិ : ៥ឆ្នាំ

ការរៀបចំថ្មីចុងក្រោយ (dernier renouvellement): ១៤មេសា២០០៤ ។

លក្ខខណ្ឌឈរឈ្មោះ : អាយុ១៨ឆ្នាំ ជាពលរដ្ឋអាហ្វ្រិកខាងត្បូង ឬមានការអនុញ្ញាត ដោយសេចក្តីសម្រេចរបស់សភា ។

III-សម័យម្រុជុំ

កំណត់ដោយក្រុមប្រឹក្សាជាតិនៃបណ្តាខេត្ត ។ ក្រុមប្រឹក្សាជាតិអាចត្រូវកោះប្រជុំជាវិសាមញ្ញដោយប្រធានាធិបតីនៃសាធារណរដ្ឋ ។

IV-ឧទាត់ឧទាហរណ៍ជាមួយដ្ឋសភានិងអំណាចនីតិម្រតិបត្តិ

អាហ្វ្រិកខាងត្បូងប្រកាន់របបសភាពីរវិសមភាព (bicamérisme inégalitaire) ។

ក-អំណាចនីតិប្បញ្ញត្តិ

១-ឥនិតផ្តួចផ្តើមធ្វើច្បាប់

សមាជិកក្រុមប្រឹក្សាជាតិមានសិទ្ធិផ្តួចផ្តើមឥនិតធ្វើច្បាប់ ដូចសមាជិករដ្ឋសភា និងប្រធានាធិបតី លើកលែងតែច្បាប់ស្តីពីហិរញ្ញវត្ថុ ។ ការផ្តួចផ្តើមឥនិតអាចផ្តោតទៅលើវិស័យដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាជាតិឬរបស់សភាមូលដ្ឋាន កសិកម្ម បរិដ្ឋាន ការដឹកជញ្ជូន ទេសចរណ៍ ពាណិជ្ជកម្ម...) ឬវិស័យមួយចំនួនទៀត (អង្គការមូលដ្ឋាន ការការពារសិទ្ធិ...) ។

២-សិទ្ធិធ្វើវិសោធនកម្ម

សមាជិកក្រុមប្រឹក្សាជាតិមានសិទ្ធិធ្វើវិសោធនកម្មលើត្រប់វិស័យ ។

៣-និតីវិធី

សេចក្តីព្រាងច្បាប់ត្រូវបញ្ជូនទៅរដ្ឋសភា លើកលែងតែសេចក្តីព្រាងណាទាក់ទងនឹងវិស័យដែលក្រុមប្រឹក្សាជាតិមានសិទ្ធិផ្តួចផ្តើមឥនិតធ្វើ ។ សេចក្តីព្រាងបែបនេះក៏អាចបញ្ជូនទៅរដ្ឋសភាដែរ ។

ខេត្តមួយ១មាន១សម្លេង ហើយការអនុម័តនឹងយកជាការបានលុះណាមានខេត្ត៥យ៉ាងតិចតាំទ្រ លើកលែងតែរដ្ឋធម្មនុញ្ញចែងខុសពីនេះ ។

ក-នីតិវិធីទាក់ទងនឹងសេចក្តីព្រាងច្បាប់ធម្មតាដែលមិនប៉ះពាល់ដល់ខេត្ត

ក្រុមប្រឹក្សាអាចយល់ព្រម កែសម្រួល ឬបដិសេធអត្ថបទច្បាប់ ដែលអនុម័តដោយរដ្ឋសភា។ ក្នុងករណីមានការកែសម្រួល ឬបដិសេធ អត្ថបទច្បាប់ត្រូវបញ្ជូនទៅរដ្ឋសភាវិញ។ រដ្ឋសភាត្រូវពិនិត្យលើការកែសម្រួលរបស់ក្រុមប្រឹក្សាជាតិនិងអនុម័តជាថ្មី ដោយមានឬគ្មានការកែសម្រួល ឬសម្រេចចោះបង់នីតិវិធី។

ក្នុងពេលអនុម័តប្រតិភូម្នាក់មាន១សម្លេង ហើយត្រូវមានវត្តមាន១/៣ នៃសមាជិក ។ នីតិវិធីនេះក៏ប្រើសំរាប់ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុដែរ។

ខ-នីតិវិធីទាក់ទងនឹងសេចក្តីព្រាងច្បាប់ធម្មតាដែលប៉ះពាល់ដល់ខេត្ត

បើក្រុមប្រឹក្សាបដិសេធអត្ថបទច្បាប់ដែលរដ្ឋសភាបញ្ជូនមកឬ បើរដ្ឋសភាបដិសេធការកែសម្រួលរបស់ក្រុមប្រឹក្សា អត្ថបទច្បាប់ត្រូវបញ្ជូនទៅគណៈកម្មការសម្របសម្រួល (commission de médiation) ដែលមានសមាជិក៩នាក់មកពីរដ្ឋសភា និង៩នាក់មកពីក្រុមប្រឹក្សាជាតិ ។ សមាជិក៩នាក់ ដែលមកពីរដ្ឋសភាត្រូវបានជ្រើសរើសតាមវិធានសមាមាត្រ ហើយសមាជិក៩នាក់ដែលមកពីក្រុមប្រឹក្សាជាប្រតិភូតំណាងខេត្តទាំង៩ ក្នុង១ខេត្តម្នាក់ ។

គណៈកម្មការសម្របសម្រួលអាចរក្សាអត្ថបទរបស់រដ្ឋសភា ឬការកែសម្រួលរបស់ក្រុមប្រឹក្សាឬអត្ថបទថ្មីមួយទៀត ។ ការអនុម័តត្រូវតែមានយ៉ាងតិច៥សម្លេងមកពីសភានីមួយៗ ។

១-បើគណៈកម្មការមិនអាចរកការព្រមព្រៀងបានក្នុងរយៈពេល៣០ថ្ងៃ អត្ថបទត្រូវចោះបង់ចោល លើកលែងតែរដ្ឋសភាអនុម័តជាថ្មីតាមសម្លេងភាគច្រើន២/៣នៃចំនួនសមាជិក ។

២-បើគណៈកម្មការរក្សាអត្ថបទរបស់រដ្ឋសភា អត្ថបទនេះត្រូវបញ្ជូនទៅក្រុមប្រឹក្សា ។

៣-បើគណៈកម្មការរក្សាការកែសម្រួលរបស់ក្រុមប្រឹក្សា អត្ថបទនោះត្រូវបញ្ជូនទៅរដ្ឋសភា ។

៤-បើគណៈកម្មការរក្សាអត្ថបទថ្មីមួយទៀត អត្ថបទថ្មីនោះត្រូវបញ្ជូនទៅសភាទាំងពីរ ។

៥-ក្នុងករណី(ខ) សេចក្ដីព្រាងច្បាប់ធម្មតាដែលប៉ះពាល់ដល់ខេត្ត និងករណី(ឃ) មានការពិភាក្សាជាថ្មី បើក្រុមប្រឹក្សាមិនអនុម័តអត្ថបទច្បាប់ អត្ថបទនោះត្រូវចោះបង់ចោលលើកលែងតែរដ្ឋសភាអនុម័តតាមសម្លេងភាគច្រើន២/៣ ។

៦-ក្នុងករណី (គ) អត្ថបទច្បាប់ទាក់ទងនឹងវិស័យដែលក្រុមប្រឹក្សាជាតិមានសិទ្ធិផ្ដួចផ្ដើមគំនិតធ្វើច្បាប់ និងករណី(ឃ) មានការពិភាក្សាជាថ្មី បើរដ្ឋសភាមិនអនុម័តអត្ថបទច្បាប់ អត្ថបទនោះត្រូវចោះបង់ចោល ប៉ុន្តែសមាជិករដ្ឋសភាអាចអនុម័តអត្ថបទ ដែលគេបានអនុម័តលើកមុន តាមសម្លេងភាគច្រើន២/៣ ។

ជ-នីតិវិធីទាក់ទងនឹងអត្ថបទក្នុងវិស័យដែលក្រុមប្រឹក្សាមានសិទ្ធិផ្ដួចផ្ដើមគំនិតធ្វើច្បាប់

អត្ថបទច្បាប់ដែលអនុម័តដោយក្រុមប្រឹក្សា ត្រូវបញ្ជូនរដ្ឋសភា:

-បើរដ្ឋសភាកែសម្រួល អត្ថបទច្បាប់ត្រូវបញ្ជូនទៅក្រុមប្រឹក្សា

-បើរដ្ឋសភាបដិសេធ ឬបើក្រុមប្រឹក្សាបដិសេធការកែសម្រួលរបស់រដ្ឋសភា អត្ថបទច្បាប់ត្រូវបញ្ជូនទៅគណៈកម្មការសម្របសម្រួល

-បើគណៈកម្មការរកការព្រមព្រៀងមិនបានក្នុងរយៈពេល៣០ថ្ងៃ អត្ថបទច្បាប់ត្រូវចោះបង់ចោល

-បើគណៈកម្មការរក្សាអត្ថបទរបស់ក្រុមប្រឹក្សា អត្ថបទនោះត្រូវបញ្ជូនទៅរដ្ឋសភា

-បើគណៈកម្មការរក្សាអត្ថបទរបស់រដ្ឋសភា អត្ថបទត្រូវបញ្ជូនទៅក្រុមប្រឹក្សា

-បើគណៈកម្មការរក្សាអត្ថបទថ្មី អត្ថបទនោះត្រូវបញ្ជូនទៅសភាទាំងពីរ ។

ក្នុងករណីដែលរដ្ឋសភាមិនអនុម័តអត្ថបទដែលបញ្ជូនមក អត្ថបទច្បាប់នោះត្រូវចោះបង់ចោល ។

រដ្ឋធម្មនុញ្ញពុំបានចែងអំពីករណី ដែលក្រុមប្រឹក្សាមិនទទួលយកអត្ថបទរបស់គណៈកម្ម-ការសម្របសម្រួលទេ ។ ក្នុងការជាក់ស្ដែងការអនុម័តអត្ថបទច្បាប់មានដំណើរទៅមុខរាប់ រហ័ស ។ ការបញ្ជូនទៅបញ្ជូនមកមានតិចបំផុត ។

ឃ-ការពិភាក្សាជាថ្មី

ប្រធានាធិបតីអាចបញ្ជូនអត្ថបទច្បាប់ទៅសភា បើមើលឃើញថាមានបញ្ហាធម្មនុញ្ញភាព។ ក្រុមប្រឹក្សាជាតិពិនិត្យម្តងទៀត បើអត្ថបទនោះជាអត្ថបទកែប្រែរដ្ឋធម្មនុញ្ញ ឬជាអត្ថបទដែលប៉ះពាល់ដល់ខេត្ត។

៩-អំណាចត្រួតពិនិត្យ

១-អំណាចបង្ខំ

ក្រុមប្រឹក្សាជាតិ ឬគណៈកម្មមួយៗរបស់ក្រុមប្រឹក្សាអាចៈ

-កោះអញ្ជើញជនណាម្នាក់ដើម្បីធ្វើសាក្សីឬផ្តល់ឯកសារ

-ទាមទាវរបាយការណ៍ពីគណៈកម្មការណាមួយ ឬពីជនណាម្នាក់ និងបង្ខំឱ្យគោរពបញ្ញត្តិជាធរមាន។

២-ក្រុមប្រឹក្សា ឬគណៈកម្មការមួយៗ អាចទទួលញត្តិពីពលរដ្ឋឬពីស្ថាប័ន ដែលមានផលប្រយោជន៍។

៣-ផ្តល់សច្ចាប័នលើសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិ សន្ធិសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិត្រូវទទួលការយល់ព្រមពីរដ្ឋសភានិងពីក្រុមប្រឹក្សាជាតិ លើកលែងតែកិច្ចព្រមព្រៀងដែលមានលក្ខណៈបច្ចេកទេសរដ្ឋបាល ឬប្រតិបត្តិ ដែលការណីទាំងនេះគ្រាន់តែជាក់បង្ហាញដល់សភាទាំងពីរក្នុងរយៈពេលសមស្រប។

V-បទឃ្លាត្តិពិសេស

ក-អំណាចធម្មនុញ្ញ

នីតិវិធីនៃការកែប្រែរដ្ឋធម្មនុញ្ញ អាស្រ័យទៅនឹងកម្មវត្ថុៈ

១- នីតិវិធីនៃការកែប្រែអាចត្រូវបានធ្វើវិសោធនកម្ម ដោយច្បាប់ដែលមានការគាំទ្រយ៉ាងតិចពីខេត្ត៦(និងយ៉ាងតិចពី៧៥%នៃសមាជិករដ្ឋសភា)។

២-ការប្រកាសស្តីពីសិទ្ធិអាចត្រូវបានកែប្រែដោយច្បាប់ដែលអនុម័តដោយខេត្ត៦ យ៉ាងតិច(និង២/ ពាយ៉ាងតិចនៃចំនួនសមាជិករដ្ឋសភា)។

៣-បញ្ញត្តិឯទៀតនៃរដ្ឋធម្មនុញ្ញ អាចត្រូវបានកែប្រែដោយច្បាប់តាមសម្តេងពីរភាគបី យ៉ាងតិចនៃចំនួនសមាជិករដ្ឋសភា និងដោយក្រុមប្រឹក្សា(យ៉ាងតិច៦ខេត្ត) បើជាបញ្ហាដែលទាក់ទងនឹងក្រុមប្រឹក្សាឬការកែសម្រួលអង្គការមូលដ្ឋានឬបទបញ្ញត្តិទាក់ទងនឹងការរៀបចំមូលដ្ឋាន ។

៤-កាលបើការពិនិត្យរបស់ក្រុមប្រឹក្សាមិនបានសម្រេច ត្រូវដាក់ឱ្យមានការពិភាក្សាជាសាធារណៈ ។

៥-កាលណាសេចក្តីព្រាង ឬបញ្ញត្តិណាមួយទាក់ទងនឹងខេត្តជាក់លាក់ណាមួយក្រុមប្រឹ-ក្សាមិនអាចអនុម័តមុនការអនុម័តរបស់សភាមូលដ្ឋានឡើយ ។

ខ-ទំនាក់ទំនងជាមួយបណ្តាខេត្ត

១-ការខ្វះចន្លោះ (défaillance)របស់ខេត្ត និងក្រុង

បើស្ថាប័នប្រតិបត្តិធ្វើអន្តរាគមន៍ ក្នុងករណីដែលខេត្តមួយមិនបានបំពេញកាតព្វកិច្ច វិធានការទាំងឡាយដែលត្រូវចាត់ ត្រូវដាក់ជូនក្រុមប្រឹក្សាជាតិក្នុងអំឡុង១៤ថ្ងៃនៃពេលប្រជុំលើកទី១របស់ក្រុមប្រឹក្សា ក្រោយចាប់ផ្តើមអន្តរាគមន៍ ។

អន្តរាគមន៍របស់នីតិប្រតិបត្តិត្រូវបានការយល់ព្រមពីក្រុមប្រឹក្សា ក្នុងរយៈពេល៣០ថ្ងៃ បើមិនដូច្នេះទេ អន្តរាគមន៍ត្រូវឈប់ ។

នីតិវិធីដូចគ្នាត្រូវអនុវត្តពេលស្ថាប័នប្រតិបត្តិខេត្តធ្វើអន្តរាគមន៍ចំពោះក្រុង ។

២-ការចូលរួមរបស់ខេត្តក្នុងការងាររបស់ក្រុមប្រឹក្សាជាតិ

តំណាងបណ្តោះអាសន្ន(ដែលមានចំនួនយ៉ាងច្រើន១០នាក់)ដែលតែងតាំងដោយរដ្ឋបាលមូលដ្ឋាន (gouvernements locaux) និងតំណាងនៃទីក្រុងផ្សេងៗអាចចូលរួមទៅតាមតម្រូវការក្នុងអង្គប្រជុំក្រុមប្រឹក្សាដោយពុំមានសិទ្ធិអនុម័ត ។

ដូចគ្នានេះដែរ បណ្តាប្រតិភូនៃក្រុមប្រឹក្សាអាចចូលរួម និង មានយោបល់ក្នុងអង្គប្រជុំរបស់ខេត្តដែលប្រតិភូទាំងនោះជាតំណាងព្រមទាំងគណៈកម្មាធិការនានា ប៉ុន្តែមិនមានសិទ្ធិអនុ-ម័តឡើយ ។

សភាមូលដ្ឋានអាចស្នើប្រតិភូម្នាក់ឱ្យតាមមើលការងាររបស់ខ្លួន។

៣-សមត្ថកិច្ចរបស់ខេត្ត

ទំនាស់ទាំងអស់ទាក់ទងនឹងសមត្ថកិច្ចរបស់ខេត្តត្រូវបញ្ជូនទៅក្រុមប្រឹក្សាជាតិ ដែលត្រូវសម្រេចក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីពេលទទួល។

៤-ទំនាស់ខាងច្បាប់ក្នុងតុលាការ

ករណីទំនាស់ទាក់ទងនឹងការចាំបាច់នៃអនុភាពមន្ត្រីនៃច្បាប់ជាតិ ត្រូវបានបញ្ជូនទៅតុលាការ តុលាការនេះត្រូវមានការយល់ព្រមឬការបដិសេធពីក្រុមប្រឹក្សាជាតិ។

ច្បាប់ជាតិ ឬច្បាប់ខេត្តមានប្រៀបជាងច្បាប់មួយទៀត តែក្នុងករណីដែលច្បាប់នោះអនុម័តដោយក្រុមប្រឹក្សាជាតិ។

បើក្រុមប្រឹក្សាជាតិមិនអនុម័តក្នុងអំឡុង៣០ថ្ងៃនៃពេលប្រជុំទី១ ក្រោយថ្ងៃទទួលនោះ ត្រូវចាត់ទុកថាមានការយល់ព្រម។

ក្នុងករណីបដិសេធច្បាប់ដែលបញ្ជូនមក ត្រូវបញ្ជាក់មូលហេតុក្នុងអំឡុង៣០ថ្ងៃទៅអាជ្ញាធរពាក់ព័ន្ធ។

 គ-គណៈកម្មការយុត្តិធម៌

ប្រតិភូ៤នាក់នៃក្រុមប្រឹក្សាជាតិ ដែលបានទទួលការគាំទ្រពីខេត្ត៦យ៉ាងតិចជាសមាជិកនៃគណៈកម្មការទទួលបន្ទុកផ្តល់ការប្រឹក្សាដល់រដ្ឋាភិបាលកណ្តាល លើបញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងប្រព័ន្ធយុត្តិធម៌ និងរដ្ឋបាលរបស់យុត្តិធម៌។

ដោយការសើរើរដ្ឋធម្មនុញ្ញថ្ងៃ២៨វិច្ឆិកា១៩៩៦ ក្រុមប្រឹក្សាជាតិអាល់ហ្សេរីបានកើតជារូបរាងនៅថ្ងៃទី៤ខែមករា១៩៩៨។

I.សមាសភាព

ក្រុមប្រឹក្សាជាតិអាល់ហ្សេរីមានសមាជិក១៤៤នាក់:

- ៩៦នាក់ត្រូវបានជ្រើសរើសដោយការបោះឆ្នោតមិនផ្ទាល់ និង សម្ងាត់ (indirect et secret -2/3)

-៤៨នាក់ត្រូវបានតែងតាំងដោយប្រធានាធិបតី(វិទ្យាសាស្ត្រ វប្បធម៌ វិជ្ជាជីវៈ សេដ្ឋកិច្ច និងសង្គម)។

ចំនួនសមាជិកក្រុមប្រឹក្សាជាតិ ឬ ព្រឹទ្ធសភាមានយ៉ាងច្រើនស្មើនឹងពាក់កណ្តាលចំនួនសមាជិកសភាប្រជាជនជាតិ (assemblée populaire nationale)ឬរដ្ឋសភា។

II.របបបោះឆ្នោត

មណ្ឌលបោះឆ្នោតមាន៤៨ហើយមួយមណ្ឌលមាន២អាសនៈ។ ការបោះឆ្នោតធ្វើតាមប្រព័ន្ធសម្លេងភាគច្រើនតែមួយជុំដោយអង្គបោះឆ្នោតដែលមានសមាជិកសភាស្រុក(assemblées populaires de Wilaya-préfectures) និងសមាជិកសភាឃុំ (assemblées populaires communales) ។ ចំនួនអ្នកបោះឆ្នោតមាន ១៥.០០៣ នាក់។

លក្ខខណ្ឌឈរឈ្មោះ :

-សមាជិកសភាប្រជាជនស្រុក និងសភាប្រជាជនឃុំ

-អាយុ : យ៉ាងតិច៤០ឆ្នាំ

-អាណត្តិ :៦ឆ្នាំ ផ្លាស់ប្តូរចំនួនពាក់កណ្តាលពីឆ្នាំម្តង

-ចោះឆ្នោតលើកទី១ : ២៥ ធ្ទូ ១៩៩៧

ការផ្តល់សុពលភាពដល់អាណត្តិសមាជិកក្រុមប្រឹក្សាជាតិ ជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាជាតិ ។

III-អំពីសម័យប្រជុំ

ក-សម័យប្រជុំសាមញ្ញ

ក្រុមប្រឹក្សាជាតិប្រជុំជាសាមញ្ញ២ដងក្នុងមួយឆ្នាំ ។ សម័យប្រជុំមួយៗមានរយៈពេលយ៉ាងច្រើន ៥ខែ: សម័យប្រជុំនិទាឃរដូវពីខែមិនា ដល់ខែកក្កដា និងសម័យប្រជុំសរទរដូវពីខែកញ្ញាដល់ខែមករា ។

ខ-សម័យប្រជុំវិសាមញ្ញ

ក្រុមប្រឹក្សាជាតិអាចកោះប្រជុំវិសាមញ្ញ តាមរបៀបវារៈជាក់លាក់ :

-តាមការផ្តើមគំនិតរបស់ប្រធានាធិបតី

-ដោយប្រធានាធិបតីតាមសំណើរបស់នាយករដ្ឋមន្ត្រី ឬពីពីរភាគបីនៃសមាជិកសភាប្រជាជនជាតិ(រដ្ឋសភា) ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភា និងអំណាចនីតិប្បញ្ញត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

អំណាចនីតិប្បញ្ញត្តិត្រូវបានអនុវត្តដោយសភា (parlement)ដែលមានរដ្ឋសភានិងក្រុមប្រឹក្សាជាតិ ។

១-សិទ្ធិផ្តួចផ្តើមធ្វើច្បាប់ : ត្មាន

២-សិទ្ធិវិសោធនកម្ម : ត្មាន (ប្រកាសលេខ០៤ អាអែអ៊ី-សេសេ ចុះថ្ងៃ១០ កុម្ភៈ ១៩៩៨ របស់ក្រុមប្រឹក្សាធម្មនុញ្ញទាក់ទងនឹងបទបញ្ជាផ្ទៃក្នុង) ។

៣-នីតិវិធី

ក-នីតិវិធីធម្មតា

សេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ត្រូវតែបានអនុម័តជាបន្តបន្ទាប់ដោយរដ្ឋសភា(លើកដំបូង) និងដោយក្រុមប្រឹក្សា(បន្ទាប់មក) ។

អត្ថបទដែលអនុម័តដោយរដ្ឋសភាត្រូវបញ្ជូនក្នុងរយៈពេល១០ថ្ងៃទៅក្រុមប្រឹក្សាជាតិ ។ ក្រុមប្រឹក្សាជាតិពិភាក្សា និងអនុម័តអត្ថបទនេះតាមសម្លេងភាគច្រើន៧ ៤ ។

ក្នុងករណីមិនព្រមព្រៀងគ្នា គណៈកម្មការចំរុះសមភាគី ដែលមានសមាជិក១០នាក់មកពីសភានីមួយៗរួមប្រជុំតាមសំណើរបស់ប្រមុខរដ្ឋាភិបាលដែលស្នើអត្ថបទមួយ ។ អត្ថបទនេះស្នើដោយរដ្ឋាភិបាលដើម្បីសុំការអនុម័តពីសភាទាំងពីរ ។

អត្ថបទនេះមិនអាចធ្វើវិសោធកម្មបានទេ លើកលែងតែមានការយល់ព្រមពីរដ្ឋាភិបាល ។ បើសិនគ្មានការព្រមព្រៀង អត្ថបទនេះត្រូវរដ្ឋាភិបាលដកយកទៅវិញ ។

ខ-នីតិវិធីចំពោះច្បាប់ថវិកា

សភាអនុម័តសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុក្នុងរយៈពេលយ៉ាងយឺត ៧៥ថ្ងៃចាប់ពីពេលបានទទួល ។ ក្រុមប្រឹក្សាជាតិមានពេល២០ថ្ងៃយ៉ាងច្រើនដើម្បីពិនិត្យ ។

ក្នុងករណីមិនបានអនុម័តក្នុងរយៈពេលនេះ ប្រធានាធិបតីប្រកាសឱ្យប្រើអត្ថបទនោះដោយបទបញ្ជា (ordonnance) ។

ការចេញបទបញ្ជា(ដោយការចាំបាច់) :

ក្នុងពេលវិស្សមកាលរបស់រដ្ឋសភា ឬនៅចន្លោះសម័យប្រជុំ ប្រធានាធិបតីអាចចេញបទបញ្ជា ។ បទបញ្ជាទាំងនេះត្រូវយកទៅសុំការយល់ព្រមពីសភាមួយៗនៅសម័យប្រជុំបន្ទាប់ ។ បទបញ្ជាដែលមិនបានការអនុម័តពីសភាត្រូវទុកជាមោឃៈ ។

ខ-អំណាចត្រួតពិនិត្យ

១-គណៈកម្មការអង្កេត

ក្រុមប្រឹក្សាជាតិ ក៏ដូចជារដ្ឋសភាអាចបង្កើតបានគ្រប់ពេល នូវគណៈកម្មការអង្កេតលើការងារដែលមានផលប្រយោជន៍ទូទៅ ។

២-ការត្រួតពិនិត្យថវិកា

រដ្ឋាភិបាលរាយការណ៍ជូនសភានីមួយៗ អំពីការប្រើប្រាស់ឥណទានថវិកាដែលសភាបានអនុម័ត ។ ការអនុវត្តថវិកាត្រូវចប់ដោយការអនុម័តរបស់សភានីមួយៗ នូវច្បាប់ស្តីពីការអនុវត្តប្រតិបត្តិការថវិកានេះ ។

៣-សំណួរ

សមាជិកសភាអាចតាំងសំណួរចំពោះរដ្ឋាភិបាលអំពីបញ្ហាបច្ចុប្បន្នភាព ។ សំណួរអាចធ្វើជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ។ បើសំណួរជាលាយលក្ខណ៍អក្សរ ចម្លើយត្រូវឱ្យជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល៣០ថ្ងៃ ។ បើជាសំណួរផ្ទាល់មាត់ ចម្លើយត្រូវធ្វើក្នុងសម័យប្រជុំ ។ បើសភាណាមួយយល់ថាជាការចាំបាច់ សភានោះអាចបើកឱ្យមានការពិភាក្សាបាន ។

៤-ការងារអន្តរជាតិ

ក-តាមសំណើរបស់ប្រធានាធិបតី ឬរបស់ប្រធានសភាណាមួយ សភាអាចបើកការពិភាក្សាអំពីនយោបាយការបរទេស ។ ការពិភាក្សានេះអាចបញ្ចប់ដោយការសម្រេចចិត្តរបស់អង្គប្រជុំរួមរបស់សភាទាំងពីរ ។

ខ-កិច្ចព្រមព្រៀងស្តីពីយុទ្ធសន្តិភាព (accords d'armistice) សន្ធិសញ្ញាសន្តិភាព (traités de paix) សម្ព័ន្ធភាព និងសហភាព (alliance et union) សន្ធិសញ្ញាទាក់ទងនឹងព្រំដែនរដ្ឋ ទាក់ទងនឹងលក្ខន្តិកៈរបស់ពលរដ្ឋ និងកិច្ចព្រមព្រៀងទាំងឡាយដែលនាំឱ្យមានចំណាយ ដែលមិនបានក្រោងទុកក្នុងថវិកាជាតិ ត្រូវតែមានការយល់ព្រមពីសភានីមួយៗ មុននឹងផ្តល់សច្ចាប័ន ។

៥-កម្មវិធីរបស់រដ្ឋាភិបាល

ក-ប្រមុខរដ្ឋាភិបាលបង្ហាញកម្មវិធីការងាររបស់ខ្លួនជូនក្រុមប្រឹក្សាជាតិ ។ ក្រុមប្រឹក្សាអាចចេញសេចក្តីសម្រេចចិត្ត ។

ខ-ប្រមុខរដ្ឋាភិបាលអាចបង្ហាញនយោបាយទូទៅជូនក្រុមប្រឹក្សាជាតិ ។

V-បនប្បញ្ញត្តិដោយឡែក

ក-ការសើរើរដ្ឋធម្មនុញ្ញ

១-ការផ្តើមគំនិតសើរើរដ្ឋធម្មនុញ្ញធ្វើឡើងដោយប្រធានាធិបតី ។ ការសើរើរដ្ឋធម្មនុញ្ញត្រូវមានការយល់ព្រមពីសភាមួយ៣តាមនីតិវិធីធម្មតា ។ ក្រោយពីមានយោបល់ពីក្រុមប្រឹក្សាធម្មនុញ្ញ អត្ថបទអាចត្រូវបានយកទៅប្រកាសឱ្យប្រើដោយមិនចាច់ធ្វើប្រជាមតិ បើសិនសភាបានអនុម័តដោយសម្លេងភាគច្រើន៣/៤នៃចំនួនសមាជិកវៀង៣ខ្លួន ។

២- សមាជិកសភាទាំងពីរចំនួន៣/៤ប្រជុំរួមគ្នាអាចស្នើធ្វើការសើរើរដ្ឋធម្មនុញ្ញ ហើយបង្ហាញសំណើនោះទៅប្រធានាធិបតីដែលអាចដាក់ឱ្យធ្វើប្រជាមតិ ។

ខ-សិទ្ធិជ្រើសរើស

ក្រុមប្រឹក្សាជាតិជ្រើសរើសសមាជិក២នាក់នៃសមាជិកទាំង៩នាក់ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

គ-ស្ថានការពិសេស

ការពិគ្រោះយោបល់របស់ប្រធានក្រុមប្រឹក្សាជាតិ :

១-ដើម្បីប្រកាសភាពអាសន្ន ឬគ្រោះមហន្តរាយដែលរយៈពេលអាចបន្ត ក្រោយពីមានការយល់ព្រមពីសភាទាំងពីរប្រជុំរួមគ្នា ។

២-ដើម្បីប្រកាសស្ថានភាពពិសេស សភាប្រជុំរួម

៣-ដើម្បីធ្វើកំណែនទូទៅ

៤-ដើម្បីប្រកាសសង្ក្រាម សភាប្រជុំរួម ។

ក្នុងករណីនេះបើតំណែងប្រធានាធិបតីនៅទំនេរ (vacances) កិច្ចការទាំងឡាយដែលត្រូវធ្វើក្នុងស្ថានភាពសង្ត្រាមត្រូវរ៉ាប់រងដោយប្រធានក្រុមប្រឹក្សាជាតិ ក្នុងនាមជាប្រមុខរដ្ឋ។

ឃ-ប្រធានាធិបតីស្ថីទី

១-ប្រធានាធិបតីមិនអាចបំពេញការងារបានដោយមានជម្ងឺ

ករណីនេះត្រូវប្រកាសដោយសភាប្រជុំរួម តាមសម្លេងភាគច្រើន២/៣ ។ តួនាទីប្រធានាធិបតីស្ថីទីត្រូវប្រគល់ជូនប្រធានក្រុមប្រឹក្សាជាតិ សំរាប់រយៈពេលយ៉ាងច្រើន៤៥ថ្ងៃ។

២-វិស្សមកាលដោយមរណភាព ឬលាលែង

ប្រធានក្រុមប្រឹក្សាជាតិទទួលជាប្រធានាធិបតីស្ថីទី សំរាប់រយៈពេលយ៉ាងច្រើន៦០ថ្ងៃ។ ក្នុងរយៈពេលនេះ ត្រូវដំណើរការបោះឆ្នោតជ្រើសរើសប្រធានាធិបតី។

ង-សមាជសភា

សភាទាំងពីរអាចប្រជុំជាសមាជក្រោមអធិបតីភាពប្រធានក្រុមប្រឹក្សាជាតិ។

ច-ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធានាធិបតី ប្រធានរដ្ឋសភា និងប្រធានក្រុមប្រឹក្សាជាតិមានសិទ្ធិស្នើទៅក្រុមប្រឹក្សាធម្មនុញ្ញ។ ក្នុងក្របខ័ណ្ឌនៃមាត្រា១៦៥នៃរដ្ឋធម្មនុញ្ញទាក់ទងនឹងធម្មនុញ្ញភាពនៃច្បាប់រហូតមកទល់ពេលនេះមានតែម្តងតត់នៅ ខែឧសភា ១៩៩៨ដែលប្រធានក្រុមប្រឹក្សាជាតិបានស្នើទៅក្រុមប្រឹក្សាធម្មនុញ្ញ។

BUNDESRAT (សភាជាន់ខ្ពស់) បានអនុម័តជាស្ថាពរនូវកំណែទំរង់ប្រព័ន្ធសហព័ន្ធអាឡឺម៉ង់នៅថ្ងៃ៧កក្កដា២០០៦ ។ ស្ថ័យភាពដែនដី (Lander) ត្រូវពង្រឹងដោយការផ្តល់អំណាចថ្មី១ ។ ផ្ទុយទៅវិញចំនួនច្បាប់សហព័ន្ធដែលតម្រូវឱ្យមានការយល់ព្រមពី LE BUNDESRAT បានថយចុះ ។

កំណែទំរង់នេះបានចូលជាធរមាននៅឆ្នាំ២០០៧ ។

I.សមាសភាព

សមាសភាពនៃសភាជាន់ខ្ពស់នេះមានសមាជិកនៃរដ្ឋាភិបាលនៃបណ្តាដែនដី(Landers-16)ដែលជាអ្នកតែងតាំងនិងដកហូតតំណែង ។ សមាជិកទាំងអស់មាន៦៩នាក់ ។

ដែនដីនីមួយ១មានពាសម្លេងយ៉ាងតិច ។ ដែនដីដែលមានប្រជាជនលើសពី២លាននាក់មាន៤សម្លេង ដែនដីដែលមានប្រជាជនលើសពី៥លាននាក់មាន៥សម្លេង ដែនដីដែលមានប្រជាជនលើសពី៧លាននាក់មាន៦សម្លេង ។

II.របបតែងតាំង

មាន១៦មណ្ឌលពហុនាម អាស្ស័យតាមដែនដីដែលមានប្រជាជនតិច ឬច្រើន ។ ដែនដីនីមួយ១អាចធ្វើប្រតិភូកម្មឱ្យសមាជិកតាមចំនួនសម្លេងដែលខ្លួនមាន ។

អាណត្តិមានរយៈពេលអាស្ស័យតាមអាណត្តិរបស់សមាជិករដ្ឋាភិបាលដែនដី ដែលខ្លួនជាតំណាង ។

III.សម័យប្រជុំ

សភាជាន់ខ្ពស់មានតែមួយសម័យប្រជុំក្នុងមួយឆ្នាំ ។ ក្នុងការអនុវត្តតាមបទបញ្ជាទូទៅ

សភាជាន់ខ្ពស់ប្រជុំនៅថ្ងៃសុក្រណាមួយ ក្នុងមួយខែ ពីម៉ោង៥:៣០ ។ នៅខែសីហាមិនប្រជុំទេ ។

IV-ទំនាក់ទំនងជាមួយសការជ្ជសភានិងជាមួយអង្គការនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-គំនិតផ្តួចផ្តើមធ្វើច្បាប់

សភាជាន់ខ្ពស់មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ផ្ទួចសមាជិករដ្ឋាភិបាលសហព័ន្ធ និងសមាជិករដ្ឋសភា(BUNDESTAG) ។ ប៉ុន្តែ ភាគច្រើននៃច្បាប់មានប្រភពមកពីរដ្ឋាភិបាល ។

២-សិទ្ធិវិសោធនកម្ម

សភាជាន់ខ្ពស់មានសិទ្ធិធ្វើវិសោធនកម្ម ។ វិសោធនកម្មមិនអាចបន្ថែមបន្ទុកលើពលរដ្ឋទេ ។ ប៉ុន្ឌែសភា ជាន់ខ្ពស់អាចស្នើរឿងនេះទៅសភាតំណាងរាស្ត្រនូវសំណើកែប្រែមាត្រាណាមួយ ។ សភាតំណាងរាស្ត្រអាចទទួលយកសំណើនេះទៅពិចារណា បើយល់ថាសមស្រប ដោយយល់ព្រម ឬមិនយល់ព្រម ។

៣-នីតិវិធីធ្វើច្បាប់

ក-ការដាក់និងការបញ្ជូនសេចក្តីព្រាងច្បាប់

សេចក្តីព្រាងច្បាប់ទាំងឡាយត្រូវបញ្ជូនទៅសភាតំណាង(រដ្ឋសភា) ប៉ុន្តែសេចក្តីព្រាងរបស់រដ្ឋាភិបាលត្រូវដាក់ជាមុនជូនសភាជាន់ខ្ពស់(ការពិនិត្យជាមុនដោយគណៈកម្មការ) ។ សភាជាន់ខ្ពស់មានសិទ្ធិកំណត់ជំហរលើសេចក្តីព្រាងច្បាប់ ក្នុងរយៈពេល៦សប្តាហ៍ (ពាសប្តាហ៍ចំពោះការណីប្រញ្ជាប់ជាពិសេសដែលស្នើដោយរដ្ឋាភិបាលសហព័ន្ធ ។ក្នុងការណីចាំបាច់ សភាជាន់ខ្ពស់អាចសុំពន្យាររយៈពេលផល់៥សប្តាហ៍ ។

សេចក្តីព្រាងរបស់សភាជាន់ខ្ពស់ត្រូវបញ្ជូនទៅរដ្ឋសភា ក្នុងរយៈពេល៦សប្តាហ៍ដោយរដ្ឋាភិបាលសហព័ន្ធ ដោយមានបញ្ជាក់នូវទស្សនៈរបស់ខ្លួន ។

ច្បាប់សហព័ន្ធត្រូវអនុម័តដោយរដ្ឋសភា ។ ក្រោយការអនុម័ត ប្រធានរដ្ឋសភាត្រូវតែបញ្ជូនភ្លាមទៅសភាជាន់ខ្ពស់ ។

សេចក្តីព្រាងច្បាប់ត្រូវពិនិត្យពីលើក ពេលបញ្ជូនទៅសភាជាន់ខ្ពស់ ។ ការពិភាក្សាជាទូទៅ ធ្វើឡើងមុនការពិនិត្យមួយមាត្រម្តង ។

សេចក្តីព្រាងច្បាប់ជាកម្មវត្ថុនៃការពិនិត្យជាមុនដោយ

គណៈកម្មការអចិន្ត្រៃយ៍ណាមួយដែលមានសមត្ថកិច្ច ។ គណៈកម្មការមួយត្រូវបានទទួលភារកិច្ចពិសេសឱ្យធ្វើការបញ្ជាក់ថា សេចក្តីព្រាងច្បាប់នោះមិនប៉ះពាល់ដល់សេរីភាពបុគ្គល ឬសិទ្ធិស៊ីវិល (libertés individuelles et aux droits civiques) ។

កាលណាសភាតំណាងរាស្ត្រអនុម័តអត្ថបទច្បាប់មួយ ហើយសភាជាន់ខ្ពស់បដិសេធ ឬមិនបានពិនិត្យ ឬបានយល់ព្រមដោយមានវិសោធនកម្មដែលមិនទទួលយកដោយសភាតំណាង និង បើ៣ខែក្រោយ សភាតំណាងបានអនុម័តជាថ្មី ដោយមាន ឬគ្មានវិសោធនកម្ម ដែលមិនបានស្នើ ឬអនុម័តដោយសភាជាន់ខ្ពស់ និងដែលសភាជាន់ខ្ពស់បដិសេធ ឬមិនបានអនុម័ត ឬបានអនុម័ត ដោយមានវិសោធនកម្មដែលមិនទទួលដោយសភាតំណាង អគ្គទេសាភិបាលអាចរំលាយសភាទាំងពីរ លើកលែងតែក្នុងរយៈពេល១ខែមុនពេលរៀបចំថ្មីនៃសភាតំណាង ។

បើអត្ថបទកែប្រែ ឬមិនកែប្រែទទួលបានការគាំទ្រតាមសម្លេងភាគច្រើននៃសមាជិកសភានីមួយៗ អត្ថបទនោះអាចបញ្ជូនទៅអគ្គទេសាភិបាលដើម្បីប្រកាសឱ្យប្រើ ។

ខ-នីតិវិធីនៃការសម្របសម្រួល

ក្នុងពាសត្តាហ៍ សភាជាន់ខ្ពស់អាចស្នើសុំកោះប្រជុំគណៈកម្មការ ដែលមានសមាជិកសភាទាំងពីរ ។ សមាសភា និងនីតិវិធីនៃការបង្កើតគណៈកម្មការ ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងអនុម័តដោយរដ្ឋសភា និងយល់ព្រមដោយសភាជាន់ខ្ពស់ ។

កាលណាសេចក្តីព្រាងច្បាប់ណាមួយតម្រូវឱ្យមានការយល់ព្រមពីសភាជាន់ខ្ពស់ ការកោះប្រជុំគណៈកម្មការនេះក៏អាចស្នើសុំដោយរដ្ឋសភា ឬដោយរដ្ឋាភិបាលសហព័ន្ធ ។

បើគណៈកម្មការស្នើកែប្រែអត្ថបទ រដ្ឋសភាត្រូវធ្វើការពិភាក្សាជាថ្មី ។

គ-នីតិវិធីបន្ត

បន្ទាប់ពីនីតិវិធីសម្របសម្រួល និងបើអត្ថបទច្បាប់ណាមួយមិនតម្រូវឱ្យមានការយល់ព្រមពីសភាជាន់ខ្ពស់ សភាជាន់ខ្ពស់អាចជំទាស់ក្នុងរយៈពេល២សប្តាហ៍ទៅនឹងច្បាប់ដែលអនុម័តដោយរដ្ឋសភា។

បើការជំទាស់អនុម័តដោយសម្លេងភាគច្រើនក្នុងសភាជាន់ខ្ពស់ ការជំទាស់ត្រូវបានលើកចោលដោយ (elle peut être levée par) សម្លេងភាគច្រើនក្នុងរដ្ឋសភា ។ បើការជំទាស់មានសម្លេងភាគច្រើន២៣យ៉ាងតិចក្នុងសភាជាន់ខ្ពស់ ការលើកចោលតម្រូវឱ្យមានសម្លេងភាគច្រើន ២៣ និងយ៉ាងតិចសម្លេងភាគច្រើននៃសមាជិករដ្ឋសភា។

បទប្បញ្ញត្តិទាំងនេះ អនុវត្តបើសិនគណៈកម្មការសម្របសម្រួលមិនអាចបានទទួលការព្រមព្រៀង។ ក្នុងការជាក់ស្តែង ការព្រមព្រៀងតែងតែមានជាធម្មតា។

ត្រូវកត់សំគាល់ថាសម្លេងអនុប្បវាទស្នើនឹងសម្លេងជំទាស់ ។

ឃ-ស្ថានភាពចាំបាច់នៃបទប្បញ្ញត្តិ

ក្នុងករណីដែលការទុកចិត្ត ដែលស្នើសុំដោយអធិការបតីសហព័ន្ធមិនបានទទួលការយល់ព្រមពីរដ្ឋសភាហើយបើសិនរដ្ឋសភាមិនត្រូវរំលាយ ប្រធានាធិបតីសហព័ន្ធអាច តាមការស្នើសុំរបស់រដ្ឋាភិបាលសហព័ន្ធ និងដោយមានការយល់ព្រមពីសភាជាន់ខ្ពស់ ប្រកាសស្ថានភាពចាំបាច់នៃបទប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់ដែលបដិសេធដោយរដ្ឋសភា ទោះបីជារដ្ឋាភិបាលសហព័ន្ធប្រកាសច្បាប់នោះជាការប្រញាប់ក៏ដោយ ។

ក្នុងករណីដែលរដ្ឋសភាបដិសេធសេចក្តីព្រាងច្បាប់ជាថ្មី ឬ ក៏អនុម័តដោយមានការតាក់តែងដែលរដ្ឋាភិបាលសហព័ន្ធប្រកាសថាមិនអាចទទួលយកបាន ឬបើសិនជាសេចក្តីព្រាងមិនត្រូវអនុម័តដោយរដ្ឋសភា ក្នុងរយៈពេល៤សប្តាហ៍ ក្រោយពេលដាក់ជូនជាថ្មី សេចក្តីព្រាងច្បាប់នោះចាត់ទុកជាមានតម្លៃពេញលក្ខណៈ បើសិនជាសភាជាន់ខ្ពស់យល់ព្រម ។

ក្នុងរយៈពេលនៃការបំពេញមុខងារនៃអធិការបតីសហព័ន្ធ បទប្បញ្ញត្តិដូចខ្លួននេះត្រូវអនុវត្ត

ចំពោះសេចក្តីព្រាងច្បាប់ដែលបដិសេធដោយរដ្ឋសភាក្នុងរយៈពេល៦ខែ រាប់ពីការប្រកាសលើកទី១អំពីស្ថានភាពចាំបាច់នៃបទប្បញ្ញត្តិ ។ហួសរយៈពេលនេះស្ថានភាពចាំបាច់មិនអាចត្រូវប្រកាសជាលើកទី២នៅក្នុងរយៈពេលនៃការបំពេញមុខងារនៃអធិកាបតីសហព័ន្ធទេ ។

ង-ការយល់ព្រមរបស់សភាជាន់ខ្ពស់ចំពោះការអនុម័តច្បាប់ខ្លះ

ច្បាប់ដែលប៉ះពាល់ជាពិសេសដល់ផលប្រយោជន៍ដែនដី(Länder) អាចចូលជាធរមានបានលុះត្រាតែមានការយល់ព្រមយ៉ាងច្បាស់លាស់ពីសភាជាន់ខ្ពស់ ។ រដ្ឋសភានិងរដ្ឋាភិបាលសហព័ន្ធអាចត្រឹមតែប្រើវិធីសម្របសម្រួលតែមួយ តាមរយៈគណៈកម្មការចំរុះ ។

បើសភាជាន់ខ្ពស់នៅតែមិនយល់ព្រម សេចក្តីព្រាងច្បាប់នោះត្រូវចាត់ទុកជាលែងបានការ ។

ច្បាប់ទាំងនោះមានច្បាប់ស្តីពីការកែប្រែរដ្ឋធម្មនុញ្ញ ។

ច្បាប់នេះត្រូវមានការយល់ព្រមពីសភាជាន់ខ្ពស់ តាមសម្លេងភាគច្រើន២/៣ ។

ច្បាប់ដែលប៉ះពាល់ដល់ចំណូលពន្ធដារនៃដែនដី គឺជាច្បាប់ដែលទាក់ទងនឹងពន្ធ ដែលដែនដី និងឃុំចូលរួម :ពន្ធលើប្រាក់ប្យៀវត្យ(impôt sur les salaires) ពន្ធលើប្រាក់ចំណូល (impôt sur le revenu) អាករលើតម្លៃបន្ថែម (taxe sur la valeur ajoutée) និងអាករលើយានជំនិះ (taxe sur les véhicules) ។

ច្បាប់ដែលប៉ះពាល់ដល់អធិបតេយ្យខាងរដ្ឋបាល(souveraineté administrative) នៃដែនដី ការផ្ទេរអធិបតេយ្យទៅសហភាពអឺរុប ក៏រាប់បញ្ចូលដែរ ។

តាមតួលេខ ច្បាប់ប្រភេទនេះមានចំនួនច្រើនដែលមានបញ្ញត្តិចែងអំពីភាពចាំបាច់នៃការយល់ព្រមពីសភាជាន់ខ្ពស់ ។

ឋាន:និងភាពសំខាន់ដែលរដ្ឋធម្មនុញ្ញផ្តល់ដល់សភាជាន់ខ្ពស់ ត្រូវបានបញ្ជាក់ដោយសិទ្ធិដែលកំណត់ដោយច្បាប់នៃការយល់ព្រម(lois d'approbation) ។ ដោយសារសិទ្ធិនេះ សភាជាន់ខ្ពស់មានឥទ្ធិពលយ៉ាងខ្លាំងលើដំណើរការធ្វើច្បាប់ ។ជិតពាក់កណ្តាលនៃច្បាប់សហព័ន្ធជាច្បាប់នៃការ

យល់ព្រមដែលភាគច្រើនទាក់ទងនឹងកិច្ចការដ៏ស្មុកស្មាញនៃនយោបាយផ្ទៃក្នុង ។ ច្បាប់មួយក្នុងចំណោមពីរ(១/២) រដ្ឋសភាមិនមានសិទ្ធិធ្វើតែឯកឯង ដោយមិនបានពិចារណាទស្សនៈរបស់សភាជាន់ខ្ពស់ ដើម្បីធ្វើការសម្រេចឡើយ ។

សភាទាំងពីរតែងធ្វើការតាមគោលការណ៍សម្របសម្រួល ថ្នឹងថ្នែង យោគយល់ និងគោរពគ្នាទៅវិញទៅមក ។សភាជាន់ខ្ពស់កម្របដិសេធសេចក្តីព្រាងច្បាប់ណាមួយជាស្ថាពរណាស់ ។

ច-បញ្ញត្តិដោយឡែកក្នុងវិស័យថវិកា

សេចក្តីព្រាងថវិកា (les projets de budget) និងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុកែតម្រូវ (les projets de loi de finances rectificatives) ត្រូវតែបញ្ជូនទៅសភាជាន់ខ្ពស់ ព្រមពេលបញ្ជូនទៅរដ្ឋសភា ។ សភាជាន់ខ្ពស់អាចកំណត់ជំហររបស់ខ្លួនលើសេចក្តីព្រាង ក្នុងរយៈពេល៦ សប្តាហ៍(ពាសប្តាហ៍ចំពោះសេចក្តីព្រាងតែតម្រូវ) ។

ខ-អំណាចត្រួតពិនិត្យ

នៅឆ្នាំបន្ទាប់ រដ្ឋមន្ត្រីហិរញ្ញវត្ថុសហព័ន្ធត្រូវបង្ហាញសភាជាន់ខ្ពស់ និងរដ្ឋសភានូវគណនីចំណូលនិងចំណាយថវិកាក៏ដូចជាស្ថានភាពនៃទុនដែលតេជំពាក់និងបំណុល ។

តុលាការគណនីសហព័ន្ធ (Cour fédérale des comptes) ត្រូវធ្វើរបាយការណ៍អំពីការអនុវត្តថវិកានិងសេដ្ឋកិច្ចរៀងរាល់ឆ្នាំជូនសភាជាន់ខ្ពស់ (ក៏ដូចជារដ្ឋសភា និងរដ្ឋាភិបាលសហព័ន្ធ) ។

សភាជាន់ខ្ពស់បានបង្កើតសភាកិច្ចការអឺរ៉ុប(ក្លូនសភាជាន់ខ្ពស់-mini Bundesrat) ដែលពិភាក្សាអំពីកិច្ចការប្រញាប់ និងសម្ចាត់ដែលទាក់ទងទៅនឹងសហភាពអឺរ៉ុប ។

ត-គណៈកម្មការ

ការងាររបស់គណៈកម្មការជាបេះដូងនៃសកម្មភាពរបស់សភាជាន់ខ្ពស់ ។ គណៈកម្មការមានចំនួន១៦ ។ សមត្ថកិច្ចរបស់គណៈកម្មការនីមួយ១អាស្រ័យជាពិសេសទៅតាមតួនាទីរបស់ក្រសួងក្នុងរដ្ឋាភិបាល ។

V-មធម្យញ្ញត្តិដោយឡែក

ក-ស្ថានភាពការពារខ្លួន(état de défense)

ការយល់ព្រមរបស់ព្រឹទ្ធសភាជាការចាំបាច់លើការសម្រេចរបស់រដ្ឋសភាអំពីការឈ្លានពានដោយអាវុធលើដែនដីសហព័ន្ធ ហើយដែលការឈ្លានពាននោះមានទ្រង់ទ្រាយធំ ។

ក្នុងក្របខ័ណ្ឌនេះ សេចក្តីព្រាងច្បាប់របស់រដ្ឋាភិបាលសហព័ន្ធដែលប្រកាសជាការប្រញាប់ត្រូវតែបញ្ជូនទៅព្រឹទ្ធសភាព្រមពេលត្មានីងរដ្ឋសភា ។ សភាទាំងពីរពិភាក្សារួមត្មាជាបន្ទាន់នូវសេចក្តីព្រាងច្បាប់ទាំងនេះ ។ សភាទាំងពីរអាចបង្កើតគណៈកម្មការរួម ។

រដ្ឋសភាអាចប្រកាសត្រប់ពេលបញ្ចប់ស្ថានភាពអាសន្ន ដោយមានការយល់ព្រមពីព្រឹទ្ធសភាតាមសេចក្តីសម្រេចដែលប្រកាសដោយប្រធានាធិបតីសហព័ន្ធ ។

ខ-អំណាចកែប្រែរដ្ឋធម្មនុញ្ញ

ការសើរើច្បាប់គោល ត្រូវតែមានការយល់ព្រមពីព្រឹទ្ធសភាតាមសម្លេងភាគច្រើន២/៣ និងការអនុម័តពីរដ្ឋសភា តាមសម្លេងភាគច្រើន២/៣ ។

គ-សមត្ថកិច្ចក្នុងការងារសហព័ន្ធ

បញ្ញត្តិខ្លះរបស់រដ្ឋាភិបាលសហព័ន្ធឬរបស់រដ្ឋមន្ត្រីសហព័ន្ធ ដែលទាក់ទងនឹងការប្រព្រឹត្តទៅរបស់សហភាពត្រូវតែមានការយល់ព្រមពីព្រឹទ្ធសភា ។

ឃ-បញ្ជារបស់ព្រឹទ្ធសភានិងរដ្ឋសភាឱ្យបញ្ចប់ការការធានានៃកងកម្លាំងប្រដាប់អាវុធ

ង-ការចោទប្រកាន់ប្រធានាធិបតីសហព័ន្ធ

ព្រឹទ្ធសភាឬរដ្ឋសភាធ្វើការចោទប្រកាន់ប្រធានាធិបតីសហព័ន្ធទៅតុលាការធម្មនុញ្ញសហព័ន្ធ (Cour constitutionnelle fédérale) ចំពោះការរំលោភរដ្ឋធម្មនុញ្ញឬ ច្បាប់សហព័ន្ធ តាមសម្លេងភាគច្រើន២/៣ ។

ច-ក្នុងករណីវិស្សមកាលនៃតំណែងប្រធានាធិបតីសហព័ន្ធ ប្រធានព្រឹទ្ធសភាទទួលកាន់កាប់តំណែងនេះ

ធ-ព្រឹទ្ធសភាជ្រើសតាំងសមាជិកតុលាការធម្មនុញ្ញសហព័ន្ធចំនួនពាក់កណ្តាល ហើយ
ពាក់កណ្តាលទៀតដោយរដ្ឋសភា។

I-សមាសភាព

សមាជិកព្រឹទ្ធសភាមាន១៧រូប តែងតាំងដោយអគ្គទេសាភិបាលដែល :

-១០រូប តាមសំណើរបស់នាយករដ្ឋមន្ត្រី

-៤រូប តាមសំណើរបស់ប្រមុខក្រុមប្រឆាំង

-១រូប យោលតាមសមត្ថកិច្ច ឬតំណាងផលប្រយោជន៍ដែលអគ្គទេសាភិបាលយល់ថាត្រូវតែមានតំណាង

-១រូបតាមសំណើរបស់របស់ក្រុមប្រឹក្សាបាប៊ូដា

-១រូបជាពលរដ្ឋបាប៊ូដា តាមសំណើរបស់នាយករដ្ឋមន្ត្រី ។

ក្នុងករណីវិស្សមកាលមួយរយៈនៃអាសនៈរបស់សមាជិកព្រឹទ្ធសភាណាម្នាក់ (អវត្តមានព្យួរការងារឬមានជម្ងឺ) អគ្គទេសាភិបាលអាចចាត់តាំងអ្នកជំនួសមួយរយៈនោះ ។

II-រយៈពេលតាំង

-អាណត្តិ : ៥ឆ្នាំ

-ការផ្លាស់ប្តូរថ្មីចុងក្រោយ : ២៣ មីនា ២០០៤

-លក្ខខណ្ឌ :អាយុ ២១ ឆ្នាំ ជាពលរដ្ឋ commonweath britanique --

- ស្គាល់នៅយ៉ាងតិច១ឆ្នាំមុនការបោះឆ្នោត ចេះភាសាអង់គ្លេស

-មិនអាចជាសមាជិកព្រឹទ្ធសភា : ជាប់ទាក់ទងជាមួយប្រទេសក្រៅ ក្ស័យធនដែលមិនមានធ្លាប់ត្រូវ ជម្ងឺសរសៃប្រសាទ មានទោសដល់ជីវិត មានទោសជាប់គុកស្នើ ឬលើសពី១ឆ្នាំ បទល្មើសបោះឆ្នោត បទឧក្រិដ្ឋប្រព្រឹត្ត១០ឆ្នាំមុនបោះឆ្នោត ។

-វិសមិតភាព : មុខងារសាធារណៈមួយចំនួន មុខងារខ្លះក្នុងការបោះឆ្នោត រដ្ឋមន្ត្រីក្រសួងធម្មការ (Ministre du culte) ។

តុលាការជាន់ខ្ពស់ត្រួតពិនិត្យសុពលភាពនៃការតែងតាំងសមាជិកព្រឹទ្ធសភា ។

III-សម័យប្រជុំ

អត្ថទេសាភិបាលកំណត់កាលបរិច្ឆេទនៃការបើកឬបិទសម័យប្រជុំ នៅក្នុងរយៈពេលនៃនីតិកាល ។ ប៉ុន្តែសភាមិនអាចមិនប្រជុំហួសពីបីខែជាប់ត្នាក្នុងនីតិកាលឬហួសពី៦ខែ បន្ទាប់ពីការពន្យារអាណត្តិសភាឬហួសពី៤ខែបន្ទាប់ពីការរំលាយបានទេ ។

ការប្រជុំត្រូវផ្ទាក កាលបើមិនមានវត្តមានសមាជិក៦នាក់ ដោយមិនគិតប្រធាន ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភា និងអំណាចនីតិប្រតិបត្តិ

សភាអង់ទីហ្គានិងបាប៉ូដាមានព្រះមហាក្សត្រអង់ត្លេស ព្រឹទ្ធសភា និង រដ្ឋសភា ។

ក-អំណាចនីតិប្បញ្ញត្តិ

មានការកំរិតជាទូទៅនៃអំណាចរបស់ព្រឹទ្ធសភាក្នុងការងារនីតិប្បញ្ញត្តិ ។

១-គំនិតផ្តួចផ្តើមធ្វើច្បាប់

សមាជិកសភាមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់លើកលែងតែច្បាប់ស្តីពីហិរញ្ញវត្ថុ ។ ម្យ៉ាងទៀត លើកលែងតែមានការយល់ព្រមពីរដ្ឋាភិបាល សមាជិកសភាមិនអាចស្នើច្បាប់ដែលបន្ថែមបន្ទុកសាធារណៈឬបន្ថយធនធានសាធារណៈ ឬទាក់ទងនឹងបំណុលសាធារណៈឡើយ ។

២-សិទ្ធិវិសោធនកម្ម

សមាជិកសភាមានសិទ្ធិធ្វើវិសោធនកម្ម ។ មុនការពិនិត្យអត្ថបទជាលើកទី២នៃព្រឹទ្ធសភា រដ្ឋសភាអាចស្នើវិសោធនកម្មដល់ព្រឹទ្ធសភា ។ បើព្រឹទ្ធសភាអនុម័ត វិសោធនកម្មនោះចាត់ទុកជាវិសោធនកម្មរបស់ព្រឹទ្ធសភាយល់ព្រមដោយរដ្ឋសភា ។

លើកលែងតែមានការយល់ព្រមពីរដ្ឋាភិបាល សមាជិកសភាមិនអាចផ្តើមធ្វើច្បាប់ ឬវិសោធនកម្មដែលនាំឱ្យបង្កើនបន្ទុកសាធារណៈឬបន្ថយធនធានសាធារណៈ ឬទាក់ទងនឹងបំណុលសាធារណៈឡើយ ។

៣-នីតិវិធី

សេចក្តីព្រាងច្បាប់អាចបញ្ជូនមកសភាណាមួយមុនក៏បានលើកលែងតែសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុដែលត្រូវតែបញ្ជូនទៅរដ្ឋសភាជាមុន ។

៤-អំណាចត្រួតពិនិត្យ

ប្រធានសម័យប្រជុំអាចតម្រូវឱ្យមានវត្តមានរបស់រដ្ឋមន្ត្រីយុត្តិធម៌ ក្នុងសម័យប្រជុំបើយល់ឃើញថាមានប្រយោជន៍ ។ ប្រធានក៏អាចតម្រូវវត្តមានរបស់រដ្ឋមន្ត្រីដែលជាសមាជិកព្រឹទ្ធ-សភាដែរដើម្បីបំភ្លឺបញ្ជាដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ។

ត-ការរំលាយ

អត្តទេសាភិបាលអាចរំលាយ ឬពន្យារនីតិកាលរបស់សភាបានត្រប់ពេល ដោយមានការយល់ព្រមពីនាយករដ្ឋមន្ត្រី ។

V-បទប្បញ្ញត្តិដោយឡែក

ក-ការសើរើរដ្ឋធម្មនុញ្ញ

ក្នុងការសើរើរដ្ឋធម្មនុញ្ញត្រូវយកសម្លេងភាគច្រើនមាន២៣ឬ៣/៤នៃសមាជសភា ទៅតាមមាត្រាដែលពាក់ព័ន្ធ ។

ខ-ប្រធានព្រឹទ្ធសភា

ប្រធានព្រឹទ្ធសភាត្រូវជ្រើសរើសសំរាប់រយៈពេល៥ឆ្នាំ ។ប្រធានព្រឹទ្ធសភាដឹកនាំការប្រជុំរួមរបស់សភាទាំងពីរ ។

នៅពេលរៀបចំឡើងវិញក្រោយពីការរំលាយ ព្រឹទ្ធសភាបោះឆ្នោតជ្រើសរើសប្រធានដែលមិនមែនជាសមាជិករដ្ឋាភិបាល ។

ត-កាលៈទេសៈពិសេស

អត្តទេសាភិបាលអាចប្រកាសស្ថានភាពអាសន្ន សំរាប់រយៈពេល៧ថ្ងៃ អំឡុងសម័យប្រជុំ និងសំរាប់រយៈពេល២១ថ្ងៃ ក្រៅសម័យប្រជុំ ល្តីកណាតែសភាបានអនុម័តនូវសេចក្តីសម្រេចចិត្ត ចិត្តអំពីការប្រកាសភាពអាសន្នជាសាធារណៈ ។

សភាក៏ធ្វើរបៀបនេះបាន ដោយការផ្តើមតំនិតរបស់ខ្លួនសំរាប់រយៈពេលពាខែយ៉ាងយូរ ហើយអាចបន្តជាថ្មី ។

ការសម្រេចអំពីរយៈពេលនៃភាពអាសន្នត្រូវមានសម្លេងភាគច្រើននៃចំនួនសមាជិកស-ភានីមួយ១ ។

ឃ-អំណាចដោយឡែករបស់សភា

ករណីខាងក្រោម ត្រូវមានការសម្រេចរបស់សភា :

-ករណីបើកបណ្តឹងឧទ្ធរណ៍ទៅក្រុមប្រឹក្សាព្រះមហាក្សត្រ (ដែលមិនមានចែងក្នុងរដ្ឋ-ធម្មនុញ្ញ)

-សមាសភាព និងអំណាចនៃក្រុមប្រឹក្សាមូលដ្ឋាននៃបាប៉ូដា

-បញ្ញត្តិទាក់ទងនឹងរដ្ឋាភិបាលតាមមណ្ឌល ។

ង-អ្នកការពារពលរដ្ឋ (OMDUDSMAN)

តាមការសម្រេចចិត្តរបស់សភានីមួយ១ មន្ត្រីមួយរូបរបស់សភាត្រូវតែងតាំងជា ombudman ដែលមិនអាចផ្ទាស់ប្តូរបាន (inamovible) ។ សភាមានអំណាចបញ្ជាក់ពីមុខងារ អំណាច និងកាតព្វកិច្ចរបស់ombudman ។

ព្រឹទ្ធសភាតំណាងឱ្យសមាសភាពនៃសហភាព ។

I.សមាសភាព

សមាជិកព្រឹទ្ធសភាទាំងអស់មាន៧២នាក់ ដែលជ្រើសតាំងដោយការបោះឆ្នោតដោយផ្ទាល់(មុនឆ្នាំ២០០១បោះឆ្នោតមិនផ្ទាល់)៖ សមាជិកព្រឹទ្ធសភាពីនាក់ក្នុងមួយខេត្ត និងសមាជិកពីនាក់របស់ទីក្រុងBuenos Aires ។

អនុប្រធានាធិបតីជាប្រធានព្រឹទ្ធសភាដោយពេញច្បាប់ ប៉ុន្តែពុំមានសិទ្ធិអនុម័ត លើកលែងតែក្នុងករណីបែងចែកសម្លេងជាពីរស្មើគ្នា ។ ប្រធានព្រឹទ្ធសភាជាអធិបតីនៃសម័យប្រជុំរួមសភាទាំងពីរ ។

II.របបបោះឆ្នោត

មាន២៤មណ្ឌលពហុនាម ពីអាសនៈក្នុងមួយមណ្ឌល ត្រូវជា២៣ខេត្ត និងរដ្ឋធានី Buenos Aire ។

ប្រព័ន្ធបោះឆ្នោត:

១-របបអន្តរកាល(សំរាប់ជាស្ថាវតី)

ការបោះឆ្នោតតាមសម្លេងភាគច្រើនដោយសភានីតិប្បញ្ញត្តិខេត្ត លើកលែងតែទីក្រុង Buenos Aireដែលបោះដោយអង្គបោះឆ្នោតពិសេស ។ នេះជាករណី ឆ្នាំ១៩៩៥ ។

អាសនៈ២ត្រូវផ្តល់ឱ្យគណបក្សដែលបានសម្លេងភាគច្រើន ហើយអាសនៈទីពីត្រូវបានទៅគណបក្សដែលបានសម្លេងក្រោមបន្ទាប់ ។

២-របបជាធរមានចាប់ពី២០០១

បោះឆ្នោតដោយផ្ទាល់តាមសម្លេងភាគច្រើនលើបញ្ជីពហុនាម : ២អាសនៈបានទៅបញ្ជីសម្លេងភាគច្រើន ១អាសនៈបានទៅបញ្ជីបន្ទាប់ ។

អាណត្តិ: ៦ឆ្នាំ ផ្លាស់ប្តូរមួយភាគបី ពីរឆ្នាំម្តង និងតាមមណ្ឌល ។

ការផ្លាស់ប្តូរចុងក្រោយ : ១៤តុលា ២០០១(ព្រឹទ្ធសភាទាំងមូលត្រូវបានផ្លាស់ប្តូរដោយការអនុវត្តប្រព័ន្ធបោះឆ្នោតថ្មី : ប្រព័ន្ធបោះឆ្នោតសកលដោយផ្ទាល់ និងផ្លាស់ប្តូរថ្មីមួយភាគបីពីរឆ្នាំម្តង ។ ក្រោយមកមានប្រើវិធីចាប់ឆ្នោតរកអ្នកដែលត្រូវចេញនៅឆ្នាំទី២ ឆ្នាំទី៤ឬឆ្នាំទី៦) ។

លក្ខខណ្ឌឈរឈ្មោះ : អាយុ៣០ឆ្នាំ មានសញ្ជាតិអាហ្ស៊ង់ទីន៦ឆ្នាំ មកទល់ពេលឈរឈ្មោះមានចំណូល ២០០០peso ក្នុងមួយឆ្នាំ មានកំណើត ឬស្នាក់នៅ២ឆ្នាំក្នុងមណ្ឌលបោះឆ្នោតមកទល់ពេលឈរឈ្មោះ ។

វិសមិតភាព : សមាជិក(membres du clergé) និងអភិបាលក្នុងខេត្ត ។

III-សម័យប្រជុំ

សភាទាំងពីរបើក និងបិទសម័យប្រជុំព្រមពេលគ្នា ។ គ្មានសភាណាមួយលើកពេលហួសពី៣ថ្ងៃ ដោយគ្មានការយល់ព្រមពីសភាមួយទៀតទេ ។

ក-សម័យប្រជុំសាមញ្ញ

សម័យប្រជុំតែមួយប្រចាំឆ្នាំពីថ្ងៃ១ មីនា ទៅ៣០ វិច្ឆិកា ។

ខ-សម័យប្រជុំវិសាមញ្ញ

ប្រធានាធិបតីអាចកោះប្រជុំសភាជាវិសាមញ្ញឬបន្តសម័យប្រជុំសាមញ្ញ ។

IV-ឧទាក់ឧទចជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

អំណាចនីតិប្បញ្ញត្តិអនុវត្តដោយសភាទាំងពីរ តីរដ្ឋសភា និងព្រឹទ្ធសភា ។ សភាទាំងពីរមានអំណាចស្មើគ្នា ។

១-គំនិតផ្តួចផ្តើមធ្វើច្បាប់

សមាជិកព្រឹទ្ធសភាមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ដូចសមាជិករដ្ឋសភា និងអង្គការប្រតិបត្តិ (ប៉ុន្តែរដ្ឋសភា មានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់អំពីវិភាគទាន និងការជ្រើសរើសទ័ព (les contributions et les recrutements des troupes)។

ថវិកាជាតិត្រូវអនុម័តដោយសភា តាមសំណើរបស់រដ្ឋាភិបាល។

២-សិទ្ធិធ្វើវិសោធនកម្ម

សមាជិកព្រឹទ្ធសភាមានសិទ្ធិធ្វើវិសោធនកម្ម។

៣-នីតិវិធី

អត្ថបទអាចបញ្ជូនទៅរដ្ឋសភាឬព្រឹទ្ធសភា លើកលែងតែមានបញ្ញត្តិចែងក្នុងរដ្ឋធម្មនុញ្ញ (ឧទាហរណ៍ ច្បាប់ស្តីពីទំនាក់ទំនងរបស់រដ្ឋជាមួយខេត្តត្រូវបញ្ជូនទៅព្រឹទ្ធសភាជាមុន)។

ក-នីតិវិធីធម្មតា

ពេលបានអនុម័តដោយសភាមួយណាហើយ អត្ថបទត្រូវបញ្ជូនទៅឱ្យសភាមួយទៀតអនុម័ត។ ក្រោយពេលពិភាក្សាជាទូទៅ សភាអាចប្រគល់សិទ្ធិ តាមសម្លេងភាគច្រើនដាច់ខាតទៅឱ្យគណៈកម្មការណាមួយពិនិត្យមួយមាត្រាម្តង១ ។ ក្នុងលក្ខខណ្ឌដូចគ្នា សភាអាចដកសិទ្ធិនេះមកវិញ ។ ពេលដែលគណៈកម្មការបានអនុម័តរួចហើយ នីតិវិធីធម្មតាត្រូវបន្តទៅទៀត។

អត្ថបទណាមួយដែលត្រូវបដិសេធទាំងស្រុងដោយសភាណាមួយ មិនអាចយកមកពិនិត្យជាថ្មីក្នុងសម័យប្រជុំប្រចាំឆ្នាំដដែលបានឡើយ។

សភាមិនអាចបដិសេធទាំងស្រុងនូវសេចក្តីព្រាងដែលផ្តើមឡើងដោយសភាខ្លួនឯង និងដែលត្រូវបញ្ជេញបញ្ជូល ឬ ធ្វើវិសោធនកម្មដោយសភាមួយទៀតបានទេ។

តាមសម្លេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកវត្តមាន សភាដែលបានពិនិត្យលើកដំបូងអាចអនុម័តបន្ថែមឬវិសោធនកម្ម ឬរក្សាសេចក្តីដើមនៃអត្ថបទ លើកលែងតែការកែប្រែដែលអនុម័តដោយសភាមួយទៀត តាមសម្លេងភាគច្រើន២/៣នៃចំនួនសមាជិកវត្តមាន។ ក្នុងករណីនេះ អត្ថបទត្រូវផ្ញើជូនប្រធានាធិបតី ជាមួយនឹងការកែប្រែរបស់សភាមួយទៀត លើក

លែងតែសភាដែលអនុម័តលើកដំបូងរក្សាអត្ថបទរបស់ខ្លួន តាមសម្លេងភាគច្រើន២/៣នៃចំនួនសមាជិកវត្តមាន ។ សភាដែលអនុម័តលើកដំបូងមិនអាចដាក់បញ្ចូលការកែប្រែថ្មីពីលើការកែប្រែរបស់សភាមួយទៀតទេ ។

ការសម្រេចរបស់សភានីមួយៗត្រូវតែមានការបញ្ជាក់យ៉ាងច្បាស់លាស់ ។ ការអនុម័តដោយតុល្យភាព (ភាពស្ងៀមស្ងាត់) ឬ ដោយសន្ទតត្រូវទុកជាឥតបានការ ក្នុងគ្រប់ករណី ។

ខ-សិទ្ធិជំទាស់របស់ប្រធានាធិបតី

ក្នុងរយៈពេល១០ថ្ងៃដែលអត្ថបទបានផ្ញើទៅប្រធានាធិបតី អត្ថបទដែលមិនត្រឡប់ទៅសមាជ(Congrès) ត្រូវចាត់ទុកថាយល់ព្រមដោយប្រធានាធិបតី ។

កាលណាអត្ថបទត្រូវបដិសេធដោយផ្នែក ផ្នែកដែលនៅសល់មិនត្រូវបានអនុម័តទេ ។ ក៏ប៉ុន្តែ បញ្ញត្តិទាំងឡាយដែលមិនមែនជាកម្មវត្ថុនៃការជំទាស់អាចត្រូវប្រកាសឱ្យប្រើ បើសិនជាបញ្ញត្តិទាំងនោះមានស្ថិយភាពដែលមានតម្លៃប៉ុនគ្នានឹងវិធាន និងបើសិនជាការអនុម័តនោះមិនធ្វើឱ្យចុះថយនូវស្មារតី ឬឯកភាពនៃអត្ថបទ (esprits ou unité du texte) ដែលអនុម័តដោយសមាជ ។ ក្នុងករណីនេះ នីតិវិធីដែលចែងចំពោះក្រឹត្យដែលមានលក្ខណៈចាំបាច់ និងបន្ទាន់អាចអនុវត្តបាន ។

បើសិនជាសេចក្តីព្រាងអត្ថបទត្រូវបដិសេធទាំងស្រុង ឬមួយផ្នែកដោយប្រធានាធិបតី អត្ថបទនោះត្រូវបញ្ជូនត្រឡប់ដោយមានមូលវិចារណ៍របស់ប្រធានាធិបតីទៅសភាដែលបានផ្តើមតំនិត ។ បើសភានេះអនុម័តជាថ្មីតាមសម្លេងភាគច្រើន២/៣ អត្ថបទនោះត្រូវបញ្ជូនទៅសភាមួយទៀត ។ បើសភាមួយទៀតនេះអនុម័តតាមសម្លេងភាគច្រើនដូចគ្នា សេចក្តីព្រាងនោះក្លាយទៅជាច្បាប់ និងត្រូវបញ្ជូនទៅប្រធានាធិបតីដើម្បីប្រកាសឱ្យប្រើ ។

ក្នុងគ្រប់ករណីការអនុម័តក្នុងសភាទាំងពីរត្រូវធ្វើជាសាធារណៈដោយយល់ព្រម ឬមិនយល់ព្រម ។ ឈ្មោះអ្នកបោះឆ្នោត ការជ្រើសរើស ក៏ដូចជាយោបល់ជំទាស់របស់ប្រធានាធិបតីត្រូវចុះផ្សាយជាបន្ទាន់ក្នុងសារព័ត៌មាន ។

បើសិនជាសភាទាំងពីរមិនព្រមព្រៀងគ្នា សេចក្តីព្រាងមិនអាចយកមកពិភាក្សាជាថ្មីក្នុងសម័យប្រជុំប្រចាំឆ្នាំដដែលបានឡើយ ។

គ-បញ្ញត្តិដោយឡែក

១-ការផ្លាស់ប្តូរប្រព័ន្ធបោះឆ្នោតឬរបបគណបក្សនយោបាយត្រូវតែអនុម័តដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកសភាទាំងពីរ ក្នុងករណីទាំង១០ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

២-សម្លេងភាគច្រើន ២/ ៣នៃចំនួនសមាជិកសភានីមួយ១ត្រូវអនុវត្តចំពោះការអនុម័តសន្ធិសញ្ញាទាក់ទងនឹងសិទ្ធិមនុស្សដើម្បីឱ្យមានតម្លៃធម្មនុញ្ញ (valeur constitutionnelle)។

៣-តាមការផ្តើមគំនិតរបស់រដ្ឋសភា សមាជអាចដាក់សេចក្តីព្រាងណាមួយពិគ្រោះយោបល់ពីប្រជាពលរដ្ឋ ។ បើការអនុម័តមានលក្ខណៈវិជ្ជមាន សេចក្តីព្រាងនេះនឹងទៅជាច្បាប់ ហើយត្រូវប្រកាសឱ្យប្រើជាស្វ័យប្រវត្តិ ។ ប៉ុន្តែសមាជ ឬប្រធានាធិបតីអាចស្នើសុំថ្លាលទ្ធផលនៃការពិគ្រោះយោបល់នេះមិនជាការចាំបាច់ទេ។

តាមសម្លេងភាគច្រើននៃសមាជិកសភានីមួយ១ សមាជកំណត់ប្រធានបទ នីតិវិធី និងកាលបរិច្ឆេទនៃការពិគ្រោះយោបល់ ។

ឧ-អំណាចត្រួតពិនិត្យ

១-ការសួរដេញដោល និងការបន្ទោស

ប្រមុខរដ្ឋាភិបាលអាចត្រូវព្រឹទ្ធសភា ឬ សភាតំណាងរាស្ត្រកោះអញ្ជើញឱ្យមកឆ្លើយបំភ្លឺ ហើយត្រូវបន្ទោសដោយសម្លេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកសភាមួយ១។

២-ព័ត៌មាន

ព្រឹទ្ធសភាអាចកោះអញ្ជើញរដ្ឋមន្ត្រីឱ្យមកពន្យល់ឬរាយការណ៍ ។ ក្រោយបើកសម័យប្រជុំ សមាជិកខុទ្ទកាល័យបង្ហាញសមាជនូវរបាយការណ៍លំអិតអំពីការងាររបស់ក្រសួង។

៣-អំណាចនីតិប្បញ្ញត្តិ ត្រួតពិនិត្យសេវាស៊ីវិលរបស់រដ្ឋលើមូលដ្ឋាននៃរបាយការណ៍របស់អធិការកិច្ចទូទៅ ដែលជាអង្គការស្វយ័តរបស់សមាជ។

៤-ការអនុម័តអនុសញ្ញាចូលជាសមាជិកអង្គការអន្តរជាតិតម្រូវឱ្យមានសម្លេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកសភាមួយ១។ សម្លេងដូចគ្នា តម្រូវចំពោះការបដិសេធអនុសញ្ញានោះ ។

ค-ទំនាក់ទំនងជាមួយប្រធានាធិបតី

១-ការជំនួសប្រធានាធិបតី

ក្នុងករណីបាត់ខ្លួន អនិច្ចកម្ម លាលែង ឬ អសមត្ថភាពនៃប្រធានាធិបតី ឬអនុប្រធានាធិបតី សមាជិកាត់តាំងវរជនឱ្យធ្វើអធិបតីរហូតដល់ចប់មូលហេតុនៃអសមត្ថភាព ឬរហូតដល់ពេលបោះឆ្នោតជ្រើសរើសប្រធានាធិបតីថ្មី ។

២-នីតិវិធីនៃក្រិត្យច្បាប់

ក្នុងកាលៈទេសៈពិសេសដែលមិនអាចអនុវត្តនីតិវិធីតាមរដ្ឋធម្មនុញ្ញបាន ប្រធានាធិបតីអាចចេញក្រិត្យដែលមានតម្លៃជាច្បាប់ លើកលែងតែក្នុងវិស័យច្បាប់ព្រហ្មទណ្ឌ ពន្ធដារ ច្បាប់បោះឆ្នោតឬប្រព័ន្ធគណបក្សដោយមានការចុះហត្ថលេខាអមរបស់រដ្ឋមន្ត្រីទាំងអស់ ។

ក្នុងរយៈពេល១០ថ្ងៃ ប្រមុខរដ្ឋាភិបាលជាបុគ្គលដាក់សេចក្តីសម្រេចដើម្បីសុំយោបល់ពីគណៈកម្មការរួមនៃសមាជ ដែលមានសមាសភាពសមាមាត្រទៅនឹងក្រុមនយោបាយរបស់សភានីមួយៗ ។ ក្នុងរយៈពេល១០ថ្ងៃ គណៈកម្មការដាក់របាយការណ៍របស់ខ្លួនជូនសម័យប្រជុំពេញអង្គនៃសភានីមួយៗដើម្បីពិភាក្សាជាបន្ទាន់ ។

៣-ការបើកសម័យប្រជុំសមាជ

ប្រធានាធិបតីបើកសម័យប្រជុំសមាជប្រចាំឆ្នាំនៃសភាទាំងពីរ ។ ប្រធានាធិបតីប្រកាសនូវសារអំពីស្ថានភាពរបស់ប្រជាជាតិ និងស្នើនូវអនុសាសន៍អំពីវិធានការដែលយល់ថាជាការមានប្រយោជន៍ ។

៤-ការចេញពីដែនដីជាតិ

ប្រធានាធិបតីអាចចេញពីដែនដីជាតិ ដោយមានការយល់ព្រមពីសមាជ ។ ក្នុងវិស្សមកាលរបស់សភា ប្រធានាធិបតីអាចចេញពីដែនដីជាតិដោយមិនមានការអនុញ្ញាត ចំពោះមូលហេតុដែលមានប្រយោជន៍សាធារណៈ ។

V -បទឧប្បញ្ញត្តិដោយឡែក

ក-រដ្ឋាភិបាលខេត្ត

១-ក្នុងករណីខ្លះ ខេត្តអាចចុះកិច្ចព្រមព្រៀងអន្តរជាតិហើយជូនដំណឹងទៅសមាជ ។

២-ខេត្តមិនអាចបង្កើតធនាគារដែលមានអំណាចចោះផ្សាយក្រដាសប្រាក់ ដោយគ្មានការអនុញ្ញាតពីសមាជ និងមិនអាចអនុម័តក្រមរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ក្រមពាណិជ្ជកម្ម ឬក្រ ក្រោយការអនុម័តរបស់សមាជ ។

៣-ព្រឹទ្ធសភាមានសមត្ថកិច្ចផ្តើមគំនិត

ក-កិច្ចព្រមព្រៀងរវាងរដ្ឋនិងខេត្ត ដើម្បីបង្កើតប្រព័ន្ធរួមគ្នានូវមូលនិធិបានមកពីអាករ ។

ខ-បញ្ញត្តិដែលបង្ហាញកូណៈដល់ការអភិវឌ្ឍន៍ស្នូលនៃខេត្ត និងតំបន់ ។

ខ-ការជំនំជម្រះឥស្សរជនខ្លះ

ព្រឹទ្ធសភាមានសមត្ថកិច្ចជំនំជម្រះជាសាធារណៈ ប្រធានាធិបតី អនុប្រធានាធិបតី ប្រមុខរដ្ឋាភិបាល រដ្ឋមន្ត្រី និងចៅក្រមតុលាការជាន់ខ្ពស់ ដែលចោទប្រកាន់ដោយរដ្ឋសភាចំពោះកំហុស និងបទឧក្រិដ្ឋក្នុងការបំពេញមុខងារ និងបទឧក្រិដ្ឋធម្មតាតាមសេចក្តីសម្រេច ដែលអនុម័តដោយសម្លេងភាគច្រើន២៣នៃចំនួនសមាជិករដ្ឋសភាវត្តមាន ។

សេចក្តីប្រកាសអំពីពិរុទ្ធភាពត្រូវមានសម្លេងភាគច្រើន២ / ៣ នៃចំនួនសមាជិកវត្តមាន ។ កាលណាជនដែលត្រូវចោទជាប្រធាន ការប្រជុំត្រូវស្ថិតក្រោមអធិបតីរបស់ប្រធានតុលាការជាន់ខ្ពស់ ។

គ-ស្ថានភាពពិសេស

១-ការប្រកាសសង្គ្រាម

ប្រធានប្រកាសសង្គ្រាមឬបញ្ជាឱ្យបង្ក្រាបសង្គ្រាមដោយមានការយល់ព្រមពីសមាជ ។

២-ស្ថានភាពអាសន្ន

ព្រឹទ្ធសភាមានសមត្ថកិច្ច ក្នុងករណីមានការវាយប្រហារពីបរទេស អនុញ្ញាតឱ្យប្រធាន

ប្រកាសស្ថានភាពអាសន្ន នៅមួយផ្នែក ឬច្រើនផ្នែកក្នុងប្រទេស សំរាប់រយៈពេលមួយមានកំណត់ ។ ក្នុងករណីបាត់សណ្តាប់ធ្នាប់ក្នុងប្រទេស ប្រធានមានសិទ្ធិចាត់វិធានការ កាលបើសមាជស្ថិតក្នុងវិស្សមកាល ។

ឃ-អំណាចក្នុងការតែងតាំង

១-ចៅក្រម

ប្រធានតែងតាំងចៅក្រមតុលាការជាន់ខ្ពស់ ដោយមានការយល់ព្រមពីព្រឹទ្ធសភាតាមសម្លេងភាគច្រើនពីរភាគបីនៃសមាជិកវត្តមាន ។ ប្រធានតែងតាំងចៅក្រមតុលាការផ្ទាល់ សហព័ន្ធ លើបញ្ជីបេក្ខជនដែលរៀបចំឡើងដោយក្រុមប្រឹក្សានៃអង្គចៅក្រម ដោយមានការយល់ព្រមពីព្រឹទ្ធសភា ។ ការពន្យារមុខការចៅក្រមហួសពីអាយុ៧៥ឆ្នាំត្រូវសម្រេចតាមសម្លេងដូចខាងលើ ។

២-អ្នកការទូត

ប្រធានតែងតាំង ឬផ្ទាស់ប្តូរអ្នកការទូត និងអនុពន្ធសេដ្ឋកិច្ច ដោយមានការយល់ព្រមពីព្រឹទ្ធសភា ។

៣-កម្លាំងប្រដាប់អាវុធ

ការតែងតាំង និងការតម្លើងថ្នាក់មន្ត្រីយោធាជាន់ខ្ពស់ជាសមត្ថកិច្ចរបស់ប្រធានដោយមានការយល់ព្រមពីព្រឹទ្ធសភា ។

ង-តំណាងពលរដ្ឋ (ombudman)

Ombudman ជាអង្គការឯករាជ្យ ។ អង្គការនេះទទួលការឧបត្ថម្ភ និងជំនួយដោយសមាជិតាមសម្លេងភាគច្រើន២/៣នៃសមាជិកវត្តមានក្នុងសភានីមួយៗ ។

ព្រឹទ្ធសភាធ្វើសកម្មភាពជាអង្គការត្រួតពិនិត្យសកម្មភាពរបស់រដ្ឋាភិបាល ។

I.សមាសភាព

ព្រឹទ្ធសភាមានសមាជិក៧៦នាក់ ដែលជ្រើសរើសដោយការបោះឆ្នោត ដោយផ្តាល់តំណាងរចនាសម្ព័ន្ធសហព័ន្ធរបស់ប្រទេស:

-១២នាក់ក្នុងរដ្ឋមួយ

-៦៤នាក់តំណាងដែនដីពីរ ។

សមាជិករដ្ឋាភិបាលជាសមាជិកព្រឹទ្ធសភា(ឬតំណាង) ។

II.របបបោះឆ្នោត

ទូទាំងប្រទេសមានផមណ្ឌលពហុនាម :

-៦មណ្ឌល(ត្រូវនឹង៦រដ្ឋ)ដែលមាន១២អាសនៈក្នុងមួយមណ្ឌល

-២មណ្ឌល (ត្រូវនឹងដែនដីពីរ)ដែលមាន២អាសនៈក្នុងមួយមណ្ឌល ។

ប្រព័ន្ធបោះឆ្នោត : ប្រព័ន្ធសមាមាត្រ ឆ្នោតតែមួយអាចផ្ទេរបាន (vote unique transférable) ដែលអ្នកបោះឆ្នោតម្នាក់ៗអាចចុះលេខ តាមលំដាប់នៃការពេញចិត្តរបស់ខ្លួនលើបេក្ខជនដែលមានឈ្មោះក្នុងបញ្ជី ។

អាណត្តិ: ៦ឆ្នាំផ្លាស់ប្តូរពាក់កណ្តាលរៀងរាល់៣ឆ្នាំ លើកលែងតែសមាជិកជាតំណាងដែនដី៤នាក់ដែលត្រូវជ្រើសរើសសំរាប់រយៈពេល៣ឆ្នាំ ។

ការផ្លាស់ប្តូរចុងក្រោយ : ៩តុលា២០០៤

លក្ខខណ្ឌអាយុ : ១៨ឆ្នាំ ។

III.សម័យប្រជុំ

ព្រឹទ្ធសភាកោះប្រជុំតាមសំណើរបស់រដ្ឋាភិបាល ឬតាមសំណើរបស់សមាជិកព្រឹទ្ធសភា

លើសពីពាក់កណ្តាល ។

IV-ឧទាក់ឧទមាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-ការផ្តួចផ្តើមតំនិតធ្វើច្បាប់

សមាជិកព្រឹទ្ធសភាមានសិទ្ធិផ្តួចផ្តើមតំនិតធ្វើច្បាប់ លើកលែងតែក្នុងវិស័យថវិកា និងសារពើពន្ធ ។

២-សិទ្ធិវិសោធនកម្ម

សមាជិកព្រឹទ្ធសភាមានសិទ្ធិផ្តួចផ្តើមតំនិតធ្វើច្បាប់លើកលែងតែក្នុងវិស័យថវិកា និងសារពើពន្ធ ។

ម្យ៉ាងទៀតវិសោធនកម្មមិនអាចបន្ថែមបន្ទុកទៅលើពលរដ្ឋ ។ ប៉ុន្តែព្រឹទ្ធសភាអាចស្នើទៅរដ្ឋសភាសុំឱ្យកែប្រែមាត្រាដែលចែងពីវិស័យនោះ ។ រដ្ឋសភា បើយល់ថាជាការត្រឹមត្រូវអាចទទួលយកសំណើនោះទៅពិនិត្យហើយអាចយល់ព្រមតាមសំណើ ឬមិនយល់ព្រម ។

៣-នីតិវិធី

សេចក្តីព្រាងច្បាប់ត្រូវពិនិត្យពាលើក ពេលបញ្ជូនមកព្រឹទ្ធសភា ។ ការពិភាក្សាជាទូទៅធ្វើឡើងមុនការពិនិត្យមួយមាត្រាម្តង១ ។

សេចក្តីព្រាងច្បាប់ត្រូវតែបានទទួលការពិនិត្យជាមុនដោយគណៈកម្មការជំនាញអចិន្ត្រៃ-យ៍ណាមួយតាមសមត្ថកិច្ច ។ ម្យ៉ាងទៀតគណៈកម្មការអចិន្ត្រៃយ៍ណាមួយត្រូវបានទទួលបន្ទុកជាពិសេសឱ្យត្រួតពិនិត្យមើលថាសេចក្តីព្រាងច្បាប់នោះមិនមានប៉ះពាល់ដល់សេរីភាពបុត្តល និងសិទ្ធិពលរដ្ឋទេ ។

ពេលរដ្ឋសភាអនុម័តអត្ថបទច្បាប់មួយហើយព្រឹទ្ធសភាបដិសេធ ឬ ខ្ជីខ្ជាក្នុងការអនុម័ត ឬ អនុម័តដោយមានវិសោធនកម្មដែលមិនទទួលយកដោយរដ្ឋសភា និងបើសិនក្រោយមកពាខែ រដ្ឋសភាអនុម័តជាថ្មីនូវអត្ថបទនោះដោយមាន ឬត្មានវិសោធនកម្មដែលមិនបានស្នើ ឬអនុម័តដោយព្រឹទ្ធសភានិងដោយព្រឹទ្ធសភាបដិសេធ ឬ ខ្ជីខ្ជាក្នុងការអនុម័ត ឬអនុម័តដោយមានវិសោ-

ធនកម្មដែលមិនទទួលយកដោយរដ្ឋសភា អគ្គទេសាភិបាលអាចរំលាយសភាទាំងពីរ លើកលែងតែក្នុងរយៈពេល៦ខែមុនការផ្លាស់ប្តូរថ្នាក់នៃរដ្ឋសភា។

បើក្រោយការរំលាយវិបត្តិនៅតែមាន អគ្គទេសាភិបាលអាចស្នើឱ្យមានការប្រជុំគណៈកម្មការដែលមានសមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភា។

បើសិនអត្ថបទកែប្រែ ឬមិនកែប្រែ ទទួលបានការគាំទ្រពីសម្លេងភាគច្រើនដាច់ខាតនៃសមាជិកសភាមួយ១ អត្ថបទនោះអាចដាក់ជូនអគ្គទេសាភិបាលដើម្បីប្រកាសឱ្យប្រើ។

៤-ការធ្វើច្បាប់ដោយប្រតិភូកម្ម (législation déléguée)

ច្បាប់ជាច្រើនទឹងមានចែងលំអិតដោយការធ្វើប្រតិភូកម្ម ។ អំណាចនេះផ្តល់ដោយសភាទៅឱ្យអគ្គទេសាភិបាលឬរដ្ឋមន្ត្រី ឬ ទៅអ្នកទទួលខុសត្រូវនៃអង្គការផ្ទាល់ការ។

អត្ថបទទាំងនេះមានកម្លាំងជាច្បាប់ហើយត្រូវដាក់ជូនព្រឹទ្ធសភា (និងរដ្ឋសភា)ដែលអាចបដិសេធបាន (អត្ថបទត្រូវតែបានពិនិត្យជាមុនដោយគណៈកម្មការមួយរបស់ព្រឹទ្ធសភា)។

ខ-អំណាចត្រួតពិនិត្យ

១-គណៈកម្មការអង្កេត

ព្រឹទ្ធសភាអាចបង្កើតគណៈកម្មការអង្កេតលើសកម្មភាពជាក់លាក់របស់រដ្ឋាភិបាល។

គណៈកម្មការនេះត្រូវរាយការណ៍ជូនព្រឹទ្ធសភាក្នុងរយៈពេលកំណត់ ។

គណៈកម្មការចប់ការងារពេលជូនរបាយការណ៍ទៅព្រឹទ្ធសភា ។

២-សំណួរ

នៅរាល់ពេលប្រជុំ រយៈពេលមួយត្រូវត្រៀមបំរុងជូនសមាជិកព្រឹទ្ធសភាដាក់សំណួរ ។ រដ្ឋមន្ត្រីដែលប្រចាំនៅព្រឹទ្ធសភា(និងតំណាងរដ្ឋមន្ត្រីដែលប្រចាំនៅរដ្ឋសភា) អាចត្រូវសួរលើគ្រប់ទិដ្ឋភាពនៃសកម្មភាពរបស់ក្រសួង។

សំណួរអាចដាក់បាននៅពេលដទៃទៀតផ្ទុចជានៅពេលពិភាក្សាទូទៅ ។

៣-ការត្រួតពិនិត្យថវិកា

គណៈកម្មការដែលបានពិនិត្យសេចក្ដីព្រាងថវិកាប្រចាំឆ្នាំនៃបណ្ណាក្រសួង និងទីភ្នាក់ងារត្រូវពិនិត្យមើលលើភាពត្រឹមត្រូវនៃការចំណាយ ។ គណៈកម្មការក៏ពិនិត្យនូវរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួង និងទីភ្នាក់ងារដែរ ។

៤-ការត្រួតពិនិត្យនយោបាយ

គណៈកម្មការអចិន្ត្រៃយ៍នានាមានតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យ និងវាយតម្លៃនយោបាយរបស់រដ្ឋាភិបាល ។ គណៈកម្មការអាចធ្វើសវនកម្ម និង សន្ទិដ្ឋានការងារត្រួតពិនិត្យដោយរបាយការណ៍ជូនព្រឹទ្ធសភាដែលមានអនុសាសន៍ផ្សេងៗ ។

៧-មញ្ញត្តិដោយឡែក

ក-ការសើរើរដ្ឋធម្មនុញ្ញ

ការសើរើរដ្ឋធម្មនុញ្ញអាចស្នើឡើងដោយសមាជិកព្រឹទ្ធសភាឬសមាជិករដ្ឋសភា ។ សេចក្ដីស្នើសើរើរដ្ឋធម្មនុញ្ញ ត្រូវអនុម័តតាមសម្លេងភាគច្រើនដាច់ខាតនៃសភានីមួយៗ ។ ក្នុងរយៈពេលពី២ទៅ៦ខែក្រោយពីការអនុម័តរបស់សភាទាំងពីរ សេចក្ដីស្នើនោះត្រូវដាក់ជូនក្នុងរដ្ឋ ឬដែនដីនីមួយៗសុំការអនុម័តពីអ្នកបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា ។

ក្នុងករណីមិនមានការព្រមព្រៀងគ្នារវាងសភាទាំងពីរ (ឬសភាណាមួយអនុម័តសេចក្ដីស្នើដែលសភាមួយទៀតបដិសេធ ឬអនុម័តដោយមានវិសោធនកម្មដែលមិនបានទទួលការយល់ព្រមពីសភាមួយទៀត ហើយក្នុងរយៈពេល ៣ខែក្រោយ ក្នុងសម័យប្រជុំតែមួយ ឬសម័យប្រជុំបន្ទាប់ អនុម័តសេចក្ដីស្នើ ឬកែប្រែឬមិនកែប្រែ ដែលសភាមួយទៀតបដិសេធ ឬអនុម័តដោយមានវិសោធនកម្មដែលមិនទទួលយកដោយសភាមួយទៀត) អគ្គទេសាភិបាលអាចដាក់សេចក្ដីស្នើសើរើដោយមាន ឬគ្មានវិសោធនកម្មដែលអនុម័តដោយសភាទាំងពីរសុំការអនុម័តក្នុងរដ្ឋ ឬដែនដីនីមួយៗពីអ្នកបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា ។

ក្នុងករណីទាំងពីរ សេចក្ដីស្នើត្រូវអនុម័តតាមសម្លេងភាគច្រើនដាច់ខាតនៃអ្នកបោះឆ្នោតនិងតាមសម្លេងភាគច្រើនដាច់ខាតនៃរដ្ឋ ។

ខ-ចំពោះរដ្ឋសហព័ន្ធ (vis-a-vis des Etats fédérés)

១-ការអនុញ្ញាតរបស់សភាតម្រូវ:

-ក្នុងករណីខ្លះដែលទាក់ទងនឹងថវិកានៃរដ្ឋសហព័ន្ធ

-ដើម្បីលើក និងរក្សាកំឡាំងទ័ព និងនាវាចរណ៍

២-ការចូល ឬបង្កើតដែនដីថ្មី ចាត់ចែងដោយសភាដែលមានសមត្ថកិច្ច ដើម្បីកែប្រែព្រំប្រទល់រដ្ឋសហព័ន្ធ។

គ-ក្នុងវិស័យតុលាការ

ចៅក្រមតុលាការអាចត្រូវបញ្ឈប់ពីការងារដោយអគ្គទេសាភិបាល តាមការសម្រេចចិត្តរបស់សភាទាំងពីរ ចំពោះសីលធម៌ និងអសមត្ថភាព។

អូទ្រីស **ក្រុមប្រឹក្សាសហព័ន្ធ**

AUTRICHE **ប៊ុនដេសរ៉ាត** (BUNDESRAT)

LE CONSEIL FEDERAL

I.សមាសភាព

ក្រុមប្រឹក្សាសហព័ន្ធអូទ្រីសមានសមាជិក៦២រូបតំណាងដែនដី(ខេត្ត)ចំនួន៩ ជ្រើសរើសដោយការបោះឆ្នោតមិនផ្ទាល (scrutin indirect) ។ ចំនួនតំណាងដែនដីនីមួយៗសមាមាត្រនឹងចំនួនប្រជាជននៃដែនដីទាំងនោះ ។ ដែនដីដែលមានប្រជាជនច្រើនជាងគេមានតំណាង១២រូប ។ សមាជិកព្រឹទ្ធសភាមួយរូបមានអ្នកបំរុងមួយរូប ។

តំណែងប្រធានក្រុមប្រឹក្សាត្រូវប្តូរ៦ខែម្តង តាមលំដាប់អក្ខរក្រមនៃដែនដី ។ ជាប្រធានក្រុមប្រឹក្សា តំណាងទី១នៃដែនដី ទទួលបន្ទុកធ្វើប្រធាន ។

II.របបឆោះឆ្នោត

សមាជិកក្រុមប្រឹក្សា និងអ្នកតំណាងត្រូវជ្រើសរើសដោយក្រុមប្រឹក្សាដែនដី (landtage) តាមរូបមន្តសមាមាត្រ ។

សមាជិកក្រុមប្រឹក្សាសហព័ន្ធមិនមែនជាសមាជិកសភាដែនដី (parlement du land) ដែលខ្លួនជាតំណាងទេ ។ អាណត្តិមានរយៈពេលស្មើនឹងនីតិកាល នៃដែនដីនីមួយៗ (៥ទៅ៦ឆ្នាំ ទៅតាមខេត្តនីមួយៗ) ។

III.សម័យប្រជុំ

ក-សម័យប្រជុំអចិន្ត្រៃយ៍

ក្នុងការអនុវត្ត ក្រុមប្រឹក្សាប្រជុំពីខែតុលា ដល់ខែកក្កដា (octobre-juillet) ។

ខ-ការកោះប្រជុំ

ប្រធានជាអ្នកកោះប្រជុំក្រុមប្រឹក្សា ។ ប្រធានត្រូវកោះប្រជុំដោយគ្មានកំណត់ពេល កាលណាសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួនយ៉ាងតិច ឬរដ្ឋាភិបាលសហព័ន្ធតម្រូវឱ្យកោះប្រជុំ ។

របៀបវារៈត្រូវកំណត់ដោយសន្ទិសីទនៃប្រធាន ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអង្គការនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-ការផ្តួចផ្តើមគំនិតធ្វើច្បាប់

អ្នកមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ គឺក្រុមប្រឹក្សាសហព័ន្ធ សមាជិកក្រុមប្រឹក្សាចំនួនមួយភាគបី សមាជិករដ្ឋសភា រដ្ឋាភិបាលសហព័ន្ធ អ្នកបោះឆ្នោត(១សែន)នាក់យ៉ាងតិច ឬមួយភាគប្រាំមួយនៃអ្នកបោះឆ្នោតពាក់ដែនដីយ៉ាងតិច ។

ភាគច្រើននៃច្បាប់ផ្តួចផ្តើមឡើងដោយរដ្ឋាភិបាល ។

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវបញ្ជូនទៅក្រុមប្រឹក្សា ។

២-សិទ្ធិវិសោធនកម្ម

ក្រុមប្រឹក្សាពុំមានសិទ្ធិធ្វើវិសោធនកម្មទេ ។

៣-នីតិវិធីធ្វើច្បាប់

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវតែបញ្ជូនជាលើកទី១មកក្រុមប្រឹក្សាជាតិ ។ អត្ថបទដែលក្រុមប្រឹក្សាជាតិបានអនុម័តត្រូវបញ្ជូនទៅក្រុមប្រឹក្សាសហព័ន្ធដោយមិនកំណត់ពេល ។ សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់អាចប្រកាសឱ្យប្រើបាន លុះត្រាតែក្រុមប្រឹក្សាសហព័ន្ធមិនជំទាស់ ។ ការជំទាស់នេះត្រូវបញ្ជូនជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាជាតិដោយប្រធានក្រុមប្រឹក្សាសហព័ន្ធ ក្នុងរយៈ៨សប្តាហ៍បន្ទាប់ពីក្រុមប្រឹក្សាសហព័ន្ធបានទទួលអត្ថបទនោះ ។

ក្រុមប្រឹក្សាសហព័ន្ធមិនត្រូវបានឱ្យធ្វើអន្តរាគមន៍ចំពោះអត្ថបទទាក់ទងនឹងហិរញ្ញវត្ថុ និងថវិកាឡើយ ។

បើក្រុមប្រឹក្សាជាតិអនុម័តឡើងវិញនូវសេចក្តីសម្រេចមុន ដោយមានវត្តមានសមាជិកពាក់កណ្តាលយ៉ាងតិច សេចក្តីសម្រេចនោះត្រូវយកទៅប្រកាសឱ្យប្រើ និងបោះពុម្ពផ្សាយ ។

បើក្រុមប្រឹក្សាសហព័ន្ធមិនជំទាស់ ឬមិនមានការជំទាស់ណា ក្នុងរយៈពេលដែលបាន

ក៉ណត់ សេចក្តីព្រាងច្បាប់ត្រូវប្រកាសឱ្យប្រើ និងបោះពុម្ពផ្សាយ ។

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវតែបានពិនិត្យដោយគណៈកម្មការណាមួយ មុនយកទៅពិនិត្យក្នុងប្រជុំពេញអង្ត ។ សារសំខាន់នៃការងាររបស់សភាស្ថិតនៅលើការងាររបស់គណៈកម្មការ ដែលសមាសភាពឆ្លុះបញ្ចាំងទៅនឹងសមាសភាពសភាទាំងមូល ។ ការពិភាក្សាក្នុងសភាត្រូវធ្វើលើសពី២៤ម៉ោងក្រោយពីការចែកបាយការណ៍របស់គណៈកម្មការ លើកលែងតែការប្រញ្ចាប់ ។

៩-អំណាចត្រួតពិនិត្យ

១-អំណាចទូទៅ

ក្រុមប្រឹក្សាសហព័ន្ធក៏ដូចជាក្រុមប្រឹក្សាជាតិមានសិទ្ធិត្រួតពិនិត្យការងាររបស់រដ្ឋាភិបាលសហព័ន្ធ មានសិទ្ធិសួរសមាជិករដ្ឋាភិបាលអំពីការងារ មានសិទ្ធិស្នើសុំព័តិមាន និងបង្ហាញនូវបំណងប្រាថ្នាលើការអនុវត្តអំណាចសហព័ន្ធ ។

២-អំណាចត្រួតពិនិត្យសហគ្រាស

ក្រុមប្រឹក្សាសហព័ន្ធ ឬក្រុមប្រឹក្សាជាតិមានសិទ្ធិត្រួតពិនិត្យរដ្ឋាភិបាលសហព័ន្ធ និងសមាជិកខ្លួនអំពីការងាររបស់សហគ្រាសដែលសហភាពមានចំណែកយ៉ាងតិច៥០ភាគរយនៃដើមទុន ហើយដែលស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការគណនី (Cour des comptes) ។

៣-សំណូរ

ក-សមាជិកក្រុមប្រឹក្សាសហព័ន្ធ មានសិទ្ធិដាក់សំណូរជាលាយលក្ខណ៍អក្សរដល់សមាជិករដ្ឋាភិបាលដែលត្រូវផ្តល់ចម្លើយជាលាយលក្ខណ៍អក្សរឬផ្ទាល់មាត់ ក្នុងពេល២ខែ លើកលែងតែមានការបញ្ជាក់ផ្សេង ។ ការជជែកគ្នាខ្លី១អាចមានក្នុងករណីចម្លើយខ្លះ ។

ខ-ជាគោលការណ៍ ពេលប្រជុំនីមួយ១របស់ក្រុមប្រឹក្សាសហព័ន្ធ (ក៏ដូចជាក្រុមប្រឹក្សាជាតិ) ចាប់ផ្តើមដោយការដាក់សំណូរ ។ ក្រោយពីចម្លើយ ម្ចាស់សំណូរ ក៏ដូចជាសមាជិកឯទៀតនៃក្រុមប្រឹក្សាមានសិទ្ធិសួរបន្ថែមបាន ។

៤-ក្រុមប្រឹក្សាសហព័ន្ធនិងគណៈកម្មការអាចស្នើឱ្យមានវត្តមាននិងអញ្ជើញសមាជិករដ្ឋាភិបាលសហព័ន្ធក្នុងការងារស៊ើបអង្កេត។

៥-ការសម្រេចចិត្តអាចត្រូវក្រុមប្រឹក្សាជាតិប្រើ ដើម្បីបង្ហាញនូវអនុសាសន៍សំរាប់ការអនុវត្តរបស់អំណាចនីតិប្រតិបត្តិ។

៦-បញ្ហាអ៊ីរ៉ុប

ក-ការតែងតាំង

រដ្ឋាភិបាលសហព័ន្ធផ្តល់ព័ត៌មានដល់ក្រុមប្រឹក្សាសហព័ន្ធ នូវសំណើដែលទទួលបានអំពីការតែងតាំងសមាជិកគណៈកម្មការ សមាជិកតុលាការយុត្តិធម៌ សមាជិកតុលាការជាន់ដំបូង សមាជិកតុលាការគណនី សមាជិកក្រុមប្រឹក្សារដ្ឋបាលនៃធនាគារអ៊ីរ៉ុបខាងវិនិយោគ សមាជិកគណៈកម្មការសេដ្ឋកិច្ចនិងសង្គម និងគណៈកម្មាធិការតំបន់។

ខ-យោបល់លើតំណែងកិច្ចការអ៊ីរ៉ុប

រដ្ឋាភិបាលសហព័ន្ធត្រូវជូនដំណឹងដោយភ្លាមកំណត់ពេលជូនក្រុមប្រឹក្សាសហព័ន្ធ ក៏ដូចជាក្រុមប្រឹក្សាជាតិនូវតំណែងកិច្ចការអ៊ីរ៉ុប និងស្នើសុំឱ្យក្រុមប្រឹក្សាបង្ហាញនូវជំហរ។

ក្នុងករណីដែលក្រុមប្រឹក្សាសហព័ន្ធស្នើទៅរដ្ឋាភិបាលសហព័ន្ធ នូវយោបល់ទាក់ទងនឹងតំណែងកិច្ចការអ៊ីរ៉ុប ដែលចាំបាច់ឱ្យមានច្បាប់សហព័ន្ធ ដែលតម្រូវឱ្យមានការយល់ព្រមពីក្រុមប្រឹក្សាសហព័ន្ធ យោបល់នោះនាំឱ្យរដ្ឋាភិបាលសហព័ន្ធចរចារ និងអនុម័តក្នុងសហគមន៍អ៊ីរ៉ុប។

 គ-ក្នុងវិស័យអន្តរជាតិ

កិច្ចព្រមព្រៀងអន្តរជាតិនានា ដែលជាប់ទាក់ទងនឹងសមត្ថកិច្ចស្វយ័តរបស់ដែនដីខេត្ត (länder) តម្រូវឱ្យមានការយល់ព្រមពីក្រុមប្រឹក្សាសហព័ន្ធ។

ឃ-សិទ្ធិចូលរួមរបស់រដ្ឋាភិបាល

សមាជិករដ្ឋាភិបាលសហព័ន្ធ ត្រូវបានការអនុញ្ញាតឱ្យចូលរួមក្នុងគ្រប់ការពិភាក្សារបស់ក្រុមប្រឹក្សា និងរបស់គណៈកម្មការ។

V-បទប្បញ្ញត្តិដោយឡែក

ក-សិទ្ធិក្នុងវិស័យធម្មនុញ្ញ

ការណាច្បាប់ធម្មនុញ្ញឬបញ្ញត្តិធម្មនុញ្ញដែលមានក្នុងច្បាប់ធម្មតាបន្ថយសមត្ថកិច្ចនីតិប្ញ្ញត្តិ ឬប្រតិបត្តិនៃដែនដីច្បាប់ ឬបញ្ញត្តិនោះត្រូវតែមានការយល់ព្រមពីក្រុមប្រឹក្សាសហព័ន្ធ ដោយមានកូរ៉ុមយ៉ាងតិចពាក់កណ្តាលនៃចំនួនសមាជិក និងតាមសម្លេងភាគច្រើន២/៣នៃសម្លេងដែលបានបោះ។ ដូចគ្នានេះដែរចំពោះការកែប្រែរដ្ឋធម្មនុញ្ញ ដែលប៉ះពាល់ដល់ក្រុមប្រឹក្សាសហព័ន្ធ។ សមាជិកក្រុមប្រឹក្សាចំនួនមួយភាគបី អាចតម្រូវឱ្យដាក់ធ្វើប្រជាមតិនូវការសើរើដោយផ្នែកនៃរដ្ឋធម្មនុញ្ញ។

ខ-សិទ្ធិរបស់ដែនដី

១-ប្រមុខរដ្ឋាភិបាលដែនដីនានាមានសិទ្ធិចូលរួមក្នុងការពិភាក្សារបស់ក្រុមប្រឹក្សាសហ-ព័ន្ធ ជាពិសេសនៅគ្រប់ពេលនៃការពិភាក្សាអំពីការងារទាក់ទងនឹងដែនដី។

២-ការយល់ព្រមរបស់ក្រុមប្រឹក្សាសហព័ន្ធជាការចាំបាច់ ចំពោះការរំលាយសភាដែនដី (Landtag:Parlement du Land) ស្នើដោយប្រធានាធិបតីសហព័ន្ធ តាមសំណើរបស់រដ្ឋាភិ-បាលសហព័ន្ធ ។ ការសម្រេចធ្វើឡើងដោយមានវត្តមានសមាជិកចំនួនពាក់កណ្តាល និងតាមសម្លេងភាគច្រើន២/៣ ។ តំណាងដែនដីដែលជាកម្មវត្ថុនៃការរំលាយគ្មានសិទ្ធិចូលរួមក្នុងការអនុម័តទេ។

គ-សមត្ថកិច្ចរបស់សភាសហព័ន្ធ(ការប្រជុំរួមនៃក្រុមប្រឹក្សាជាតិ និងក្រុមប្រឹក្សាសហ -ព័ន្ធ)

១-សច្ចាប្រណិធានៃប្រធានាធិបតីសហព័ន្ធធ្វើឡើងនៅមុខសភាសហព័ន្ធពេលចូលកាន់មុខតំណែង។

២-ការទទួលខុសត្រូវរបស់ប្រធានាធិបតីសហព័ន្ធនៅមុខសភាសហព័ន្ធ សម្តែងឡើងដោយសភាសហព័ន្ធដាក់ការចោទប្រកាន់ទៅតុលាការធម្មនុញ្ញ (Cour constitutionnelle) ពីបទរំលោភរដ្ឋធម្មនុញ្ញ។

តាមការសម្រេចរបស់ក្រុមប្រឹក្សាជាតិ ឬក្រុមប្រឹក្សាសហព័ន្ធ អធិការបតីសហព័ន្ធត្រូវកោះប្រជុំសភាសហព័ន្ធដើម្បីពិនិត្យអំពីការទទួលខុសត្រូវនេះ ។ ការសម្រេចចោទប្រកាន់ត្រូវមានសមាជិកច្រើនជាងពាក់កណ្តាលនៃក្រុមប្រឹក្សានីមួយៗចូលរួម និងតាមសម្លេងភាគច្រើន ២/៣នៃសម្លេងដែលបានបោះ ។

៣-ប្រធានាធិបតីអាចជាកម្មវត្ថុចោទប្រកាន់ដោយអាជ្ញាធរសាធារណៈ លុះត្រាតែមានការយល់ព្រមពីសភាសហព័ន្ធ ។

សំណើសុំចោទប្រកាន់ប្រធានាធិបតីត្រូវអាជ្ញាធរមានសមត្ថកិច្ចបញ្ជូនទៅសុំការសម្រេចពីក្រុមប្រឹក្សាសហព័ន្ធ បើសភាសហព័ន្ធយល់ព្រមឱ្យចោទប្រកាន់ ។ បើក្រុមប្រឹក្សាសហព័ន្ធសម្រេចឱ្យចោទប្រកាន់ អធិកាបតីសហព័ន្ធកោះប្រជុំសភាសហព័ន្ធ ។

៤-ការញ្ជូរតំណែងប្រធានាធិបតីសហព័ន្ធ

ប្រធានាធិបតីអាចត្រូវដកហូតពីមុខតំណែង ដោយសេចក្តីសម្រេចរបស់ប្រជាពលរដ្ឋ (le plébiscite) ដែលរៀបចំឡើងតាមសំណើរបស់សភាសហព័ន្ធ ដែលមានសមាជិកយ៉ាងតិចពាក់កណ្តាលចូលរួមនិងតាមសម្លេងភាគច្រើន២/៣ ។

៥-ការសម្រេចចិត្តអំពីការប្រកាសសង្គ្រាម

ឃ-តុលាការធម្មនុញ្ញ

១-តុលាការធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់សហព័ន្ធតាមសំណើរបស់សមាជិកក្រុមប្រឹក្សាសហព័ន្ធចំនួនមួយភាគបី ឬសមាជិកក្រុមប្រឹក្សាជាតិចំនួនមួយភាគបី ឬពីរដ្ឋាភិបាលសហព័ន្ធ ។

២-សមាជិកពានាក់ (ក្នុង១២នាក់) និងសមាជិកបំរុងម្នាក់ (ក្នុង៦នាក់) នៃតុលាការធម្មនុញ្ញត្រូវតែងតាំងដោយប្រធានាធិបតីសហព័ន្ធតាមសំណើរបស់ក្រុមប្រឹក្សាសហព័ន្ធ ។

បាហាម៉ាស	**ព្រឹទ្ធសភា**
BAHAMAS	LE SENAT

I.សមាសភាព

ព្រឹទ្ធសភាបាហាម៉ាសមានសមាជិកចំនួន១៦នាក់ដែលតែងតាំងដោយអគ្គទេសាភិបាល ។

សមាសភាពខាងនយោបាយរបស់ព្រឹទ្ធសភា ឆ្លើយតបទៅនឹងសមាសភាពនយោបាយរបស់រដ្ឋសភា ក្នុងពេលដូចគ្នា ។

សមាជិកព្រឹទ្ធសភា៩នាក់ស្នើដោយរដ្ឋមន្ត្រីទី១ ៤នាក់ស្នើដោយប្រមុខគណបក្សប្រឆាំង ៣នាក់ស្នើដោយរដ្ឋមន្ត្រីទី១ដោយមានការពិគ្រោះយោបល់ជាមួយប្រមុខគណបក្សប្រឆាំង ។

II.រយៈពេលកាន់តំណែង

អាណត្តិ :៥ឆ្នាំ

ការរៀបចំចុងក្រោយ : ២ ឧសភា ២០០២

លក្ខខណ្ឌតែងតាំង: អាយុ៣០ឆ្នាំ ស្គាល់នៅ១ឆ្នាំយ៉ាងតិចមុនដាក់ស្នើបេក្ខភាព ។

មិនអាចតែងតាំង: ក្ស័យធន(មិនទាន់មានទីតាំងសម្ងាត់ឡើងវិញ) សសៃប្រសាទ ជាប់ភាពពិតិច្ចចំពោះរដ្ឋផ្សេង កំហុសក្នុងការបោះឆ្នោត ឧក្រិដ្ឋកម្ម ទោសប្រហារជីវិត ។

វិសមិតភាពៈចៅក្រម អ្នកវាជការ (លើសពីពីរខែ) ក្នុងទ័ពរបស់ព្រះមហាក្សត្រ សមាជិកលេខាធិការដ្ឋានផ្ទាល់របស់រដ្ឋាភិបាល និយោជិតក្រសួង... ។

ប្រធាននិងអនុប្រធានសភានីមួយ១មិនអាចជារដ្ឋមន្ត្រីឬជារដ្ឋលេខាធិការទេ ។

III.សម័យប្រជុំ

ក-អគ្គទេសាភិបាលសម្រេចលើកាលបរិច្ឆេទនៃការបើក និងបិទសម័យប្រជុំ ។

ខ-ពេលប្រជុំត្រូវលើកបើសិនពុំមានកូរ៉ុម៦(គិតទាំងប្រធានអង្គប្រជុំផង) ។

IV.ធំនាក់ធំនឹងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

សភាបាហាម៉ាសមានមហាក្សត្រីយានីអង់ហ្គេស ព្រឹទ្ធសភា និងរដ្ឋសភា ។

ក-អំណាចនីតិប្បញ្ញត្តិ

ព្រឹទ្ធសភាមានអំណាចតិចតួចក្នុងការងារនីតិប្បញ្ញត្តិ ។

១-ឥទ្ធិពលផ្តួចផ្តើមធ្វើច្បាប់

សមាជិកសភាមានសិទ្ធិផ្តួចផ្តើមឥទ្ធិពលធ្វើច្បាប់ លើកលែងតែច្បាប់ហិរញ្ញវត្ថុ ។

សមាជិកសភាមានសិទ្ធិដាក់ញត្តិស្នើសុំឱ្យពិនិត្យសេចក្តីស្នើច្បាប់ទាំងនោះ ។

លើកលែងតែមានការយល់ព្រមពីរដ្ឋាភិបាល សមាជិកសភាមិនអាចស្នើច្បាប់ដែលបន្ថែមបន្ទុកសាធារណៈ ឬបន្ថយធនធានសាធារណៈ ឬដែលទាក់ទងនឹងបំណុលសាធារណៈ ។

២-សិទ្ធិវិសោធនកម្ម

ព្រឹទ្ធសភាជាហាម៉ាសមានសិទ្ធិធ្វើវិសោធនកម្ម ។ លើកលែងតែមានការយល់ព្រមពីរដ្ឋាភិបាល សមាជិកព្រឹទ្ធសភាមិនអាចធ្វើវិសោធនកម្មដែលបន្ថែមបន្ទុកសាធារណៈ ឬបន្ថយធនធានសាធារណៈ ឬដែលទាក់ទងនឹងបំណុលសាធារណៈ ។

៣-នីតិវិធីធ្វើច្បាប់

សេចក្តីព្រាងច្បាប់អាចបញ្ជូនមកសភាណាមួយក៏បាន លើកលែងតែច្បាប់ស្តីពីហិរញ្ញវត្ថុដែលត្រូវតែបញ្ជូនមករដ្ឋសភា ។ សេចក្តីព្រាងច្បាប់ត្រូវតែពិនិត្យដោយសភាទាំងពីរ ។

ប្រធានអង្គប្រជុំអាចចូលរួមក្នុងការអនុម័តពេលដែលសម្លេងចែកជាពីរស្មើ ។

១-នីតិវិធីធម្មតា

បើអត្ថបទណាមួយត្រូវបានរដ្ឋសភាអនុម័តនៅសម័យប្រជុំពីរបន្តបន្ទាប់ (ទោះមាន ឬគ្មានការកំណត់យៅក្នុងរយៈពេលចន្លោះនោះ) និងបើត្រូវបានព្រឹទ្ធសភាបដិសេធនៅសម័យប្រជុំនីមួយ១ អត្ថបទនោះត្រូវបញ្ជូនទៅអគ្គទេសាភិបាល ដើម្បីប្រកាសឱ្យប្រើ ទោះជាអត្ថបទនោះត្រូវបញ្ជូនទៅព្រឹទ្ធសភាយ៉ាងតិច១ខែ មុនចប់សម័យប្រជុំក៏ដោយ ។

ដើម្បីអនុវត្តបញ្ញត្តិនោះបានរដ្ឋសភាត្រូវមានរយៈពេល៩ខែ ពីពេលពិនិត្យមួយទៅពេលពិនិត្យបន្ទាប់ ។

ច្បាប់ត្រូវបានប្រកាសឱ្យប្រើដោយអគ្គទេសាភិបាលដែលអនុវត្តអំណាចនីតិប្រតិបត្តិ ក្នុងនាមព្រះមហាក្សត្រីយានីអង់គ្លេស ។

២-បញ្ញត្តិដោយឡែកក្នុងវិស័យថវិកា

បើសិនច្បាប់ថវិកាមិនបានព្រឹទ្ធសភាអនុម័តក្នុងខែបន្ទាប់ពីរដ្ឋសភាបញ្ជូនទៅឱ្យ ទោះជាអត្ថបទនោះត្រូវបញ្ជូនទៅយ៉ាងតិច១ខែមុនចប់សម័យប្រជុំក៏ដោយ ច្បាប់នោះត្រូវចាត់ទុកថាបានអនុម័ត និងត្រូវបញ្ជូនទៅអគ្គទេសាភិបាលដើម្បីប្រកាសឱ្យប្រើ បើសិនណារដ្ឋសភាមិនមានការសម្រេចផ្សេងទេ ។

ខ-អំណាចត្រួតពិនិត្យ

សម្ភារភាពរបស់ខុទ្ទកាល័យ (រដ្ឋមន្ត្រីទី១និងរដ្ឋមន្ត្រីផ្នាក់ទទួលខុសត្រូវចំពោះសភា ។

ត្រូវតែងតាំងជារដ្ឋមន្ត្រីទី១ ប្រមុខគណបក្សដែលមានសម្លេងភាគច្រើននៅរដ្ឋសភា និងត្រូវបានរដ្ឋសភាប្រគល់ការទុកចិត្តនៅសម័យប្រជុំទី១ ក្រោយការតែងតាំង ។

ค-ការរំលាយ និងការពន្យារ

១-ការរំលាយ

អគ្គទេសាភិបាលមានសិទ្ធិរំលាយសភាក្នុងករណីវិស្សមកាលនៃតំណែងរដ្ឋមន្ត្រីទី១ និងបើយល់ថាពុំមានតំណាងរាស្ត្រណាម្នាក់ទទួលបានការគាំទ្រពីភាគច្រើននៃសមាជិករដ្ឋសភា ។

២-ការពន្យារ

អគ្គទេសាភិបាលអាចពន្យារអាណត្តិរបស់សភាបានត្រប់ពេល ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីទី១ ។ ក្នុងពេលសង្គ្រាមអាចពន្យារ១២ខែ (១ឆ្នាំ) ។

V-បទឧបញ្ញត្តិដោយឡែក(ការកែតម្រូវធម្មនុញ្ញ)

ក្នុងការកែទម្រង់រដ្ឋធម្មនុញ្ញ ការសម្រេចចុងក្រោយត្រូវយកតាមសម្លេងភាគច្រើន២/៣ ឬ៧៥នៃសមាជិកសភានីមួយ១ អាស្រ័យតាមបញ្ញត្តិដែលជាកម្មវត្ថុនៃការសើរើ ដូចមានរៀបរាប់ក្នុងរដ្ឋធម្មនុញ្ញ (សិទ្ធិជាមូលដ្ឋាន អំណាចសាធារណៈ) ។

ម្យ៉ាងទៀត សេចក្តីព្រាងច្បាប់ ក្រោយការអនុម័តរបស់សភាទាំងពីរ ត្រូវដាក់ជូនពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតធ្វើប្រជាមតិ តាមសម្តេងភាគច្រើន ។

ក្រុមប្រឹក្សាពិគ្រោះយោបល់

LE CONSEIL CONSULTATIF

គម្រោងវិសោធនកម្មធម្មនុញ្ញជាតិដែលបានចែងអំពីការបង្កើតសភាពីរជាន់ត្រូវបានដាក់ឆ្នោតប្រជាមតិថ្ងៃ១៤ និង ១៥កុម្ភៈ ២០០១ ។ សេចក្តីព្រាងត្រូវបានអនុម័តដោយ ៩៤,៨%នៃចំនួនអ្នកបោះឆ្នោត ។

ក្នុងគំនិតអ្នកបង្កើត ក្រុមប្រឹក្សាដែលមានអំណាចនីតិប្បញ្ញត្តិពិតប្រាកដ ជាអង្គការសម្របសម្រួល(Organe régulateur) ។ ក្រុមប្រឹក្សាជានាគុណ្យភាពរវាងរដ្ឋាភិបាល និងរដ្ឋសភាដែលកើតពីការបោះឆ្នោតដើម្បីបង្ការវិបត្តិទាំងឡាយដែលអាចនាំទៅដល់ការរំលាយសភាជាន់ទាប ។

I.សមាសភាព

ក្រុមប្រឹក្សាមានសមាជិក៤០នាក់ តែងតាំងដោយមហាក្សត្រ ។

II. របបតែងតាំង

-អាណត្តិ : ៤ឆ្នាំ អាចតែងតាំងជាថ្មី

-អាយុអប្បបរមា: ៣៥ ឆ្នាំ

-ការតែងតាំងលើកទី១ : ១៦ វិច្ឆិកា ២០០២ ។

មហាក្សត្រប្រើអំណាចតែងតាំងដើម្បីធានាឱ្យមានភាពជាតំណាងប្រសើរបំផុតនៃសង្គមជាតិ ។

III.សម័យប្រជុំ

ក្រុមប្រឹក្សាពិគ្រោះយោបល់ប្រជុំព្រមគ្នានឹងសភាជាន់ទាប(រដ្ឋសភា) ។ ពេលសភាជាន់ទាបរំលាយ សម័យប្រជុំក្រុមប្រឹក្សាត្រូវល្សីត ។

ក-សម័យប្រជុំធម្មតា

សម័យប្រជុំធម្មតាបើកនៅថ្ងៃសៅរ៍ទី២ ខែតុលា ឬនៅថ្ងៃធ្វើការទី១ បើថ្ងៃបើកបិទចំថ្ងៃបុណ្យ ។ មហាក្សត្រអាចកោះប្រជុំសភាមុនពេលកំណត់ ។ មហាក្សត្រអាចផ្ទាស់ប្តូរពេលបើក

យ៉ាងយូរ២ខែ ។ សម័យប្រជុំធម្មតាមានរយៈពេលយ៉ាងតិច៧ខែ ហើយមិនអាចបិទមុនការអនុម័តថវិកាបានទេ ។

ខ-សម័យប្រជុំវិសាមញ្ញ

សភាទាំងពីរអាចកោះប្រជុំជាវិសាមញ្ញបើមហាក្សត្រយល់ថាមានប្រយោជន៍ ឬ តាមសំណើពីភាគច្រើននៃសមាជិកសភានីមួយៗ តាមរបៀបវារៈជាក់លាក់ ។

IV-ទំនាក់ទំនាងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្យញ្ញត្តិ

អំណាចនីតិប្យញ្ញត្តិត្រូវប្រគល់ឱ្យព្រះមហាក្សត្រ និងសភា ។

១-សិទ្ធិផ្តួចផ្តើមធ្វើច្បាប់

សមាជិកក្រុមប្រឹក្សាសមាជិករដ្ឋសភានិងមហាក្សត្រមានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់ ។ ការណាការផ្តួចផ្តើមចេញពីសភា សេចក្តីស្នើច្បាប់ត្រូវបញ្ជូនទៅសុំយោបល់ពីគណៈកម្មការមានសមត្ថកិច្ចនៃសភាដែលដាក់សេចក្តីស្នើ ។ បើមានការយល់ព្រមពីសភា សេចក្តីស្នើនោះត្រូវផ្ញើទៅរដ្ឋាភិបាល ដើម្បីបញ្ជូនទៅរដ្ឋសភា ក្រោមរូបភាពជាសេចក្តីព្រាងច្បាប់ ។

ក្នុងករណីដែលសភាបដិសេធ សេចក្តីស្នើនោះមិនអាចដាក់ឡើងវិញ ក្នុងសម័យប្រជុំដដែលទេ ។

២-សិទ្ធិវិសោធនកម្ម

សមាជិកក្រុមប្រឹក្សា និងសមាជិករដ្ឋសភាមានសិទ្ធិធ្វើវិសោធនកម្ម ។

៣-នីតិវិធីធ្វើច្បាប់

ពុំមានច្បាប់ណាមួយអាចចាត់ជាបានការដោយពុំមានការយល់ព្រមពីសភាទាំងពីរ ឬពីសភាប្រជុំរួមគ្នា ទៅតាមករណីនីមួយៗឡើយ ។

ក-នីតិវិធីធម្មតា

សេចក្តីព្រាងច្បាប់ ត្រូវរដ្ឋមន្ត្រីទី១បញ្ជូនមករដ្ឋសភាអនុម័ត រួចបញ្ជូនមកក្រុមប្រឹក្សា។ បើក្រុមប្រឹក្សាមិនយល់ព្រមតាមការអនុម័តរបស់រដ្ឋសភា ប្រធានក្រុមប្រឹក្សាបញ្ជូនសេចក្តីព្រាងនោះទៅឱ្យរដ្ឋសភាពិនិត្យឡើងវិញ ។ ចើរដ្ឋសភាយល់ព្រម ប្រធានរដ្ឋសភាផ្ញើអត្ថបទនោះទៅរដ្ឋមន្ត្រីទី១ដើម្បីដាក់ថ្វាយព្រះមហាក្សត្រ។

រដ្ឋសភាអាចបដិសេធអត្ថបទរបស់ក្រុមប្រឹក្សា និងរក្សាការសម្រេចលើកទី១របស់ខ្លួនដោយគ្មានបញ្ហូលវិសោធនកម្មថ្មី ។ ក្នុងករណីនេះ អត្ថបទច្បាប់ត្រូវបញ្ជូនទៅក្រុមប្រឹក្សាដើម្បីពិនិត្យឡើងវិញ ។ក្រុមប្រឹក្សាអាចទទួលយកតាមរដ្ឋសភាឬរក្សាការសម្រេចលើកទី១របស់ខ្លួន ។

ក្រោយការពិនិត្យខ្វែងគ្នាពីរលើកនៅសភានីមួយៗ សភាត្រូវកោះប្រជុំរួមក្រោមអធិបតីភាពប្រធានក្រុមប្រឹក្សាដើម្បីពិនិត្យបញ្ញត្តិដែលមិនព្រមព្រៀងគ្នា ។ ការអនុម័តរបស់សភា (ប្រជុំរួម) ត្រូវយកសម្លេងភាគច្រើននៃចំនួនសមាជិកវត្តមាន ។ បើត្រូវសភាបដិសេធ អត្ថបទនោះមិនអាចដាក់ជូនសភាជាថ្មីក្នុងសម័យប្រជុំដដែលទេ ។

សច្ចាប័ន និងការប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ : ក្រោយពេលបញ្ជូនទៅព្រះមហាក្សត្រ៦ខែ បើព្រះមហាក្សត្រមិនបញ្ជូនទៅឱ្យសភាពិនិត្យជាថ្មីទេ អត្ថបទច្បាប់ត្រូវចាត់ទុកថាបានទទួលសច្ចាប័ន និងប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ ។

ក្នុងករណីមានការពិនិត្យជាថ្មី បើក្រុមប្រឹក្សានិងរដ្ឋសភា ឬសភាអនុម័តយល់ព្រមតាមសម្លេងភាគច្រើន២/៣នៃចំនួនសមាជិករៀងខ្លួន ព្រះមហាក្សត្រត្រូវផ្តល់សច្ចាប័ននិងប្រកាសឱ្យប្រើក្នុងរយៈពេល១ខែចាប់ពីពេលអនុម័តចុងក្រោយ ។

ខ-នីតិវិធីប្រញាប់

រដ្ឋាភិបាលអាចស្នើសុំជាការប្រញាប់លើអត្ថបទសេដ្ឋកិច្ចឬហិរញ្ញវត្ថុ ។ ក្នុងករណី នេះរដ្ឋសភាមានពេល១៥ថ្ងៃ សំរាប់ពិនិត្យ ។ ហួសរយៈពេលនេះ ក្នុងគ្រប់ករណី សេចក្តីព្រាងត្រូវបញ្ជូនទៅក្រុមប្រឹក្សាដែលមានពេល១៥ថ្ងៃដែរសំរាប់ពិនិត្យ ។

ក្នុងករណីមិនព្រមព្រៀងគ្នា អត្ថបទត្រូវបញ្ជូនទៅសភាដែលមានពេល១៥ថ្ងៃសំរាប់

ពិនិត្យ ។ បើមិនមានការសម្រេចក្នុងរយៈពេលនេះទេ មហាក្សត្រអាចផ្សព្វផ្សាយសេចក្តីព្រាងជាក្រិត្យដែលមានកម្លាំងជាច្បាប់ ។

ត-នីតិវិធីចំពោះថវិកា

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុដែលរៀបចំដោយរដ្ឋាភិបាល ត្រូវបញ្ជូនទៅរដ្ឋសភាយ៉ាងឆាប់ពីរខែមុនដំណាច់ឆ្នាំសារពើពន្ធ និងដាក់ជូនក្រុមប្រឹក្សាដើម្បីពិនិត្យស្របតាមបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ។

ក្នុងចន្លោះសម័យប្រជុំ បើជាការប្រញាប់ ព្រះមហាក្សត្រអាចផ្សព្វផ្សាយក្រិត្យដែលមានកម្លាំងជាច្បាប់ ។ ក្រិត្យច្បាប់ទាំងនេះត្រូវបញ្ជូនទៅក្រុមប្រឹក្សា និងរដ្ឋសភាក្នុងខែបន្ទាប់ពីពេលប្រកាសឱ្យប្រើក្នុងសម័យប្រជុំ ឬក្នុងខែនៃការប្រជុំទី១របស់សភានីមួយ១ ក្នុងករណីរំលាយឬចុងបញ្ចប់នៃនីតិកាល ។ បើសភាមិនយល់ព្រម ក្រិត្យច្បាប់ទាំងនោះត្រូវអស់តម្លៃដោយមានអានុ-ភាពប្រតិសកម្ម ។

ខ-អំណាចត្រួតពិនិត្យ

១-ក្រោយពេលបង្កើត រដ្ឋាភិបាលបង្ហាញកម្មវិធីរបស់ខ្លួនចំពោះសភា ។ សភាអាចធ្វើ-ការកត់សំគាល់លើកម្មវិធីនោះ ។

២-សមាជិកក្រុមប្រឹក្សាអាចតាំងសំណួរជាលាយលក្ខណ៍អក្សរចំពោះរដ្ឋមន្ត្រី លើបញ្ហាដែលទាក់ទងនឹងសមត្ថកិច្ចរបស់រដ្ឋមន្ត្រីនោះ ។

៣-ការត្រួតពិនិត្យថវិកា

ថវិកាឆ្នាំចាស់ត្រូវបញ្ជូនជាដំបូងទៅរដ្ឋសភាឯខែបន្ទាប់ពីដាច់ឆ្នាំសារពើពន្ធចាស់ ។ ថវិកានេះត្រូវមានការយល់ព្រមពីសភាទាំងពីរ ព្រមដោយការកត់សំគាល់ និងចុះផ្សាយក្នុងរដ្ឋកិច្ច ។

៤-ការងារអន្តរជាតិ

ព្រះមហាក្សត្រចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិ និងជូនដំណឹងទៅក្រុមប្រឹក្សា និងរដ្ឋសភា ។ ប៉ុន្តែអនុសញ្ញាអំពីសន្តិភាពនិង សម្ព័ន្ធភាព អនុសញ្ញាទាក់ទងនឹងដែនដីជាតិ ធនធានធម្មជាតិ អធិបតេយ្យ សិទ្ធិពលរដ្ឋ ពាណិជ្ជកម្ម នាវាចរណ៍ លំនៅដ្ឋាន ឬ អនុសញ្ញាដែលនាំឱ្យមានការកែប្រែបញ្ញត្តិតតិយុត្ត ត្រូវតែប្រកាសឱ្យប្រើដោយច្បាប់ ។

៥-ក្រុមប្រឹក្សាពិគ្រោះយោបល់ក៏ដូចជារដ្ឋសភាអាចតម្រូវវត្តមានរបស់រដ្ឋមន្ត្រីនៅពេលពិភាក្សាលើវិស័យដែលស្ថិតក្នុងសមត្ថកិច្ចរបស់រដ្ឋមន្ត្រីនោះ ។

V-បទឃ្យញ្ញត្តិដោយឡែក

ក-អំណាចធម្មនុញ្ញ

ក្រៅពីព្រះមហាក្សត្រ សមាជិកក្រុមប្រឹក្សា ឬសមាជិករដ្ឋសភា១៥នាក់មានសិទ្ធិស្នើកែប្រែរដ្ឋធម្មនុញ្ញ ។ សេចក្តីស្នើនេះត្រូវដាក់សុំយោបល់របស់គណៈកម្មការនៃសភាដែលដាក់សំណើ ។ បើមានការយល់ព្រមពីសភានោះ សេចក្តីស្នើនោះត្រូវផ្ញើទៅរដ្ឋាភិបាល ដើម្បីបញ្ជូនទៅរដ្ឋសភាក្រោមរូបភាពជាវិសោធនកម្មរដ្ឋធម្មនុញ្ញ ។

បើសភាបដិសេធ សេចក្តីស្នើនោះមិនអាចយកមកដាក់ឱ្យសភាពិនិត្យឡើងវិញក្នុងសម័យប្រជុំដដែលបានឡើយ ។

វិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវអនុម័តដោយសភាទាំងពីរ តាមសម្លេងភាគច្រើន ២/៣ នៃសមាជិកនិងដោយព្រះមហាក្សត្រ ។

ខ-ក្រុមប្រឹក្សា និងរដ្ឋសភាអាចប្រជុំរួមគ្នាជាសភា(Assemblée nationale) តាមការកោះរបស់ព្រះមហាក្សត្រ ។

ការកោះប្រជុំអាចផ្តើមដោយមហាក្សត្រ ឬតាមសំណើរបស់រដ្ឋមន្ត្រីទី១ ។

គ-ការត្រួតពិនិត្យធម្មនុញ្ញភាព

ច្បាប់អាចត្រូវប្តឹងទៅឱ្យតុលាការធម្មនុញ្ញពិនិត្យ ។ មហាក្សត្រអាចដាក់ច្បាប់ទាំងអស់ឱ្យតុលាការពិនិត្យអំពីធម្មនុញ្ញភាពមុននឹងប្រកាសឱ្យប្រើ ។

ឃ-ការប្រកាសសង្ក្រាម

១-ក្រិត្យប្រកាសសង្ក្រាមត្រូវបង្ហាញរដ្ឋសភាភ្លាម ដើម្បីសម្រេច ។

២-ច្បាប់អាជ្ញាសឹកអាចប្រកាសដោយក្រិត្យបានសំរាប់តែរយៈពេលពាខែ យ៉ាងយូរ ។ ការបន្តរយៈពេលត្រូវតែមានការយល់ព្រមពីសភាតាមសម្លេងភាគច្រើននៃសមាជិកវត្តមាន ។

ព្រឹទ្ធសភា

LE SENAT

I.សមាសភាព

ព្រឹទ្ធសភាបានបានមានសមាជិក២១នាក់ តែងតាំងដោយអគ្គទេសាភិបាល :

-១២នាក់ តាមសេចក្តីស្នើរបស់រដ្ឋមន្ត្រីទី១

-២នាក់ តាមសេចក្តីស្នើរបស់ប្រមុខគណបក្សប្រឆាំង

-៧នាក់ តំណាងឱ្យសាសនា សេដ្ឋកិច្ច សង្គម ឬក្រុមដែលមានប្រយោជន៍ តាមការយល់ឃើញរបស់អគ្គទេសាភិបាល ។

II.របបតែងតាំង

-អាណត្តិ : ៥ឆ្នាំ

-ការរៀបចំចុងក្រោយ: ២១ ឧសភា ២០០៣

-លក្ខខណ្ឌតែងតាំង: អាយុ២១ឆ្នាំ ពលរដ្ឋបានតស្នាក់នៅក្នុងប្រទេសយ៉ាងតិច ១២ខែ មុនពេលបោះឆ្នោត ។

-មិនអាចតែងតាំង:

-វិសមិតភាព : អ្នករដ្ឋការ កងកម្លាំងប្រដាប់អាវុធ ឧត្តមបាល ចៅក្រម រដ្ឋអាជ្ញា អ្នកត្រួតពិនិត្យគណនី ។

III.របបប្រជុំ

ក-សម័យប្រជុំសាមញ្ញ

អគ្គទេសាភិបាលកំណត់កាលបរិច្ឆេទនៃការបើក និងបិទសម័យប្រជុំ។ ប៉ុន្តែមិនអាចបញ្ឈប់ការប្រជុំលើសពី៦ខែជាប់ៗគ្នាឡើយ ។

ខ-សម័យប្រជុំពេញច្បាប់ (session de droit)

ព្រឹទ្ធសភាត្រូវប្រជុំយ៉ាងយូរ១ខែ ក្រោយការបោះឆ្នោតជ្រើសរើសសមាជិកសភា ។

ค-ការលើកពេលប្រជុំ

ការប្រជុំត្រូវលើកតាមការសម្រេចរបស់ប្រធានអង្គប្រជុំ បើសមាជិកព្រឹទ្ធសភាណាម្នាក់ឃើញថាពុំមានកូរ៉ុមផសំរាប់ប្រជុំ ។

IV.ធំនាក់ធំនឧ៩ាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

សភាមានមហាក្សត្រីយានីអង់ភ្លេស ព្រឹទ្ធសភា និងរដ្ឋសភា ។

ក-អំណាចនីតិប្បញ្ញត្តិ

ក្នុងវិស័យនីតិប្បញ្ញត្តិ ព្រឹទ្ធសភាមានអំណាចមានកំរិត ។

១-ឥតមានចូលចូលរួមធ្វើច្បាប់

សមាជិកព្រឹទ្ធសភាមានសិទ្ធិចូលចូលរួមធ្វើច្បាប់ ដូចសមាជិករដ្ឋសភា និងរដ្ឋាភិបាល ។ ប៉ុន្តែអំណាចរបស់សភាទាំងពីរមានកំរិតក្នុងវិស័យថវិកា និងហិរញ្ញវត្ថុ ដែលសំដៅដល់ការកែប្រែច្បាប់ពន្ធដារ ការបន្ថែមបន្ទុកសាធារណៈការ បន្ថយធនធានសាធារណៈ ឬដែលទាក់ទងនឹងបំណុលសាធារណៈ ។

ម្ចាស់សំណើមានសិទ្ធិដាក់ញត្តិសុំឲ្យមានការពិភាក្សាលើសេចក្តីស្នើច្បាប់ ។

២-សិទ្ធិវិសោធនកម្ម

ព្រឹទ្ធសភាក៏ដូចរដ្ឋសភាមានសិទ្ធិធ្វើវិសោធនកម្ម ប៉ុន្តែអំណាចធ្វើវិសោធនកម្មរបស់សភាទាំងពីរមានកំរិតក្នុងវិស័យថវិកានិងហិរញ្ញវត្ថុដែលសំដៅដល់ការកែប្រែច្បាប់ ពន្ធដារ ការបន្ថែមបន្ទុកសាធារណៈ ការបន្ថយធនធានសាធារណៈ ឬដែលទាក់ទងនឹងបំណុលសាធារណៈ ។

៣-នីតិវិធីធ្វើច្បាប់

ច្បាប់ទាំងអស់ត្រូវតែបានអនុម័តដោយសភាទាំងពីរ ។ សេចក្តីព្រាងច្បាប់ត្រូវតែបញ្ជូនមកសភាណាមួយ លើកលែងតែច្បាប់ហិរញ្ញវត្ថុដែលត្រូវផ្ញើមករដ្ឋសភាជាលើកដំបូង ។

ក្នុងករណីសម្លេងបែកជាពីរស្មើ ប្រធានអង្គប្រជុំអាចចូលរួមអនុម័ត ។

ក-នីតិវិធីធម្មតា

បើសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ត្រូវបានរដ្ឋសភាពិនិត្យ និងអនុម័តក្នុងពីរអាណត្តិជាប់គ្នា (ទោះជាមាន ឬមិនមានការរំលាយសភាក្នុងរយៈពេលនោះ) និងត្រូវព្រឹទ្ធសភាបដិសេធភាល់ពេលក្រោយពេលព្រឹទ្ធសភាអនុម័តជាលើកទី២ អត្ថបទនោះត្រូវបញ្ជូនទៅអគ្គទេសាភិបាលដើម្បីប្រកាសឱ្យប្រើបើសិនជារដ្ឋសភាមិនសម្រេចផ្សេងទៀត។

ក្រោយពេលព្រឹទ្ធសភាពិនិត្យលើកទី១ រដ្ឋសភាអាចស្នើធ្វើវិសោធនកម្ម ។ បើត្រូវបានព្រឹទ្ធសភាអនុម័ត វិសោធនកម្មនោះក្លាយជាវិសោធនកម្មរបស់ព្រឹទ្ធសភាដែលចាត់ទុកថារដ្ឋសភាបានយល់ព្រម។

ក្នុងនាមមហាក្សត្រីយានីអង់គ្លេស អគ្គទេសាភិបាលប្រកាសឱ្យប្រើច្បាប់ ។

ខ-បញ្ញត្តិដោយឡែកក្នុងវិស័យថវិកា

ថវិកាដែលរដ្ឋសភាបានអនុម័ត ហើយបញ្ជូនទៅព្រឹទ្ធសភាក្នុងរយៈពេលកំណត់ បើព្រឹទ្ធសភាមិនអនុម័តដោយគ្មានវិសោធនកម្មក្នុងរយៈពេល១ខែបន្ទាប់ពីបានទទួល ច្បាប់ថវិកានោះត្រូវបញ្ជូនទៅអគ្គទេសាភិបាលដើម្បីប្រកាសឱ្យប្រើ បើរដ្ឋសភាមិនសម្រេចផ្សេងទៀត ។

ខ-អំណាចត្រួតពិនិត្យ

សម្ព័ន្ធភាពនៃខុទ្ទកាល័យដែលមានរដ្ឋមន្ត្រីទី១ និងរដ្ឋមន្ត្រី៥នាក់ទៀតទទួលខុសត្រូវចំពោះសភា ។

ค-ការរំលាយ និងការពន្យារពេល

១-ការរំលាយ

ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីទី១ អគ្គទេសាភិបាលអាចរំលាយសភាបានគ្រប់ពេល ។

ពេលតំណែងរដ្ឋមន្ត្រីទី១នៅទំនេរ ហើយបើយល់ថាមិនមានសមាជិកណាម្នាក់មានការគាំទ្រពីសមាជិកភាគច្រើនទេ អគ្គទេសាភិបាលមានសិទ្ធិរំលាយសភា ។

២-ការពន្យារអាណត្តិ

ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីទី១ អគ្គទេសាភិបាលអាចពន្យាអាណត្តិសភាបាន

ត្រប់ពេល ។

V-បទប្បញ្ញត្តិផ្សេងៗ

ក-ការសើរើរដ្ឋធម្មនុញ្ញ

ការសើរើរដ្ឋធម្មនុញ្ញធ្វើឡើងដោយច្បាប់ ដែលអនុម័តដោយសមាជិកនៃសភានីមួយៗ តាមសម្លេងភាគច្រើនពីរភាគបី ។

ខ-ប្រធានព្រឹទ្ធសភា

ក្រោយការរំលាយសភា នៅពេលបើកសម័យប្រជុំ ព្រឹទ្ធសភាត្រូវជ្រើសរើសប្រធានដែលមិនមែនជារដ្ឋមន្ត្រី ឬជារដ្ឋលេខាធិការ និងជ្រើសរើសអនុប្រធានរបស់ខ្លួនមួយនាក់ ។

គ-ស្ថានភាពអាសន្ន

១-សភាអាចអនុម័តសេចក្តីសម្រេចចិត្តប្រកាសភាពអាសន្ន (រយៈពេលអាសន្នសាធារណៈ) តាមសម្លេងភាគច្រើនពីរភាគបីនៃចំនួនសមាជិកសភានីមួយៗ បើយល់ឃើញថាស្ថាប័នប្រជាធិបតេយ្យនានារបស់រដ្ឋទទួលរងការគំរាមដោយវិទ្ធំង្សនា ។

សេចក្តីប្រកាសនេះអាចធ្វើបានដោយអត្តទេសាភិបាល ។

២-ពេលសង្ក្រាម អាណត្តិរបស់សភាអាចពន្យាបានយ៉ាងច្រើន២ឆ្នាំ ។

៣-បើរយៈពេលអាសន្នបានកំណត់ដោយសភា រយៈពេលនេះអាចបញ្ចប់បានត្រប់ពេលដោយសភាទាំងពីរ តាមសម្លេងភាគច្រើននៃសមាជិក ។

I.សមាសភាព

ក្រុមប្រឹក្សាសាធារណរដ្ឋមានសមាជិក៦៤នាក់:

- ៥៦ ជ្រើសតាំងដោយការបោះឆ្នោតមិនផ្ទាល់ ពហុនាមនៅវ៧មណ្ឌល (៦តំបន់ និងរដ្ឋធានី - ទីក្រុងមីនស្ក) មណ្ឌលមួយមានផអាសនៈ ។

-ផនាក់យ៉ាងច្រើន តែងតាំងដោយប្រមុខរដ្ឋ(Chef de l'Etat) ។

II.របបបោះឆ្នោត

-អាណត្តិ : ៤ឆ្នាំ

-ការរៀបចំចុងក្រោយ : ១៥ វិច្ឆិកា ២០០៤

-អង្គបោះឆ្នោត : សមាជិកសភានៃក្រុមប្រឹក្សាមូលដ្ឋាន (députés des conseils locaux) និងទីក្រុងមីនស្ក

-លក្ខខណ្ឌ : បេក្ខភាពជ្រើសរើសដោយអធិបតីនៃក្រុមប្រឹក្សាមូលដ្ឋាននៃសមាជិកសភា (présidium des conseils locaux des députés) ក្នុងតំបន់ និងទីក្រុងមីនស្ក និងដោយគណៈកម្មាធិការនាយករៀងៗខ្លួន ។

កំណត់ចំណាំ : ក្រុមប្រឹក្សាសាធារណរដ្ឋបានកើតឡើងដោយប្រជាមតិធម្មនុញ្ញ (référendum constitutionnel) ថ្ងៃ២៤ វិច្ឆិកា ១៩៩៦ ។ ប្រជាមតិនេះមិនបានទទួលស្គាល់ដោយក្រុមប្រឆាំង និងពីសហគមន៍អន្តរជាតិទេ ។

បែលហ្ស៊ិក **ព្រឹទ្ធសភា**

BELGIQUE LE SENAT

I.សមាសភាព

សមាជិកព្រឹទ្ធសភាមានចំនួន៧១នាក់:

-៤០នាក់ជ្រើសរើសដោយការបោះឆ្នោតដោយផ្ទាល់(២៥នាក់ និយាយភាសាអៀឡង់ និង១៥នាក់ និយាយភាសាបារាំង)

-២១នាក់ជ្រើសរើសក្នុងសហគមន៍ ដោយក្រុមប្រឹក្សាសហគមន៍ ហើយស្ថិតនៅជាស-មាជិក ពេលត្រូវជ្រើសតាំងជាសមាជិកព្រឹទ្ធសភា:១០នាក់ដោយ conseil flamand ១០នាក់ ដោយក្រុមប្រឹក្សាសហគមន៍បារាំង និង១នាក់ ដោយក្រុមប្រឹក្សាសហគមន៍អាឡឺម៉ង់ ។

-១០នាក់ដោយការតែងតាំង (៦នាក់តែងតាំងដោយសមាជិកនិយាយភាសាអៀរឡង់ និង៤នាក់ទៀតតែងតាំងដោយសមាជិកនិយាយភាសាបារាំង ។

រដ្ឋធម្មនុញ្ញកំណត់ឱ្យពលរដ្ឋប្រ៊ីចសែលមានតំណាងអប្បបរមានៅព្រឹទ្ធសភា : យ៉ាងតិច ១នាក់ ដែលនិយាយភាសាអៀរឡង់ និង ៦នាក់ដែលនិយាយភាសាបារាំង ត្រូវមានទីលំនៅក្នុងតំបន់ប្រើភាសា២នៃទីក្រុងប្រ៊ីចសែល ក្នុងពេលបោះឆ្នោត ។

សមាជិកពេញសិទ្ធិ :សមាជិកខ្លះនៃរាជវង្ស : ព្រះរាជបុត្រព្រះមហាក្សត្រ ឬ (បើគ្មានព្រះរាជបុត្រ) សន្តតិវង្សបែល (descendants belges) ក្នុងសាខារាជវង្ស ត្រូវបានយាងឱ្យត្រងរាជសម្បត្តិ ។

II.រមបបោះឆ្នោត

ក-ប្រព័ន្ធបោះឆ្នោត

១-ការបោះឆ្នោតដោយផ្ទាល់

-តាមប្រព័ន្ធសមាមាត្រ

-ប្រទេសត្រូវចែកជាពាមណ្ឌលពហុនាម (Flandres , Wallonie et Bruxelles-Hal-Vilvorde) និងអង្គបោះឆ្នោត ២(បារាំង និងអៀឡង់) ។

២-ការបែងចែកសមាជិកព្រឹទ្ធសភាតាមសហគមន៍ និង សមាជិកតែងតាំងអាស្រ័យទៅតាមលទ្ធផលនៃការបោះឆ្នោតដោយផ្ទាល់ លើកលែងតែការបោះឆ្នោតជ្រើសរើសសមាជិកនិយាយភាសាអាឡឺម៉ង់(សម្លេងភាគច្រើន)។

ខ-អាណត្តិ : ៤ឆ្នាំ

គ-ការរៀបចំចុងក្រោយ : ១៨ ឧសភា ២០០៣

ឃ-អាយុ : ២១ ឆ្នាំ

III-សម័យប្រជុំ

ក-សម័យប្រជុំសាមញ្ញ

មាន១សម័យប្រជុំក្នុង១ឆ្នាំ ដែលបើកនៅថ្ងៃអង្គារទី២ខែតុលា ។ សម័យប្រជុំសាមញ្ញមានរយៈពេលយ៉ាងតិច៤០ថ្ងៃ។

ខ-សម័យប្រជុំវិសាមញ្ញ

ព្រះមហាក្សត្រជាអ្នកកោះប្រជុំ។ ក្នុងការជាក់ស្តែង សម័យប្រជុំវិសាមញ្ញមានច្រើនតែក្រោយការរំលាយសភា ។ កាលណាមហាក្សត្ររំលាយសភា អត្ថបទរំលាយត្រូវមានចែងអំពីការកោះប្រជុំក្នុងរយៈពេល២ខែ ។ កាលណាសភាទាំងពីរត្រូវរំលាយក្រោយការប្រកាសសើរើរដ្ឋធម្មនុញ្ញ ព្រះមហាក្សត្រត្រូវតែកោះប្រជុំសភាថ្មីក្នុងរយៈពេលដូចគ្នា។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនិតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

របបសភាពីរស្មើភាពចំពោះការធ្វើច្បាប់ស្ថាប័នជាមូលដ្ឋានទម្រង់រដ្ឋ និងស្ថាប័នរដ្ឋ (សេចក្តីព្រាងអាចបញ្ជូនមករដ្ឋសភា ឬបញ្ជូនមកព្រឹទ្ធសភា)។ សមត្ថកិច្ចរបស់ព្រឹទ្ធសភាមានកំរិតចំពោះការធ្វើច្បាប់ធម្មតា ។

១-ការផ្តើមគំនិតធ្វើច្បាប់

ព្រឹទ្ធសភា រដ្ឋសភា និងមហាក្សត្រមានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់ ។

២-សិទ្ធិវិសោធនកម្ម

ព្រឹទ្ធសភា និងរដ្ឋសភាមានសិទ្ធិវិសោធនកម្ម ។

៣-នីតិវិធីធ្វើច្បាប់

ក-នីតិវិធីចំពោះការធ្វើច្បាប់ធម្មតា

នីតិវិធីធម្មតាប្រើចំពោះច្បាប់ទាំងអស់ ក្រៅពីច្បាប់ដែលតម្រូវឱ្យមានការយល់ព្រមពីសភាទាំងពីរ ឬដែលជាសមត្ថកិច្ចផ្តាច់មុខរបស់រដ្ឋសភា ដូចជាច្បាប់ថវិកា និងគណនីរដ្ឋ សញ្ញាតូបនីយកម្ម ការទទួលខុសត្រូវរដ្ឋប្បវេណី និងព្រហ្មទណ្ឌនៃសមាជិករដ្ឋាភិបាលសហព័ន្ធ ការកំណត់ចំនួនកងប្រដាប់អាវុធប្រចាំឆ្នាំ (ហៅថាច្បាប់ឯកសភា -Lois monocamérales) ។

សេចក្តីព្រាងច្បាប់ទាំងអស់របស់រដ្ឋាភិបាលត្រូវតែបញ្ជូនមករដ្ឋសភា ។ ពេលដែលរដ្ឋ-សភាអនុម័តរួចរដ្ឋសភាត្រូវបញ្ជូនអត្ថបទនោះមកព្រឹទ្ធសភា ។ ព្រឹទ្ធសភាពិនិត្យអត្ថបទនោះ បើសមាជិកព្រឹទ្ធសភាយ៉ាងតិច១៥នាក់ស្នើសុំ ក្នុងរយៈពេល១៥ថ្ងៃ ។

ព្រឹទ្ធសភាអាចធ្វើវិសោធនកម្មសេចក្តីព្រាងច្បាប់ក្នុងរយៈពេល៦០ថ្ងៃ និងផ្ញើត្រឡប់ទៅរដ្ឋសភាវិញដើម្បីពិនិត្យជាថ្មី ។

បើព្រឹទ្ធសភាបដិសេធអត្ថបទដែលបញ្ជូនមកនោះ ត្រូវចាត់ទុកថាជាមិនមានវិសោធនកម្មទេ ។

ចំនួននៃការបង្ហិលទៅបង្ហិលមកមានកំរិត លើយរដ្ឋសភាជាអ្នកសម្រេចចុងក្រោយ ។

ប្រសិនជារដ្ឋសភាអនុម័តជាថ្មីលើវិសោធនកម្ម ព្រឹទ្ធសភាអាចពិនិត្យជាថ្មីលើសេចក្តីព្រាងច្បាប់ និងអាចស្នើជាយថាហេតុនូវវិសោធនកម្មថ្មី ។ ក្នុងករណីនេះក៏រដ្ឋសភាជាអ្នកសម្រេចចុងក្រោយ ។

គណៈកម្មការមានសមត្ថកិច្ចរបស់សភាអាចពន្យារ ឬបន្ថយរយៈពេលដែលកំណត់ខាងលើ ។ គណៈកម្មការកាត់សេចក្តីចំពោះការតវ៉ាអំពីនីតិវិធី ។

ភាគច្រើននៃច្បាប់ត្រូវតែបានការពិនិត្យជាមុនដោយគណៈកម្មការណាមួយ ។

៤-ការងារក្នុងបន្ទុកសភាទាំងពីរពេញលក្ខណៈ

គេអាចចែកជាប្រភេទនូវច្បាប់ទាំងឡាយដែលស្ថិតក្នុងបន្ទុកសភាទាំងពីរ :

១-បញ្ញត្តិស្ថាប័នមូលដ្ឋាន

-រដ្ឋធម្មនុញ្ញនិងច្បាប់ដែលត្រូវអនុម័តតាមសម្លេងភាគច្រើនពិសេស

-ច្បាប់ធម្មតាខ្លះដែលអ្នករៀបរៀងយល់ថាមានសារៈសំខាន់ តម្រូវឱ្យមានការយល់ព្រមពីរសភាទាំងពីរ ។ ទាំងនេះជាប្រភេទច្បាប់ដែលទាក់ទងនឹងទំនាក់ រដ្ឋសហព័ន្ធ និងការប្រព្រឹត្ត ទៅរបស់សភា ។

-កិច្ចការទាំងឡាយដែលត្រូវដោះស្រាយដោយសភាទាំងពីរ ស្របតាមការកំណត់របស់ រដ្ឋធម្មនុញ្ញ ។ ដើម្បីចៀសវាងការភាន់ច្រឡំ បញ្ញត្តិទាំងនេះត្រូវបានចែងក្នុងបញ្ជីមួយ ។

ទាំងនេះជាមុខងារដែលសភាត្រូវបំពេញចំពោះព្រះមហាក្សត្រ ។

២-ច្បាប់ផ្តល់ការយល់ព្រមលើអនុសញ្ញាអន្តរជាតិ

ព្រឹទ្ធសភា ក៏ដូចជារដ្ឋសភា មានសមត្ថកិច្ចស្មើគ្នាក្នុងការអនុម័តច្បាប់ដែលផ្តល់អំណាច ដល់ស្ថាប័នច្បាប់អន្តរជាតិសាធារណៈ ក៏ដូចជាចំពោះច្បាប់ដែលអនុញ្ញាតជាបណ្តោះអាសន្ន ឱ្យ អំណាចសហព័ន្ធជំនួសអង្គការមូលដ្ឋាន ក្នុងករណីដែលអង្គការទាំងនេះមិនបានគោរពកាតព្វកិច្ច អន្តរជាតិ ។

៣-ច្បាប់ផ្តល់ការយល់ព្រមលើកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងរដ្ឋសហព័ន្ធ និង សហគមន៍ ។

៤-ច្បាប់ទាក់ទងនឹងក្រុមប្រឹក្សារដ្ឋ តុលាការអាជ្ញាកណ្តាល និងការរៀបចំតុលាការ ។

៥-ច្បាប់សញ្ជាតិ

៦-ការព្យួរនីតិវិធីសភា

លើកលែងតែថវិកា និងច្បាប់ដែលតម្រូវឱ្យយកតាមសម្លេងភាគច្រើន ពិសេសញត្តិដែល មានបញ្ជាក់មូលហេតុ អាចស្នើឡើងដោយពីរភាគបីនៃសមាជិកក្រុមសាសានីមួយ១ ។

នៅពេលបញ្ជូនទៅ និងមុនពេលអនុម័តក្នុងអង្គប្រជុំ ញត្តិនេះអាចប្រកាសថាបញ្ញត្តិនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ទំនាក់ទំនងរវាងសហគមន៍នានា ។ ក្នុងករណីនេះនីតិវិធីសភាត្រូវព្យួរ ហើយញត្តិត្រូវជូនទៅក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលត្រូវផ្តល់យោបល់ដោយបញ្ជាក់ហេតុផល ក្នុងរយៈពេល១០ថ្ងៃ និងស្នើឱ្យរដ្ឋសភាពិនិត្យលើយោបល់នេះឬលើសេចក្តីព្រាងឬសេចក្តីស្នើវិសោធនកម្មជាយថាហេតុ ។

នីតិវិធីនេះអាចប្រើបានតែម្តងតត់ដោយក្រុមភាសានីមួយ១ ចំពោះសេចក្តីព្រាង ឬសេចក្តីស្នើមួយ ។

ខ-អំណាចត្រួតពិនិត្យ

១-សិទ្ធិស៊ើបអង្កេត

ព្រឹទ្ធសភា(ក៏ដូចជាប្រធាន) អាចបង្កើតគណៈកម្មការស៊ើបអង្កេត ដែលមានអំណាចដូចចៅក្រមស៊ើបអង្កេត(juge d'instruction) ។

២-ញត្តិ

ព្រឹទ្ធសភាមានសិទ្ធិបញ្ជូនញត្តិដែលបានទទួលទៅរដ្ឋមន្ត្រី ដែលត្រូវឆ្លើយបំភ្លឺលើខ្លឹមសារតាមតម្រូវការរបស់សភា ។

៣-សំណួរ

ព្រឹទ្ធសភាអាចដាក់សំណួរជាលាយលក្ខណ์អក្សរ ឬផ្ទាល់មាត់ដល់រដ្ឋាភិបាលសុំឱ្យឆ្លើយជាប្រភេទសំណួរលំអិតដែលអាចនាំឱ្យមានការពិភាក្សា ។ ការឆ្លើយសំណួរផ្ទាល់មាត់ធ្វើនៅម៉ោង៣រសៀល រៀងរាល់ថ្ងៃព្រហស្បតិ៍ ។

៤-ក្នុងការងារអន្តរជាតិគ្រប់អនុសញ្ញាមានតម្លៃពេញលេញ ក្រោយពីបានការយល់ព្រមពីសភា ។ សេចក្តីព្រាងសច្ចាប៉ន់លើអនុសញ្ញាត្រូវព្រឹទ្ធសភាពិនិត្យជាដំបូង ។

គ-ការវិលាយ

ព្រះមហាក្សត្រមានសិទ្ធិវិលាយរដ្ឋសភា ។ការវិលាយរដ្ឋសភានាំដល់ការវិលាយព្រឹទ្ធសភា ។

V.បទឃ្សោនតិះដៀលខ្សែក

ក-អំណាចធម្មនុញ្ញ

ព្រឹទ្ធសភាដូចជាព្រះមហាក្សត្រ ឬរដ្ឋសភាអាចផ្ដួចផ្ដើមគំនិតសើរើរដ្ឋធម្មនុញ្ញ ។ ក្នុងស្ថានភាពនេះសភាទាំងពីរត្រូវរលាយ ។ សភាដែលទើបជាប់ថ្មីអនុម័តចំណុច ដែលសើរើដោយមានការយល់ព្រមពីមហាក្សត្រ ។ សមាជិកចំនួនពីរភាគបីយ៉ាងតិចនៃសភានីមួយ១ ត្រូវមានវត្តមានហើយសម្លេងដែលទុកជាបានការគឺពីរភាគបីនៃឆ្នោតដែលបានបោះ ។

ខ-ការដោះស្រាយទំនាស់រវាងស្ថាប័នរដ្ឋសហព័ន្ធ

កាលបើសភាណាមួយយល់ថាអាចនឹងខូចប្រយោជន៍ដោយសេចក្ដីព្រាងច្បាប់ ឬ សេចក្ដីស្នើច្បាប់ដែលបញ្ជូនមកសភាមួយទៀត ព្រឹទ្ធសភាអាចត្រូវស្នើឱ្យដោះស្រាយវិវាទនោះដោយវិធីសម្រុះសម្រួល (par la voie de concertation) ។ បើព្រឹទ្ធសភាមិនអាចដោះស្រាយបានកិច្ចការនោះត្រូវបញ្ជូនទៅគណៈកម្មការសម្រុះសម្រួលរបស់រដ្ឋាភិបាល ។

គ-អំពីរាជាធិបតេយ្យ

១-បើគ្មានក្សត្រាបន្តវង្ស មហាក្សត្រអាចជ្រើសរើសអ្នកស្នង ដោយមានការយល់ព្រមពីសភាទាំងពីរ ។

២-សភាទាំងពីរប្រជុំរួមគ្នាសំរេចអំពីការតែងតាំងរាជានុសិទ្ធិ និងអ្នកអាណាព្យាបាល ។

៣-សភាទាំងពីរផ្ដល់ការយល់ព្រមលើ:

-ការតែងតាំងមហាក្សត្រសំរាប់ត្រប់ត្រងរដ្ឋមួយផ្សេង

-ការដកសិទ្ធិពីក្សត្រដែលទៅរៀបអភិសេកដោយគ្មានការយល់ព្រមពីព្រះមហាក្សត្រ ។

ឃ-ការតែងតាំង

សមាជិកក្រុមប្រឹក្សារដ្ឋ និងសមាជិកតុលាការអាជ្ញាកណ្ដាលត្រូវតែងតាំងដោយមហាក្សត្រ ។

ប៊ីលីស់	**ព្រឹទ្ធសភា**
BELIZE	LE SENAT

I-សមាសភាព

ព្រឹទ្ធសភាមានសមាជិកចំនួន ១២ នាក់ ។

II-របៀបជ្រើសរើស

-សមាជិកព្រឹទ្ធសភាត្រូវតែងតាំងដោយអគ្គទេសាភិបាល :

-៦នាក់តាមសំណើរបស់រដ្ឋមន្ត្រីទី១

-៣នាក់តាមសំណើរបស់ប្រធានគណបក្សប្រឆាំង

-១នាក់តាមសំណើរបស់ក្រុមប្រឹក្សាព្រះវិហារ និងសមាគមវិហារគ្រឹស្តសាសនាគ្រាស

-១នាក់ តាមសំណើរបស់សភាពាណិជ្ជកម្ម និងឧស្សាហកម្មនិងក្រុមប្រឹក្សាសហគ្រាស

-១នាក់តាមសំណើរបស់សមាជជាតិនៃសហជីពនិងគណៈកម្មាធិការជីវភាពសង្គមស៊ីវិល

-អាណត្តិ : ៥ ឆ្នាំ

-ការរៀបចំចុងក្រោយ : ៥ មីនា ២០០៣

-លក្ខខណ្ឌជ្រើសរើស : អាយុ ១៨ ឆ្នាំ និង ពលរដ្ឋប៊ីលីស់

-មិនអាចជ្រើសរើស : មានជាប់ពាក់ព័ន្ធកិច្ចជាមួយប្រទេសក្រៅ និងស្នាក់នៅក្នុងប្រទេសតិចជាងមួយឆ្នាំ

-វិសមិតភាព : សមាជិកសភាតំណាងកងកំលាំងប្រដាប់អាវុធ ភ្នាក់ងារនគរបាល ឬអ្នកជាប់កិច្ចសន្យាជាមួយរដ្ឋាភិបាល ។

សមាជិកព្រឹទ្ធសភាអាចជាសមាជិករដ្ឋាភិបាលប៉ុន្តែសមាជិករដ្ឋាភិបាលមិនអាចតែងតាំងជាសមាជិកព្រឹទ្ធសភាបានទេ ។

III-សម័យប្រជុំ

ព្រឹទ្ធសភាប្រជុំយ៉ាងតិចណាស់មួយដងក្នុងមួយឆ្នាំ តាមការកោះរបស់អគ្គទេសាភិបាល ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-ការផ្ដួចផ្ដើមគំនិតធ្វើច្បាប់

សមាជិកព្រឹទ្ធសភាមានសិទ្ធិផ្ដួចផ្ដើមគំនិតធ្វើច្បាប់ លើកលែងតែច្បាប់ដែលមានផលប៉ះពាល់ដល់ពន្ធដារ ។

២-សិទ្ធិវិសោធនកម្ម

សមាជិកព្រឹទ្ធសភាមានសិទ្ធិធ្វើវិសោធនកម្ម ។

៣-នីតិវិធី

ពេលដែលសេចក្ដីព្រាងច្បាប់ណាមួយត្រូវបានអនុម័តដោយសភាតំណាង(រដ្ឋសភា) ព្រឹទ្ធសភាពិនិត្យសេចក្ដីព្រាងនោះ។ ព្រឹទ្ធសភាអាចយល់ព្រមឬបដិសេធ ។ ព្រឹទ្ធសភាត្រូវពិនិត្យ ក្នុងរយៈ ពេល៦ខែចំពោះច្បាប់ធម្មតា និងក្នុងរយៈពេល១ខែចំពោះច្បាប់ហិរញ្ញវត្ថុ ។ សភាតំណាងអាចតម្រូវឱ្យទទួលយកគំនិតរបស់ខ្លួន។

ខ-អំណាចត្រួតពិនិត្យ

ព្រឹទ្ធសភាអាចបង្កើតគណៈកម្មការស៊ើបអង្កេត និងរៀបចំសវនកម្មសមាជិក រដ្ឋាភិបាល និងឥស្សរជនឯទៀតលើវិស័យនានានៃនយោបាយរបស់ប្រទេស ។

V-បទប្បញ្ញត្តិផ្សេងៗ

ប្រធានព្រឹទ្ធសភាត្រូវជ្រើសតាំងសំរាប់ពេល៥ឆ្នាំ ពីក្នុងចំណោមសមាជិកព្រឹទ្ធសភា ។ អនុប្រធានព្រឹទ្ធសភាត្រូវជ្រើសតាំងពីក្នុងចំណោមសមាជិកព្រឹទ្ធសភា ។ ប្រធាន និងអនុប្រធានត្រូវមានអាយុយ៉ាងតិច៣០ឆ្នាំ ។

ប៉ូលីវី **ព្រឹទ្ធសភា**

BOLIVIE LE SENAT

I.សមាសភាព

ព្រឹទ្ធសភាមានសមាជិក២៧នាក់ ជ្រើសរើសដោយការបោះឆ្នោតសកល ដោយផ្ទាល់ ។

អាណត្តិ : ៥ឆ្នាំ

II.របៀបជ្រើសរើស

ព្រឹទ្ធសភាចែកចេញជា៩មណ្ឌលបោះឆ្នោត ជាពហុនាម(ពាអាសនៈ) ទៅតាមខេត្ត (départements) ។

ប្រព័ន្ធបោះឆ្នោត : សម្លេងភាគច្រើន តាមបញ្ជី ។ គណបក្សដែលបានសម្លេងឆ្នោតលើស គេបានទទួល២អាសនៈ គណបក្សបន្ទាប់បាន១អាសនៈ ។

ការរៀបចំលើកចុងក្រោយ : ៣០ មិថុនា ២០០២

លក្ខខណ្ឌអាយុ : ៣៥ ឆ្នាំ

វិសមិតភាព : fonction ministérielle ។

III.របៀបប្រជុំ

សភាទាំងពីរបើក និងបិទសម័យប្រជុំព្រមគ្នា ។

ក-សម័យប្រជុំសាមញ្ញ

ក្នុងមួយឆ្នាំមានពីរសម័យប្រជុំ : សម័យប្រជុំទី១មាន៦០ថ្ងៃចាប់ពីថ្ងៃ ច័ន្ទទី៣ (3ième lundi)ខែសីហា ។ សម័យប្រជុំទី២ មាន៣០ថ្ងៃ ចាប់ពីថ្ងៃច័ន្ទទី១ នៃអឌ្ឍមាសទី២ ខែ មករា (1er lundi de la seconde quinzaine de janvier) ។

សម័យប្រជុំសាមញ្ញអាចពន្យារពេលដល់១២០ថ្ងៃ តាមគំនិតផ្តើមរបស់សមាជិកសភាទាំងពីរ ឬរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ។

៤-សម័យប្រជុំវិសាមញ្ញ

សម័យអាចកោះប្រជុំជាវិសាមញ្ញ តាមរបៀបវារៈមួយជាក់លាក់ តាមគំនិតផ្តើមរបស់ប្រធានាធិបតី ឬតាមសំណើរបស់សមាជិកភាពច្រើននៃសភាទាំងពីរ ។

IV-ទំនាក់ទំនងរវាងរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-គំនិតផ្តួចផ្តើមធ្វើច្បាប់

សមាជិកព្រឹទ្ធសភាមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ដូចសមាជិករដ្ឋសភា និងអង្គការនីតិប្រតិបត្តិ ។

ថវិកាជាតិត្រូវដាក់ជូនសមាជ ដោយរដ្ឋាភិបាល ។

២-សិទ្ធិធ្វើវិសោធនកម្ម

សមាជិកព្រឹទ្ធសភាមានសិទ្ធិធ្វើវិសោធនកម្ម ។

៣-នីតិវិធី

សេចក្តីព្រាងច្បាប់ដែលដាក់ឱ្យសភាមួយពិនិត្យរួចហើយ ត្រូវដាក់ឱ្យសភាមួយទៀតពិនិត្យ ។ កាលបើសេចក្តីព្រាងច្បាប់ណាមួយត្រូវសភានីមួយៗអនុម័ត សេចក្តីព្រាងច្បាប់នោះត្រូវបញ្ជូនទៅប្រមុខរដ្ឋដើម្បីប្រកាសឱ្យប្រើ ក្នុងរយៈពេល ១០ថ្ងៃ ។ បើមានវិសោធនកម្ម សភាដើមត្រូវពិនិត្យឡើងវិញ ។ ក្នុងករណីចុងក្រោយនេះ សេចក្តីព្រាងច្បាប់ ត្រូវអនុម័តតាមសម្លេងភាគច្រើនដាច់ខាត ។ បើសិនគ្មានការព្រមព្រៀងគ្នាទេ សេចក្តីព្រាង ច្បាប់ត្រូវបញ្ជូនទៅសមាជដែលមានរយៈពេល២០ថ្ងៃ សំរាប់អនុម័ត ។

អត្ថបទច្បាប់ណាដែលត្រូវបដិសេធទាំងស្រុងដោយសភាណាមួយ មិនត្រូវយកមកពិនិត្យឡើងវិញក្នុងសម័យប្រជុំប្រចាំឆ្នាំដដែលឡើយ ។

៤-សិទ្ធិជំទាស់ (droit de véto)

ប្រធានាធិបតីមានសិទ្ធិសង្កេត (droit d'observation) លើអត្ថបទច្បាប់ ។ សភាទាំងពីរត្រូវយកអត្ថបទច្បាប់ដែលប្រធានាធិបតីផ្តល់ការសង្កេតនោះមកពិនិត្យឡើងវិញ ហើយអនុ-ម័តតាមសម្លេងភាគច្រើនពីរភាគបី ។ ប៉ុន្តែប្រធានាធិបតីមិនអាចប្រើសិទ្ធិនេះ លើច្បាប់ដែលហៅថាច្បាប់ចាំបាច់នៃកំណែទំរង់ (loi dite de nécessité de réforme) ដែលបើកឱ្យមាននីតិវិធីកំណែទំរង់រដ្ឋធម្មនុញ្ញ ។

ខ-អំណាចត្រួតពិនិត្យ

១-ព័ត៌មាន

តាមគំនិតផ្តើមរបស់សមាជិកសភា សភានីមួយ១អាចស្នើរដ្ឋមន្ត្រីទាំងឡាយផ្តល់ព័ត៌មានជាណាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ។

២-គណៈកម្មការអង្កេត

តាមគំនិតផ្តើមរបស់សមាជិកសភា ព្រឹទ្ធសភាអាចបង្កើតគណៈកម្មការស៊ើបអង្កេតបញ្ហាដែលជាផលប្រយោជន៍ជាតិ ។

៣-ការសួរដេញដោល និងការបន្ទោស

តាមការស្នើសុំរបស់សមាជិកសភា សភានីមួយ១អាចកោះអញ្ជើញរដ្ឋមន្ត្រី ជាបុគ្គល ឬជាសមូហភាពមកសួរដេញដោល និងអាចសម្រេចឱ្យមានការបោះឆ្នោតបន្ទោស តាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកវត្តមាន ។ ការអនុម័តបន្ទោសតម្រូវឱ្យរដ្ឋមន្ត្រីពាក់ព័ន្ធដាក់ពាក្យសុំលាលែងទៅប្រធានាធិបតីដែលផ្តល់ការសម្រេច ។

គ-ទំនាក់ទំនងជាមួយប្រធានាធិបតី

១-ការជំនួសប្រធានាធិបតី

ក្នុងករណីអវត្តមានប្រធានាធិបតីនៃសាធារណរដ្ឋ និងអនុប្រធានាធិបតី ប្រធានព្រឹទ្ធ-សភាទទួលជាប្រធានាធិបតីស្តីទី ។

២-ការបើកសមាជិកសភា

រាល់ឆ្នាំប្រធានាធិបតីបើកប្រជុំសមាជិកសភាទាំងពីរ ។ ក្នុងពេលនោះប្រធានាធិបតីថ្លែងសារមួយអំពីស្ថានភាពរបស់ប្រជាជាតិ ។

៣-ការប្រកាសសង្គ្រាម

ប្រធានាធិបតីប្រកាសសង្គ្រាម ដោយមានការយល់ព្រមពីសមាជិកសភា ។

៤-ស្ថានភាពអាសន្ន

ក្នុងករណីនេះមានការរំជើបរំជួលដល់ផ្ទៃក្នុងធ្ងន់ធ្ងរ ឬសង្គ្រាមអន្តរជាតិ ប្រធានាធិបតីដោយមានយោបល់យល់ព្រមពីក្រុមប្រឹក្សារដ្ឋមន្ត្រី ប្រកាសស្ថានភាពអាសន្ននៅតំបន់ណាមួយឬច្រើនសំរាប់រយៈពេលមានកំណត់ ។ សមាជិកសភាសម្រេចអំពីកាលានុវត្តនភាពនៃវិធាននេះ និងសម្រេចអំពីការពន្យាររយៈពេលអាសន្នហួសពី៩០ថ្ងៃ ។

៥-ការចាកចេញពីប្រទេស

ប្រធានាធិបតីអាចចាកចេញពីប្រទេសដោយមានការយល់ព្រមពីសមាជិកសភា ។

៦-មុខងារដោយឡែក

សមាជិកសម្រេចអំពីប្រក្រតីភាពនៃការបោះឆ្នោតជ្រើសរើសប្រធានាធិបតី និងអនុ-ប្រធានាធិបតី ។ សមាជិកមានសមត្ថកិច្ចសម្រេចលើការសុំលាលែងរបស់ប្រធានាធិបតី និងអនុ-ប្រធានាធិបតី ។

V.បទឧបសម្ព្ធន្ធ៍ដោយឡែក

ក-អំណាចធម្មនុញ្ញ

១-ព័ន្ធិតផ្ទួចផ្ដើម

សមាជិកព្រឹទ្ធសភា ឬសមាជិករដ្ឋសភាចំនួនពីរភាគបីអាចស្នើច្ចៃវិសោធនកម្មរដ្ឋធម្ម-នុញ្ញ ។

២-នីតិវិធី

សេចក្តីស្នើត្រូវពិភាក្សា និងអនុម័តជាពីរលើក (en 2 tours) ក្នុងសភានីមួយៗ និងត្រូវទទួលសម្លេងពីរភាគបីនៃសមាជិកសភានីមួយៗ ។

ខ-អំណាចសម្រេចសេចក្តី

១-ទាក់ទងនឹងប្រធានាធិបតី និងអនុប្រធានាធិបតី

សមាជិមានសមត្ថកិច្ចសម្រេចលើពាក្យសុំលាលែងរបស់ប្រធានាធិបតី និងអនុប្រធានាធិបតី ដោយយល់ព្រម ឬមិនយល់ព្រម ។

-ទាក់ទងនឹងចៅក្រមខ្ពស់

ព្រឹទ្ធសភាពិនិត្យការចោទប្រកាន់របស់រដ្ឋសភាប្រឆាំងនឹងប្រធានតុលាការកំពូល និងអគ្គរដ្ឋអាជ្ញា ដែលសម្រេចតែមួយលើកតាមសម្លេងភាគច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភាវត្តមាន ស្របតាមច្បាប់ស្តីពីការទទួលខុសត្រូវ(Loi des Responsabilités) ។

គ-ការតែងតាំង

១-ព្រឹទ្ធសភាមានសមត្ថកិច្ចផ្តាច់មុខក្នុងការ:

ក-យល់ព្រម ឬមិនយល់ព្រមលើការតែងតាំងនាយទាហានជាន់ខ្ពស់ខ្លះ

ខ-យល់ព្រមឬមិនយល់ព្រមលើការតែងតាំងរដ្ឋទូតនិងរដ្ឋមន្ត្រីដែលស្នើដោយប្រធានាធិបតី

គ-ចោះឆ្នោត តាមសម្លេងភាគច្រើនដាច់ខាតនៃឆ្នោតដែលបានចោះ ជ្រើសតាំងចៅក្រមនៃតុលាការតំបន់ (Cours de districts) តុលាការជាតិនៃការងារ (Cours nationale du travail) តុលាការជាតិខាងរ៉ែ(Cours nationale des mines) តាមបញ្ជីបេក្ខជនបីនាក់ ដែលស្នើដោយតុលាការកំពូល ។

ឃ-ស្នើបេក្ខជនពានាក់ទៅប្រធានាធិបតី ដើម្បីជ្រើសតាំងអគ្គត្រួតពិនិត្យ (Controleur general) នៃសាធារណរដ្ឋ និងអគ្គត្រួតពិនិត្យនៃធនាគារ(Superintendant des banques) ។

២-សមាជិកជ្រើសតាំង តាមសម្លេងភាគច្រើនពីរភាគបី ដូរ :

-ចៅក្រមតុលាការកំពូល (les juges de la Cour suprème)

-ចៅក្រមនៃតុលាការធម្មនុញ្ញ (les juges du Tribulal constitutionel)

-ទីប្រឹក្សានៃក្រុមប្រឹក្សានៃអង្គចៅក្រម (les conseillers du Conseil de la magistrature)

-អគ្គរដ្ឋអាជ្ញា (le procureur général) នៃសាធារណរដ្ឋ

-អ្នកការពារពលរដ្ឋ (le Défenseur du peuple) ។

បូស្ស៊ី-ហេហ្សេគូចន សភាប្រជាជន

BOSNIE-HERZEGOVINE LA CHAMBRE DES PEUPLES
(DOM NARODA)

សភាប្រជាជនមានសមត្ថកិច្ចដោយឡែក សំរាប់ការពារផលប្រយោជន៍ជាអាយុជីវិត របស់សហគមន៍បូស្ស៊ី ក្រូអាស៊ី និងសែប៊ី ។

ការសើរើរដ្ឋធម្មនុញ្ញកំពុងស្ថិតក្នុងការពិភាក្សា ។ ក្នុងចំណោមចំណុចដែលត្រូវកែមាន នីតិវិធីនីតិប្បញ្ញត្តិ ។

I-សមាសភាព

សភាប្រជាជនមានសមាជិក១៥នាក់ ជាតំណាង :

-សហព័ន្ធបូស្ស៊ី-ហេហ្សេកូវីន ១០នាក់(ជនជាតិក្រូអាស៊ី៥នាក់ និងជនជាតិបូស្ស៊ី ៥នាក់)

-សែប៊ី ៥នាក់ ។

តំណែងប្រធានសភាប្រជាជនផ្លាស់ប្តូរជាបន្តបន្ទាប់ពីជនជាតិសែប៊ី ជនជាតិបូស្ស៊ី និងជនជាតិក្រូអាស៊ី ។

II-រមបតែងតាំង

តំណាង ១០នាក់របស់សហព័ន្ធបូស្ស៊ី-ហេហ្សេកូវីនត្រូវតែងតាំង ដោយតំណាងប្រជាជាតិទាំងពីរក្នុងសភាប្រជាជននៃសហព័ន្ធ ។

តំណាង៥នាក់របស់សែប៊ីត្រូវតែងតាំងដោយរដ្ឋសភាសែប៊ី ។

-អាណត្តិ : ៤ឆ្នាំ

-ការរៀបចំចុងក្រោយ : ៥ តុលា ២០០២

-លក្ខខណ្ឌអាយុ : ១៨ឆ្នាំ ។

III-សម័យប្រជុំ

សភាប្រជាជនប្រជុំតាមការកោះរបស់ប្រធាន តាមសំណើរបស់អនុប្រធានណាម្នាក់ របស់គណៈអធិបតី(la présidence) នៃក្រុមប្រឹក្សារដ្ឋមន្ត្រី ឬរបស់សមាជិកសភា ៤នាក់ ។

បើប្រធានមិនកោះប្រជុំក្នុងរយៈ៧ថ្ងៃក្រោយមានសំណើ សភាអាចប្រជុំកោះដោយអនុប្រធានទី១ ។ សភាប្រជាជនអាចប្រជុំពេញមួយឆ្នាំ ។

IV.ធ្លាក់ធ្លុះនៃនយោបាយមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

សភាមាន រដ្ឋសភា និង សភាប្រជាជន ។

ក-អំណាចនីតិប្បញ្ញត្តិ

ឃ-ប្រភេទកូវ៉ែនប្រកាន់របបសភាពីរស្មើភាព(bicamérisme égalitaire) ។

១-ឥទ្ធិពលផ្តួចផ្តើមធ្វើច្បាប់

សមាជិកសភាប្រជាជន ក៏ដូចជាសមាជិករដ្ឋសភា សមាជិកគណៈអធិបតី ឬក្រុមប្រឹក្សារដ្ឋមន្ត្រី ឬ គណៈកម្មការសភាណាមួយមានសិទ្ធិផ្តួចផ្តើមឥទ្ធិពលធ្វើច្បាប់ ។

២-សិទ្ធិវិសោធនកម្ម

សមាជិកសភាប្រជាជនមានសិទ្ធិធ្វើវិសោធនកម្ម ។

៣-នីតិវិធី

អត្ថបទច្បាប់នីមួយ១ត្រូវតែបានការអនុម័តយល់ព្រមពីសភាទាំងពីរ ។ លើកលែងតែមានការសម្រេចផ្សេងពីអ្នកស្នើច្បាប់ សេចក្តីស្នើនោះត្រូវតែបញ្ជូនទៅរដ្ឋសភាជាលើកដំបូង។ សេចក្តីស្នើច្បាប់ត្រូវបានពិនិត្យដោយគណៈកម្មការណាមួយ ក្នុងចំណោមគណៈកម្មការទាំង៨ របស់សភាប្រជាជន ។ ក្នុងសភានីមួយ១ ការសម្រេចផ្សេង១ត្រូវមានសម្លេងគាំទ្រយ៉ាងតិច១៣ នៃអង្គនីមួយ១ ។

ក្នុងករណីផ្ទុយ អង្គប្រជុំដែលមានប្រធាននិងអនុប្រធានទាំងអស់ត្រូវរកការព្រមព្រៀងក្នុងរយៈពេល៣ថ្ងៃ ។ បើកិច្ចការនេះត្រូវបរាជ័យ ការសម្រេចទាំងឡាយត្រូវយកតាមសម្លេងភាគច្រើននៃចំនួនវត្តមាន ។

អត្ថបទច្បាប់ដែលសភាមួយបានអនុម័ត ត្រូវបញ្ជូនទៅសភាមួយទៀត ក្នុងរយៈពេល ៧ថ្ងៃ ។ បើសភាលើកក្រោយកែប្រែ ត្រូវបញ្ជូនត្រឡប់ទៅសភាលើកមុន ដែលត្រូវពិនិត្យឡើង

វិញ រួចហើយត្រូវបញ្ជូនត្រឡប់ទៅវិញដោយមាន ឬមិនមានសំណើវិសោធនកម្មទៅសភាមួយទៀតដើម្បីសម្រេចចុងក្រោយ ។

នីតិវិធីការពារផលប្រយោជន៍ជាអាយុជីវិត : សេចក្តីស្នើមួយត្រូវបានប្រកាសថាផ្ទុយពីផលប្រយោជន៍របស់អង្គណាមួយ (បូស្នី ក្រូអាស៊ី ឬសែប៊ី) ដោយសម្លេងភាគច្រើន (majorité appropriée) នៃប្រតិភូរបស់ខ្លួន ។

ក្នុងសភាប្រជាជន ការអនុម័តត្រូវយកតាមសម្លេងភាគច្រើននៃប្រតិភូវត្តមានរបស់អង្គនីមួយ១ ។ បើសភាប្រជាជនមិនអាចសម្រេចសេចក្តីស្នើនោះបាន ប្រធានសភាប្រជាជនត្រូវប្រជុំជាបន្ទាន់ទូវគណៈកម្មការមួយដែលមានសមាជិកពានាក់ (តំណាងបូស្នី១នាក់ ក្រូអាស៊ី១នាក់ សែប៊ី១នាក់) ដើម្បីដោះស្រាយ ។ បើគណៈកម្មការបរាជ័យក្នុងរយៈពេល៥ថ្ងៃ បញ្ហានោះត្រូវបញ្ជូនទៅកាន់តុលាការធម្មនុញ្ញ (Cour constitutionnelle) ដែលពិនិត្យអំពីប្រក្រតីភាពនៃនីតិវិធី ។ តុលាការធម្មនុញ្ញប្រើនីតិវិធីប្រញាប់ ។ បើតុលាការធម្មនុញ្ញសម្រេចថាមានប្រក្រតីភាព សេចក្តីស្នើនោះត្រូវដាក់ឱ្យសភាប្រជាជនអនុម័ត ក្នុងរយៈពេល១០ថ្ងៃ ។ ការអនុម័តត្រូវយកតាមសម្លេងភាគច្រើននៃប្រតិភូវត្តមានរបស់អង្គនីមួយ១ ។

៥-អំណាចត្រួតពិនិត្យ

១-ញត្តិបន្ទោស

សភាប្រជាជនអាចអនុម័តញត្តិបន្ទោសក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលត្រូវដាក់ពាក្យសុំណាលែង ។

២-ផ្តល់សច្ចាប័នដល់អនុសញ្ញា

អនុសញ្ញាទាំងឡាយអាចទទួលសច្ចាប័នបាន លុះត្រាតែមានការយល់ព្រមពីសភាប្រជាជន ។

៣-របាយការណ៍អំពីសកម្មភាពនៃស្ថាប័ន

ក្រុមប្រឹក្សារដ្ឋមន្ត្រី រាយការណ៍អំពីសកម្មភាពនៃវិស័យសមត្ថកិច្ចនៃស្ថាប័នកណ្តាល ។ របាយការណ៍ត្រូវមានបញ្ជាក់អំពីស្ថានភាពចំណាយយ៉ាងតិចម្តងក្នុងមួយឆ្នាំ ។

ត-ការរំលាយ

សភាប្រជាជនអាចត្រូវរំលាយដោយគណៈអធិបតី(ពានាក់ៈបូស្ទី១នាក់ ក្រូអាស៊ី ១នាក់ សែប៊ី១នាក់) ឬរំលាយដោយខ្លួនឯង ។ ក្នុងករណីនេះ សេចក្តីសម្រេចត្រូវមានសម្លេងភាគច្រើន នៃប្រតិភូអង្គពីរយ៉ាងតិច ។

V-មធម្យញ្ញត្តិដោយឡែក

ប្រធានសភាប្រជាជន ឬសមាជិកសភាប្រជាជនចំនួន១/ ៤ (ឬសមាជិកគណៈអធិបតី ១នាក់ ឬប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី ប្រធានរដ្ឋសភា ឬសមាជិករដ្ឋសភាចំនួន១/ ៤ សមាជិកសភាសភាមូលដ្ឋានន៊ីមួយ ៗចំនួន១/៤) អាចស្នើសុំឱ្យតុលាការធម្មនុញ្ញដោះស្រាយវិវាទដែលកើតមានរវាងអង្គនានា ឬរវាងអង្គនានានិងរដ្ឋកណ្តាលឬរវាងស្ថាប័នរូមនានា ។

<u>ចំណាំ</u> : នៅចុងឆ្នាំ១៩៩៨ រដ្ឋាភិបាលបានបង្កើតគណៈកម្មការមួយឱ្យតាក់តែងសេចក្តីព្រាងកែទំរង់សមាសភាព និង អាណត្តិសភាបណ្តាប្រធាន (ការពិភាក្សាផ្តោតជាពិសេសលើការពង្រីកការជ្រើសរើសសមាជិក)។

នៅខែកក្កដា ឆ្នាំ២000 ប្រមុខរដ្ឋបានបង្កើតគណៈកម្មការបាឡូពី (commission Balopi) ទទួលរៀបចំសេចក្តីព្រាងអំពីរបៀបតែងតាំងថ្មីនៃសមាជិកសភាបណ្តាប្រធានឱ្យបានកាន់តែប្រសើរ។ បាឡូពីជាឈ្មោះអតីតរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ លោកធ្វើជាប្រធានគណៈកម្ម-ការ។

នៅខែវិច្ឆិកា ឆ្នាំ២000 គណៈកម្មការបាឡូពីបានស្នើនូវរបៀបជាតំណាងលើមូលដ្ឋានដែនដីនិងលែងផ្អែកលើមូលដ្ឋានជនជាតិ ឬកុលសម្ព័ន្ធ ។ គណៈកម្មការបានស្នើឱ្យពង្រីកសិទ្ធិជាពិសេសសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់។ រដ្ឋាភិបាលបានទទួលយកសេចក្តីព្រាងនោះ។

រដ្ឋសភាទទួលពិនិត្យ ហើយមិនផ្តល់ការយល់ព្រមលើខ្ជឹមសារជាទូទៅទេ ។

នៅឆ្នាំ ២00៤នៅពេលបើកសម័យប្រជុំ សេចក្តីព្រាងថ្មីបានដាក់ចេញដែលមានលក្ខណៈកាន់តែអព្យាក្រឹត និងទូលំទូលាយដោយដកចេញនូវការពាក់ព័ន្ធនឹងកុលសម្ព័ន្ធជាក់លាក់ខ្លះ ។ សេចក្តីព្រាងត្រូវផ្អាក ។

I.សមាសភាព

សភានៃបណ្តាប្រធានមានសមាជិក១៥នាក់ :

-៨នាក់ ជាប្រធានប្រពៃណី (ពហុ : héréditaires) នៃកុលសម្ព័ន្ធសំខាន់ៗ ដែលរាប់ដោយរដ្ឋធម្មនុញ្ញបូតស្វាណា (Bakgatla , Bakwena , Bamalete , Bamangwato, Bangwaketse ,Barolong ,Batawana et Batakwa) ជាសមាជិកពេញសិទ្ធិ (membres de droit)

-៧នាក់ ជាសមាជិកជ្រើសតាំង ។

II-របៀបជ្រើសតាំង

សមាជិកជ្រើសតាំង៨នាក់ក្នុងចំណោមសមាជិកជ្រើសតាំងទាំង៧នាក់ត្រូវបានជ្រើសតាំងដោយ និងពីក្នុងចំណោមអនុប្រធាន (sous-chefs) ស្រុក(districts) ទាំង៤(Chobe, North East, Ghanzi, Kgalagadi) ។

សមាជិកជ្រើសតាំងពីនាក់ទៀត ត្រូវជ្រើសតាំងដោយសមាជិក១២នាក់ផ្សេងទៀត ពីក្នុងចំណោមជនដែលមិនមែនជាសកម្មជនគយោបាយក្នុងរយៈពេល៥ឆ្នាំចុងក្រោយ(មាត្រា៧៥-២នៃរដ្ឋធម្មនុញ្ញ ។

សមាជិកជ្រើសតាំងទាំង៧នាក់ត្រូវរៀបចំជាថ្មីនៅពេលបោះឆ្នោតនីតិប្បញ្ញត្តិ ។ អាណត្តិមាន៥ឆ្នាំ ។

III-សម័យប្រជុំ

ក-សម័យប្រជុំសាមញ្ញ

សភាបណ្តាប្រធានប្រជុំ៣លើកក្នុងមួយឆ្នាំ មួយលើកមានរយៈពេលពី១ទៅ៣សប្តាហ៍ ។

ខ-សម័យប្រជុំវិសាមញ្ញ

សភាអាចកោះប្រជុំជាវិសាមញ្ញ បើយល់ឃើញថាជាការចាំបាច់ ។

IV-ទំនាក់ទំនងជាមួយអំណាចផ្សេងៗ

ក-ការកិច្ច

សភាបណ្តាប្រធានត្រូវតែពិនិត្យជាចាំបាច់ក្នុងករណីស្នើរដ្ឋធម្មនុញ្ញ ការអនុម័តច្បាប់ទាក់ទងនឹងទំនៀមទំលាប់(droit coutumier) ច្បាប់គ្រួសារ ឬបុគ្គល ច្បាប់ទាក់ទងនឹងរបបកម្មសិទ្ធិដីធ្លី និងទិដ្ឋភាពខ្លះនៃច្បាប់រដ្ឋប្បវេណី ។

សមាជិកសភាបណ្តាប្រធានអាចពិនិត្យបញ្ហាឯទៀត ដែលខ្លួនយល់ថាសមហេតុផល ។ សមាជិកសភាបណ្តាប្រធានមានសិទ្ធិកោះសមាជិករដ្ឋាភិបាល និងមានសិទ្ធិសួរដេញដោលសមាជិករដ្ឋសភា ។

ខ-ទីតាំងនៃសភាបណ្តាប្រធាន

ក្នុងការអនុវត្ត ហាក់ដូចជាសភាពិត្រោះយោបល់នេះមានឥទ្ធិពលតូរឱ្យកត់សំគាល់ ។ យ៉ាងណាមិញ សមាជិករដ្ឋសភាតែងស្នាក់ស្នើរក្នុងការប្រឈមជាមួយប្រធានប្រពៃណី (chefs traditionnels : Kgnosi) ។ កិត្យានុភាពនៃសភាបណ្តាប្រធានកាន់តែលើកកំពស់កាលដែលប្រធានម្នាក់ៗពិនិត្យកុលសម្ព័ន្ធរបស់ខ្លួន នៅពេលប្រជុំសភាប្រពៃណី(assemblées traditionnelles: Kgotla) ។

ចាវចនាដែលដាក់នៅសាលប្រជុំមានសេចក្តីថា " ប្រធានជាប្រធានដោយប្រជាជន :Kgosi ke Kgosi Ka Bathe " ។

ផ្ទុយមកវិញ ប្រធានមិនអាចជាសមាជិកគណបក្សនយោបាយ ហើយជាគោលការណ៍មិនអាចចូលរួមក្នុងដំណើរការបោះឆ្នោត និងក្នុងការពិភាក្សាអំពីនយោបាយទូទៅ ។ បញ្ញត្តិមានលក្ខណៈប្រពៃណីចំពោះសមាជិកពេញសិទ្ធិនិងតំណាង៤នាក់របស់ស្រុក និងមានលក្ខណៈធម្មនុញ្ញចំពោះសមាជិកពានាក់ ដែលត្រូវជ្រើសតាំងជាពិសេសហើយមានគោលបំណងបង្ការនូវទំនាស់ខាងមនសិការរបស់ប្រជាជន ដែលនៅតែមានភក្តីភាពយ៉ាងទូលំទូលាយចំពោះប្រធានរបស់ខ្លួន និងបង្ការនូវវិបត្តិនយោបាយរវាងអាជ្ញាធរប្រពៃណី និងរដ្ឋាភិបាលដែលកើតពីការបោះឆ្នោតជាសកល ។

សរុបមក សភាបណ្តាប្រធានមានស្ថាប័នដើមដែលអនុញ្ញាតឱ្យបូតស្វាណា ឆ្លងកាត់អន្តរកាលទៅរកភាពទាន់សម័យ:

-សភាបណ្តាប្រធានការពារនូវសាមត្តីភាព និងភាពចូលរួមជាប្រពៃណី ដោយបញ្ជៀសនូវការបែកបាក់កុលសម្ព័ន្ធរបស់ជាតិ ។

-ធានានូវឆន្ទៈរបស់បណ្តាប្រធានដែលដឹកនាំអាជ្ញាធរប្រពៃណី ក្នុងក្របខ័ណ្ឌនៃរបបប្រជាធិបតេយ្យអាស្រ័យសភាត្រឹមត្រូវតាមច្បាប់ពិតប្រាកដ ។

-បង្ការលក្ខណៈឱ្យមានការយកចិត្តទុកដាក់ដល់ផលប្រយោជន៍របស់ពួកគង្វាល(les pasteurs) និងពួកកសិករដែលតែងតែត្រូវវណ្ណៈអ្នកទីក្រុងធ្វើឱ្យបាត់បង់ផលប្រយោជន៍ ដូចនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ។

ចាប់តាំងពីមានច្បាប់ស្តីពីភាពជាប្រធាន (Chieftainship Act) ឆ្នាំ១៩៦៦ ប្រធានាធិបតីនៃសាធារណរដ្ឋក៏មានន្ទរសិទ្ធិពិនិត្យមើលលើការតែងតាំងបណ្តាប្រធាន ដោយកុលសម្ព័ន្ធសិទ្ធិព្យូរ និងទំលាក់បណ្តាប្រធាន ។

I.សមាសភាព

ព្រឹទ្ធសភាមានសមាជិក៨១រូបជាតំណាងរដ្ឋសមាជិកសហព័ន្ធ (états fédérés) និងស្រុកសហព័ន្ធ (district fédéral) ដោយរដ្ឋនីមួយៗនៃរដ្ឋទាំង២៦ មានសមាជិកព្រឹទ្ធសភាពីនាក់ និងស្រុកមានពីនាក់ ។

សមាជិកព្រឹទ្ធសភាត្រូវជ្រើសតាំងដោយការបោះឆ្នោតដោយផ្ទាល់ ។

II.របបជ្រើសតាំង

សមាជិកសភាត្រូវជ្រើសតាំងដោយការបោះឆ្នោត តាមសម្លេងភាគច្រើន តែមួយជុំ ។

អ្នកបោះជ្រើសយកបេក្ខជនពីរនាក់ បើបោះសើរើអាសនៈចំនួនពីរភាគបី និងជ្រើសយកបេក្ខជន១នាក់ បើបោះសើរើអាសនៈចំនួនមួយភាគបី ។

ព្រឹទ្ធសភាមានអាណត្តិ ៨ ឆ្នាំ សើរើរាល់៤ឆ្នាំ ឆ្លាស់គ្នាម្តងពីរភាគបី ម្តងមួយភាគបី ។

ការសើរើចុងក្រោយ: ៦ តុលា ២០០២

អាយុ : ៣៥ឆ្នាំ

II.សម័យប្រជុំ

ក-សម័យប្រជុំសាមញ្ញ

ព្រឹទ្ធសភាប្រជុំសាមញ្ញ២ដងក្នុងមួយឆ្នាំ : លើកទី១ ពីថ្ងៃ១៥ កុម្ភៈ ដល់ ៣០ មិថុនា លើកទី២ ពីថ្ងៃទី១សីហា ដល់១៥ធ្នូ ។ សម័យប្រជុំមិនបញ្ចប់បានទេ បើមិនទាន់បានអនុម័តច្បាប់ថវិកា ។

ក្នុងមួយឆ្នាំ សភាប្រជុំលើសពី២០០ថ្ងៃ (ប្រជុំរួមជាមួយរដ្ឋសភាលើសពី៥០ពេល) ។

ថ្ងៃធម្មតាសំរាប់ប្រជុំគឺចន្ទ អង្គារ ពុធនិងល្ងាចថ្ងៃព្រហស្សតឺចាប់ពីមោង១៤:៣០ និងព្រឹកថ្ងៃសុក្រចាប់ពីមោង៥:០០ ។

ខ-សម័យប្រជុំវិសាមញ្ញ

សម័យប្រជុំវិសាមញ្ញធ្វើតាមរបៀបវារៈមួយយ៉ាងជាក់លាក់ ។

១-តាមការផ្តើមគំនិតរបស់ប្រធានព្រឹទ្ធសភាសហព័ន្ធ ក្នុងស្ថានភាពអាសន្នឬអន្តរាគមន៍ ក្នុងករណីមានសំណើសុំប្រកាសភាពអាសន្នឬការសច្ចាប្រណិធាន និងការចូលកាន់តំណែងប្រធានាធិបតី និងអនុប្រធានាធិបតី ។

២-តាមការផ្តើមគំនិតរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ប្រធានសភាទាំងពីរ ឬតាមសំណើរបស់សមាជិកសភាភាគច្រើន ក្នុងករណីប្រញាប់ ឬមានប្រយោជន៍សំខាន់ជាសាធារណៈ ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្បញ្ញត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

រដ្ឋសភា និងព្រឹទ្ធសភាមានអំណាចនីតិប្បញ្ញត្តិស្មើគ្នា ។

១-ការផ្តួចផ្តើមគំនិតធ្វើច្បាប់

សមាជិកព្រឹទ្ធសភា និងគណៈកម្មការព្រឹទ្ធសភា ផ្ទួចជាសមាជិករដ្ឋសភានិងគណៈកម្មការរបស់សភា សមាជជាតិ(សភា : le Parlement) ប្រធានាធិបតីនៃសាធារណរដ្ឋ តុលាការសហព័ន្ធជាន់ខ្ពស់ អគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋ និងពលរដ្ឋ (អ្នកបោះឆ្នោត១ភាគរយនៃរដ្ឋយ៉ាងតិច៥ និងតំណាងអ្នកបោះឆ្នោត០,៣ភាគរយយ៉ាងតិចរបស់រដ្ឋនីមួយ១) លើកលែងតែវិស័យខ្លះដែលជាសមត្ថកិច្ចរបស់ប្រធានាធិបតីតែម្នាក់ឯង(ចំនួនកងទ័ព ការរៀបចំរដ្ឋបាល និងតុលាការ បញ្ញត្តិពន្ធដារនិងថវិកា សេវាសាធារណៈ បុគ្គលិករដ្ឋបាល ដែនដី... ។

២-សិទ្ធិវិសោធនកម្ម

សមាជិកព្រឹទ្ធសភាមានសិទ្ធិធ្វើវិសោធនកម្ម ។

៣-នីតិវិធី

ក-នីតិវិធីសំរាប់ច្បាប់ធម្មតា

សេចក្តីព្រាងច្បាប់ដែលសភាមួយបានអនុម័តរួច ត្រូវបញ្ជូនឱ្យសភាមួយទៀតអនុម័ត ហើយប្រកាសឱ្យប្រើក្នុងករណីមានការព្រមព្រៀងគ្នា ឬទុកចោលក្នុងករណីបដិសេធ ។

បើមានវិសោធនកម្ម ត្រូវបញ្ជូនទៅសភាដើមដើម្បីពិនិត្យជាថ្មី ។

មុនពេលពិនិត្យក្នុងសម័យប្រជុំសភា អត្ថបទច្បាប់ត្រូវតែពិនិត្យដោយគណៈកម្មការណាមួយ ឬច្រើន ។

ខ-បញ្ញត្តិដោយឡែក

សេចក្តីព្រាងដែលផ្តើមដោយប្រធានាធិបតី និងតុលាការសហព័ន្ធជាន់ខ្ពស់ត្រូវបញ្ជូនទៅឱ្យរដ្ឋសភាពិនិត្យមុន ។

បើប្រធានាធិបតីបានស្នើជាការប្រញាប់ សេចក្តីព្រាងនោះត្រូវចុះក្នុងរបៀបវារៈ ហើយសេចក្តីព្រាងឯទៀតត្រូវព្យួររហូតដល់ចប់ការអនុម័តសេចក្តីព្រាងប្រញាប់នោះ ។ សភាត្រូវពិនិត្យជាបន្តបន្ទាប់ក្នុងរយៈពេល៤៥ថ្ងៃ ។ វិសោធនកម្មរបស់ព្រឹទ្ធសភាត្រូវរដ្ឋសភាពិនិត្យក្នុងរយៈពេល ១០ថ្ងៃ ។

គ-វិស័យថវិកា

គណៈកម្មការចំរុះអចិន្ត្រៃយ៍ ដែលមានសមាជិកព្រឹទ្ធសភា និងសមាជិករដ្ឋសភាផ្តល់យោបល់លើវិសោធនកម្ម ដែលស្នើក្នុងលក្ខខណ្ឌនៃការទទួលខ្លះ ។

ឆ-ការអនុម័តនៅតាមគណៈកម្មការ

សេចក្តីព្រាងច្បាប់អាចពិនិត្យ និងអនុម័តនៅតាមគណៈកម្មការ លើកលែងតែមួយភាគដប់នៃសមាជិកសភា ស្នើឱ្យបញ្ជូនអត្ថបទនោះទៅសម័យប្រជុំពេញអង្គ ។

ម-សិទ្ធិជំទាស់របស់ប្រធានាធិបតី

បើប្រធានាធិបតីនៃសាធារណរដ្ឋចាត់ទុកថាផ្នែកណាមួយ ឬទាំងស្រុងនៃសេចក្តីព្រាងណាមួយផ្ទុយនឹងរដ្ឋធម្មនុញ្ញឬផ្ទុយនឹងផលប្រយោជន៍សាធារណៈ ប្រធានាធិបតីប្រើសិទ្ធិជំទាស់

ទាំងស្រុងឬមួយផ្នែក ក្នុងរយៈពេល១៥ថ្ងៃធ្វើការ ចាប់ពីពេលបានទទួល ហើយជូនដំណឹងទៅ ប្រធានព្រឹទ្ធសភាក្នុងរយៈពេល៤៨ម៉ោង ។

ការជំទាស់នេះត្រូវសម្រេចដោយសមាជជាតិ(ក្រោមអធិបតីភាពរបស់ប្រធានព្រឹទ្ធ-ភាជានិច្ច)ក្នុងរយៈពេល៣០ថ្ងៃចាប់ពីពេលបានទទួល និងត្រូវបានផ្ទាកដោយសម្លេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភានិងសមាជិករដ្ឋសភា នាពេលបោះឆ្នោតជាសម្ងាត់ ។

បើមិនបានពិនិត្យក្នុងរយៈពេលនេះទេ ការជំទាស់នេះត្រូវចុះជាអាទិភាពក្នុងរបៀបវារៈសម័យប្រជុំខាងមុខរហូតដល់ដល់ការសម្រេចជាស្ថាពរលើកលែងតែការពិនិត្យវិធានការបណ្តោះអាសន្ន ។

នៅពេលគ្មានឬផ្ទាកការជំទាស់ ប្រធានាធិបតីត្រូវប្រកាសឱ្យអនុវត្តច្បាប់ ក្នុងរយៈពេល ៤៨ម៉ោង ឬដោយប្រធានឬអនុប្រធានព្រឹទ្ធសភា បើប្រធានាធិបតីអវត្តមាន ។

ខ្លឹមសារច្បាប់ដែលត្រូវបដិសេធ អាចយកមកដាក់ក្នុងសេចក្ដីព្រាងថ្មី នាសម័យប្រជុំដដែល លុះត្រាមានការសម្រេចពីសភាណាមួយ តាមសម្លេងភាគច្រើនដាច់ខាត ។

៦-វិធានការបណ្តោះអាសន្ន

ក្នុងករណីនៃផលប្រយោជន៍ដោយឡែក ឬករណីប្រញាប់ ប្រធានាធិបតីអាចចេញនូវ វិធានការបណ្តោះអាសន្នដែលមានតម្លៃជាច្បាប់ ។ វិធានការនេះត្រូវដាក់ជាបន្ទាន់ជូនសមាជ ។ បើសភាវិស្សមកាល ត្រូវកោះប្រជុំជាវិសាមញ្ញក្នុងរយៈពេល៥ថ្ងៃ ។

វិធានការបណ្តោះអាសន្ននោះត្រូវអស់តម្លៃបើមិនបានទៅជាច្បាប់ក្នុងរយៈពេល ៣០ថ្ងៃ ចាប់ពីពេលផ្សព្វផ្សាយ ។ សមាជជាតិត្រូវសម្រេចលើចំនាត់ទំនងគតិយុត្តដែលចេញពីវិធានការ នោះ ។

៧-ប្រតិភូកម្ម

ប្រធានាធិបតីអាចស្នើសមាជសុំធ្វើប្រតិភូកម្មអំណាច ។ មិនអាចធ្វើប្រតិភូកម្មបានចំពោះ បទដ្ឋានដែលស្ថិតក្នុងសមត្ថកិច្ចផ្ទាល់មុខរបស់សមាជរបស់រដ្ឋសភា ឬរបស់ព្រឹទ្ធសភាសហព័ន្ធ

ច្បាប់អង្គការ ការរៀបចំអំណាចតុលាការ លក្ខន្តិកៈចៅក្រម សញ្ញាតិ ពលរដ្ឋ សិទ្ធិ ផ្ទៃនការ រយៈពេលច្រើនឆ្នាំ និងវិស័យថវិកា ។

ខ-អំណាចត្រួតពិនិត្យ

១-គណៈកម្មការស៊ើបអង្កេត

ព្រឹទ្ធសភាសហព័ន្ធ រដ្ឋសភាឬសភាទាំងពីរ តាមសំណើរបស់សមាជិកចំនួនមួយភាគបី អាចបង្កើតគណៈកម្មការស៊ើបអង្កេត ដើម្បីសិក្សាលើបញ្ហាជាក់លាក់ណាមួយ ក្នុងរយៈពេលមានកំណត់ ។

សេចក្តីសន្និដ្ឋានរបស់គណៈកម្មការ ត្រូវបញ្ជូនទៅក្រសួងសាធារណៈដើម្បីសម្រេចពីការទទួលខុសត្រូវរបស់ជនល្មើស ខាងស៊ីវិល ឬខាងព្រហ្មទណ្ឌ ។

គណៈកម្មការនេះមានសិទ្ធិស៊ើបអង្កេតដូចអាជ្ញាធរតុលាការ ។

២-ការវិនិច្ឆ័យបទល្មើសនៃការទទួលខុសត្រូវ

ក្រោមអធិបតីភាពរបស់ប្រធានតុលាការសហព័ន្ធជាន់ខ្ពស់ ព្រឹទ្ធសភាមានសិទ្ធិផ្តាច់មុខ ក្នុងការស៊ើបអង្កេតនិងវិនិច្ឆ័យប្រធានាធិបតី និងអនុប្រធានាធិបតីនៃសាធារណរដ្ឋអំពីបទល្មើសនៃការទទួលខុសត្រូវ និងវិនិច្ឆ័យរដ្ឋមន្ត្រី សមាជិកតុលាការសហព័ន្ធជាន់ខ្ពស់ អគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋ និងអគ្គមេធាវីសហព័ន្ធ លើបទល្មើសដូចគ្នានេះ ។

ការផ្តន្ទាទោសត្រូវសម្រេច ដោយសម្លេងភាគច្រើន២/៣នៃចំនួនសមាជិកព្រឹទ្ធសភា ។ ទោសមានការដកមុខតំណែង ការហាមមិនឱ្យកាន់តំណែងក្នុងមុខងារសាធារណៈចំនួន ៨ឆ្នាំ ដោយមិនទាន់គិតដល់ទោសដទៃទៀត ។

៣-ការកោះអញ្ជើញរដ្ឋមន្ត្រី

ព្រឹទ្ធសភា ឬគណៈកម្មការនានា កោះអញ្ជើញរដ្ឋមន្ត្រីឬប្រធានស្ថាប័ន ដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ប្រធានាធិបតីនៃសាធារណរដ្ឋ ក្នុងករណីដែលអ្នកទាំងនោះអវត្តមានមិនសមហេតុផល ដើម្បីឱ្យផ្តល់ព័ត៌មានដោយផ្ទាល់ខ្លួនអំពីអវត្តមាននោះ ។ អវត្តមានមិនសមហេតុផលនេះជាបទល្មើសនៃការទទួលខុសត្រូវ ។

៤-សំណូរជាលាយលក្ខណ៍អក្សរ

ការិយាល័យរបស់ព្រឹទ្ធសភា ឬរដ្ឋសភាអាចដាក់សំណូរជាលាយលក្ខណ៍អក្សរដល់ឥស្សរជនដូចខាងលើឱ្យផ្តល់ព័ត៌មាន ។ ការមិនផ្តល់ចម្លើយក្នុងរយៈពេល ៣០ថ្ងៃ ឬការផ្តល់ព័ត៌មានខុសជាបទល្មើសនៃការទទួលខុសត្រូវ ។

៥-វិស័យហិរញ្ញវត្ថុ និងថវិកា

ក-សមាជជាតិឃ្លាំមើលគណនី ហិរញ្ញវត្ថុ ថវិកា ប្រតិបត្តិការ បេតិកភ័ណ្ឌរបស់សហភាពអង្គភាពរដ្ឋបាល ដោយផ្ទាល់ ឬប្រយោលអំពីភាពត្រឹមត្រូវ ស្របច្បាប់ កាលានុវត្តនភាពសេដ្ឋ-កិច្ច ការផ្តល់ជំនួយ និងការបដិសេធបំណុល ។

តាមសំណើរបស់ព្រឹទ្ធសភា ឬរដ្ឋសភា ឬរបស់គណៈកម្មការស៊ើបអង្កេត ឬបច្ចេកទេស ឬតាមការផ្តើមគំនិតរបស់ខ្លួន តុលាការគណនីសហព័ន្ធអាចធ្វើអធិការកិច្ច ឬ សវនកម្មគណនី ហិរញ្ញវត្ថុ ថវិកា ប្រតិបត្តិការឬបេតិកភ័ណ្ឌក្នុងអង្គភាពរដ្ឋបាលនៃអំណាចទាំងបី ។

គណៈកម្មការចំរុះអចិន្ត្រៃយ៍សមាជិកព្រឹទ្ធសភា និងសមាជិករដ្ឋសភា :

-ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាង ក៏ដូចជាលើរបាយការណ៍ប្រចាំឆ្នាំ លើផែនការ និងកម្មវិធីផ្សេងៗ ដែលប្រធានាធិបតីដាក់ជូន

-តាមដាននិងឃ្លាំមើលថវិកា ដោយមិនរំខានដល់កិច្ចការរបស់គណៈកម្មការរបស់សមាជ ឬរបស់សភា ។

ខ-ព្រឹទ្ធសភាមានសមត្ថកិច្ចផ្តាច់មុខ ក្នុងការអនុញ្ញាតឱ្យអង្គភាពនានា ក៏ដូចជាសហព័ន្ធធ្វើប្រតិបត្តិការហិរញ្ញវត្ថុ (ឥណទាន បំណុល និងការ ធានា) ។

៦-វិស័យអន្តរជាតិ

ក-ព្រឹទ្ធសភាមានសមត្ថកិច្ចផ្តាច់មុខ ក្នុងការយល់ព្រមលើការជ្រើសរើសប្រធានបេសកកម្មការទូត ដែលមានលក្ខណៈអចិន្ត្រៃយ៍ដោយការបោះឆ្នោតជាសម្ងាត់ ។

ខ-សមាជជាតិមានសមត្ថកិច្ចផ្តាច់មុខក្នុងការ:

១-សម្រេចជាស្ថាពរលើអនុសញ្ញា កិច្ចព្រមព្រៀង ឬបទដ្ឋានអន្តរជាតិដែលដាក់បន្ទុកធ្ងន់ធ្ងរដល់ជាតិ ។

២-អនុញ្ញាតឱ្យប្រកាសសង្គ្រាម ឬបញ្ចប់សង្គ្រាម ឱ្យទ័ពបរទេសឆ្លងកាត់ ឬតាំងជាបណ្តោះអាសន្ន ។

៧-កាលៈទេសៈដោយឡែក

សមាជជាតិមានសមត្ថកិច្ចផ្តាច់មុខក្នុងការៈ

ក-អនុញ្ញាតឱ្យប្រធានាធិបតីឬអនុប្រធានាធិបតីសាធារណរដ្ឋអវត្តមានពីប្រទេសលើសពី ១៥ថ្ងៃ ។

ខ-ញ្យរបទដ្ឋានគតិយុត្តរបស់នីតិប្រតិបត្តិដែលហូសពីសមត្ថកិច្ចឬហូសពីដែនប្រតិភូកម្ម ។

គ-យល់ព្រមលើការផ្ទូចផ្តើមដែលមានលក្ខណៈជាសកម្មភាពនុយក្លេអ៊ែរ ។

ឃ-អនុញ្ញាតឱ្យធ្វើប្រជាមតិ និងកោះប្រជាសិទ្ធិ (សេចក្តីសម្រេចរបស់ប្រជារាស្ត្រៈ le plébicite) ។

V-បទឃ្យញ្ញត្តិដោយឡែក

ក-អំណាចធម្មនុញ្ញ

១-គំនិតផ្ទូចផ្តើមធ្វើច្បាប់

សមាជិកព្រឹទ្ធសភា ឬសមាជិករដ្ឋសភាយ៉ាងតិចចំនួនមួយភាគបី ប្រធានាធិបតីនៃសាធារណរដ្ឋឬលើសពីពាក់កណ្តាលនៃសភារដ្ឋសមាជិកមានសិទ្ធិស្នើធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ។

២-នីតិវិធី

សេចក្តីស្នើត្រូវពិភាក្សា និងអនុម័តក្នុងសភានីមួយ១ជាពីរជុំ ហើយចាត់ទុកថាយល់ព្រមកាលបើមានសម្លេងគាំទ្រចំនួន៣/៥នៃសមាជិកសភានីមួយ១ ។

ខ-បណ្តឹងអំពីធម្មនុញ្ញភាព

ការិយាល័យព្រឹទ្ធសភាសហព័ន្ធអាចដាក់បណ្តឹងអំពីធម្មនុញ្ញភាព ។

គ-កាលៈទេសៈពិសេស

សមាជជាតិមានសិទ្ធិផ្តាច់មុខក្នុងការសម្រេចអំពីស្ថានភាពការពារខ្លួន អន្តរាគមន៍សហព័ន្ធ ការប្រកាសភាពអាសន្ន ឬព្យួរស្ថានភាពទាំងនោះ ។

ឃ-ការតែងតាំង

ព្រឹទ្ធសភាមានសិទ្ធិផ្តាច់មុខក្នុងការ:

១-សម្រេចតែងតាំងចៅក្រមខ្ពស់ សមាជិកតុលាការគណនី អភិបាលដែនដី ប្រធាននិងនាយកធនាគារកណ្តាល អគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋ និងមុខតំណែងទទួលខុសត្រូវខ្ពស់ទៀត ។

២-ជ្រើសរើសសមាជិកក្រុមប្រឹក្សាសាធារណរដ្ឋ ដែលប្រធានព្រឹទ្ធសភាជាសមាជិក ។

ង-មុខងារដោយឡែករបស់ប្រធានព្រឹទ្ធសភាសហព័ន្ធ

ប្រធានព្រឹទ្ធសភាសហព័ន្ធទទួលជាស្តីទីប្រធានាធិបតីឬអនុប្រធានាធិបតីកាលបើប្រធានរដ្ឋសភាអវត្តមាន និងជាសមាជិកក្រុមប្រឹក្សាការពារជាតិ ។

ច-ព្រឹទ្ធសភាមានសិទ្ធិផ្តាច់មុខក្នុងការអនុញ្ញាតឱ្យខ្ចីប្រាក់ ។

ឆ-គណៈកម្មការតំណាងសមាជជាតិ

គណៈកម្មការនេះត្រូវជ្រើសតាំងដោយសភាទាំងពីរ នៅពេលប្រជុំចុងក្រោយនៃសម័យប្រជុំ តាមរូបមន្តសមាមាត្រនៃគណបក្ស សំរាប់វិស្សមកាលរបស់សភា ។

ឃាតកម្មនៅខែតុលា ឆ្នាំ១៩៩៣ លើរូបប្រធានាធិបតីជាប់ឆ្នោតបាននាំមកនូវសង្គ្រាមស៊ីវិលនៅBurundi ។

ដំណើរការរកសន្តិភាពឆ្នាំ១៩៩៨បាននាំដល់ការព្រមព្រៀងខាងនយោបាយ ថ្ងៃ ២៨ ខែ សីហា ឆ្នាំ២០០០ នៅអារុស្សា (Arusha) ។

នៅខែវិច្ឆិកា ឆ្នាំ២០០១ រដ្ឋធម្មនុញ្ញអន្តរកាលមួយត្រូវបានប្រកាសឱ្យប្រើ ដើម្បីតាំពារស្ថាប័ននៃរដ្ឋាភិបាលថ្មីដែលកើតនៅថ្ងៃទី១ ខែ វិច្ឆិកា ឆ្នាំ២០០១ ។

ផ្ទៃតតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩២ និងបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៦ រដ្ឋធម្មនុញ្ញអន្តរកាលបានដាក់បញ្ចូលនូវអនុសាសន៍នៃកិច្ចព្រមព្រៀងArusha និងការព្រមព្រៀង ថ្ងៃ ២៣ ខែ កក្កដា ឆ្នាំ២០០១ ។ រដ្ឋធម្មនុញ្ញក្រោយអន្តរកាលត្រូវបានអនុម័តដោយប្រជាមតិ នៅថ្ងៃទី២៨ ខែ កុម្ភ: ឆ្នាំ២០០៥ ។ រដ្ឋធម្មនុញ្ញនេះតាំទ្រការរៀបចំឡើងវិញនូវរបបសភាពីរ ។

ការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភាប្រព្រឹត្តទៅនៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៥ ។

អន្តរកាលបានបញ្ចប់នៅថ្ងៃទី ២៦ ខែសីហាឆ្នាំ២០០៥ ពេលប្រធានាធិបតីនៃសាធារណរដ្ឋដែលជ្រើសតាំងដោយការប្រជុំរួមនៃសភាទាំងពីរស្បថចូលកាន់តំណែង ។

I.សមាសភាព

១-គណ: ប្រតិភូ ២នាក់តំណាងខេត្តនីមួយ១នៃខេត្តទាំង១៧ ជ្រើសរើសដោយការបោះឆ្នោតប្រយោល មកពីសហគមន៍ជនជាតិផ្សេង១

២-សមាជិកពានាក់មកពីជនជាតិត្វា (Twa)

៣-អតីតប្រមុខរដ្ឋ(បច្ចប្បន្នមាន៤នាក់) ។

សមាជិកជាស្ត្រីត្រូវមានយ៉ាងតិច៣០ភាគរយ ។ អាចមានសមាជិកបន្ថែមដើម្បីធានាសមភាព Hutus-Tutsis និងកូតា៣០ភាគរយសម្រាប់ស្ត្រី ។

បច្ចុប្បន្ន ព្រឹទ្ធសភាមានសមាជិក៥៨នាក់ ។

II.-របៀបបោះឆ្នោត

សមាជិកព្រឹទ្ធសភាត្រូវជ្រើសតាំង ដោយការបោះឆ្នោតតាមសម្លេងភាគច្រើនជាពីរជុំ ។នៅពីរជុំដំបូងត្រូវយកតាមសម្លេងភាគច្រើន២/ ៣ ។នៅជុំទី៣មានតែបេក្ខជនពីររូបដែលបានសម្លេងច្រើនជាងគេ ហើយត្រូវយកតាមសម្លេងភាគច្រើនដោយប្រៀប ។

ក្នុងខេត្តនីមួយៗ សមាជិកទាំងពីររូបត្រូវជ្រើសតាំងដោយការបោះឆ្នោតផ្សេងគ្នា ។

គណៈអ្នកបោះឆ្នោត:សមាជិកក្រុមប្រឹក្សាឃុំ ។

អាយុ : ៣៥ឆ្នាំ

អាណត្តិ : ៥ឆ្នាំ

ការបោះឆ្នោតលើកទី១ : ២៥ កក្កដា ២០០៥ ។

វិសមិតភាព : សមាជិករដ្ឋាភិបាល ។

III.-របៀបប្រជុំ

ក-សម័យប្រជុំសាមញ្ញ

ព្រឹទ្ធសភាប្រជុំ៣ដងក្នុងមួយឆ្នាំ ។ សម័យប្រជុំនីមួយៗមានរយៈពេល៣ខែ ។

ខ-សម័យប្រជុំវិសាមញ្ញ

ព្រឹទ្ធសភាអាចកោះប្រជុំជាវិសាមញ្ញ តាមសំណើរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ឬតាមសំណើរបស់សមាជិកព្រឹទ្ធសភាលើសពីពាក់កណ្តាល តាមរបៀបវារៈមួយយ៉ាងជាក់លាក់ សំរាប់រយៈពេល១៥ថ្ងៃយ៉ាងច្រើន ។

IV.-ផ្នត់ផ្ទំនិងជ៖ាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ព្រឹទ្ធសភាសម្រេចកិច្ចការផ្សេងៗតាមសម្លេងភាគច្រើន២/៣ នៃសមាជិកព្រឹទ្ធសភាវត្តមាន ឬតំណាងដូចនៅរដ្ឋសភាដែរ ។

ក-អំណាចនីតិប្បញ្ញត្តិ

ព្រឹទ្ធសភានិងរដ្ឋសភាជាអំណាចនីតិប្បញ្ញត្តិដែលមានអំណាចមិនស្មើគ្នា ។

ព្រឹទ្ធសភាមានអំណាចនីតិប្បញ្ញត្តិទូទៅ ប៉ុន្តែរដ្ឋធម្មនុញ្ញបានផ្តល់នូវបុព្វសិទ្ធិពិសេស ក្នុងវិស័យច្បាប់អង្គការ ច្បាប់ចោះឆ្នោត និងសមូហភាពដែនដី ។

១-ការផ្តួចផ្តើមតំនិតធ្វើច្បាប់

ប្រធានាធិបតីនៃសាធារណរដ្ឋ រដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភាមានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់ ។

រដ្ឋាភិបាលជាម្ចាស់នៃរបៀបវារៈជាអាទិភាព ។ ប៉ុន្តែបើសិនជាសេចក្តីស្នើច្បាប់ណាមួយមិនត្រូវបានពិនិត្យនៅសម័យប្រជុំពីរជាប់គ្នា សេចក្តីស្នើនោះត្រូវចុះជាអាទិភាព ក្នុងរបៀបវារៈនៃសម័យប្រជុំខាងមុខ ។

ប៉ុន្តែ សេចក្តីស្នើរបស់សមាជិកព្រឹទ្ធសភា ឬសមាជិករដ្ឋសភាដែលបន្ថយនូវធនធានសាធារណៈ បង្កើតឬបន្ថែមបន្ទុកសាធារណៈមិនអាចទទួលយកបានទេ លើកលែងតែមានសំណើបង្កើតចំណូលសំរាប់បំពេញឱ្យវិញ ។

២-សិទ្ធិវិសោធនកម្ម

រដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភាមានសិទ្ធិធ្វើវិសោធនកម្ម ។ ប៉ុន្តែមិនអាចធ្វើបានទេ បើវិសោធនកម្មនោះបន្ថយនូវធនធានសាធារណៈ បង្កើតឬបន្ថែមបន្ទុកសាធារណៈ លើកលែងតែមានសំណើបង្កើតចំណូលសំរាប់បំពេញឱ្យវិញ ។

៣-នីតិវិធី

ក-នីតិវិធីធម្មតា

សេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ត្រូវបញ្ជូនព្រមពេលត្មាមករដ្ឋសភា និងព្រឹទ្ធសភា ។ អត្ថបទត្រូវអនុម័តជាលើកដំបូងនៅរដ្ឋសភា ហើយប្រធានរដ្ឋសភាត្រូវបញ្ជូនភ្ជាមទៅព្រឹទ្ធសភា ។ ព្រឹទ្ធសភាពិនិត្យតាមសំណើរបស់ការិយាល័យ ឬរបស់សមាជិកយ៉ាងតិចចំនួនមួយភាគបី ដែលធ្វើឡើងក្នុងរយៈពេលៗថ្ងៃ គិតពីពេលទទួល ។

ព្រឹទ្ធសភាអាចអនុម័តដោយគ្មាន ឬដោយមានវិសោធនកម្មក្នុងរយៈពេល១០ថ្ងៃ ចាប់ពីពេលដាក់សំណើ ។

បើអត្ថបទមានវិសោធនកម្ម ព្រឹទ្ធសភាត្រូវបញ្ជូនវិសោធនកម្មនោះទៅឱ្យរដ្ឋសភាអនុម័ត ដោយយល់ព្រមឬបដិសេធទាំងស្រុង ឬមួយផ្នែកនៃវិសោធនកម្មរបស់ព្រឹទ្ធសភា ។

បើព្រឹទ្ធសភាមិនបានសម្រេចក្នុងរយៈពេល១០ថ្ងៃ ឬបើព្រឹទ្ធសភាជំរាបរដ្ឋសភាថាមិនមានវិសោធនកម្មទេ ប្រធានរដ្ឋសភាបញ្ជូនអត្ថបទនោះទៅប្រធានាធិបតីនៃសាធារណរដ្ឋដើម្បីប្រកាសឱ្យប្រើ ។

នៅពេលពិនិត្យលើកទី២ បើរដ្ឋសភាអនុម័តវិសោធនកម្មថ្មី អត្ថបទត្រូវបញ្ជូនទៅព្រឹទ្ធសភាដើម្បីពិនិត្យតែវិសោធនកម្មនោះ ក្នុងរយៈពេល៥ថ្ងៃចាប់ពីពេលបញ្ជូន ។

ព្រឹទ្ធសភាអាចយល់ព្រមដោយឥតកែប្រែ ឬយល់ព្រមដោយមានការកែប្រែ ។ បើមានវិសោធនកម្មថ្មី ព្រឹទ្ធសភាត្រូវបញ្ជូនទៅរដ្ឋសភាវិញដើម្បីសម្រេចជាចុងក្រោយ ។

ខ-បទប្បញ្ញត្តិដោយឡែក(មាត្រា១៨៧នៃរដ្ឋធម្មនុញ្ញ)

អត្ថបទដែលទាក់ទងនឹងមាត្រានេះ ត្រូវរដ្ឋសភាពិនិត្យជាមុន និងត្រូវដាក់បញ្ចូលដោយស្វ័យប្រវត្តិក្នុងរបៀបវារៈរបស់ព្រឹទ្ធសភាដែលត្រូវពិនិត្យក្នុងរយៈពេល៣០ថ្ងៃ ។

បើព្រឹទ្ធសភាមិនមានវិសោធនកម្ម ត្រូវបញ្ជូនទៅប្រធានរដ្ឋសភា ដែលបញ្ជូនទៅប្រធានាធិបតីនៃសាធារណរដ្ឋដើម្បីប្រកាសឱ្យប្រើ ។ ផ្ទុយពីនេះ ប្រធានព្រឹទ្ធសភាបញ្ជូនទៅរដ្ឋសភាដើម្បីពិនិត្យជាថ្មី ។

ក្នុងករណីមិនមានការព្រមព្រៀងគ្នា ប្រធានសភាទាំងពីរបង្កើតគណៈកម្មការចំរុះ ដើម្បីដោះស្រាយ ក្នុងរយៈពេល១៥ថ្ងៃធ្វើការ ។

អត្ថបទដែលស្នើដោយគណៈកម្មការចំរុះ ត្រូវបញ្ជូនទៅសភានីមួយៗ ដើម្បីអនុម័ត ។ មិនមានវិសោធនកម្មណាមួយអាចត្រូវបានលើកឡើងទេ ។

បើគណៈកម្មការចំរុះមិនអាចរកដំណោះស្រាយបាន ឬបើអត្ថបទត្រូវសភាណាមួយ បដិសេធ ប្រធានាធិបតីនៃសាធារណរដ្ឋអាចស្នើឱ្យរដ្ឋសភាអនុម័តជាចុងក្រោយឬអាចជំរុះចោលអត្ថបទច្បាប់នោះ ។

៤-ការធ្វើនីតិសម្បទាបទដ្ឋានគតិយុត្ត

ដើម្បីអនុវត្តកម្មវិធីរបស់ខ្លួន រដ្ឋាភិបាលអាចស្នើសុំការអនុញ្ញាតពីសភាឱ្យប្រើ ក្រឹត្យ-ច្បាប់ សំរាប់មួយរយៈពេលមានកំណត់ ។ សភាត្រូវផ្តល់ការយល់ព្រមលើក្រឹត្យ-ច្បាប់ទាំងនេះនៅសម័យប្រជុំបន្ទាប់ ។ បើមិនបានទទួលសច្ចាប័នទេក្រឹត្យ-ច្បាប់ទាំងនោះត្រូវជំរុះចោល ។

៥-ការពិភាក្សាជាថ្មី

ក្នុងរយៈពេលប្រកាសឱ្យប្រើ (៣០ថ្ងៃចាប់ពីពេលបញ្ជូនអត្ថបទ) ប្រធានាធិបតីនៃសាធារណរដ្ឋអាចស្នើសភាឱ្យពិនិត្យអត្ថបទនៅផ្នែកណាមួយ ឬទាំងស្រុងជាថ្មីឡើងវិញ ឬស្នើតុលាការធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាព ។

អត្ថបទត្រូវអនុម័តតាមសម្លេងភាគច្រើន៧/៤នៃសមាជិកសភានីមួយៗ ។

៦-បទឃ្លាញត្តិដោយឡែកសំរាប់ច្បាប់អង្គការ

ច្បាប់អង្គការត្រូវអនុម័តតាមសម្លេងភាគច្រើន២/៣ នៃសមាជិកព្រឹទ្ធសភាវត្តមាន ឬដោយតំណាង បើសិនជាសម្លេងនេះមិនតិចជាងចំនួនភាគច្រើនដាច់ខាតនៃសមាជិកព្រឹទ្ធសភាទាំងអស់ ។ តុលាការធម្មនុញ្ញត្រូតពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់អង្គការ ដែលប្រធានាធិបតីស្នើសុំ ។

៧-ការអនុម័តថវិកា

បើរដ្ឋសភាមិនបានអនុម័តថវិកាទាន់ថ្ងៃ៣១ខែធ្នូ រដ្ឋាភិបាលអាចប្រើជាបណ្តោះអាសន្នមួយភាគដប់ពីរនៃថវិកាឆ្នាំចាស់ ។

តាមសំណើរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ សភាប្រជុំជាសមាជក្នុងរយៈពេល១៥ថ្ងៃ ដើម្បីពិនិត្យសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុឡើងវិញ ។

បើសិនជាសភាមិនបានអនុម័តថវិកានៅដំណាច់សម័យប្រជុំ ថវិកាត្រូវរៀបចំជាស្ថាពរដោយក្រឹត្យ-ច្បាប់របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ។

ខ-អំណាចត្រួតពិនិត្យ

ព្រឹទ្ធសភាមានអំណាចត្រួតពិនិត្យដូចរដ្ឋសភា លើកលែងតែការអនុម័តញត្តិបន្ទោស ឬញត្តិដកសេចក្តីទុកចិត្ត ។ ប៉ុន្តែរដ្ឋធម្មនុញ្ញបានផ្តល់នូវសមត្ថកិច្ចពិសេសមួយចំនួនដល់ព្រឹទ្ធសភា ។

១-ការពិភាក្សា

ព្រឹទ្ធសភាអាចពិភាក្សាលើសកម្មភាពនិងលើនយោបាយរបស់រដ្ឋាភិបាល ។

២-សំណួរ

សមាជិកព្រឹទ្ធសភាអាចដាក់សំណួរផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរដល់សមាជិករដ្ឋាភិបាលដើម្បីឱ្យផ្តល់ព័ត៌មានអំពីសកម្មភាពរបស់ខ្លួន ។

ក្នុងសម័យប្រជុំ មានកម្មវិធីជាអាទិភាពប្រចាំសប្តាហ៍សំរាប់សំណួរ និងចម្លើយ ។ រដ្ឋាភិបាលត្រូវតែផ្តល់នូវការពន្យល់ទាំងអស់តាមសំណើ លើការគ្រប់គ្រង និងសកម្មភាពនានា ។

៣-ការត្រួតពិនិត្យថវិកា

តុលាការគណនី ជួយសភាក្នុងការងារត្រួតពិនិត្យការអនុវត្តថវិកា ។ តុលាការគណនីផ្តល់នូវរបាយការណ៍អំពីប្រក្រតីភាពនៃគណនីទូទៅរបស់រដ្ឋ និងលើភាពត្រឹមត្រូវនៃការប្រើប្រាស់មូលនិធិតាមនីតិវិធីជាធរមាននិងតាមថវិកាដែលសភាបានអនុម័ត ។

៤-គណៈកម្មការស៊ើបអង្កេត

ព្រឹទ្ធសភាអាចបង្កើតគណៈកម្មការអង្កេតលើកម្មវត្ថុមួយជាក់លាក់ នៃសកម្មភាពរបស់រដ្ឋាភិបាល ។

៥-ការត្រួតពិនិត្យលើការការពារ និងការងារសន្តិសុខ

ក-ការរក្សាសន្តិសុខនិងការការពារជាតិស្ថិតក្រោមការត្រួតពិនិត្យរបស់សភា ។

៥-គណៈកម្មការចំពោះកិច្ច របស់សភាមានភារកិច្ចត្រួតពិនិត្យមើលការងារសន្តិសុខ និងការងារការពារជាតិ ។

៦-ការងារព័ត៌មាន

ក-វិស័យការពារ និងសន្តិសុខ

១-ក្នុងករណីប្រើប្រាស់កងកម្លាំងប្រដាប់អាវុធដើម្បីការពារជាតិ ពង្រឹងសណ្ដាប់ធ្នាប់និងសន្តិសុខសាធារណៈ ឬការបំពេញកាតព្វកិច្ច ឬការសន្យាអន្តរជាតិ ប្រធានាធិបតីនៃសាធារណរដ្ឋផ្ដល់ព័ត៌មានយ៉ាងឆាប់រហ័ស និងយ៉ាងលម្អិតដល់សភាអំពីមូលហេតុ ទីកន្លែង និងរយៈពេលនៃការប្រើប្រាស់ ។

នៅក្រៅសម័យប្រជុំ សភាត្រូវកោះប្រជុំជាវិសាមញ្ញ ក្នុងរយៈពេល៧ថ្ងៃក្រោយការប្រើប្រាស់កម្លាំង ។

២-ព្រឹទ្ធសភា ឬរដ្ឋសភាត្រូវបានព័ត៌មាន ក្នុងរយៈពេល៧ថ្ងៃយ៉ាងយូរ អំពីការចូលរួមនៃកងកម្លាំងក្នុងប្រតិបត្តិការការពារសន្តិភាពក្នុងពិភពលោក ។

៤-ក្រុមប្រឹក្សាជាតិបង្កើតដើម្បីឱ្យប្រជាជនចូលរួមក្នុងការងារសាធារណៈ

-ក្រុមប្រឹក្សាជាតិដើម្បីឯកភាពជាតិ និងសម្រុះសម្រួល

-ទីតាំងជាតិសំរាប់បម្ការប្រឆាំងគ្រោះប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

-ក្រុមប្រឹក្សាជាតិខាងសន្តិសុខ

-ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម

-ក្រុមប្រឹក្សាជាតិនៃតមនាគមន៍ ។

ក្រុមប្រឹក្សានីមួយ១ផ្ដល់របាយការណ៍ប្រចាំឆ្នាំដល់ប្រធានាធិបតី ដល់រដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា ។

គ-អ្នកការពារប្រជាជនរាយការណ៍ប្រចាំឆ្នាំដល់រដ្ឋសភានិងព្រឹទ្ធសភា ។

ឃ-ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមរាយការណ៍ប្រចាំឆ្នាំអំពីស្ថានភាពខាងវិស័យយុត្តិ-ធម៌ ដល់រដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា ។

៧-អំណាចត្រួតពិនិត្យពិសេសរបស់ព្រឹទ្ធសភា

អំណាចនេះត្រូវបានផ្តល់ឱ្យព្រឹទ្ធសភា ដោយមានគោលបំណងការពារសមធម៌នៃការបែងចែកមុខតំណែងសាធារណៈរវាងជនជាតិ ក្រុម ភេទ និងតំបន់នានា ស្របតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ។

ក-ព្រឹទ្ធសភាអាចដំណើរការស៊ើបអង្កេតក្នុងរដ្ឋបាលសាធារណៈ និងដាក់ចេញនូវអនុសាសន៍ដើម្បីធានានូវផលប្រយោជន៍របស់គ្រប់តំបន់ គ្រប់ក្រុមពីសេវាសាធារណៈ ។

ខ-ព្រឹទ្ធសភាត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ដែលតម្រូវឱ្យមានភាពជាតំណាងជនជាតិ ភេទ និង តុល្យភាពក្នុងគ្រប់រចនាសម្ព័ន្ធ និង គ្រប់ស្ថាប័នរដ្ឋ ជាពិសេសក្នុងរដ្ឋបាលសាធារណៈ និងក្នុងអង្គភាពការពារនិងសន្តិសុខ ។

គ-ទំនាក់ទំនងជាមួយរដ្ឋាភិបាល

សមាជិករដ្ឋាភិបាលអាចចូលរួមក្នុងការប្រជុំរបស់ព្រឹទ្ធសភា ឬរដ្ឋសភា ហើយត្រូវចូលរួមរាល់ពេលដែលមានការស្នើសុំ ដោយអាចមានអ្នកជំនាញនៅអមជាមួយ ។

ឃ-ទំនាក់ទំនងជាមួយប្រធានាធិបតី

ប្រធានាធិបតីនៃសាធារណរដ្ឋទាក់ទងជាមួយសមាជិកសភា តាមរយៈសារលិខិត ដែលមិនអាចពិភាក្សាលើបាន ។

ង-មុខងារផ្តល់ប្រឹក្សា

ព្រឹទ្ធសភាផ្តល់ប្រឹក្សាដល់ប្រធានាធិបតីនៃសាធារណរដ្ឋ និងដល់ប្រធានរដ្ឋសភាលើគ្រប់បញ្ហា ជាពិសេសលើវិស័យនីតិប្បញ្ញត្តិ ។

V-បទប្បញ្ញត្តិផ្សេងៗ

ក-អំណាចតែងតាំង

ព្រឹទ្ធសភាផ្តល់ការយល់ព្រមលើការតែងតាំងឱ្យកាន់មុខតំណែងដូចតទៅ:

ប្រធានអង្គភាពការពារ និងសន្តិសុខ អភិបាលខេត្ត រដ្ឋទូត អ្នកការពារប្រជាជន សមាជិកនគ្គមក្រុមប្រឹក្សានៃអង្គចៅក្រម សមាជិកតុលាការកំពូល សមាជិកតុលាការធម្មនុញ្ញ អគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋ និងចៅក្រមនៃមហាអយ្យការនៃសាធារណរដ្ឋ ប្រធានសាលានគ្ទរណ៍និងប្រធានតុលាការរដ្ឋបាល អគ្គរដ្ឋអាជ្ញាអមសាលានគ្ទរណ៍ ប្រធានតុលាការជាន់ខ្ពស់ ប្រធានតុលាការពាណិជ្ជកម្ម ប្រធានតុលាការការងារ រដ្ឋអាជ្ញានៃសាធារណរដ្ឋ សមាជិកគណៈកម្មការជាតិ ជ្រើសរើសមន្ត្រីក្រឹត ។

ប្រធានាធិបតីនៃសាធារណរដ្ឋដំណើរការតែងតាំងឱ្យកាន់មុខតំណែងទាំងនេះ ក្រោយបានការយល់ព្រមពីព្រឹទ្ធសភា លើកលែងតែការតែងតាំងអ្នកការពារប្រជាជន(ombudsman) ដែលរដ្ឋសភាជាអ្នកតែងតាំង តាមសម្លេងភាគច្រើន៧ ៤ បន្ទាប់ពីព្រឹទ្ធសភាបានយល់ព្រមលើឈ្មោះដែលបានស្នើ ។

ខ-ការស្នើរដ្ឋធម្មនុញ្ញ

១-ការផ្ទេរផ្តើមគំនិត

ប្រធានាធិបតីនៃសាធារណរដ្ឋ ក្រោយពីបានពិគ្រោះជាមួយរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភាមានសិទ្ធិផ្ទេរផ្តើមគំនិតស្នើរដ្ឋធម្មនុញ្ញ តាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកសភានីមួយៗ ។

២-នីតិវិធី

សេចក្តីព្រាងឬសេចក្តីស្នើវិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវអនុម័ត តាមសម្លេងភាគច្រើន៤/៥ នៃសមាជិករដ្ឋសភា និងតាមសម្លេងភាគច្រើន២/៣នៃសមាជិកព្រឹទ្ធសភា ។

ប្រធានាធិបតីនៃសាធារណរដ្ឋអាចដាក់សេចក្តីព្រាងវិសោធនកម្មរដ្ឋធម្មនុញ្ញជូនប្រជាជនធ្វើប្រជាមតិ ។

ការស្នើរើមិនត្រូវឱ្យប៉ះពាល់ដល់ឯកភាពជាតិ សម្ព័ន្ធភាពជនជាតិប្ដូរនន្ធ ត្រហាវាសកម្ម(laicité de l'Etat) ការសម្រុះសម្រួល ប្រជាធិបតេយ្យ បូរណភាពទឹកដីនៃសាធារណរដ្ឋ ។

ត-ការត្រួតពិនិត្យធម្មនុញ្ញភាព និងការបកស្រាយរដ្ឋធម្មនុញ្ញ

១-របៀបត្រួតពិនិត្យ

ក-ត្រូវធ្វើការត្រួតពិនិត្យធម្មនុញ្ញភាព ច្បាប់អង្គការ មុនប្រកាសឱ្យប្រើ និងបទបញ្ជាផ្ទៃក្នុងរដ្ឋសភានិងព្រឹទ្ធសភា មុនដាក់ឱ្យអនុវត្ត ។

ខ-ការត្រួតពិនិត្យធ្វើតាមសំណើរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា សមាជិករដ្ឋសភា ឬព្រឹទ្ធសភាចំនួនមួយភាគបួន ឬអ្នកការពារប្រជាជន ។

កាលណាតុលាការធម្មនុញ្ញប្រកាសថា កាតព្វកិច្ចអន្តរជាតិណាមួយមានបញ្ញត្តិផ្ទុយនឹងរដ្ឋធម្មនុញ្ញ ការអនុញ្ញាតឱ្យផ្តល់សច្ចាប័នអាចធ្វើបានតែនៅក្រោយវិសោធនកម្ម ឬការសើរើរដ្ឋ - ធម្មនុញ្ញ ។

តុលាការអាចពិនិត្យធម្មនុញ្ញភាពនៃច្បាប់ តាមសំណើរបស់រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានផលប្រយោជន៍ និងរបស់ក្រសួងសាធារណៈ ។

២-តុលាការធម្មនុញ្ញមានសមត្ថកិច្ចបកស្រាយរដ្ឋធម្មនុញ្ញ តាមសំណើរបស់ប្រធានាធិប-តីនៃសាធារណរដ្ឋ ប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា ឬសមាជិករដ្ឋសភា ឬព្រឹទ្ធសភាចំនួនមួយភាគបួន ។

ឃ-ប្រជាមតិ

ប្រធានាធិបតីនៃសាធារណរដ្ឋ ក្រោយពីបានពិគ្រោះជាមួយបណ្តាអនុប្រធានាធិបតីនៃសាធារណរដ្ឋ ប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភាអាចដាក់ឱ្យធ្វើប្រជាមតិនូវគ្រប់សេចក្តីព្រាងអត្ថបទធម្មនុញ្ញ អត្ថបទច្បាប់ដែលអាចមានផលអវិជ្ជមានធ្ងន់ធ្ងរដល់ជីវិត និងអនាគតរបស់ប្រជាជាតិ ឬដល់ចរិតនិងដំណើរការរបស់ស្ថាប័ននៃសាធារណរដ្ឋ ។

ង-ការបង្កើតក្រុមសមាជិកសភាត្រូវហាមនៅក្នុងព្រឹទ្ធសភា ។

ច-ការប្រជុំសភាជាសមាជ

សភាទាំងពីររួមប្រជុំជាសមាជដើម្បី :

-ទទួលសារលិខិតរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ

-ទំលាក់ប្រធានាធិបតីនៃសាធារណរដ្ឋពីមុខតំណែង ចំពោះកំហុសធ្ងន់ធ្ងរ ការបំពានធ្ងន់ធ្ងរ អំពើពុករលួយ ដោយការសម្រេចចិត្ត តាមមតិភាគច្រើន២៣នៃសមាជិកសមាជ

-ចោទប្រកាន់ប្រធានាធិបតីពីបទក្បត់ ដោយការបោះឆ្នោតសម្ងាត់ តាមសម្លេងភាគច្រើន២/៣នៃសមាជិកសមាជ

-ពិនិត្យសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុឡើងវិញ

-ជ្រើសតាំងប្រធានាធិបតីនៃសាធារណរដ្ឋទី១ ក្រោយអន្តរកាល

-វាយតម្លៃការអនុវត្តកម្មវិធីរបស់រដ្ឋាភិបាល រាល់៦ខែម្តង

-ទទួលសច្ចាប្រណិធានរបស់គណៈកម្មការជាតិរៀបចំការបោះឆ្នោតឯករាជ (ដែលសមាជិកត្រូវតែងតាំងដោយក្រឹត្យ ក្រោយពីបានការយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភា។

ន-ការពិគ្រោះយោបល់

១-ការប្រកាសសង្គ្រាម

ប្រធានាធិបតីនៃសាធារណរដ្ឋប្រកាសសង្គ្រាម និងចុះហត្ថលេខាលើ armistice ក្រោយពីបានពិគ្រោះជាមួយរដ្ឋាភិបាល ការិយាល័យរដ្ឋសភានិងព្រឹទ្ធសភានិងក្រុមប្រឹក្សាសន្តិសុខជាតិ។

២-ស្ថានភាពពិសេស

កាលបើស្ថាប័ននៃសាធារណរដ្ឋ ឯករាជជាតិ បូរណភាពទឹកដី ឬការអនុវត្តកាតព្វកិច្ចអន្តរជាតិត្រូវគំរាមកំហែង ក្នុងទ្រង់ទ្រាយធ្ងន់ធ្ងរ និងបន្ទាន់ ហើយដែលដំណើរការជាប្រក្រតីនៃអំណាចសាធារណៈត្រូវអាក់ខាន ប្រធានាធិបតីនៃសាធារណរដ្ឋអាចប្រកាសដោយក្រឹត្យ-ច្បាប់នូវស្ថានភាពពិសេស និងចាត់ត្រាវិធានការដែលកាលៈទេសៈតម្រូវ ក្រោយពីបានពិគ្រោះជាមួយរដ្ឋាភិបាល ការិយាល័យរដ្ឋសភា និងព្រឹទ្ធសភា ក្រុមប្រឹក្សាសន្តិសុខជាតិ និង តុលាការធម្មនុញ្ញ។

ជ-ការតែងតាំងអនុប្រធានាធិបតីនៃសាធារណរដ្ឋ

អនុប្រធានាធិបតីទាំងអស់ ត្រូវតែងតាំងដោយប្រធានាធិបតីនៃសាធារណរដ្ឋ ក្រោយពីបានការយល់ព្រមពីរដ្ឋសភានិងព្រឹទ្ធសភាលើបេក្ខភាព ដោយការបោះឆ្នោតតាមសម្លេងភាគច្រើន ។ អនុប្រធានាធិបតីត្រូវជ្រើសរើសពីក្នុងចំណោមអ្នកជាប់ឆ្នោត។

ឈ-សមត្ថកិច្ចរបស់តុលាការយុត្តិធម៌ជាន់ខ្ពស់

តុលាការយុត្តិធម៌ជាន់ខ្ពស់មានសមត្ថកិច្ចជំនំជំរះប្រធានាធិបតីនៃសាធារណរដ្ឋ ប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា អនុប្រធានាធិបតីទាំងអស់អំពីបទឧក្រិដ្ឋ ឬមជ្ឈឹមដែលបានប្រព្រឹត្ត នៅក្នុងអាណត្តិ ។

ក្នុងករណីមានការផ្តន្ទាទោសឥស្សរជនណា ឥស្សរជននោះត្រូវដកហូតពីតំណែង ។

ញ-សមាសភាពអង្គការពារនិងសន្តិសុខ

ក្នុងរយៈពេលដែលព្រឹទ្ធសភាកំណត់ អង្គការពារ និងសន្តិសុខមិនអាចមានលើសពីហាសិបភាគរយនៃសមាជិក ក្នុងក្រុមជនជាតិពិសេសមួយ ដោយត្រូវគិតពីការធានាតុល្យភាពនៃជនជាតិ និងបង្ការនូវសកម្មភាពប្រល័យពូជសាសន៍ និងរដ្ឋប្រហារ ។

កំណត់ចំណាំ : ការវិវត្តន៍ស្ថាប័នចាប់ពីក្រោយសង្គ្រាមស៊ីវិល ។

រដ្ឋធម្មនុញ្ញឆ្នាំ២០០៥ បន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាព និងអន្តរកាល បានចែងអំពីសភាពីរ និងការផ្តល់ដល់ព្រឹទ្ធសភានូវបេសកកម្មពិនិត្យមើលការគោរពនូវរបបពហុជនជាតិ ក្នុងជីវភាពសាធារណៈ ។

ក-កិច្ចព្រមព្រៀងអារុស្សា

កិច្ចព្រមព្រៀងអារុស្សាដើម្បីសន្តិភាព និងការបង្រួបបង្រួមប៊ុ�ដែលហែកហួរជាច្រើនឆ្នាំដោយអស្ថេរភាពនយោបាយ និងសង្គ្រាមស៊ីវិល ដែលចុះហត្ថលេខាតាំងពីថ្ងៃ ២០ ខែកញ្ញា ឆ្នាំ២០០០ ដោយគ្រប់ភាគីនយោបាយត្រូវបានរដ្ឋសភាផ្តល់សច្ចាប័ន ។

កិច្ចព្រមព្រៀងសន្តិភាពបានចែងជាពិសេសនូវគោលការណ៍សំរាប់រៀបចំអនាគតស្ថាប័នរបស់ប្រទេស ។ ស្ថាប័នថ្មីរបស់ប្រទេសត្រូវរៀបចំដោយមានការរួមបញ្ចូល និងធានាឱ្យមានគ្រប់សមាសភាពក្នុងសង្គម ។ កិច្ចព្រមព្រៀងចេញនូវគោលការណ៍ទូទៅអំពីការគោរពពហុភាព នៃជនជាតិ និងសាសនា និងទទួលស្គាល់ពលរដ្ឋចាម ហ៊ីនឌូ ចាកទុតស៊ី និងបាត្តា ជាសមាសភាពរបស់សង្គមជាតិប៊ីយរុនឌី ។

កិច្ចព្រមព្រៀងចែងអំពីការបង្កើតប្រព័ន្ធសភាពីរ ហើយព្រឹទ្ធសភាមានមុខងារតំណាង

និងធានានូវលក្ខណៈពហុជនជាតិនៃសង្គមប៊ូរុនឌី ។

ក្នុងរយៈពេលអន្តរកាល មុនការរៀបចំស្ថាប័នថ្មី ព្រឹទ្ធសភាក៏នឹងត្រូវរៀបចំបង្កើតឡើងដែរ ។

ការរៀបចំអំណាចនីតិប្បញ្ញត្តិ:

I-ព្រឹទ្ធសភា

១-សមាសភាព

ព្រឹទ្ធសភាមានតំណាងខេត្តនីមួយ១២នាក់ ដែលជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាឃុំក្នុងខេត្តមកពីសហគមន៍ជនជាតិនានា ដោយការបោះឆ្នោតផ្ទៀងផ្ទាត់ ។

អតីតៈប្រធានម្នាក់មានសិទ្ធិជាសមាជិកព្រឹទ្ធសភា ។

ព្រឹទ្ធសភាអាចជ្រើសតាំងសមាជិកដោយខ្លួនឯងរហូតពីនាក់ នៃក្រុមបាតូដើម្បីធានានូវភាពជាតំណាងរបស់សហគមន៍នេះ ។

ការិយាល័យរបស់ព្រឹទ្ធសភាមានលក្ខណៈពហុជនជាតិ ។

២-សមត្ថកិច្ច

ក-អនុម័តវិសោធនកម្មរដ្ឋធម្មនុញ្ញ ច្បាប់អង្គការ និងច្បាប់បោះឆ្នោត :

-ការអនុម័តវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវយកតាមសម្លេងភាគច្រើន៤/៥នៅរដ្ឋសភា និង ២/៣នៅព្រឹទ្ធសភា

-ការអនុម័តវិសោធនកម្មច្បាប់អង្គការ ត្រូវយកតាមសម្លេងភាគច្រើន២/៣នៅរដ្ឋសភា និងដោយមានការយល់ព្រមពីព្រឹទ្ធសភា ។

ខ-ពិនិត្យរបាយការណ៍របស់អ្នកការពារប្រជាជនលើគ្រប់ទិដ្ឋភាពរដ្ឋបាលសាធារណៈ ។

គ-ដឹកនាំការស៊ើបអង្កេតក្នុងរដ្ឋបាលសាធារណៈ និងលើកអនុសាសន៍ ដើម្បីធានានូវផលប្រយោជន៍របស់តំបន់និងក្រុមពីសេវាសាធារណៈ ។

ឃ-ត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិរដ្ឋធម្មនុញ្ញ ដែលតម្រូវឱ្យមានភាពជាតំណាង ឬតុល្យភាពក្នុងសមាសភាពនៃមុខងារសាធារណៈ ឬនៃអង្គការពារ និងសន្តិសុខ ។

ក្នុងរយៈពេលដែលព្រឹទ្ធសភាកំណត់ កងទ័ពមិនអាចមានចំនួនលើសពីហាសិបភាគរយនៃសមាជិកនៃក្រុមជនជាតិពិសេសមួយឡើយ ។

ង-សង្កេតមើលថាក្រុមប្រឹក្សាឃុំមានសមាសភាពជនជាតិផ្សេងៗ ។ ក្នុងករណីជុំវិញនេះ ព្រឹទ្ធសភាអាចបញ្ជាឱ្យជ្រើសរើសសមាជិកបន្ថែម ចេញពីក្រុមដែលមានតំណាងតិច ក្នុងលក្ខខណ្ឌដែលសមាជិកបន្ថែមនោះមិនលើសពីមួយភាគប្រាំនៃសមាជិកក្រុមប្រឹក្សា ។ សមាជិកបន្ថែមត្រូវជ្រើសតាំងដោយព្រឹទ្ធសភាចេញពីបញ្ជីឈ្មោះដែលរៀបចំដោយក្រុមប្រឹក្សាឃុំឬដោយមេកុលសម្ព័ន្ធភ្នំក្នុងឃុំ ។

ច-ផ្តល់ប្រឹក្សាដល់ប្រធានាធិបតី និងប្រធានរដ្ឋសភាលើគ្រប់បញ្ហា ជាពិសេសលើការងារនីតិប្បញ្ញត្តិ ។

ឆ-ត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងអារុស្សា ។

ជ-សង្កេត ឬស្នើវិសោធនកម្មដែលទាក់ទងនឹងនីតិកម្ម ដែលរដ្ឋសភាអនុម័ត តាក់តែង និងដាក់សេចក្តីព្រាងច្បាប់ឱ្យរដ្ឋសភាអនុម័ត ។ រដ្ឋសភាត្រូវពិនិត្យសេចក្តីព្រាងវិសោធនកម្ម និងបើសិនរដ្ឋសភាយល់ព្រម វិសោធនកម្មនោះអាចមានអានុភាព មុនដាក់សុំការយល់ព្រមពីប្រធានាធិបតី ។

ឈ-អនុម័តអត្ថបទច្បាប់អំពីការកំណត់ភារកិច្ច និងអំណាចរបស់ខេត្ត ឃុំ និងភ្នំតូចៗ ។

ញ-យល់ព្រមលើការតែងតាំង:

ក-ប្រធានកម្លាំងការពារ នគរបាល និងសេវាស៊ីវិការណ៍

ខ-អភិបាលខេត្ត ដែលតែងតាំងដោយប្រធានាធិបតីនៃសាធារណរដ្ឋ

គ-អ្នកការពារប្រជាជន

ឃ-សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ង-សមាជិកតុលាការកំពូល

ច-សមាជិកតុលាការធម្មនុញ្ញ(តាមសម្លេងភាគច្រើន២/៣)

ឆ-អគ្គរដ្ឋអាជ្ញា និងចៅក្រមនៃមហាអយ្យការ

ជ-ប្រធានសាលាឧទ្ធរណ៍ និងប្រធានតុលាការរដ្ឋបាល

ឈ-អគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍

ញ-ប្រធានតុលាការជាន់ខ្ពស់ តុលាការពាណិជ្ជកម្ម និងតុលាការការងារ

ដ-រដ្ឋអាជ្ញានៃសាធារណរដ្ឋ

ឋ-អនុប្រធានាធិបតីនៃសាធារណរដ្ឋ(ចំនួនពីរនាក់) ។

រដ្ឋសភាក៏មានអំណាចនេះដែរ ។

II-ព្រឹទ្ធសភាអន្តរកាល

ក្នុងអន្តរកាលពីពាទៅ៦ខែ ចាប់ពីពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងអារុស្សា និងបញ្ចប់ដោយការបោះឆ្នោតជ្រើសរើសប្រធានាធិបតីថ្មី អង្គការនីតិប្បញ្ញត្តិអន្តរកាលមាន រដ្ឋសភា និងព្រឹទ្ធសភា :

១-សមាសភាពព្រឹទ្ធសភាអន្តរកាល

ព្រឹទ្ធសភាត្រូវបង្កើតដោយប្រធានាធិបតីនៃសាធារណរដ្ឋ និងការិយាល័យសភាដោយគោរពនូវតុល្យភាពនយោបាយ ជនជាតិ និងតំបន់ ។

ព្រឹទ្ធសភាមានជាពិសេសអតីត:ប្រមុខរដ្ឋ សមាជិកពានាក់ជាជនជាតិត្វា និងសមាជិកចេញពីរដ្ឋសភាអន្តរកាល ដែលជ្រើសរើសបន្ថែមដោយប្រធានាធិបតីនៃសាធារណរដ្ឋ និងការិយាល័យរដ្ឋសភាអន្តរកាល ។ ពុំមានការជំនួសសមាជិករដ្ឋសភាអន្តរកាលដែលត្រូវជ្រើសរើសទៅជាសមាជិកព្រឹទ្ធសភាអន្តរកាលទេ ។

២-សមត្ថកិច្ចរបស់ព្រឹទ្ធសភាអន្តរកាល

ព្រឹទ្ធសភាអន្តរកាលបំពេញមុខងារដែលមានចែងឡាយ់ក្នុងគោលការណ៍ធម្មនុញ្ញដូចមានក្នុងកិច្ចព្រមព្រៀង ។

៣-ការអនុម័តរដ្ឋធម្មនុញ្ញ

រដ្ឋសភានិងព្រឹទ្ធសភាអន្តរកាលអនុម័តរដ្ឋធម្មនុញ្ញ ក្នុងរយៈពេល១៨ខែតាមសម្លេងភាគច្រើន២៣ ស្របតាមគោលការណ៍នៃជំពូកទី១ នៃកិច្ចព្រមព្រៀងអារុស្សា ។

ខ-រដ្ឋធម្មនុញ្ញអន្តរកាល

ព្រឹទ្ធសភាអន្តរកាល:

១-បទប្បញ្ញត្តិធម្មនុញ្ញ

សមាជិកព្រឹទ្ធសភាមានយ៉ាងច្រើន៥៤នាក់ តែងតាំងដោយប្រធានាធិបតីនៃសាធារណរដ្ឋ អនុប្រធានាធិបតី និងការិយាល័យរដ្ឋសភាអន្តរកាលដោយគោរពសមធម៌នៃជនជាតិ និងនយោបាយ ។

ព្រឹទ្ធសភាមានអតីតៈប្រមុខរដ្ឋ ជនជាតិ៣នាក់ និងសមាជិក២នាក់ ពីខេត្តនីមួយៗ ។

ព្រឹទ្ធសភាយល់ព្រមលើការតែងតាំងមន្ត្រីជាន់ខ្ពស់នៃសេវាការពារយុត្តិធម៌ (ចៅក្រមតុលាការកំពូល សមាជិក៧នាក់នៃតុលាការធម្មនុញ្ញ) និងអភិបាលខេត្ត ។

សភាប្រជុំ៣ដងក្នុងមួយឆ្នាំជាសាមញ្ញ និងអាចកោះជាវិសាមញ្ញយ៉ាងឆាប់ដោយក្រិត្យរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ។ ប្រធាន និងអនុប្រធានព្រឹទ្ធសភា(ឬរដ្ឋសភា) ត្រូវតែចេញមកពីក្រុមនយោបាយផ្សេងគ្នា ។

២-សមាជិកព្រឹទ្ធសភាអន្តរកាល៥៣នាក់ត្រូវតែងតាំងនៅថ្ងៃ២៥ មករា ២០០២ ។

វិសោធនកម្មរដ្ឋធម្មនុញ្ញដែលប្រកាសឱ្យប្រើនាខែមីនា ឆ្នាំ១៩៩៩ បានបង្កើតព្រឹទ្ធសភាម្តើងវិញ ។

I-សមាសភាព

ចំនួនសមាជិកព្រឹទ្ធសភាមានយ៉ាងច្រើនស្មើនឹងពាក់កណ្តាលចំនួនសមាជិករដ្ឋសភា ។

-ចំនួនសមាជិកព្រឹទ្ធសភា :៦១រូប

- ២រូប ជ្រើសតាំងដោយព្រះមហាក្សត្រ

-២រូបជ្រើសរើសដោយរដ្ឋសភា តាមសម្លេងភាគច្រើនដោយប្រៀប

-៥៧រូប ជ្រើសរើសដោយការបោះឆ្នោតអសកល ។

នៅនីតិកាលទី១ សមាជិកទាំង៦១រូបត្រូវបានតែងតាំងដោយព្រះមហាក្សត្រ ។

II-របបបោះឆ្នោត

ប្រព័ន្ធ : អសកល សមាមាត្រ មធ្យមភាគខ្ពស់បំផុត

មណ្ឌល : ភូមិភាគ(ទាំងអស់មាន៨)

អាណត្តិ : ៦ឆ្នាំ (នីតិកាលទី១ អាណត្តិ៥ឆ្នាំ)

អាយុ : ៤០ឆ្នាំ សញ្ជាតិកម្ពុជាពីកំណើត

អង្គបោះឆ្នោត :សមាជិករដ្ឋសភា និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង តាមមណ្ឌល

ចំនួនអាសនៈតាមមណ្ឌល : ត្រូវព្រឹទ្ធសភាកំណត់មុនពេលបោះឆ្នោត ។

III-សម័យប្រជុំ

ក-សម័យប្រជុំដំបូង : ៦០ថ្ងៃយ៉ាងយូរក្រោយថ្ងៃបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ

ខ-សម័យប្រជុំសាមញ្ញ : ២ ក្នុងមួយឆ្នាំ (៣ខែយ៉ាងតិចក្នុងមួយសម័យប្រជុំ)

គ-សម័យប្រជុំវិសាមញ្ញ : តាមសំណូមពររបស់ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ឬសមាជិកព្រឹទ្ធ-សភា មួយភាគបីយ៉ាងតិច ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភា និងអំណាចនីតិប្រតិបត្តិ

រដ្ឋធម្មនុញ្ញបង្កើតប្រព័ន្ធសភាពីរ វិសមភាព ។

ក-អំណាចនីតិប្បញ្ញត្តិ

១-សិទ្ធិផ្តើមគំនិតធ្វើច្បាប់ : មាន (ដូចសមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រី)

សេចក្តីស្នើច្បាប់របស់ព្រឹទ្ធសភា ត្រូវផ្ញើជូនរដ្ឋសភាដោយគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ក្រោយពីគណៈកម្មការជំនាញណាមួយបានពិនិត្យរួច ។

២-សិទ្ធិវិសោធនកម្ម

រដ្ឋធម្មនុញ្ញចែងមិនបានច្បាស់អំពីសិទ្ធិវិសោធនកម្មរបស់ព្រឹទ្ធសភាទេ ។ ប៉ុន្តែ រដ្ឋ-ធម្មនុញ្ញបានទទួលស្គាល់សិទ្ធិ" កែប្រែ" អត្ថបទដែលដាក់ឱ្យពិនិត្យ ស្របតាមមាត្រា១១៣ថ្នាក់នៃរដ្ឋធម្មនុញ្ញ ។ អត្ថបទកែប្រែនេះ ត្រូវបញ្ជូនទៅរដ្ឋសភាដើម្បីពិនិត្យឡើងវិញ ។

៣-នីតិវិធី:

រយៈពេល១ខែ (៥ថ្ងៃ ក្នុងករណីប្រញាប់) ព្រឹទ្ធសភាផ្តល់យោបល់របស់ខ្លួនលើអត្ថបទច្បាប់ ដែលរដ្ឋសភាអនុម័តលើកដំបូង ។ បើហួសរយៈពេលនេះ ព្រឹទ្ធសភាមិនបានផ្តល់យោបល់ អត្ថបទច្បាប់ត្រូវប្រកាសឱ្យប្រើ ។

បើព្រឹទ្ធសភាសុំឱ្យកែប្រែ រដ្ឋសភាត្រូវពិនិត្យភ្លាម ហើយអាចបដិសេធយោបល់នោះ ឬទទួលយកមួយផ្នែក ។

បើព្រឹទ្ធសភាបដិសេធអត្ថបទច្បាប់ ឬសុំឱ្យកែប្រែ រដ្ឋសភាត្រូវពិនិត្យជាលើកទី២ និងអនុម័តតាមសម្លេងភាគច្រើនដាច់ខាត ។

រយៈពេលនៃការបញ្ជូនទៅ-មករវាងរដ្ឋសភានិងព្រឹទ្ធសភាមាន១ខែ ។

អត្ថបទដែលដាក់ជូនព្រឹទ្ធសភា ត្រូវតែបានពិនិត្យជាមុនដោយគណៈកម្មការជំនាញណាមួយឬច្រើន ។

៤-អំណាចត្រួតពិនិត្យ

រដ្ឋធម្មនុញ្ញមិនបានចែងអំពីអំណាចត្រួតពិនិត្យរបស់ព្រឹទ្ធសភាទេ ។

ค-អំណាចសម្រេច

រដ្ឋសភា និងព្រឹទ្ធសភាអាចប្រជុំជាសមាជ ដើម្បីសម្រេចបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ។

V-**មធម្យញ្ញត្តិរដ្ឋនៅ**

ក-សមត្ថកិច្ចរបស់ប្រធានព្រឹទ្ធសភា

១-ប្រធានព្រឹទ្ធសភាទទួលជាប្រមុខរដ្ឋស្តីទី ក្នុងករណីព្រះមហាក្សត្រអវត្តមាន អសមត្ថភាព ឬសោយទីវង្គត ។

២-ប្រធានព្រឹទ្ធសភាជាសមាជិកក្រុមប្រឹក្សាព្រះរាជបល្ល័ង្ត ។

៣-ប្រធានព្រឹទ្ធសភាផ្តល់ការយល់ព្រមដល់ការប្រកាសអាសន្ន ដោយព្រះមហាក្សត្រ ។

ខ-ការប្រកាសសង្ត្រាម

ព្រឹទ្ធសភាផ្តល់ការយល់ព្រមដល់ការប្រកាសសង្ត្រាម ដោយព្រះមហាក្សត្រ ។

គ-ប្រធានព្រឹទ្ធសភា ឬសមាជិកចំនួន១/៤ អាចបញ្ជូនអត្ថបទច្បាប់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យ មុនប្រកាសឱ្យប្រើ ។

ឃ-អំណាចជ្រើសតាំង

ព្រឹទ្ធសភាជ្រើសតាំងសមាជិក១រូបនៃអង្គប្រឆាំងអំពើពុករលួយ ។

កាណាដា	**ព្រឹទ្ធសភា**
CANADA	LE SENAT

I-សមាសភាព

ព្រឹទ្ធសភាកាណាដាមានសមាជិក១០៥នាក់ តែងតាំងដោយអគ្គទេសាភិបាល តាមសំណើរបស់នាយករដ្ឋមន្ត្រី និងបែងចែកទៅតាមតំបន់ ។

សមាជិកព្រឹទ្ធសភាកាន់តំណែងរហូតដល់អាយុ៧៥ឆ្នាំ ។

តំណាងតាមតំបន់ :

-សមាជិក២៤នាក់ សំរាប់តំបន់ទីមួយ១នៃតំបន់ទាំង៤ អុងតារីយ៉ូ ក្បិក ខេត្តជាប់សមុទ្រ ខេត្តបស្ចឹម

-សមាជិក៦នាក់ សំរាប់តំបន់ដីថ្ម

-សមាជិក១នាក់ សំរាប់ដែនដីពាយព្យ

-សមាជិក១នាក់ សំរាប់យូកុន

-សមាជិក១នាក់ សំរាប់នូណាវុត ពីឆ្នាំ១៩៩៩ ។

រដ្ឋធម្មនុញ្ញអនុញ្ញាតឱ្យរដ្ឋាភិបាល ដោយមានការយល់ព្រមពីមហាក្សត្រ បន្ថែមជាបណ្តុះអាសន្ននូវអាសនៈព្រឹទ្ធសភាពី៤ទៅ៨ ។រដ្ឋាភិបាលអាចប្រើវិធីពិសេសនេះសំរាប់ដោះស្រាយភាពទាល់ច្រកខាងនីតិកម្ម (រហូតដល់សព្វថ្ងៃមានប្រើវិធាននេះតែម្តងគត់) ។

អាយុយ៉ាងតិច : ៣០ឆ្នាំ

ប្រធានព្រឹទ្ធសភាត្រូវតែងតាំងដោយអគ្គទេសាភិបាល តាមសំណើរបស់នាយករដ្ឋមន្ត្រី ។

II-របបផ្ទៃសណ្ឋាន

(ស្ថាន)

III-របបប្រជុំ

ប្រធានព្រឹទ្ធសភាកោះប្រជុំព្រឹទ្ធសភា ។ តាមបទបញ្ជាផ្ទៃក្នុង ព្រឹទ្ធសភាអាចប្រជុំពី

ថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ។ ជាធម្មតា ព្រឹទ្ធសភាប្រជុំថ្ងៃអង្គារ ពុធ និងព្រហស្បតិ៍ ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

តាមច្បាប់ ព្រឹទ្ធសភាមានអំណាចស្មើនឹងរដ្ឋសភា លើកលែងតែក្នុងវិស័យហិរញ្ញវត្ថុ និងធម្មនុញ្ញ ។

ក-អំណាចនីតិប្បញ្ញត្តិ

១-ការផ្តួចផ្តើមគំនិតធ្វើច្បាប់

សមាជិកព្រឹទ្ធសភាមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ លើកលែងតែវិស័យហិរញ្ញវត្ថុសាធារណៈដែលជាសិទ្ធិរបស់រដ្ឋាភិបាល និងរបស់រដ្ឋសភា ។

២-សិទ្ធិធ្វើវិសោធនកម្ម

សមាជិកព្រឹទ្ធសភាមានសិទ្ធិធ្វើវិសោធនកម្ម ប៉ុន្តែក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ វិសោធនកម្មអាចទទួលយកបាន លុះត្រាតែមានការបន្ថយអាករ ពន្ធ ឬចំណាយសាធារណៈ ។ វិសោធនកម្មណាដែលបន្ថែមអាករ ពន្ធ ឬ ចំណាយសាធារណៈមិនអាចទទួលយកបានទេ ។

៣-នីតិវិធី

អត្ថបទទាំងអស់ត្រូវតែអនុម័តដោយព្រឹទ្ធសភា និងរដ្ឋសភា ។

ក-នីតិវិធីធម្មតា

សេចក្តីព្រាងច្បាប់អាចបញ្ជូនមកព្រឹទ្ធសភា ឬរដ្ឋសភា ។ ក្នុងសភានីមួយៗ នីតិវិធីមានលំដាប់លំដោយដូចតទៅ :

-ការអានលើកទី១ : ការទទួល ការអាន និងការចែកអត្ថបទ

-ការអានលើកទី២ : ពិនិត្យជាគោលការណ៍លើអត្ថបទ

-ការបញ្ជូនអត្ថបទទៅឱ្យគណៈកម្មការជំនាញពិនិត្យគ្រប់មាត្រា ក្រោយពីបានធ្វើសវនកម្មដែលចាំបាច់ និងអនុម័តរបាយការណ៍ដែលមានឬគ្មានវិសោធនកម្ម ។

-ការអានលើកទី៣: ពិភាក្សាក្នុងសម័យប្រជុំពេញអង្គលើរបាយការណ៍របស់គណៈកម្ម-

ការ ។ សភាអាចយល់ព្រម កែសម្រួល លើកទៅពេលក្រោយ ឬបដិសេធ ។

-ពេលអនុម័តរួច អត្ថបទត្រូវបញ្ជូនទៅសភាមួយទៀត ។ តាមទ្រឹស្តី ក្នុងករណីដែលការមិនព្រមព្រៀងគ្នានៅបន្ត សន្និសីទនៃសភាទាំងពីរដែលមានតំណាងសភាទាំងពីរជាសមាជិកអាចកោះប្រជុំ ។ ក្នុងការអនុវត្ត វិធីនេះកម្រមានប្រើណាស់ ។ ជាក់ស្តែង សេចក្តីព្រាងវិសោធនកម្ម អាចបញ្ជូនទៅមករហូតមានការព្រមព្រៀង ឬរហូតបោះបង់ចោលអត្ថបទច្បាប់ ។

ខ-បទឫញ្ញត្តិដោយឡែក

១-សេចក្តីព្រាងច្បាប់ផលប្រយោជន៍ឯកជន ដែលពលរដ្ឋលើកឡើងត្រូវដាក់ឱ្យព្រឹទ្ធ-ភា ។ សេចក្តីព្រាងនោះគួសបញ្ជាក់អំពីការខ្វះខាតរបស់ច្បាប់ ។

២-សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុត្រូវសិក្សាជាដំបូងនៅរដ្ឋសភា ។

ព្រឹទ្ធសភាមានសិទ្ធិធ្វើវិសោធនកម្ម ប៉ុន្តែសំរាប់តែបន្ថយអាករ ពន្ធ ឬចំណាយសាធារណៈ ។

ខ-អំណាចត្រួតពិនិត្យ

១-ការទទួលខុសត្រូវរបស់រដ្ឋាភិបាល

ព្រឹទ្ធសភាមិនអាចចាប់កំហុស រដ្ឋាភិបាលលើការទទួលខុសត្រូវទេ ។រដ្ឋសភាតែឯងអាចអនុម័តផ្តល់ការទុកចិត្ត ក្នុងកាលៈទេសៈខ្លះ ។

២-តួនាទីសំខាន់របស់គណៈកម្មការនានារបស់ព្រឹទ្ធសភា

ក្រុមដែលមានសមាជិកព្រឹទ្ធសភាពី១២ ទៅ១៥នាក់ ទទួលភារកិច្ចពិនិត្យស៊ីជំរៅ លើបញ្ហាធំៗដែលមានប្រយោជន៍ជាសាធារណៈ លើកឡើងនូវអនុសាសន៍ និងពិនិត្យលើចំណាយរបស់រដ្ឋាភិបាល បន្ថែមពីលើមុខងារនីតិឫញ្ញត្តិរបស់ខ្លួន ។

គណៈកម្មការអចិន្ត្រៃយ៍នីមួយៗមានលក្ខណៈជាជំនាញ ។

គណៈកម្មការធ្វើសវនកម្មជាមួយរដ្ឋមន្ត្រី មន្ត្រី អ្នកជំនាញ ... និងទទួលបាននូវសំណុំរឿង និងឯកសារនានា។

៣-អំណាចរបស់ព្រឹទ្ធសភាក្នុងការស៊ើបអង្កេត

គណៈកម្មការអចិន្ត្រៃយ៍នីមួយៗរបស់ព្រឹទ្ធសភាអាចធ្វើការស៊ើបអង្កេត និងធ្វើរបាយ-

ការណ៍ លើគ្រប់បញ្ហាដែលព្រឹទ្ធសភាប្រគល់ឱ្យ ។

៤-សំណូរ

សំណូរអាចលើកឡើងនៅពេលប្រជុំប្រចាំថ្ងៃ ។ សមាជិកព្រឹទ្ធសភាម្នាក់អាចដាក់សំណូរ ដោយមិនឱ្យដឹងមុន ទៅសមាជិកព្រឹទ្ធសភាដែលជាសមាជិករដ្ឋាភិបាល ឬទៅប្រមុខរដ្ឋាភិបាល ឬទៅប្រធានគណៈកម្មការរបស់ព្រឹទ្ធសភា ។ ចម្លើយអាចតម្រូវឱ្យផ្តល់ជាលាយលក្ខណ៍អក្សរ ។ ប្រមុខរដ្ឋាភិបាលមានមុខងារឆ្លើយនៅកម្មវិធីសំណូរ និងធានានូវដំណើរការនៃវិធានការ ដែលជាគំនិតផ្តើមរបស់រដ្ឋាភិបាល ។ ប្រមុខនេះអាចចូលរួមក្នុងគ្រប់គណៈកម្មការរបស់ព្រឹទ្ធសភា ។

V-បទប្បញ្ញត្តិដោយឡែក

អំណាចក្នុងការកែប្រែរដ្ឋធម្មនុញ្ញ :

មានការបែងចែកគ្នារវាងការកែប្រែ ដែលមិនប៉ះពាល់ដល់អំណាចសហព័ន្ធ និងការកែប្រែដែលប៉ះពាល់ព្រមគ្នាដល់អំណាចសហព័ន្ធ និងអំណាចរបស់ខេត្តនានា ។

ករណីទី១-ត្រូវមានការព្រមព្រៀងពីព្រឹទ្ធសភានិងផ្តើមគំនិតដោយសភា ។

ករណីទី២-គំនិតផ្តើមនៃនីតិវិធីជាសិទ្ធិរបស់ព្រឹទ្ធសភា រដ្ឋសភា និងសភានីតិប្បញ្ញត្តិនៃខេត្តនានា ។

I.សមាសភាព

ព្រឹទ្ធសភាឈីលីមានសមាជិកចំនួន ៣៨នាក់ ជ្រើសរើសដោយការបោះឆ្នោត ដោយផ្ទាល់ ក្នុងតំបន់ទាំង ១៣ ។

ការសើរើរដ្ឋធម្មនុញ្ញខែសីហាឆ្នាំ២០០៥ បានលប់ចោលសមាជិកព្រឹទ្ធសភាពីរប្រភេទ ដែលមានក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៨០ :

-សមាជិកតែងតាំង៩នាក់ (អតីតសមាជិកតុលាការកំពូល២នាក់ អតីតអគ្គ:ត្រួតពិនិត្យនៃសាធារណរដ្ឋ១នាក់ អតីត:នាយអគ្គសេនាធិការ១នាក់នៃកងទ័ពទាំងបីគឺ ជើងគោក អាកាស និងសមុទ្រ អតីតសាកលវិទ្យាធិការនៃសាកលវិទ្យាល័យ១នាក់ អតីតរដ្ឋមន្ត្រី១នាក់..) ។

-សមាជិកព្រឹទ្ធសភាក្នុងតំណែងមួយជីវិត ដែលជាអតីត:ប្រមុខរដ្ឋនៃសាធារណរដ្ឋ ដែលកាន់តំណែង៦ឆ្នាំជាប់ៗគ្នាមិនដាច់ ។

II.របបជ្រើសរើស

ប្រទេសចែកជា១៥មណ្ឌលពហុនាម ត្រូវនឹង១៣តំបន់ លើកលែងតែមណ្ឌល៦ ដែលចែកជាពីរ:

-៧ មាន២អាសន:

-៦តំបន់មាន៤អាសន:(ចែកជាពីរស្រុក-districts ស្រុកមួយមាន២អាសន:) ។

របៀបបោះឆ្នោត :

ការបោះឆ្នោតយកតាមសម្លេងភាគច្រើនលើបញ្ជីជាកញ្ចប់(scrutin majorité à listes bloquées) ដែលបែងចែកអាសន:តាមប្រព័ន្ធ D'Hondt ។ ក្នុងមណ្ឌលនីមួយៗ អ្នកជាប់ឆ្នោតគឺ បេក្ខជនពីរនាក់ក្នុងបញ្ជីតែមួយ លើបញ្ជីនោះបានទទួលសម្លេងយ៉ាងតិច២ដងលើសបញ្ជីដែលបានសម្លេងបន្ទាប់ ។ ករណីផ្ទុយពីនេះ បេក្ខជន១នាក់នៃបញ្ជីនីមួយៗដែលបានសម្លេងច្រើន ត្រូវបានតែងតាំង ។

-លក្ខខណ្ឌអាយុ: ៤០ ឆ្នាំ

-អាណត្តិ : ៨ឆ្នាំ ប្តូរថ្មីចំនួនពាក់កណ្តាលរាល់៤ឆ្នាំ អាស្រ័យតាមលេខរៀងតំបន់ (សេស ឬគត់តួរូមនឹងតំបន់ទីក្រុង ។

-ការផ្ទាស់ប្តូរចុងក្រោយ : ១១ ធ្នូ ២០០៥ ។

III-រមបម្រជុំ

ក-សម័យប្រជុំសាមញ្ញ

ព្រឹទ្ធសភាឈឺលឺមានមួយសម័យប្រជុំក្នុងមួយឆ្នាំ ពីថ្ងៃទី២១ឧសភា ដល់ថ្ងៃ១៨កញ្ញា ។

ខ-សម័យប្រជុំវិសាមញ្ញ

ប្រធានាធិបតីនៃសាធារណរដ្ឋអាចកោះប្រជុំសមាជសភាជាវិសាមញ្ញដើម្បីពន្យារសម័យប្រជុំសាមញ្ញ រយៈពេល១០ថ្ងៃ ឬក្នុងចន្លោះសម័យប្រជុំ ។

បើប្រធានាធិបតីមិនកោះប្រជុំ ប្រធានព្រឹទ្ធសភាអាចកោះប្រជុំសមាជជាវិសាមញ្ញ តាមពាក្យសុំជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខាដោយសមាជិកភាគច្រើននៃសភានីមួយៗ ។

ការកោះនេះអាចធ្វើបានតែក្នុងចន្លោះសម័យប្រជុំ ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-គំនិតផ្តួចផ្តើមធ្វើច្បាប់

សមាជិកព្រឹទ្ធសភា ឬរដ្ឋសភា (ឬក្រុមដែលមានសមាជិកព្រឹទ្ធសភាយ៉ាងច្រើន៥នាក់ ឬសមាជិករដ្ឋសភាយ៉ាងច្រើន១០នាក់) និងប្រធានាធិបតីនៃសាធារណរដ្ឋ មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ លើកលែងតែវិស័យហិរញ្ញវត្ថុសាធារណៈ រដ្ឋបាលមូលដ្ឋាន កម្លាំងប្រដាប់អាវុធ សេវាសាធារណៈថ្មី បទប្បញ្ញត្តិខ្លះនៃច្បាប់ការងារនិងសន្តិសុខសង្គម ។

មានតែព្រឹទ្ធសភាទេដែលមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ស្តីពីការលើកលែងទោស ។

២-សិទ្ធិធ្វើវិសោធនកម្ម

សមាជិកព្រឹទ្ធសភា ឬសមាជិករដ្ឋសភាមានសិទ្ធិធ្វើវិសោធនកម្ម ប៉ុន្តែវិសោធនកម្មត្រូវមានទំនាក់ទំនងផ្ទាល់ជាមួយកម្មវត្ថុនៃអត្ថបទដែលសិក្សា ។ សេចក្តីព្រាងដែលមានបំណងបង្កើតឬកែប្រែសេវាការងារ និងផលហិរញ្ញវត្ថុដែលស្នើឡើងដោយប្រធានាធិបតីនៃសាធារណរដ្ឋ មិនអាចធ្វើវិសោធនកម្មបានទេ ។ អត្ថបទនេះអាចត្រឹមតែទទួលយកឬបដិសេធទាំងស្រុង ឬមួយភាគ ។

៣-នីតិវិធី

អត្ថបទអាចបញ្ជូនមកសភាណាមួយមុនក៏បាន ។

ក-នីតិវិធីធម្មតា

សេចក្តីព្រាងច្បាប់ ត្រូវតែបានពិនិត្យជាទូទៅជាមុនដោយគណៈកម្មការមានសមត្ថកិច្ចនិងបន្តពិភាក្សាទូទៅនៅក្នុងសភា ។ បន្ទាប់មកមានការសិក្សាលំអិតក្នុងគណៈកម្មការ មុនការពិភាក្សាលំអិតក្នុងសភា ។

ពេលអនុម័តរួច អត្ថបទត្រូវបញ្ជូនទៅឱ្យសភាមួយទៀតអនុម័ត ។

បើអត្ថបទត្រូវបដិសេធដោយសភាដំបូង អត្ថបទនោះមិនអាចដាក់ឡើងវិញមុនរយៈពេលមួយឆ្នាំទេ ។

១-អត្ថបទដែលត្រូវបដិសេធទាំងស្រុងដោយសភាទី២ (ព្រឹទ្ធសភា) ត្រូវដាក់ឱ្យគណៈកម្មការចំរុះសមភាគី (រដ្ឋសភានិងព្រឹទ្ធសភា) ដែលផ្តល់នូវការណែនាំ ដើម្បីដោះស្រាយវិបត្តិ ។ អត្ថបទរបស់គណៈកម្មការចំរុះ ត្រូវដាក់ជូនសភាទី១ និងត្រូវសម្រេចតាមសម្លេងភាគច្រើននៃសមាជិកវត្តមានរបស់សភានីមួយ១ ។

បើគណៈកម្មការចំរុះមិនអាចរកការព្រមព្រៀងបាន ឬបើសភាដើមបដិសេធការព្រមព្រៀង ប្រធានាធិបតីនៃសាធារណរដ្ឋអាចស្នើសុំឱ្យសភានោះដាក់ដិសេធអត្ថបទ តាមសម្លេងភាគច្រើន២/៣នៃសមាជិកវត្តមាន បើសភាដើមនោះនៅសេក្សាដំហររបស់ខ្លួន ។ ក្នុងករណីនេះ អត្ថបទត្រឡប់ទៅព្រឹទ្ធសភាវិញដើម្បីពិនិត្យជាលើកទី២ ហើយអាចបដិសេធបានតាមសម្លេងភាគច្រើន២/៣នៃសមាជិកវត្តមាន ។

២-សេចក្តីព្រាងកែប្រែដោយព្រឹទ្ធសភាត្រឡប់ទៅសភាទី១ : ការកែប្រែត្រូវអនុម័ត ដោយរដ្ឋសភា តាមសម្លេងភាគច្រើននៃសមាជិកវត្តមាន ។

បើសេចក្តីព្រាងកែប្រែនោះត្រូវបដិសេធ គណៈកម្មការចំរុះត្រូវរួមប្រជុំ ។ ក្នុងករណីបរាជ័យឬបដិសេធការព្រមព្រៀងរបស់គណៈកម្មការចំរុះ ប្រធានាធិបតីនៃសាធារណរដ្ឋអាចស្នើសុំរដ្ឋសភាឱ្យពិនិត្យអត្ថបទឡើងវិញ នៅពេលសភាទី២ ពិនិត្យលើកទី២ ។ ការកែប្រែចាត់ថាបានអនុម័តបើសមាជិក២/៣មិនបដិសេធ ។

ប្រធានាធិបតីនៃសាធារណរដ្ឋអាចប្រកាសជាការប្រញាប់ ក្នុងនីតិវិធីទូទៅ ឬចំពោះការអានណាមួយ : សភាពាក់ព័ន្ធត្រូវសម្រេចក្នុងរយៈពេលយ៉ាង យូរ៣០ថ្ងៃ ។

គ្រប់អត្ថបទដែលសភាទាំងពីរបានអនុម័តយល់ព្រម ត្រូវដាក់ជូនប្រធានាធិបតីនៃសាធារណរដ្ឋដើម្បីប្រកាសឱ្យប្រើ បើសិនប្រធានាធិបតីយល់ព្រមលើខ្លឹមសារនៃអត្ថបទ ។

ខ-នីតិវិធីសំរាប់ច្បាប់ហិរញ្ញវត្ថុ

ប្រធានាធិបតីនៃសាធារណរដ្ឋ បញ្ជូនសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុទៅសមាជិកសភាពាក់ខែ យ៉ាងតិចមុនថ្ងៃដាក់ឱ្យអនុវត្ត ។ សេចក្តីព្រាងត្រូវបញ្ជូនឱ្យរដ្ឋសភាពិនិត្យជាលើកដំបូង ។

បើសមាជិកមិនបានពិនិត្យក្នុងរយៈពេល៦០ថ្ងៃបន្ទាប់ពេលបញ្ជូន សេចក្តីព្រាងរបស់ប្រធានាធិបតីត្រូវចូលជាធរមាន ។

សមាជិកមិនអាចបង្កើនឬបន្ថយគំរោងចំណូល ។ សមាជិកអាចត្រឹមតែបន្ថយគំរោងចំណាយ លើកលែងតែចំណាយណាដែលមានចែងក្នុងច្បាប់ជាអចិន្ត្រៃយ៍ ។

គំរោងចំណូលក្នុងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ ឬក្នុងគំរោងមួយទៀតជាសមត្ថកិច្ចផ្ទាល់មុខរបស់ប្រធានាធិបតី តាមរយៈការណ៍ដែលភ្នាក់ងារបច្ចេកទេសមានសមត្ថកិច្ចដាក់ជាប់មក ។

សមាជិកមិនអាចអនុម័តចំណាយបន្ថែម ដោយមិនបញ្ជាក់ពីចំណូលចាំបាច់ក្នុងថវិកាជាតិ ។ បើយល់ថាចំណូលនេះមិនគ្រប់គ្រាន់ទេ មុនប្រកាសឱ្យប្រើច្បាប់ ប្រធានាធិបតីនៃសាធារណរដ្ឋ តាមរយៈការណ៍គាំទ្ររបស់អង្គការដែលជាប្រភពនៃចំណូលថ្មីដែលមានហត្ថលេខាអមរបស់អគ្ន

ត្រួតពិនិត្យនៃសាធារណរដ្ឋអាចបន្ថយចំណាយទាំងអស់សមាមាត្រជាមួយនឹងចំណូល ដោយមិនគិតពីប្រភេទ ។

គ-បទប្បញ្ញត្តិដោយឡែក

សេចក្តីព្រាងច្បាប់ទាក់ទងនឹងវិភាគទានគ្រប់ប្រភេទទាក់ទងនឹងថវិកា និងការជ្រើសរើសបុគ្គលិករបស់រដ្ឋបាលសាធារណៈ ត្រូវបញ្ជូនទៅរដ្ឋសភាពិនិត្យជាលើកដំបូង ។ សេចក្តីព្រាងច្បាប់ស្តីពីការលើកលែងទោស និងអនុគ្រោះទោសត្រូវបញ្ជូនទៅព្រឹទ្ធសភាពិនិត្យជាលើកដំបូង ។

ការអនុម័ត ការកែប្រែ ឬការដាក់ជានិរាករណ៍នូវច្បាប់អង្គការត្រូវធ្វើតាមសម្លេងភាគច្រើន៧៥ ។

ឃ-សិទ្ធិជំទាស់របស់ប្រធានាធិបតី

បើប្រធានាធិបតីមិនយល់ព្រមលើអត្ថបទច្បាប់ ប្រធានាធិបតីបញ្ជូនត្រឡប់ទៅសភាដែលស្នើ ដោយសេចក្តីសម្រេចដែលមានបញ្ជាក់ហេតុផល ក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីពេលបញ្ជូនមក ។

បើសភាទាំងពីរយល់ព្រមតាមមូលហេតុនៃសេចក្តីសម្រេច ច្បាប់កែប្រែត្រូវបញ្ជូនត្រឡប់ទៅប្រធានាធិបតីវិញ ដើម្បីប្រកាសឱ្យប្រើ ។

ដូចគ្នានេះដែរ បើសិនជាសភាទាំងពីរបដិសេធទាំងស្រុង ឬមួយផ្នែកនៃការជំទាស់ និងរក្សាអត្ថបទរបស់ខ្លួន តាមសម្លេងភាគច្រើន២/៣នៃសមាជិកវត្តមាន អត្ថបទនោះត្រូវបញ្ជូនត្រឡប់ទៅប្រធានាធិបតីវិញដើម្បីប្រកាសឱ្យប្រើ ។

រយៈពេលសំរាប់ប្រធានាធិបតីជំទាស់ត្រូវព្យួរក្នុងចន្លោះសម័យប្រជុំ ។

៤-ការផ្តល់នីតិសម្បទាដល់បទប្បញ្ញត្តិ

ប្រធានាធិបតីអាចសុំអនុញ្ញាតពីសមាជិកឱ្យចេញបទប្បញ្ញត្តិដែលមានតម្លៃជាច្បាប់សំរាប់រយៈពេលយ៉ាងយូរមួយឆ្នាំ លើកលែងតែបទប្បញ្ញត្តិអំពីសញ្ជាតិ ភាពជាពលរដ្ឋ ច្បាប់ចោះឆ្នោតប្រជាមតិ ការធានារបស់ធម្មនុញ្ញ ច្បាប់អង្គការ ប្រព័ន្ធយុត្តិធម៌... ។

អង្គការត្រួតពិនិត្យរដ្ឋបាល ត្រូវផ្តល់ទិដ្ឋាការឱ្យក្រឹត្យ-ច្បាប់ ។ ក្រឹត្យ-ច្បាប់នេះត្រូវបដិសេធ បើហួសរយៈពេលដែលច្បាប់ស្តីពីការផ្តល់នីតិសម្បទាកំណត់ ។

ការចុះផ្សាយ សុពលភាព និងអានុភាពនៃក្រឹត្យ-ច្បាប់ស្ថិតក្រោមបញ្ញត្តិដូចច្បាប់ដែរ ។

ខ-អំណាចត្រួតពិនិត្យ

ព្រឹទ្ធសភាឈរលើពុំមានសិទ្ធិត្រួតពិនិត្យសកម្មភាពរបស់រដ្ឋាភិបាលឬអង្គការចំណុះរដ្ឋាភិ-បាលទេ ។

គ-អំណាចផ្តល់យោបល់

ព្រឹទ្ធសភាផ្តល់យោបល់ដល់ប្រធានាធិបតីនៃសាធារណរដ្ឋ រាល់ពេលស្នើសុំ ។

V-បទឧបសម្ព្រន្ធនិងបន្ទាន

ក-អំណាចធម្មនុញ្ញ

១-ការផ្តួចផ្តើមគំនិតកែប្រែរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់សមាជិកព្រឹទ្ធសភាជាក្រុមយ៉ាងច្រើន៥នាក់ ឬសមាជិករដ្ឋសភាជាក្រុមយ៉ាងច្រើន១០នាក់ ឬរបស់ប្រធានាធិបតីនៃសាធារណ-រដ្ឋ ។

២-នីតិវិធីអនុម័ត

ក-ការកែប្រែរដ្ឋធម្មនុញ្ញត្រូវអនុម័តដោយសភានីមួយៗ តាមសម្លេងភាគច្រើន ៧៥ នៃសមាជិកសភា ។ នីតិវិធីប្រញាប់អាចតម្រូវឱ្យប្រើ ។

ខ-សភាទាំងពីរប្រជុំជាសមាជដោយមានកូរ៉ុមភាគច្រើន នៃចំនួនសមាជិកសមាជទាំងអស់ ត្រូវអនុម័តដោយគ្មានការពិភាក្សាទូវអត្ថបទដែលអនុម័តដោយសភានីមួយៗក្នុងរយៈពេល ៦០ថ្ងៃបន្ទាប់ពីការអនុម័ត ។

អត្ថបទដែលសមាជអនុម័តតាមសម្លេងភាគច្រើន ត្រូវបញ្ជូនទៅប្រធានាធិបតីនៃសា-ធារណរដ្ឋ ។

ค-សិទ្ធិជំទាស់របស់ប្រធានាធិបតី

ប្រធានាធិបតីអាចជំទាស់ទាំងស្រុងនឹងការកែប្រែរដ្ឋធម្មនុញ្ញ ។

បើសមាជិករក្សាជំហរ តាមសម្លេងភាគច្រើន២/៣នៃសមាជិកសភានីមួយៗ ប្រធានាធិបតីត្រូវប្រកាសឱ្យប្រើអត្ថបទបើសិនជាមិនដាក់ធ្វើប្រជាមតិ ។

បើប្រធានាធិបតីប្រើសិទ្ធិជំទាស់មួយផ្នែក បើការជំទាស់នេះត្រូវអនុម័តតាមសម្លេងភាគច្រើន២/៣ ឬ៧៥នៃសមាជិករបស់សភានីមួយៗ ទៅតាមការអនុម័តនៅការអានលើកទី១ អត្ថបទច្បាប់កែប្រែត្រូវបញ្ជូនត្រឡប់ទៅប្រធានាធិបតីនៃសាធារណរដ្ឋវិញ ដើម្បីប្រកាសឱ្យប្រើ ។

បើសភាទាំងពីរបដិសេធ (ទាំងស្រុង ឬមួយផ្នែក) លើការជំទាស់របស់ប្រធានាធិបតី សភាទាំងពីរអាចរក្សាអត្ថបទរបស់ខ្លួន ដែលត្រូវទទួលសម្លេងភាគច្រើន២/៣ នៃសមាជិកសភានីមួយៗ ។ ក្នុងករណីនេះ វិសោធនកម្មត្រូវបញ្ជូនទៅប្រធានាធិបតីដើម្បីប្រកាសឱ្យប្រើ បើប្រធានាធិបតីមិនដាក់ធ្វើប្រជាមតិចំណុចដែលមានទំនាស់ រដ្ឋសភាឬព្រឹទ្ធសភាអាចស្នើតុលាការធម្ម-នុញ្ញឱ្យពិនិត្យអំពីធម្មនុញ្ញភាពរបស់សមាជ ។

ឃ-ការកែប្រែនីតិវិធីខាងលើត្រូវមានការយល់ព្រមពីប្រធានាធិបតីនៃសាធារណរដ្ឋ និងបានការអនុម័តពីសភានីមួយៗ តាមសម្លេងភាគច្រើន២/៣ ហើយប្រជាមតិមិនអាចធ្វើទេ ។

ង-ការកែប្រែបទប្បញ្ញត្តិជាមូលដ្ឋាននៃប្រព័ន្ធស្ថាប័ន តុលាការធម្មនុញ្ញ កងកម្លាំងប្រដាប់អាវុធ និងនគរបាល និងក្រុមប្រឹក្សាជាតិខាងសន្តិសុខ ពេលអនុម័តរួចត្រូវបញ្ជូនជាថ្មីទៅសភាទាំងពីរ ។ បើសភាទាំងពីរអនុម័តសេចក្តីស្នើតាមសម្លេងភាគច្រើន២/៣ នៃសមាជិកសភានីមួយៗ អត្ថបទត្រូវបញ្ជូនទៅប្រធានាធិបតីនៃសាធារណរដ្ឋ ។ បើប្រធានាធិបតីមិនយល់ព្រមប្រធានាធិបតីរៀបចំធ្វើប្រជាមតិ ។

ខ-សិទ្ធិរបស់ព្រឹទ្ធសភាចំពោះប្រធានាធិបតីនៃសាធារណរដ្ឋ

១-ការអនុញ្ញាតឱ្យចេញពីប្រទេស

ប្រធានាធិបតីនៃសាធារណរដ្ឋមិនអាចចាកចេញពីប្រទេសលើសពី៣០ថ្ងៃ ឬក្នុងរយៈពេល៩០ថ្ងៃចុងក្រោយនៃអាណត្តិរបស់ខ្លួនដោយពុំមានការយល់ព្រមពីព្រឹទ្ធសភាឡើយ ។

២-អសមត្ថភាព និងការលាលែងពីតំណែងប្រធានាធិបតី

ព្រឹទ្ធសភាមានសមត្ថកិច្ច :

-ប្រកាសអំពីអសមត្ថភាពរបស់ប្រធានាធិបតីដោយមូលហេតុសុខភាព

-វាយតម្លៃមូលហេតុនៃការលាលែងរបស់ប្រធានាធិបតី និងផ្តល់ការយល់ព្រម ឬមិនផ្តល់ ។

ក្នុងគ្រប់ករណី ត្រូវមានការសម្រេចពីតុលាការធម្មនុញ្ញ ។

៣-វិស្សមកាលរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ

ក-ក្នុងករណីអសមត្ថភាពរបស់ប្រធានាធិបតី ប្រធានព្រឹទ្ធសភាទទួលជាស្តីទីប្រធានាធិ-បតី(បើប្រធានព្រឹទ្ធសភាអវត្តមាន ប្រធានតុលាការធម្មនុញ្ញ និងបន្ទាប់មកប្រធានរដ្ឋសភាទទួលជាស្តីទី ។

បើអសមត្ថភាពនោះទៅជាស្ថាពរ ប្រធានាធិបតីស្តីទីចាត់វិធានការចាំបាច់ដើម្បី ចោះឆ្នោតជាថ្មី ក្នុងរយៈពេល១០ថ្ងៃបន្ទាប់ពីពេលព្រឹទ្ធសភាសម្រេច ។

ខ-ក្នុងករណីអសមត្ថភាពបណ្តោះអាសន្ន(ដោយមានជម្ងឺ ចេញក្រៅប្រទេសឬមូលហេតុសំខាន់ផ្សេងទៀត) តំណែងប្រធានាធិបតីធ្លាក់ទៅលើបណ្តារដ្ឋមន្ត្រី តាមលំដាប់ពិធីការ ឬបើរដ្ឋមន្ត្រីមិនអាចទទួល ត្រូវធ្លាក់ទៅលើប្រធានព្រឹទ្ធសភា (បន្ទាប់ទៅ លើប្រធានតុលាការកំពូល និងប្រធានរដ្ឋសភា) ។

ក្នុងករណីវិស្សមកាល ឥស្សរជនដែលទទួលជាស្តីទីត្រូវទទួលការតែងតាំងពីព្រឹទ្ធសភាតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកព្រឹទ្ធសភា ក្នុងរយៈពេល១០ថ្ងៃ នៃវិស្សមកាល និងត្រូវទទួលតំណែងរហូតដល់ការចោះឆ្នោតសភាខាងមុខ ។ នៅរយៈពេលនេះ មានការរៀបចំចោះឆ្នោតជ្រើសរើសប្រធានាធិបតី ។

ប្រធានាធិបតីតែងតាំងនេះមិនអាចឈរឈ្មោះជាបេក្ខជនប្រធានាធិបតីថ្មី នៅពេលខាង

មុខឡើយ ។

ក្នុងចន្លោះពេល១០ថ្ងៃសំរាប់ការតែងតាំងអ្នកបន្តវេន រដ្ឋមន្ត្រី (ក្នុងលំដាប់ឋានានុក្រមស្របច្បាប់ ជាអ្នកទទួលបន្ទុកក្នុងនាទីជាអនុប្រធានាធិបតី ។

ត-អំណាចក្នុងវិស័យព្រហ្មទណ្ឌ

១-ការប្រកាសពីពិរុទ្ធភាព

ព្រឹទ្ធសភាត្រូវសម្រេចពីពិរុទ្ធភាពរបស់អ្នកដែលរដ្ឋសភាបានចោទប្រកាន់:

-ប្រធានាធិបតីពីបទប៉ះពាល់ដល់កិត្តិយស និងដល់សន្តិសុខប្រជាជាតិ និងបទបំពានរដ្ឋ-ធម្មនុញ្ញ(ការប្រកាសរបស់តុលាការធម្មនុញ្ញអំពីការប៉ះពាល់ដល់បទបញ្ជាស្ថាប័នរបស់សាធារណរដ្ឋត្រូវមានការយល់ព្រមពី ព្រឹទ្ធសភា តាមសម្លេងភាគច្រើននៃសមាជិក)

-បណ្តារដ្ឋមន្ត្រី ចំពោះមូលហេតុដូចគ្នាបូអំពើក្បត់ អំពើកំហែងយក អំពើបង្ខែងមូលនិធិ និងអំពើពុករលួយ

-ចៅក្រមតុលាការជាន់ខ្ពស់ និងអគ្គត្រួតពិនិត្យសាធារណរដ្ឋពីបទបោះបង់តំណែង

-ឧត្តមសេនីយនិងឧត្តមនាវី ពីបទប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កិត្តិយស និងដល់សន្តិសុខជាតិ

-នាយក្រុមភ័ស្តុភារ និងអភិបាល ពីបទរំលោភរដ្ឋធនុញ្ញ ពីបទក្បត់ បទបះបោរ បទបង្ខែងមូលនិធិ និងបទកំហែងយក ។

ព្រឹទ្ធសភាចេញសេចក្តីសម្រេច និងប្រកាសថាមានពិរុទ្ធ ឬគ្មានពិរុទ្ធ ។

ការប្រកាសអំពីពិរុទ្ធភាព ត្រូវមានសម្លេងភាគច្រើន២/៣នៃសមាជិកព្រឹទ្ធសភា ចំពោះប្រធានាធិបតី និងសម្លេងភាគច្រើនដាច់ខាត ចំពោះអ្នកឯទៀត ។

ការប្រកាសអំពីពិរុទ្ធភាពនាំឱ្យដកតំណែងពីជនជាប់ចោទ និងហាមកាន់ត្រប់តំណែង ក្នុងមុខងារសាធារណៈរយៈពេល៥ឆ្នាំ ។

មានតែសមាជទេ ដែលមានសមត្ថកិច្ចលើកលែងទោសជនដែលត្រូវប្រកាសថាមានពិរទ្ធ ។

២-ព្រឹទ្ធសភាសម្រេចបញ្ជូនរដ្ឋមន្ត្រីទៅតុលាការ ពីបទធ្វើឱ្យខូចខាតប្រយោជន៍នៅក្នុងការបំពេញមុខងារ ។

៣-ព្រឹទ្ធសភាមានសមត្ថកិច្ចផ្តល់ឱ្យវិញនូវភាពជាពលរដ្ឋឈឺលី ជនដែលត្រូវផ្តន្ទាទោសដាក់ទណ្ឌកម្មលើរូបរាងកាយ ។

ឃ-អំណាចក្នុងការតែងតាំង

១-តុលាការធម្មនុញ្ញ

ព្រឹទ្ធសភាជ្រើសរើសមាជិក១នាក់ (ក្នុងចំណោម៧) នៃតុលាការធម្មនុញ្ញ តាមសម្លេងភាគច្រើននៃសមាជិក ។

២-ការតែងតាំងអគ្គៈត្រួតពិនិត្យនៃសាធារណរដ្ឋ ដោយប្រធានាធិបតីនៃសាធារណរដ្ឋត្រូវមានការយល់ព្រមរបស់ព្រឹទ្ធសភា ។

ង-ភារកិច្ចដោយឡែករបស់ប្រធានព្រឹទ្ធសភា

១-ប្រធានព្រឹទ្ធសភាជាសមាជិកក្រុមប្រឹក្សាជាតិសន្តិសុខ និង

២-ជាអធិបតីនៃសម័យប្រជុំរួមសភាទាំងពីរ ។

ច-កាលៈទេសៈពិសេស

១- សមាជមានសមត្ថកិច្ចក្នុងការអនុញ្ញាតឱ្យប្រធានាធិបតីនៃសាធារណរដ្ឋប្រកាសស្ថានភាពអាសន្ននៅចំណុចណាមួយឬច្រើនក្នុងប្រទេស ។ សមាជត្រូវតែកោះប្រជុំដោយពេញច្បាប់ ដើម្បីពិនិត្យអំពីការប្រកាសភាពអាសន្ន ។ នៅគ្រប់ពេល តាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកសភានីមួយៗ សមាជអាចទុកជាមោឃៈនូវស្ថានភាពអាសន្នដែលសម្រេចរួចហើយ ។

២-ប្រធានាធិបតីនៃសាធារណរដ្ឋត្រូវផ្តល់ព័ត៌មានដល់សមាជ អំពីវិធានការនានាដែលបានចាត់សំរាប់ស្ថានភាពអាសន្ន និងគ្រោះមហន្តរាយ ។

ឆ-ប្រធានាធិបតីនៃសាធារណរដ្ឋប្រកាសសង្គ្រាម បន្ទាប់ពីច្បាប់អនុញ្ញាត ។

កូឡុំប៊ី **ព្រឹទ្ធសភា**

COLOMBIE LE SENAT

I-សមាសភាព

ព្រឹទ្ធសភាកូឡុំប៊ីមានសមាជិក ១០២នាក់ :

-១០០នាក់ជ្រើសតាំងដោយការបោះឆ្នោតដោយផ្ទាល់

-២នាក់តំណាងសហគមន៍ជនជាតិដើម ។

ប្រធានព្រឹទ្ធសភាជាអធិបតីនៃសមាជរវាងរដ្ឋសភា និងព្រឹទ្ធសភា ។

I-រមបរជ្ជើសរីស

ចំនួនមណ្ឌលពហុនាមមាន២ :

-១មណ្ឌលមាន១០០អាសន:

-១មណ្ឌលពិសេសមាន២អាសន:(សំរាប់សហគមន៍ជនជាតិតណ្ឌា) ។

ប្រព័ន្ធបោះឆ្នោត:

១-តាមបញ្ជីបិទ (scrutin de liste fermée) តាមរូបមន្តសមាមាត្រ និងសំណល់ធំបំផុត (représentation proportionnelle au plus fort reste) ។

២-នៅមណ្ឌលពិសេស ប្រើប្រព័ន្ធផលចែក (système de quotient) ។

អាណត្តិ : ៤ឆ្នាំ

ការរៀបចំចុងក្រោយ:១០ មីនា ២០០២

អាយុ : ៣០ឆ្នាំ ។

II-រមបប្រជុំ

ក-សម័យប្រជុំសាមញ្ញ

ព្រឹទ្ធសភាមាន២សម័យប្រជុំសាមញ្ញក្នុងមួយឆ្នាំ :

លើកទី១ : ពីថ្ងៃទី២០ កក្កដា ដល់ថ្ងៃទី១៦ ធ្នូ

លើកទី២ : ពីថ្ងៃទី១៦ មីនា ដល់ថ្ងៃទី២០ មិថុនា ។

ខ-សម័យប្រជុំវិសាមញ្ញ

សម័យប្រជុំវិសាមញ្ញ ត្រូវកោះប្រជុំដោយប្រធានាធិបតីនៃសាធារណរដ្ឋ សំរាប់រយៈពេល និងតាមរបៀបវារៈដែលកំណត់ដោយប្រធានាធិបតី ។

គ-សម័យប្រជុំពិសេស (sessions spéciales)

សមាជិកសភាសម្រេចកោះប្រជុំព្រឹទ្ធសភាជាសម័យប្រជុំពិសេសក្នុងស្ថានភាពបន្ទាន់(état d'urgence) ។

ឃ-សម័យប្រជុំអចិន្ត្រៃយ៍ (sessions permanentes)

នេះជាសម័យប្រជុំដែលមានរយៈពេលកន្លះម៉ោង មុនពេលចប់សម័យប្រជុំសម្រាប់បញ្ចប់របៀបវារៈ ។

IV.ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-គំនិតផ្តួចផ្តើមធ្វើច្បាប់

សមាជិកព្រឹទ្ធសភាមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ដូចសមាជិករដ្ឋសភានិងរដ្ឋាភិបាល ។ ទន្ទឹមនឹងនេះ តុលាការធម្មនុញ្ញ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តុលាការយុត្តិធម៌កំពូល ក្រុមប្រឹក្សារដ្ឋ ក្រុមប្រឹក្សាជាតិបោះឆ្នោត អគ្គរដ្ឋអាជ្ញាប្រជាជាតិ អគ្គត្រួតពិនិត្យនៃសាធារណ-រដ្ឋ អង្គពន្ធដារប្រជាជាតិ និងអ្នកការពារប្រជាជនក៏មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ក្នុងវិស័យដែលជាសមត្ថកិច្ចរៀងៗខ្លួន ។ ម្យ៉ាងទៀតប្រជាជនក៏អាចមានសិទ្ធិ ដែលមានកំណត់ក្នុងការផ្តួចផ្តើមធ្វើច្បាប់ដែរ ។

២-សិទ្ធិវិសោធនកម្ម

សមាជិកព្រឹទ្ធសភាមានសិទ្ធិធ្វើវិសោធនកម្ម ។

៣-នីតិវិធី

ក-នីតិវិធីសំរាប់ច្បាប់ធម្មតា

សេចក្តីព្រាងច្បាប់ធម្មតាត្រូវចុះផ្សាយក្នុងរដ្ឋកិច្ចរបស់សមាជិមុនពេលបញ្ជូនទៅគណៈ-
កម្មការ ។ សេចក្តីព្រាងត្រូវអនុម័តនៅការអានលើកទី១ ដោយគណៈកម្មការមានសមត្ថកិច្ចនៃ
សភានីមួយ១ ដោយព្រមព្រៀងគ្នា ។

បន្ទាប់ពីដំណើរការរយៈពេលអប្បបរមា៧ថ្ងៃ សេចក្តីព្រាងត្រូវបញ្ជូនទៅសភាណាមួយ
ដើម្បីពិនិត្យនៅការអានលើកទី២ ។

សេចក្តីព្រាងត្រូវបានអនុម័តដោយព្រមព្រៀងគ្នារវាងសភាទាំងពីរ នៅការអានលើកទី
២ ។ រយៈពេលអប្បបរមា១៥ថ្ងៃត្រូវបានតម្រូវឱ្យរវាងការអនុម័តរបស់សភាមួយ និងការបញ្ជូន
ទៅសភាមួយទៀត ។

ក្នុងករណីមិនមានការព្រមព្រៀងគ្នារវាងសភាទាំងពីរលើសេចក្តីព្រាងច្បាប់ គណៈកម្ម-
ការចំរុះមួយត្រូវបង្កើត ឡើងដើម្បីរៀបចំអត្ថបទរួមមួយ ។

នៅទីបញ្ចប់ សេចក្តីព្រាងច្បាប់ត្រូវប្រធានាធិបតីនៃសាធារណរដ្ឋប្រកាសឱ្យប្រើ ឬ ក្នុង
ករណីប្រធានាធិបតីបដិសេធត្រូវប្រធានសមាជិប្រកាសឱ្យប្រើ ។

ខ-បទប្បញ្ញត្តិដោយឡែក

សេចក្តីព្រាងច្បាប់អំពីទំនាក់ទំនងអន្តរជាតិត្រូវបញ្ជូនទៅព្រឹទ្ធសភាមុន ហើយសេចក្តី
ព្រាងច្បាប់ហិរញ្ញវត្ថុត្រូវបញ្ជូនទៅរដ្ឋសភាមុន ។

គ-សិទ្ធិជំទាស់របស់ប្រធានាធិបតីនៃសាធារណរដ្ឋ

ប្រធានាធិបតីនៃសាធារណរដ្ឋអាចមិនប្រកាសឱ្យប្រើច្បាប់ ដោយមូលហេតុអធម្មនុញ្ញ
ឬមូលហេតុនៃការមិនស្រុះស្រួលគ្នា ។ ពេលនោះ អត្ថបទត្រូវបញ្ជូនទៅសភាដើម (chambre
d'origine) ។ ករណីទី១ បើអត្ថបទនោះត្រូវអនុម័តជាថ្មីម្តងមុន តុលាការធម្មនុញ្ញត្រូវពិនិត្យ
និង សម្រេចក្នុងរយៈពេល៦ថ្ងៃ ។ បើការសម្រេចថាអត្ថបទនោះស្រប នឹងរដ្ឋធម្មនុញ្ញ ប្រធានា
ធិបតីនៃសាធារណរដ្ឋត្រូវប្រកាសឱ្យប្រើ ។ ករណីទី២ អត្ថបទត្រូវអនុម័តតាមសម្លេងភាគច្រើន
ដាច់ខាត ដោយសភាទាំងពីរដើម្បីបង្ខំប្រធានាធិបតីឱ្យប្រកាសឱ្យប្រើច្បាប់ ។

បើប្រធានាធិបតីនៃសាធារណរដ្ឋមិនប្រកាសឱ្យប្រើ ប្រធានសមាជិជាអ្នកប្រកាស ។

ខ-អំណាចត្រួតពិនិត្យ

១-ការទទួលព័ត៌មាន

ព្រឹទ្ធសភាអាចអញ្ជើញរដ្ឋមន្ត្រី ឬមន្ត្រីជាន់ខ្ពស់នានាដើម្បីបំភ្លឺ ឬរាយការណ៍ ។

អាជ្ញាធរដូចខាងក្រោមនេះត្រូវផ្តល់របាយការណ៍ប្រចាំឆ្នាំ ក្នុងរយៈពេល១៥ថ្ងៃបន្ទាប់ពីពេលបើកសម័យប្រជុំ :អគ្គរដ្ឋអាជ្ញាប្រជាជាតិ អ្នកការពារប្រជាជន អគ្គត្រួតពិនិត្យនៃសាធារណរដ្ឋ រដ្ឋមន្ត្រី និងប្រធាននាយកដ្ឋានធនាគារនៃសាធារណរដ្ឋ ។

២-សំណួរជាលាយលក្ខណ៍អក្សរ

សមាជិកព្រឹទ្ធសភា ឬសមាជិករដ្ឋសភាអាចដាក់សំណើជាលាយលក្ខណ៍អក្សរដល់រដ្ឋាភិបាលឱ្យផ្តល់ព័ត៌មាន ។

៣-ញត្តិបន្ទោស

ការមិនគោរពកាតព្វកិច្ចផ្តល់ព័ត៌មាន ឬបង្ហាញខ្លួនតាមការអញ្ជើញរបស់ព្រឹទ្ធសភា ឬរបស់រដ្ឋសភាអាចនាំឱ្យមានការអនុម័តញត្តិបន្ទោសប្រឆាំងនឹងរដ្ឋមន្ត្រីមួយរូប ឬច្រើនរូប ។ ការអនុម័តញត្តិបន្ទោសនាំឱ្យបាត់មុខតំណែង ។

V-បទឧបសម្ព្ធន្ធ៏ដោយឡែក

ក-អំណាចធម្មនុញ្ញ

រដ្ឋធម្មនុញ្ញអាចធ្វើវិសោធនកម្មដោយសមាជិកតាមសំណើរបស់សមាជិក១០នាក់ ឬសំណើរបស់រដ្ឋាភិបាលឬរបស់អ្នកបោះឆ្នោតយ៉ាងតិច៥ភាគរយ ឬរបស់សមាជិកក្រុមប្រឹក្សាក្រុង២០% ឬរបស់សមាជិកក្រុមប្រឹក្សាជាន់ខ្ពស់ ២០% ។

សេចក្ដីស្នើត្រូវពិភាក្សានិងអនុម័តជាពីរដុំ ដោយសមាជិកក្នុងពីរសម័យប្រជុំជាប់គ្នា ។ នៅជុំទី១ អត្ថបទត្រូវអនុម័តតាមសម្លេងភាគច្រើននៃសភានីមួយ១ និងនៅជុំទី២ តាមសម្លេងភាគច្រើនដាច់ខាត ។

ខ-វិស្សមកាលរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ

ព្រឹទ្ធសភាសម្រេចលើការលាលែងរបស់ប្រធានាធិបតី និងអនុប្រធានាធិបតីនៃសាធារ-ណរដ្ឋ ។ ព្រឹទ្ធសភាអនុញ្ញាតឱ្យប្រធានាធិបតី ឬអនុប្រធានាធិបតីសំរាកជាបណ្តោះអាសន្ធពីមុខងារ ហើយអាចប្រកាសអំពីអសមត្ថភាពខាងកាយសម្បទាជាអចិន្ត្រៃយ៍ ។

ត-ការជំនុំជម្រះឥស្សរជនខ្លះ

ព្រឹទ្ធសភាមានសមត្ថកិច្ចក្នុងការជំនុំជម្រះការចោទប្រកាន់របស់រដ្ឋសភាប្រឆាំងនឹងប្រធានាធិបតីនៃសាធារណរដ្ឋ ឬប្រធានាធិបតីស្តីទី ចៅក្រមតុលាការធម្មនុញ្ញ តុលាការយុត្តិធមិកំពូល និងក្រុមប្រឹក្សារដ្ឋ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងអត្ត ពន្ធដារប្រជាជាតិ ។

ឃ-ក្នុងវិស័យអន្តរជាតិ

ព្រឹទ្ធសភាមានសិទ្ធិដាច់មុខក្នុងការ :

១-អនុញ្ញាតឱ្យប្រកាសសង្ត្រាម ។

២-អនុញ្ញាឱ្យទ័ពបរទេសចូលមកក្នុងដែនដីនៃសាធារណរដ្ឋ ។

៣-អនុញ្ញាតឱ្យអតីត: ប្រធានាធិបតីនៃសាធារណរដ្ឋចេញពីដែនដីជាតិក្នុងឆ្នាំបន្ទាប់ពីចប់មុខងារ ។

ង-ការតែងតាំងឥស្សរជនខ្លះ

ព្រឹទ្ធសភាមានសិទ្ធិដាច់មុខក្នុងការតែងតាំង:

១-អត្តរដ្ឋអាជ្ញាប្រជាជាតិ ។

២-ចៅក្រមតុលាការធម្មនុញ្ញ ។

ចេញពីវិបត្តិនៃបណ្តាឆ្នាំ១៩៩០ កិច្ចព្រមព្រៀងសន្តិភាព និងដំណើរនៃ"ការពិភាក្សាថ្នាក់ជាតិដោយគ្មានបដិសេធន៍ (dialogue national sans exslusive): និង"អនុសញ្ញាជាតិដើម្បីសន្តិភាព (convention nationale pour la paix)ស្ថាប័នថ្មីៗ បានបង្កើតឡើង ហើយការបោះឆ្នោតបានរៀបចំឡើងនៅឆ្នាំ២០០២ ។

ថ្ងៃទី១៥ ខែសីហាឆ្នាំ២០០១ ប្រធានាធិបតីកុងហ្គោបានប្រកាសធ្វើប្រជាមតិរដ្ឋធម្មនុញ្ញនៅថ្ងៃ២០ ខែ មករា ឆ្នាំ២០០២ ។

សេចក្តីព្រាងរដ្ឋធម្មនុញ្ញ ដែលអនុម័តដោយសភាអន្តរកាលពីថ្ងៃទី២ ខែកញ្ញាឆ្នាំ២០០១ បានស្នើឱ្យបង្កើតរបបប្រធានាធិបតីនិយមឡើងវិញ ដោយអាស្រ័យសភាពីរថ្នាក់ ។

សេចក្តីព្រាងត្រូវអនុម័តដោយ៨៤,២៦% នៃសម្លេងដែលបានបោះនិងមានសម្លេងប្រឆាំង ១១,២៥% នាប្រជាមតិថ្ងៃទី២០ ខែ មករា ឆ្នាំ២០០២ ។

ព្រឹទ្ធសភាជាតំណាងរបស់សមូហភាពដែនដី ។ព្រឹទ្ធសភាមានមុខងារ៣ គឺមុខងារនីតិប្ញ-ញត្តិ(fonction législative) មុខងារសម្របសម្រួល (modérateur) និងមុខងារជាក្រុមប្រឹក្សាប្រជាជាតិ (conseil de la Nation) ។

ការបង្កើតសភា បន្ទាប់មកការធ្វើសច្ចាប្រណិធានរបស់ប្រធានាធិបតីនៃសាធារណរដ្ឋដែលទើបជាប់ឆ្នោត (M.Denis Sassou N'Guesso) បានបញ្ចប់សម័យអន្តរកាល ។

I-សមាសភាព

ព្រឹទ្ធសភាមានសមាជិក៦៦នាក់ ដែលជ្រើសតាំងដោយការបោះឆ្នោតមិនផ្ទាល់(scrutin indirect)ដោយក្រុមប្រឹក្សានៃសមូហភាពមូលដ្ឋាន(conseils des collectivités locales) ។

II-របបជ្រើសតាំង

អាណត្តិ : ៦ឆ្នាំ ប្តូរថ្មីពាក់កណ្តាលរាល់ពីឆ្នាំ

អាយុ : ៤៥ ឆ្នាំ

វិសមិតភាព :ជាមួយគ្រប់មុខងារដែលមានលក្ខណៈសាធារណៈ សមាជិកព្រឹទ្ធសភាណាលាលែងពីគណបក្សនយោបាយ ឬពីក្រុមនយោបាយដែលខ្លួនជាតំណាង សមាជិកនោះត្រូវបាត់លក្ខណៈជាសមាជិកព្រឹទ្ធសភា ។

ការបោះឆ្នោតលើកទី១ : ១១-០៧-២០០២

ការប្តូរថ្មីចុងក្រោយ:០២-១០-២០០៥

I-របបប្រជុំ

ក-សម័យប្រជុំសាមញ្ញ

ព្រឹទ្ធសភាកោះប្រជុំជាសាមញ្ញពាដងក្នុងមួយឆ្នាំដោយប្រធានព្រឹទ្ធសភា:

-លើកទី១ បើកនៅថ្ងៃទី២មីនា

-លើកទី២ បើកនៅថ្ងៃទី២កក្កដា

-លើកទី៣ បើកនៅថ្ងៃទី១៥តុលា ។

សម័យប្រជុំនីមួយ១មានរយៈពេលយ៉ាងយូរ៦០ថ្ងៃ ។

ខ-សម័យប្រជុំវិសាមញ្ញ

ប្រធានព្រឹទ្ធសភាកោះប្រជុំជាវិសាមញ្ញ តាមរបៀបវារៈយ៉ាងជាក់លាក់ តាមសំណើរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ឬរបស់សមាជិកព្រឹទ្ធសភាភាគច្រើន ។

ត-សម័យប្រជុំពេញច្បាប់ (session de droit)

ជាការប្រជុំក្រោយពេលបោះឆ្នោត ។ បើការប្រជុំនេះធ្វើឡើងនៅក្រៅសម័យប្រជុំសាមញ្ញ សម័យប្រជុំវិសាមញ្ញត្រូវបើកដោយពេញច្បាប់ សំរាប់រយៈពេល១៥ថ្ងៃ ។

IV-ឆំនាក់ឆំនងជាមួយរដ្ឋសភា និងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-ត់និតផ្តួចផ្តើមធ្វើច្បាប់

សមាជិកព្រឹទ្ធសភា ឬសមាជិករដ្ឋសភាឬប្រធានាធិបតីមានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់ ។

ប្រធានាធិបតីអាចជូនសារទៅព្រឹទ្ធសភាឬរដ្ឋសភាបានគ្រប់ពេល ។ សភាមិនអាចយកសារនេះទៅពិភាក្សាបានឡើយ ។

មួយឆ្នាំម្តងប្រធានាធិបតីផ្ញើសារអំពីស្ថានភាពរបស់ប្រជាជាតិជូនសមាជសភា ។

V-បទឃ្លាឆ្លងផ្ទៃទូទៅ

ក-ការសើរើរដ្ឋធម្មនុញ្ញ

១-ការផ្តួចផ្តើមគំនិតសើរើជាសិទ្ធិរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ និងសមាជិកសភា ។

២-បើជាគំនិតផ្តើមរបស់សភា សេចក្តីស្នើសើរើរដ្ឋធម្មនុញ្ញត្រូវអនុម័តតាមសម្លេងភាគច្រើន២/៣នៃសមាជិកសភាប្រជុំជាសមាជ ក្រោយពីការសម្រេចរបស់តុលាការធម្មនុញ្ញអំពីធម្មនុញ្ញភាពនៃអត្ថបទ ។

៣-ក្នុងគ្រប់ករណី ការសើរើរដ្ឋធម្មនុញ្ញទៅជាស្វាពរបាន លុះណាមានការសម្រេចពីប្រជាមតិ ។

ខ-សមត្ថកិច្ចដោយឡែករបស់ប្រធានព្រឹទ្ធសភា

១-ស្តីទីប្រធានាធិបតីនៃសាធារណរដ្ឋ

បើប្រធានាធិបតីចូលមរណភាព ឬមិនអាចបំពេញការកិច្ចជាស្ថាពរ ប្រធានព្រឹទ្ធសភាទទួលបំពេញមុខងារប្រធានាធិបតីជាបណ្តោះអាសន្នសំរាប់រយៈពេលយ៉ាងយូរ ៩០ថ្ងៃ ។

ប្រធានព្រឹទ្ធសភាមិនអាចជាបេក្ខជនប្រធានាធិបតីទេ ។

២-បើបេក្ខជនប្រធានាធិបតីណាម្នាក់ទទួលអនិច្ចកម្ម ឬអសមត្ថភាពជាស្ថាពរ ប្រធានព្រឹទ្ធសភាអាចស្នើក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពន្យារពេលបោះឆ្នោត តាមការកំណត់របស់រដ្ឋធម្ម-នុញ្ញ ។

៣-ប្រធានាធិបតីនៃសាធារណរដ្ឋពិគ្រោះយោបល់ជាមួយប្រធានព្រឹទ្ធសភា មុនធ្វើការចាត់វិធានការជាពិសេស បើកាលណាស្ថាប័ននៃសាធារណរដ្ឋ ឯករាជជាតិ បូរណភាពដែនដី ឬការ

អនុវត្តកាតព្វកិច្ចអន្តរជាតិទទួលការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ហើយដំណើរការរបស់អំណាចសាធារណៈទទួលការគំរាមកំហែង ឬខ្វះនិរន្តរភាព ។

៤-ប្រធានព្រឹទ្ធសភា ស្នើសុំប្រធានាធិបតីតែងតាំងសមាជិកតុលាការធម្មនុញ្ញពីរនាក់ក្នុងចំណោម៩ ។

៥-ប្រធានព្រឹទ្ធអាចស្នើក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមឱ្យពិនិត្យរាល់កិច្ចការដែលទាក់ទងនឹងសេដ្ឋកិច្ច សង្គម ។

ត-ការប្រកាសសង្គ្រាម (déclaration de guerre)

ការប្រកាសសង្គ្រាមត្រូវមានការអនុញ្ញាតពីសភាដែលប្រជុំរួមជាសមាជ ។

ក្នុងស្ថានភាពពិសេស(circontances exceptionnelles)បើសភាមិនអាចប្រជុំបាន ការប្រកាសសង្គ្រាមត្រូវធ្វើនៅក្រុមប្រឹក្សារដ្ឋមន្ត្រី ដោយប្រធានាធិបតីនៃសាធារណរដ្ឋដែលត្រូវជូនដំណឹងជាបន្ទាន់ដល់ប្រជាជាតិ ។

ឃ-ស្ថានភាពអាសន្ន និងស្ថានភាពបន្ទាន់

ការពន្យារស្ថានភាពអាសន្ន និងស្ថានភាពបន្ទាន់លើសពី១៥ថ្ងៃ ត្រូវមានការអនុញ្ញាតពីសភាដែលប្រជុំដោយពេញច្បាប់ជាសមាជ បើសិនជាសភាមិនស្ថិតក្នុងសម័យប្រជុំ ។

ក្នុងស្ថានភាពពិសេស បើសភាមិនអាចប្រជុំបាន ប្រធានាធិបតីនៃសាធារណរដ្ឋអាចសម្រេចរក្សាស្ថានភាពអាសន្ន ឬស្ថានភាពបន្ទាន់ ។

ង-តុលាការយុត្តិធម៌ជាន់ខ្ពស់

១-សមាសភាព

សមាសភាពរបស់តុលាការយុត្តិធម៌ជាន់ខ្ពស់មានសមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា និងសមាជិកតុលាការកំពូល ដែលមានចំនួនស្មើគ្នា ។

២-សមត្ថកិច្ច

តុលាការយុត្តិធម៌ជាន់ខ្ពស់មានសមត្ថកិច្ចជំនុំជម្រះ :

-ប្រធានាធិបតីនៃសាធារណរដ្ឋពីបទក្បត់

-សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា រដ្ឋមន្ត្រី សមាជិកតុលាការកំពូល សមាជិកតុលាការធម្មនុញ្ញ ចំពោះបទឧក្រឹដ្ឋ ឬមជ្ឈឹមក្នុងការអនុវត្តមុខងាររបស់ខ្លួន ។

៣-ការចាទប្រកាន់

ការចាទប្រកាន់ធ្វើឡើងដោយសភាប្រជុំជាសមាជ ដែលសម្រេចជាសម្លាត់តាមសម្លេងភាគច្រើន២/៣នៃចំនួនសមាជិក ។

នៅថ្ងៃទី១ខែមេសាឆ្នាំ២០០៣ ការចរចារវាងប្រតិភូកុងហ្គោ បានអនុម័តរដ្ឋធម្មនុញ្ញបណ្តោះអាសន្ន សំរាប់ពង្រឹងដំណើរការប្រកួតប្រជែងនយោបាយរបស់ប្រទេស និងរៀបចំអនុម័តរដ្ឋធម្មនុញ្ញជាស្ថាពរ ។

អត្ថបទនៃរដ្ឋធម្មនុញ្ញចុងក្រោយបានអនុម័តដោយប្រជាមតិថ្ងៃ១៨ធ្នូ ឆ្នាំ២០០៥ បន្ទាប់មកត្រូវប្រកាសឱ្យប្រើដោយប្រធានាធិបតីនៃសាធារណរដ្ឋ Joseph Kabila ថ្ងៃ១៨ កុម្ភៈ ឆ្នាំ ២០០៦ ។

ចាប់ពីពេលនោះមក សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោមានសភាពីរថ្នាក់(រដ្ឋសភា និង ព្រឹទ្ធសភា ។ អត្ថិភាពនៃសភាពីរដែលមានចែងអះអាងក្នុងរដ្ឋធម្មនុញ្ញបណ្តោះអាសន្នត្រូវបានរក្សាទុក ។ក្នុងអតីតកាលព្រឹទ្ធសភាត្រូវបានបំបាត់ដោយរដ្ឋធម្មនុញ្ញថ្ងៃ២៤មិថុនាឆ្នាំ១៩៦៧ ។ ស្ថាប័នថ្មីៗ បានបញ្ចប់ទ្រឹះបបសភាមួយដែលមានរយៈពេលជិត៤០ឆ្នាំ ហើយរបបសភាពីរដែលធ្លាប់មានតាំងពីឆ្នាំ១៩៦៤ មកបានកើតឡើងវិញ ។

ការបង្កើតឡើងនូវស្ថាប័នថ្មីៗបានធ្វើឱ្យមានការបោះឆ្នោត ។ ការបោះឆ្នោតប្រធានាធិបតី និងបោះឆ្នោតនីតិប្បញ្ញត្តិ បានប្រព្រឹត្តទៅនាចន្លោះខែកក្កដា និងតុលា ឆ្នាំ ២០០៦ ។ Joseph Kabila ត្រូវបានទទួលជាប្រធានាធិបតីនៃសាធារណរដ្ឋ និងតែងតាំងរដ្ឋសភាដែលមានតំណាងមកពីគណបក្សនយោបាយចំនួន៦៥ ប៉ុន្តែកម្លាំងគណបក្សនយោបាយពីរបានលេចឡើង : គណបក្សលោក Kabila(គណបក្សប្រជាជនដើម្បីកសាងប្រជាធិបតេយ្យ -Parti du Peuple pour la reconstruction de la démocratie : PPRD)ដែលបានសម្លេង ២២% និងគណបក្សសហភាពដើម្បីប្រជាជាតិ(Union pour la Nation :UN)របស់លោកJean-Pierre Bembaដែលបានសម្លេង១២% ។

ការបោះឆ្នោតព្រឹទ្ធសភាបានប្រព្រឹត្តទៅនៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៧ ។ សមាជិកព្រឹទ្ធសភាចំនួន១០៨នាក់ ត្រូវជ្រើសរើសដោយសមាជិករដ្ឋសភារបស់ខេត្ត សំរាប់អាណត្តិ៥ឆ្នាំ

ឬការចាប់ខ្លួនសមាជិកព្រឹទ្ធសភាអាចធ្វើទៅបាន លុះត្រាមានការអនុញ្ញាតពីការិយាល័យរបស់ព្រឹទ្ធសភា។

មុខងារនៃសមាជិកសភាមានវិសមិតភាពជាមួយមុខងារជាសមាជិករដ្ឋាភិបាល ជាកងកម្លាំងប្រដាប់អាវុធ ជានគរបាលជាតិ ចៅក្រម និងមន្ត្រីស៊ីវិល។

៣-ស្ថិយភាពផ្ទៃក្នុងរបស់សភា

រដ្ឋធម្មនុញ្ញចែងថា សភានីមួយៗដឹកនាំដោយការិយាល័យដែលមានសមាជិក៧នាក់។ សភានីមួយៗអនុម័តបទបញ្ជាផ្ទៃក្នុងដែលចែងអំពីវិធាននៃការប្រព្រឹត្តទៅ ចំនួន រៀបចំជ្រើសតាំង សមាសភាព និងសមត្ថកិច្ចនៃគណៈកម្មការអចិន្ត្រៃយ៍ ឬការរៀបចំសេវារដ្ឋបាលទាន។ បទបញ្ជាផ្ទៃក្នុងត្រូវបញ្ជូនទៅឱ្យតុលាការធម្មនុញ្ញពិនិត្យ។

៤-សម័យប្រជុំ

ក្នុងមួយឆ្នាំ ព្រឹទ្ធសភាប្រជុំជាសាមញ្ញពីរដង ។ សម័យប្រជុំលើកទី១ ចាប់ពីថ្ងៃ ទី១៥ ខែមីនាដល់ថ្ងៃទី១៥ខែមិថុនា និងសម័យប្រជុំលើកទី២ ចាប់ពីថ្ងៃទី ១៥ ខែកញ្ញា ដល់ថ្ងៃ ទី ១៥ ខែធ្នូ។

សភានីមួយៗប្រជុំជាវិសាមញ្ញដោយពេញច្បាប់១៥ថ្ងៃ ក្រោយការប្រកាសលទ្ធផលបោះឆ្នោតជាផ្លូវការ ។សភានីមួយៗអាចប្រជុំជាវិសាមញ្ញ តាមការកោះរបស់ប្រធាន តាមរបៀបវារៈជាក់លាក់ តាមសំណើរបស់ការិយាល័យ ឬរបស់សមាជិកចំនួនពាក់កណ្តាល ឬរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ឬរបស់រដ្ឋាភិបាល។ សម័យប្រជុំវិសាមញ្ញត្រូវបញ្ចប់ពេលអស់រៀបវារៈដើម ឬយ៉ាងយូរបំផុត៣០ថ្ងៃក្រោយពេលបើក។

II-បេសកកម្ម និងសមត្ថកិច្ចរបស់ព្រឹទ្ធសភា

សភាអនុម័តច្បាប់ និងត្រួតពិនិត្យរដ្ឋាភិបាល(មាត្រា១០០ ៣) ។

ក-អំណាចនីតិប្បញ្ញត្តិ

ជាទូទៅ ព្រឹទ្ធសភា និងរដ្ឋសភាមានអំណាចនីតិប្បញ្ញត្តិស្មើគ្នា ប៉ុន្តែរដ្ឋធម្មនុញ្ញផ្តល់

ផ្តល់សិទ្ធិអាទិភាពឱ្យរដ្ឋសភាសម្រេចជាចុងក្រោយ កាលបើសភាទាំងពីរមិនអាចរកការព្រមព្រៀងគ្នាបាន បន្ទាប់ពីការបញ្ជូនអត្ថបទច្បាប់ទៅមកវាងសភាទាំងពីរ ។

១-សិទ្ធិផ្តួចផ្តើមធ្វើច្បាប់

ការផ្តួចផ្តើមធ្វើច្បាប់ និងវិសោធនកម្មច្បាប់ជាសិទ្ធិរបស់រដ្ឋាភិបាល និងរបស់សមាជិកសភាម្នាក់ៗ (មាត្រា ១៣០ ក) ។

សិទ្ធិនេះមានកំរិតខ្លះ :

-ការផ្តួចផ្តើមរបស់សភាត្រូវកាត់បន្ថយក្នុងវិស័យហិរញ្ញវត្ថុ ។ ម្យ៉ាងទៀត សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុត្រូវតែផ្តួចផ្តើមជាពិសេសដោយរដ្ឋាភិបាល ។ មាត្រា១២៧ និង១៣៤ ឥតានចែងអំពីការមិនអាចទទួលបានចំពោះសេចក្តីស្នើច្បាប់ ឬហិរញ្ញវត្ថុដែលសំដៅកាត់បន្ថយចំណូល ឬបន្ថែមចំណាយរបស់រដ្ឋ ។

-វិស័យរបស់ច្បាប់មានកំណត់ផ្តួចរៀបរាប់នៅមាត្រា ១២២និង ១២៣ ក ។ ក្នុងពេលពិភាក្សា បើសិនរដ្ឋធម្មនុញ្ញមិនចែងអំពីយន្តការដែលអនុញ្ញាតឱ្យសំអាងលើភាពមិនអាចទទួលបានទូវបញ្ញត្តិដែលត្រួតជាន់លើក្របខ័ណ្ឌបទបញ្ញា រដ្ឋធម្មនុញ្ញអនុញ្ញាតឱ្យតែ ប្រែដោយក្រឹត្យ ក្រោយការប្រកាសឱ្យប្រើច្បាប់បើសិនជាតុលាការធម្មនុញ្ញទទួលស្គាល់ ថាបញ្ញត្តិនោះពិតជាមានលក្ខណៈជាបទបញ្ជាមែន (មាត្រា ១២៨ ក) ។

២-ការពិនិត្យ និងអនុម័តច្បាប់

រដ្ឋាភិបាលមានសិទ្ធិជាអាទិភាពក្នុងការកំណត់របៀបវារៈរបស់សភានីមួយៗ ។ ការចុះនូវសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬសេចក្តីប្រកាសអំពីនយោបាយទូទៅក្នុងរបៀបវារៈជាការតម្រូវ បើសិនរដ្ឋាភិបាលស្នើសុំ(មាត្រា ១១៧ ក) ។

អត្ថបទច្បាប់ទាំងឡាយត្រូវតែទទួលបានការអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភា:

-ត្រប់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវអនុម័តជាបន្តបន្ទាប់ ដោយសភាទាំងពីរព្រមព្រៀងគ្នា(មាត្រា ១៣៥ ក) ។ បើជាសេចក្តីព្រាងច្បាប់ រដ្ឋាភិបាលអាចបញ្ជូនទៅសភាណាមួយក៏បាន លើកលែងតែច្បាប់ហិរញ្ញវត្ថុ ដែលត្រូវតែបញ្ជូនទៅរដ្ឋសភាជាដំបូង ។

-សភាដែលទទួលពិនិត្យអត្ថបទ (ដែលសភាមួយទៀតអនុម័តរួចហើយ) ពិភាក្សាតែ

លើអត្ថបទច្បាប់ដែលបញ្ជូនមកតែប៉ុណ្ណោះ(មាត្រា ១៣២) ។

-កាលបើអត្ថបទមិនបានអនុម័តក្រោយការអានលើកទី១នៅសភាទាំងពីរ ការិយាល័យសភាទាំងពីរបង្កើតគណៈកម្មការចំរុះសមភាគី ដើម្បីរៀបចំអត្ថបទរួមត្រង់ចំណុចដែលមិនទាន់ឯកភាព (មាត្រា ១៣៥) ។ អត្ថបទរួមនេះ ត្រូវបញ្ជូនទៅឱ្យសភាទាំងពីរអនុម័ត ។

-ក្នុងករណីការងាររបស់គណៈកម្មការចំរុះបរាជ័យ ឬបើអត្ថបទរួមមិនបានការយល់ព្រមពីសភាទាំងពីរ រដ្ឋសភាសម្រេចជាចុងក្រោយ ។

៣-ការត្រួតពិនិត្យធម្មនុញ្ញភាព និងការប្រកាសឱ្យប្រើ

អត្ថបទដែលសភាបានអនុម័តត្រូវបញ្ជូនទៅប្រធានាធិបតីនៃសាធារណរដ្ឋដើម្បីប្រកាសឱ្យប្រើ ។ ក្នុងរយៈពេល១៥ថ្ងៃ ប្រធានាធិបតីអាចសុំឱ្យរដ្ឋសភា ឬព្រឹទ្ធសភាពិនិត្យឡើងវិញ (មាត្រា ១៣៥) ។

ក្នុងរយៈពេល១៥ថ្ងៃបន្ទាប់ពីការបញ្ជូនច្បាប់ដែលបានអនុម័តជាស្ថាពរ ប្រធានាធិបតីនៃសាធារណរដ្ឋ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា ឬសមាជិកសភានីមួយៗយ៉ាងតិចមួយភាគដប់(១/១០) អាចសុំឱ្យតុលាការធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពរបស់ច្បាប់ ។

ឃ-បញ្ញត្តិដោយឡែកចំពោះច្បាប់អង្គការ (lois organiques) និងបញ្ញត្តិ-ច្បាប់ (ordonnances-lois)

ច្បាប់អង្គការត្រូវអនុម័តតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភា និងព្រឹទ្ធសភា ។ម្យ៉ាងទៀតការពិនិត្យ និងអនុម័តមិនអាចធ្វើមុនរយៈពេល១៥ថ្ងៃបន្ទាប់ពីបានទទួលអត្ថបទទេ។ ជាទីបញ្ចប់ តុលាការធម្មនុញ្ញត្រូវតែពិនិត្យច្បាប់អង្គការ(មាត្រា ១២៤) ។

រដ្ឋាភិបាលអាចប្រើបញ្ញត្តិ-ច្បាប់ដើម្បីអនុវត្តកម្មវិធីរបស់ខ្លួនឱ្យបានឆាប់រហ័ស ។ ចំពោះកិច្ចការនេះ រដ្ឋាភិបាលស្នើសុំព្រឹទ្ធសភាឬរដ្ឋសភាឱ្យផ្តល់នីតិសម្បទា ដែលអនុញ្ញាតឱ្យចាត់វិធានការដូចតាមផ្លូវច្បាប់ធម្មតា សំរាប់រយៈពេលមួយ និងក្នុងវិស័យជាក់លាក់ ។ ហួសរយៈពេលនេះ បញ្ញត្តិ-ច្បាប់ត្រូវផ្តល់សុពលភាព ដោយច្បាប់ផ្តល់សច្ចាប័ន បើផ្ទុយពីនេះ បញ្ញត្តិ-ច្បាប់ត្រូវអស់តម្លៃ(មាត្រា ១៣០) ។

២-អំណាចត្រួតពិនិត្យ

រដ្ឋាភិបាលមិនទទួលខុសត្រូវចំពោះព្រឹទ្ធសភា ដូចចំពោះរដ្ឋសភាទេ ។ ក្នុងពេលនោះដែរ ប្រធានាធិបតីនៃសាធារណរដ្ឋអាចប្រកាសរំលាយរដ្ឋសភា ប៉ុន្តែមិនអាចរំលាយព្រឹទ្ធសភាបានទេ (មាត្រា ១៤៦ដល់១៤៨ ត) ។

ដោយសាររដ្ឋាភិបាលមិនទទួលខុសត្រូវចំពោះព្រឹទ្ធសភា ព្រឹទ្ធសភាមានសិទ្ធិតិចតួចក្នុងការទទួលព័តិមានឬក្នុងការត្រួតពិនិត្យលើរដ្ឋាភិបាល សហត្រាស ត្រឹះស្ថាននិងសេវាសាធារណៈ ដូចជា :

-សំណួរផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ មាន ឬត្មានការពិភាក្សា ដោយត្មានការ អនុម័ត

-បញ្ហាបច្ចុប្បន្នភាព (questions d'actualité)

-ការកោះសួរដេញដោល (interpellations)

-គណៈកម្មការស៊ើបអង្កេត (commissions d'enquête)

-សវនកម្មដោយគណៈកម្មការ (auditions par les commissions) ។

III-បញ្ញត្តិផ្សេងៗ

១-ព្រឹទ្ធសភា និងការសើរើរដ្ឋធម្មនុញ្ញ

សភាទាំងពីរមានតួនាទីជាក់លាក់ក្នុងការសើរើរដ្ឋធម្មនុញ្ញ ។ជាក់ស្តែង ការផ្តួចផ្តើមសើរើរដ្ឋធម្មនុញ្ញមិនមែនជាសិទ្ធិឯកឯងរបស់សភាទាំងពីរទេ ពីព្រោះការផ្តួចផ្តើមអាចមកពីប្រធានាធិបតីសាធារណរដ្ឋ ពីរដ្ឋាភិបាល ពីសភានីមួយៗ តាមគំនិតផ្តើមរបស់សមាជិកពាក់កណ្តាល ឬក៏មកដោយផ្ទាល់ពីពលរដ្ឋកុងហ្គោ តាមញត្តិដែលចុះហត្ថលេខា យ៉ាងតិច ១00.000នាក់ (មាត្រា ២១៨ ត) ។

ប៉ុន្តែសភាទាំងពីរមានសិទ្ធិដាច់មុខក្នុងការសម្រេចព្រមឱ្យបន្ត ឬមិនព្រមឱ្យបន្តសេចក្តីព្រាង សេចក្តីស្នើ ឬញត្តិសុំសើរើ ។

ម្យ៉ាងទៀត ព្រឹទ្ធសភា និងរដ្ឋសភាប្រជុំរួមជាសមាជអនុម័តការសើរើ តាមសម្លេង ៣/៥នៃសមាជិក បើការសើរើនេះមិនបានដាក់ធ្វើប្រជាមតិទេ ។

២-អំណាចក្នុងស្ថានភាពវិបត្តិធ្ងន់ធ្ងរ

ប្រធានាធិបតីនៃសាធារណរដ្ឋប្រកាសសង្គ្រាម តាមការសម្រេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រោយពីបានយោបល់យល់ព្រមពីក្រុមប្រឹក្សាការពារជាតិជាន់ខ្ពស់ និងការអនុញ្ញាតពីរដ្ឋសភា និងព្រឹទ្ធសភា(មាត្រា ១៤៣ ក) ។

កាលណាប្រធានាធិបតីនៃសាធារណរដ្ឋប្រកាសស្ថានភាពបន្ទាន់ ឬស្ថានភាពអាសន្ន ព្រឹទ្ធសភានិងរដ្ឋសភាត្រូវកោះប្រជុំជាវិសាមញ្ញ ។

៣-អំណាចតែងតាំង

ប្រជុំជាសមាជ ព្រឹទ្ធសភា និងរដ្ឋសភាតែងតាំងសមាជិកតុលាការធម្មនុញ្ញពីនាក់ (លើ ៩នាក់) ។ ប្រធានាធិបតី តែងតាំងពីនាក់ និងក្រុមប្រឹក្សានៃអង្គចៅក្រមតែងតាំងពីនាក់) ។

អេហ្ស៊ីប **សភាពិគ្រោះយោបល់**

EGYPTE Assemblée consultataive

ម៉ាហ្ស្លីស អាល-ជូរ៉ា Majlis Al-Choura

សភាពិគ្រោះយោបល់បង្កើតឡើងដោយរដ្ឋធម្មនុញ្ញសីរីថ្ងៃ ២២ ខុសភា ។

I-**សមាសភាព**

សភាពិគ្រោះយោបល់មានសមាជិក២៦៤នាក់ :

-២/៣ ជាសមាជិកជ្រើសតាំង

-១/៣ ជាសមាជិកតែងតាំងដោយប្រធានាធិបតីនៃសាធារណរដ្ឋ ។

II-**របៀបជ្រើសតាំងឬតែងតាំង**

១-សមាជិក១៧៦នាក់ ជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយផ្ទាល់ ក្នុង៨៨ មណ្ឌល ដែលសមាជិកពាក់កណ្តាលយ៉ាងតិចត្រូវតែជាកម្មករ និងកសិករ ។

២-សមាជិក៨៨នាក់ជាសមាជិកតែងតាំង ។

៣-អាណត្តិ : ៦ឆ្នាំ ប្តូរថ្មីពាក់កណ្តាលរៀងរាល់ពីឆ្នាំ ។

៤-អាយុ : ៣៥ឆ្នាំយ៉ាងតិច ។

៥-ក្នុងករណីអាសនៈណាមួយវិស្សមកាល សភាជ្រើសតាំងអ្នកជំនួសរហូតដល់ផុត អាណត្តិ ឬប្រធានាធិបតីតែងតាំងអ្នកជំនួស បើសិនជាសមាជិកតែងតាំង ។

៦-សមាជិកសភាពិគ្រោះយោបល់អាចជាសមាជិករដ្ឋាភិបាល ។

III-**សម័យប្រជុំ**

ក-សម័យប្រជុំសាមញ្ញ

សភាពិគ្រោះយោបល់ ក៏ដូចជាសភាប្រជាជន (assemblée du Peuple) ត្រូវកោះប្រជុំដោយប្រធានាធិបតីនៃសាធារណរដ្ឋ មុនថ្ងៃព្រហស្បតិ៍ ទី២ ខែវិច្ឆិកា ។

សម័យប្រជុំសាមញ្ញប្រចាំឆ្នាំមានរយៈពេលយ៉ាងតិចពាំខែ ។ សម័យប្រជុំត្រូវបញ្ចប់ដោយ ប្រធានាធិបតីនៃសាធារណរដ្ឋ ។ សម័យប្រជុំមិនអាចបញ្ចប់មុនពេលអនុម័តថ្វិកាទូទៅរបស់រដ្ឋបានទេ ។

ខ-សម័យប្រជុំវិសាមញ្ញ

ប្រធានាធិបតីនៃសាធារណរដ្ឋកោះប្រជុំសភាជាវិសាមញ្ញ ក្នុងករណីចាំបាច់ ឬតាមញត្តិដែលចុះហត្ថលេខាដោយសមាជិកចំនួនពាក់កណ្តាល ។ ប្រធានាធិបតីប្រកាសបិទសម័យប្រជុំ ។

ត-ដំណើរការប្រជុំ

ប្រធានសភាកំណត់ពេលបើក និងពេលបិទពេលប្រជុំនីមួយៗ ព្រមទាំងកំណត់ពេលម៉ោងនៃពេលប្រជុំលើកក្រោយ ។

សភាប្រជុំជាសាធារណៈ ។ សភាសម្រេចប្រជុំជាសម្ងាត់ (à huis clos) តាមសំណើរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ របស់រដ្ឋាភិបាល របស់ប្រធានសភាពិគ្រោះយោបល់ ឬរបស់សមាជិកយ៉ាងតិច២០នាក់ ដោយមានការយល់ព្រមពីសភាផង ។

IV-ភារកិច្ចរបស់សភាពិគ្រោះយោបល់

ភារកិច្ចរបស់សភាមានកំណត់នៅមាត្រា១៥៤ និង ១៥៥នៃរដ្ឋធម្មនុញ្ញ ។ សភាពិគ្រោះយោបល់ទទួលបន្ទុកសិក្សា និងណែនាំឱ្យយោបល់ចំពោះការងារដែលយល់ថាចាំបាច់:

-ដើម្បីរក្សាគោលការណ៍បដិវត្តថ្ងៃ២៣ ខែកក្កដា ឆ្នាំ១៥៥២ និងថ្ងៃ១៥ ខែឧសភា ឆ្នាំ ១៥៧១

-ដើម្បីពង្រឹងឯកភាពជាតិ និងសន្តិសុខសង្គម

-ដើម្បីការពារសម្ព័ន្ធភាពប្រជាជន និងសមិទ្ធផលសង្គមនិយម ក៏ដូចជាសមាសធាតុជាជាមូលដ្ឋានសង្គមនិងមនោគមវិជ្ជា សិទ្ធិ សេរីភាព និងកាតព្វកិច្ចសាធារណៈ

-និងដើម្បីពង្រឹងពង្រីកប្រព័ន្ធសង្គមនិយមប្រជាធិបតេយ្យ ។

១-តំនិតផ្តួចផ្តើមធ្វើច្បាប់

សមាជិកសភានីតិប្បញ្ញតិ ប្រធានាធិបតីនៃសាធារណរដ្ឋ និងសមាជិកសភាប្រជាជនមានសិទ្ធិផ្ទូចផ្តើមគំនិតធ្វើច្បាប់ ។

២-យោបល់ជាចាំបាច់លើបញ្ហាមួយចំនួន(មាត្រា១៩៥) :

-សេចក្តីស្នើអំពីវិសោធនកម្មមួយឬច្រើនមាត្រានៃរដ្ឋធម្មនុញ្ញ

-សេចក្តីព្រាងច្បាប់បំពេញបន្ថែមរដ្ឋធម្មនុញ្ញ

-សេចក្តីព្រាងជែនការទូទៅសំរាប់អភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច

-សន្ធិសញ្ញាសន្តិភាព និងសម្ព័ន្ធភាព ក៏ដូចជាសន្ធិសញ្ញាដែលអាចឱ្យមានការកែប្រែដែនដី ឬអធិបតេយ្យ

-សេចក្តីព្រាងច្បាប់ដែលប្រធានាធិបតីនៃសាធារណរដ្ឋបញ្ជូនបក (ដូចជាសេចក្តីព្រាងថវិកាទូទៅរបស់រដ្ឋចាប់ ពីឆ្នាំ១៩៩៧)

-បញ្ហាទាក់ទងនឹងនយោបាយទូទៅរបស់រដ្ឋ ឬនយោបាយចំពោះកិច្ចការអាវាប់ឬកិច្ចការបរទេសដែលប្រធានាធិបតីនៃសាធារណរដ្ឋបញ្ជូនមកសភា ។

V-ទំនាក់ទំនងជាមួយសភាប្រជាជនតិចអំណាចនីតិប្រតិបត្តិ

ក-ភាពមិនទទួលខុសត្រូវ

ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី និងសមាជិករដ្ឋាភិបាលមិនទទួលខុសត្រូវចំពោះសភាពិត្រោះយោបល់ទេ ។

ខ-សំណើពិភាក្សា

សមាជិកសភា(ពិត្រោះយោបល់ឬប្រជាជនយ៉ាងតិច២០នាក់) អាចលើកបញ្ហាដែលមានលក្ខណៈទូទៅដើម្បីស្វែងយល់ពីនយោបាយរបស់រដ្ឋាភិបាល ។ ការិយាល័យសភាត្រូវបញ្ជូលនេះក្នុងរបៀបវារៈនៃពេលប្រជុំខាងមុខ ។

បញ្ហានេះអាចយកមកពិភាក្សាក្នុងពេលប្រជុំនោះ កាលបើ[illegible]សំណើបស់រដ្ឋាភិបាល ។

 គ-ការអនុម័តសំណូមពរ

សមាជិកសភា (ពិគ្រោះយោបល់ឬប្រជាជន) មានសិទ្ធិអនុម័តសំណូមពរ លើការងារទូទៅជូនប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី អនុប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី ឬរដ្ឋមន្ត្រីម្នាក់ៗ ។

ឃ-ការប្រកាសនិងសវនកម្មនៃអង្គការប្រតិបត្តិ

១-របស់ប្រធានាធិបតីនៃសាធារណរដ្ឋ

ប្រធានាធិបតីនៃសាធារណរដ្ឋអាចថ្លែងក្នុងសម័យប្រជុំរួមសភាទាំងពីរ ក្រោមអធិបតីភាពប្រធានសភាប្រជាជនអំពីនយោបាយទូទៅរបស់រដ្ឋាភិបាល ។ ប្រធានាធិបតីអាចថ្លែងការណ៍ផ្សេងៗទៀតក្នុងសភាពិគ្រោះយោបល់ ។

២-របស់រដ្ឋាភិបាល

រដ្ឋាភិបាលអាចថ្លែងជូនសភា ឬជូនគណៈកម្មការរបស់សភាអំពីកិច្ចការ ដែលពាក់ព័ន្ធនឹងសមត្ថកិច្ច ។ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី និងសមាជិករដ្ឋាភិបាល ត្រូវតែថ្លែងជូនសភាពិគ្រោះយោបល់ ឬ ជូនគណៈកម្មការរាល់ពេលដែលមានការស្នើសុំ ហើយអាចមានមន្ត្រីជាន់ខ្ពស់ទៅជាមួយ ។ នៅពេលអនុម័ត សមាជិករដ្ឋាភិបាលមិនអាចចូលរួមទេ លើសិនជាមិនមែនសមាជិកសភាពិគ្រោះយោបល់ ។

ង-ការរំលាយ

ប្រធានាធិបតីនៃសាធារណរដ្ឋអាចរំលាយសភាបានតែពេលណាដែលមានការចាំបាច់ ។

ក្រឹត្យរំលាយសភាត្រូវមានភ្ជាប់នូវការកោះឱ្យមានការបោះឆ្នោតថ្មី ក្នុងថេរៈវេលាមិនហួសពី៦០ថ្ងៃ បន្ទាប់ពីការផ្សព្វផ្សាយក្រឹត្យរំលាយសភា ។ សភាត្រូវកោះប្រជុំក្នុងរយៈពេល១០ថ្ងៃ បន្ទាប់ពីការបោះឆ្នោត ។

VI-បទឧបសម្ព្ធន្ធ្ធ

ក-ប្រធានសភាពិគ្រោះយោបល់ ជាប្រធានក្រុមប្រឹក្សាជាន់ខ្ពស់នៃអង្គការសារព័ត៌មាន (ដែលតែងតាំងនិងធ្វើនាយកនៃអង្គការសារព័ត៌មានជាតិ) ។

ខ-សភាពិគ្រោះយោបល់ត្រួតមើល :

១-គណៈកម្មាធិការនៃគណបក្សដែលអនុញ្ញាត ព្យូរឬហាមច្រាមគណបក្សនយោបាយ ។

២-ក្រុមប្រឹក្សាសិទ្ធិមនុស្សជាតិ ។

ETHIOPIE LA CHAMBRE DE LA FEDERATION

យ៉ៃហ្ស្យេដេរីស្ស៊ីន ម៉េកា ប៊ីតេ

YEFEDERESHEIN MEKIR BETE

សភាសហភាព (parlement fédéral) អេត្យូពីមានសភាពីរ : សភាតំណាងប្រជាជន (chambre des représentants du peuple) និងសភាសហព័ន្ធ (chambre de la Fédération) ដែលសមាជិកជាតំណាងប្រជាជាតិនានា សញ្ជាតិនានា និងតំណាងប្រជាជនអេត្យូពី។

សភាសហព័ន្ធមានសមត្ថកិច្ចយ៉ាងជាក់លាក់ និងសំខាន់សំរាប់ការប្រព្រឹត្តទៅរបស់សហព័ន្ធ។ រដ្ឋធម្មនុញ្ញត្រូវបានកែប្រែនៅឆ្នាំ២០០២។

I -សមាសភាព

សភាសហព័ន្ធមានសមាជិក១១២នាក់ (ជ្រើសតាំង)។

ប្រជាជាតិនីមួយៗ សញ្ជាតិនីមួយៗ ឬប្រជាជនមានតំណាងម្នាក់យ៉ាងតិចនៅសភាសហព័ន្ធ ។ ចំពោះប្រជាជាតិ និងសញ្ជាតិនានា មានតំណាងបន្ថែមម្នាក់សំរាប់ប្រជាជន១លាននាក់។

II-របៀបជ្រើសតាំង

សមាជិកសភាសហព័ន្ធត្រូវជ្រើសតាំងដោយការបោះឆ្នោតដោយផ្ទាល់ (direct) ឬដោយមិនផ្ទាល់ឬប្រយោល (indirect)។

សមាជិក ?ត្រូវជ្រើសតាំងដោយប្រយោលដោយសភានៃរដ្ឋ (ខេត្ត) ទាំង៩របស់ប្រទេស ឬដោយផ្ទាល់ដោយប្រជាជន តាមការសម្រេចរបស់សភានៃរដ្ឋ។

អាណត្តិ : ៥ឆ្នាំ

ការរៀបចំចុងក្រោយ: ៣ និង៦ ខែ តុលា ឆ្នាំ ២០០៥

ខ-អំណាចត្រួតពិនិត្យ

បើយល់ថាជាការចាំបាច់ សភាសហព័ន្ធអាចកំណត់ពេលម៉ោង និងទីកន្លែងដែលមន្ត្រីរដ្ឋាភិបាល ឬ អ្នកវិជ្ជាជីវ: ឬបុគ្គលត្រូវមកបំភ្លឺ ឬមកពន្យល់ ឬជាសាក្សី តាមការអញ្ជើញរបស់សភា ។

v-បទប្បញ្ញត្តិដោយឡែក

ក-សមត្ថកិច្ចពិសេសចំពោះការប្រព្រឹត្តទៅរបស់សហព័ន្ធ

១-អំណាច និងការទទួលខុសត្រូវរបស់សភាសហព័ន្ធ

-សម្រេចបញ្ហាដែលទាក់ទងនឹងការគោរពសិទ្ធិស្ម័យសម្រេចរបស់ប្រជាជាតិ សញ្ជាតិ និងប្រជាជន គិតទាំងសិទ្ធិអបគមន៍

-លើកតំកើងសមភាពរវាងពលរដ្ឋនានានៃអេត្យូពី លើកតំកើង និងពង្រឹងឯកភាពជាតិ ផ្អែកលើការព្រមព្រៀងទៅវិញទៅមក

-ដោះស្រាយទំនាស់រវាងរដ្ឋ និងរដ្ឋ

-បែងចែកផលពីពន្ធដារ និងឧបត្ថម្ភធនដល់រដ្ឋនានា

-អនុញ្ញាតឱ្យរដ្ឋាភិបាលកណ្តាលធ្វើអន្តរាគមន៍ដល់រដ្ឋណាមួយ ដែលបំពានលើបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ។

២-សមត្ថកិច្ចក្នុងវិស័យសិទ្ធិមនុស្ស

តាមការផ្តួចផ្តើមផ្ទាល់ ក្រុមប្រឹក្សាតំណាងប្រជាជនកោះប្រជុំរួមជាមួយក្រុមប្រឹក្សាសហព័ន្ធ ដើម្បីអនុម័តវិធានការសំខាន់ៗជាចាំបាច់នៅពេលដែលសិទ្ធិមនុស្សក្នុងរដ្ឋណាមួយត្រូវរំលោភ ឬនៅពេលរដ្ឋណាមួយស្ថិតក្នុងស្ថានភាពរំលោភសិទ្ធិមនុស្ស ។

ក្រុមប្រឹក្សាផ្តល់ការណែនាំដល់រដ្ឋ ដើម្បីឱ្យអនុវត្តសេចក្តីសម្រេចនៃការប្រជុំរួម ។

ខ-អំណាចពិសេសក្នុងវិស័យធម្មនុញ្ញ

១-សមាសភាពនៃក្រុមប្រឹក្សាធម្មនុញ្ញ

ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិក១១នាក់ ក្នុងនោះសភាសហព័ន្ធតែងតាំងពាក់ ។ ក្រុមប្រឹក្សាធម្មនុញ្ញដឹកនាំដោយប្រធានតុលាការកំពូលសហភាព(Cour suprême fédéral) ។

២-ការបកស្រាយរដ្ឋធម្មនុញ្ញ

ក្នុងករណីមានទំនាស់លើបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ក្រុមប្រឹក្សាធម្មនុញ្ញ ដោយមានសំអាងហេតុផលនិងមានអនុសាសន៍ផង បញ្ជូនទំនាស់នេះទៅសភាសហព័ន្ធ ដែលត្រូវសម្រេចក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីថ្ងៃទទួល ។ បើក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យឃើញថា ពុំមានអ្វីត្រូវបកស្រាយទេ ក្រុមប្រឹក្សាត្រូវបញ្ជូនត្រឡប់ទៅតុលាការដែលពាក់ព័ន្ធវិញ ។

ភាគីដែលមានផលប្រយោជន៍អាចប្តឹងឧទ្ធរណ៍ទៅសភាសហព័ន្ធ ។

៣-ធម្មនុញ្ញភាពនៃច្បាប់

ពេលមានបញ្ហាធម្មនុញ្ញភាពនៃច្បាប់របស់រដ្ឋកណ្តាល ឬរបស់រដ្ឋជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ តាមសំណើរបស់តុលាការ ឬ របស់ភាគីណាមួយ ទទួលពិនិត្យបញ្ហានោះ ហើយបញ្ជូនទៅសភាសហព័ន្ធដើម្បីសម្រេចជាស្ថាពរ ។

៤-បទបញ្ជារបស់ក្រុមប្រឹក្សាធម្មនុញ្ញ

ក្រុមប្រឹក្សាធម្មនុញ្ញរៀបចំសេចក្តីព្រាងបទបញ្ជារបស់ខ្លួន និងដាក់ឱ្យសភាសហព័ន្ធអនុម័ត ។

ค-ការសើរើរដ្ឋធម្មនុញ្ញ

១-ការផ្ដួចផ្ដើម

សេចក្តីស្នើវិសោធនកម្មរដ្ឋធម្មនុញ្ញអាចដាក់ជូនប្រជាជនឬជនទាំងឡាយ ដែលមានការពាក់ព័ន្ធ ដើម្បីសម្រេចអំពីការផ្ដើមនីតិវិធីសើរើ បើសេចក្តីស្នើនោះបានទទួលការគាំទ្រពីរភាគបី(២/៣) នៃសមាជិកសភាតំណាងប្រជាជន ឬសភាសហព័ន្ធ ឬមួយភាគបី(១/៣) នៃសភារដ្ឋជាសមាជិកនានានៃសហភាព ។ សភារដ្ឋនីមួយៗអនុម័តតាមសម្លេង ភាគច្រើននៃចំនួនសមាជិករបស់ខ្លួន ។

២-នីតិវិធី

ក-មាត្រាអំពីសិទ្ធិ និងសេរីភាពជាមូលដ្ឋាន ក៏ដូចជាបញ្ញត្តិអំពីការសើរើរដ្ឋធម្មនុញ្ញអាចត្រូវធ្វើវិសោធនកម្ម ដោយការអនុម័ត:

- របស់សភានៃរដ្ឋសមាជិកទាំងអស់ តាមសម្លេងភាគច្រើនធម្មតា

-របស់សភាតំណាងប្រជាជន តាមសម្លេងភាគច្រើន២/៣ និង

-របស់សភាសហព័ន្ធ តាមសម្លេងភាគច្រើន២/៣ ។

ខ-មាត្រាឯទៀតនៃរដ្ឋធម្មនុញ្ញអាចធ្វើវិសោធនកម្ម ដោយការអនុម័ត:

-របស់សភាទាំងពីរនៃសហភាព (parlement fédéral) ប្រជុំជារួមតាមសម្លេងភាគច្រើន២/៣

-របស់ពីរភាគបីនៃសភារដ្ឋសមាជិក តាមសម្លេងភាគច្រើនធម្មតា ។

ឃ-ការបោះឆ្នោតជ្រើសរើសប្រធានាធិបតី

ប្រធានាធិបតីនៃសាធារណៈរដ្ឋត្រូវជ្រើសរើសដោយសភាទាំងពីរ ប្រជុំរួមគ្នាតាមសម្លេងភាគច្រើន២/៣ ។

ង-ការកំណត់មណ្ឌល

សភាសហព័ន្ធកំណត់មណ្ឌលបោះឆ្នោត លើមូលដ្ឋាននៃលទ្ធផលនៃការជំរឿនជាតិដែលធ្វើរាល់១០ឆ្នាំ ។ សេចក្តីស្នើត្រូវបញ្ជូនទៅគណៈកម្មការជាតិរៀបចំការបោះឆ្នោត ។

ព្រឹទ្ធសភាជាសភាទី២ដែលរដ្ឋធម្មនុញ្ញផ្តល់នូវបេសកកម្មពិសេស :

-តំណាងរបស់សមូហភាពដែនដីនៃសាធារណរដ្ឋ

-តំណាងរបស់ជនជាតិបារាំងរស់នៅក្រៅប្រទេសបារាំង ។

I-សមាសភាព

ព្រឹទ្ធសភាមានសមាជិក៣៣១នាក់ ជ្រើសតាំងដោយការបោះឆ្នោតសកល ដោយមិនផ្ទាល់(នៅឆ្នាំ២០១០ និងមានចំនួន៣៤៦នាក់ តាមកំណែទំរង់ឆ្នាំ ២០០៣)ដែល:

-៣១៥ តំណាងសមូហភាពដែនដី :

-៣១៣អាសន:ក្នុងថ្នាក់ខេត្ត-départements(ទីក្រុងធំ១និងឯនាយសមុទ្រ):

-៣០៤ អាសន:ចំពោះខេត្តក្រុងធំ១(៣១៥អាសន: នៅឆ្នាំ២០១០)

-៥ អាសន:ចំពោះខេត្តឯនាយសមុទ្រ(១១អាសន: នៅឆ្នាំ២០១០)

-៦អាសន:ក្នុងថ្នាក់សមូហភាពនាយសមុទ្រ ដែលមានលក្ខន្តិក:ពិសេស (ម៉ៃយ៉ុត នូវែលកាឡេដូណា ប៉ូលីណេស៊ីបារាំង សាំងពីយែ និងមីកីឡុង និងកោះវ៉ាលី និងហ្ជ៉ុយទុយណា ណា(៨អាសន: នៅឆ្នាំ២០១០) ។

-១២ តំណាងជនជាតិបារាំងរស់នៅក្រៅប្រទេសបារាំង ។

II-រមមរឿសតាំង

គណ:អ្នកបោះឆ្នោត (collège électoral):

១-សមាជិកព្រឹទ្ធសភាតំណាងសមូហភាពដែនដី ត្រូវជ្រើសតាំងដោយគណ:អ្នកបោះ-ឆ្នោត ដែលមានសមាជិករដ្ឋសភា (députés) ទីប្រឹក្សាតំបន់ (conseillers régionaux) អត្តទីប្រឹក្សាខេត្តនីមួយ១ (conseillers généraux de chaque département) និងតំណាងក្រុមប្រឹក្សាក្រុង (représentants des conseils municipaux)ដែលចំនួនប្រែប្រួលទៅតាមចំនួនប្រជាជននៃឃុំនានា ដែលពាក់ព័ន្ធ និងចំនួនសមាជិកនៃក្រុមប្រឹក្សាក្រុងនានា ។

២-សមាជិកព្រឹទ្ធសភាតំណាងជនជាតិបារាំងនៅក្រៅប្រទេសត្រូវជ្រើសរើសដោយគណ:អ្នកបោះឆ្នោត ដែលមានសមាជិកសភាបារាំងជាប់ឆ្នោតនៅបរទេស ។

ប្រព័ន្ធបោះឆ្នោតចំនុះ :

១-ប្រព័ន្ធសម្លេងភាគច្រើនលើបញ្ជីបោះពីរជុំ (crutin majoritaire de liste à deux tours) តាមខេត្តដែលរើសពី១ ទៅ៣នាក់ (ចាប់ពីការរៀបចំថ្មីជាផ្នែកឆ្នាំ ២០០៤-ច្បាប់លេខ ២០០៣-៦៥៧ ចុះថ្ងៃ៣០-៧-២០០៣)។

២-ប្រព័ន្ធសមាមាត្រ តាមរូបមន្តមធ្យមភាគខ្ពស់បំផុត តាមខេត្តដែលរើសមាជិកយ៉ាងតិច៤នាក់ (ចាប់ពីការរៀបចំថ្មីជាផ្នែក ឆ្នាំ២០០៤-ច្បាប់លេខ ២០០៣-៦៥៧ ចុះថ្ងៃ៣០-៧-២០០៣)។

សមាជិក១២នាក់តំណាងជនជាតិបារាំងនៅបរទេស ត្រូវជ្រើសតាំងតាមប្រព័ន្ធសមា-មាត្រ។

បញ្ជីត្រូវដាក់បេក្ខជនឆ្លាស់គ្នាប្រុស -ស្រី (ច្បាប់លេខ២០០០-៤៥៣ ចុះថ្ងៃ ៦- ៦-២០០០)។

អាណត្តិ : លើកមុន៥ ឆ្នាំប្តូរថ្មី១/៣រៀងរាល់៣ឆ្នាំ។ ចាប់ពីការប្តូរថ្មីជា ផ្នែក ឆ្នាំ២០០៤ អាណត្តិមាន៦ឆ្នាំ ប្តូរថ្មីពាក់កណ្តាលរៀងរាល់៣ឆ្នាំ។

ជាអន្តរកាល ចំពោះការប្តូរថ្មីជាផ្នែកឆ្នាំ២០០៤ រយៈពេលនៃអាណត្តិនៃអាសនៈភាគខ្លះនៃសេរី គ (série c) បច្ចុប្បន្ន មានកំណត់៦ឆ្នាំ ភាគខ្លះ៥ឆ្នាំ តាមការចាប់ឆ្នោត។

ការប្តូរថ្មីចុងក្រោយ : ២៦ កញ្ញា ឆ្នាំ២០០៤

អាយុ : ៣០ឆ្នាំ ចាប់ពីការប្តូរថ្មីជាផ្នែក ឆ្នាំ២០០៤(កាលមុន ៣៥ឆ្នាំ)

វិសមិតភាព : អាណត្តិសមាជិកសភាមានវិសមិតភាពជាអាម៉ីជាមួយមុខងារជាសមាជិករដ្ឋាភិបាល និងមុខងារជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ។

បណ្តឹងទាក់ទងនឹងការបោះឆ្នោតព្រឹទ្ធសភាជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

III-សម័យប្រជុំ

ក-សម័យប្រជុំសាមញ្ញ

ព្រឹទ្ធសភាមាន១សម័យប្រជុំប្រចាំឆ្នាំ ដែលចាប់ផ្តើមពីថ្ងៃធ្វើការទី១ (1er jour ouvrable) ខែតុលា និងចប់នៅថ្ងៃធ្វើការចុងក្រោយ (dernier jour ouvrable) នៃ ឧសភា។

ចំនួនថ្ងៃដែលសភានីមួយ១ត្រូវប្រជុំក្នុងសម័យប្រជុំសាមញ្ញមិនអាចលើសពី១២០ថ្ងៃទេ ។សប្តាហ៍ នៃការប្រជុំត្រូវកំណត់ដោយសភានីមួយ១ (តាមធម្មតាសភាព្យូរការប្រជុំពាសប្តាហ៍ចុងខែធ្នូ ដើមខែមករា១ សប្តាហ៍ ខែកុម្ភ: និង ២សប្តាហ៍ខែមេសា ។

ក្រោយពីបានពិគ្រោះយោបល់ជាមួយប្រធានសភាដែលពាក់ព័ន្ធ នាយករដ្ឋមន្ត្រី ឬសមាជិកភាគច្រើនរបស់សភានោះអាចសម្រេចឱ្យមានការប្រជុំបន្ថែម (ព្រឹទ្ធសភា ក៏ដូចជារដ្ឋសភា ប្រជុំបន្ថែមដោយពេញច្បាប់ដើម្បីអនុម័តព្យូរការចាប់ខ្លួន អនុម័តវិធានការដកហូត ឬការបន្ថយ សេរីភាព ឬការចោទប្រកាន់សមាជិកសភាណាម្នាក់) ។

ពេលវេលា និង ម៉ោងប្រជុំមានកំណត់ក្នុងបទបញ្ជារបស់សភានីមួយ១ ។ តាមបទបញ្ជា ព្រឹទ្ធសភាប្រជុំជាសាធារណ:នៅថ្ងៃអង្គារ ពុធ និងព្រហស្បតិ៍នៃសប្តាហ៍នីមួយ១ : ថ្ងៃអង្គារ និង ព្រហស្បតិ៍ ពេលព្រឹក ពីម៉ោង៩កន្លះ ដល់ម៉ោង១៣ ពេលរសៀលពីម៉ោង ១៦(ថ្ងៃអង្គារ) និង ពីម៉ោង១៥(ថ្ងៃពុធ និងព្រហស្បតិ៍)ដល់ម៉ោង២០ ។

ព្រឹទ្ធសភាអាចពន្យារម៉ោងប្រជុំជាសាធារណ:ហួសពីម៉ោងកំណត់បាន តាមសំណើរបស់ សន្ធិសីទនៃបណ្តាប្រធាន (Conférence des Présidents)របស់រដ្ឋាភិបាល ឬ របស់គណ: កម្មការខ្លឹមសារ (commission saisie au fond) ។

ខ-សម័យប្រជុំវិសាមញ្ញ

សភាប្រជុំជាវិសាមញ្ញតាមសំណើរបស់នាយករដ្ឋមន្ត្រី ឬរបស់សមាជិកភាគច្រើនរបស់ រដ្ឋសភា តាមរបៀបវារ: មួយជាក់លាក់ ។

កាលណាសភាប្រជុំជាវិសាមញ្ញតាមសំណើរបស់សមាជិករដ្ឋសភា ក្រឹត្យបញ្ជប់ត្រូវចេញ នៅពេលអស់របៀបវារ: នៃសម័យប្រជុំ ឬ យ៉ាងយូរណាស់១២ថ្ងៃចាប់ពីពេលប្រជុំ ។ មានតែ នាយករដ្ឋមន្ត្រីទេដែលអាចស្នើកោះប្រជុំជាថ្មីមុនដំណាច់ខែ បន្ទាប់ពីចេញក្រឹត្យបញ្ជប់ ។

គ-សម័យប្រជុំពេញច្បាប់ (sessions de droit)

១-សភាប្រជុំដោយពេញច្បាប់ ក្នុងរយ:ពេលអនុវត្តមាត្រា១៦នៃរដ្ឋធម្មនុញ្ញ(អំណាច ពិសេសរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ បើសិនជាស្ថាប័នរដ្ឋ ឯករាជជាតិ បូរណភាព ដែនដី ឬ ការអនុវត្តការធានាអន្តរជាតិត្រូវគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ និងជាបន្ទាន់ហើយការប្រព្រឹត្តទៅ ជាធម្មតារបស់អំណាចសាធារណ:តាមរដ្ឋធម្មនុញ្ញត្រូវរអាក់រអូល) ។

២-សម័យប្រជុំដោយពេញច្បាប់១៥ថ្ងៃ នាថ្ងៃព្រហស្បតិ៍ទី២ បន្ទាប់ពីការបោះឆ្នោតនីតិប្បញ្ញត្តិក្រោយការរំលាយរដ្ឋសភាបើសិនជាការប្រជុំនេះមិនស្ថិតក្នុងរយៈពេលនៃសម័យប្រជុំជាសាមញ្ញ ។ សម័យប្រជុំមានរយៈពេល ១៥ថ្ងៃ ។

៣-ក្រៅសម័យប្រជុំ សភាប្រជុំដោយពេញច្បាប់ដើម្បីស្តាប់សារដែលប្រធានាធិបតីនៃសាធារណរដ្ឋបញ្ជូនមកតាមមាត្រា១៨នៃរដ្ឋធម្មនុញ្ញ ។

IV-ចំនាក់ចំនងជាមួយរដ្ឋសភា និងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-ការផ្តួចផ្តើមធ្វើច្បាប់

សមាជិកព្រឹទ្ធសភា នាយករដ្ឋមន្ត្រី និងសមាជិករដ្ឋសភាមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។

ប៉ុន្តែសេចក្តីស្នើច្បាប់មិនអាចទទួលយកបានទេ បើសិនជាច្បាប់នោះនាំឱ្យមានការកាត់បន្ថយធនធានសាធារណៈ ឬមានការបង្កើត ឬ បន្ថែមបន្ទុកសាធារណៈ ។

២-សិទ្ធិវិសោធនកម្ម

សមាជិកព្រឹទ្ធសភា នាយករដ្ឋមន្ត្រី និងសមាជិករដ្ឋសភាមានសិទ្ធិធ្វើវិសោធនកម្ម ។

ប៉ុន្តែ សេចក្តីស្នើវិសោធនកម្មច្បាប់មិនអាចទទួលយកបានទេ បើសិនជាវិសោធនកម្មនោះនាំឱ្យមានការកាត់បន្ថយធនធានសាធារណៈ ឬមានការបង្កើតឬ បន្ថែមបន្ទុកសាធារណៈ ។

៣-នីតិវិធី

ក-នីតិវិធីធម្មតា

សេចក្តីព្រាងច្បាប់ត្រូវដាក់ជូនការិយាល័យរបស់សភាណាមួយ លើកលែងតែសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ និងសេចក្តីព្រាងច្បាប់ហិរញ្ញប្បទានសន្តិសុខសង្គមដែលត្រូវដាក់ជូនរដ្ឋសភាពិនិត្យជាមុន ។ សេចក្តីព្រាងដែលកម្មវត្ថុសំខាន់ផ្តោតលើការរៀបចំសមូហភាពដែនដី និងសេចក្តីព្រាងច្បាប់ទាក់ទងនឹងអង្គការតំណាងជនជាតិភាគតិចរស់នៅក្រៅប្រទេស ត្រូវដាក់ជូនព្រឹទ្ធសភាពិនិត្យជាមុន ។

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវបញ្ជូនទៅឱ្យគណៈកម្មការណាមួយនៃគណៈកម្មការទាំង៦ពិនិត្យ ឬគណៈកម្មការដែលបង្កើតជាពិសេសឱ្យពិនិត្យកិច្ចការនោះ ។

ត្រប់សេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ត្រូវតែបានពិនិត្យជាបន្តបន្ទាប់ដោយសភាទាំងពីរ ដើម្បីឱ្យមានការព្រមព្រៀងគ្នា ។

ក្នុងករណីដែលនៅតែមិនមានការព្រមព្រៀងគ្នា ក្រោយការពិនិត្យពីរលើកក្នុងសភានីមួយ១(ឬមួយលើក១ក្នុងករណីប្រញាប់ដែលប្រកាសដោយរដ្ឋាភិបាល) នាយករដ្ឋមន្ត្រីមានសិទ្ធិស្នើឱ្យមានការប្រជុំគណៈកម្មការចំរុះសមភាគី(សមាជិកព្រឹទ្ធសភា៧នាក់និងសមាជិករដ្ឋសភា៧នាក់) ដើម្បីតាក់តែងអត្ថបទរួមមួយ លើចំណុចដែលមានបញ្ហានោះ ។

អត្ថបទដែលគណៈកម្មការចំរុះតាក់តែងបាននោះ រដ្ឋាភិបាលអាចដាក់ឱ្យសភាទាំងពីរអនុម័ត ។ ពុំមានវិសោធនកម្មណាមួយអាចទទួលយកបាន្ធើយ លើកលែងតែមានការយល់ព្រមពីរដ្ឋាភិបាល ។

ក្នុងករណីបរាជ័យរបស់គណៈកម្មការចំរុះ ឬបើសិនជាអត្ថបទរួមនោះមិនបានអនុម័តដោយសភាទាំងពីរ រដ្ឋាភិបាលអាច ក្រោយពីការពិនិត្យលើកទី១ក្នុងសភានីមួយ១ស្នើឱ្យរដ្ឋសភាសម្រេចជាស្ថាពរ ។ ក្នុងករណីនេះ រដ្ឋសភាអាចយកអត្ថបទរួមរបស់គណៈកម្មការចំរុះ ឬអត្ថបទអនុម័តចុងក្រោយដោយរដ្ឋសភា ដែលមានការកែប្រែដោយវិសោធនកម្ម ដែលព្រឹទ្ធសភាបានអនុម័ត ។

ប្រធានាធិបតីនៃសាធារណរដ្ឋប្រកាសឱ្យប្រើច្បាប់ក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីអត្ថបទច្បាប់ដែលអនុម័តជាស្ថាពរបានបញ្ជូនទៅរដ្ឋាភិបាល ។

ខ-បទប្បញ្ញត្តិដោយឡែកសំរាប់អនុម័តច្បាប់អង្គការ

សេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ត្រូវអនុម័តដោយរដ្ឋសភាបានលុះណាតែក្រោយពេលដាក់មកចំនួន១៥ថ្ងៃ

បើគ្មានការព្រមព្រៀងរវាងសភាទាំងពីរ អត្ថបទត្រូវរដ្ឋសភាអនុម័តជាលើកចុងក្រោយតែតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិករបស់ខ្លួន ។

ច្បាប់អង្គការទាក់ទងនឹងព្រឹទ្ធសភា ត្រូវតែអនុម័តដោយព្រមព្រៀងគ្នារវាងសភាទាំងពីរ ។

គ-បទប្បញ្ញត្តិដោយឡែកសំរាប់ច្បាប់ហិរញ្ញវត្ថុ

ព្រឹទ្ធសភាមានរយៈពេល២០ថ្ងៃ សំរាប់ពិនិត្យលើកទី១ទ្ធូវសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុ ។

បើរដ្ឋសភាមិនបានអនុម័តលើកទី១ក្នុងរយៈពេល៤០ថ្ងៃក្រោយពេលបានទទួល រដ្ឋាភិបាលបញ្ជូនមកព្រឹទ្ធសភា ដែលត្រូវពិនិត្យក្នុងរយៈពេល១៥ថ្ងៃ ។

បើសភាមិនបានអនុម័តក្នុងរយៈពេល៧០ថ្ងៃ បទប្បញ្ញត្តិនៃសេចក្តីព្រាងអាចត្រូវប្រកាសឱ្យប្រើដោយបញ្ញត្តិ (par ordonnance) ។

រយៈពេលនេះត្រូវព្យូរ ពេលណាសភាមិនស្ថិតក្នុងសម័យប្រជុំ និងសំរាប់សភានីមួយ១ នៅសប្តាហ៍នៃសម័យប្រជុំដែលសភាព្យូរការប្រជុំ ។

ឃ-ការពិនិត្យជាថ្មី

ប្រធានាធិបតីនៃសាធារណរដ្ឋអាចស្នើឱ្យសភាពិនិត្យឡើងវិញលើច្បាប់ឬមាត្រាខ្លះ១មុនហួសរយៈពេលកំណត់នៃការប្រកាសឱ្យប្រើ ។

៤-ការផ្តល់នីតិសម្បទាលើបញ្ញត្តិ

ដើម្បីអនុវត្តកម្មវិធីរបស់ខ្លួន រដ្ឋាភិបាលអាចស្នើសុំការអនុញ្ញាតពីសភាឱ្យចេញបញ្ញត្តិដាក់ឱ្យប្រើវិធានការដែលមានលក្ខណៈដូចជាច្បាប់ សំរាប់រយៈពេលមួយជាកំណត់ ។ បញ្ញត្តិទាំងនោះចូលជាធរមានចាប់ពីពេលផ្សព្វផ្សាយ ប៉ុន្តែលែងមានតម្លៃបើសេចក្តីព្រាងច្បាប់ផ្តល់សច្ចាប័នមិនបានដាក់មកសភា មុនពេលដែលកំណត់ដោយច្បាប់ស្តីពីនីតិសម្បទា (loi d'habilitation) ។

៥-ប្រជាមតិ (référendum)

ក្នុងសម័យប្រជុំ តាមសំណើរបស់រដ្ឋាភិបាល ឬតាមសំណើរួមរបស់សភាទាំងពីរ ប្រធានាធិបតីនៃសាធារណរដ្ឋអាចដាក់ធ្វើប្រជាមតិ នូវសេចក្តីព្រាងច្បាប់ទាំងអស់ស្តីពីការរៀបចំអំណាចសាធារណៈ ស្តីពីការកែទំរង់នយោបាយសេដ្ឋកិច្ច ឬសង្គមជាតិ និងសេវាសាធារណៈដែលពាក់ព័ន្ធ ឬដែលអាចឱ្យមានការផ្តល់សច្ចាប័នលើអនុសញ្ញា (មិនផ្ទុយនឹងរដ្ឋធម្មនុញ្ញ) ដែលមានផលប៉ះពាល់ដល់ការប្រព្រឹត្តទៅរបស់ស្ថាប័ននានា ។

កាលណាប្រជាមតិធ្វើឡើងតាមសំណើរបស់រដ្ឋាភិបាល រដ្ឋាភិបាលត្រូវធ្វើសេចក្តីផ្ទើងការណ៍ដែលមានការពិភាក្សាជូនសភានីមួយ១ ។

៩-អំណាចត្រួតពិនិត្យ

រដ្ឋាភិបាលទទួលខុសត្រូវចំពោះសភា ប៉ុន្តែចំពោះតែរដ្ឋសភាដែលមានអំណាចបន្ទោសរដ្ឋាភិបាល ។ មធ្យោបាយត្រួតពិនិត្យឯទៀតមានសំរាប់ព្រឹទ្ធសភា ។

១-សិទ្ធិខាងព័ត៌មាន

ក-សំណួរ (questions)

ស្របតាមរដ្ឋធម្មនុញ្ញ សភាប៉ះពាល់ជាអាទិភាពមួយពេលយ៉ាងតិចក្នុងសប្តាហ៍ សំរាប់សមាជិកសភាតាំងសំណួរ និងសំរាប់រដ្ឋាភិបាលឆ្លើយ ។

ក្រៅពីពេលប្រជុំប្រចាំសប្តាហ៍ ព្រឹកថ្ងៃអង្គារដែលត្រៀមសំរាប់សំណួរផ្ទាល់មាត់ គ្មានការពិភាក្សា ព្រឹទ្ធសភារៀបចំពេលសួរផ្ទាល់មាត់មានការពិភាក្សា (ដែលខ្លះទាក់ទងនឹងការងារអ៊ីរ៉ុប) ក៏ដូចជារៀបចំ២ដងក្នុង១ខែនូវពេលប្រជុំរយៈ១ម៉ោងសំរាប់សំណួរបច្ចុប្បន្នភាពចំពោះរដ្ឋាភិបាល (ផ្សាយផ្ទាល់តាមស្ថានីយ៍ ប៉ុស្តិ៍លេខ៣ -France 3) ។

ម្យ៉ាងទៀត សមាជិកព្រឹទ្ធសភាអាចដាក់សំណួរជាលាយលក្ខណ៍អក្សរចំពោះរដ្ឋាភិបាល (នៅសម័យប្រជុំឆ្នាំ២០០៣-២០០៤ មានសំណួរ៤.៥៦១ និង ១ទទួលចំឡើយ ២០.៤៨៨) ។

ខ-ការពិភាក្សា (débats)

ព្រឹទ្ធសភាអាចស្នើរៀបចំការពិភាក្សាលើសេចក្ដីថ្លែងការណ៍របស់រដ្ឋាភិបាល ។

គ-បេសកកម្មរកព័ត៌មាននៃគណៈកម្មការអចិន្ត្រៃយ៍ (mission d'information des commissions permanentes)

ក្នុងការងារព័ត៌មាន គណៈកម្មការអចិន្ត្រៃយ៍មានសមត្ថកិច្ច ដែលអនុញ្ញាតឲ្យបំពេញមុខងារត្រួតពិនិត្យលើនយោបាយរបស់រដ្ឋាភិបាល ។ ចំពោះតម្រូវការនេះ គណៈកម្មការអាចបង្កើតក្រុមបេសកកម្មស្វែងរកព័ត៌មានការរៀប ចំសវនកម្ម ... ។

ការបដិសេធមិនទទួលមកតាមការកោះរបស់គណៈកម្មការ ត្រូវរងការពិន័យជាប្រាក់ ៧.៥០០អ៊ីរ៉ូ លើកលែងតែការសម្ងាត់នៃការការពារជាតិ កិច្ចការបរទេស សន្តិសុខក្នុងនិងក្រៅប្រទេស និងឯករាជភាពនៃតុលាការ ។

២-នាយករដ្ឋមន្ត្រីអាចស្នើព្រឹទ្ធសភាឲ្យអនុម័តសេចក្ដីថ្លែងការណ៍នយោបាយទូទៅ ។

៣-អំណាចស៊ើបអង្កេត

ក-គណៈកម្មការស៊ើបអង្កេត

ព្រឹទ្ធសភាអាចបង្កើតគណៈកម្មការស៊ើបអង្កេតសំរាប់រយៈពេលយ៉ាងយូរ៦ខែ ដែលមានសមត្ថកិច្ចស៊ើបរកព័ត៌មានលើការណីជាក់លាក់ឬលើការត្រប់ត្រងសេវាសាធារណៈ ឬសហត្រាសជាតិ ។

ជនទាំងឡាយដែលគណៈកម្មការយល់ថាមានប្រយោជន៍ចំពោះសវនកម្មហើយមិនឆ្លើយតបនឹងការកោះត្រូវរងទោសគុក២ឆ្នាំ និងទោសពិន័យជាប្រាក់ ៧.៥០០អឺរូ ។

អ្នកវាយការណ៍របស់គណៈកម្មការធ្វើការងាររបស់ខ្លួន ទាំងលើឯកសារ (sur pièces) ទាំងនៅលើទីកន្លែង (sur place) ។

ខ-ការស៊ើបអង្កេតនៃគណៈកម្មការអចិន្ត្រៃយ៍

១-ការអនុវត្តអំណាចស៊ើបអង្កេត

គណៈកម្មការអចិន្ត្រៃយ៍មានសិទ្ធិស្នើសុំសភានូវបុព្វសិទ្ធិ (prérogatives) សំរាប់បេសកកម្មស៊ើបអង្កេតមួយជាក់លាក់ និងសំរាប់រយៈពេលមិនលើសពី៦ ខែ ។

២-ការត្រួតពិនិត្យលើការអនុវត្តច្បាប់

ចាប់ពីឆ្នាំ១៩៧២ ដោយអនុវត្តការសម្រេចរបស់ការិយាល័យព្រឹទ្ធសភា គណៈកម្មការអចិន្ត្រៃយ៍ត្រួតពិនិត្យការអនុវត្តបទបញ្ជានានានៃច្បាប់ (contrôle de l'application réglementaire des lois) ។

៣-ការត្រួតពិនិត្យសហត្រាសសាធារណៈ

ការត្រួតពិនិត្យធ្វើឡើងដោយគណៈកម្មការ ដែលសមត្ថកិច្ចត្របដណ្តប់លើសកម្មភាពរបស់សហត្រាសជាតិ ឬ ក្រុមហ៊ុនសេដ្ឋកិច្ចចំរុះ : គណៈកម្មការចាត់តាំងអ្នកវាយការណ៍ទទួលបន្ទុកតាមមើល និងវាយតម្លៃការត្រប់ត្រងសហត្រាសទាំងនោះ ។

អ្នកវាយការណ៍អាចទទួលរបាយការណ៍ពិសេសពីតុលាការគណនី ហើយមានសមត្ថកិច្ចទទួលបាននូវឯកសារទាំងអស់ទាក់ទងនឹងដំណើរការរបស់សហត្រាស ដែលស្ថិតក្រោមការត្រួតពិនិត្យ ។ ម្យ៉ាងទៀតអ្នកវាយការណ៍មាន អំណាចស៊ើបអង្កេតលើឯកសារ និងនៅលើទីកន្លែង ។

គ-ការត្រួតពិនិត្យការអនុវត្តច្បាប់ហិរញ្ញវត្ថុ

អ្នកវាយការណ៍ពិសេស (rapporteurs spéciaux) នៃគណៈកម្មការហិរញ្ញវត្ថុ តាមមើលនិងត្រួតពិនិត្យជាអចិន្ត្រៃយ៍លើឯកសារ និងនៅលើទីកន្លែងនូវការប្រើប្រាស់ឥណទានដែល

បានកំណត់ ។ លើកលែងតែការសម្ងាត់នៃការការពារជាតិ កិច្ចការបរទេស សន្តិសុខក្នុងនិង ក្រៅប្រទេស និងឯករាជភាពនៃតុលាការ អ្នកវាយការណ៍ពិសេសមានសិទ្ធិទទួលបានឯកសារ ទាំងអស់នៃសេវាគ្រប់ប្រភេទ ។

តុលាការគណនីជួយសភា ក្នុងការត្រួតពិនិត្យការអនុវត្តច្បាប់ហិរញ្ញវត្ថុ និងដំណើរការ ស៊ើបអង្កេត ដែលគណៈកម្មការហិរញ្ញវត្ថុស្នើសុំ ។

បទប្បញ្ញត្តិជូចគ្នានេះត្រូវផ្តល់ឱ្យគណៈកម្មការកិច្ចការសង្គម និងអ្នកវាយការណ៍របស់ ខ្លួនក្នុងការត្រួតពិនិត្យការអនុវត្តច្បាប់ហិរញ្ញប្បទានសន្តិសុខសង្គម ។

៤-ការអភិវឌ្ឍន៍នៃការវាយតម្លៃ :ចាប់ពីដើមទសវត្សឆ្នាំ៨០ សមត្ថភាពរបស់សភាមាន ការរីកចំរើន ។

ហ្គាបុង ព្រឹទ្ធសភា

GABON LE SENAT

I-សមាសភាព

ព្រឹទ្ធសភាហ្គាបុងមានសមាជិក៩១នាក់ ជាតំណាងសមូហភាពដែនដី ។

II-របបបោះឆ្នោត

សមាជិកព្រឹទ្ធសភាត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយប្រយោល (មិនផ្ទាល់) ដោយសមាជិកក្រុមប្រឹក្សាក្រុង (membres des conseils municipaux) និងសមាជិកសភាខេត្ត (membres des assemblées départementales) ។

អាណត្តិ : ៦ឆ្នាំ

ការបោះឆ្នោតលើកទី១ : ២៦ ខែ មករា និង ៥ ខែ កុម្ភៈ ឆ្នាំ១៩៩៧

ការផ្ទាស់ប្តូរថ្មីចុងក្រោយ: ៥ ខែ កុម្ភៈ ឆ្នាំ២០០៣

លក្ខខណ្ឌអាយុ: ៤០ឆ្នាំ ជាជនជាតិហ្គាបុង

មិនអាចឈរឈ្មោះ : មន្ត្រីជាន់ខ្ពស់ខ្លះរបស់រដ្ឋាភិបាល និង សមាជិកកងប្រដាប់អាវុធ

វិសមិតភាព : សមាជិករដ្ឋាភិបាល សមាជិកតុលាការធម្មនុញ្ញ សមាជិកក្រុមប្រឹក្សាតមនាគមន៍ជាតិ ចៅក្រម មន្ត្រីជាន់ខ្ពស់ខ្លះ អត្តហេរញ្ញិក និងគណនេយ្យការសាធារណៈ បុត្តលិកនៃក្រុមប្រឹក្សារដ្ឋបាលសហគ្រាសសាធារណៈ ឬពាក់កណ្តាលសាធារណៈ បុត្តលិកដែលទទួលប្រាក់ក់រៃពីប្រទេសក្រៅ ឬពីអង្គការអន្តរជាតិ នាយនិងនាយរងនៃកម្លាំងសន្តិសុខ និងកម្លាំងការពារ ។

លក្ខខណ្ឌតំណាង : ត្រូវស្នើឡើងដោយគណបក្សនយោបាយ ក្រុមចំរុះគណបក្សនយោបាយ ឬដោយបុត្តល ។

III-សម័យប្រជុំ

ក-សម័យប្រជុំដោយពេញច្បាប់

ព្រឹទ្ធសភាប្រជុំនៅថ្ងៃធ្វើការទី១ក្រោយពីបោះឆ្នោត១៥ថ្ងៃ ។ របៀបវារៈមានតែការបោះឆ្នោតជ្រើសរើសប្រធាន និងការិយាល័យរបស់ព្រឹទ្ធសភា ។

ម្យ៉ាងទៀត ព្រឹទ្ធសភាប្រជុំនៅពេលប្រជាជាតិស្ថិតក្នុងភាពអាសន្ន ។

ខ-សម័យប្រជុំសាមញ្ញ

ព្រឹទ្ធសភាប្រជុំជាសមញ្ញពីរដងក្នុង១ឆ្នាំ :

- លើកទី១ បើកនៅថ្ងៃធ្វើការទី១ខែមីនា និងចប់នៅថ្ងៃធ្វើការចុងក្រោយខែ មិថុនា យ៉ាងយូរ ។

- លើកទី២ បើកនៅថ្ងៃធ្វើការទី១ខែកញ្ញា និងបិទនៅថ្ងៃធ្វើការចុងក្រោយខែ ធ្នូ យ៉ាងយូរ ។

គ-សម័យប្រជុំវិសាមញ្ញ

ព្រឹទ្ធសភាកោះប្រជុំជាវិសាមញ្ញ តាមរបៀបវារៈមួយជាក់លាក់ តាមសំណើរបស់ :

- ប្រធានាធិបតី តាមសំណើរបស់នាយករដ្ឋមន្ត្រី

-សមាជិកភាពច្រើនជាច់ខាតរបស់សភា ។

សម័យប្រជុំវិសាមញ្ញត្រូវបើក និងបិទដោយក្រឹត្យរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ។ សម័យប្រជុំវិសាមញ្ញមិនអាចហួសពី១៥ថ្ងៃទេ ។

IV-ដំណាក់កាលនៃការដាក់ជូនសេចក្ដីសម្រេចនីតិកម្ម

ក-អំណាចនីតិប្រតិបត្តិ

១-ការផ្ដួចផ្ដើមគំនិតធ្វើច្បាប់

ព្រឹទ្ធសភាមានសិទ្ធិផ្ដួចផ្ដើមគំនិតធ្វើច្បាប់ ។

២-សិទ្ធិវិសោធនកម្ម

សេចក្ដីស្នើច្បាប់ និងសេចក្ដីស្នើវិសោធនកម្មច្បាប់មិនអាចទទួលយកបានឡើយ កាលបើសេចក្ដីទាំងនោះនាំឱ្យកាត់បន្ថយចំណូលសាធារណៈបង្កើត ឬបន្ថែមបន្ទុកសាធារណៈដោយមិនធានាការដោះស្រាយចំណូល ។

វិសោធនកម្មមិនត្រូវមិនមានទំនាក់ទំនងជាមួយអត្ថបទដែលកំពុងពិភាក្សាទេ ។

៣-នីតិវិធី

ក-ការដាក់អត្ថបទ (dépôt des textes)

សេចក្តីព្រាងច្បាប់ត្រូវដាក់ជូនមកការិយាល័យរបស់សភាណាមួយ ។ សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់អង្គការ (lois organiques) ត្រូវលើកមកពិភាក្សា និងអនុម័តក្នុងសភា លុះណាតែហួស១៥ថ្ងៃ ចាប់ពីពេលដាក់ជូនមក ។

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ និងសេចក្តីព្រាងស្តីពីរដ្ឋធម្មនុញ្ញត្រូវដាក់ជូនជាលើកដំបូងមករដ្ឋសភា ។ សេចក្តីព្រាងដែលទាក់ទងនឹងសមុហភាពដែនដី ត្រូវដាក់ជូនជាលើកដំបូងមកព្រឹទ្ធសភា ។

សេចក្តីស្នើច្បាប់ទាំងឡាយដែលសភាដាក់ជូនរដ្ឋាភិបាល ហើយមិនបានពិនិត្យ ក្នុងរយៈពេល៦០ថ្ងៃត្រូវតែយកមកពិភាក្សា និងអនុម័តនៅក្នុងសភា ។

ខ-នីតិវិធីពិនិត្យ

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទាំងអស់ត្រូវតែពិនិត្យជាបន្តបន្ទាប់ដោយសភាទាំងពីរដើម្បីរកការព្រមព្រៀងគ្នា ។

ការអនុម័តជាការប្រញាប់អាចស្នើសុំដោយរដ្ឋាភិបាល ឬដោយសមាជិកភាគច្រើនដាច់ខាតរបស់សភា ។

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវបញ្ជូនទៅគណៈកម្មការមានសមត្ថកិច្ចរបស់សភាណាមួយពិនិត្យមុនយកទៅពិភាក្សា និងអនុម័តក្នុងសម័យប្រជុំពេញអង្គរបស់សភានោះ ។

បើរដ្ឋាភិបាលស្នើសុំ សភាដែលពិនិត្យអនុម័តតែម្តងគត់ (vote unique) លើអត្ថបទទាំងមូល ឬផ្នែកណាមួយនៃអត្ថបទដែលពិភាក្សា ដោយទទួលយកតែវិសោធនកម្មទាំងឡាយដែលស្នើឡើង ឬ ដែលទទួលយកដោយរដ្ឋាភិបាល ។

ការមិនទទួលយកវិសោធនកម្មទាំងឡាយ(irrecevabilité des amendements) អាចលើកឡើងដោយនាយករដ្ឋមន្ត្រី ឬប្រធានសភា តាមសំណើរបស់សមាជិកខ្លួនចំនួន ១/៥ ។ ក្នុងករណីមិនព្រមព្រៀងគ្នា តុលាការធម្មនុញ្ញពិនិត្យ និងសម្រេចក្នុងរយៈពេល៨ថ្ងៃ ។

ក្រោយបើកការពិភាក្សាជាសាធារណៈ ពុំមានវិសោធនកម្មណាមួយអាចទទួលយកបានឡើយ បើសិនជាវិសោធនកម្មទាំងនោះមិនបានពិនិត្យជាមុននៅក្នុងគណៈកម្មការជំនាញ ។

នាយករដ្ឋមន្ត្រីមានសិទ្ធិបង្កើតការប្រជុំគណៈកម្មការចំរុះនៃសភាទាំងពីរ ដែលទទួលបន្ទុកស្នើនូវអត្ថបទមួយលើបញ្ហាត្តិដែលកំពុងពិភាក្សា ។

បើគណៈកម្មការចំរុះមិនអាចរកអត្ថបទរួមបាន រដ្ឋាភិបាលស្នើសុំឱ្យរដ្ឋសភាសម្រេចជាស្ថាពរ ។

បើគណៈកម្មការចំរុះអនុម័តបានអត្ថបទរួម អត្ថបទរួមនេះទៅជាអត្ថបទរបស់សភាបានលុះត្រាតែសភានីមួយៗអនុម័តយល់ព្រម ។

 គ-បទប្បញ្ញត្តិទាក់ទងនឹងច្បាប់អង្គការ

ច្បាប់អង្គការត្រូវពិនិត្យនិងអនុម័តតាមនីតិវិធីធម្មតា ។ មុនប្រកាសឱ្យប្រើច្បាប់អង្គការត្រូវពិនិត្យដោយតុលាការធម្មនុញ្ញ តាមសំណើរបស់នាយករដ្ឋមន្ត្រី ។

បើជាការប្រញាប់ រយៈពេល១៥ថ្ងៃ ត្រូវបន្ថយមក៨ថ្ងៃ ។

ឃ-នីតិវិធីទាក់ទងនឹងថវិកា

នីតិវិធីសំរាប់ថវិកាដូចគ្នានឹងកម្មវិធីសំរាប់ច្បាប់ធម្មតា ។ ប៉ុន្តែ បើនៅសម័យប្រជុំអំពីថវិកា សភាមិនបានអនុម័តថវិកា រដ្ឋាភិបាលត្រូវបានអនុញ្ញាតឱ្យចេញបញ្ញត្តិ (ordonnance) ប្រើថវិកាឆ្នាំមុន ។

៤-ការផ្តល់នីតិសម្បទាអត្ថបទ

ក្នុងករណីប្រញាប់ ក្នុងរយៈពេលដែលសភាមិនប្រជុំ រដ្ឋាភិបាលអាចស្នើសុំសភាអនុញ្ញាត

ឱ្យចេញបញ្ញត្តិប្រើវិធានការទាំងឡាយដែលមានលក្ខណៈដូចជាច្បាប់ ដើម្បីអនុវត្តកម្មវិធីរបស់ខ្លួន ។ បញ្ញត្តិទាំងនោះត្រូវទទួលសច្ចាប័នពីសភានៅសម័យប្រជុំខាងមុខ ។ សភាមានសិទ្ធិកែប្រែបញ្ញត្តិទាំងនោះតាមរយៈវិសោធនកម្ម ។

ខ-អំណាចត្រួតពិនិត្យ

១-មធ្យោបាយត្រួតពិនិត្យ មានដូចតទៅ :

-ការកោះអញ្ជើញ

-សំណួរជាលាយលក្ខណ៍អក្សរនិងផ្ទាល់មាត់ :១ពេលក្នុង១សប្តាហ៍ត្រៀមសំរាប់សំណួរ ។ បញ្ហាបច្ចុប្បន្នភាពអាចជាកម្មវត្ថុនៃការកោះអញ្ជើញរដ្ឋាភិបាល ទោះបីជាក្នុងសម័យប្រជុំវិសាមញ្ញក៏ដោយ ។

-គណៈកម្មការស៊ើបអង្កេត និងត្រួតពិនិត្យ ។

២-អង្គការនីតិប្រតិបត្តិត្រូវផ្តល់ឱ្យសភានូវរាល់ព័តិមានដែលសភាស្នើសុំ លើការគ្រប់គ្រងនិង សកម្មភាពរបស់ខ្លួន ។

៣-វិស័យអន្តរជាតិ

ក-សច្ចាប័ន

អនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិត្រូវផ្តល់សច្ចាប័ន ក្រោយការអនុម័តច្បាប់អនុញ្ញាតដោយសភា ។ ត្មានវិសោធនកម្មណាមួយអាចទទួលយកបានទេ ។

ខ-ការចរចា

ប្រធានាធិបតីនៃសាធារណរដ្ឋ និងប្រធានសភាទាំងពីរត្រូវបានទទួលព័តិមានអំពីការចរចាដែលឈានទៅរកការព្រមព្រៀងជាអន្តរជាតិ ដែលមិនចាំបាច់មានសច្ចាប័ន ។

គ-ទំនាក់ទំនងជាមួយប្រធានាធិបតីនៃសាធារណរដ្ឋ

ប្រធានាធិបតីនៃសាធារណរដ្ឋទាក់ទងជាមួយសភានីមួយ១ តាមសារដែលអានដោយប្រធានសភានោះ ។ តាមសំណើរបស់ប្រធានាធិបតី សភានីមួយ១អាចទទួលសារ ។ សារទាំងនោះមិនអាចយកមកពិភាក្សាបានឡើយ ។

៧-បទប្បញ្ញត្តិដោយឡែក

ក-ការសើរើរដ្ឋធម្មនុញ្ញ

១-ការផ្តួចផ្តើម

ការផ្តួចផ្តើមគំនិតសើរើរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ក្រុមប្រឹក្សារដ្ឋមន្ត្រី និងសមាជិកសភា ។

២-នីតិវិធី

សេចក្តីស្នើសើរើរដ្ឋធម្មនុញ្ញត្រូវដាក់មកការិយាល័យរដ្ឋសភា (ឬព្រឹទ្ធសភា) ដោយសមាជិករដ្ឋសភា (ឬព្រឹទ្ធសភា)យ៉ាងតិច១/៣ ។

ការសើរើត្រូវសម្រេចតាមរយៈប្រជាមតិ ឬតាមរយៈសភា ។ បើតម្រូវតាមរយៈសភា សេចក្តីព្រាង ឬសេចក្តីស្នើសើរើត្រូវអនុម័តជាបន្តបន្ទាប់ដោយរដ្ឋសភា និងព្រឹទ្ធសភាដោយព្រមព្រៀងគ្នា ។

ការអនុម័តត្រូវមានវត្តមានយ៉ាងតិច២/៣នៃសមាជិកសភា ប្រជុំរួមជាសមាជ ។ សម្លេងសម្លេងភាគច្រើន២/៣ត្រូវប្រើសំរាប់អនុម័ត ។

ខ-វិស្សមកាលរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ

ក្នុងករណីវិស្សមកាល ឬករណីដែលមិនអាចបំពេញមុខងារបាន ប្រធានព្រឹទ្ធសភា ឬ (បើប្រធានព្រឹទ្ធសភាមិនអាចបំពេញមុខងារបាន) អនុប្រធានព្រឹទ្ធសភាទទួលជាប្រធានាធិបតីស្តីទី ។ វិស្សមកាលនេះត្រូវបញ្ជាក់ដោយតុលាការធម្មនុញ្ញ តាមសំណើរបស់រដ្ឋាភិបាល និងតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិករបស់ខ្លួន ។ ក្នុងករណីពុំមានការសម្រេចរបស់តុលាការធម្មនុញ្ញ ការិយាល័យនៃសភាទាំងពីរសម្រេចរួម តាមសម្លេងភាគច្រើននៃសមាជិករបស់ខ្លួន ។ ប្រធានាធិបតីស្តីទីមិនអាចដាក់ឱ្យធ្វើប្រជាមតិ ឬ រំលាយរដ្ឋសភាបានឡើយក្នុងរយៈពេលកាន់ជាស្តីទីនេះ ។

ប្រមុខរដ្ឋស្តីទីមិនអាចជាបេក្ខជនបោះឆ្នោតប្រធានាធិបតីឡើយ ។

ត-អនុប្រធានាធិបតីនៃសាធារណរដ្ឋ

អនុប្រធានាធិបតីតែងតាំងដោយប្រធានាធិបតីដែលបញ្ចប់ពីមុខងារ ក្រោយពីបានពិគ្រោះយោបល់ជាមួយប្រធានសភាទាំងពីរ ។

យ-អំណាចពិសេស

១-ស្ថានភាពបន្ទាន់ ឬស្ថានភាពអាសន្ន

បើស្ថានភាពតម្រូវ ក្រោយការអនុម័តរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី និងការពិគ្រោះយោបល់ជាមួយប្រធានសភាទាំងពីរ ប្រធានាធិបតីនៃសាធារណរដ្ឋអាចប្រកាសដោយក្រឹត្យដាក់ប្រជាជាតិក្នុងស្ថានភាពបន្ទាន់ ឬស្ថានភាពអាសន្នដែលផ្តល់អំណាចឱ្យប្រធានាធិបតី ។

២-ស្ថានភាពប្រុងប្រៀប និងស្ថានភាពប្រកាសអាសន្ន

ក- បើស្ថានភាពតម្រូវ ក្រោយការអនុម័តរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី និងការពិគ្រោះយោបល់ ជាមួយប្រធានសភាទាំងពីរ នាយករដ្ឋមន្ត្រីអាចចេញប្រកាសដាក់ប្រជាជាតិ ក្នុងស្ថានភាពប្រុងប្រៀប តាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ ។

ខ-ការប្រកាសស្ថានភាពអាសន្នធ្វើឡើង ក្រោយមានការអនុម័តរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី និងការពិគ្រោះយោបល់ជាមួយការិយាល័យនៃសភាទាំងពីរ ។

ត-ការបន្តស្ថានភាពណាមួយនៃស្ថានភាពទាំងពីរនេះលើសពី២១ថ្ងៃ ត្រូវមានការអនុញ្ញាតពីសភាទាំងពីរ ។

ង-តុលាការយុត្តិធម៌ជាន់ខ្ពស់

១-តុលាការមានសមាជិក១៣នាក់ ដែល៦នាក់ជ្រើសរើសដោយសភា អាស្រ័យតាមចំនួនសមាជិកនៃក្រុមនយោបាយនានា ។

២-ប្រធានាធិបតីត្រូវផ្តន្ទាទោសដោយតុលាការយុត្តិធម៌ជាន់ខ្ពស់ ក្នុងករណីរំលោភពាក្យសម្បថ ឬប្រព្រឹត្តក្បត់ធ្ងន់ធ្ងរ ។ប្រធានាធិបតីត្រូវចោទប្រកាន់ ដោយសភាតាមសម្លេងភាគច្រើន ២/៣ នៃចំនួនសមាជិករបស់ខ្លួន ដោយការបោះឆ្នោតសាធារណៈ ។

៣-អនុប្រធានាធិបតី ប្រធាន និងអនុប្រធានអង្គការជាន់ខ្ពស់ សមាជិករដ្ឋាភិបាលនិងសមាជិកតុលាការធម្មនុញ្ញ ត្រូវទទួលខុសត្រូវខាងព្រហ្មទ័ណ្ឌចំពោះមុខតុលាការយុត្តិធម៌ជាន់ខ្ពស់ លើសកម្មភាពក្នុងការប្រតិបត្តិមុខងារ និងដែលសកម្មភាពនោះមានលក្ខណៈជាបទល្មើសមជ្ឈឹម ឬ ឧក្រិដ្ឋ ក៏ដូចជាអ្នកសមគំនិតនិងសហការី ក្នុងករណីប៉ះពាល់ដល់សុវត្ថិភាពជាតិ ។
ក្នុងករណីនេះ ប្រធានាធិបតីអាចប្តឹងទៅតុលាការយុត្តិធម៌ជាន់ខ្ពស់ ។

ច-ការប្រជុំ

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់ តាមសំណើរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ នាយករដ្ឋមន្ត្រី ឬរបស់សមាជិកព្រឹទ្ធសភាចំនួន១/៥ ។

ឆ-ការរំលាយរដ្ឋសភា

រដ្ឋសភាអាចរំលាយដោយប្រធានាធិបតីនៃសាធារណរដ្ឋ ក្រោយពីបានពិគ្រោះយោបល់ជាមួយនាយករដ្ឋមន្ត្រី និងប្រធានសភា ។

ជ-តុលាការធម្មនុញ្ញ

១-សមាសភាព

តុលាការធម្មនុញ្ញមានសមាជិក៩នាក់ ដែល៣នាក់តែងតាំងដោយប្រធានព្រឹទ្ធសភា សំរាប់អាណត្តិ៧ឆ្នាំ ផ្លាស់ប្តូរថ្មីតែ១ដង ។ សមាជិកទាំងអស់ធ្វើសច្ចាប្រណិធាននៅមុខប្រធានាធិបតីនៃសាធារណរដ្ឋ សភា និងតុលាការយុត្តិធម៌រដ្ឋបាល និងគណនី ។

២-សមត្ថកិច្ច

តុលាការធម្មនុញ្ញសម្រេចលើបទបញ្ជារបស់ព្រឹទ្ធសភា អំពីធម្មនុញ្ញភាព ។

ប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភាចំនួន១/១០ អាចសុំឱ្យតុលាការធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ។ក្នុងករណីដែលតុលាការសម្រេចថាមិនស្របនឹងរដ្ឋធម្មនុញ្ញ សភាត្រូវយកទៅពិនិត្យឡើងវិញនៅសម័យប្រជុំបន្ទាប់ ។

ប្រធានព្រឹទ្ធសភាឬសមាជិកព្រឹទ្ធសភាចំនួន១/១០អាចសុំឱ្យតុលាការធម្មនុញ្ញបកស្រាយរដ្ឋធម្មនុញ្ញ និងអត្ថបទនានាដែលមានតម្លៃធម្មនុញ្ញ ។

រៀងរាល់ឆ្នាំ តុលាការធម្មនុញ្ញផ្ញើរបាយការណ៍សកម្មភាពរបស់ខ្លួនទៅប្រធានាធិបតីនៃសាធារណរដ្ឋ និងប្រធានសភាទាំងពីរ ។

ឈ-ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម

ដោយមានការចូលរួមពីអង្គភាពផ្សេងៗជាសមាជិក តាមតម្រូវការរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ រដ្ឋាភិបាលនិងសភា ក្រុមប្រឹក្សារៀបចំចងក្រងឯកសារប្រចាំឆ្នាំអំពីសភាពការណ៍សេដ្ឋកិច្ចនិងសង្គម ។

រដ្ឋាភិបាល និងសភាមានកាតព្វកិច្ចពិនិត្យលើយោបល់ឬរបាយការណ៍ ដែលក្រុមប្រឹក្សារៀបចំឡើង ក្នុងរយៈពេលយ៉ាងយូរបំផុត៣ខែសំរាប់រដ្ឋាភិបាល និងមុនពេលចប់សម័យប្រជុំសំរាប់សភា ។

ញ-តុលាការគណនី

តុលាការគណនីមានភារកិច្ចត្រួតពិនិត្យការអនុវត្តច្បាប់ហិរញ្ញវត្ថុ និងផ្តល់ព័ត៌មាននេះដល់សភា ។

ត-ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

នៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រឹទ្ធសភាមានតំណាង២នាក់ជាសមាជិកព្រឹទ្ធសភាចាត់តាំងដោយប្រធានព្រឹទ្ធសភា ។ សមាជិកទាំង២នាក់ជាអ្នកពិគ្រោះយោបល់ ។

ថ-ក្រុមប្រឹក្សាគមនាគមន៍ជាតិ

ក្រុមប្រឹក្សាមានសមាជិក៩នាក់ ដែលពានាក់ចាត់តាំងដោយប្រធានព្រឹទ្ធសភា ។

I-សមាសភាព

ព្រឹទ្ធសភាមានសមាជិកចំនួន១៣នាក់ ដែលតែងតាំងដោយអគ្គទេសាភិបាល :

-៧នាក់ តាមសំណើរបស់នាយករដ្ឋមន្ត្រី

-៣នាក់ តាមសំណើរបស់ប្រមុខគណបក្សជំទាស់

-៣នាក់ តាមសំណើរបស់នាយករដ្ឋមន្ត្រី (តំណាងផលប្រយោជន៍ ដែលនាយករដ្ឋមន្ត្រីយល់ថាចាំបាច់) ក្រោយពីបានពិគ្រោះយោបល់ជាមួយអង្គការដែលមានភាពជាតំណាងនានា ។

II-របបតែងតាំង

អាណត្តិ : ៥ឆ្នាំ

ការរៀបចំចុងក្រោយ : ២៧ វិច្ឆិកា ឆ្នាំ ២០០៣

លក្ខខណ្ឌអាយុ : ១៨ឆ្នាំ ជាពលរដ្ឋ commonweath រស់នៅរយៈពេល១២ខែមុនការតែងតាំង និយាយភាសាអង់គ្លេស ។

មិនអាចតែងតាំងបាន : ក្យាយធនដែលមិនទាន់មានទីតាំសម្ឫទ្ធាឡើងវិញ សសៃប្រសាទ ជាប់ការពាក់ព័ន្ធជាមួយប្រទេសក្រៅ មានទោសដល់ជីវិត ទោសគុកលើសពី១ឆ្នាំ ជាប់កិច្ចសន្យារដ្ឋបាល ។

តុលាការកំពូលវិនិច្ឆ័យអំពីសុពលភាពនៃការតែងតាំងសមាជិកព្រឹទ្ធសភា ។

III-សម័យប្រជុំ

ក-អគ្គទេសាភិបាលកំណត់ពេលបើក និងបិទសម័យប្រជុំ ។ ព្រឹទ្ធសភាមានយ៉ាងតិច១សម័យប្រជុំក្នុង១ឆ្នាំ ហើយមានរយៈពេលមិនលើសពី៦ខែ ។

ខ-ការលើកពេលប្រជុំ

បើកកូរ៉ុមមិនគ្រប់ (ចំនួន៦) ពេលប្រជុំត្រូវលើកទៅពេលក្រោយ ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

សភាមានព្រះមហាក្សត្រអង់គ្លេស ព្រឹទ្ធសភា និងរដ្ឋសភា(សភាតំណាង) ។

ក-អំណាចនីតិប្បញ្ញត្តិ

១-ឥទ្ធិពលផ្តួចផ្តើមធ្វើច្បាប់

សមាជិកព្រឹទ្ធសភា ឬសមាជិករដ្ឋសភាមានសិទ្ធិផ្តួចផ្តើមឥទ្ធិពលធ្វើច្បាប់ ។ ប៉ុន្តែសិទ្ធិនេះត្រូវបានកំរិតចំពោះសេចក្តីស្នើច្បាប់ធានាហិរញ្ញវត្ថុសាធារណៈ ច្បាប់បង្កើត ឬបង្កើនពន្ធដារ ឬបន្ទុកផ្សេងៗ (ទៅតាមការវាយតម្លៃរបស់ប្រធានប្រជុំ) លើកលែងតែរដ្ឋាភិបាលយល់ព្រម ។

២-សិទ្ធិវិសោធនកម្ម

សមាជិកព្រឹទ្ធសភា ឬសមាជិករដ្ឋសភាមានសិទ្ធិធ្វើវិសោធនកម្ម ។ ប៉ុន្តែសិទ្ធិនេះត្រូវបានកំរិតចំពោះសេចក្តីស្នើវិសោធនកម្មច្បាប់ធានាហិរញ្ញវត្ថុសាធារណៈ ច្បាប់បង្កើត ឬបង្កើនពន្ធដារ ឬបន្ទុកផ្សេងៗ(ទៅតាមការវាយតម្លៃរបស់ប្រធានអង្គប្រជុំ) លើកលែងតែរដ្ឋាភិបាលយល់ព្រម ។

៣-នីតិវិធី

សេចក្តីព្រាងច្បាប់អាចដាក់ជូនសភាណាមួយក៏បាន លើកលែងតែសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុដែលត្រូវតែដាក់ជូនរដ្ឋសភា ។ ការអនុម័តត្រូវយកតាមសម្លេងភាគច្រើន ។ ប្រធានអង្គប្រជុំមិនអនុម័តទេ លើកលែងតែមានការចែកសម្លេងជាពីរស្មើគ្នា នៅពេលអនុម័តអត្ថបទច្បាប់ជាលើកចុងក្រោយ ។

ក-នីតិវិធីធម្មតា

សេចក្តីព្រាងច្បាប់ត្រូវតែអនុម័តដោយសភាទាំងពីរ ។

បើសេចក្តីព្រាងច្បាប់ណាមួយ ដែលអនុម័តពីរដងដោយរដ្ឋសភា នៅពីរសម័យប្រជុំបន្តបន្ទាប់គ្នា ហើយបានបញ្ជូនទៅព្រឹទ្ធសភាយ៉ាងតិចរយៈ១ខែ មុនចប់សម័យប្រជុំនីមួយៗ ត្រូវព្រឹទ្ធ-សភាបដិសេធរាល់លើក សេចក្តីព្រាងច្បាប់នោះត្រូវបញ្ជូនទៅអគ្គទេសាភិបាល ដើម្បីប្រកាសឱ្យប្រើ បើសិនជារដ្ឋសភាមិនសម្រេចអ្វីផ្សេងពីនេះ ហើយបើចម្ងាយពីពេលប្រជុំមួយទៅពេលប្រជុំមួយទៀតរបស់រដ្ឋសភា មានរយៈពេលយ៉ាងតិច១ខែ ។

នៅពេលពិនិត្យលើកទី២ រដ្ឋសភាអាចសុំឱ្យព្រឹទ្ធសភាធ្វើវិសោធនកម្ម ។ បើព្រឹទ្ធសភាយល់ព្រម វិសោធនកម្មទាំងនោះចាត់ទុកថាជាវិសោធនកម្មរបស់ព្រឹទ្ធសភាដែលមានការយល់ព្រមពីរដ្ឋសភា ។

ដើម្បីអនុវត្តបទប្បញ្ញត្តិខាងលើ អត្ថបទដែលចាត់ទុកថាបដិសេធដោយព្រឹទ្ធសភា ជាអត្ថបទដែលមិនបានអនុម័តដោយគ្មានវិសោធនកម្ម ឬបានអនុម័តដោយមានវិសោធនកម្មដែលរដ្ឋសភាបដិសេធ ។

ចំពោះច្បាប់ធម្មតាផ្សេងពីច្បាប់ហិរញ្ញវត្ថុ វិសោធនកម្មរបស់ព្រឹទ្ធសភាត្រូវចាត់ទុកថាអនុម័តដោយរដ្ឋសភា លុះណាតែបានអនុម័តយល់ព្រមតាមសម្លេងភាគច្រើន ២/៣យ៉ាងតិច នៃចំនួនសមាជិករដ្ឋសភា ។

ខ-បទប្បញ្ញត្តិដោយឡែកសំរាប់ច្បាប់ហិរញ្ញវត្ថុ

១-សេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុត្រូវដាក់ជូនរដ្ឋសភាអនុម័តជាលើកដំបូង ។

រដ្ឋសភាអាចសម្រេចទោះជាមានការជំទាស់ពីព្រឹទ្ធសភាក៏ដោយ ។

បើសិនជាសេចក្ដីព្រាងច្បាប់ដែលអនុម័តដោយរដ្ឋសភា មិនបានព្រឹទ្ធសភាអនុម័តដោយគ្មានវិសោធនកម្ម ក្នុងខែបន្ទាប់ពីពេលរដ្ឋសភាបញ្ជូនទៅ ទោះបីជាបានបញ្ជូនទៅយ៉ាងតិច១ ខែមុនចប់សម័យប្រជុំក៏ដោយ សេចក្ដីព្រាងច្បាប់នោះត្រូវបញ្ជូនទៅអគ្គទេសាភិបាលដើម្បីប្រកាសឱ្យប្រើ បើសិនជារដ្ឋសភាមិនសម្រេចអ្វីផ្សេងទៀត ។

លក្ខណៈរបស់ច្បាប់ហិរញ្ញវត្ថុត្រូវបញ្ជាក់ដោយប្រធានរដ្ឋសភា នៅពេលបញ្ជូនអត្ថបទនោះទៅព្រឹទ្ធសភា ។

២-សភាអាចសម្រេចបង្កើតមូលនិធិជាយថាហេតុ និងអនុញ្ញាតឱ្យរដ្ឋមន្ត្រីហិរញ្ញវត្ថុប្រើមូលនិធិ គ្មានការគ្រោងទុក ក្នុងករណីចាំបាច់ ។ សេចក្ដីព្រាងច្បាប់កែតម្រូវហិរញ្ញវត្ថុត្រូវដាក់ជូនរដ្ឋសភាយ៉ាងឆាប់បំផុត ។

ខ-អំណាចត្រួតពិនិត្យ

រដ្ឋាភិបាលទទួលខុសត្រូវរួមចំពោះសភាលើរាល់អនុសាសន៍ ដែលលើកទៅអគ្គទេសា-

ភិបាលដោយ ឬតាមបញ្ជាទូទៅរបស់រដ្ឋាភិបាលលើកិច្ចការដែលបំពេញដោយ ឬតាមបញ្ជារបស់រដ្ឋមន្ត្រីណាម្នាក់ ក្នុងការអនុវត្តមុខងាររបស់ខ្លួន (ប៉ុន្តែញត្តិបន្ទោសត្រូវអនុម័តដោយរដ្ឋសភា តែឯកឯង) ។

ត-ការរំលាយ និងពន្យារពេល

១-អត្តទេសាភិបាលអាចរំលាយឬពន្យារអាណត្តិសភាបានគ្រប់ពេល តាមយោបល់របស់នាយករដ្ឋមន្ត្រី ។

២-បើសភាបដិសេធការអនុម័តផ្តល់ការទុកចិត្តដែលនាយករដ្ឋមន្ត្រីបានស្នើ (ប្រមុខនៃសម្លេងភាគច្រើន) ឬបើសភាអនុម័តដកសេចក្តីទុកចិត្តពីរដ្ឋាភិបាល ពេលនោះរដ្ឋសភា (ក៏ដូចជាព្រឹទ្ធសភា) ត្រូវរលាយ បើរដ្ឋសភាមិនអាចរកជំនួសដោយសម្លេងភាគច្រើន ។

ការបោះឆ្នោតត្រូវរៀបចំក្នុងរយៈពេលពាខែ និងដោយមានការតែងតាំងសមាជិកព្រឹទ្ធ-សភាផង ។

V-បទប្បញ្ញត្តិដោយឡែក

ក-ការសើរើរដ្ឋធម្មនុញ្ញ

សេចក្តីព្រាងច្បាប់ធម្មនុញ្ញ (ឬកែប្រែបទប្បញ្ញត្តិទាក់ទងនឹងការរៀបចំតុលាការ) មិនអាចបញ្ជូនទៅព្រឹទ្ធសភាបានឡើយ បើសិនរដ្ឋសភាមិនបានអនុម័តជាមុននូវសេចក្តីសម្រេចចិត្ត ដែលស្នើសើរើនេះ តាមសម្លេងភាគច្រើន២ពានៃសមាជិករបស់ខ្លួន ។

ចំពោះការសើរើបទប្បញ្ញត្តិខ្លះនៃរដ្ឋធម្មនុញ្ញ (ឬបទប្បញ្ញត្តិទាក់ទងនឹងការរៀបចំអង្ត-ការតុលាការ) លក្ខខណ្ឌនៃរយៈពេលត្រូវ ក្នុងចន្លោះការអានពីរ កំណត់ដោយសភានោះ ហើយត្រូវមានការយល់ព្រមពីសភាទាំងពីរ ។

ក្នុងករណីដែលអត្ថបទត្រូវព្រឹទ្ធសភាបដិសេធ មានការតម្រូវឱ្យបដិសេធ២លើក ជាបន្តបន្ទាប់ ហើយមានការធ្វើប្រជាមតិ ដែលអនុម័តតាមសម្លេងភាគច្រើន២ពានៃអ្នកបោះ ។

ក្នុងគ្រប់ករណី រដ្ឋសភាអនុម័តជាចុងក្រោយលើអត្ថបទសើរើរដ្ឋធម្មនុញ្ញ តាមសម្លេងភាគច្រើន២/៣នៃសមាជិករបស់ខ្លួន ។

ខ-ប្រធានព្រឹទ្ធសភា

ប្រធានព្រឹទ្ធសភាត្រូវជ្រើសរើសក្នុងព្រឹទ្ធសភា ។ ប្រធានព្រឹទ្ធសភាមិនអាចជារដ្ឋមន្ត្រី ឬជារដ្ឋលេខាធិការឡើយ ។

គ-ស្ថានភាពបន្ទាន់

អគ្គទេសាភិបាលអាចប្រកាសស្ថានភាពបន្ទាន់(ករណីសង្គ្រាម) ដោយមិនមានរំលងចោលបញ្ញត្តិធម្មនុញ្ញទាក់ទងនឹងទាសភាព និងការប្រកាន់ពូជសាសន៍ ។

ការប្រកាសនេះត្រូវមានការយល់ព្រមពីសភាក្នុងរយៈពេល២១ថ្ងៃ ។ សភាក៏អាចអនុ-ម័ត រយៈពេលបន្ទាន់ (យ៉ាងយូរ៦ខែអាចបន្តបាន) តាមសម្លេងភាគច្រើននៃសមាជិករបស់ខ្លួន ។

ឃ-រដ្ឋមន្ត្រី ក៏ដូចជារដ្ឋលេខាធិការត្រូវជ្រើសរើសពីក្នុងចំណោមសមាជិកព្រឹទ្ធសភា ឬពីអ្នកតំណាង ។

ហាយទី **ព្រឹទ្ធសភា**

HAITI LE SENAT

អំណាចនីតិប្បញ្ញត្តិបានវិស្សមកាលតាំងពីខែមករា ឆ្នាំ២០០៤ ដោយចប់អាណត្តិ របស់រដ្ឋសភា និងមួយផ្នែកនៃព្រឹទ្ធសភា ។

ការបោះឆ្នោតព្រឹទ្ធសភាដែលត្រោងច្នើនៅខែវិច្ឆិកាឆ្នាំ២០០៥ បានប្រព្រឹត្តទៅនៅខែ កុម្ភៈ(ជុំទី១) និងខែមេសា (ជុំទី២) ឆ្នាំ២០០៦ ។

I-សមាសភាព

ព្រឹទ្ធសភាមានសមាជិកជ្រើសតាំងចំនួន២៧នាក់(៣នាក់ក្នុងមួយខេត្ត) ។

II-បេបបោះឆ្នោត

ប្រព័ន្ធ :បោះឆ្នោតដោយផ្ទាល់ តាមសម្លេងភាគច្រើនដាច់ខាត ជា២ជុំ បើចាំបាច់

អាណត្តិ : ៦ឆ្នាំ ផ្ទាស់ប្តូរថ្មី១/៣ រៀងរាល់២ឆ្នាំ

ការផ្ទាស់ប្តូរចុងក្រោយ: ៧ កុម្ភៈ និង ២១ មេសា ឆ្នាំ២០០៦

លក្ខខណ្ឌ :អាយុ៣០ឆ្នាំ សញ្ជាតិហាយទីពីកំណើត មានសិទ្ធិស៊ីវិល និងនយោបាយ រស់នៅរយៈពេលយ៉ាងតិច៤ឆ្នាំជាប់ត្នាក្នុងខេត្ត កម្មសិទ្ធិការលើដីធ្លី និងប្រកបមុខរបរណាមួយក្នុងខេត្ត ។

មិនអាចជាសមាជិកព្រឹទ្ធសភា : មានទោសដែលទាក់ទងដល់រូបកាយ និងដល់ក្បៀវ្លោះ ។

វិសមិតភាព : អភិបាលមូលនិធិសាធារណៈ អ្នកមានផលប្រយោជន៍ពីកិចួសន្យាជាមួយរដ្ឋាភិបាល តំណាងឬភ្នាក់ងារ ឬសហគ្រាស ឬក្រុមហ៊ុនដែលបានចុះហត្ថលេខាជាមួយរដ្ឋ ប្រតិភូ ឬប្រតិភូរង ចៅក្រម និងមន្ត្រីជាន់ខ្ពស់នៃក្រសួង លើកលែងតែបានលាលែងយ៉ាងតិច៦ខែមុនពេលបោះឆ្នោត សមាជិករដ្ឋាភិបាល និងអត្តនាយកនៃរដ្ឋបាលសាធារណៈ លើកលែងតែបានលាលែងយ៉ាងតិច១ឆ្នាំមុនពេលបោះឆ្នោត ត្រប់តំណែងដែលទទួលប្រាក់ឈ្នួលពីរដ្ឋ លើកលែងតែមុខងារត្រួបង្រៀន ។

III-សម័យប្រជុំ

ក-សម័យប្រជុំអចិន្ត្រៃយ៍

ព្រឹទ្ធសភាប្រជុំជាអចិន្ត្រៃយ (រដ្ឋសភាមាន២សម័យប្រជុំក្នុង១ឆ្នាំ) ។ ព្រឹទ្ធសភាប្រជុំ៣ ថ្ងៃក្នុង១សប្តាហ៍ (អង្គារ ពុធ ព្រហស្បតិ៍) ថ្ងៃច័ន្ទ និងសុក្រ សំរាប់ប្រជុំគណៈកម្មការនានា ។

ព្រឹទ្ធសភាអាចលើកពេលប្រជុំ លើកលែងតែក្នុងសម័យប្រជុំពិនិត្យច្បាប់ ។ កាលណាលើកពេលប្រជុំ ព្រឹទ្ធសភាទុកឱ្យគណៈកម្មការអចិន្ត្រៃយ៍មួយទទួលបន្ទុកដោះស្រាយកិច្ចការប្រចាំថ្ងៃភ្លាម១ ។ គណៈកម្មការនេះមិនអាចចេញប្រកាសអ្វីបានទេ លើកលែងតែការកោះប្រជុំព្រឹទ្ធសភា ។ ក្នុងករណីប្រញាប់ រដ្ឋាភិបាលក៏អាចកោះប្រជុំព្រឹទ្ធសភាមុនផុតរយៈពេលលើកពេលប្រជុំ ។

ខ-របៀបវារៈ

សន្ធិសីទបណ្តាប្រធានបង្កើតរួមគ្នា នូវរបៀបវារៈប្រជុំ សំរាប់១ខែ ។ របៀបវារៈមានតាមលំដាប់អាទិភាព ។

ព្រឹទ្ធសភាអាចប្រជុំជាផ្លូវការបានលុះត្រាតែមានកូរ៉ុម១៤ ដោយរាប់ទាំងប្រធានផង ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

ពុំមានសភាណាមួយអាចប្រជុំ ឬអាចចេញសេចក្តីសម្រេចចិត្តអ្វីបានឡើយបើពុំមានសមាជិកវត្តមានចំនួនភាគច្រើន ។

កិច្ចការទាំងអស់ត្រូវអនុម័តតាមសម្លេងភាគច្រើននៃសមាជិកវត្តមាន ។

១-សិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់

សភានីមួយ១ និងរដ្ឋាភិបាលមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។ ប៉ុន្តែមានតែរដ្ឋាភិបាលទេទើបមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ថវិកា និងពន្ធដារ ។

២-សិទ្ធីវិសោធនកម្ម

សភានីមួយ១មានសិទ្ធិធ្វើវិសោធនកម្ម ។ វិសោធនកម្មដែលអនុម័តដោយសភាណាមួយ អាចជាចំណែកនៃសេចក្តីព្រាងច្បាប់ ក្រោយពីសភាមួយទៀតបានអនុម័តដោយទម្រង់ និងខ្លឹមសារដូចគ្នា ។

៣-នីតិវិធីធ្វើច្បាប់

ក-នីតិវិធីធម្មតា

ក្នុងករណីមិនព្រមព្រៀងគ្នា សេចក្តីព្រាងច្បាប់ត្រូវផ្ទាករហូតដល់សម័យប្រជុំខាងមុខ ។ ក្នុងករណីមិនព្រមព្រៀងគ្នានៅសម័យប្រជុំខាងមុខ សភានីមួយ១ចាត់តាំងតាមបញ្ជី និងចំនួនស្មើគ្នាដើម្បីបង្កើតគណៈកម្មការទទួលតាក់តែងអត្ថបទជាស្ថាពរ ដែលត្រូវដាក់ជូនសភាទាំងពីរដោយចាប់ផ្តើមនៅសភាដែលអនុម័តជាខាងដើម ។

ក្នុងករណីមិនព្រមព្រៀងគ្នា សេចក្តីព្រាងឬសេចក្តីស្នើច្បាប់ត្រូវដកចេញ ។ ក្នុងករណីមិនព្រមព្រៀងគ្នារវាងស្ថាប័ននីតិប្បញ្ញត្តិនិងស្ថាប័ននីតិប្រតិបត្តិ គណៈកម្មការសម្របសម្រួលមួយទទួលដោះស្រាយទំនាស់ ។ បើគណៈកម្មការនេះបរាជ័យក្នុងការងារ សាលាវិនិច្ឆ័យទទួលដោះស្រាយទំនាស់ ។ សេចក្តីសម្រេចរបស់សាលាវិនិច្ឆ័យជាសេចក្តី សម្រេចចុងក្រោយ និងតម្រូវចំពោះភាគីទាំងអស់ ។

ខ-នីតិវិធីថវិកា

សេចក្តីព្រាងច្បាប់ថវិកា និងពន្ធដារត្រូវដាក់មករដ្ឋសភាជាលើកដំបូង ។ ក្នុងករណីមិនព្រមព្រៀងគ្នា សភាទាំងពីរបង្កើតគណៈកម្មការសមភាគីមួយ ដើម្បីដោះស្រាយទំនាស់ជាលើកចុងក្រោយ ។

៤-សិទ្ធិជំទាស់

ប្រធានាធិបតីនៃសាធារណរដ្ឋមានសិទ្ធិជំទាស់ទាំងស្រុងឬមួយផ្នែកនៃសេចក្តីព្រាងច្បាប់មុនប្រកាសឱ្យប្រើ ។

បើសភាណាមួយនិងសភាមួយទៀតបដិសេធការជំទាស់នេះ ប្រធានាធិបតីក៏នៅតែប្រកាសឱ្យប្រើច្បាប់ ។

ខ-អំណាចត្រួតពិនិត្យ

១-សភានីមួយៗមានសិទ្ធិស៊ើបអង្កេតលើបញ្ហាដែលជាសមត្ថកិច្ច ។

២-សិទ្ធិសួរ និងសួរដេញដោលសមាជិករដ្ឋាភិបាលឬរដ្ឋាភិបាលទាំងមូល លើបញ្ហានៃការគ្រប់គ្រងត្រូវផ្តល់ឱ្យសមាជិកគ្រប់រូបរបស់សភា ។ សំណើសុំសួរដេញដោលរបស់សមាជិកសភាណាត្រូវមានការគាំទ្រពីសមាជិកនៃសភានោះចំនួន ៥នាក់ ។ការសួរដេញដោលត្រូវបញ្ចប់ ដោយការអនុម័តផ្តល់ការទុកចិត្ត ឬអនុម័តញត្តិបន្ទោស តាមសម្លេងភាគច្រើន ។

កាលណាសំណើសួរដេញដោលឈានដល់ការអនុម័តញត្តិបន្ទោសដែលទាក់ទងនឹងកម្មវិធីឬការប្រកាសនយោបាយទូទៅរបស់រដ្ឋាភិបាល នាយករដ្ឋមន្ត្រីត្រូវដាក់ទៅប្រធានាធិបតីនៃសាធារណរដ្ឋនូវពាក្យលាលែងរបស់រដ្ឋាភិបាល ។

ទីតាំងនេះអាចប្រើបានតែ១ដងក្នុង១ឆ្នាំ ។

៣-ព្រឹទ្ធសភាតាមមើលការអនុវត្តច្បាប់ និងការអនុវត្តថវិកាជាតិ ។

៤-ព្រឹទ្ធសភាអាចបង្កើតបេសកកម្មរកព័ត៌មាន ឬស៊ើបអង្កេត ។

៥-ក្រោយការតែងតាំង នាយករដ្ឋមន្ត្រីនិងរដ្ឋាភិបាលត្រូវបង្ហាញខ្លួនចំពោះសភា ដើម្បីបានទទួលការអនុម័តផ្តល់ការទុកចិត្តលើការប្រកាសនយោបាយទូទៅរបស់រដ្ឋាភិបាល ។

 គ-ការរំលាយ និងការពន្យារ

ព្រឹទ្ធសភា(ឬរដ្ឋសភា) មិនអាចត្រូវរំលាយ ឬពន្យារអាណត្តិឡើយ ។

៧-ចរិយាសម្ព័ន្ធនៃនីតិប្រតិបត្តិ

ក-ការជ្រើសរើសប្រធានព្រឹទ្ធសភា

ពេលចាប់ផ្តើមនីតិកាលទីមួយ១ និងនៅពេលប្រជុំទី១បន្ទាប់ពីការផ្លាស់ប្តូរថ្មីជាផ្នែក ការិ-យាល័យ (សមាជិកដែលមានអាយុច្រើនជាងគេ) រៀបចំការបោះឆ្នោតជាសម្ងាត់ជ្រើសរើសប្រធាន តាមសម្លេងភាគច្រើនដាច់ខាតនៃចំនួនដែលបានបោះ ។ បើនៅជុំទី១ ពុំមានបេក្ខជនណាបានទទួលសម្លេងភាគច្រើនដាច់ខាត ត្រូវរៀបចំជុំទី២សំរាបបេក្ខជនដែលមានចំណាត់ថ្នាក់

ទី១ និងទី២ ។ នៅជុំទី២ ត្រូវយកតាមសម្លេងភាគច្រើនដោយប្រៀបនៃចំនួនដែលបានបោះ ។ បើបានសម្លេងស្មើគ្នា បេក្ខជនដែលមានអាយុច្រើនជាងជាអ្នកឈ្នះ ។

ខ-ការកិច្ចរបស់សភាជាតិ

-ការបើកនិងបិទសម័យប្រជុំនីមួយៗ

-ការទទួលសម្បថរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ស្របតាមរដ្ឋធម្មនុញ្ញ

-ការផ្តល់សច្ចាប័នលើសេចក្តីសម្រេចទាំងអស់អំពីការប្រកាសសង្គ្រាម ការយល់ព្រមលើអនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ

-ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ

-ការផ្តល់សច្ចាប័នលើសេចក្តីសម្រេចរបស់រដ្ឋាភិបាល អំពីការប្តូរទីតាំងទីស្នាក់ការរបស់រដ្ឋាភិបាល

-កាលានុវត្តនភាពនៃស្ថានភាពអាសន្ន

-ការបង្កើតក្រុមប្រឹក្សាបោះឆ្នោតអចិន្ត្រៃយ៍

-ការទទួលតុល្យការនៃសកម្មភាពរបស់រដ្ឋាភិបាល នៅពេលបើកសម័យប្រជុំនីមួយៗ ។

សភាជាតិដឹកនាំដោយប្រធានព្រឹទ្ធសភា ដែលមានប្រធានរដ្ឋសភាជាជំនួយក្នុងហ៊ានៈ ជាអនុប្រធាន ។ ការប្រជុំសភាជាតិត្រូវធ្វើជាសាធារណៈ ។

ក្នុងករណីប្រញាប់ រដ្ឋាភិបាលអាចកោះប្រជុំសភាជាតិជាវិសាមញ្ញ ។

សភាជាតិមិនអាចប្រជុំ ឬធ្វើការសម្រេច និងសម្រេចចិត្ត ដោយគ្មានវត្តមានសមាជិកភាគច្រើននៃសភានីមួយៗឡើយ ។

ค-តុលាការយុត្តិធម៌ជាន់ខ្ពស់

ក្រោយពី២៧នៃសមាជិករដ្ឋសភាបានធ្វើការចោទប្រកាន់ ព្រឹទ្ធសភាអាចប្រគល់ទៅតុលាការយុត្តិធម៌ជាន់ខ្ពស់ ។ ការងាររបស់តុលាការត្រូវដឹកនាំដោយប្រធានព្រឹទ្ធសភា ដោយមានប្រធាននិងអនុប្រធានសាលាវិនិច្ឆ័យជាជំនួយ ។

តុលាការចាត់តាំងសមាជិកព្រឹទ្ធសភាជាគណៈកម្មការ ឱ្យទទួលបន្ទុកស៊ើបអង្កេត ។

អាចបង្ហាញមុខចំពោះតុលាការយុត្តិធម៌ជាន់ខ្ពស់ :

-ប្រធានាធិបតីនៃសាធារណរដ្ឋចំពោះអំពើក្បត់ ឬបទឧក្រឹដ្ឋ ឬមជ្ឈឹមឯទៀតទាំងអស់ដែលបានប្រព្រឹត្តក្នុងការបំពេញមុខងារ

-នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការចំពោះអំពើក្បត់ និងការតៃបន្ទំ ឬរំលោភអំណាចឬបទឧក្រឹដ្ឋឬ មជ្ឈឹមដែលបានប្រព្រឹត្តក្នុងការបំពេញមុខការ

-សមាជិកក្រុមប្រឹក្សាបោះឆ្នោតអចិន្ត្រៃយ៍ និងតុលាការគណនីជាន់ខ្ពស់ និងវិវាទរដ្ឋបាលចំពោះបទល្មើសធ្ងន់ធ្ងរដែលបានប្រព្រឹត្តក្នុងការបំពេញមុខងារ

-ចៅក្រម និងមន្ត្រីក្រសួងសាធារណៈអមសាលាវិនិច្ឆ័យ ចំពោះបទឧក្រឹដ្ឋ ក្នុងពេលបំពេញមុខងារ

-អ្នកការពារពលរដ្ឋ ។

តុលាការយុត្តិធម៌ជាន់ខ្ពស់អាចកាត់សេចក្តីដកហូតតំណែង ព្យួរតំណែង ឬដកហូតសិទ្ធិមិនឱ្យបំពេញមុខងារសាធារណៈរយៈពេល៥ឆ្នាំយ៉ាងឆាប់និង១៥ឆ្នាំយ៉ាងយូរ ។

ឃ-អំណាចតែងតាំង

១-ចៅក្រមសាលាវិនិច្ឆ័យត្រូវតែងតាំងដោយប្រធានាធិបតីនៃសាធារណរដ្ឋ លើបញ្ជីឈ្មោះពានាក់ដែលស្នើដោយព្រឹទ្ធសភា ។

២-ប្រធានាធិបតីនៃសាធារណរដ្ឋតែងតាំង ក្រោយពីការយល់ព្រមរបស់ព្រឹទ្ធសភា អត្តមេបញ្ជាការកងកម្លាំងប្រដាប់អាវុធ នាយអត្តនគរបាល ឯកអត្តរដ្ឋទូត និងអត្តភារធារី ក្រុមប្រឹក្សារដ្ឋបាលនៃអង្គការស្វយ័ត ។

ក្រុមប្រឹក្សាមានសមត្ថកិច្ចពិសេសក្នុងការការពារផលប្រយោជន៍ នៃសមាធាតុសហព័ន្ធ ឥណ្ឌា ដោយគោរពផលប្រយោជន៍ជាតិ ។

I-សមាសភាព

ក្រុមប្រឹក្សាមានសមាជិក២៤៥នាក់ :

-២ពាន់នាក់ ជ្រើសរើសដោយសភានីតិប្បញ្ញត្តិនៃរដ្ឋនិងដែនដីនៃសហព័ន្ធ

-១២នាក់ តែងតាំងដោយប្រមុខរដ្ឋ តាមវិស័យអក្សរសាស្ត្រ សិល្ប: វិទ្យាសាស្ត្រ និងសង្គម ។

អនុប្រធានសហព័ន្ធឥណ្ឌាត្រូវជាប្រធានក្រុមប្រឹក្សាបណ្ណារដ្ឋជាស្វ័យប្រវត្តិ ។ អនុប្រធាន នេះត្រូវជ្រើសតាំងដោយអង្គចេះឆ្នោតដែលជាសមាជិកសភាទាំងពីរ ។

II-របបចេះឆ្នោត

ចំនួនអាសនៈនៅក្រុមប្រឹក្សាដែលត្រូវផ្តល់ឱ្យរដ្ឋ និងដែនដីនៃសហព័ន្ធ ត្រូវតាមតាម សមាមាត្រនៃចំនួនប្រជាជន ។

ប្រព័ន្ធចេះឆ្នោត :ឯកត្តនាម សម្លេងភាគច្រើន ដោយមិនផ្ទាល់ ឆ្នោតតែមួយ អាចផ្ទាស់ ប្តូរបាន ។

អាណត្តិ : ៦ឆ្នាំ ផ្ទាស់ប្តូរថ្មី១៣ រៀងរាល់២ឆ្នាំ

ការផ្ទាស់ប្តូរថ្មីចុងក្រោយ : ២៧ មិថុនា ឆ្នាំ២០០៤

លក្ខខណ្ឌអាយុ : ៣០ឆ្នាំ

សមាជិកក្រុមប្រឹក្សាអាចជាសមាជិករដ្ឋាភិបាល ។

II-សម័យប្រជុំ

ក្រុមប្រឹក្សាមាន៣សម័យប្រជុំ :

១-សម័យប្រជុំអនុម័តថវិកា(កុម្ភៈ-ឧសភា) session budgétaire

២-សម័យប្រជុំរដូវវស្សា(កក្កដា-សីហា) session de la mousson

៣-សម័យប្រជុំសិសិរៈ(វិច្ឆិកា-ធ្នូ) session d'hiver ។

ក្រុមប្រឹក្សាប្រជុំជាមធ្យម៨០-៩០ថ្ងៃ ក្នុង១ឆ្នាំ ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

ក្រុមប្រឹក្សាមានសិទ្ធិស្នើនីតិរដ្ឋសភា លើកលែងតែក្នុងវិស័យថវិកា ។

១-គំនិតផ្តួចផ្តើមធ្វើច្បាប់

ក្រុមប្រឹក្សា ក៏ដូចសមាជិករដ្ឋសភា និងរដ្ឋាភិបាលមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។

២-សិទ្ធិវិសោធនកម្ម

ក្រុមប្រឹក្សាមានសិទ្ធិធ្វើវិសោធនកម្ម លើកលែងតែច្បាប់ហិរញ្ញវត្ថុ ដែលក្រុមប្រឹក្សាមានត្រឹមសិទ្ធិផ្តល់អនុសាសន៍ទៅរដ្ឋសភា ។

៣-នីតិវិធីធ្វើច្បាប់

ក-នីតិវិធីធម្មតា

អត្ថបទច្បាប់នីមួយៗត្រូវអនុម័តដោយសភាទាំងពីរ ។ សេចក្តីព្រាងច្បាប់នានាអាចដាក់ទៅសភាណាមួយក៏បាន ក្រោយពីបានការយល់ព្រមជាមុនពីសភានោះ(ការអានលើកទី១) ។

ការអានលើកទី២ មាន២ដំណាក់កាល : ទី១ គឺជាការពិភាក្សាទូទៅ ។ សេចក្តីព្រាងអាចត្រូវបញ្ជូនទៅឱ្យគណៈកម្មការរបស់សភានោះ ឬគណៈកម្មការចំរុះដែលមានសមាជិកមកពីសភាទាំងពីរ ឬចែកផ្សាយដើម្បីទទួលប្រតិកម្ម ឬក៏ចាប់ពិនិត្យភ្លាមៗ ។

គណៈកម្មការពិនិត្យ១មាត្រម្តង១ ដូចជានៅពេលប្រជុំពេញអង្គដែរ ។ គណៈកម្មការអាចធ្វើវិសោធនកម្ម ទទួលយោបល់ពីអង្គការដែលចាប់អារម្មណ៍ ឬពីអ្នកជំនាញ ។

ក្រោយពីពិនិត្យចប់ ត្រូវបញ្ជូនអត្ថបទទៅសម័យប្រជុំពេញអង្គ ។

ទី២ តឹការពិនិត្យរបស់សភាម្តង១មាត្រា១ ។

ការអានលើកទី៣ :តាមគំនិតផ្តើមរបស់អ្នករាយការណ៍ សេចក្តីព្រាងអាចត្រូវអនុម័ត ។ នៅដំណាន់នេះ ការពិភាក្សាកំរិតត្រឹមផ្តល់ទឡ្ហីករណ៍លើការគាំទ្រ ឬការជំទាស់នឹងអត្ថបទ ។

មានតែវិសោធនកម្មស្របតាមច្បាប់ ឬផ្ទាល់មាត់ ឬដែលមានផលប្រយោជន៍ទេទើបអាចទទួលយកបាន ។ ចំពោះសេចក្តីព្រាងធម្មតា សម្លេងភាគច្រើនធម្មតានៃអ្នកដែលបានបោះត្រូវទុកជាបានការសំរាប់ការអនុម័ត ។

ប៉ុន្តែ ចំពោះសេចក្តីព្រាងច្បាប់ធម្មនុញ្ញ ត្រូវប្រើសម្លេងភាគច្រើននៃសមាជិកសភា បូកនឹងសម្លេងភាគច្រើន ២/៣នៃអ្នកដែលបានបោះ ។

ក្រោយពីសភាមួយបានអនុម័ត សេចក្តីព្រាងត្រូវបញ្ជូនទៅសភាមួយទៀត ដែលប្រើនីតិវិធីដូចគ្នា(លើកលែងតែការអានលើកទី១) ។

ការពិភាក្សារួមគ្នានៃសភាទាំងពីរ : បើសេចក្តីព្រាងដែលសភាមួយអនុម័ត ហើយសភាមួយទៀតបដិសេធ ឬបើសភាទាំងពីរបដិសេធជាចុងក្រោយនូវអត្ថបទដែលធ្វើវិសោធនកម្ម ឬបើហួសរយៈពេល៦ខែ ចាប់ពីពេលបញ្ជូនទៅសភាមួយទៀត(ហើយបើសភានេះមិនបានពិនិត្យ) ប្រធានសហព័ន្ធអាចកោះប្រជុំរួមសភាទាំងពីរ ដើម្បីដោះស្រាយបញ្ហា ។

ក្នុងករណីនេះ បើភាគច្រើននៃអ្នកដែលបានបោះអនុម័តយល់ព្រមលើអត្ថបទ ដែលមានវិសោធនកម្មជាយថាហេតុ អត្ថបទនេះត្រូវចាត់ទុកថាបានការយល់ព្រមពីសភាទាំងពីរ ។

នីតិវិធីនេះមិនអាចប្រើចំពោះសេចក្តីព្រាងច្បាប់ធម្មនុញ្ញបានឡើយ ។

ខ-នីតិវិធីចំពោះច្បាប់ថវិកា

សេចក្តីព្រាងច្បាប់ថវិកាដែលរដ្ឋសភា (Lok Sabha) អនុម័តលើកដំបូងត្រូវបញ្ជូនទៅក្រុមប្រឹក្សា ដែលត្រូវបញ្ជូនត្រឡប់ទៅរដ្ឋសភាវិញ ក្នុងរយៈពេល១៤ថ្ងៃ ចាប់ពីថ្ងៃដែលរដ្ឋសភាបញ្ជូនទៅ ដែលជាយថាហេតុមានអនុសាសន៍ជាវិសោធនកម្មទៅជាមួយផង ។

ក្រោយពីការពិនិត្យឡើងវិញរបស់រដ្ឋសភា សេចក្តីព្រាងត្រូវចាត់ទុកថាបានការយល់ព្រមពីសភាទាំងពីរ :

- ក្នុងអត្ថបទដែលវិសោធនកម្មតាមអនុសាសន៍នានា ឬខ្លះ១របស់ក្រុមប្រឹក្សា អាស្រ័យតាមការដែលរដ្ឋសភាបានយល់ព្រមតាមអនុសាសន៍ទាំងស្រុង ឬខ្លះ១ ។

- ក្នុងអត្ថបទដែលយល់ព្រមដោយរដ្ឋសភា បើរដ្ឋសភាបដិសេធអនុសាសន៍របស់ក្រុមប្រឹក្សាទាំងស្រុង ក៏ដូចជាបើសិនណាក្រុមប្រឹក្សាមិនបានពិនិត្យហួសពី១៤ថ្ងៃ ។

៩-អំណាចត្រួតពិនិត្យ

១-ក្រុមប្រឹក្សាមានសិទ្ធិបង្កើតគណៈកម្មការស៊ើបអង្កេត ។

២-មានសិទ្ធិចេញសេចក្តីសម្រេចចិត្តដាក់សំណូរពិភាក្សានិងអនុម័តញត្តិលើកពេលប្រជុំ ។

ត-បទប្បញ្ញត្តិដោយឡែក

ការពិភាក្សាធ្វើជាភាសាអង់គ្លេស និងភាសាឥណ្ឌា ។

ការអនុម័តវិសោធនកម្មនៅឆ្នាំ២០០១ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៥ (វិសោធនកម្មលើកទី ទី៣) បានផ្តល់លទ្ធភាពដល់ការបង្កើតសភានៃតំណាងតំបន់នៃសាធារណរដ្ឋអណ្ឌូណេស៊ី នៅឆ្នាំ ២០០៤ ។ សភានេះមានមុខងារធ្វើឱ្យផលប្រយោជន៍នៃខេត្តនានាត្រូវមានតំណាងនៅថ្នាក់ជាតិ ។ សភានៃតំណាងមានជាអាទិ៍អំណាចផ្តើមគំនិតធ្វើច្បាប់ក្នុងវិស័យដែលមានប្រយោជន៍ដោយផ្ទាល់ ទៅនឹងជីវភាពនយោបាយ និងសេដ្ឋកិច្ចរបស់ខេត្តនានា ។ ក្រោយរយៈកាលនៃអំណាចបែបអាជ្ញា និងមជ្ឈការ ដែលបានបញ្ចប់នៅឆ្នាំ១៩៩៨ ការបង្កើតសភានៃតំណាងធ្វើយ៉ាងតបយ៉ាងទល់ទ្ចលាយ ទៅនឹងឆន្ទៈ លើកកម្លាំងទឹកចិត្តចលនាប្រជាធិតេយ្យរបស់ប្រទេស ដោយបង្កើតបរអំណាច ភ្ជាប ខេត្ត (contre-pouvoirs au niveau provincial) ប្រឈមនឹងអំណាចថ្នាក់កណ្តាល ។

I-សមាសភាព

សភានៃតំណាងមានសមាជិកទាំងអស់១២៨នាក់ ដែលជាតំណាងរបស់ខេត្តទាំង ៣២ របស់អណ្ឌូណេស៊ី (៤នាក់ ក្នុង១ខេត្ត) ។

II-របបបោះឆ្នោត

សមាជិកសភានៃតំណាងត្រូវជ្រើសរើសដោយការបោះឆ្នោតជាសកល ដោយផ្ទាល់ក្នុង ភ្ជាបខេត្តនីមួយៗ មានអាណត្តិ៥ឆ្នាំ ។

ការបោះឆ្នោតលើកទី១ : ខែ មេសា ឆ្នាំ ២០០៤ ។

មុខការសំខាន់របស់សភានៃតំណាងគឺជានាថ្នាផលប្រយោជន៍របស់ខេត្តនានា ត្រូវបាន ទទួលការយកចិត្តទុកដាក់នៅថ្នាក់ជាតិ ។

លក្ខខណ្ឌដើមដែលតម្រូវចំពោះបេក្ខភាពគឺសមាជិកគណបក្សនយោបាយ មិនអាចធ្វើជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសសមាជិកសភានៃតំណាងបានឡើយ ។

ឥនិតនេះ គឺសំដៅបញ្ឈៀសការជ្រៀតចូលនៃយុទ្ធសាស្ត្ររបស់គណបក្សនយោបាយទៅក្នុងបេសកកម្មទី១របស់សភានៃតំណាង ។

III-ទំនាក់ទំនងជាមួយដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

សភានៃតំណាងអាចស្នើច្បាប់នានា ប៉ុន្តែចំពោះតែវិស័យទាំងឡាយដែលរដ្ឋធម្មនុញ្ញបានកំណត់ដូចជា :

- ស្ថយ័តភាពនៃតំបន់ ទំនាក់ទំនងរវាងអំណាចកណ្តាល និងរដ្ឋាភិបាលតំបន់នានា

-ការបង្កើត ការបែងចែក ឬការរួមបញ្ចូលតំបន់នានា

-ការគ្រប់គ្រងធនធានធម្មជាតិ និងធនធានសេដ្ឋកិច្ចផ្សេងៗ

-ការបែងចែកពន្ធដាររវាងអំណាចកណ្តាល និងរដ្ឋាភិបាលតំបន់នានា ។

សភានៃតំណាងធ្វើអន្តរាគមន៍ក្នុងការពិភាក្សាលើសេចក្តីស្នើច្បាប់ ដែលធ្វើមដោយរដ្ឋ-សភា ឬលើសេចក្តីព្រាងរបស់រដ្ឋាភិបាល កាលណាអត្ថបទទាំងនោះចូលក្នុងដែនសមត្ថកិច្ចរបស់សភានៃតំណាង ។

សភានៃតំណាងត្រូវបានរដ្ឋសភាពិគ្រោះយោបល់លើអត្ថបទ ដែលទាក់ទងនឹងថវិការដ្ឋពន្ធដារ សិក្សាធិការ និង កិច្ចការសាសនា ។

ខ-អំណាចត្រួតពិនិត្យ

សភានៃតំណាងធានានូវការអនុវត្តច្បាប់នានា ដែលនៅក្នុងវិស័យជាសមត្ថកិច្ចរបស់ខ្លួន ។

ត-ទំនាក់ទំនងជាមួយប្រធានាធិបតីនៃសាធារណរដ្ឋ

សភានៃតំណាងអាចប្រជុំជាសមាជជាមួយរដ្ឋសភា ។ សភាតែមួយតត់ដែលបង្កើតឡើង

នេះឈ្មោះថាសភាពិគ្រោះយោបល់របស់ប្រជាជន ។ ក្នុងឋានៈជាសមាជិកសមាជនេះ សមាជិកទាំងឡាយរបស់សភានៃតំណាងមានអំណាចដកហូតតំណែងប្រធានាធិបតីនៃសាធារណរដ្ឋ ។

IV-**បទប្បញ្ញត្តិដោយឡែក**

ក-ការសើរើរដ្ឋធម្មនុញ្ញ

ក្នុងឋានៈជាសមាជិកសភាពិគ្រោះយោបល់របស់ប្រជាជន សមាជិកសភានៃតំណាងក៏មានអំណាចធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដែរ ។

ខ-តុលាការគណនី

សភានៃតំណាងត្រូវបានពិគ្រោះយោបល់ក្នុងការតែងតាំងសមាជិកនានានៃអង្គការសវនកម្មជាតិ ។

អៀរឡង់ **ព្រឹទ្ធសភា**

IRLANDE LE SENAT

អៀរឡង់ប្រកាន់របបសភាពីរវិសមភាព ។

I-សមាសភាព

ព្រឹទ្ធសភាមានសមាជិក៦០នាក់ :

- ៤៩នាក់ ជ្រើសរើដោយការបោះឆ្នោតជាប្រយោល :
  - ពានាក់ដោយសកលវិទ្យាល័យជាតិ
  - ពានាក់ដោយសកលវិទ្យាល័យDUBLIN
  - ៤ពានាក់ តាមបញ្ជីបេកូជន
- ១១នាក់ តែងតាំងដោយនាយករដ្ឋមន្ត្រី ។

II-របបបោះឆ្នោត

មណ្ឌលបោះឆ្នោត : ៤១

ប្រព័ន្ធបោះឆ្នោត :សមាមាត្រ ឆ្នោតតែមួយ អាចផ្លាស់ប្តូរបាន

អាយុ :២១ឆ្នាំ

អាណត្តិ :៥ឆ្នាំ

ការផ្លាស់ប្តូរថ្មីចុងក្រោយ : ១៦-១៧កក្កដា ២០០២ ។

ការបោះឆ្នោតជាទូទៅត្រូវធ្វើនៅក្នុងរយៈពេល៩០ថ្ងៃក្រោយពីការរំលាយសភាតំណាង (Chambre des représentants) ។

ក្នុងករណីវិស្សមកាលនៃអាសនៈណាមួយក្នុងអាណត្តិ នាយករដ្ឋមន្ត្រីចាត់តាំងអ្នកជំនួសឬក៏រៀបចំការបោះឆ្នោតតាមផ្ទែកដើម្បីបំពេញវិញ ។

អាណត្តិជាសមាជិកព្រឹទ្ធសភាមិនមានវិសមិតភាពជាមួយមុខងារជាសមាជិករដ្ឋាភិបាលទេ លើកលែងតែរដ្ឋមន្ត្រីហិរញ្ញវត្ថុ (ប៉ុន្តែសមាជិករដ្ឋាភិបាលមិនអាចជាប្រធានព្រឹទ្ធសភាបានទេ) ។

III-សម័យប្រជុំ

ព្រឹទ្ធសភាមានយ៉ាងតិច១សម័យប្រជុំក្នុង១ឆ្នាំ ។

ព្រឹទ្ធសភាប្ឋរដ្ឋសភាអាចត្រូវកោះប្រជុំបានគ្រប់ពេល តាមសំណើរបស់ប្រធានាធិបតី ។

IV-ឧទាក់ឧទាចជាមួយរដ្ឋសភា និងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-ឥនិតផ្តួចផ្តើមធ្វើច្បាប់

ព្រឹទ្ធសភាមានសិទ្ធិផ្តួចផ្តើមឥនិតធ្វើច្បាប់ លើកលែងតែវិស័យហិរញ្ញវត្ថុ ។

ជាទូទៅ ច្បាប់មានប្រភពពីរដ្ឋាភិបាល ។

២-សិទ្ធិវិសោធនកម្ម

ព្រឹទ្ធសភាមានសិទ្ធិធ្វើវិសោធនកម្មច្បាប់ លើកលែងតែវិស័យហិរញ្ញវត្ថុ ។ ម្យ៉ាងទៀត វិសោធនកម្មណាដែលតម្រូវ ឬបង្កើនបន្ទុកហិរញ្ញវត្ថុដល់ប្រជាជន ឬដល់អង្គការរដ្ឋ ត្រូវតែផ្តើមដោយរដ្ឋមន្ត្រី១រូប ។

៣-នីតិវិធីធ្វើច្បាប់

ក-ចំពោះច្បាប់ធម្មតា

សេចក្តីព្រាងច្បាប់អាចដាក់មកសភាណាមួយក៏បាន ។

អត្ថបទច្បាប់ដែលផ្តើម និងអនុម័តដោយសភាជាន់ទាប លើកលែងតែច្បាប់ហិរញ្ញវត្ថុ ត្រូវបញ្ជូនទៅព្រឹទ្ធសភា ដែលអាចធ្វើវិសោធនកម្មបាន ។ វិសោធនកម្មទាំងនោះ ត្រូវសភាជាន់ទាបអនុម័តជាបន្ត ។

អត្ថបទច្បាប់ដែលផ្តើម និងអនុម័តដោយព្រឹទ្ធសភាត្រូវបញ្ជូនទៅសភាជាន់ទាប ។ បើសភាជាន់ទាបធ្វើវិសោធនកម្ម អត្ថបទនោះត្រូវចាត់ទុកថាជាអត្ថបទដែលផ្តើមឡើងដោយសភាជាន់ទាប ។

គ្រប់សេចក្តីព្រាងដែលព្រឹទ្ធសភាបដិសេធ ឬអនុម័តយល់ព្រមដោយមានវិសោធនកម្ម

ដែលសភាជាន់ទាបមិនទទួលយក ក្នុងរយៈពេល៩០ថ្ងៃ ឬរយៈពេលវែងជាងដែលសភាទាំងពីរ ព្រមទទួល ឬបើក្នុងរយៈពេលនេះ ព្រឹទ្ធសភាមិនបានពិនិត្យ ត្រូវចាត់ទុកថាបានអនុម័តដោយ សភាទាំងពីរ ។

ខ-ចំពោះវិស័យហិរញ្ញវត្ថុ

សេចក្តីព្រាងច្បាប់ដែលសភាជាន់ទាបអនុម័តរួច ត្រូវបញ្ជូនទៅព្រឹទ្ធសភាដើម្បីផ្តល់អនុ សាសន៍ ។ ជុំតរយៈពេល ២១ថ្ងៃ អត្ថបទត្រូវផ្ញើទៅសភាជាន់ទាបវិញដែលអាចយល់ព្រម ឬ បដិសេធវិសោធនកម្មរបស់ព្រឹទ្ធសភា ទាំងអស់ឬមួយផ្នែក ។

ត្រប់សេចក្តីព្រាងដែលមិនបញ្ជូនត្រឡប់ក្នុងរយៈពេល ឬបញ្ជូនត្រឡប់ដោយមានអនុ-សាសន៍ដែលសភាជាន់ទាបមិនទទួលយក ត្រូវចាត់ទុកថាយល់ព្រមដោយសភាទាំងពីរ នៅពេល ហួសរយៈពេល ។

ព្រឹទ្ធសភាអាចអនុម័ត ដោយមានវត្តមានសមាជិកយ៉ាងតិចពាក់ នូវសេចក្តីសម្រេច ចិត្តដែលស្នើឱ្យប្រធានាធិបតីបញ្ជូនបញ្ហាក្នុងសេចក្តីព្រាងដែលមានលក្ខណៈហិរញ្ញវត្ថុទៅគណៈ-កម្មការដែលមានបុព្វសិទ្ធិ(មានសមាសភាពស្នើឆ្នាមកពីសភាទាំងពីរ និងមានចៅក្រមតុលាការ ជាប្រធានជាអធិបតីដែលមានសិទ្ធិអនុម័ត ក្នុងករណីចែកសម្លេងជា២ ស្មើ) ។

សេចក្តីសម្រេចរបស់គណៈកម្មការ(ដែលសម្រេចក្នុងរយៈពេល២១ថ្ងៃបន្ទាប់ពីថ្ងៃបញ្ជូន ទៅព្រឹទ្ធសភា) ជាសេចក្តីសម្រេចស្ថាពរ និងមិនអាចតវ៉ាបានឡើយ ។

គ-ការប្រកាសឱ្យប្រើច្បាប់

តាមសំណើរបស់រដ្ឋាភិបាល ដោយមានការយល់ព្រមជាមុនពីព្រឹទ្ធសភា រយៈពេលដែល ប្រធានាធិបតីត្រូវប្រកាសឱ្យប្រើច្បាប់អាចត្រូវបង្រួញឱ្យខ្លី ។

អ៊ីតាលីប្រកាន់របបសភា២ស្មើភាពគ្នា ។

វិធានៃការសើរើរដ្ឋធម្មនុញ្ញក្នុងផ្លូវសហព័ន្ធត្រូវបានបញ្ជាក់ឡើង។

ដំហានៃការងាររបស់សភាចំពោះការសើរើរដ្ឋធម្មនុញ្ញត្រូវបញ្ចប់ដោយការអនុម័តអត្ថបទ ថ្ងៃ១៦វិច្ឆិកា ២០០៥ដោយព្រឹទ្ធសភា។ សេចក្ដីព្រាងដែលដាក់ធ្វើប្រជាមតិ ថ្ងៃទី២៦ មិថុនា ២០០៦មានលើកអំពីការកែទំរង់ប្រព័ន្ធសភាពីរ ដែលព្រឹទ្ធសភាសហព័ន្ធមានសមាជិក២៥២នាក់ ដែលលើនោះមានបន្ថែមប្រតិភូនៃតំបន់ដែលគ្មានសិទ្ធិបោះឆ្នោតចំនួន៤២នាក់ ។

ប្រជាមតិបានបដិសេធសេចក្ដីព្រាងកំណែទំរង់រដ្ឋធម្មនុញ្ញ ។

I-សមាសភាព

សមាជិកព្រឹទ្ធសភាមានចំនួន ៣២១ នាក់ :

ក-សមាជិក៣១៥នាក់ ជ្រើសរើសដោយការបោះឆ្នោតដោយផ្ទាល់ :

-លើមូលដ្ឋានតំបន់ សមាមាត្រនឹងចំនួនប្រជាជននៃតំបន់នីមួយៗ ដែលមិនអាចមានចំនួនសមាជិកព្រឹទ្ធសភាតិចជាង៧នាក់ លើកលែងតែឡឺ ម៉ូលីស (Le Molise-2 sénateurs) និងឡាវ៉ាឡេ ដាអូស្ត (La Vallée d'Aoste-1 sénateur)។

-ក្នុងក្របខ័ណ្ឌ៤មណ្ឌល (អឺរុប អាស៊ី-អាហ្វ្រិក អាមេរិកខាងជើង អាមេរិកខាងត្បូង) សំរាប់សមាជិកព្រឹទ្ធសភា៦នាក់តំណាងរបស់ជនជាតិអ៊ីតាលីនៅបរទេស(ជ្រើសរើសជាលើកទី១ នៅឆ្នាំ២០០៦ តាមច្បាប់ឆ្នាំ២០០១) ។

ខ-អតីតប្រធានាធិបតីនៃសាធារណរដ្ឋជាសមាជិកព្រឹទ្ធសភាដោយស្វ័យប្រវត្តិ និងមួយជីវិត (បច្ចុប្បន្នមាន២នាក់) ។

គ-ប្រធានាធិបតីនៃសាធារណរដ្ឋអាចតែងតាំងពលរដ្ឋ ដែលមានកេរ្តិ៍ឈ្មោះល្បីជាសមាជិកព្រឹទ្ធសភាមួយជីវិតចំនួន៥នាក់ (បច្ចុប្បន្នតែងតាំងបាន ៤នាក់) ។

II-បេបបោះឆ្នោត

ប្រព័ន្ធបោះឆ្នោត :សកល ដោយផ្ទាល់ ប្រព័ន្ធចំរុះ(សម្លេងភាគច្រើនធម្មតា សំរាប់សមាជិកព្រឹទ្ធសភា៧៥%(២៣២នាក់)និងបោះជាសមាមាត្រសំរាប់សមាជិក២៥%(៨៣នាក់) ។

អាយុ : ៤០ឆ្នាំ អាណត្តិ :៥ ឆ្នាំ

ការផ្លាស់ប្តូរថ្មីចុងក្រោយ : ៩ -១០ មេសា ២០០៦ ។

ព្រឹទ្ធសភាជាចៅក្រមនៃការបោះឆ្នោតជ្រើសរើសសមាជិកខ្លួន ។ សមាជិកព្រឹទ្ធសភាអាចជារដ្ឋមន្ត្រី ។

III-សម័យប្រជុំ

ក-សម័យប្រជុំសាមញ្ញ

ព្រឹទ្ធសភាមាន២សម័យប្រជុំសាមញ្ញក្នុង១ឆ្នាំ ដែលបើកនៅថ្ងៃធ្វើការ ទី១ នៃខែ កុម្ភៈ និងខែតុលា ។

ខ-សម័យប្រជុំវិសាមញ្ញ

តាមការផ្តើមគំនិតរបស់ប្រធានព្រឹទ្ធសភា (ឬរបស់ប្រធានរដ្ឋសភា) របស់ប្រធានាធិបតីនៃសាធារណរដ្ឋ ឬពីសមាជិកព្រឹទ្ធសភា ឬសមាជិករដ្ឋសភាចំនួន ១/៣ ព្រឹទ្ធសភាអាចកោះប្រជុំជាវិសាមញ្ញ ។

កាលណាសភាណាមួយប្រជុំជាវិសាមញ្ញ សភាមួយទៀតត្រូវតែប្រជុំជាស្វ័យប្រវត្តិ ។

ត-ក្នុងការអនុវត្ត ព្រឹទ្ធសភាប្រជុំពេញមួយឆ្នាំ ផ្តាកតែ១អាទិត្យ ថ្ងៃសំរាប់បុណ្យខួបនៃជនជាតិជ្វីហ្វ (pâques) និងនៅខែសីហា ពី៤ទៅ៥អាទិត្យ ។

IV-ឧទាត់ឧទាហរមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

១-គំនិតផ្តួចផ្តើមធ្វើច្បាប់

អ្នកមានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់ :

-សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា

-រដ្ឋាភិបាល អង្គការ ឬ ស្ថាប័នធម្មនុញ្ញដែលមានការចាត់តាំង(តំបន់ជនជាតិ ឬក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និងការងារ)

-អ្នកបោះឆ្នោតយ៉ាងតិច៥០.000នាក់ ។

២-សិទ្ធិវិសោធនកម្ម

សមាជិកព្រឹទ្ធសភាមានសិទ្ធិធ្វើវិសោធនកម្ម។

៣-នីតិវិធីធ្វើច្បាប់

ក-នីតិវិធីធម្មតា

សេចក្តីព្រាងច្បាប់អាចដាក់ជូនសភាណាមួយក៏បាន ។ ត្រូវសេចក្តីព្រាងច្បាប់ត្រូវតែពិនិត្យដោយគណៈកម្មការណាមួយមុន រួចទៅអនុម័តដោយសម័យប្រជុំពេញអង្គនៃសភានោះ។ នោះ។ ព្រឹទ្ធសភាមានប្រើនីតិវិធីប្រញាប់ ។

ខ-ការអនុម័តនៅតាមគណៈកម្មការ

ការអនុម័តអត្ថបទច្បាប់អាចប្រគល់ឱ្យគណៈកម្មការអចិន្ត្រៃយ៍ ឬឯកទេស ដែលមានសមាសភាពសមាមាត្រនឹងចំនួនសមាជិកក្រុមសមាជិកសភា លើកលែងតែវិស័យធម្មនុញ្ញ និងបោះឆ្នោត និងចំពោះសេចក្តីព្រាងច្បាប់ដែលទាក់ទងនឹងការធ្វើប្រតិភូកម្មអំណាចនីតិប្បញ្ញត្តិ ការអនុញ្ញាតឱ្យផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិ ការអនុម័តថវិកា និងច្បាប់នៃបទបញ្ជា និងការដកចេញនូវសេចក្តីព្រាងច្បាប់ផ្តល់សច្ចាប័នលើក្រឹត្យ-ច្បាប់ ។

ប៉ុន្តែសេចក្តីព្រាងអាចបញ្ជូនទៅសភា បើរដ្ឋាភិបាលឬ១/១០នៃសមាជិកព្រឹទ្ធសភា ឬ ១/៥ នៃគណៈកម្មការតម្រូវដើម្បីពិនិត្យ និងអនុម័ត ឬមួយដើម្បីយល់ព្រមចុងក្រោយដោយការប្រកាសនៃការអនុម័ត (déclarations de vote) ។

គ-ការលើកលែងទោស និងការដាក់ទោសឡើងវិញ (remise de peine)

កិច្ចការនេះត្រូវបានផ្តល់ដោយច្បាប់ដែលអនុម័តម្តង១មាត្រា។ និងដោយការអនុម័តជាចុងក្រោយតាមសម្លេងភាគច្រើន២/៣នៃសមាជិកសភានីមួយ។ ។

៩-អំណាចត្រួតពិនិត្យ

១-សិទ្ធិស៊ើបអង្កេត

ព្រឹទ្ធសភាអាចបង្កើតគណៈកម្មការនានាឱ្យស៊ើបអង្កេតលើការងារដែលមានផលប្រយោជន៍សាធារណៈ ។ គណៈកម្មការទាំងនោះមានអំណាច និងព្រំដែនដូចគ្នានឹងអាជ្ញាធរតុលាការ ។

គណៈកម្មការស៊ើបអង្កេតនៃសភាទាំងពីរត្រូវបង្កើតដោយច្បាប់មួយ ។

២-ការទទួលខុសត្រូវរបស់រដ្ឋាភិបាល

ព្រឹទ្ធសភាផ្តល់ ឬបដិសេធការទុកចិត្តដល់រដ្ឋាភិបាលដោយញត្តិ ដែលមានបញ្ជាក់ហេតុផល និងតាមការបោះឆ្នោតដោយហៅឈ្មោះ ។

ក្នុងរយៈពេល១០ថ្ងៃក្រោយការបង្កើត រដ្ឋាភិបាលត្រូវបង្ហាញខ្លួនចំពោះសភាទាំងពីរដើម្បីស៊ុំការទុកចិត្ត ។

ការអនុម័តផ្ទុយរបស់សភាមួយ ឬទាំងពីរទៅនឹងសំណើណាមួយរបស់រដ្ឋាភិបាល មិនបណ្តាលឱ្យរដ្ឋាភិបាលលាលែងជាចាំបាច់ឡើយ ។

ញត្តិដកការទុកចិត្តត្រូវចុះហត្ថលេខាដោយ១/១០នៃសមាជិកសភា និង ៣ថ្ងៃ ក្រោយការដាក់ទើបអាចលើកមកពិភាក្សាបាន ។

៣-ការត្រួតពិនិត្យរបស់តុលាការគណនី

តុលាការគណនីផ្តល់ព័តិមានដោយផ្ទាល់ទៅសភាទាំងពីរ អំពីលទ្ធផលនៃការផ្ទៀងផ្ទាត់ត្រួតពិនិត្យទាំងឡាយដែលខ្លួនបានធ្វើ ។

ត-ការរំលាយ

ព្រឹទ្ធសភាអាចរំលាយដោយប្រធានាធិបតីនៃសាធារណរដ្ឋ ដែលមិនអាចប្រើអំណាចនេះក្នុងរយៈពេល១០ខែចុងក្រោយនៃអាណត្តិរបស់ខ្លួនឡើយ ។

V-បទឃ្យញ្ញត្តិដោយឡែក

ក-អំណាចធម្មនុញ្ញ

ច្បាប់ធម្មនុញ្ញទាំងឡាយត្រូវអនុម័តដោយសភានីមួយ១ ជា២លើកបន្តបន្ទាប់ ក្នុងរយៈពេលយ៉ាងតិច៣ខែ និងត្រូវអនុម័តតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកសភានីមួយ១នៅការអានលើកទី២ ។

លើកលែងតែច្បាប់ត្រូវបានអនុម័តនៅជុំទី២ដោយសភានីមួយ១ តាមសម្លេងភាគច្រើន ២/៣នៃសមាជិករបស់ខ្លួន សេចក្តីព្រាងច្បាប់ធម្មនុញ្ញនោះអាចដាក់ធ្វើប្រជាមតិ កាលណាក្នុងរយៈពេល៣ខែចាប់ពីពេលផ្សព្វផ្សាយ មានសំណើសុំធ្វើប្រជាមតិពី១/៥ នៃសមាជិកសភាណាមួយ ឬ ពីអ្នកបោះឆ្នោត៥០០.០០០នាក់ ឬក្រុមប្រឹក្សាតំបន់ចំនួន ៥ ។

ខ-ចំពោះប្រធានាធិបតីនៃសាធារណរដ្ឋ

១-ការបោះឆ្នោតជ្រើសរើសប្រធានាធិបតី

ប្រធានាធិបតីត្រូវជ្រើសតាំងដោយសភាប្រជុំរួមគ្នា ។ ប្រតិភូតំបន់នានាក៏ចូលរួមដែរ ។

២-ប្រធានព្រឹទ្ធសភាទទួលជាប្រធានាធិបតីស្តីទី បើប្រធានាធិបតីមិនអាចបំពេញការងារបាន ។

៣-ការចោទប្រកាន់

ការចោទប្រកាន់ប្រធានាធិបតីនៃសាធារណរដ្ឋ ធ្វើឡើងដោយសភាប្រជុំរួមតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិករបស់ខ្លួនក្នុងករណីក្បត់ ឬប្រព្រឹត្តផ្ទុយនឹងរដ្ឋធម្មនុញ្ញ ។

គ-ការចោទប្រកាន់រដ្ឋមន្ត្រី

ការចោទប្រកាន់រដ្ឋមន្ត្រីធ្វើឡើងដោយមានការអនុញ្ញាតពីព្រឹទ្ធសភា ឬពីរដ្ឋសភា តាមលក្ខខណ្ឌនៃរដ្ឋធម្មនុញ្ញ ចំពោះអំពើល្មើសក្នុងការបំពេញមុខងាររបស់ខ្លួន ។

ឃ-ការតែងតាំង

១-ការបោះឆ្នោត

សភាទាំងពីរប្រជុំរួមជ្រើសតាំង១/៣នៃសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

២-ការតែងតាំង

សភាទាំងពីរប្រជុំរួមតែងតាំង១/៣នៃសមាជិក១៥នាក់នៃតុលាការធម្មនុញ្ញ ។

ង-ការប្រកាសសង្គ្រាម

សភាទាំងពីរផ្តល់ឱ្យរដ្ឋាភិបាលនូវអំណាចប្រកាសសង្គ្រាម ។

ច-តាមតំបន់

១-ការរំលាយក្រុមប្រឹក្សាតំបន់តាមយោបល់របស់គណៈកម្មការ ដែលមានសមាសភាពសមាជិកព្រឹទ្ធសភា និងសមាជិករដ្ឋសភា ។

២-កាលណារដ្ឋាភិបាលយល់ឃើញថាច្បាប់តំបន់ណាមួយ ហួសពីសមត្ថកិច្ចតំបន់ ឬផ្ទុយនឹងផលប្រយោជន៍ជាតិ ឬផ្ទុយនឹងផលប្រយោជន៍តំបន់ឯទៀត រដ្ឋាភិបាលអាចលើកបញ្ហាទាំងនេះនៅចំពោះមុខសភាទាំងពីរ ។

ហ្សាម៉ាអ៊ីក **ព្រឹទ្ធសភា**

JAMAIQUE LE SENAT

I-សមាសភាព

ព្រឹទ្ធសភាមានសមាជិក២១នាក់ តែងតាំងដោយអត្តទេសាភិបាល :

-១៣នាក់ តាមការយល់ព្រមរបស់នាយករដ្ឋមន្ត្រី

-៨នាក់ តាមការយល់ព្រមរបស់ប្រមុខគណបក្សជំទាស់ ។

II-របបតែងតាំង

អាណត្តិ : ៥ឆ្នាំ

ការផ្លាស់ប្តូរចុងក្រោយ: ១០ តុលា ២០០២

លក្ខខណ្ឌអាយុ: ២១ឆ្នាំ

មិនអាចតែងតាំងបាន : អ្នកជាប់កាតព្វកិច្ចជាមួយប្រទេសក្រៅ ពលរដ្ឋហ្សាម៉ាអ៊ីក ឬ ពលរដ្ឋ commenwealth ក្ស័យធនដែលមិនទាន់មាននីតិសម្បទា ។

វិសមិតភាព : មន្ត្រីរដ្ឋការ ចៅក្រមតុលាការជាន់ខ្ពស់ ភាគីនៃកិច្ចសន្យារដ្ឋាភិបាល សមាជិកកងកម្លាំងការពារ ... ។

តុលាការកំពូលជាចៅក្រមកាត់ក្តីទំនាស់តវ៉ាទៅសាលានុទ្ធរណ៍ ។

ការតែងតាំងសភាត្រូវធ្វើឡើង ពាខែយ៉ាងយូរក្រោយការរំលាយសភា បន្ទាប់ពីញត្តិដក ការទុកចិត្ត ឬក្រោយពីការបោះឆ្នោតសភា ។

III-សម័យប្រជុំ

ក-សម័យប្រជុំសាមញ្ញ

កាលបរិច្ឆេទនៃការបើក និងបិទសម័យប្រជុំត្រូវកំណត់ដោយអត្តទេសាភិបាល ។ព្រឹទ្ធសភា មិនអាចមិនរួមប្រជុំលើសពី៦ខែជាប់ៗគ្នាឡើយ ។

ខ-សម័យប្រជុំវិសាមញ្ញ

ក្នុងករណីប្រញាប់ តាមសំណើរបស់នាយករដ្ឋមន្ត្រី អគ្គទេសាភិបាលអាចកោះប្រជុំសភាជាវិសាមញ្ញ ។

ค-សម័យប្រជុំពេញច្បាប់ (session de droit)

ព្រឹទ្ធសភាប្រជុំដោយពេញច្បាប់យ៉ាងយូរ១ខែក្រោយការបោះឆ្នោតសភា ។

ឃ-ការលើកពេលប្រជុំ (ajournement)

សម័យប្រជុំសាធារណៈត្រូវលើកពេលប្រជុំបើមិនគ្រប់កូរ៉ុមចំនួន៨ ដោយមិនកំណត់ប្រធានអង្គប្រជុំ ។

ង-ព្រឹទ្ធសភាមានគណៈកម្មាធិការអចិន្ត្រៃយ៍(គណៈកម្មការទូទៅរបស់សភា) ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

ព្រឹទ្ធសភាមានអំណាចមានកំណត់ក្នុងមុខងារនីតិប្បញ្ញត្តិ ។

១-ការផ្តួចផ្តើមគំនិតធ្វើច្បាប់

សមាជិកសភាមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។ ប៉ុន្តែសិទ្ធិនេះត្រូវបានកំណត់ក្នុងវិស័យថវិកា និងហិរញ្ញវត្ថុ (ការបង្កើតពន្ធថ្មី ការបន្ថែមពន្ធ ការបង្កើនបន្ទុកលើហិរញ្ញ វត្ថុសាធារណៈ ឬលើបំណុលសាធារណៈ) លើកលែងតែមានអនុសាសន៍របស់រដ្ឋាភិបាល ។

សមាជិកសភាម្នាក់ៗអាចដាក់សេចក្តីស្នើច្បាប់ និងស្នើឱ្យពិនិត្យអត្ថបទច្បាប់ ។

២-សិទ្ធិវិសោធនកម្ម

សមាជិកសភាមានសិទ្ធិធ្វើវិសោធនកម្ម ។ ប៉ុន្តែសិទ្ធិនេះត្រូវបានកំណត់ក្នុងវិស័យ ថវិកា និងហិរញ្ញវត្ថុ (ការបង្កើតពន្ធថ្មី ការបន្ថែមពន្ធ ការបង្កើនបន្ទុកលើហិរញ្ញវត្ថុសាធារណៈ ឬលើបំណុលសាធារណៈ)លើកលែងតែមានអនុសាសន៍របស់រដ្ឋាភិបាល ។

មិនអាចចាត់ទុកថាជាវិសោធនកម្ម ការតាក់តែងអត្ថបទឬការធ្វើបច្ចុប្បន្នភាពជាធម្មតានៃអត្ថបទ ។

ជ-នីតិវិធីធ្វើច្បាប់

សេចក្ដីព្រាងច្បាប់នានាអាចដាក់ទៅសភាណាមួយក៏បាន លើកលែងតែច្បាប់ហិរញ្ញវត្ថុដែលត្រូវតែដាក់ជូនរដ្ឋសភា ។

ញ-នីតិវិធីធម្មតា

សេចក្ដីព្រាងច្បាប់នានាត្រូវតែពិនិត្យដោយសភាទាំងពីរ ។ មុនទីងបញ្ជូនទៅព្រឹទ្ធសភា រដ្ឋសភាអាចលើកឡើងនូវវិសោធនកម្ម ។ បើសិនជាព្រឹទ្ធសភាយល់ព្រមតាមវិសោធនកម្មនោះ ត្រូវចាត់ទុកថារដ្ឋសភាបានអនុម័តយល់ព្រម ។

បើសិនជាសេចក្ដីព្រាងច្បាប់ណាមួយត្រូវបានរដ្ឋសភាអនុម័ត២លើក ក្នុងសម័យប្រជុំតែមួយ ហើយបញ្ជូនទៅព្រឹទ្ធសភា(លើកទី១) ៧ខែយ៉ាងតិច មុនចប់សម័យប្រជុំ និង (លើកទី២) ១ខែយ៉ាងតិចមុនចប់សម័យប្រជុំ និងត្រូវព្រឹទ្ធសភាបដិសេធរាល់ៗលើក ឬ បើសិនព្រឹទ្ធសភាបដិសេធនៅ២សម័យប្រជុំបន្ដបន្ទាប់ ដែលរាល់លើក សេចក្ដីព្រាងត្រូវបញ្ជូនមក១ខែយ៉ាងតិចមុនចប់សម័យប្រជុំ ហើយការពិនិត្យលើកទី២ធ្វើឡើង៦ខែ ។

ក្រោយការពិនិត្យលើកទី១ សេចក្ដីព្រាងនោះត្រូវបញ្ជូនទៅអគ្គទេសាភិបាលដើម្បីប្រកាសឱ្យប្រើបើសិនជារដ្ឋសភាមិនសម្រេចអ្វីផ្សេង ។

អត្ថបទស្ថាពរត្រូវមានវិសោធនកម្មដែលអនុម័តដោយព្រឹទ្ធសភា និងយល់ព្រមដោយរដ្ឋសភា ។

ដើម្បីអនុវត្ដបញ្ញត្ដិខាងលើ សេចក្ដីព្រាងច្បាប់ដែលចាត់ទុកថាព្រឹទ្ធសភាបដិសេធ ជាសេចក្ដីព្រាងដែលព្រឹទ្ធសភាមិនបានអនុម័តដោយគ្មានការកែប្រែ ក្នុងរយៈពេល ១ខែ ក្រោយពីបានបញ្ជូនទៅឬដែលព្រឹទ្ធសភាបានអនុម័តដោយមានវិសោធនកម្ម ដែលរដ្ឋសភាមិនយល់ព្រម ។

បទប្បញ្ញត្ដិទាំងនេះមិនអនុវត្ដចំពោះច្បាប់ខ្លះ ដែលត្រូវតែមានការយល់ព្រមពីសភាទាំងពីរដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ(ច្បាប់ធម្មនុញ្ញឬបញ្ញត្ដិខ្លះនៃច្បាប់បោះឆ្នោត) ។

ក្រោយពីសភាទាំងពីរបានអនុម័តជាស្ថាពរ ច្បាប់ត្រូវដាក់ជូនអគ្គទេសាភិបាល ដើម្បីប្រកាសឱ្យប្រើ ។

ខ-បទប្បញ្ញត្តិដោយឡែកចំពោះច្បាប់ថវិកា

បើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ (ដែលលក្ខណៈហិរញ្ញវត្ថុត្រូវបានប្រធានរដ្ឋសភាបញ្ជាក់ពេលបញ្ជូនទៅព្រឹទ្ធសភា) ដែលត្រូវបានរដ្ឋសភាអនុម័ត(បញ្ជូនមករដ្ឋសភា យ៉ាងតិច១ខែមុនចប់នីតិកាល) មិនត្រូវបានព្រឹទ្ធសភាអនុម័តក្នុងរយៈ ពេល១ខែ ចាប់ពីពេលបញ្ជូនមក សេចក្តីព្រាងនេះត្រូវជូនទៅអគ្គទេសាភិបាល ដើម្បីចុះហត្ថលេខា បើសិនជារដ្ឋសភាមិនមានអ្វីសម្រេចផ្សេងពីនេះ ។

ខ-អំណាចត្រួតពិនិត្យ

ក្នុងការអនុវត្តច្បាប់ ការយល់ព្រមរបស់ព្រឹទ្ធសភាជាការចាំបាច់ចំពោះលិខិតូបករណ៍ដែលមានលក្ខណៈជាលក្ខន្តិក :(instruments statutaires) : បទដ្ឋានខ្លះរបស់អគ្គទេសាភិបាល ឬរដ្ឋមន្ត្រី(បទដ្ឋានសំរាប់អនុវត្តច្បាប់) ។

គ-ការរំលាយនិងការពន្យារអាណត្តិ

អគ្គទេសាភិបាលអាចរំលាយ ឬពន្យារអាណត្តិរបស់សភាបានគ្រប់ពេល ដោយមានការយល់ព្រមពីនាយករដ្ឋមន្ត្រី ។

សភាត្រូវរលាយបន្ទាប់ពីការអនុម័តដកការទុកចិត្តពីរដ្ឋាភិបាល (សម្លេងភាគច្រើននៃសមាជិករដ្ឋសភា) ។

នីតិកាលអាចត្រូវពន្យារ ២ឆ្នាំយ៉ាងយូរ ក្នុងករណីមានសង្គ្រាម ។

V-បទប្បញ្ញត្តិដោយឡែក

ក-ការសើរើរដ្ឋធម្មនុញ្ញ

រយៈពេល៣ខែត្រូវកន្លងផុតទៅរវាងពេលដាក់សេចក្តីព្រាងមករដ្ឋសភា និងការពិភាក្សាលើកទី១ ហើយបន្ទាប់មក៣ខែរវាងការចាប់ផ្តើម និងការបញ្ចប់ការពិភាក្សាក្នុងរដ្ឋសភា ។

ម្យ៉ាងទៀត ចំពោះការកែប្រែបញ្ញត្តិខ្លះដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ : ក្នុងរយៈពេលចន្លោះពី២ទៅ៦ខែក្រោយការយល់ព្រមដោយសភាទាំងពីរ ត្រូវរៀបចំធ្វើប្រជាមតិតាមសម្លេងភាគច្រើនដែលបានបោះ ។

ខ-ប្រធានព្រឹទ្ធសភា

ប្រធានព្រឹទ្ធសភាត្រូវជ្រើសតាំងនៅដើមនីតិកាល ។ ប្រធានព្រឹទ្ធសភាមិនអាចជារដ្ឋមន្ត្រីឬជារដ្ឋលេខាធិការឡើយ ។ ប្រធានមិនចូលរួមក្នុងការអនុម័តទេ លើកលែងតែក្នុងករណីចែកសម្លេងស្មើគ្នា ចំពោះការអនុម័តអត្ថបទច្បាប់ជាចុងក្រោយ(លើកលែងតែករណីស្តីពីរដ្ឋធម្មនុញ្ញ) ។

គ-ស្ថានភាពបន្ទាន់

សភាមានសិទ្ធិអនុម័តសេចក្តីសម្រេចចិត្តប្រកាសស្ថានភាពបន្ទាន់(តាមសម្លេងភាគច្រើន)សំរាប់១២ខែ(អាចបន្ត) ។ បើជាសេចក្តីសម្រេចចិត្តរបស់អត្តទេសាភិបាល រយៈពេលនេះអាចពី១ខែទៅ១២ខែយ៉ាងច្រើន ។

ឃ-អត្តទេសាភិបាលតែងតាំងលេខាធិការនិងលេខាធិការរងព្រឹទ្ធសភា តាមសំណើរបស់គណៈកម្មការសេវាសាធារណៈដែលមានប្រធានព្រឹទ្ធសភា និងរដ្ឋមន្ត្រីហិរញ្ញវត្ថុ ។

JAPON LA CHAMBRE DES CONSEILLERS

I-សមាសភាព

សភានៃទីប្រឹក្សាមានសមាជិក២៤២នាក់ ជ្រើសតាំងដោយការបោះឆ្នោតសកល ដោយផ្ទាល់ ។

II-របបបោះឆ្នោត

ប្រព័ន្ធ : ចំរុះ

-១៤៦នាក់ជ្រើសតាំងតាមសម្លេងភាគច្រើនសាមញ្ញក្នុងមណ្ឌលភូមិសាស្ត្រ ។

ត្រូវចាត់ទុកថាជាប់ឆ្នោតតាមលំដាប់នៃសម្លេងបានការ បេក្ខជនដែលបានទទួលសម្លេងស្មើឬលើសពី១/៦នៃផលចែកវាងសម្លេងឆ្នោតដែលបានការ និង ចំនួនអាសនៈក្នុងមណ្ឌល ។

-៩៦នាក់ ជ្រើសរើសក្នុងកំរិតជាតិ តាមប្រព័ន្ធសមាមាត្រ លើបញ្ជី ។

អាណត្តិ : ៦ឆ្នាំ ផ្លាស់ប្តូរថ្មីចំនួនពាក់កណ្តាលរៀងរាល់ពីរឆ្នាំ

ការផ្លាស់ប្តូរចុងក្រោយ : ១១ កក្កដា ២០០៤

អាយុ : ៣០ ឆ្នាំ

មណ្ឌល :

-៤៧មណ្ឌលពហុនាម ទីក្រុងធំ១ និងប្រហាក់ប្រហែលខេត្ត

-មណ្ឌលថ្នាក់ជាតិ សំរាប់អាសនៈដែលនៅសល់ ។

III-សម័យប្រជុំ

ក-សម័យប្រជុំសាមញ្ញ

សភានៃទីប្រឹក្សាមាន១សម័យប្រជុំ ក្នុង១ឆ្នាំ ។

២-សម័យប្រជុំវិសាមញ្ញ

តាមការកោះប្រជុំរបស់ខុទ្ទកាល័យ តាមសំណើរបស់សមាជិក១/៤យ៉ាងតិច នៃសភា

ណាមួយ ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្បញ្ញត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-ការផ្តើមគំនិតធ្វើច្បាប់

សភានៃទីប្រឹក្សាមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។

២-សិទ្ធិវិសោធនកម្ម

សភានៃទីប្រឹក្សាមានសិទ្ធិធ្វើវិសោធនកម្មច្បាប់ ។

៣-នីតិវិធីធ្វើច្បាប់

ក-នីតិវិធីចំពោះច្បាប់ធម្មតា

សេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ត្រូវពិនិត្យជាបន្តបន្ទាប់ដោយសភាទាំងពីរ ។ ប៉ុន្តែ បើសភានៃទីប្រឹក្សាអនុម័តនូវអត្ថបទមួយផ្សេង សេចក្តីស្នើច្បាប់ឬសេចក្តីព្រាងច្បាប់នោះក្លាយជាច្បាប់បាន លុះត្រាណារដ្ឋសភាអនុម័តជាលើកទី២ តាមសម្លេងភាគច្រើន២/៣នៃសមាជិកវត្តមាន ។

ដោយមិនរាំងដល់បញ្ហត្តិទាំងនេះ រដ្ឋសភាអាចកោះប្រជុំគណៈកម្មការរួមសភាទាំងពីរ ។

ក្នុងករណីដែលសភានៃទីប្រឹក្សាមិនបានពិនិត្យជាស្ថាពរ ក្នុងរយៈពេល៦០ថ្ងៃ ពីពេលទទួល សេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ដែលរដ្ឋសភាបានអនុម័ត ដោយមិនគិតវិស្សមកាលរបស់សភា រដ្ឋសភាអាចសម្រេចថាការដែលមិនបានពិនិត្យនេះមានន័យថាសភានៃទីប្រឹក្សាបានបដិសេធនូវអត្ថបទខាងលើនោះហើយ ។

ខ-នីតិវិធីចំពោះច្បាប់ហិរញ្ញវត្ថុ

ថវិកាត្រូវតែបញ្ជូនទៅរដ្ឋសភាពិនិត្យជាមុន ។ បើសភានៃទីប្រឹក្សាអនុម័តផ្សេង ហើយបើមិនអាចរកការព្រមព្រៀងបាន ទោះបីជាមានគណៈកម្មការចំរុះ ឬបើសភានៃទីប្រឹក្សាមិនបានអនុម័តអត្ថបទជាស្ថាពរក្នុងរយៈពេល៣០ថ្ងៃ (មិនរាប់វិស្សមកាល) បន្ទាប់ពីបានទទួលអត្ថបទ

ថវិកាដែលរដ្ឋសភាបានអនុម័ត ការសម្រេចរបស់រដ្ឋសភាត្រូវចាត់ទុកជាសេចក្តីសម្រេចរបស់សភាទាំងពីរ ។

ត-នីតិវិធីខាងលើនេះក៏អនុវត្តចំពោះការយល់ព្រមលើអនុសញ្ញានានាដែរ ។

៩-អំណាចត្រួតពិនិត្យ

១-ការតែងតាំងខុទ្ធកាល័យ

ក-នាយករដ្ឋមន្ត្រីត្រូវតែងតាំងដោយសភាទាំងពីរ តាមសេចក្តីសម្រេចចិត្ត ។ បើសភាទាំងពីរមិនយល់ព្រម ហើយបើមិនអាចរកការព្រមព្រៀងបាន ទោះជាមានគណៈកម្មការចំរុះនៃសភាទាំងពីរហើយក្តី ឬបើសិនជាសភានៃទីប្រឹក្សាមិនស្នើតែងតាំងជនណាម្នាក់ ក្នុងរយៈពេល ១០ថ្ងៃ (មិនគិតវិស្សមកាល) បន្ទាប់ពីការតែងតាំងរបស់រដ្ឋសភា សេចក្តីសម្រេចរបស់រដ្ឋសភាត្រូវចាត់ទុកថាជាសេចក្តីសម្រេចរបស់សភាទាំងពីរ ។

ខ-ភាគច្រើននៃរដ្ឋមន្ត្រី (តែងតាំងដោយនាយករដ្ឋមន្ត្រី) ត្រូវជ្រើសរើសពីក្នុងចំណោមសមាជិកសភាទាំងពីរ ។

២-សិទ្ធិស៊ើបអង្កេត

សភានៃទីប្រឹក្សា ឬរដ្ឋសភាអាចដំណើរការស៊ើបអង្កេតលើការងាររបស់រដ្ឋាភិបាលហើយអាចតម្រូវឱ្យមានវត្តមាន និងសវនកម្មនៃសាក្សី ព្រមទាំងការផ្តល់ឯកសារនានា ។

៣-គណៈកម្មការឃ្លាំមើលការងាររដ្ឋបាល

គណៈកម្មការនេះបង្កើតឡើង បន្ទាប់ពីការងាររបស់គណៈកម្មការស៊ើបអង្កេតលើរចនាសម្ព័ន្ធរដ្ឋបាលនិងហិរញ្ញវត្ថុនិងអចិការកិច្ចរដ្ឋបាលឆ្នាំ១៩៩៥ ។ គណៈកម្មការទទួលការតវ៉ាពីពលរដ្ឋនិងផ្តល់ព័តិមានទៅវិញ ដូចជាអ្នកការពារពលរដ្ឋ (ombudsman) ។

៤-រដ្ឋមន្ត្រីនានាត្រូវតែបង្ហាញមុខចំពោះសភាទាំងពីរ បើកាលណាវត្តមាននោះជាការតម្រូវដើម្បីឆ្លើយនិងពន្យល់សភា ។

៥-បទប្បញ្ញត្តិដោយឡែកសំរាប់វិស័យហិរញ្ញវត្ថុសាធារណៈ

ក-មូលនិធិបំរុង

ដើម្បីបំពេញនូវអតុល្យភាពនៃថវិកាឥតគ្រោងទុក សភាទាំងពីរអាចអនុញ្ញាតឱ្យបង្កើតមូលនិធិបំរុងមួយ ។ ការប្រើមូលនិធិនេះស្ថិតក្រោមការទទួលខុសត្រូវរបស់ខុទ្ទកាល័យដែលត្រូវបានទទួលការយល់ព្រមជាលំដាប់លំដោយពីសភាទាំងពីរលើចំណាយនៃមូលនិធិ ។

ខ-ចំណាយទាំងអស់របស់គ្រួសារក្សត្រ (famille impériale) ត្រូវសម្រេចដោយសភាទាំងពីរ ក្នុងក្របខ័ណ្ឌនៃថវិកា ។

គ-ក្នុងចន្លោះពេលទៀងទាត់ឬយ៉ាងយូរណាស់១ឆ្នាំម្តង ខុទ្ទកាល័យត្រូវផ្តល់របាយការណ៍អំពីស្ថានភាពនៃហិរញ្ញវត្ថុជាតិដល់សភាទាំងពីរ និងដល់ពលរដ្ឋ ។

ឃ-ការលើកពេលប្រជុំសភានៃទីប្រឹក្សា

សភានៃទីប្រឹក្សាលើកពេលប្រជុំពេលរដ្ឋសភាត្រូវរំលាយ ។ ប៉ុន្តែសភានៃទីប្រឹក្សាអាចត្រូវកោះប្រជុំជាវិសាមញ្ញ ក្នុងករណីប្រជាជាតិជួបគ្រោះថ្នាក់ ។

V-បទឧបសម្ព័ន្ធនិងជាយចុងក្រោយ

ក-អំណាចធម្មនុញ្ញ

ការសើរើរដ្ឋធម្មនុញ្ញត្រូវផ្តើមដោយសភាទាំងពីរ ដោយការអនុម័តតាមសម្លេងភាគច្រើន២/៣នៃចំនួនសមាជិកសភានីមួយៗ ។ ជាបន្តបន្ទាប់ ការសើរើនេះត្រូវដាក់ធ្វើប្រជាមតិ ។

ខ-សភានៃទីប្រឹក្សា ឬរដ្ឋសភាជាចៅក្រមសម្រេចសេចក្តីអំពីការបោះឆ្នោតជ្រើសរើសសមាជិករបស់ខ្លួន ។ សមាជិកសភាអាចត្រូវដកចេញពីអាសនៈលុះណាតែមានការសម្រេចចិត្តពីសភា តាមសម្លេងភាគច្រើន២/៣នៃសមាជិកសភាសាមី ។

គ-ការដកហូតចៅក្រម

សភាទាំងពីរអាចបង្កើតតុលាការ ដែលមានសមាសភាពជាសមាជិកសភាទាំងពីរ ចោទប្រកាន់ និងឈានទៅការវិនិច្ឆ័យដកហូតតំណែងចៅក្រមណាម្នាក់ ។

ហ្ជ្រឌដានី **ព្រឹទ្ធសភា**

JORDANIE LE SENAT

I-សមាសភាព

ព្រឹទ្ធសភាមានសមាជិក៤០នាក់ តែងតាំងដោយព្រះមហាក្សត្រ(ចំនួនសមាជិកព្រឹទ្ធ-សភាមិនអាចច្រើនជាងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទេ) ។

ព្រះមហាក្សត្រតែងតាំងប្រធានព្រឹទ្ធសភា ពីក្នុងចំណោមសមាជិកព្រឹទ្ធសភា ។

II-របបតែងតាំង

អាយុ : ៤០ឆ្នាំ

អាណត្តិ : ៤ឆ្នាំ

ការផ្ទាស់ប្តូរចុងក្រោយ : ១៧ វិច្ឆិកា ២០០៣

សមាជិកព្រឹទ្ធសភាត្រូវតែងតាំងពីក្នុងចំណោម :

-រដ្ឋមន្ត្រី និងអតីតរដ្ឋមន្ត្រី

-រដ្ឋទូត

-ប្រធានរដ្ឋសភា

-ប្រធាន និងចៅក្រមសាលាវិនិច្ឆ័យ (cour de cassation) សាលាឧទ្ធរណ៍ និងសាលាសារីយ៉ា

-នាយទាហានចូលនិវត្តន៍ចាប់ពីថ្នាក់ lieutenent-général

-អតីតសមាជិកព្រឹទ្ធសភា(២អាណត្តិយ៉ាងតិច)

-ឥស្សរជនដែលមានស្នាដៃចំពោះប្រទេសជាតិ ។

III-សម័យប្រជុំ

សម័យប្រជុំព្រឹទ្ធសភាដូចគ្នានឹងសម័យប្រជុំរដ្ឋសភា ។ ព្រឹទ្ធសភាព្យួរការប្រជុំ ក្នុងករណីរដ្ឋសភាត្រូវរំលាយ ។

ក-សម័យប្រជុំសាមញ្ញ

ព្រឹទ្ធសភាមាន១សម័យប្រជុំសាមញ្ញក្នុង១ឆ្នាំ ដែលមានរយៈពេល៤ខែ ចាប់ផ្តើមពីថ្ងៃទី១ខែតុលា(ឬថ្ងៃធ្វើការបន្ទាប់) ។ ព្រះមហាក្សត្រអាចពន្យារពេលបើកសម័យប្រជុំរហូតដល់២ខែយ៉ាងយូរ ។

ខ-សម័យប្រជុំវិសាមញ្ញ

ព្រះមហាក្សត្រអាចពន្យារសម័យប្រជុំសាមញ្ញរយៈពេលមួយ ដែលមិនលើសពីពីរខែដើម្បីបម្លើយការងារដែលនៅសល់ ។ព្រះមហាក្សត្រអាចកោះប្រជុំសភាទាំងពីររួមគ្នា តាមរបៀបវារៈជាក់លាក់ និងមិនបញ្ជាក់រយៈពេល ។ សម័យប្រជុំវិសាមញ្ញអាចត្រូវបន្តដោយព្រះរាជក្រឹត្យ ។ ព្រះមហាក្សត្រអាចកោះប្រជុំសភាជាវិសាមញ្ញ តាមសំណើ(ដែលត្រូវបញ្ជាក់ឱ្យបានច្បាស់)របស់សមាជិករដ្ឋសភាលើសពីពាក់កណ្តាល ។

សភាពិភាក្សាតែលើបញ្ហាដែលមានចែងក្នុងព្រះរាជក្រឹត្យកោះប្រជុំ ។

គ-ការលើកពេលប្រជុំ

អាចលើកសម័យប្រជុំដោយព្រះរាជក្រឹត្យបានពាក់ដងយ៉ាងច្រើន ឬ២ដងបើមានករណីលើកពេលបើក ។ ព្រឹទ្ធសភា ឬរដ្ឋសភាអាចលើកពេលប្រជុំម្តងម្តាលបាន ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-ការផ្តួចផ្តើមគំនិតធ្វើច្បាប់

ក្រុមដែលមានសមាជិកព្រឹទ្ធសភា (ឬសមាជិករដ្ឋសភា)១០នាក់ ឬច្រើនជាងអាចស្នើច្បាប់បាន ។ សេចក្តីស្នើនេះត្រូវផ្ញើទៅគណៈកម្មាធិការមានសមត្ថកិច្ចរបស់រដ្ឋសភា(ឬព្រឹទ្ធសភា)ពិនិត្យ ។ បើរដ្ឋសភា(ឬព្រឹទ្ធសភា)យល់ព្រមទទួល សេចក្តីស្នើនោះត្រូវជូនទៅរដ្ឋាភិបាល ហើយទៅជាសេចក្តីព្រាងច្បាប់ ដែលត្រូវបញ្ជូនមករដ្ឋសភាវិញក្នុងសម័យប្រជុំដដែល ឬសម័យប្រជុំខាងមុខ ។

២-សិទ្ធិវិសោធនកម្ម

ព្រឹទ្ធសភាមានសិទ្ធិធ្វើវិសោធនកម្ម។

៣-នីតិវិធីធ្វើច្បាប់

ក-នីតិវិធីធម្មតា

សេចក្ដីព្រាងច្បាប់នានាត្រូវនាយករដ្ឋមន្ត្រីបញ្ជូនមករដ្ឋសភាពិនិត្យជាលើកដំបូង ប៉ុន្តែសេចក្ដីព្រាងច្បាប់ទាំងអស់ត្រូវតែពិនិត្យដោយសភាទាំងពីរ ។

បើសភាណាមួយបដិសេធ២លើកនូវសេចក្ដីព្រាង ខណៈដែលសភាមួយទៀតយល់ព្រមព្រឹទ្ធសភានិងរដ្ឋសភាត្រូវប្រជុំរួមគ្នាក្រោមអធិបតីភាពប្រធានព្រឹទ្ធសភាដើម្បីពិភាក្សាលើចំណុចដែលជាកម្មវត្ថុនៃការខ្វែងគ្នា ។ ការយល់ព្រម អាស្រ័យលើការអនុម័តសេចក្ដីសម្រេចចិត្ត តាមសម្លេងភាគច្រើនពីរភាគបី (២/៣) នៃសមាជិកវត្តមាននៃសភាទាំងពីរ ។ បើត្រូវបដិសេធ សេចក្ដីព្រាងនោះមិនអាចយកមកជូនសភាវិញក្នុងសម័យប្រជុំដដែលបានទេ ។

ករណីសេចក្ដីស្នើច្បាប់ណាមួយត្រូវសភាទាំងពីរបដិសេធ សេចក្ដីស្នើនោះមិនអាចយកមកដាក់ឡើងវិញក្នុងសម័យប្រជុំដដែលបានទេ ។

ខ-នីតិវិធីចំពោះច្បាប់ហិរញ្ញវត្ថុ

សេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុត្រូវដាក់ជូនរដ្ឋសភាយ៉ាងតិច១ខែ មុនចាប់ផ្ដើមឆ្នាំសារពើពន្ធថ្មី ។ រដ្ឋសភាអាចកាត់បន្ថយចំណាយបើយល់ថាមានប្រយោជន៍ជាសាធារណៈ ប៉ុន្តែមិនអាចបង្កើនចំណាយបានទេ ។ ប៉ុន្តែសភា ក្រោយពីពិភាក្សាលើថវិកាចប់ អាចស្នើច្បាប់បង្កើតចំណាយថ្មី ។ ក្នុងរយៈពេលពិភាក្សា មិនអាចមានសេចក្ដីស្នើលប់ចោលអាការដែលមានស្រាប់ ឬបង្កើតអាការថ្មី ក៏ដូចជាមិនអាចបង្កើន ឬបន្ថយអាការដែលមានស្រាប់ ក៏ដូចជាការកែប្រែចំណាយ ឬចំណូល ដែលកំណត់ក្នុងកិច្ចសន្យា ។

គ-សិទ្ធិជំទាស់របស់មហាក្សត្រ

ក្នុងរយៈពេល៦ខែចាប់ពីថ្ងៃបញ្ជូនច្បាប់ទៅ ព្រះមហាក្សត្រអាចបញ្ជូនច្បាប់ត្រឡប់ទៅសភាវិញ ដោយបញ្ជាក់ពីមូលហេតុដែលព្រះអង្គមិនចុះហត្ថលេខា ។

ក្នុងករណីនេះ បើព្រឹទ្ធសភានិងរដ្ឋសភាអនុម័តច្បាប់នោះ តាមសម្លេងភាគច្រើន២/៣ ច្បាប់នោះត្រូវតែប្រកាសឱ្យប្រើ ។ ករណីផ្ទុយពីនេះ អត្ថបទមិនអាចយកមកពិភាក្សាឡើងវិញ ក្នុងសម័យប្រជុំដដែលបានទេ ហើយរដ្ឋសភាអាចលើកយកមកវិញនៅសម័យប្រជុំសាមញ្ញបន្ទាប់ ។

៥-នីតិកម្មបណ្តោះអាសន្ន

ក្នុងករណីដែលរដ្ឋសភាមិនប្រជុំឬត្រូវរំលាយ ក្រុមប្រឹក្សារដ្ឋមន្ត្រីមានសិទ្ធិ ដោយមានការយល់ព្រមពីមហាក្សត្រ ចេញវិធានច្បាប់បណ្តោះអាសន្ន បើជាការចាំបាច់ សំរាប់រយៈពេលមួយមានកំណត់ ។ វិធានទាំងនេះមានតម្លៃជាច្បាប់លុះណាតែរដ្ឋសភាអនុម័ត(ដោយមាន ឬគ្មានវិសោធនកម្ម) នៅពេលចាប់ផ្តើមសម័យប្រជុំបន្ទាប់ ។បើសភាបដិសេធ ក្រុមប្រឹក្សារដ្ឋមន្ត្រី ដោយដោយមានការយល់ព្រមពីព្រះមហាក្សត្រ ប្រកាសមោឃភាព ហើយបន្ទាប់ពីការប្រកាសនេះ អត្ថបទនេះលែងមានអានុភាព (បើសិនជាមោឃភាពនេះមិនប៉ះពាល់ដល់កិច្ចសន្យា ឬសិទ្ធិដែលទទួលរួចហើយ) ។

ខ-អំណាចត្រួតពិនិត្យ

១-សំណួរ

សមាជិកព្រឹទ្ធសភាគ្រប់រូបអាចដាក់សំណួរទៅរដ្ឋមន្ត្រីលើបញ្ហា ដែលទាក់ទងនឹងវិស័យសាធារណៈ ។

២-ការសួរដេញដោល

សមាជិកព្រឹទ្ធសភាគ្រប់រូបអាចកោះរដ្ឋមន្ត្រីមកសួរដេញដោល លើបញ្ហាដែលទាក់ទងនឹងវិស័យសាធារណៈ ។

ការសួរដេញដោលមិនអាចធ្វើបានមុនរយៈពេល៨ថ្ងៃ ចាប់ពីពេលដែលរដ្ឋមន្ត្រីបានទទួលសំណួរ លើកលែងតែក្នុងករណីប្រញាប់ និងដោយមានការយល់ព្រមពីរដ្ឋមន្ត្រី ។

៣-ជាការឆ្លើយតបនឹងសារបស់មហាក្សត្រ ថ្នែងពេលចាប់ផ្តើមសម័យប្រជុំសាមញ្ញនីមួយៗព្រឹទ្ធសភា(ឬរដ្ឋសភា) អាចដាក់ញត្តិសំដែលយោបល់ ។

គ-ការរំលាយព្រឹទ្ធសភា និងការដាក់សមាជិកជំនួស

មហាក្សត្រអាចរំលាយព្រឹទ្ធសភានិងដកដាក់ជំនួសសមាជិកព្រឹទ្ធសភា។

V-បទឧបសម្ព័ន្ធផ្សេងៗ

ក-ការកែប្រែរដ្ឋធម្មនុញ្ញ

ការកែប្រែរដ្ឋធម្មនុញ្ញធ្វើឡើងតាមនីតិវិធីដូចច្បាប់ធម្មតា តែត្រូវអនុម័តតាមសម្លេងភាគច្រើន២៣នៃសមាជិកសភានីមួយៗ។

បើកាលណាត្រូវប្រើនីតិវិធីសម្របសម្រួល ពីការប្រជុំរួមនៃសភាទាំងពីរ ការអនុម័តក៏ត្រូវយកតាមសម្លេងភាគច្រើន២៣ដែរ។

ក្នុងគ្រប់ករណី ការកែប្រែ ទូលជាធរមានក្រោយពីមហាក្សត្រចុះហត្ថលេខា។

ខ-ចំពោះរាជាធិបតេយ្យ

១-វិស្សមកាលនៃរាជបល្ល័ង្ក

ក្នុងករណីមហាក្សត្រសោយទិវង្គតពុំមានរាជទាយាទ រាជបល្ល័ង្កត្រូវបានទៅឥស្សរជនដែលជ្រើសរើសដោយរដ្ឋសភា ក្នុងចំណោមបច្ចាញ្ជាតិនៃស្ថាបនិកឧត្តមកម្មអារ៉ាប់ Feu le Roi Hussein Ibn Ali ?។

២-អវត្តមានមហាក្សត្រ

បើមហាក្សត្រស្ថិតនៅក្រៅប្រទេសលើសពី៤ខែ ហើយបើសភាមិនស្ថិតក្នុងសម័យប្រជុំ សភាត្រូវតែកោះប្រជុំជាបន្ទាន់ដើម្បីពិនិត្យបញ្ហានេះ ។

៣-ការជំនួសមហាក្សត្រ

បើមហាក្សត្រមានជម្ងឺសន្ធ្រឹមសន្ធ្រាម សភាចេញសេចក្ដីសម្រេចចិត្ត និងដាក់អ្នកបន្ត្រាជជំនួស។

គ-អំណាចតុលាការ

តុលាការជាន់ខ្ពស់ដែលមានសមត្ថកិច្ចដើម្បីវិនិច្ឆ័យរដ្ឋមន្ត្រី ចំពោះបទល្មើសប្រព្រឹត្តមុនការ ស្ថិតក្រោមអធិបតីភាពប្រធានព្រឹទ្ធសភា។ តុលាការមានសមាជិក៨នាក់ ដែលសមាជិក៣នាក់ត្រូវជ្រើសរើសដោយព្រឹទ្ធសភា។

ឃ-ការបកស្រាយរដ្ឋធម្មនុញ្ញ

ព្រឹទ្ធសភា(ជុំចជារដ្ឋសភាឬក្រុមប្រឹក្សារដ្ឋមន្ត្រី) អាចស្នើតុលាការជាន់ខ្ពស់ឱ្យបកស្រាយបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ។ សេចក្តីសម្រេចចិត្តនេះ ត្រូវអនុម័តតាមសម្លេងភាគច្រើនដាច់ខាត ។

ង-ព្រឹទ្ធសភា (ជុំចជារដ្ឋសភា)ដាក់ជូនមហាក្សត្រផ្តល់ការយល់ព្រមលើបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

I-សមាសភាព

ព្រឹទ្ធសភាមានសមាជិក៣៩នាក់ :

-៣២នាក់ ជ្រើសរើសដោយការបោះឆ្នោតដោយផ្ទាល់ ដែលមានតំណាង២នាក់ ក្នុង១ តំបន់ និងទីក្រុងនានានៃអាស្ថាណា (រដ្ឋធានីផ្លូវការរបស់ប្រទេស តាំងពី ខែធ្នូ ឆ្នាំ១៩៩៧)និងអាល់ម៉ាទី

- ៧នាក់ តែងតាំងដោយប្រធានាធិបតីនៃសាធារណរដ្ឋ ។

ម្យ៉ាងទៀត អតីតប្រធានាធិបតីនៃសាធារណរដ្ឋជាសមាជិកព្រឹទ្ធសភា ដោយពេញសិទ្ធិអស់មួយជីវិត ។

II-របបបោះឆ្នោត

ប្រព័ន្ធបោះឆ្នោត : ការបោះឆ្នោតធ្វើឡើងដោយសភាមូលដ្ឋានទាំង១៤តំបន់ និងទីក្រុង ២ដែលក្រុងនីមួយ១ ជ្រើសរើសសមាជិក២នាក់ ។ ការបោះឆ្នោតយកតាម សម្លេងភាគច្រើនជា២ជុំ ។

អាណត្តិ(សំរាប់អាសនៈជ្រើសរើសដោយបោះឆ្នោត): ៦ឆ្នាំ ផ្លាស់ប្តូរថ្មីពាក់កណ្តាលរាល់ពីឆ្នាំ (ពោលគឺផ្លាស់ប្តូរថ្មី១/២នៅរាល់តំបន់ និង ទីក្រុង) ។

សមាជិកព្រឹទ្ធសភាតែងតាំងត្រូវផ្លាស់ប្តូរថ្មីសំរាប់អាណត្តិទាំងមូលរបស់សភា ។

ការផ្លាស់ប្តូរថ្មីចុងក្រោយ : ១៩ សីហា ២០០៥

លក្ខខណ្ឌ : អាយុ៣០ឆ្នាំ សញ្ជាតិកាហ្ស៊ាក់ស្ថានច្រើនជាង៥ឆ្នាំ មានសញ្ញាបត្រកំរិតជាន់ខ្ពស់ និងមានពិសោធន៍វិជ្ជាជីវៈយ៉ាងតិច៥ឆ្នាំ ។

III-សម័យប្រជុំ

ក-សម័យប្រជុំសាមញ្ញ

ព្រឹទ្ធសភាមាន១សម័យប្រជុំប្រចាំឆ្នាំ ពីថ្ងៃធ្វើការទី១នៃខែកញ្ញារហូតដល់ថ្ងៃធ្វើការចុងក្រោយនៃខែមិថុនា ។

ខ-សម័យប្រជុំវិសាមញ្ញ

តាមការផ្តួចផ្តើមផ្ទាល់ ឬតាមសំណើរបស់ប្រធានសភាទាំងពីរ ឬរបស់១/៣យ៉ាងតិចនៃចំនួនសមាជិកសភាទាំងអស់ ប្រធានាធិបតីនៃសាធារណរដ្ឋអាចប្រជុំសភាជាវិសាមញ្ញ តាមរបៀបវារៈយ៉ាងជាក់លាក់ ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-ការផ្តួចផ្តើមគំនិតធ្វើច្បាប់

សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងរដ្ឋាភិបាលមានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់ ប៉ុន្តែអត្ថបទច្បាប់ត្រូវតែដាក់ជូនរដ្ឋសភា (Majilis) ។ សេចក្តីព្រាងដែលក្រោងកាត់បន្ថយធនធាន ឬបន្ថែមចំណាយរបស់រដ្ឋាភិបាលត្រូវតែមានការយល់ព្រមជាមុនពីរដ្ឋាភិបាល ។

២-សិទ្ធិវិសោធនកម្ម

ព្រឹទ្ធសភាមានសិទ្ធិធ្វើវិសោធនកម្ម ។

៣-នីតិវិធីធ្វើច្បាប់

ក-នីតិវិធីធម្មតា

សេចក្តីព្រាងនានាត្រូវរដ្ឋសភាពិនិត្យជាមុន បន្ទាប់ទៅព្រឹទ្ធសភាដែលមានរយៈពេលយ៉ាងច្រើន៦០ថ្ងៃ ។ បើសេចក្តីព្រាងច្បាប់ត្រូវបដិសេធដោយព្រឹទ្ធសភា សេចក្តីព្រាងនោះត្រូវបញ្ជូនទៅរដ្ឋសភាវិញ។ បើរដ្ឋសភាអនុម័តសេចក្តីព្រាងដោយសម្លេងភាគច្រើនពីរភាគបី សេចក្តីព្រាងត្រូវបញ្ជូនទៅព្រឹទ្ធសភាពិនិត្យជាលើកទី២ ។ សេចក្តីព្រាងដែលត្រូវបដិសេធជាលើកទី២ មិនអាចយកមកដាក់ឡើងវិញក្នុងសម័យប្រជុំដដែលបានទេ ។

បើសមាជិកព្រឹទ្ធសភាភាគច្រើនកែប្រែអត្ថបទច្បាប់ ការកែប្រែនេះត្រូវដាក់ជូនរដ្ឋសភា ។

បើសមាជិករដ្ឋសភាភាគច្រើនយល់ព្រម អត្ថបទត្រូវបានអនុម័ត ផ្ទុយទៅវិញ បើរដ្ឋសភាមិនយល់ព្រមនឹងវិសោធនកម្មរបស់ព្រឹទ្ធសភា នីតិវិធីសម្របសម្រួលត្រូវយកមកប្រើ ។

ខ-ការសន្យាទទួលខុសត្រូវលើអត្ថបទច្បាប់

បើសេចក្ដីព្រាងរបស់រដ្ឋាភិបាលមិនបានទទួលការអនុម័ត នាយករដ្ឋមន្ត្រីមានសិទ្ធិពេញច្បាប់ ដាក់បញ្ជាក់នៃការទុកចិត្ត នៅក្នុងសម័យប្រជុំរួមនៃសភាទាំងពីរ ។

ការអនុម័តធ្វើឡើងក្នុងរយៈពេល៤៨ម៉ោង ។ បើសម្លេងបដិសេធការទុកចិត្តមិនបានចំនួនភាគច្រើនដែលតម្រូវទេ សេចក្ដីព្រាងនោះត្រូវចាត់ទុកថាបានទទួលការអនុម័ត ។

រដ្ឋាភិបាលអាចប្រើសិទ្ធិនេះមិនលើសពី២ដងក្នុងមួយឆ្នាំ ។

គ-សិទ្ធិជំទាស់របស់ប្រធានាធិបតី

ក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីព្រឹទ្ធសភាបញ្ជូនសេចក្ដីព្រាងច្បាប់ដើម្បីប្រកាសឱ្យប្រើ ប្រធានាធិបតីអាចបង្ខិតអត្ថបទច្បាប់ (ទាំងស្រុង ឬមួយផ្នែក) ដើម្បីពិនិត្យជាលើកទី២ ។

ក្នុងរយៈពេល១ខែយ៉ាងយូរ សភាទាំងពីរត្រូវប្រជុំរួមគ្នា ។ ការមិនគោរពតាមរយៈពេលនេះ មានន័យថាយល់ព្រមតាមគំនិតរបស់ប្រធានាធិបតី ។

បើសម្លេងភាគច្រើន២/៣នៃចំនួនសមាជិកសភានីមួយៗរក្សាការសម្រេចលើកទី១របស់ខ្លួន ក្នុងរយៈពេល៧ថ្ងៃ ប្រធានាធិបតីចុះហត្ថលេខាប្រកាសឱ្យប្រើ ។

បើសិនយោបល់របស់ប្រធានាធិបតីមិនត្រូវបានបដិសេធទេ សេចក្ដីព្រាងត្រូវចាត់ទុកថាមិនបានអនុម័ត ឬអនុម័តយកតាមគំនិតរបស់ប្រធានាធិបតី ។

ឆ-ការកែប្រែបទបញ្ញត្តិដែលទាមទារដោយប្រធានាធិបតីនៃសាធារណរដ្ឋ

ប្រធានាធិបតីមានសិទ្ធិស្នើសើរើជាមុន ឬជាបន្ទាន់នូវសេចក្ដីព្រាងច្បាប់ ។ ក្នុងករណីនេះ សភាត្រូវដំណើរការសើរើក្នុងរយៈពេល១ខែចាប់ពីពេលស្នើ ។ បើសភាមិនយល់ព្រមតាមសំណើ ប្រធានាធិបតីអាចចេញក្រឹត្យដែលមានតម្លៃជាច្បាប់ឱ្យអនុវត្តតាមសំណើរហូតដល់សភាអនុម័តច្បាប់ថ្មី ។

ជ-ការធ្វើច្បាប់ដោយប្រតិភូកម្ម

តាមការផ្តើមគំនិតរបស់ប្រធានាធិបតី និងតាមសម្លេងភាគច្រើន២/៣នៃសមាជិកសភានីមួយ១ សភាអាចធ្វើប្រតិភូកម្មអំណាចធ្វើច្បាប់ឱ្យប្រធានាធិបតី សំរាប់រយៈពេលមិនលើសពី១ឆ្នាំ ។

៩-អំណាចត្រួតពិនិត្យ

១-ការប្រគល់អំណាចរបស់នាយករដ្ឋមន្ត្រី

សភាទាំងពីរប្រជុំរួមគ្នាផ្តល់ការយល់ព្រមដល់ការតែងតាំងនាយករដ្ឋមន្ត្រីដោយប្រធានាបតី ។

២-ការអនុម័តការទុកចិត្ត និងញត្តិបន្ទោស

សភាទាំងពីរប្រជុំរួមគ្នា:

-ផ្តល់ការយល់ព្រម ឬបដិសេធកម្មវិធីនយោបាយរបស់រដ្ឋាភិបាលដែលដាក់បង្ហាញដោយនាយករដ្ឋមន្ត្រី ក្នុងខែដែលតែងតាំង ។ ការបដិសេធជាលើកទី២ដែលដាក់ ក្នុងរយៈពេល២ខែ តាមសម្លេងភាគច្រើន២/៣នៃសមាជិកសភានីមួយ១ស្មើនឹងការមិនទុកចិត្ត ។ ករណីផ្ទុយ កម្មវិធីនយោបាយត្រូវបានអនុម័ត ។

-អនុម័តដកសេចក្តីទុកចិត្តទុកចិត្ត តាមសំណើរបស់សមាជិកទាំងអស់នៃសភាទាំងពីរ (ឬក្នុងករណីនានាដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ តាមការបោះឆ្នោតដែលយកតាមសម្លេងភាគច្រើន២/៣នៃសមាជិកសភានីមួយ១) ។ ក្នុងករណីនេះ រដ្ឋាភិបាលត្រូវដាក់ការសុំលាលែងទៅប្រធានាធិបតីដែលត្រូវផ្តល់ការយល់ព្រម ឬបដិសេធក្នុងរយៈពេល១០ថ្ងៃ ។

៣-សិទ្ធិក្នុងការបង្កើតគណៈកម្មការស៊ើបអង្កេត

៤-ការត្រួតពិនិត្យសមាជិករដ្ឋាភិបាល

តាមការផ្តួចផ្តើមគំនិតរបស់សមាជិកព្រឹទ្ធសភាយ៉ាងតិច១/៣ ព្រឹទ្ធសភាអាចស្នើសុំរបាយការណ៍ពីរដ្ឋមន្ត្រីអំពីសកម្មភាព និងតាមការបោះឆ្នោតដោយសម្លេងភាគច្រើនពីរភាគបី ស្នើសុំប្រធានាធិបតីបញ្ឈប់រដ្ឋមន្ត្រី ដែលមិនគោរពច្បាប់ពីមុខតំណែង ។

បើប្រធានាធិបតីមិនធ្វើតាមសំណើរហូតហូសរយៈពេល៦ខែ ចាប់ពីពេលដាក់សំណើលើកទី១ តាមការបោះឆ្នោតដោយសម្លេងភាគច្រើន២/៣យ៉ាងតិច ព្រឹទ្ធសភាមានសិទ្ធិទាមទារឱ្យ

រដ្ឋមន្ត្រីនោះលាលែងពីមុខតំណែង ។ ក្នុងករណីនេះ ប្រធានាធិបតីត្រូវតែបញ្ឈប់សមាជិករដ្ឋាភិបាលនោះ ។

៥-ការអនុវត្តថវិកា

រដ្ឋាភិបាលដាក់បង្ហាញសភានូវរបាយការណ៍អំពីការអនុវត្តថវិកា និងការធានាអនុវត្ត ។

ឆ-ការរំលាយសភា

ប្រធានាធិបតីអាចរំលាយសភា ក្នុងករណីដែល:

-សភាអនុម័តដកសេចក្តីទុកចិត្តពីរដ្ឋាភិបាល

-សភាជំទាស់ពីរដងនឹងការប្រគល់អំណាចរបស់នាយករដ្ឋមន្ត្រី

-វិបត្តិនយោបាយកើតមានឡើងបណ្តាលមកពីការមិនព្រមគ្នាដោយមិនអាចដោះស្រាយបានរវាងសភាទាំងពីរ ឬរវាងសភាជាមួយផ្នែកណាមួយនៃអង្គការនីតិប្រតិបត្តិ ។ សភាមិនអាចរំលាយបានទេនៅក្នុងរយៈពេលនៃការអនុវត្តស្ថានភាពអាសន្ន ឬច្បាប់អាជ្ញាសឹក៦ខែចុងក្រោយនៃអាណត្តិប្រធានាធិបតី ឬក្នុងរយៈពេល១ឆ្នាំ ។

V-បទឧក្រិដ្ឋនិងការផ្តន្ទាទោស

ក-ការកែប្រែរដ្ឋធម្មនុញ្ញ

តាមសំណើរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ សភាទាំងពីរប្រជុំរួមគ្នាដាក់បង្ហាញការកែប្រែរដ្ឋធម្មនុញ្ញ។ ការកែប្រែរដ្ឋធម្មនុញ្ញត្រូវមានការគាំទ្រពីសមាជិកសភាទាំងពីរយ៉ាងតិច៧៥ ។ ការកែប្រែរដ្ឋធម្មនុញ្ញអាចធ្វើតាមប្រជាមតិ រៀបចំឡើងតាមការសម្រេចរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ឬតាមសំណើរបស់សភា ឬរបស់រដ្ឋាភិបាល ។

បើប្រធានាធិបតី បដិសេធសេចក្តីស្នើសុំកែទម្រង់រដ្ឋធម្មនុញ្ញរបស់សភាមុនធ្វើប្រជាមតិ សភាមានសិទ្ធិអនុម័តច្បាប់បញ្ចូលជាមួយរដ្ឋធម្មនុញ្ញនូវការកែប្រែដែលបានស្នើតាមសម្លេងយ៉ាងតិច៤/៥ នៃសមាជិកសភានីមួយៗ ។ ក្នុងករណីនេះ ប្រធានាធិបតីនៃសាធារណរដ្ឋចុះហត្ថលេខាលើច្បាប់នេះ ឬដាក់ការកែប្រែធ្វើប្រជាមតិ ដែលលទ្ធផលមានសុពលភាព បើសិនជាជាងពាក់កណ្តាលនៃអ្នកបោះឆ្នោតបានចូលរួមបោះ ។

ការកែប្រែត្រូវបានអនុម័ត បើសិនជាងពាក់កណ្តាលនៃអ្នកបោះឆ្នោតយល់ព្រម ។

ខ-អំពីប្រធានាធិបតីនៃសាធារណរដ្ឋ

១-វិស្សមកាលនៃប្រធានាធិបតី

ក្នុងករណីដែលប្រធានាធិបតីអវត្តមាន ជាប់ខ្លួន ឬអនិច្ចកម្ម ប្រធានព្រឹទ្ធសភាទទួលអំណាចជាប្រធានាធិបតីរហូតចប់អាណត្តិ(ករណីប្រធានព្រឹទ្ធសភាមិនអាចបំពេញមុខងារនេះបាន ប្រធានរដ្ឋសភាជាអ្នកទទួល បើប្រធានរដ្ឋសភាមិនអាចបំពេញមុខងារនេះបាន នាយករដ្ឋមន្ត្រីជាអ្នកទទួល) ។

២-អសមត្ថភាពរបស់ប្រធានាធិបតី

ក្នុងករណីដែលប្រធានាធិបតីអសមត្ថភាពដោយសារមានជម្ងឺ ត្រូវបង្កើតគណៈកម្មការសភាសមភាគីដែលមានសមាជិកព្រឹទ្ធសភា និងសមាជិករដ្ឋសភា ព្រមទាំងត្រូពេទ្យជំនាញ ។

ការសុំលាលែងត្រូវអនុម័តនៅសម័យប្រជុំរួមសភាទាំងពីរ តាមសម្លេងភាគច្រើនយ៉ាងតិច៧៥នៃសមាជិកសភានីមួយ១ លើមូលដ្ឋាននៃសេចក្ដីសន្និដ្ឋានរបស់គណៈកម្មការសភា និងរបស់ក្រុមប្រឹក្សាធម្មនុញ្ញ អំពីប្រក្រតីភាពនៃនីតិវិធី ។

៣-ការទទួលខុសត្រូវរបស់ប្រធានាធិបតី

ប្រធានាធិបតីទទួលខុសត្រូវចំពោះសកម្មភាពក្នុងអាណត្តិតែក្នុងករណីអំពើក្បត់ធ្ងន់ធ្ងរ ។

ក្នុងការចោទប្រកាន់ អនុម័តដោយរដ្ឋសភា ការស្រាវជ្រាវត្រូវដឹកនាំធ្វើដោយព្រឹទ្ធសភាដែលតាមសម្លេងភាគច្រើននៃសមាជិករបស់ខ្លួន ដាក់សេចក្ដីសន្និដ្ឋាននៃការស៊ើបអង្កេតជូនសភាទាំងពីរប្រជុំរួមគ្នា ។ សេចក្ដីសម្រេចចុងក្រោយត្រូវធ្វើតាមសម្លេងភាគច្រើន៣/៤នៃសមាជិកសភានីមួយ១ ដោយតិតដល់យោបល់របស់តុលាការកំពូលលើភាពស្របច្បាប់នៃការចោទប្រកាន់ និងយោបល់របស់ក្រុមប្រឹក្សាធម្មនុញ្ញលើប្រក្រតីភាពនៃនីតិវិធី ។

អវត្តមាននៃសេចក្ដីសម្រេចក្នុងរយៈពេល២ខែ ចាប់ពីពេលចោទប្រកាន់ត្រូវចាត់ទុកថាការចោទប្រកាន់នោះមោឃៈ ។

៤-សេចក្ដីស្នើទំលាក់នាយករដ្ឋមន្ត្រីមិនអាចធ្វើបានឡើយ កាលណាប្រធានាធិបតីពិនិត្យសេចក្ដីស្នើរំលាយសភាជាមុន ។

 គ-អំណាចក្នុងវិស័យតុលាការ

១-ប្រធាន និងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមិនអាចត្រូវឃាត់ខ្លួន ចាប់ខ្លួននិងផ្តន្ទាទោសឧក្រិដ្ឋ ដោយគ្មានការអនុញ្ញាតពីសភា លើកលែងតែក្នុងករណីឧក្រិដ្ឋជាក់ស្តែង ។

២-អគ្គរដ្ឋអាជ្ញាមិនអាចត្រូវឃាត់ខ្លួន ឬមិនអាចត្រូវដាក់វិន័យរដ្ឋបាលដោយនីតិវិធីតុលាការ ឬទទួលទោសឧក្រិដ្ឋ ដោយគ្មានការយល់ព្រមពីសភាឡើយ លើកលែងតែក្នុងករណីឧក្រិដ្ឋជាក់ស្តែង ។

៣-ព្រឹទ្ធសភាមានសិទ្ធិផ្តាច់មុខក្នុងការលើកអភ័យឯកសិទ្ធិ:

-អគ្គរដ្ឋអាជ្ញា

-ប្រធាន និងចៅក្រមតុលាការកំពូល ។

ឃ-ការតែងតាំង

១-ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធានព្រឹទ្ធសភាតែងតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ២រូប ។

២-តុលាការកំពូល

ប្រធានតុលាការកំពូល និងប្រធានគណៈកម្មការនានានៃតុលាការ ត្រូវជ្រើសរើសដោយព្រឹទ្ធសភា តាមសំណើរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ លើមូលដ្ឋាននៃអនុសាសន៍របស់ក្រុមប្រឹក្សាតុលាការជាន់ខ្ពស់ ។

បទប្បញ្ញត្តិដូចគ្នានេះ ត្រូវយកមកអនុវត្តចំពោះការដកហូតតំណែងខាងលើ ។

៣-អគ្គរដ្ឋអាជ្ញា

ព្រឹទ្ធសភាអនុញ្ញាតឱ្យប្រធានាធិបតីនៃសាធារណរដ្ឋតែងតាំងប្រធានក្រុមប្រឹក្សាសន្តិសុខជាតិ ។

៤-ក្រុមប្រឹក្សាតុលាការជាន់ខ្ពស់

ព្រឹទ្ធសភាតែងតាំងសមាជិក២រូបនៃក្រុមប្រឹក្សាតុលាការជាន់ខ្ពស់ ។

៥-ក្រុមប្រឹក្សាសន្តិសុខជាតិ

ព្រឹទ្ធសភាឱ្យប្រធានាធិបតីនៃសាធារណរដ្ឋតែងតាំងប្រធានក្រុមប្រឹក្សាសន្តិសុខជាតិ ។

៦-ធនាគារកណ្តាល

ព្រឹទ្ធសភាឱ្យប្រធានាធិបតីនៃសាធារណរដ្ឋតែងតាំងប្រធានធនាគារកណ្តាល ។

៧-គណៈកម្មការគណនី

ព្រឹទ្ធសភា ក៏ផ្ទុចជារដ្ឋសភាតែងតាំងសមាជិកពារូបនៃគណៈកម្មការគណនីសំរាប់អាណត្តិ ៥ឆ្នាំ ដើម្បីធ្វើការត្រួតពិនិត្យ និងការអនុវត្តថវិកា ។

ង-ក្រុមប្រឹក្សាធម្មនុញ្ញ

ក្រុមប្រឹក្សាអាចត្រូវសុំឱ្យពិនិត្យ តាមសំណើរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ប្រធានព្រឹទ្ធសភា ១/៥នៃចំនួនសមាជិកសភាទាំងអស់(ក៏ផ្ទុចជារបស់ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី) ។

ច-រដ្ឋបាលមូលដ្ឋាន

ព្រឹទ្ធសភាមានសិទ្ធិផ្តាច់មុខ ក្នុងការកំរិតអំណាចរបស់សភាមូលដ្ឋាននានា ។

ឡីសូថូ ព្រឹទ្ធសភា

LESOTHO LE SENAT

កំណត់ចំណាំ:ក្រោយការរំជើបរំជួលដែលកើតនៅចុងឆ្នាំ១៩៩៨ បណ្តាលមកពីការបោះឆ្នោតខែឧសភា ១៩៩៨ ដែលគណបក្សប្រឆាំងតវ៉ា គណៈកម្មការមួយដែលមានឈ្មោះថា "អាជ្ញាធរនយោបាយស្តីទី (Interim political authority-I.P.A) " ត្រូវបានបង្កើតឡើង ។ អាជ្ញាធរនេះមានសមាជិក២៤នាក់មកពីគណបក្សសម្ថេងភាគច្រើន និងគណបក្សប្រឆាំងមានភារកិច្ចរៀបចំការបោះឆ្នោតទូទៅខាងមុខ (ដែលបានធ្វើនៅខែ ឧសភា ឆ្នាំ២០០២) និងដើម្បីធ្វើសំណើនានាដែលទាក់ទងនឹងការបោះឆ្នោត និងការរៀបចំស្ថាប័នដែលទាក់ទងនឹងប្រព័ន្ធសភា ។ អាជ្ញាធរស្នើឬកែទំរង់ព្រឹទ្ធសភាដោយការបោះឆ្នោត(បច្ចុប្បន្នតែងតាំង) ឬ បន្ថែមសមាជិករដ្ឋសភា និងរំលាយព្រឹទ្ធសភា ។

I-សមាសភាព

សមាជិកពាពានាក់ (តែងតាំង):

-២២នាក់ ជាប្រធានប្រពៃណី

-១១នាក់ តែងតាំងដោយព្រះមហាក្សត្រតាមសំណើរបស់ក្រុមប្រឹក្សារដ្ឋ (Conseil d'Etat) ។

II-រមមតែងតាំង

អាណត្តិ : ៥ឆ្នាំ

ការផ្ទាស់ប្តូរចុងក្រោយ : ២៦ ឧសភា ២០០២

លក្ខខណ្ឌ : អាយុ ២១ ឆ្នាំ ពលរដ្ឋLesotho និយាយភាសាlesotho ឬ anglais ។

ហាមឃាត់ : ក្ស័យធនដែលមិនបាននីតិសម្បទា ផ្ទែកមួយនៃកិច្ចសន្យារដ្ឋបាល មុខងារបោះឆ្នោត មានកំហុសក្នុងការបោះឆ្នោត ។

វិសមិតភាព :សមាជិកកម្លាំងសន្តិសុខ ឧត្តរបាល សមាជិកក្រុមគ្រប់គ្រងពន្ធនាគារ(ព្រះមហាក្សត្រ តាមយោបល់របស់នាយករដ្ឋមន្ត្រី អាចជ្រើសរើសរដ្ឋមន្ត្រីក្នុងចំណោមសមាជិកព្រឹទ្ធសភាដែលព្រះអង្គបានតែងតាំង) ។

ប្រធានប្រពៃណី (chef traditionnel) ម្នាក់១ ក្រោយពីបានជូនព័ត៌មានទៅប្រធានព្រឹទ្ធសភា អាចតែងតាំងសមាជិកម្នាក់ដើម្បីជំនួសខ្លួន ក្នុងឋានៈជាសមាជិកព្រឹទ្ធសភាដែលមានលក្ខណៈជាទូទៅឬសំរាប់តែសម័យប្រជុំខ្លះ ។ ដូចគ្នានេះ ប្រធានប្រពៃណីអាចតែងតាំងអ្នកផ្សេងទៀត ឬអាចដកហូតតំណែងវិញបាន ។

III-សម័យប្រជុំ

សម័យប្រជុំធ្វើនៅLesotho តាមទីកន្លែង និងពេលវេលាដែលកំណត់ដោយព្រះមហាក្សត្រ ក្នុងលក្ខខណ្ឌដែល:

-ចន្លោះរវាងពេលកំណត់ប្រជុំសភា និងពេលពន្យារសម័យប្រជុំចុងក្រោយមិនលើសពី១២ខែ

-ក្រោយការរំលាយសភា ពេលកំណត់ប្រជុំរបស់រដ្ឋសភាមិនលើសពី១៤ថ្ងៃ ក្រោយការបោះឆ្នោតសមាជិករដ្ឋសភា និងពេលកំណត់ប្រជុំព្រឹទ្ធសភាធ្វើឡើងនៅពេលសមស្រប ក្រោយពេលដែលប្រធានប្រពៃណីទាំងឡាយតែងតាំងសមាជិកព្រឹទ្ធសភាម្នាក់ ឬច្រើននាក់ ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

សភាមានព្រះមហាក្សត្រ ព្រឹទ្ធសភា និងរដ្ឋសភា ។

ក-អំណាចនីតិប្បញ្ញត្តិ

សភាជាអង្គការតែមួយដែលមានអំណាចនីតិប្បញ្ញត្តិ ។ អំណាចរបស់សភានៅក្នុងការធ្វើច្បាប់ត្រូវធ្វើដោយបញ្ជូនសេចក្តីព្រាងច្បាប់ទៅសភាទាំងពីរ និងដោយការយល់ព្រមពីព្រះមហាក្សត្រ ។

១-ឥទ្ធិពលផ្តួចផ្តើមធ្វើច្បាប់

ព្រឹទ្ធសភាពុំមានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់ទេ ។ ឥទ្ធិពលផ្តួចផ្តើមធ្វើច្បាប់ជាសិទ្ធិផ្តាច់មុខរបស់រដ្ឋសភា (លើកលែងតែការបង្កើនព័ន្ធដារ ឬអាកដែលត្រូវមានការយល់ព្រមពីរដ្ឋាភិបាល) ។

២-សិទ្ធិវិសោធនកម្ម

ព្រឹទ្ធសភាមានសិទ្ធិធ្វើវិសោធនកម្ម ។ ប៉ុន្តែសភាណាមួយអាចអនុម័តវិសោធនកម្មដែលបង្កើនពន្ធដារ ឬអាករលុះត្រាតែមានការយល់ព្រមពីរដ្ឋាភិបាល ។

៣-នីតិវិធីធ្វើច្បាប់

ការកំរិតអំណាចរបស់ព្រឹទ្ធសភា : ពេលដែលរដ្ឋសភាអនុម័តសេចក្តីព្រាងច្បាប់ណាមួយ សេចក្តីព្រាងច្បាប់នោះត្រូវបញ្ជូនទៅព្រឹទ្ធសភា ដោយគ្មានកំណត់ពេល ។

បើសភាយល់ព្រម ព្រះមហាក្សត្រត្រូវប្រកាសឱ្យប្រើ ។ បើមិនត្រូវបានព្រឹទ្ធសភាយល់ព្រមក្នុងរយៈពេល៤៨ម៉ោងទេ ឬបើត្រូវបានព្រឹទ្ធសភាយល់ព្រមដោយមានវិសោធនកម្ម ដែលរដ្ឋសភាមិនទាន់បានយល់ព្រម សេចក្តីព្រាងដែលមានវិសោធនកម្មនេះ ត្រូវអនុម័តដោយសភាទាំងពីរ លើកលែងតែរដ្ឋសភាសម្រេចផ្ទុយ និងបញ្ជូនទៅព្រះមហាក្សត្រដើម្បីប្រកាសឱ្យប្រើ ។

ករណីសេចក្តីព្រាងច្បាប់ ដែលមិនមែនជាសេចក្តីព្រាងច្បាប់ស្តីពីសាលាទានត្រូវអនុម័តដោយរដ្ឋសភា និងក្រោយពីបញ្ជូនទៅព្រឹទ្ធសភាយ៉ាងតិច៣០ថ្ងៃ មុនចប់សម័យប្រជុំមិនត្រូវបានយល់ព្រមដោយព្រឹទ្ធសភាក្នុងរយៈពេល៣០ថ្ងៃ ក្រោយពេលបញ្ជូនមកឬត្រូវបានយល់ព្រមដោយមានវិសោធនកម្មដោយព្រឹទ្ធសភា ដែលរដ្ឋសភាមិនបានយល់ព្រម ក្នុងរយៈពេល៣០ថ្ងៃ ក្រោយពីបញ្ជូនទៅព្រឹទ្ធសភា សេចក្តីព្រាងដែលមានវិសោធនកម្មនោះត្រូវបានយល់ព្រមដោយសភាទាំងពីរ លើកលែងតែរដ្ឋសភាសម្រេចផ្ទុយ និងបញ្ជូនទៅព្រះមហាក្សត្រដើម្បីប្រកាសឱ្យប្រើ ។

ខ-ការពន្យារ និងរំលាយសភា

ព្រះមហាក្សត្រអាចបន្តអាណត្តិ ឬរំលាយសភាបានគ្រប់ពេល ។

គ-សិទ្ធិចំពោះរដ្ឋាភិបាល

រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការ សមាជិករដ្ឋសភាមានសិទ្ធិចូលរួមក្នុងសម័យប្រជុំរបស់ព្រឹទ្ធសភា និងរួមចំណែកក្នុងដំណើរការ ប៉ុន្តែមិនត្រូវបានចាត់ទុកជាសមាជិកព្រឹទ្ធសភាទេ និងពុំមានសិទ្ធិអនុម័តឡើយ ។ ដូចនេះដែរ ចំពោះរដ្ឋមន្ត្រីឬ រដ្ឋលេខាធិការ សមាជិកព្រឹទ្ធសភា ក្នុងសម័យប្រជុំរដ្ឋសភា ។

V-ចនម្បញ្ញត្តិដោយឡែក

ក-ការកែប្រែរដ្ឋធម្មនុញ្ញ

សភាមានសិទ្ធិកែប្រែរដ្ឋធម្មនុញ្ញ ។ ដើម្បីបានការអនុម័ត សេចក្តីព្រាងច្បាប់ធម្មនុញ្ញត្រូវដាក់ពិភាក្សាក្នុងសភាទាំងពីរ និងត្រូវអនុម័តតាមសម្លេងភាគច្រើន២/៣ នៃសមាជិកសភា ។ ក្នុងករណីទាំងនេះ សេចក្តីព្រាងមិនត្រូវដាក់ធ្វើប្រជាមតិទេ ។

សេចក្តីព្រាងនេះត្រូវបញ្ជូនទៅព្រះមហាក្សត្រដើម្បីផ្តល់ការយល់ព្រម ។

ខ-ប្រធានព្រឹទ្ធសភា

ប្រធានព្រឹទ្ធសភា(ឬអនុប្រធាន) ត្រូវជ្រើសរើសក្នុងសមាជិកព្រឹទ្ធសភា ឬក្នុងចំណោមឥស្សរជនដែលបំពេញតាមលក្ខខណ្ឌតម្រូវ ដោយមិនមែនជារដ្ឋមន្ត្រី ឬរដ្ឋលេខាធិការ ។ ប្រធានព្រឹទ្ធសភាអាចត្រូវដកហូត តាមសម្លេងភាគច្រើន២/៣នៃសមាជិកព្រឹទ្ធសភា ។

ប្រធានព្រឹទ្ធសភាមានអាណត្តិ៥ឆ្នាំ ។ប្រធានព្រឹទ្ធសភាជាឥស្សរជនទី៣ ក្នុងឋានានុក្រមរបស់រដ្ឋ ។ ប្រធានព្រឹទ្ធសភាស្ថិតនៅលំដាប់លើប្រធានរដ្ឋសភា ។

ប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភាដឹកនាំការប្រជុំរួមនៃសភាទាំងពីរ ដោយការប្តូរវេនគ្នា ។

ត-អត្តរដ្ឋអាជ្ញាមានសិទ្ធិចូលរួមក្នុងការងាររបស់រដ្ឋសភា ឬព្រឹទ្ធសភានិងចូលរួមក្នុងដំណើរការនៃសភានីមួយ១ ប៉ុន្តែពុំមានសិទ្ធិអនុម័តទេ ។

ចាប់ពីពេលដែលប្រមុខរដ្ឋលាលែងនាឆ្នាំ២០០៣ រដ្ឋត្រូវដឹកនាំដោយស្ថាប័នអន្តរកាល។ កិច្ចព្រមព្រៀងសន្តិភាពអាក់ក្រា (Accra) ថ្ងៃ១៨ សីហា រវាងរដ្ឋាភិបាលលីបេរីយ៉ានិងចលនារួបរួមដើម្បីសំរុះសំរួលនិងប្រជាធិបតេយ្យលីបេរីយ៉ា (movement des libériens unis pour la réconciliation et la démocratie LURD) ចលនាដើម្បីប្រជាធិបតេយ្យនៃលីបេរីយ៉ា (movement pour la démocratie au Libéria MODEL) និងគណបក្សនយោបាយឯទៀតចែងអំពីការរៀបចំការបោះឆ្នោតប្រធានាធិបតី នាខែវិច្ឆិកា ឆ្នាំ២០០៥ និងការបោះឆ្នោតសភានាខែធ្នូឆ្នាំ២០០៥។

ការបោះឆ្នោតបានប្រព្រឹត្តទៅនៅខែតុលា ឆ្នាំ២០០៥។

I-សមាសភាព

ព្រឹទ្ធសភាមានសមាជិកជ្រើសតាំង៣០នាក់ ក្នុងមណ្ឌលពហុនាមចាំង១៥ (២ក្នុងមួយមណ្ឌលដែលត្រូវនឹងខេត្ត)។

II-របៀបបោះឆ្នោត

-បោះឆ្នោតដោយផ្ទាល់

-ប្រព័ន្ធសមាមាត្រតាមបញ្ជី ។ សម្លេងដែលនៅសល់ត្រូវផ្តល់តាមលំដាប់ចុះ ឱ្យទៅគណបក្សនយោបាយ ក្រុមចំរុះ សម្ព័ន្ធភាព ទៅតាមអត្រានៃអាសនៈដែលបានទទួលបាន។

-អាណត្តិ : ៩ឆ្នាំ ផ្ទាស់ប្តូរពាក់កណ្តាល ស្របតាមបញ្ញត្តិអន្តរកាលនៃការបោះឆ្នោតព្រឹទ្ធសភា

សមាជិកព្រឹទ្ធសភា២នាក់ ក្នុងមណ្ឌលតែមួយដែលបានទទួលសំឡេងច្រើនជាងគេត្រូវជាប់ឆ្នោតចាំង២នាក់។ អ្នកដែលនៅលើគេ (សមាជិកដើម principal) ភារអាណត្តិជាធម្មតា ៩ឆ្នាំ។ អ្នកនៅបន្ទាប់ សមាជិករង (adjoint) បានអាណត្តិវិញ្ចាស់ ២ឆ្នាំ ដើម្បីពានាដ៏ប្តូរភាពនៃការងារនីតិប្បញ្ញត្តិ អាណត្តិបន្តបន្ទាប់ទៀតបានជាធម្មតា ៩ឆ្នាំ។

ការផ្លាស់ប្តូរចុងក្រោយ : ១១ តុលា ឆ្នាំ២០០៥

លក្ខខណ្ឌ : អាយុ ៣០ឆ្នាំ ពលរដ្ឋលីបេរីយ៉ាពីកំណើត

វិសមិតភាព: សមាជិករដ្ឋាភិបាល ។

បែបបទឈរឈ្មោះ : បេក្ខជនត្រូវស្នើដោយគណបក្សនយោបាយ ក្រុមចំរុះសម្ព័ន្ធភាព។ បញ្ជីនីមួយ១ត្រូវមានឈ្មោះ២នាក់ ជាអ្នករស់នៅក្នុងប្រទេសក្នុងអំឡុងពេលតែងតាំងជាបេក្ខជន និងពេលឃោសនាបោះឆ្នោត ។

III-**សម័យប្រជុំ**

សភាទាំងពីរប្រជុំនៅក្នុងទីក្រុងដូចគ្នាជានិច្ច ។

ក-សម័យប្រជុំសាមញ្ញ

ព្រឹទ្ធសភាប្រជុំ១ដងក្នុងមួយឆ្នាំ ចាប់ផ្តើមពីថ្ងៃអង្គារទីពីរ(២ ថ្ងៃធ្វើការ)ខែមករា ។

ខ-សម័យប្រជុំវិសាមញ្ញ

ប្រធានព្រឹទ្ធសភាតាមការផ្តើមគំនិតផ្ទាល់ ឬតាមសំណើរបស់សមាជិកចំនួនយ៉ាងតិចមួយភាគបួននៃសភានីមួយ១អាចកោះប្រជុំសភាទាំងពីរជាវិសាមញ្ញដើម្បីពិនិត្យបញ្ហាបន្ទាន់ និងកិច្ចការរបស់ជាតិ ។

បើការប្រជុំវិសាមញ្ញត្រូវបានស្នើឡើង ដោយសមាជិកសភា ការកោះត្រូវធ្វើមិនឱ្យលើសពី៤៨ម៉ោង ក្រោយពីបានទទួលសំណើ ។

គ-ការពន្យារសម័យប្រជុំ

ក្នុងលក្ខខណ្ឌដូចគ្នានឹងការប្រជុំជាវិសាមញ្ញ ប្រធានអាចពន្យាររយៈពេលសម័យប្រជុំសាមញ្ញ ។

ឃ-ការលើកពេលប្រជុំ

គ្មានសភាណាមួយអាចលើកពេលប្រជុំលើសពី៥ថ្ងៃ ដោយគ្មានការយល់ព្រមពីសភាមួយទៀតបានទេ ។

IV-ឧទាហ៉ឧទាហ៉ណ៍ខាងមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

អំណាចនីតិប្បញ្ញត្តិត្រូវប្រគល់ឱ្យសភាទាំងពីរ :ព្រឹទ្ធសភា និងរដ្ឋសភា ។

សភាទាំងពីរប្រជុំនៅទីក្រុងដូចគ្នាជានិច្ច ។ សភានីមួយ១បង្កើតគណៈកម្មការ និងអនុ-គណៈកម្មការរបស់ខ្លួន ។ គណៈកម្មការដែលសមត្ថកិច្ចពាក់ព័ន្ធនឹងចំណូល និងពន្ធដារត្រូវមានសមាជិកព្រឹទ្ធសភា១រូប សំរាប់តំបន់នីមួយ១ ។

នៅថ្ងៃច័ន្ទទី៤ (ថ្ងៃធ្វើការនៃឆ្នាំនីមួយ១) ប្រធានបង្ហាញកម្មវិធីការងារនីតិប្បញ្ញត្តិនៃរដ្ឋបាលសំរាប់សម័យប្រជុំខាងមុខ ។

១-គំនិតផ្តូចផ្តើមធ្វើច្បាប់

ព្រឹទ្ធសភាមានសិទ្ធិផ្តូចផ្តើមធ្វើច្បាប់លើកលែងតែច្បាប់ស្តីពីហិរញ្ញវត្ថុ និងពន្ធដារ (ដែលជាសមត្ថកិច្ចរបស់រដ្ឋសភា) ។

២-សិទ្ធិវិសោធនកម្ម

ព្រឹទ្ធសភាមានសិទ្ធិធ្វើវិសោធនកម្ម ។

៣-នីតិវិធីធ្វើច្បាប់

ច្បាប់នានាត្រូវតែបានការអនុម័តពីសភាទាំងពីរ ។

សិទ្ធិជំទាស់របស់ប្រធានាធិបតី : ក្រោយពីត្រូវបានសភាទាំងពីរអនុម័ត សេចក្តីស្នើច្បាប់ត្រូវបញ្ជូនទៅប្រធានាធិបតីដើម្បីផ្តល់ការយល់ព្រម ។ បើប្រធានាធិបតីយល់ព្រម ត្រូវបញ្ជូនទៅព្រះមហាក្សត្រ ។ ផ្ទុយទៅវិញ ប្រធានាធិបតីត្រូវបញ្ជូនត្រឡប់ទៅសភាវិញ ដោយមានបង្ហាញនូវគំនិតជំទាស់របស់ខ្លួនផង ។ ប្រធានាធិបតីអាចមិនយល់ព្រមលើផ្នែកណាមួយ ឬលើសេចក្តីស្នើទាំងស្រុង ។

សភាអនុម័តទល់នឹងការជំទាស់របស់ប្រធានាធិបតី តាមសម្លេងភាគច្រើន២/៣នៃសមាជិកសភានីមួយ១ ។

បើប្រធានាធិបតីមិនបញ្ជូនត្រឡប់នូវសេចក្តីស្នើច្បាប់ ក្នុងរយៈពេល២០ថ្ងៃ ចាប់ពីថ្ងៃបញ្ជូនមក សេចក្តីស្នើច្បាប់ក្លាយទៅជាច្បាប់ បើសភាមិនបង្ហឧបស័ត្តដល់ការបញ្ជូនត្រឡប់ដោយលើកពេលប្រជុំ ។

៩-អំណាចត្រួតពិនិត្យ

១-វិស័យហិរញ្ញវត្ថុសាធារណៈ

ក-ការចោះផ្សាយក្រដាស់ប្រាក់ តម្រូវឱ្យមានការអនុញ្ញាតជាក់លាក់ពីសភា ។

ខ-របាយការណ៍ប្រចាំឆ្នាំអំពីស្ថានភាពហិរញ្ញវត្ថុសាធារណៈ ត្រូវប្រធានាធិបតីបញ្ជូនទៅសភា និងផ្សព្វផ្សាយ ។

ត-កម្ចីសាធារណៈត្រូវមានការអនុញ្ញាតពីច្បាប់ ។

២-អំណាចផ្តល់ការអនុញ្ញាត

ប្រធានាធិបតីតែងតាំងសមាជិកខុទ្ធកាល័យ និងទីប្រឹក្សា ដោយមានការយល់ព្រមពីសភា ។

៣-វិស័យអន្តរជាតិ

ប្រធានាធិបតីចុះអនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ ដោយមានការយល់ព្រមពីសភាតាមសម្លេងភាគច្រើននៃសមាជិកសភានីមួយ១ ។

៤-របាយការណ៍អំពីស្ថានភាពសាធារណរដ្ឋ

ប្រធានាធិបតីបង្ហាញសភានូវរបាយការណ៍ប្រចាំឆ្នាំ អំពីស្ថានភាពរបស់សាធារណរដ្ឋ ។ ក្នុងវិស័យសេដ្ឋកិច្ច របាយការណ៍នេះត្រូវមានចែងអំពីចំណាយ និងចំណូល ។

V-បឧម្បញ្ញត្តិផ្សេងៗ

ក-ការកែប្រែរដ្ឋធម្មនុញ្ញ

ការកែប្រែរដ្ឋធម្មនុញ្ញ អាចត្រូវស្នើដោយសមាជិកព្រឹទ្ធសភាចំនួន២ /៣ (ក៏ដូចជាដោយសមាជិករដ្ឋសភាចំនួន ២ /៣ ឬដោយញត្តិជុំនសភាពីប្រជាជនយ៉ាងតិច១០.000នាក់ និងទទួលបានការយល់ព្រមពី២ /៣នៃសមាជិកសភាទាំងពីរ) ។

ការកែប្រែរដ្ឋធម្មនុញ្ញត្រូវអនុម័តដោយប្រជាមតិ តាមសម្លេងភាគច្រើន២ /៣នៃអ្នកបោះឆ្នោតដែលបានចុះឈ្មោះ ។ ប្រជាមតិត្រូវធ្វើ១ឆ្នាំក្រោយការសម្រេចរបស់សភា ។

ខ-អំណាចតុលាការ

ព្រឹទ្ធសភាមានសមត្ថកិច្ចផ្តាច់មុខ ក្នុងការវិនិច្ឆ័យករណីចោទប្រកាន់ដែលជាសមត្ថកិច្ចរបស់រដ្ឋសភាតែមួយ ។

បើជាការវិនិច្ឆ័យប្រធាន អនុប្រធាន ឬអនុប្រធានណាមួយនៃតុលាការជាន់ខ្ពស់ ព្រឹទ្ធសភាត្រូវស្ថិតក្រោមអធិបតីភាពប្រធានតុលាការជាន់ខ្ពស់ ។បើជាការវិនិច្ឆ័យប្រធានតុលាការជាន់ខ្ពស់ ឬចៅក្រមនៃតុលាការជាន់ទាប ប្រធានព្រឹទ្ធសភាដឹកនាំការប្រជុំ ។

ការសម្រេចរបស់ព្រឹទ្ធសភាត្រូវយកតាមសម្លេងភាគច្រើន២ /៣នៃសមាជិកព្រឹទ្ធសភា ។

ក្នុងករណីនេះ ការផ្តន្ទាទោសមិនអាចហួសពីការដកហូត ឬការហាមឃាត់ការប្រកបមុខងារសាធារណៈ(ប៉ុន្តែសាមីខ្លួនអាចត្រូវជំនុំជម្រះដោយតុលាការធម្មតា ចំពោះអំពើដូចគ្នា) ។

គ-អធិបតីព្រឹទ្ធសភា

អនុប្រធានាធិបតីនៃសាធារណរដ្ឋជាប្រធានព្រឹទ្ធសភា ។ ប្រធានព្រឹទ្ធសភាដឹកនាំការពិភាក្សារបស់ព្រឹទ្ធសភា ប៉ុន្តែគ្មានសិទ្ធិអនុម័តទេ លើកលែងតែសម្លេងបែកជាពីរស្មើគ្នា ។

រាល់៦ឆ្នាំ ព្រឹទ្ធសភាបោះឆ្នោតជ្រើសរើសប្រធានបំរុង(président pro tempore) សំរាប់ដឹកនាំព្រឹទ្ធសភា ពេលប្រធានព្រឹទ្ធសភាអវត្តមាន ។

ប្រធានបំរុងអាចត្រូវដកពីមុខងារដោយការសម្រេចចិត្ត តាមសម្លេងភាគច្រើន២ /៣នៃសមាជិកព្រឹទ្ធសភា ។

ឃ-ការជំនួសអនុប្រធាន

បើតំណែងអនុប្រធាននៅទំនេរដោយអនិច្ចកម្ម លាលែង ដកពីតំណែង អសមត្ថភាព ឬ ដោយហេតុផ្សេង ប្រធានស្នើបេក្ខជនមួយរូប ដោយមានការយល់ព្រមពីសភាទាំងពីរ ឱ្យបំពេញ មុខងារជាអនុប្រធាន រហូតដល់ការបោះឆ្នោតទូទៅខាងមុខ ។

បើភាពទំនេរនេះកើតមានមុនប្រធានជាប់ឆ្នោតចូលកាន់តំណែង នីតិវិធីដូចត្នានេះត្រូវ យកមកប្រើក្រោយពេលចូលកាន់តំណែង ។

ង-អំណាចក្នុងការងារការពារជាតិ

សភាមានអំណាច :

-ធានាការការពារប្រទេស

-ប្រកាសសង្គ្រាម និងអនុញ្ញាតឱ្យប្រធានាធិបតីចុះកិច្ចព្រមព្រៀងសន្តិភាព (conclure la paix)

-ដំឡើង ឬបំពេញបន្ថែមតម្រូវការរបស់កម្លាំងទ័ពនៃសាធារណរដ្ឋ

-បង្កើតបទបញ្ជាសំរាប់ដឹកនាំកម្លាំងប្រដាប់អាវុធ ។

ច-អំណាចក្នុងការតែងតាំង

ប្រធានាធិបតី ដោយមានការយល់ព្រមពីព្រឹទ្ធសភា តែងតាំង :

-អ្នកការទូត

-ប្រធាន និង អនុប្រធានតុលាការជាន់ខ្ពស់ និង ចៅក្រមតុលាការជាន់ទាប

-អភិបាលមូលដ្ឋាន

-យោធាចាប់ពីថ្នាក់អនុសេនី(lieutenant)ឬថ្នាក់សមមូល

-នាយនគរបាល ។

ឆ-កាល:ទេស:ពិសេស

ប្រធានាធិបតី ក្រោយពីបានពិគ្រោះជាមួយប្រធានរដ្ឋសភា និងប្រធានបំរុងព្រឹទ្ធសភា (président pro tempore) ព្រឹទ្ធសភាអាចប្រកាសស្ថានភាពអាសន្នលើទីកដីមួយផ្នែក ឬទាំងមូល នៃសាធារណរដ្ឋ ។ប្រធានាធិបតីត្រូវផ្លែងក្នុងសភាប្រជុំរួមជាសាមញ្ញ ឬវិសាមញ្ញជាបន្ទាន់ ក្រោយ

ការប្រកាស ឬក្នុងរយៈពេល៧ថ្ងៃយ៉ាងយូរអំពីព្រឹត្តការណ៍ និងកាលៈទេសៈ ដែលនាំឱ្យមានការប្រកាសភាពអាសន្ន ។

ក្នុង៧២ម៉ោង សភាសម្រេចថាតើការប្រកាសនោះត្រឹមត្រូវ ឬតើវិធានការដែលបានចាត់នោះសមស្របឬទេ ? ដោយសេចក្ដីសម្រេចចិត្តរួមដែលអនុម័ត តាមសម្លេងភាគច្រើន២/៣នៃសមាជិកសភានីមួយៗ ។ បើមិនមានសម្លេងគាំទ្រ២/៣ទេ ការប្រកាសនោះត្រូវទុកជាមោឃៈ ។

បើសភាចាត់ទុកជាការចាំបាច់នូវការប្រកាស ឬការកែប្រែវិធានការនានា ប្រធានាធិបតីត្រូវតែអនុវត្តជាបន្ទាន់នូវការសម្រេចរបស់សភា ។

ព្រឹទ្ធសភាបង្កើតឡើងដោយការសើរើរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៨ ។

ការដាក់ឱ្យដំណើការព្រឹទ្ធសភានេះបានធ្វើឡើងដោយបទបញ្ជាថ្ងៃ២៨ ខែធ្នូ ឆ្នាំ ២០០០ ស្តីពីច្បាប់អង្គការអំពីព្រឹទ្ធសភា បំពេញដោយក្រឹត្យ ថ្ងៃ៨មករា ឆ្នាំ២០០១ ។

សភានេះមានភារកិច្ចទី១ជាតំណាងរបស់ខេត្តស្វយ័តនានា ។ សភានេះក៏មានតួនាទីជាអង្គការប្រឹក្សា (organe consultatif)សំរាប់រដ្ឋាភិបាលលើបញ្ហាសេដ្ឋកិច្ច សង្គម និងការរៀបចំដែនដី ។

I-សមាសភាព

ព្រឹទ្ធសភាមានសមាជិក៩០នាក់:

-៦០នាក់ ជ្រើសតាំងដោយការបោះឆ្នោតសកល ជាប្រយោល (suffrage universel indirect) ដែលមាន ១០អាសនៈក្នុង១ខេត្ត(ចំនួន៦ខេត្ត)

-៣០នាក់ ចាត់តាំងដោយប្រមុខរដ្ឋ ទៅតាមសមត្ថកិច្ចពិសេសខាងច្បាប់ សេដ្ឋកិច្ច សង្គម និងវប្បធម៌ ។

II-របបបោះឆ្នោតនិងតែងតាំង

ក-សមាជិកជ្រើសតាំង

មណ្ឌល : សមាជិកព្រឹទ្ធសភាត្រូវបានជ្រើសរើសនៅខេត្តស្វយ័តនីមួយៗ ។

អង្គបោះឆ្នោត : ទីប្រឹក្សាខេត្ត (ជ្រើសតាំងដោយការបោះឆ្នោតសកលដោយផ្ទាល់) និងមេឃុំ(ជ្រើសតាំងជាតំណាងក្នុងខេត្ត) ។

ប្រព័ន្ធបោះឆ្នោត: សមាមាត្រ តាមបញ្ជីមធ្យមភាគខ្ពស់បំផុត ... ។

អាណត្តិ: ៦ឆ្នាំ

ការបោះឆ្នោតលើកទី១ : ១៨ មីនា ២០០១

លក្ខខណ្ឌ : អាយុយ៉ាងតិច ៤០ឆ្នាំ មានឈ្មោះបោះឆ្នោត ស្នាក់នៅលើទឹកដីនៃសាធារណរដ្ឋថ្មីដាក់បេក្ខភាព ជាអ្នកពោរពេញច្បាប់ និងបទបញ្ជាពន្ធដារ និងបានបង់ពន្ធដារ អាករគ្រប់ប្រភេទពីឆ្នាំមុន ។

វិសមិតភាព : មុខងារសាធារណៈដែលមានអាណត្តិដោយបោះឆ្នោត និងការងារសាធារណៈទាំងអស់ លើកលែងតែការអប់រំក៏ដូចជាសមាជិករដ្ឋាភិបាល ។

ខ-សមាជិកតែងតាំង

ការតែងតាំងត្រូវធ្វើឡើង២១ថ្ងៃ បន្ទាប់ពីការប្រកាសជាផ្លូវការនូវលទ្ធផលនៃការបោះឆ្នោតព្រឹទ្ធសភា ។ ការតែងតាំងចុងក្រោយធ្វើនៅខែកក្កដា ឆ្នាំ ២០០២ ។

III-សម័យប្រជុំ

ព្រឹទ្ធសភាប្រជុំដោយពេញសិទ្ធិក្នុងរយៈពេលសម័យប្រជុំរដ្ឋសភា ។

ព្រឹទ្ធសភាអាចរួមប្រជុំជាពិសេស ។ កាលណារដ្ឋសភាមិនប្រជុំ ព្រឹទ្ធសភាអាចពិភាក្សាតែលើបញ្ហាដែលរដ្ឋាភិបាលសុំឱ្យផ្តល់យោបល់ ដែលមិនរាប់បញ្ចូលសេចក្តីព្រាងច្បាប់នានាទេ ។

ក-សម័យប្រជុំសាមញ្ញ

ព្រឹទ្ធសភាប្រជុំជាសាមញ្ញ២ដងក្នុង១ឆ្នាំ ។ សម័យប្រជុំនីមួយៗមិនត្រូវតិចជាង ៦០ថ្ងៃ និងមិនត្រូវលើសពី៩០ថ្ងៃទេ ។

សម័យប្រជុំលើកទី១ចាប់ផ្តើមនៅថ្ងៃអង្គារទី១នៃខែឧសភា ហើយសម័យប្រជុំលើកទី២ចាប់ផ្តើមនៅថ្ងៃអង្គារចុងក្រោយនៃខែកញ្ញា ។

ខ-សម័យប្រជុំវិសាមញ្ញ

ព្រឹទ្ធសភាកោះប្រជុំជាវិសាមញ្ញតាមរបៀបវារៈមួយយ៉ាងជាក់លាក់ តាមក្រឹត្យរបស់ប្រធានាធិបតីតាមការផ្តើមគំនិតផ្ទាល់ ឬតាមសំណើរបស់ភាគច្រើនដាច់ខាតនៃសមាជិកសភាទាំងពីរ ។

រយៈពេលនៃសម័យប្រជុំមិនត្រូវលើសពី១២ថ្ងៃទេ ។ ក្រឹត្យបិទសម័យប្រជុំត្រូវចេញនៅពេលដែលរដ្ឋសភាអស់របៀបវារៈ ។

ប្រធានាធិបតីនៃសាធារណរដ្ឋតែងកងង អាចផ្តើមគំនិតកោះប្រជុំវិសាមញ្ញជាថ្មី មុនផុតរយៈពេល១ខែបន្ទាប់ពីពេលបិទ ។

គ-សម័យប្រជុំពិសេស

សម័យប្រជុំពិសេសត្រូវកោះដោយរដ្ឋាភិបាល តាមរបៀបវារៈជាក់លាក់ ដែលបញ្ជាក់ក្នុងក្រឹត្យកោះប្រជុំ ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-គំនិតផ្តួចផ្តើមធ្វើច្បាប់

ព្រឹទ្ធសភាមានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់(ក៏ដូចជានាយករដ្ឋមន្ត្រី និងសមាជិកសភា) ។ ប៉ុន្តែសេចក្តីស្នើច្បាប់ដែលនាំឱ្យបន្ថយធនធានសាធារណៈនិងបន្ថែមទម្ងន់ទៅរដ្ឋមិនអាចធ្វើបានទេ លើកលែងតែច្បាប់ហិរញ្ញវត្ថុ ។

២-សិទ្ធិវិសោធនកម្ម

ព្រឹទ្ធសភាមានសិទ្ធិវិសោធនកម្ម ដូចជាសមាជិករដ្ឋសភា ។ ប៉ុន្តែវិសោធនកម្មដែលនាំឱ្យបន្ថយធនធានសាធារណៈ និងបន្ថែមទម្ងន់ទៅរដ្ឋមិនអាចធ្វើបានទេ លើកលែងតែច្បាប់ហិរញ្ញវត្ថុ ។

៣-នីតិវិធីធ្វើច្បាប់

សេចក្តីព្រាងច្បាប់ ត្រូវបញ្ជូនមកការិយាល័យសភាណាមួយ លើកលែងតែសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុដែលត្រូវតែបញ្ជូនមករដ្ឋសភាមុន ។

ក-នីតិវិធីធម្មតា :

សេចក្តីស្នើ ឬវិសោធនកម្មរបស់សមាជិកសភាត្រូវផ្ញើជូនរដ្ឋាភិបាលដែលមានពេល៣០ថ្ងៃចំពោះសេចក្តីស្នើច្បាប់ និង ១៥ថ្ងៃចំពោះវិសោធនកម្មសំរាប់ធ្វើការសង្កេត ។ បើហួសរយៈពេលនេះ សភាដែលស្នើដំណើរការពិនិត្យសេចក្តីស្នើឬវិសោធនកម្មនោះដើម្បីអនុម័ត ។

សេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ត្រូវតែដាក់ឱ្យគណៈកម្មការជំនាញណាមួយពិនិត្យមុននឹងពិភាក្សាក្នុងសម័យប្រជុំ ។ ពេលដែលសភាណាមួយពិនិត្យរួចហើយ សេចក្តីព្រាង ឬសេចក្តីស្នើច្បាប់នោះត្រូវបញ្ជូនទៅឱ្យសភាមួយទៀតពិនិត្យ ។

ការពិភាក្សាត្រូវធ្វើជាបន្តបន្ទាប់រហូតដល់បានអត្ថបទរួមតែមួយ ។

បើសិនណាក្រោយពីបានពិនិត្យ២ដងនៅសភានីមួយ១ ឬក្នុងករណីរដ្ឋាភិបាលប្រកាសការប្រញាប់ បើក្រោយពីបានពិនិត្យម្តងនៅសភានីមួយ១ ប៉ុន្តែនៅមិនព្រមព្រៀងគ្នា នាយករដ្ឋមន្ត្រីមានសិទ្ធិកោះប្រជុំគណៈកម្មការចំរុះសមភាគី ដើម្បីស្វែងរកអត្ថបទនៅលើចំណុចដែលខ្វែងគ្នា។ អត្ថបទរបស់គណៈកម្មការចំរុះ រដ្ឋាភិបាលអាចដាក់ជូនសភាទាំងពីរអនុម័ត ។ ត្រានវិសោធនកម្មណាមួយអាចលើកឡើងបានទេ លើកលែងតែមានការយល់ព្រមពីរដ្ឋាភិបាល ។

បើគណៈកម្មការមិនអាចអនុម័តបានអត្ថបទរួម ឬបើសិនជាអត្ថបទនោះមិនបានអនុម័តតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រាខាងលើ រដ្ឋសភាអនុម័តជាលើកចុងក្រោយតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិករបស់ខ្លួន ។

បើក្នុងដំណាក់កាលនៃនីតិវិធីមានសេចក្តីស្នើឬវិសោធនកម្ម ដែលមិនស្ថិតក្នុងវិស័យរបស់ច្បាប់ រដ្ឋាភិបាលអាចជំទាស់បាន ។ ក្នុងករណីមិនព្រមព្រៀងគ្នារវាងរដ្ឋាភិបាល និងរដ្ឋសភា ឬព្រឹទ្ធសភា តុលាការធម្មនុញ្ញជាន់ខ្ពស់សម្រេចក្នុងរយៈពេល៨ថ្ងៃ តាមសំណើរបស់នាយករដ្ឋមន្ត្រី ឬរបស់ប្រធានសភាណាមួយ ។

មុនហួសពេលប្រកាសឱ្យប្រើ(៣សប្តាហ៍) ប្រធានាធិបតីនៃសាធារណរដ្ឋអាចស្នើសុំឱ្យសភា (ដែលមិនអាចបដិសេធ) ពិភាក្សាជាថ្មីលើច្បាប់ ឬលើមាត្រាខ្លះ ។

ច្បាប់ធម្មតាអាចបញ្ជូនទៅតុលាការធម្មនុញ្ញជាន់ខ្ពស់ មុនប្រកាសឱ្យប្រើដោយប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភាចំនួន១/៤ ។

ខ-នីតិវិធីដោយឡែកចំពោះច្បាប់ហិរញ្ញវត្ថុ

សភាមានពេលយ៉ាងច្រើន៦០ថ្ងៃសំរាប់ពិនិត្យសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ ។ បើមិនបានពិនិត្យក្នុងរយៈពេល ៣០ថ្ងៃក្រោយពេលដាក់ស្នើ ត្រូវចាត់ទុកថារដ្ឋសភាបានអនុម័តយល់ព្រមហើយសេចក្តីព្រាងត្រូវបញ្ជូនទៅព្រឹទ្ធសភា ។

ព្រឹទ្ធសភាមានរយៈ១៥ថ្ងៃ ចាប់ពីពេលថ្មើមក សំរាប់ការពិនិត្យលើកទី១ ហើយសភានីមួយៗមានរយៈពេល៥ថ្ងៃសំរាប់ការពិនិត្យជាបន្តបន្ទាប់ ។ បើសភាណាមួយមិនបានពិនិត្យក្នុងរយៈពេលដែលបានកំណត់ឱ្យទេ ត្រូវចាត់ទុកថាសភានោះបានអនុម័តយល់ព្រមលើច្បាប់ ។

បើសភាមិនបានអនុម័តសេចក្តីស្នើច្បាប់ហិរញ្ញវត្ថុ មុនបិទសម័យប្រជុំលើកទី២ បទប្បញ្ញត្តិនៃសេចក្តីព្រាងអាចចូលជាធរមានដោយបញ្ញត្តិ ដោយមានបញ្ជូលវិសោធនកម្មមួយឬច្រើនដែលសភាទាំងពីរបានអនុម័ត ។

វិសោធនកម្មដែលនាំឱ្យមានការបង្កើនចំណាយឬបន្ថយធនធានសាធារណៈត្រូវមានភ្ជាប់មកជាមួយនូវសំណើបង្កើនចំណូល ឬសេដ្ឋកិច្ចសមមូល ។

ត-បទប្បញ្ញត្តិដោយឡែកសំរាប់ច្បាប់រៀបចំអង្គការ

សេចក្តីស្នើ ឬសេចក្តីព្រាងច្បាប់រៀបចំអង្គការ អាចត្រូវពិនិត្យនិងអនុម័តនៅសភាដែលដាក់លើកដំបូងលុះត្រាតែហួសរយៈពេល១៥ថ្ងៃចាប់ពីពេលដាក់ជូន ។

ការអនុម័តត្រូវយកតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកសភានីមួយៗ ។

បើគ្មានការព្រមព្រៀងគ្មានវាងសភាទាំងពីរ ក្រោយពីបានពិនិត្យ២ដង រដ្ឋសភាសម្រេចជាស្ថាពរ តាមសម្លេងភាគច្រើន២ /៣នៃចំនួនសមាជិក ។

បើរដ្ឋសភាមិនបានអនុម័តសេចក្តីព្រាងច្បាប់រៀបចំអង្គការមុនបិទសម័យប្រជុំ បទប្បញ្ញត្តិនៃសេចក្តីព្រាងនេះត្រូវចូលជាធរមានតាមបញ្ញត្តិ ដោយមានបញ្ជូលវិសោធនកម្មមួយ ឬច្រើនដែលសភាណាមួយបានអនុម័ត ។

ច្បាប់រៀបចំអង្គការទាក់ទងនឹងព្រឹទ្ធសភា និងទាក់ទងនឹងសន្ទិសីទអន្តរខេត្តត្រូវមានការព្រមព្រៀងគ្មានវាងសភាទាំងពីរ ។

ការប្រកាសឱ្យប្រើច្បាប់រៀបចំអង្គការធ្វើបានតែក្រោយពេលដែលតុលាការធម្មនុញ្ញជាន់ខ្ពស់ប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ។

ឃ-ការធានាការទទួលខុសត្រូវរបស់រដ្ឋាភិបាលលើអត្ថបទមួយ

រដ្ឋាភិបាលអាចធានាការទទួលខុសត្រូវ ដោយតម្រូវឱ្យសភាណាមួយអនុម័តតែ១ដងលើអត្ថបទទាំងមូល ឬមួយផ្នែកនៃអត្ថបទដែលកំពុងពិភាក្សា:

- នៅសម័យប្រជុំវិសាមញ្ញ បើសិនជាអត្ថបទត្រូវបានដាក់ជូនមក៤៨ ម៉ោងពីពេលបើកសម័យប្រជុំ

- ក្នុងរយៈពេលមួយ១ ។

ង-ទីតិសម្បទាអត្ថបទមានលក្ខណៈជាច្បាប់

តាមសម្តេងភាគច្រើនដាច់ខាតនៃសភានីមួយ១ សភាអាចអនុញ្ញាតឱ្យប្រធានាធិបតីនៃសាធារណរដ្ឋចេញបញ្ញត្តិរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីចាត់វិធានការដែលមានលក្ខណៈជាច្បាប់សំរាប់រយៈពេលមានកំណត់ និងកម្មវត្ថុជាក់លាក់ណាមួយ។

បញ្ញត្តិទាំងនេះចូលជាធរមានចាប់ពីពេលចុះផ្សាយ ប៉ុន្តែត្រូវអស់តម្លៃបើសិនជាសេចក្តីព្រាងច្បាប់ផ្តល់សច្ចាប័នមិនបានដាក់ជូនរដ្ឋសភា មុនរយៈពេលដែលមានកំណត់ក្នុងច្បាប់ស្តីពីទីតិសម្បទា។

ខ-អំណាចត្រួតពិនិត្យ

១-មធ្យោបាយទទួលព័ត៌មានរបស់ព្រឹទ្ធសភាមាន : សំណួរផ្ទាល់មាត់ សំណួរជាលាយលក្ខណ៍អក្សរ ការកោះសួរដេញដោល និងគណៈកម្មការអង្កេត ។

ក-ក្នុងសម័យប្រជុំសាមញ្ញ មួយខែម្តងយ៉ាងតិចជាពេលប៉ុរងជាអាទិភាពសំរាប់សំណួរ ។

ខ-គណៈកម្មការអង្កេតទទួលបន្ទុកប្រមូលព័ត៌មានអំពីករណីជាក់លាក់ និងផ្តល់ការសន្និដ្ឋានដល់ការិយាល័យ ។គណៈកម្មការទាំងនេះត្រូវព្រឹទ្ធសភាបង្កើតឡើង តាមសេចក្តីសម្រេចចិត្តដែលដាក់ស្នើដោយសមាជិកព្រឹទ្ធសភាយ៉ាងតិច៥នាក់ ។

ព្រឹទ្ធសភាមិនអាចបង្កើតគណៈកម្មការអង្កេតបានទេ ចំពោះការណីដែលបានជូនទៅតុលាការឬតុលាការកំពុងដំណើរការ...។ បើសិនជាគណៈកម្មការបានបង្កើតរួចហើយ ការងាររបស់ខ្លួនត្រូវបញ្ចប់ពេលបើកការស្រាវជ្រាវផ្ទែកតុលាការទាក់ទងនឹងកិច្ចការ ដែលជាមូលហេតុនៃការបង្កើតគណៈកម្មការ ។

គណៈកម្មការអង្កេតមិនអាចបង្កើតឡើងវិញលើកម្មវត្ថុដូចគ្នា មុនផុតរយៈពេល ១ខែចាប់ពីពេលចប់ការងារ ។

២-ការផ្តល់សច្ចាប័ន ឬការយល់ព្រមលើសន្ធិសញ្ញាសម្ព័ន្ធភាព ពាណិជ្ជកម្ម ឬសន្ធិសញ្ញាឬកិច្ចព្រមព្រៀងទាក់ទងនឹងអង្គការអន្តរជាតិ កិច្ចសន្យា ហិរញ្ញវត្ថុរបស់រដ្ឋ សន្ធិសញ្ញាដែលកែប្រែបញ្ញត្តិច្បាប់ ឬដែលទាក់ទងនឹងស្ថានភាពបុត្តល សន្ធិសញ្ញាសន្តិភាព ឬដែលទាក់ទងនឹងដែនដីត្រូវមានច្បាប់អនុញ្ញាត ។

ត-អំណាចផ្តល់ការប្រឹក្សា

រដ្ឋាភិបាលពិគ្រោះយោបល់ជាមួយព្រឹទ្ធសភាលើបញ្ហាសេដ្ឋកិច្ច សង្គម និងការរៀបចំដែនដី ។

ឃ-ទំនាក់ទំនងជាមួយប្រធានាធិបតី

ប្រធានាធិបតីនៃសាធារណរដ្ឋទាក់ទងជាមួយសភាតាមសារ ដែលមិនអាចពិភាក្សាបានឡើយ ។

៤-បនប្បញ្ញត្តិដោយឡែក

ក-ខេត្តស្វយ័ត

១-សមាជិកព្រឹទ្ធសភាជាសមាជិកពេញច្បាប់ នៃក្រុមប្រឹក្សាខេត្ត...។

២-អ្នកមានកំហុសអាចត្រូវដកពីតំណែងដោយប្រធានាធិបតីនៃសាធារណរដ្ឋ ក្រោយពីពិគ្រោះយោបល់ជាមួយគណៈកម្មការចំរុះសភាទាំងពីរ ។

៣-ប្រធានព្រឹទ្ធសភា (ក៏ជាប្រធានរដ្ឋសភា) ឬតំណាងចូលរួមដោយពេញច្បាប់ក្នុងសន្និសីទអន្តរខេត្ត ដើម្បីពិនិត្យបញ្ហាទាក់ទងនឹងផលប្រយោជន៍រួមរវាងអំណាចកណ្តាល និងខេត្ត ស្មើគណៈមួយឬច្រើន ឬរវាងខេត្តស្មើគ្នាពីរឬច្រើន។

ខ-វិស្សមកាលនៃប្រធានាធិបតី

១-ក្នុងករណីវិស្សមកាលនៃប្រធានាធិបតីនៃសាធារណរដ្ឋដោយការលាលែង អនិច្ចកម្ម ឬដោយមិនអាចបំពេញមុខងារបាន តំណែងប្រមុខរដ្ឋត្រូវកាន់កាប់ជាបណ្តោះអាសន្នដោយប្រធានព្រឹទ្ធសភា។

២-វិស្សមកាលមួយរយៈពេល

វិស្សមកាលនេះត្រូវប្រកាសដោយតុលាការធម្មនុញ្ញជាន់ខ្ពស់ តាមសំណើរបស់សភាដែលអនុម័តដោយឡែកពីគ្នា តាមសម្លេងភាគច្រើន២/៣ ដោយមូលហេតុអសមត្ថភាពរាងកាយ ឬស្មារតី ។

រយៈពេលនេះមិនអាចលើសពី៦ខែបានទេ។ បើហួសរយៈពេល៦ខែនេះ តុលាការធម្មនុញ្ញជាន់ខ្ពស់អាចប្រកាសប្តូរពីវិស្សមកាលបណ្តោះអាសន្នទៅជាវិស្សមកាលស្ថាពរ។

គ-អំណាចក្នុងវិស័យជំនំជម្រះ

១-តុលាការយុត្តិធម៌ជាន់ខ្ពស់មានសមាជិកព្រឹទ្ធសភា២នាក់ជាសមាជិកពេញសិទ្ធិ និង២នាក់ទៀតជាសមាជិកបំរុង ដែលជ្រើសតាំងដោយព្រឹទ្ធសភា។

២-ប្រធានាធិបតីនៃសាធារណរដ្ឋ អាចត្រូវចោទប្រកាន់ទៅតុលាការយុត្តិធម៌ជាន់ខ្ពស់បានតែ ដោយសភាទាំងពីរដែលអនុម័តដោយឡែកពីគ្នា ដោយការបោះឆ្នោតសាធារណៈតាមសម្លេងភាគច្រើន២/៣នៃសមាជិកសភានីមួយៗ ចំពោះអំពើបំពេញកិច្ចការក្នុងមុខងារ ក្នុងករណីក្បត់ធ្ងន់ធ្ងរ ឬការរំលោភរដ្ឋធម្មនុញ្ញយ៉ាងធ្ងន់ធ្ងរ និងច្រំដែលៗ។

ឃ-តុលាការធម្មនុញ្ញជាន់ខ្ពស់

១-សមាជិកតុលាការធម្មនុញ្ញជាន់ខ្ពស់ត្រូវតែងតាំងដោយព្រឹទ្ធសភា ។

២-ប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភាចំនួន១/៤អាចបញ្ជូនទៅតុលាការធម្មនុញ្ញជាន់ខ្ពស់នូវអត្ថបទដែលមានតម្លៃជាច្បាប់ឬបទបញ្ជា ក៏ដូចជាវិស័យទាំងអស់ដែលទាក់ទងនឹងសមត្ថកិច្ចរបស់ខ្លួន ដើម្បីវាយតម្លៃអំពីធម្មនុញ្ញភាព ។

៣-ប្រធានព្រឹទ្ធសភាអាចពិគ្រោះយោបល់ជាមួយតុលាការធម្មនុញ្ញជាន់ខ្ពស់លើធម្មនុញ្ញភាពនៃគ្រប់សេចក្ដីព្រាងច្បាប់ ឬលើការបកស្រាយបទប្បញ្ញត្តិធម្មនុញ្ញណាមួយ ។

ង-ការសើរើរដ្ឋធម្មនុញ្ញ

ការផ្ដួចផ្ដើមកំណែតសើរើរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ របស់សភាដោយការអនុម័តដាច់ដោយឡែកពីគ្នាតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកសភានីមួយៗ ។

សេចក្ដីព្រាង ឬសេចក្ដីស្នើសើរើរដ្ឋធម្មនុញ្ញត្រូវអនុម័តតាមសម្លេងភាគច្រើន៧/៨នៃសមាជិករដ្ឋសភា និងព្រឹទ្ធសភា ។

ម៉ាឡេស៊ី ព្រឹទ្ធសភា

MALAISIE LE SENAT

DEWAN NEGARA

I-សមាសភាព

ព្រឹទ្ធសភាមានសមាជិក៦៩នាក់:

-២៦នាក់ជ្រើសរើសដោយមិនផ្ទាល់ (២នាក់ក្នុងមួយរដ្ឋ)

-៤៣នាក់ តែងតាំងដោយម្រមុខរដ្ឋ ដែលមាន២នាក់សំរាប់ដែនដីសហភាពកូឡាឡាំពូ និង១នាក់សំរាប់ដែនដីសហភាពឡាបួន ។

អ្នកដែលត្រូវបានតែងតាំង ត្រូវតែជាអ្នកដែលបានបំពេញការងារដ៏ល្អប្រសើរ ឬបានត្រឿងឥស្សរិយយសខាងពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សកម្មភាពវប្បធមិសង្គមឬមានភាពជាតំណាងពូជសាសន៍ភាគតិច ឬមានសមត្ថកិច្ចតំណាងផលប្រយោជន៍នៃអូរ៉ង់អាស្លី (Orang asli-peuplement originel de la Malaisie péninsulaire et de Bornéo) ។

II-របបបោះឆ្នោត

-បោះឆ្នោតមិនផ្ទាល់

-សភានីមួយ៣នៃសភានីតិប្បញ្ញត្តិខេត្តទាំង១៣ជ្រើសរើសសមាជិកព្រឹទ្ធសភា២នាក់

អាណត្តិ : ៣ឆ្នាំ ផ្ទាស់ប្តូរថ្មីតែម្តងគត់

ការផ្ទាស់ប្តូរចុងក្រោយ : ២២ មីនា ២០០៤

លក្ខខណ្ឌ : អាយុ ៣០ឆ្នាំ ជនជាតិម៉ាឡេស៊ី រស់នៅក្នុងសហភាព

ហាមឃាត់: ជាប់កាតព្វកិច្ចជាមួយរដ្ឋបរទេសមានទោសជាប់ពន្ធនាគារ១ឆ្នាំឬច្រើនជាងឬមានទោសពិន័យយ៉ាងតិច ២០០០ ringgit ។

វិសមិតភាព : ភ្នាក់ងារសាធារណៈពេញម៉ោងនៅអង្គភាពដែលបានកំរៃក្រៅច្រើន

លក្ខខណ្ឌបន្ថែម : មានការគាំទ្រពីអ្នកបោះឆ្នោតក្នុងមណ្ឌល២នាក់ និងមិនចាំបាច់ជាសមាជិកគណបក្សនយោបាយណាមួយទេ ។

III-**សម័យប្រជុំ**

សភា(ព្រឹទ្ធសភានិងរដ្ឋសភា) ត្រូវកោះប្រជុំដោយប្រមុខរដ្ឋ ។ ចន្លោះពីសម័យប្រជុំមួយទៅសម័យប្រជុំមួយត្រូវមានរយៈពេល៦ខែយ៉ាងច្រើន ។

IV-**ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ**

ក-អំណាចនីតិប្បញ្ញត្តិ

១-សិទ្ធិផ្តួចផ្តើមធ្វើច្បាប់

គំនិតផ្តួចផ្តើមធ្វើច្បាប់ជាសិទ្ធិរបស់ព្រឹទ្ធសភា (ដូចជារដ្ឋសភា) លើកលែងតែវិស័យហិរញ្ញវត្ថុ និងពន្ធដារ ។

២-សិទ្ធិវិសោធនកម្ម

ព្រឹទ្ធសភាមានសិទ្ធិវិសោធនកម្ម ប៉ុន្តែមានកំរិតក្នុងវិស័យហិរញ្ញវត្ថុ និងពន្ធដារ ។

៣-នីតិវិធីធ្វើច្បាប់

ក-ច្បាប់ទាំងឡាយត្រូវតែអនុម័តដោយសភាទាំងពីរ ។ បន្ទាប់ពីសភាណាមួយបានអនុម័តរួច សេចក្តីព្រាងច្បាប់ត្រូវបញ្ជូនទៅសភាមួយទៀត ។ បើសភាក្រោយនេះអនុម័តឬមានការព្រមព្រៀងគ្នារវាងសភាទាំងពីរ សេចក្តីព្រាងច្បាប់ត្រូវបញ្ជូនទៅប្រមុខរដ្ឋ ដែលមានពេល៣០ថ្ងៃសំរាប់ចុះហត្ថលេខា ។ បើហួសរយៈពេលហើយប្រមុខរដ្ឋមិនបានចុះហត្ថលេខា អត្ថបទនោះក្លាយជាច្បាប់ ។

ខ-ច្បាប់ដែលត្រូវអនុម័តតែដោយរដ្ឋសភា

១-សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុត្រូវតែដាក់ជូនរដ្ឋសភា ។ កាលបើរដ្ឋសភាអនុម័តរួច សេចក្តីព្រាងនេះត្រូវបញ្ជូនទៅព្រឹទ្ធសភា ។

បើសេចក្តីព្រាងច្បាប់នេះបានបញ្ជូនទៅ១ខែយ៉ាងតិចមុនចប់សម័យប្រជុំ ក្នុងករណីដែលព្រឹទ្ធសភាមិនអនុម័តដោយគ្មានការកែប្រែ ក្នុងរយៈពេល១ខែ សេចក្តីព្រាងត្រូវបញ្ជូនទៅប្រមុខរដ្ឋចុះហត្ថលេខា បើសិនជារដ្ឋសភាមិនសម្រេចអ្វីផ្សេងទៀត ។

២-ក្នុងករណីខាងក្រោមនេះ:

-សេចក្តីព្រាងច្បាប់(ដែលមិនមែនហិរញ្ញវត្ថុ)ដែលរដ្ឋសភាបានអនុម័តដែលផ្ញើជូនព្រឹទ្ធសភា ១ខែមុនចប់សម័យប្រជុំ ហើយព្រឹទ្ធសភាមិនបានអនុម័ត ឬបានអនុម័តដោយមានវិសោធនកម្ម ដែលរដ្ឋសភាមិនទទួលយក។

-នៅសម័យប្រជុំបន្ទាប់ ប៉ុន្តែមិនមុនផុត១ឆ្នាំបន្ទាប់ពីការអនុម័តលើកទី១ របស់រដ្ឋសភា សេចក្តីព្រាងច្បាប់ដដែលដែលគ្មានវិសោធនកម្មផ្សេងពីវិសោធនកម្មដែលទទួលស្គាល់ដោយប្រធាន រដ្ឋសភាថាជាការចាំបាច់ដោយសារការកន្លងទៅនៃពេលវេលាចាប់តាំងពីការអនុម័តលើកទី១ ឬ ដោយទទួលយកវិញនូវវិសោធនកម្មរបស់ព្រឹទ្ធសភាត្រូវតែអនុម័តជាថ្មីដោយរដ្ឋសភា និងបញ្ជូន ទៅព្រឹទ្ធសភាយ៉ាងតិច១ខែមុនចប់សម័យប្រជុំ ។ ព្រឹទ្ធសភាមិនអនុម័ត ឬអនុម័តដោយមាន

វិសោធនកម្មដែលរដ្ឋសភាមិនគាំទ្រ។

-អត្ថបទនេះ បើសិនរដ្ឋសភាមិនសម្រេចអ្វីផ្សេងត្រូវបញ្ជូនទៅប្រមុខរដ្ឋ ដើម្បីចុះហត្ថ-លេខាដោយភ្ជាប់ទៅនូវការកែប្រែដែលសភាទាំងពីរបានយល់ព្រម។

ខ-អំណាចត្រួតពិនិត្យ

បើនាយករដ្ឋមន្ត្រីបាត់ការទុកចិត្តពីរដ្ឋសភា នាយករដ្ឋមន្ត្រីត្រូវដាក់ពាក្យលាលែងរបស់ គណៈរដ្ឋមន្ត្រី បើសិនជាប្រមុខរដ្ឋមិនរំលាយរដ្ឋសភាទេ។

គ-ទំនាក់ទំនងជាមួយប្រមុខរដ្ឋ

ប្រមុខរដ្ឋអាចប្រាស្រ័យដោយផ្ទាល់ជាមួយសភានីមួយៗ ឬសភាទាំងពីរប្រជុំរួមគ្នា។

ឃ-សិទ្ធិចូលក្នុងរដ្ឋាភិបាល

រដ្ឋមន្ត្រីនានាត្រូវជ្រើសរើសពីក្នុងចំណោមសមាជិកសភា ហើយអ្នកទី១ត្រូវតែជាសមាជិក រដ្ឋសភា។ បន្ថែមពីលើសិទ្ធិជាសមាជិកសភាណាមួយ សមាជិករដ្ឋាភិបាលម្នាក់ៗមានសិទ្ធិចូលរួម ក្នុងអង្គប្រជុំរបស់សភាមួយទៀត។

អត្តរដ្ឋអាជ្ញា ឬសមាជិកណាក៏ដោយរបស់រដ្ឋាភិបាលអាចត្រូវតែងតាំងជាសមាជិកគណៈកម្មការណាមួយដោយសភាដែលខ្លួនជាសមាជិក ។

ង-ការរំលាយ ឬពន្យារពេល

ប្រមុខរដ្ឋអាចពន្យារអាណត្តិឬរំលាយសភា ។ ក្នុងករណីរំលាយ ការបោះឆ្នោតជាទូទៅត្រូវរៀបចំឡើងក្នុងរយៈពេល៦០ថ្ងៃក្រោយថ្ងៃរំលាយ ហើយសភាត្រូវកោះប្រជុំយ៉ាងយូរ១២០ថ្ងៃក្រោយថ្ងៃនោះ ។

V-**បទប្បញ្ញត្តិដោយឡែក**

ក-ការកែប្រែរដ្ឋធម្មនុញ្ញ

បទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញអាចកែប្រែបានដោយច្បាប់សហព័ន្ធ (loi fédérale) ។ ដើម្បីអនុម័តដោយសភាមួយអត្ថបទ (លើកលែងចំពោះបញ្ញត្តិខ្លះ) ត្រូវទទួលបានសម្លេង២/៣យ៉ាងតិចនៃសភានោះនៅពេលពិនិត្យលើកទី២ និងលើកទី៣ ។ ក្នុងករណីខ្លះបទប្បញ្ញត្តិរដ្ឋធម្មនុញ្ញដែលអនុញ្ញាតឱ្យសភាបន្ថយសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពក្នុងការប្រជុំ ក្នុងការបង្កើតសមាគម ឬម្យ៉ាងទៀតដែលទាក់ទងនឹងសិទ្ធិពលរដ្ឋ ក្រុមប្រឹក្សាព្រះមហាក្សត្រ (conseil royal) ឬបញ្ញត្តិខ្លះដែលទាក់ទងនឹងរដ្ឋនានា ភាសាជាតិ ឬផលប្រយោជន៍របស់ពលរដ្ឋប្រភេទខ្លះ មិនអាចធ្វើវិសោធនកម្ម ដោយគ្មានការយល់ព្រមពីក្រុមប្រឹក្សាព្រះមហាក្សត្របានឡើយ ។

ខ-ស្ថានភាពអាសន្ន

ការប្រកាសភាពអាសន្នរបស់មុខរដ្ឋអស់មានឥទ្ធិពលបើសភាទាំងពីរអនុម័តសេចក្តីសម្រេចចិត្តបដិសេធចោល ។

I-សមាសភាព

សភាទីប្រឹក្សាមានសមាជិកជាទីប្រឹក្សា២៧០នាក់ ជ្រើសតាំងដោយការ បោះឆ្នោតមិនផ្ទាល់ ។

II -របបបោះឆ្នោត

ក-ទីប្រឹក្សា១៦២នាក់(៧៥) ត្រូវជ្រើសតាំងក្នុងតំបន់ធំមួយ១ ដោយអ្នកតំណាងនានានៃសម្ព័ន្ធភាពមូលដ្ឋាន -représentants des collectivités locales (ទីប្រឹក្សាមូលដ្ឋាន និងតំបន់-conseillers locaux et régionaux) សភាឃុំនិងខេត្ត (préfectorales et provinciales) ។

ខ-ទីប្រឹក្សា១០៨នាក់(២/៥)ត្រូវជ្រើសរើសក្នុងតំបន់ធំមួយ១ ដោយសមាជិកជាប់ឆ្នោតនៃសភាមុខរបរ(Chambre professionnelles,industrie,agriculture,artisanat,commerce, services, pêches maritimes) និងសមាជិកជាប់ឆ្នោតថ្នាក់ជាតិដោយតំណាងកម្មករ ។

ត-អាណត្តិ : ៩ ឆ្នាំ ផ្លាស់ប្តូរ១/៣ រៀងរាល់ពីឆ្នាំ

ឃ-ការបោះឆ្នោតលើកទី១ : ៥ ធ្នូ ១៩៩៧

ការផ្លាស់ប្តូរចុងក្រោយ : កញ្ញា ២០០៦

III-សម័យប្រជុំ

ក-សម័យប្រជុំសាមញ្ញ

សភាទីប្រឹក្សាប្រជុំ២ដងក្នុង១ឆ្នាំ :

-លើកទី១ បើកនៅថ្ងៃសុក្រទី២នៃខែ តុលា

-លើកទី២ បើកនៅថ្ងៃសុក្រទី២នៃខែ មេសា ។

ការបិទសម័យប្រជុំអាចប្រកាសដោយក្រឹត្យ កាលបើសភាបានប្រជុំពាក់ខែយ៉ាងតិច ។

ខ-សម័យប្រជុំវិសាមញ្ញ

-តាមសំណើរបស់សមាជិកភាគច្រើនដាច់ខាតនៃសភា ណាមួយ ឬ

-ដោយក្រឹត្យ តាមរបៀបវារៈមួយជាក់លាក់ ។

សម័យប្រជុំវិសាមញ្ញត្រូវបិទដោយក្រឹត្យពេលអស់របៀបវារៈ ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-ឥទិតផ្តួចផ្តើមធ្វើច្បាប់

សភាទីប្រឹក្សាមានសិទ្ធិផ្តួចផ្តើមឥទិតធ្វើច្បាប់ ដូចនាយការដ្ឋមន្ត្រី និងតំណាងរាស្ត្រ ។ប៉ុន្តែសេចក្តីស្នើមិនអាចទទួលយកបានទេ កាលបើប្រៀបធៀបនឹងច្បាប់ហិរញ្ញវត្ថុនាំឱ្យថយចុះនូវធនធានសាធារណៈ ឬបង្កើត ឬបន្ថែមបន្ទុកសាធារណៈ ។

ម្យ៉ាងទៀត មានតែរដ្ឋាភិបាលទេដែលអាចដាក់សេចក្តីព្រាងច្បាប់កែប្រែចំណាយវិនិយោគដែលចេញពីផែនការអភិវឌ្ឍន៍ ដែលសភាបានអនុម័ត ។

២-សិទ្ធិវិសោធនកម្ម

សភាទីប្រឹក្សាមានសិទ្ធិធ្វើវិសោធនកម្ម ដូចរដ្ឋាភិបាលនិងតំណាងរាស្ត្រ ។ ប៉ុន្តែសេចក្តីស្នើមិនអាចទទួលយកបានទេ កាលបើប្រៀបធៀបនឹងច្បាប់ហិរញ្ញវត្ថុនាំឱ្យថយចុះនូវធនធានសាធារណៈ ឬបង្កើត ឬបន្ថែមបន្ទុកសាធារណៈ ។

៣-នីតិវិធីធ្វើច្បាប់

ក-ការដាក់ និងការបញ្ជូនទៅ-មក

សេចក្តីព្រាងច្បាប់នានាត្រូវដាក់ជូនការិយាល័យសភាណាមួយ និងដាក់ជូនគណៈកម្មការណាមួយពិនិត្យ ។

សេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ត្រូវដាក់ពិនិត្យជាបន្តបន្ទាប់ដោយសភាទាំងពីរដើម្បីបានអត្ថបទតែមួយ ។

ក្រោយសភានីមួយ១បានពិនិត្យ២ដង(ម្តងបើរដ្ឋាភិបាលប្រកាសជាការប្រញាប់)រដ្ឋាភិបាលអាចកោះប្រជុំគណៈកម្មការចំរុះសមភាគី ។ អត្ថបទរបស់គណៈកម្មការចំរុះអាចត្រូវរដ្ឋាភិបាលដាក់ឱ្យសភាទាំងពីរអនុម័ត ។ ត្មានវិសោធនកម្មណាមួយអាចទទួលយកបានដោយត្មានការយល់ព្រមពីរដ្ឋាភិបាលទេ ។

ក្នុងករណីដែលគណៈកម្មការចំរុះបរាជ័យ ឬករណីបដិសេធអត្ថបទរបស់គណៈកម្មការចំរុះ រដ្ឋាភិបាលអាចសុំឱ្យរដ្ឋសភាសម្រេចជាចុងក្រោយ ដែលអាចសម្រេចលើអត្ថបទកែប្រែ (ករណីដែលគួរ-le cas échéant) ដោយវិសោធនកម្មរបស់សភា និងទទួលយកវិញដោយរដ្ឋាភិបាល តាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភា ។

៩-បទឃ្យញ្ញត្តិដោយឡែក

១-ច្បាប់រៀបចំអង្គការទាក់ទងនឹងសភាទីប្រឹក្សាត្រូវអនុម័តដោយសភាទាំងពីរ ។

២-សន្ធិសញ្ញាធានាខាងហិរញ្ញវត្ថុរដ្ឋមិនអាចផ្តល់សច្ចាប័ន ដោយគ្មានការអនុញ្ញាតជាមុនពីច្បាប់ ។

៣-ក្រឹត្យ-ច្បាប់

ក្នុងចន្លោះសម័យប្រជុំ ដោយមានការយល់ព្រមពីគណៈកម្មការសភាទាំងពីរដែលមានការពាក់ព័ន្ធ ក្នុងរយៈពេល៦ថ្ងៃ រដ្ឋាភិបាលអាចចេញក្រឹត្យ-ច្បាប់ ដែលត្រូវដាក់សុំសច្ចាប័នពីសភានៅសម័យប្រជុំសាមញ្ញបន្ទាប់ ។

ក្នុងករណីដែលមិនមានការព្រមព្រៀងគ្នារវាងគណៈកម្មការសភាទាំងពីរ រដ្ឋាភិបាលអាចស្នើបង្កើតគណៈកម្មការចំរុះសមភាគី ។

បើគណៈកម្មការចំរុះមិនអាចរកការព្រមព្រៀងបាន ក្នុងរយៈពេល៣ថ្ងៃបន្ទាប់ពីថ្ងៃស្នើសុំ ឬបើសេចក្តីសម្រេចរបស់គណៈកម្មការចំរុះមិនបានការអនុម័តពីគណៈកម្មការសភាទាំងពីរ ក្នុងរយៈពេល៤ថ្ងៃ នោះត្រូវសន្មតថាពុំមានការព្រមព្រៀងឡើយ ។

គ-រប្បៀបវារៈរបស់សភាទីប្រឹក្សា(ជូចជារដ្ឋសភា) ត្រូវរៀបចំដោយការិយាល័យរបស់ខ្លួន ។

រប្បៀបវារៈមានជាអាទិភាព និងតាមលំដាប់ដែលរដ្ឋាភិបាលបានកំណត់ គឺសេចក្តីព្រាងច្បាប់ដែលដាក់ជូនដោយរដ្ឋាភិបាលនិងសេចក្តីស្នើច្បាប់ដែលរដ្ឋាភិបាលយល់ព្រម ។

៩-សំណួរ

ក្នុងមួយសប្តាហ៍ មានកម្មវិធី១ពេលសំរាប់សំណួរបស់ទីប្រឹក្សានិងចម្លើយរបស់រដ្ឋាភិបាល ។

ចម្លើយត្រូវផ្តល់ក្នុងរយៈពេល២០ថ្ងៃ បន្ទាប់ពីពេលផ្ញើមក ។

២-គណៈកម្មការអង្កេត

គណៈកម្មការអង្កេតអាចបង្កើតឡើងតាមសំណើរបស់ទីប្រឹក្សាភាគច្រើន(ឬព្រះមហាក្សត្រ) ដើម្បីរកព័ត៌មានអំពីកិច្ចការយ៉ាងជាក់លាក់ ។បេសកកម្មរបស់គណៈកម្មការអង្កេតត្រូវបញ្ចប់នៅពេលផ្តល់របាយការណ៍ ។ ពេលដែលករណីនោះស្ថិតក្នុងដំណើរការរបស់តុលាការ គណៈកម្មការអង្កេតមិនអាចបង្កើតបានឡើយ ។បើគណៈកម្មការត្រូវបានបង្កើតរួចហើយ ការងាររបស់គណៈកម្មការត្រូវបញ្ចប់ចាប់ពីពេលបើកព័ត៌មានរបស់តុលាការ អំពីកិច្ចការដែលជាមូលហេតុនៃការបង្កើតគណៈកម្មការ ។

៣-ការទទួលខុសត្រូវរបស់រដ្ឋាភិបាល

ក្រោយពេលមហាក្សត្រតែងតាំងសមាជិករដ្ឋាភិបាល នាយករដ្ឋមន្ត្រីត្រូវបង្ហាញខ្លួននៅមុខសភាទាំងពីរដើម្បីថ្លែងអំពីកម្មវិធីរបស់រដ្ឋាភិបាល ។កម្មវិធីនេះជាកម្មវត្ថុនៃការពិភាក្សារបស់សភាទីប្រឹក្សា តែមិនមានការអនុម័តអ្វីឡើយ ។

៤-ញត្តិព្រមាន ឬបន្ទោស

ក-សភាទីប្រឹក្សាអាចអនុម័តញត្តិព្រមានរដ្ឋាភិបាលដែលត្រូវចុះហត្ថលេខាដោយទីប្រឹក្សា ១៣យ៉ាងតិច ។

ញត្តិនេះត្រូវអនុម័តដោយទីប្រឹក្សា តាមមតិភាគច្រើនដាច់ខាត ។ការអនុម័តអាចធ្វើបានតែ៣ថ្ងៃគត់ ក្រោយពេលដាក់ញត្តិ ដែលត្រូវបញ្ជូនភ្លាមទៅនាយករដ្ឋមន្ត្រី ដែលមានពេល៣ថ្ងៃដើម្បីបង្ហាញសាន្ទវជ្ជបណ្ឌិតរបស់រដ្ឋាភិបាលលើមូលហេតុនៃការព្រមាន ។

ប្រកាសរបស់រដ្ឋាភិបាលមានការពិភាក្សាតែពុំមានការអនុម័តអ្វីឡើយ ។

ខ- ញត្តិបន្ទោសអាចទទួលយកបានលុះត្រាតែមានហត្ថលេខារបស់ទីប្រឹក្សាចំនួន១៣យ៉ាងតិច ។

ញត្តិនេះត្រូវអនុម័តតាមសម្លេងភាគច្រើន២ / ៣នៃចំនួនទីប្រឹក្សាទាំងអស់ ។

ការអនុម័តអាចធ្វើបានតែក្នុងពេល ៣ថ្ងៃតត់ក្រោយពេលដាក់ញត្តិ ។

ការអនុម័តញត្តិបន្ទោសបណ្តាលឱ្យរដ្ឋាភិបាលលាលែង ។

ត-ការរំលាយ

ព្រះមហាក្សត្រអាចរំលាយសភាណាមួយ ឬសភាទាំងពីរ ក្រោយពីការពិគ្រោះយោបល់ជាមួយប្រធានសភាទាំងពីរ និងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ព្រមទាំងផ្ទើសារជូនប្រជាជាតិ ។

ការបោះឆ្នោតត្រូវធ្វើឡើងក្នុងពេលពាខែក្រោយការរំលាយ ។

ក្នុងចន្លោះពេលនោះ ព្រះមហាក្សត្រកាន់អំណាចសភាក្នុងវិស័យនីតិប្បញ្ញត្តិ ។

ការរំលាយជាថ្មីអាចធ្វើបានតែក្នុងពេល១ឆ្នាំ ក្រោយការបោះឆ្នោតសភាថ្មី ។

V-បនប្បញ្ញត្តិដោយឡែក

ក-អំណាចធម្មនុញ្ញ

១-ការផ្ទូចផ្តើមគំនិតសើរើរដ្ឋធម្មនុញ្ញ

សមាជិកសភាទីប្រឹក្សា ព្រះមហាក្សត្រ និងសមាជិករដ្ឋសភាមានសិទ្ធិផ្ទូចផ្តើមគំនិតសើរើរដ្ឋធម្មនុញ្ញ ។

២-ការអនុម័ត

សេចក្តីស្នើវិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវអនុម័តតាមសម្លេងភាគច្រើន២/៣នៃចំនួនសមាជិកសភាដែលផ្តើមគំនិត ។ សេចក្តីស្នើនេះត្រូវបញ្ជូនទៅសភាមួយទៀតដែលត្រូវអនុម័តតាមសម្លេងភាគច្រើន២/៣នៃសមាជិករបស់សភានោះ ។

ការសើរើទៅជាស្ថាពរក្រោយពីបានការយល់ព្រមពីប្រជាមតិ ។

ខ-ប្រធានសភាទីប្រឹក្សាជាសមាជិកក្រុមប្រឹក្សារាជានុសិទ្ធិ (conseil de régence)

 គ-ស្ថានភាពអាសន្ន

ព្រះមហាក្សត្រប្រកាសស្ថានភាពអាសន្នពេលបូរណភាពដែនដីត្រូវគំរាមកំហែង ឬពេលមានព្រឹត្តិការណ៍ដែលអាចបណ្តាលឱ្យមានភាពមិនប្រក្រតីនៃដំណើរការរបស់ស្ថាប័នធម្មនុញ្ញ ។

ប្រធានសភាទាំងពីរ ក៏ដូចជាប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានពិគ្រោះយោបល់ជាមុន និងមានសារធ្វើជូនប្រជាជាតិ ។

ស្ថានភាពអាសន្នមិនធ្វើឱ្យមានការរំលាយសភាទេ ។

ឃ-ការបន្តស្ថានភាពអាសន្ន

ការបន្តស្ថានភាពអាសន្នហួសពី៣០ថ្ងៃ ត្រូវធ្វើឡើងដោយច្បាប់ ។

ង-ការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់សមាជិករដ្ឋាភិបាល ចំពោះបទឧក្រិដ្ឋ និងបទមជ្ឈឹម ក្នុងការបំពេញមុខងារ

១-ការចោទប្រកាន់

សភាតាំងពីរធ្វើការចោទប្រកាន់ទៅតុលាការជាន់ខ្ពស់ ។

ពាក្យសុំចោទប្រកាន់ត្រូវចុះហត្ថលេខាដោយសមាជិកសភា ដែលពាក្យសុំបានដាក់ជាលើកដំបូងចំនួនយ៉ាងតិច១/៤ ។

ពាក្យសុំនេះត្រូវអនុម័តយល់ព្រមពីសភានីមួយៗជាសម្ងាត់ តាមសម្លេងភាគច្រើន២/៣ នៃសមាជិកសភា លើកលែងតែសមាជិកដែលត្រូវចាត់ឱ្យតាមដានស្រាវជ្រាវ ឬកាត់សេចក្តី ។

២-តុលាការជាន់ខ្ពស់មានសមាសភាពចំនួនស្មើគ្នាមកពីទីប្រឹក្សា និងតំណាងជាប់ឆ្នោត ។

ច-ការត្រួតពិនិត្យធម្មនុញ្ញភាព

១-សិទ្ធិស្នើ

ប្រធានសភាទីប្រឹក្សា ឬសមាជិកសភានេះចំនួន១/៤អាចស្នើក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពរបស់ច្បាប់មុនទើងប្រកាស់ឱ្យប្រើ ។

២-សមាសភាពក្រុមប្រឹក្សា

សមាជិក៣នាក់ (២/១២) នៃក្រុមប្រឹក្សា ត្រូវតែងតាំងដោយប្រធានសភាទីប្រឹក្សាក្រោយ

ពីបានពិគ្រោះយោបល់ជាមួយក្រុមនានា ។

រដ្ឋប្រហារថ្ងៃទី៣ ខែសីហាឆ្នាំ២០០៥ ដែលដឹកនាំដោយ Ely Ould Mohamed Vall បានផ្តួលរំលំប្រធានាធិបតីកាន់តំណែង Maaouiya Ould Taya ។

សភាត្រូវរំលាយនៅថ្ងៃទី៥ខែសីហា ។

រដ្ឋអំណាចយោធាថ្មីបានប្រកាសនូវឆន្ទៈរបស់ខ្លួនក្សាទុកនូវរដ្ឋធម្មនុញ្ញថ្ងៃ២០ខែកក្កដា ឆ្នាំ១៩៩១ ហើយ សន្យានាំត្រឡប់មកវិញយ៉ាងឆាប់នូវលិទ្ធិប្រជាធិបតេយ្យ ។

នៅខែមិថុនា ឆ្នាំ២០០៦ ការសើរើរដ្ឋធម្មនុញ្ញត្រូវប្រជាមតិអនុម័តយ៉ាងទូលំទូលាយ ។ រដ្ឋធម្មនុញ្ញកំណត់អាណត្តិប្រធានាធិបតី៥ឆ្នាំ និងហាមមិនឱ្យកាន់អំណាចលើសពី២អាណត្តិ ។

ការសើរើរធ្វើឱ្យមានការបោះឆ្នោតច្រើន : ក្រុង (municipales) នីតិប្បញ្ញត្តិ(législatives) នៅខែវិច្ឆិកាឆ្នាំ២០០៦ បន្ទាប់មកបោះឆ្នោតព្រឹទ្ធសភា (sénatoriale) នៅខែកុម្ភៈឆ្នាំ២០០៧ ។

ការបោះឆ្នោតជ្រើសរើសប្រធានាធិបតីធ្វើឡើងនៅខែមីនា ឆ្នាំ២០០៧ ។

Ely Ould Mohamed Vall មិនបានឈរឈ្មោះជាបេក្ខជននៅពេលនោះទេ ។

ចាប់ពីពេលនោះតមក ព្រឹទ្ធសភាម៉ូរីតានីបានទទួលនូវអំណាចយ៉ាងពេញលេញ ដែលរដ្ឋធម្មនុញ្ញបានប្រគល់ឱ្យ ។

I-សមាសភាព

ព្រឹទ្ធសភាមានសមាជិកជ្រើសតាំងចំនួន៥៦នាក់ :

-៥៣នាក់ ជាតំណាងសមូហភាពដែនដីជ្រើសរើសដោយ ការបោះឆ្នោតសកល មិនផ្ទាល់ universel indirect)

-៣នាក់ តំណាងពលរដ្ឋម៉ូរីតានីរស់នៅឯបរទេស ។

II-របៀបបោះឆ្នោត

១-តំណាងសមូហភាពដែនដី(១នាក់ក្នុងមួយមណ្ឌល)

-ឯកត្តនាម ពីរជុំ(ជុំទី១ តាមសម្លេងភាគច្រើនដាច់ខាតនៃឆ្នោតដែលបានបោះ)

-សមាមាត្រនៅមណ្ឌលNouakchot (កែប្រែបញ្ជីលថ្មី មុនពេលបោះឆ្នោតឆ្នាំ២០០២)

-មណ្ឌលបោះឆ្នោត: moughataa មណ្ឌលរដ្ឋបាលបន្ទាប់បន្សំ ត្រូវនឹងខេត្ត(département)

-អ្នកបោះឆ្នោត (collège électoral) :មេឃុំ(maires) និងទីប្រឹក្សាក្រុងនៃឃុំ (conseillers municipaux des communes)ក្នុងមណ្ឌល ។

២-តំណាងពលរដ្ឋរស់នៅឯបរទេស

-ឯកត្តនាម ពីរជុំ

-អ្នកបោះឆ្នោត : សមាជិកព្រឹទ្ធសភាតំណាងសម្ព័ន្ធភាពដែនដីទាំង៥៣នាក់ ។

-អាណត្តិ: ៦ឆ្នាំ ផ្លាស់ប្តូរថ្មីមួយភាគបីរៀងរាល់២ឆ្នាំ

-ការផ្លាស់ប្តូរថ្មីចុងក្រោយ: ១១ មេសា ២០០២

លក្ខខណ្ឌ:អាយុ៣៥ឆ្នាំ ពលរដ្ឋម្តាយ៣ឬបានសញ្ជាតិម្តាយ៣យ៉ាងតិច១០ឆ្នាំ ត្រូវនៅ ពីបទល្មើសបោះឆ្នោត ។

ហាម : បានសញ្ជាតិតិចជាង១០ឆ្នាំ ពុករលួយ មានកំហុសក្នុងការបោះឆ្នោត ក្ស័យធន មិនទាន់មានទីតិសម្បទា ។

វិសមិតភាព : សមាជិករដ្ឋាភិបាល ភ្នាក់ងារនៃមុខងារសាធារណៈខ្លះ ។

ii-**សម័យប្រជុំ**

ក-សម័យប្រជុំសាមញ្ញ(២ ក្នុងមួយឆ្នាំ)

-សម័យប្រជុំលើកទី១ :បើកនៅថ្ងៃច័ន្ទទី២នៃខែវិច្ឆិកា

-សម័យប្រជុំលើកទី២ :បើកនៅថ្ងៃច័ន្ទទី២នៃខែឧសភា

-សម័យប្រជុំនីមួយៗមានរយៈពេលមិនលើសពី២ខែទេ ។

ខ-សម័យប្រជុំវិសាមញ្ញ

-តាមសំណើរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ

-តាមសំណើរបស់សមាជិករដ្ឋសភាចំនួនភាគច្រើន

-តាមរបៀបវារៈយ៉ាងជាក់លាក់ ។

សម័យប្រជុំវិសាមញ្ញមានរយៈពេលមិនលើសពី១ខែទេ ។

ការបើក និងបិទសម័យប្រជុំវិសាមញ្ញធ្វើឡើងដោយក្រឹត្យរបស់ប្រធានាធិបតីសាធារណរដ្ឋ ។

គ-សម័យប្រជុំពេញច្បាប់ (sessions de droit)

ព្រឹទ្ធសភាប្រជុំដោយពេញច្បាប់ កាលណាប្រធានាធិបតីនៃសាធារណរដ្ឋអនុវត្តអំណាចពិសេសដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងក្នុងពេលអនុវត្តស្ថានភាពអាសន្នឬបន្ទាន់ ។

ឃ-ការបិទសម័យប្រជុំអាចមានការយឺតយ៉ាវដោយពេញច្បាប់ ក្នុងករណីមានបញ្ហាទុកចិត្តឬមានញត្តិបន្ទោស ។

ង-ការប្រជុំសម្ងាត់

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់ (siéger à huis clos) តាមសំណើរបស់រដ្ឋាភិបាល ឬពីសមាជិកវត្តមានចំនួន១ / ៤ ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-សិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់

សមាជិកសភា និងសមាជិករដ្ឋាភិបាលមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។

សេចក្តីស្នើច្បាប់មិនអាចទទួលយកទេ កាលបើនាំឱ្យមានការកាត់បន្ថយចំណូលសាធារណៈ ឬការបង្កើត ឬបង្កើនបន្ទុកសាធារណៈ លើកលែងតែមានភ្ជាប់ទៅជាមួយនូវសំណើបង្កើនចំណូលឬសេដ្ឋកិច្ចសមមូល ។

២-សិទ្ធិវិសោធនកម្ម

សមាជិកសភា និងសមាជិករដ្ឋាភិបាលមានសិទ្ធិវិសោធនកម្ម ។ សេចក្តីស្នើវិសោធនកម្ម មិនអាចទទួលយកទេ កាលបើនាំឱ្យមានការកាត់បន្ថយចំណូលសាធារណៈ ឬការបង្កើតឬបង្កើនបន្ទុកសាធារណៈ លើកលែងតែមានភ្ជាប់ទៅជាមួយនូវសំណើបង្កើនចំណូលឬសេដ្ឋកិច្ចសមមូល ។

៣-នីតិវិធីធ្វើច្បាប់

ក-ការដាក់អត្ថបទ

សេចក្តីព្រាងច្បាប់ត្រូវដាក់ជូនការិយាល័យសភាណាមួយ លើកលែងតែសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ ដែលត្រូវតែដាក់ជូនរដ្ឋសភាជាលើកដំបូង ។

ខ-នីតិវិធីពិនិត្យ

នៅសភាដែលទទួលសេចក្តីព្រាងលើកដំបូង ការពិភាក្សាត្រូវធ្វើលើអត្ថបទរបស់រដ្ឋាភិបាល ។

តាមសំណើរបស់រដ្ឋាភិបាល ឬរបស់សភាដែលទទួលពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវបញ្ជូនទៅគណៈកម្មការនានា ដែលមានសមត្ថកិច្ចពិសេស ដែលតែងតាំងឡើងឱ្យពិនិត្យ ។

បើពុំមានសំណើទេ សេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់នោះ ត្រូវបញ្ជូនទៅគណៈកម្ម-ការអចិន្ត្រៃយ៍ណាមួយក្នុងចំណោមគណៈកម្មការអចិន្ត្រៃយ៍ទាំង៥ ។

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវតែពិនិត្យជាបន្តបន្ទាប់ដោយសភាទាំងពីរ រហូតមានការឯកភាពលើអត្ថបទតែមួយ ។

សភាដែលទទួលពិនិត្យអត្ថបទដែលសភាមួយទៀតបញ្ជូនមកត្រូវពិនិត្យលើអត្ថបទ ដែលបញ្ជូនមកនោះ ។

ក្នុងករណីមិនមានការព្រមព្រៀងគ្នា ក្រោយពីការអានលើកទី១នៅសភានីមួយៗ កាលណារដ្ឋាភិបាលប្រកាសជាការប្រញាប់ សេចក្តីព្រាងត្រូវដាក់ឱ្យគណៈកម្មការចំរុះសមភាគី ដើម្បីស្នើទុវអត្ថបទមួយលើបញ្ហាដែលត្រូវបន្តពិភាក្សា ។

អត្ថបទនេះអាចដាក់ឱ្យសភាទាំងពីរអនុម័ត ។ ក្នុងករណីនេះ មិនអាចមានវិសោធនកម្មណាមួយទេ ។

លើគណៈកម្មការចំរុះមិនអាចរកបានទុវអត្ថបទរួមទេ ឬបើសិនជាអត្ថបទនោះមិនត្រូវបានសភាទាំងពីរអនុម័តទេ ក្រោយពីការអានជាថ្មីលើកទី១នៅសភានីមួយៗ រដ្ឋាភិបាលអាចស្នើសុំរដ្ឋសភាឱ្យសម្រេចជាចុងក្រោយ ។

ភាពមិនអាចទទួលបាន:

សេចក្តីស្នើច្បាប់ ឬសេចក្តីស្នើវិសោធនកម្មត្រូវប្រកាសថាមិនអាចទទួលយកបាន កាលបើសេចក្តីស្នើទាំងនោះផ្ទៃតទៅលើបទបញ្ជា ឬផ្ទុយទៅនឹងការអនុញ្ញាតរបស់សភាឱ្យរដ្ឋាភិបាលចេញបទប្បញ្ញត្តិ ។

បើសភាធ្វើហួសពីសមត្ថកិច្ច ប្រធានាធិបតីនៃសាធារណរដ្ឋអាចស្នើក្រុមប្រឹក្សាធម្មនុញ្ញឱ្យធ្វើការសម្រេច ក្នុងរយៈពេល៨ថ្ងៃ ។

ក្រោយបើកការពិភាក្សា រដ្ឋាភិបាលអាចជំទាស់នឹងការពិនិត្យលើវិសោធនកម្ម ដែលមិនបានដាក់ឱ្យគណៈកម្មការពិនិត្យជាមុន ។

ការអនុម័តជាកញ្ចប់ :

បើរដ្ឋាភិបាលស្នើសុំ សភាដែលទទួលពិនិត្យអនុម័តតែ១ដង(un seul vote) លើអត្ថបទទាំងមូល ឬផ្នែកណាមួយនៃអត្ថបទដោយរក្សាទុកតែវិសោធនកម្មដែលរដ្ឋាភិបាលបានស្នើ ឬបានយល់ព្រម ។

ឆ-បទប្បញ្ញត្តិទាក់ទងនឹងច្បាប់រៀបចំអង្គការ

សភាដែលបានទទួលអត្ថបទត្រូវពិនិត្យនិងអនុម័ត៧ថ្ងៃក្រោយពីអត្ថបទបានបញ្ជូនមក ។

ក្នុងករណីមានគណៈកម្មការចំរុះសមភាគី អត្ថបទអាចត្រូវអនុម័តជាលើកចុងក្រោយដោយរដ្ឋសភាតែតាមសម្លេងភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភា ។

ច្បាប់រៀបចំអង្គការដែលទាក់ទងនឹងព្រឹទ្ធសភា ត្រូវតែអនុម័តយល់ព្រមដោយសភាទាំងពីរ ។

ច្បាប់រៀបចំអង្គការត្រូវប្រកាសឱ្យប្រើ ក្រោយពេលដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសអំពីធម្មនុញ្ញភាព ។

ឃ-បទប្បញ្ញត្តិទាក់ទងនឹងច្បាប់ហិរញ្ញវត្ថុ

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុត្រូវដាក់ជូនរដ្ឋសភាពិនិត្យជាលើកដំបូងនៅពេលបើកសម័យប្រជុំខែវិច្ឆិកា ។

បើរដ្ឋសភាមិនបានអនុម័តលើកដំបូងក្នុងរយៈពេល៣០ ថ្ងៃក្រោយពេលដាក់ជូន រដ្ឋាភិ-

បានសុំព្រឹទ្ធសភាឱ្យពិនិត្យក្នុងរយៈពេល១៥ថ្ងៃ ។ជាបន្ទាប់មក គណៈកម្មការចំរុះត្រូវប្រជុំ ។

បើសភាមិនបានអនុម័តវិការនៅដំណាច់សម័យប្រជុំ ឬបើមិនអនុម័តដោយមានតុល្យភាពទេ រដ្ឋាភិបាលបញ្ជូនសេចក្ដីព្រាងវិការ ក្នុងរយៈពេល១៥ថ្ងៃទៅរដ្ឋសភា ដែលត្រូវកោះប្រជុំជាវិសាមញ្ញ ។

រដ្ឋសភាត្រូវអនុម័តក្នុងរយៈពេល៨ថ្ងៃ ។ បើវិការមិនបានអនុម័តនៅដំណាច់រយៈពេលនេះ ប្រធានាធិបតីនៃសាធារណរដ្ឋសម្រេចដោយបញ្ជូតិ្ត លើមូលដ្ឋាននៃចំណុលឆ្នាំមុន ។

៤-ទ្រឹតិ្តសម្សទាបទប្បញ្ញត្ដិ

ដោយមានការយល់ព្រមពីប្រធានាធិបតី រដ្ឋាភិបាលអាចស្នើសុំការអនុញ្ញាតពីសភាឱ្យចេញបញ្ជូតិ្តកំណត់ទូវិធានការដែលមានលក្ខណៈជាច្បាប់ សំរាប់រយៈពេលមួយជាកំណត់ ដើម្បីអនុវត្ដកម្មវិធីរបស់ខ្លួន ។

៥-យោបល់របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម

ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមអាចចាត់សមាជិកខ្លួនម្នាក់ ឱ្យបង្ហាញនូវយោបល់របស់ខ្លួនលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ដែលបានដាក់ឱ្យក្រុមប្រឹក្សាពិនិត្យ ។

ខ-អំណាចត្រួតពិនិត្យ

១-ត្រួតពិនិត្យការអនុវត្ដច្បាប់ហិរញ្ញវត្ថុ

សភាត្រួតពិនិត្យការអនុវត្ដវិការដ្ឋ និងវិការ ឧបសម្ព័ន្ធ ។

ស្ថានភាពចំណាយត្រូវដាក់ជូនសភានៅដំណាច់ឆមាសនីមួយ១ សំរាប់ឆមាសបន្ទាប់ ។

គណនីស្ថាពរនៃប្រតិបត្ដិការ ត្រូវដាក់ក្នុងសម័យប្រជុំពិនិត្យវិការនៃឆ្នាំបន្ទាប់ និងអនុ-ម័តដោយច្បាប់មួយ ។

តុលាការគណនីជួយសភា និងរដ្ឋាភិបាលក្នុងការត្រួតពិនិត្យការអនុវត្ដច្បាប់ហិរញ្ញវត្ថុ ។

២-សំណួរ

-សំណួរជាលាយលក្ខណ៍អក្សរ

-សំណួរផ្ទាល់មាត់

-សំណួរផ្ទាល់មាត់ដោយមានការពិភាក្សា ។

រៀងរាល់ថ្ងៃព្រហស្បតិ៍នៃសប្តាហ៍ មានកម្មវិធីជាអាទិភាពសំរាប់សំណួររបស់សមាជិកសភា និងចម្លើយរបស់រដ្ឋាភិបាល ។

៣-សិទ្ធិទទួលព័ត៌មាន

រដ្ឋាភិបាលត្រូវផ្តល់ជូនសភានូវការពន្យល់ទាំងអស់ ដែលបានស្នើសុំលើការងារគ្រប់គ្រង និងលើសកម្មភាពរបស់រដ្ឋាភិបាល ។

៤-ការប្រកាសអំពីនយោបាយទូទៅ

នាយករដ្ឋមន្ត្រីមានសិទ្ធិស្នើសុំព្រឹទ្ធសភាឲ្យផ្តល់ការយល់ព្រមលើការប្រកាសអំពីនយោ-បាយទូទៅរបស់រដ្ឋាភិបាល ។

៥-គណៈកម្មការអង្កេត

ព្រឹទ្ធសភាអាចបង្កើតគណៈកម្មការអង្កេតចំពោះកិច្ច ដើម្បីដំណើការស៊ើបអង្កេតលើការងារជាក់លាក់នានា ។

៦-វិស័យអន្តរជាតិ

សន្ធិសញ្ញាសន្តិភាព សម្ព័ន្ធភាព កិច្ចព្រមព្រៀងពាណិជ្ជកម្ម សន្ធិសញ្ញាឬកិច្ចព្រមព្រៀងទាក់ទងនឹងអង្គការអន្តរជាតិ កិច្ចព្រមព្រៀងដែលធានាហិរញ្ញវត្ថុរដ្ឋ កិច្ចព្រមព្រៀងទាក់ទងនឹងស្ថានភាពបុគ្គល និងកិច្ចព្រមព្រៀងទាក់ទងនឹងព្រំដែនរដ្ឋត្រូវតែផ្តល់សច្ចាប័នដោយច្បាប់ ។

V-ចរិយាភ្ជាប់ជាយសម្ព័ន្ធ

ក-ការសើរើរដ្ឋធម្មនុញ្ញ

ការនិតផ្តួចផ្តើមសើរើរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ និងរបស់

សមាជិកសភា ។

ដើម្បីអាចដាក់ធ្វើប្រជាមតិ សេចក្តីព្រាងត្រូវតែ:

-ចុះហត្ថលេខាដោយសមាជិកសភាដែលស្នើសុំចំនួនយ៉ាងតិចមួយភាគបី

-អនុម័តតាមសម្លេងភាគច្រើន២/៣នៃសមាជិករដ្ឋសភានិង២/៣នៃសមាជិកព្រឹទ្ធសភា ។

ប្រធានាធិបតីនៃសាធារណរដ្ឋ អាចសម្រេចដាក់សេចក្តីព្រាងនេះជូនសភាប្រជុំជាសមាជ ដែលត្រូវអនុម័តតាមសម្លេងភាគច្រើន៣/៥នៃឆ្នោតដែលបានបោះ ។

ខ-វិស្សមកាលនៃប្រធានាធិបតីសាធារណរដ្ឋ

ក្នុងករណីដែលប្រធានាធិបតីវិស្សមកាល ឬមិនអាចបំពេញការងារបាន ប្រធានព្រឹទ្ធ-សភាទទួលជាប្រធានាធិបតីស្តីទី ។

ប្រធានាធិបតីស្តីទីមិនអាចបញ្ចប់មុខងាររបស់សមាជិករដ្ឋាភិបាល មិនអាចសុំឲ្យធ្វើប្រជាមតិ ឬមិនអាចរំលាយរដ្ឋសភាបានទេ ។

ក្នុងរយៈពេលស្តីទីនេះ មិនអាចកែប្រែរដ្ឋធម្មនុញ្ញបានឡើយ ។

គ-អំណាចពិសេស

កាលបើមានមហន្តរាយគំរាមកំហែងដល់ស្ថាប័នធម្មនុញ្ញនៃសាធារណរដ្ឋ ប្រធានាធិបតីនៃសាធារណរដ្ឋចាត់វិធានការដែលតម្រូវដោយកាលៈទេសៈ ក្រោយពីគ្រោះយោបល់ជាផ្លូវការជាមួយនាយករដ្ឋមន្ត្រី ប្រធានសភាទាំងពីរ និងក្រុមប្រឹក្សាធម្មនុញ្ញ ។

ឃ-ការប្រកាសសង្គ្រាម ស្ថានភាពសង្គ្រាម និងស្ថានភាពអាសន្ន

១-ការប្រកាសសង្គ្រាមត្រូវមានការអនុញ្ញាតពីសភា ។

២-ស្ថានភាពសង្គ្រាម និងស្ថានភាពអាសន្នត្រូវកំណត់ដោយក្រឹត្យរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ សំរាប់រយៈពេលជាអតិបរមា៣០ថ្ងៃ ។ រយៈពេលនេះអាចពន្យារដោយសភា ។ សភាអាចកោះប្រជុំដោយពេញច្បាប់ បើសភាមិនស្ថិតក្នុងសម័យប្រជុំ ។

ង-ប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបីអាចស្នើក្រុមប្រឹក្សាធម្មនុញ្ញឲ្យ:

-ពិនិត្យអត្ថបទច្បាប់ មុនប្រកាសឲ្យប្រើ

-ពិនិត្យលើសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងដែលមានលក្ខណៈជ្ជុយនឹងរដ្ឋធម្មនុញ្ញ ។

ការអនុញ្ញាឱ្យផ្តល់សច្ចាប័ន ឬផ្តល់ការយល់ព្រមលើអត្ថបទទាំងនោះ អាចធ្វើបានតែនៅពេលក្រោយពីការសើរើរដ្ឋធម្មនុញ្ញ ។

ច-តុលាការយុត្តិធម៌ជាន់ខ្ពស់

១-សមាសភាពតុលាការជាន់ខ្ពស់មានសមាជិកជ្រើសរើសមានចំនួនស្មើគ្នាដោយរដ្ឋសភានិងព្រឹទ្ធសភា ក្រោយការផ្លាស់ប្តូរទូទៅឬជាផ្ទែក១ ។

២-ក្នុងករណីល្មើសក្បត់ធ្ងន់ធ្ងរ ប្រធានាធិបតីនៃសាធារណរដ្ឋអាចត្រូវចោទប្រកាន់ដោយសភាទាំងពីរដោយការអនុម័តតែមួយដង ជាសាធារណៈ និងតាមសម្លេងភាគច្រើនដាច់ខាត ។

ប្រធានាធិបតីត្រូវវិនិច្ឆ័យដោយតុលាការយុត្តិធម៌ជាន់ខ្ពស់ ។

៣-នីតិវិធីនេះត្រូវអនុវត្តបានចំពោះនាយករដ្ឋមន្ត្រី និងសមាជិករដ្ឋាភិបាល ក្នុងករណីរូមក្បត់ ប្រឆាំងនឹងភាពសុខសាន្តរបស់រដ្ឋ ។

ឆ-សភាតំបន់ និងអនុតំបន់

ព្រឹទ្ធសភាជ្រើសតាំងតំណាងក្នុងសភាតំបន់ និងអនុតំបន់ និងអ្នកបំរុងនៅសម័យប្រជុំលើកទី១ បន្ទាប់ពីការផ្លាស់ប្តូរជាផ្ទែក ។

ជ-អំណាចតែងតាំង

ប្រធានព្រឹទ្ធសភាតែងតាំង :

-សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ១នាក់លើ៦នាក់

-សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម១នាក់

-សមាជិកអាជ្ញាធរសម្របសម្រួលគមនាគមន៍១នាក់ ។

ឈ-ញត្តិ

ញត្តិត្រូវបញ្ជូនទៅប្រធានព្រឹទ្ធសភា ។ញត្តិអាចស្នើឡើងដោយសមាជិកព្រឹទ្ធសភាម្នាក់ ។

នៅថ្ងៃទី២ វិច្ឆិកា ២០០៤ ក្រៅពីការបោះឆ្នោតប្រធានាធិបតី និងនីតិប្បញ្ញត្តិដែលរៀបចំឡើងតាមការផ្តើមគំនិតរបស់ប្រធានាធិបតី មានការពិគ្រោះយោបល់ជាមួយប្រជាជនលើវិសោធនកម្មរដ្ឋធម្មនុញ្ញចំនួន៥ជាបន្តបន្ទាប់:(១) ការទទួលស្គាល់សញ្ជាតិ២ (២) ការបោះឆ្នោតប្រធានាធិបតី និងអនុប្រធានាធិបតីនៃសាធារណរដ្ឋក្នុងក្របខ័ណ្ឌជាក្រុម(៣) ការកំណត់អាណត្តិនីតិប្បញ្ញត្តិត្រឹម៣អាណត្តិដែលមានរយៈពេល៤ឆ្នាំ(៤) ការផ្លាស់ប្តូរពីសភា២ថ្នាក់ទៅជា១ថ្នាក់ (៥) ការកែសំរួលប្រាក់បំណាច់របស់សមាជិកសភា ។

មានតែសំណើទី៤(ការផ្លាស់ប្តូរពីសភា២ថ្នាក់ទៅជា១ថ្នាក់)ទេដែលមិនត្រូវបានតាំទ្រ ។

I-សមាសភាព

ព្រឹទ្ធសភាមានសមាជិកជ្រើសតាំង១៤នាក់ ។ ចំនួនសមាជិកព្រឹទ្ធសភាត្រូវកំណត់ដោយគណៈកម្មការឯករាជមួយ ទៅតាមចំនួនប្រជាជន ។

II-បេបឆោះឆ្នោត

ប្រព័ន្ធបោះឆ្នោតៈដោយផ្ទាល់ តាមសម្លេងភាគច្រើនក្នុងពាមណ្ឌលពហុនាមឬឯកត្តនាម (៤សំរាប់តំបន់ខាងជើង ៥សំរាប់រដ្ឋធានីkoror និង១សំរាប់កោះខាងត្បូង) ។

អាណត្តិ:៤ឆ្នាំ

ការផ្លាស់ប្តូរចុងក្រោយ: ២ វិច្ឆិកា ២០០៤ (៥វិច្ឆិកា ១៩៩៦មានការបោះឆ្នោតរបៀបដូចគ្នា តាំងពីប្រទេសបានឯករាជ្យ នាខែតុលា១៩៩៤) ។

លក្ខខណ្ឌ : អាយុ២៥ឆ្នាំ ពលរដ្ឋPalaos រស់នៅក្នុងប្រទេសយ៉ាងតិច៥ឆ្នាំ និងក្នុងមណ្ឌល១ឆ្នាំ មុនពេលបោះឆ្នោត ។

III-សម័យប្រជុំ

ក-សម័យប្រជុំសាមញ្ញ

សម័យប្រជុំសាមញ្ញបើកនៅថ្ងៃអង្គារទី២ខែមករាបន្ទាប់ពីការបោះឆ្នោតទូទៅ ។

ខ-សម័យប្រជុំវិសាមញ្ញ

សភានីមួយៗអាចកោះប្រជុំបានគ្រប់ពេលដោយប្រធានរបស់ខ្លួន ឬតាមសំណើជាលាយលក្ខណ៍អក្សររបស់សមាជិកភាគច្រើនរបស់ខ្លួន ឬដោយប្រធានាធិបតី ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

សភាជាតិមានព្រឹទ្ធសភា និងរដ្ឋសភា ។ ព្រឹទ្ធសភា និងរដ្ឋសភាមានអំណាចស្មើគ្នា លើកលែងតែមុខងារបន្ថែម ដែលប្រគល់ឱ្យព្រឹទ្ធសភា ។

ព្រឹទ្ធសភាមាន១១គណៈកម្មការអចិន្ត្រៃយ៍ ដើម្បីសិក្សាលើសេចក្តីព្រាងច្បាប់ សេចក្តីសម្រេចចិត្ត និងការងារផ្សេងៗទៀត ។

គណៈកម្មការពិសេសអាចត្រូវបង្កើត កាលបើចាំបាច់ ។

ក-អំណាចនីតិប្បញ្ញត្តិ

១-នីតិវិធីធម្មតា

ច្បាប់ទាំងឡាយត្រូវអនុម័ត តាមសម្លេងភាគច្រើននៃសមាជិកសភានីមួយៗ ក្នុងការអាន ៣ នៅថ្ងៃខុសគ្នា ។

អត្ថបទត្រូវដាក់ជូនប្រធានាធិបតីដើម្បីចុះហត្ថលេខា ។

២-សិទ្ធិជំទាស់របស់ប្រធានាធិបតី

បើប្រធានាធិបតីជំទាស់នឹងសេចក្តីព្រាងច្បាប់ណាមួយ សេចក្តីព្រាងនោះត្រូវបញ្ជូនទៅសភានីមួយៗវិញ ក្នុងរយៈពេល ១៥ថ្ងៃ ដោយភ្ជាប់ទៅជាមួយនូវមូលហេតុនៃការជំទាស់ ។

ប្រធានាធិបតីអាចបន្ថយការជំទាស់មកនៅមួយភាគនៃអត្ថបទ និងបញ្ជូនទៅសភាវិញ តាមនីតិវិធីដូចគ្នា ។ ប្រធានាធិបតីក៏អាចបញ្ជូនទៅវិញ ដោយមានសំណើកែប្រែបានដែរ ។

បើក្នុងរយៈពេល១៥ថ្ងៃ ចាប់ពីពេលបញ្ជូនទៅប្រធានាធិបតី បើមិនមានចុះហត្ថលេខា មិនមានជំទាស់ ឬមិនបញ្ជូនត្រឡប់មកសភាវិញ សេចក្តីព្រាងនោះត្រូវទៅជាច្បាប់ ។

ដូចគ្នានេះដែរ ក្នុងករណីជំទាស់ទាំងស្រុង ឬ១ភាគ បើសេចក្តីព្រាងនោះត្រូវអនុម័ត តាមសម្លេងភាគច្រើន២/៣យ៉ាងតិចនៃសមាជិកសភានីមួយៗ ក្នុងរយៈពេល៣០ថ្ងៃចាប់ពីថ្ងៃបញ្ជូនមក ។

សភាជាតិ (le Parlement) អាចអនុម័តសេចក្តីព្រាង ដែលប្រធានាធិបតីបញ្ជូនត្រឡប់វិញ តាមសម្លេងភាគច្រើននៃសមាជិកវត្តមាន ស្របតាមស់ណើកែប្រែដែលប្រធានាធិបតីបានលើកឡើង និងបញ្ជូនទៅប្រធានាធិបតីវិញដើម្បីពិនិត្យ ។ ប្រធានាធិបតីមិនអាចបញ្ជូនទៅវិញឱ្យធ្វើវិសោធនកម្មម្តងទៀតបានទេ ។

៣-នីតិវិធីខាងថ្វិកា

សេចក្តីព្រាងថ្វិកាត្រូវដាក់ជូនដោយប្រធានាធិបតី ។

សភាអាចកែប្រែសេចក្តីព្រាងនេះបាន ។

៤-គំនិតផ្តួចផ្តើមរបស់ប្រជាជន

ច្បាប់មួយអាចត្រូវអនុម័ត ឬទុកជាមោឃៈតាមការផ្តើមគំនិតរបស់ប្រជាជន ដែលចុះហត្ថលេខាដោយអ្នកមានឈ្មោះបោះឆ្នោតចំនួន១០ភាគរយយ៉ាងតិច ។

ច្បាប់នេះអាចមានអានុភាពបានដោយការបោះឆ្នោត តាមសម្លេងភាគច្រើននៃអ្នកបោះពេលបោះឆ្នោតទូទៅខាងមុខ ។

ក្នុងក្របខ័ណ្ឌនេះ ប្រធានាធិបតីមិនអាចប្រើសិទ្ធិជំទាស់បានទេ ។

ច្បាប់ដែលអនុម័តឬទុកជាមោឃៈដោយគំនិតផ្តើមរបស់ប្រជាជនអាចកែប្រែ លប់ចោលឬធ្វើឡើងវិញតែតាមការផ្តើមគំនិតមួយទៀតរបស់ប្រជាជន ។

៩-អំណាចត្រួតពិនិត្យ

១-វិស័យហិរញ្ញវត្ថុសាធារណៈ

អ្នកត្រួតពិនិត្យរដ្ឋធ្វើរបាយការណ៍ជូនសភា១ដង យ៉ាងតិចក្នុង១ឆ្នាំ អំពីការត្រួតពិនិត្យគណនីរបស់ក្រសួងនានានិងរចនាសម្ព័ន្ធដែលទទួលមូលនិធិសាធារណៈ ។

២-សមាសភាពរបស់រដ្ឋាភិបាល

សមាជិកខុទ្ធកាល័យត្រូវតែងតាំងដោយប្រធានាធិបតី ដោយមានការយល់ព្រមពីព្រឹទ្ធ-

សភា ។

៣-វិស័យអន្តរជាតិ

ប្រធានាធិបតីចរចា និងផ្តល់សច្ចាប័នលើសន្ធិសញ្ញា ដោយមានការយល់ព្រមពីសភា ។

៤-ប្រធានាធិបតីរាយការណ៍ប្រចាំឆ្នាំជូនសភាអំពីការវិវត្តខាងរដ្ឋបាល ។

V-មនឃ្យញ្ញត្តិដោយឡែក

ក-ការបាត់បង់អាណត្តិសភា

សមាជិកព្រឹទ្ធសភាអាចបាត់បង់អាសនៈតាមនីតិវិធីរំលឹក ផ្តើមដោយញ្ញត្តិដែលចុះហត្ថ លេខាដោយអ្នកបោះឆ្នោតយ៉ាងតិច២៥ភាគរយ ពេលបោះឆ្នោតចុងក្រោយ ។

ការរំលឹកអាចអនុម័តបានតែ១ដង ក្នុងអាណត្តិ ។ នីតិវិធីនេះមិនអាចយកមកប្រើនៅឆ្នាំ ទី១ នៃអាណត្តិទី១ទេ ។

ខ-អង្គការដឹកនាំព្រឹទ្ធសភា

ព្រឹទ្ធសភាដឹកនាំដោយប្រធាន អនុប្រធាន និង floor leader ។

គណៈកម្មការប្រតិបត្តិមួយមានប្រធានគណៈកម្មការអចិន្ត្រៃយ៍ទាំងអស់ ។

គ-អំណាចក្នុងការតែងតាំង

ព្រឹទ្ធសភាមានអំណាចផ្តល់ការយល់ព្រមចំពោះការតែងតាំងរបស់ប្រធានាធិបតី តាម សម្លេងភាគច្រើន២/៣ ។

១-រួមជាមួយរដ្ឋសភា(អ្នកត្រួតពិនិត្យហិរញ្ញវត្ថុរដ្ឋ...)

២-តែឯកឯង(រដ្ឋទូត និងមុខងាររដ្ឋបាល) ។

ឃ-ការចោទប្រកាន់

១-ប្រធានាធិបតី និងអនុប្រធានាធិបតី

ប្រធានាធិបតី និងអនុប្រធានាធិបតីអាចត្រូវចោទពីបទក្បត់ ពុករលួយ ឧក្រិដ្ឋធ្ងន់ធ្ងរ ខ្វះខ្នាក្នុងមុខងារ ដោយការបោះឆ្នោត តាមសម្លេងភាគច្រើនពីរភាគបីនៃសមាជិកសភានីមួយៗ ។

២-ចៅក្រម

ចៅក្រមនៃតុលាការកំពូល អាចត្រូវចោទពីបទក្បត់ ពុករលួយ ឧក្រិដ្ឋធ្ងន់ធ្ងរឬភាពមិនប្រក្រតី ឬអសមត្ថភាព ខ្វះខ្នាក្នុងមុខងារ ដោយការបោះឆ្នោតតាមសម្លេងភាគច្រើន ២/ ៣នៃសមាជិកសភានីមួយៗ ។

ចៅក្រមនៃតុលាការជាតិ និងតុលាការថ្នាក់ក្រោម អាចត្រូវចោទ ដោយការអនុម័តតាមសម្លេងភាគច្រើននៃសមាជិកសភានីមួយៗ ។

ង-ការបាត់បង់អាណត្តិប្រធានាធិបតី

ប្រធានាធិបតី និងអនុប្រធានាធិបតីអាចត្រូវដកពីតំណែង ។ ការផ្តើមគំនិតត្រូវមានការ

សម្រេចចិត្ត អនុម័តតាមសម្លេងភាគច្រើន២/៣នៃសមាជិកសភាមូលដ្ឋាន ក្នុងមួយភាគបួនយ៉ាងតិចនៃតំបន់នានា ។

សភាបង្កើតគណៈកម្មការបោះឆ្នោតទទួលបន្ទុកត្រួតមើលលើទឹកដីទាំងមូលនូវការពិគ្រោះជាមួយប្រជាជន ដែលរៀបចំឡើងក្នុងរយៈពេល៣០ថ្ងៃយ៉ាងតិច និង៦០ថ្ងៃយ៉ាងច្រើន ក្រោយបានទទួលសេចក្តីសម្រេចចិត្ត ។

ច-វិស្សមកាលរបស់ប្រធានាធិបតី

ប្រធានព្រឹទ្ធសភារ៉ាប់រងមុខងារប្រធានាធិបតី ក្នុងករណីប្រធានាធិបតី និងអនុប្រធានា-ធិបតីទទួលអនិច្ចកម្ម ។

ឆ-ការសើរើរដ្ឋធម្មនុញ្ញ

១-ការផ្តួចផ្តើមគំនិត

ការផ្តួចផ្តើមគំនិតសើរើរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់ប្រជាជន ឬរបស់សភា ។ គណៈកម្មការសើរើទទួលយកមកពិនិត្យ ។

២-នីតិវិធី

ក-សភាអាចដាក់ឱ្យអង្គបោះឆ្នោតពិនិត្យ អំពីការបង្កើតគណៈកម្មការសើរើរដ្ឋធម្មនុញ្ញ យ៉ាងតិច១ដងក្នុង១ឆ្នាំ ។ បើចម្លើយផ្តល់មកជាវិជ្ជមាន តាមសម្លេងភាគច្រើននៃអ្នកបោះ គណៈកម្មការត្រូវរួមប្រជុំក្នុងរយៈពេល៦ខែ ។

ខ-តំនិតផ្តើមរបស់ប្រជាជនត្រូវមានហត្ថលេខាយ៉ាងតិច២៥ភាគរយ នៃអ្នកដែលបានចុះឈ្មោះបោះឆ្នោត ។

គ-តំនិតផ្តួចផ្តើមរបស់សភាត្រូវអនុម័តតាមសម្លេងភាគច្រើន៣/៤នៃសមាជិកសភានីមួយ១ ។

ឃ-ក្នុងករណីទាំងអស់ សេចក្តីស្នើវិសោធនកម្មចូលជាធរមាន ពេលបានការអនុម័តតាមសម្លេងភាគច្រើន និងក្នុងយ៉ាងតិចបីភាគបួននៃតំបន់នានានៅពេលបោះឆ្នោតទូទៅខាងមុខ ។

ជ-អំណាចរៀបចំមូលដ្ឋាន

មួយចំណែកនៃដែនដីPalaos អាចដាក់ជាតំបន់ ដោយមានការយល់ព្រមពីសភា និងពីភាគច្រើនបីភាគបួននៃរដ្ឋនានា ។

ឈ-ស្ថានភាពបន្ទាន់

ការប្រកាសស្ថានភាពបន្ទាន់ដោយប្រធានាធិបតី ត្រូវសុំការយល់ព្រមពីសភា ។ ប្រធានាធិបតីមិនអាចប្រើអំណាចពិសេសសំរាប់រយៈពេលលើសពី១០ថ្ងៃ ដោយគ្មានការអនុញ្ញាតពីសភាបានឡើយ ។

ប៉ារ៉ាហ្គាយ
PARAGUAY

ព្រឹទ្ធសភា
LE SENAT

I-សមាសភាព

ព្រឹទ្ធសភាមានសមាជិក៥៤នាក់ ជ្រើសតាំងដោយការបោះឆ្នោតដោយផ្ទាល់ ។

អតីតប្រធានាធិបតីនៃសាធារណរដ្ឋជាសមាជិកព្រឹទ្ធសភាមួយជីវិត (sénateurs à vie) ប៉ុន្តែមិនមានសិទ្ធិអនុម័តទេ ។

II-របៀបបោះឆ្នោត

ប្រព័ន្ធ:សមាមាត្រ តាមបញ្ជីជាកញ្ចប់(à listes bloquées) ក្នុងមណ្ឌលថ្នាក់ជាតិតែមួយ ពហុនាម ដោយការបែងចែកសំណល់តាមមធ្យមភាគខ្ពស់បំផុត(à la plus forte moyenne) ។

អាណត្តិ :៥ឆ្នាំ

ការផ្លាស់ប្តូរចុងក្រោយ : ២៧ មេសា ២០០៣

អាយុ : ៣៥ឆ្នាំ ។

III-សម័យប្រជុំ

ក-សម័យប្រជុំសាមញ្ញ

ព្រឹទ្ធសភាមាន១សម័យប្រជុំសាមញ្ញប្រចាំឆ្នាំ ពីថ្ងៃទី១ ខែកក្កដាដល់ថ្ងៃទី៣០ ខែមិថុនា ដោយមានអាក់ខានពីថ្ងៃទី ៣១ ខែធ្នូ ដល់ថ្ងៃទី១ខែមីនា ។

ខ-សម័យប្រជុំវិសាមញ្ញ

សភាទាំងពីរអាចប្រជុំជាវិសាមញ្ញ ឬពន្យារសម័យប្រជុំសាមញ្ញ ដោយសេចក្តីសម្រេចដែលអនុម័តតាមសម្លេង១/៤នៃសមាជិកសភានីមួយ១ តាមសម្លេង២/៣នៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃសមាជ ឬដោយក្រឹត្យរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ។

ប្រធានសមាជ (គឺប្រធានព្រឹទ្ធសភា) ឬប្រធានគណៈកម្មការអចិន្ត្រៃយ៍ត្រូវកោះប្រជុំសភាក្នុងរយៈពេល៤៨ម៉ោង ក្នុងចន្លោះសម័យប្រជុំ ។

សម័យប្រជុំវិសាមញ្ញដែលអាចតែសភាតែមួយ ពោះប្រជុំតាមរបៀបវារៈមួយយ៉ាងជាក់លាក់ ហើយបិទនៅពេលចប់របៀបវារៈ ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

ជាប្រព័ន្ធសភាពីរដែលស្មើភាពគ្នា ។

១-សិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់

សមាជិកព្រឹទ្ធសភា(សមាជិករដ្ឋសភា ប្រធានាធិបតីនៃសាធារណរដ្ឋ ប្រជាជន និងក្នុងករណីខ្លះ តុលាការយុត្តិធម៌កំពូល) មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។

២-សិទ្ធិវិសោធនកម្ម

សមាជិកព្រឹទ្ធសភាមានសិទ្ធិវិសោធនកម្ម ។

៣-នីតិវិធី

ការពិនិត្យជាមុនទូវិសេចក្តីព្រាងច្បាប់នៅតាមគណៈកម្មការ ដែលមានសមាសភាពសមាមាត្រនឹងក្រុមនៅក្នុងព្រឹទ្ធសភា ។

ក-នីតិវិធីធម្មតា

សេចក្តីព្រាងច្បាប់នានាត្រូវពិនិត្យជាបន្តបន្ទាប់ ដោយសភាទាំងពីរ ។

បើអត្ថបទមួយត្រូវសភាមួយអនុម័ត ហើយត្រូវសភាមួយទៀតបដិសេធ អត្ថបទនោះត្រូវបញ្ជូនត្រឡប់ទៅសភាដើម្បីពិនិត្យជាថ្មី ។បើសភាដើមរក្សាអត្ថបទរបស់ខ្លួនតាមសម្លេងភាគច្រើនដាច់ខាត អត្ថបទត្រូវបញ្ជូនទៅសភាមួយទៀត ដែលអាចត្រាន់តែបដិសេធតាមសម្លេងភាគច្រើន២៣ ។ ករណីផ្ទុយពីនេះ អត្ថបទត្រូវចាត់ទុកថាបានអនុម័ត ។

បើអត្ថបទមួយត្រូវសភាមួយអនុម័ត ហើយត្រូវសភាមួយទៀតកែប្រែមួយផ្នែក អត្ថបទនោះត្រូវបញ្ជូនត្រឡប់ទៅសភាដើម្បីពិនិត្យតែលើបញ្ញត្តិដែលកែប្រែនោះ :

១-បើសភាដើមអនុម័តការកែប្រែនោះ អត្ថបទត្រូវបានអនុម័ត ។

២-បើសភាដើមបដិសេធការកែប្រែនោះ តាមសម្លេងភាគច្រើនដាច់ខាត សេចក្តីព្រាងត្រូវបញ្ជូនទៅសភាមួយទៀត។ បើសភានេះនៅរក្សាការកែប្រែរបស់ខ្លួន តាមសម្លេងភាគច្រើនដាច់ខាត សេចក្តីព្រាងច្បាប់ត្រូវបានអនុម័ត។ ក្នុងករណីផ្ទុយ អត្ថបទដែលពិនិត្យដោយសភាទី១ ត្រូវបានអនុម័ត។

៣-បើការកែប្រែខ្លះត្រូវទទួលយក សេចក្តីព្រាងច្បាប់ត្រូវបញ្ជូនត្រឡប់ទៅសភាទី២ ដើម្បីពិនិត្យតែលើការកែប្រែដែលត្រូវបដិសេធ :បើសភាទី២នៅរក្សា ឬដកការកែប្រែចេញតាមសម្លេងភាគច្រើនដាច់ខាត សេចក្តីព្រាងច្បាប់ត្រូវអនុម័ត។

ប្រធានាធិបតីនៃសាធារណរដ្ឋអាចដក ឬបដិសេធសេចក្តីព្រាងច្បាប់ដែលខ្លួនបានដាក់ជូនសមាជ លើកលែងតែអត្ថបទនោះត្រូវបានអនុម័តដោយសភាដែលអត្ថបទនោះបានដាក់ឱ្យពិនិត្យ។

ខ-នីតិវិធីប្រញាប់

ប្រធានាធិបតីនៃសាធារណរដ្ឋ អាចស្នើសុំឱ្យសមាជពិនិត្យសេចក្តីព្រាងច្បាប់ណាមួយជាការប្រញាប់។

ក្នុងករណីនេះ សភានីមួយៗមានពេល៣០ថ្ងៃដើម្បីពិនិត្យអត្ថបទ ។ អត្ថបទនោះចាត់ទុកថាបានអនុម័ត បើមិនត្រូវបានបដិសេធក្នុងរយៈពេលនេះទេ។

នីតិវិធីប្រញាប់អាចត្រូវស្នើសុំពេលណាក៏បានក្នុងដំណើរការធ្វើច្បាប់។

សភានីមួយៗអាចបដិសេធសំណើសុំជាការប្រញាប់ តាមសម្លេងភាគច្រើន២/៣នៅពេលណាក៏បាន ហើយបន្តដំណើរការតាមនីតិវិធីធម្មតា។

ប្រធានាធិបតីនៃសាធារណរដ្ឋ អាចស្នើសុំប្រកាសជាការប្រញាប់ទៅសមាជតែសេចក្តីព្រាងច្បាប់ចំនួនពីរក្នុងសម័យប្រជុំ លើកលែងតែសភាដែលទទួលពិនិត្យដំបូងទទួលយកការប្រញាប់ជាបន្ថែមនេះ តាមសម្លេងភាគច្រើន២/៣ ។

គ-ការអនុម័តជាស្វ័យប្រវត្តិ

ក្នុងសម័យប្រជុំ បើអត្ថបទត្រូវសភាណាមួយអនុម័តរួច អត្ថបទនោះត្រូវបញ្ជូនទៅសភា

មួយទៀត ដែលត្រូវពិនិត្យក្នុងរយៈពេល៣ខែ ។ បើហួសរយៈពេលនេះ និងក្រោយពេលដែលប្រធានសភាដើមដែលពិនិត្យលើកដំបូងបានបញ្ជាក់អំពីការហួសពេលនេះ ទៅសមាជិកនៃសភាមួយទៀត អត្ថបទនោះត្រូវចាត់ទុកថានោះបានអនុម័តដោយសភាមួយទៀត ។

ការប្រើប្រាស់ពេលវេលានេះ ត្រូវព្យួរនៅចន្លោះពេលពី ថ្ងៃ២ខែធ្នូ ដល់ថ្ងៃ១ខែមីនា ។

ឃ-សិទ្ធិជំទាស់របស់ប្រធានាធិបតី

១-ការជំទាស់ជាផ្នែក

សេចក្តីព្រាងច្បាប់ ដែលជាកម្មវត្ថុនៃការជំទាស់ជាផ្នែករបស់ប្រធានាធិបតីនៃសាធារ-ណរដ្ឋត្រូវបញ្ជូនទៅសភាដែលបានពិនិត្យជាលើកដំបូង ដើម្បីពិនិត្យលើការជំទាស់ក្នុងរយៈពេល ៦០ថ្ងៃ ។បើសភាមិនទទួលយកការជំទាស់ តាមសម្លេងភាគច្រើនដាច់ខាត សេចក្តីព្រាងត្រូវបញ្ជូនទៅសភាមួយទៀតដើម្បីពិនិត្យជូចគ្នា និងក្នុងរយៈពេលជូចគ្នា ។

បើសភានេះអនុម័តសេចក្តីសម្រេចជូចគ្នា អត្ថបទនោះត្រូវបានទទួលការអនុម័ត ហើយប្រធានាធិបតីត្រូវប្រកាសឱ្យប្រើក្នុងរយៈពេល៥ថ្ងៃ ។

បើសភាទាំងពីរមិនអាចបដិសេធការជំទាស់នេះបាន សេចក្តីព្រាងច្បាប់មិនអាចយកមកពិនិត្យឡើងវិញក្នុងសម័យប្រជុំនេះបានទេ ។

ការជំទាស់ដែលប្រធានាធិបតីបានលើកឡើងអាចត្រូវសភាទាំងពីរទទួលយកឬបដិសេធចោលទាំងស្រុងឬជាផ្នែក ។

សភាទាំងពីរអាចសម្រេច តាមសម្លេងភាគច្រើនដាច់ខាតទទួលយកផ្នែកនៃសេចក្តីព្រាងដែលមិនមានខ្វែងគ្នា ហើយបន្តយកទៅប្រកាសឱ្យប្រើ ។

២-ការជំទាស់ទាំងស្រុង

បើប្រធានាធិបតីបដិសេធអត្ថបទច្បាប់ទាំងស្រុង អត្ថបទនេះត្រូវបញ្ជូនត្រឡប់ទៅសភាដែលពិនិត្យលើកដំបូងដែលត្រូវពិនិត្យអត្ថបទឡើងវិញ ។

បើសភានេះនៅរក្សាអត្ថបទរបស់ខ្លួនតាមសម្លេងភាគច្រើនដាច់ខាត អត្ថបទត្រូវបញ្ជូនទៅសភាមួយទៀត ។ បើសភាមួយទៀតនេះមានជំហរជូចគ្នា អត្ថបទត្រូវប្រកាសឱ្យប្រើក្នុងរយៈ

ពេល៥ថ្ងៃធ្វើការ ។

បើសមាជមិនអាចបដិសេធការជំទាស់នេះបាន សេចក្ដីព្រាងច្បាប់មិនអាចយកមកពិនិត្យម្តងវិញក្នុងសម័យប្រជុំនេះបានទេ ។

ង-ការប្រកាសឱ្យប្រើ

សេចក្ដីព្រាងច្បាប់ទាំងអស់ដែលមិនមែនជាកម្មវត្ថុនៃការជំទាស់ ឬដែលមិនបញ្ជូនត្រឡប់ដោយប្រធានាធិបតីនៃសាធារណរដ្ឋទៅសភាទទួលលើកដំបូងក្នុងរយៈពេល ៦ថ្ងៃធ្វើការ បើមានក្រោម១០មាត្រា ក្នុងរយៈពេល១២ថ្ងៃ បើមានពី១១ទៅ ២០មាត្រាឬក្នុងរយៈពេល ២០ថ្ងៃ បើមានលើសពី២០មាត្រា ត្រូវចាត់ទុកថាត្រូវបានអនុម័ត ។

ក្នុងគ្រប់ករណី ច្បាប់ត្រូវចាត់ទុកថាបានប្រកាសឱ្យប្រើជាស្វ័យប្រវត្តិនិងបញ្ជាឱ្យចុះផ្សាយ ។

បើប្រធានាធិបតីនៃសាធារណរដ្ឋមិនគោរពតាមនីតិវិធីនៃការប្រកាសឱ្យប្រើ ប្រធានឬប្រធានរដ្ឋសភាប្រកាសឱ្យប្រើច្បាប់ និងបញ្ជាឱ្យចុះផ្សាយ ។

ច-ការពិនិត្យតាមគណៈកម្មការ

ព្រឹទ្ធសភា (រដ្ឋសភា) តាមសម្លេងភាគច្រើនដាច់ខាត អាចផ្ទេរសិទ្ធិឱ្យគណៈកម្មការនានាពិនិត្យសេចក្ដីព្រាងច្បាប់ សេចក្ដីសម្រេចចិត្ត ឬសេចក្ដីប្រកាសនានា ។

ព្រឹទ្ធសភាអាចដកសិទ្ធិនេះវិញពេលណាក៏បាន មុនពេលដែលគណៈកម្មការសម្រេចតាមសម្លេងភាគច្រើន ។

មិនអាចផ្ទេរសិទ្ធិឱ្យគណៈកម្មការ ការពិភាក្សាលើថវិកា ក្រមនានា សន្ធិសញ្ញា អន្តរជាតិ បទប្បញ្ញត្តិពន្ធដារ ការការពារអត្ថបទទាក់ទងនឹងការរៀបចំរដ្ឋាភិបាលឬសេចក្ដីព្រាងច្បាប់ដែលផ្តើមចេញពីប្រជាជន ។

ឆ-នីតិវិធីខាងថវិកា

រៀងរាល់ឆ្នាំ ប្រធានាធិបតីនៃសាធារណរដ្ឋត្រូវដាក់គំរោងថវិកាជូនសមាជ យ៉ាងយូរបំផុតនៅថ្ងៃទី១កញ្ញា ។ គំរោងនេះត្រូវអនុម័តជាការប្រញាប់ ។

គណៈកម្មការរួមនៃសភាទាំងពីរត្រូវបង្កើតឡើង ទទួលបន្ទុកពិនិត្យថ្វិកា និងធ្វើរបាយការណ៍ជូនសភានីមួយ ក្នុងរយៈពេលយ៉ាងយូរ៦០ថ្ងៃ ។

ជាបន្ទាប់ រដ្ឋសភាពិនិត្យសេចក្តីព្រាងក្នុងពេលប្រជុំជាសាធារណៈ ហើយសេចក្តីសម្រេចត្រូវធ្វើក្នុងរយៈពេល១៥ថ្ងៃយ៉ាងយូរ ។

ព្រឹទ្ធសភាមានរយៈពេលដូចគ្នាសំរាប់ពិនិត្យថ្វិកា ដែលត្រូវកែប្រែជាយថាហេតុដោយរដ្ឋសភា ។ បើព្រឹទ្ធសភាយល់ព្រម ថ្វិកាត្រូវបានអនុម័ត ។ បើព្រឹទ្ធសភាមិនយល់ព្រម អត្ថបទដែលមានការកែប្រែរបស់ព្រឹទ្ធសភា ត្រូវបញ្ជូនត្រឡប់ទៅរដ្ឋសភាវិញដែលត្រូវពិនិត្យចំណុចមិនព្រមព្រៀង ក្នុងរយៈពេល១០ថ្ងៃ ។

ព្រឹទ្ធសភាដែលពិនិត្យសាជាថ្មីនូវចំណុចទាំងនោះ ត្រូវអនុម័តក្នុងរយៈពេល១០ថ្ងៃ ។ បើតាមសម្លេងភាគច្រើនដាច់ខាត ព្រឹទ្ធសភារក្សាប្ចុងកការកែប្រែចេញវិញ សេចក្តីព្រាងច្បាប់នោះត្រូវបានអនុម័ត ។

រយៈពេលទាំងអស់ខាងលើមានលក្ខណៈចាំបាច់ ហើយការមិនគោរពតាមពេលវេលាទាំងនេះ ត្រូវចាត់ទុកថាជាការយល់ព្រម ។ ថ្វិកាអាចត្រូវបដិសេធចោលទាំងស្រុងតែតាមសម្លេងភាគច្រើន៧ពានៃសមាជិកសភានីមួយៗ ។

ក្នុងករណីបដិសេធ ឬមិនគោរពតាមពេលដែលត្រូវដាក់ស្នើ ថ្វិកាឆ្នាំមុនត្រូវបន្តអនុវត្ត ។

៨-អំណាចត្រួតពិនិត្យ(ស្នើត្តារវាងសភាទាំងពីរ)

១-ការស្នើសុំព័តិមាន

ព្រឹទ្ធសភាអាចស្នើឱ្យរដ្ឋាភិបាល ក៏ដូចជារដ្ឋបាល ឬការិយាល័យផ្តល់របាយការណ៍លើការងារដែលជាផ្ទលប្រយោជន៍សាធារណៈ លើកលែងតែសកម្មភាពរបស់តុលាការ ។

របាយការណ៍ត្រូវផ្តល់ជូនក្នុងរយៈពេលកំណត់ ដែលមិនអាចតិចជាង១៥ថ្ងៃ ។

២-ការកោះអញ្ជើញសួរដេញដោល

ក-នីតិវិធី

តាមសម្លេងភាគច្រើនដាច់ខាត ព្រឹទ្ធសភាអាចកោះអញ្ជើញជាបុគ្គលនិងសួរដេញដោល

រដ្ឋមន្ត្រី និងនាយករដ្ឋបាលថ្នាក់កណ្តាល វិមជ្ឈការ សុយ័ត ក៏ដូចជាអង្គការទទួលបន្ទុកចាត់ចែងមូលនិធិសាធារណៈ ឬមូលនិធិដែលរដ្ឋមានចំណែកធំជាង ។

សំណួរត្រូវផ្ញើជូន៥ថ្ងៃយ៉ាងតិចមុនថ្ងៃកំណត់ការអញ្ជើញ ។ លើកលែងតែមានមូលហេតុស្របច្បាប់ ជនដែលត្រូវអញ្ជើញត្រូវមកតាមការអញ្ជើញ ឆ្លើយនឹងសំណួរ និងផ្តល់នូវគ្រប់ព័ត៌មានដែលស្នើសុំ ។

ច្បាប់បានកំណត់អំពីការចូលរួមរបស់ក្រុមភាគច្រើន និងក្រុមជំទាស់ក្នុងការពាក់តែងសំណួរ ។ បញ្ញត្តិទាំងនេះមិនអនុវត្តចំពោះប្រធានាធិបតីនៃសាធារណរដ្ឋ អនុប្រធានាធិបតីនិងចៅក្រមទេ ។

ខ-ពិន័យ

បើជនដែលត្រូវបានការអញ្ជើញ មិនឆ្លើយតបនឹងការអញ្ជើញ ឬបើសភាយល់ថាការចូលខ្លួនមកនេះមិនគ្រប់គ្រាន់ទេ សភាទាំងពីរអាចអនុម័តញត្តិបន្ទោសប្រឆាំងនឹងជននោះ និងស្នើឱ្យប្រធានាធិបតី ឬអ្នកគ្រប់គ្រងតាមឋានានុក្រមជាជននោះពីតំណែងតាមសម្លេងភាគច្រើន២/៣ ។

បើញត្តិនោះមិនត្រូវបានអនុម័តទេ ពុំមានញត្តិណាមួយទៀតអាចត្រូវបានដាក់ស្នើក្នុងសម័យប្រជុំដដែលលើប្រធានបទដដែល និងចំពោះរដ្ឋមន្ត្រី ឬឥស្សរជនដដែលឡើយ ។

៣-គណៈកម្មការស៊ើបអង្កេត

សភាទាំងពីរនៃសមាជអាចបង្កើតគណៈកម្មការចំរុះស៊ើបអង្កេតរាល់បញ្ហាដែលមានផលប្រយោជន៍សាធារណៈ ។

លើកលែងតែរដ្ឋមន្ត្រី ជនទាំងឡាយ ក៏ដូចជាបុគ្គលឯកជនត្រូវចូលខ្លួនមកសភាទាំងពីរដើម្បីបង្ហាញនូវព័ត៌មាន និងឯកសារដែលត្រូវស្នើសុំ ។ បើធ្វើផ្ទុយពីនេះ ត្រូវទទួលពិន័យដែលមានចែងក្នុងច្បាប់ ។

ប្រធានាធិបតីនៃសាធារណរដ្ឋ អនុប្រធានាធិបតី សមាជិកនុទ្ទកាល័យ និងចៅក្រមមិនអាចត្រូវសួរលើមុខការឡើយ ។

សកម្មភាពរបស់គណៈកម្មការស៊ើបអង្កេត មិនអាចរំខានដល់ការងារតុលាការ ឬសិទ្ធិ ឬការធានានៃរដ្ឋធម្មនុញ្ញ ។

ការសន្និដ្ឋានមិនជាប់ជំពាក់ជាមួយតុលាការ និងមិនប៉ះពាល់ដល់ការសម្រេចរបស់តុលាការឡើយ ។ប៉ុន្តែលទ្ធផលនៃការស៊ើបអង្កេតរបស់ខ្លួនអាចបញ្ជូនទៅតុលាការ ។ក្នុងទិដ្ឋភាពច្បាប់ចៅក្រមអាចធ្វើសកម្មភាព និងស៊ើបអង្កេតដោយផ្ទែកលើលទ្ធផលរបស់គណៈកម្មការ ។

៧-មធម្យញ្ញត្តិដោយឡែក

ក-អំណាចធម្មនុញ្ញ

១-ការកែទំរង់រដ្ឋធម្មនុញ្ញ

ការកែទំរង់រដ្ឋធម្មនុញ្ញអាចស្នើនៅ១០ឆ្នាំក្រោយការប្រកាសឱ្យប្រើ ដោយសមាជិកព្រឹទ្ធសភា២៥ភាគរយ (ក៏ដូចជាសមាជិករដ្ឋសភា២៥ភាគរយ ប្រធានាធិបតីនៃសាធារណរដ្ឋ ឬញត្តិដែលចុះហត្ថលេខាដោយអ្នកបោះឆ្នោត៣០.០០០នាក់) ។តាមសម្លេងភាគច្រើន២/៣នៃសមាជិកសភាទាំងពីរអាចប្រកាសពីភាពចាំបាច់នៃការកែទំរង់រដ្ឋធម្មនុញ្ញ ។ ក្នុងករណីនេះ តុលាការជាន់ខ្ពស់រៀបចំការបោះឆ្នោតត្រូវរៀបចំការបោះឆ្នោតទូទៅ ដែលមិនត្រូវជាន់ជាមួយការបោះឆ្នោតឯទៀត ក្នុងរយៈពេល១៨០ថ្ងៃ ។

PAYS-BAS LA PREMIERE CHAMBRE DES ETATS GENERAUX

I-សមាសភាព

ព្រឹទ្ធសភា(សភាទី១) មានសមាជិក៧៥រូប ជ្រើសរើសដោយសមាជិកក្រុមប្រឹក្សាខេត្ត ។

II-របបបោះឆ្នោត

សមាជិកព្រឹទ្ធសភាត្រូវជ្រើសដោយការបោះឆ្នោតដោយមិនផ្ទាល់(ប្រយោល)តាមប្រ-ព័ន្ធសមាមាត្រ ។ មណ្ឌលបោះឆ្នោតជាក្រុមប្រឹក្សាខេត្តទាំង១២ ។

អង្គបោះឆ្នោតមានសមាសភាពជាសមាជិកក្រុមប្រឹក្សាខេត្ត ។

ការបោះឆ្នោតជ្រើសរើសសមាជិកសភាទី១ប្រព្រឹត្តទៅក្នុងរយៈពេល៣ខែ បន្ទាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត ។

អាណត្តិ : ៤ឆ្នាំ

សភាទី១ (កំដូចជាសភាទី២) អាចរំលាយដោយព្រះរាជក្រឹត្យ (décret royal) ។

ការផ្លាស់ប្តូរចុងក្រោយ : ២៩ ឧសភា ២០០៧ ។

អាចឈរឈ្មោះ : មានឈ្មោះបោះឆ្នោត អាយុយ៉ាងតិច១៨ឆ្នាំ មានសញ្ជាតិនៅឡង់ (néerlandaise) ។

សភាទី១ កាត់សេចក្តីលើការបោះឆ្នោតជ្រើសរើសសមាជិករបស់ខ្លួន ។

មិនមានជនណាអាចជាសមាជិករដ្ឋសភាផង ជាសមាជិកព្រឹទ្ធសភាផងបានទេ ។

III-សម័យប្រជុំ

ព្រឹទ្ធសភាមាន១សម័យប្រជុំក្នុង១ឆ្នាំ ដែលបើកនៅថ្ងៃអង្គារទី៣ខែកញ្ញា ដែលជាថ្ងៃថ្លែងសារបស់ព្រះមហាក្សត្រ(le Jour du Discours du Trône) ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

សភាទី១មានអំណាចនីតិប្បញ្ញត្តិ និងអំណាចត្រួតពិនិត្យមានកំរិត ។

ក-អំណាចនីតិប្បញ្ញត្តិ

១-គំនិតផ្ទួចផ្តើមធ្វើច្បាប់

សភាទី១មិនមានសិទ្ធិផ្ទួចផ្តើមគំនិតធ្វើច្បាប់ទេ ។ សិទ្ធិនេះជារបស់សភាទី២ (រដ្ឋសភា) និងរដ្ឋាភិបាល ។

២-សិទ្ធិវិសោធនកម្ម

សភាទី១មិនអាចធ្វើវិសោធនកម្មអត្ថបទបានឡើយ ។

សភាទី១បានត្រឹមតែផ្តល់ការយល់ព្រម ឬបដិសេធអត្ថបទទាំងមូល ។

៣-នីតិវិធីធ្វើច្បាប់

សេចក្តីព្រាងច្បាប់របស់រដ្ឋាភិបាលត្រូវដាក់នៅសភាទី២ (រដ្ឋសភា) ជាមុនជាសេចក្តីស្នើរបស់សមាជិករដ្ឋសភា ។ ក្រោយពេលដែលសភាទី២បានអនុម័តរួច អត្ថបទត្រូវបញ្ជូនទៅសភាទី១(ព្រឹទ្ធសភា)ដែលត្រូវអនុម័តនាពេលប្រជុំពេញអង្គ ក្រោយពេលដែលគណៈកម្មការជំនាញពិនិត្យរួចជាមុន ។ សភាទី១អាចផ្តល់ការយល់ព្រម ឬបដិសេធអត្ថបទទាំងមូល ដោយមិនអាចធ្វើវិសោធនកម្មបានឡើយ ។ បើយល់ព្រមទាំងស្រុង អត្ថបទត្រូវអនុម័តជាស្ថាពរ ។ បើមិនដូច្នេះទេ អត្ថបទត្រូវបដិសេធជាស្ថាពរ(មិនមានក្នុងការជាក់ស្តែង ។

ខ-អំណាចត្រួតពិនិត្យ

១-នយោបាយក្នុងប្រទេស

រៀងរាល់ឆ្នាំ នៅថ្ងៃអង្គារទី៣ ខែកញ្ញា យោបាយទូទៅរបស់រដ្ឋាភិបាលត្រូវបង្ហាញដោយព្រះមហាក្សត្រ (ឬព្រះរាជតំណាង) ចំពោះសភាជាតិដែលប្រជុំរួមគ្នា ។

សមាជិកសភាទី១អាចដាក់សំណួរជាលាយលក្ខណ៍អក្សរចំពោះរដ្ឋាភិបាល ប៉ុន្តែមិនមានពេលសម្រាប់សំណួរផ្ទាល់មាត់ឡើយ ។

សភាទី១មានសិទ្ធិស៊ើបអង្កេត ដូចសភាទី២ និងសភាជាតិប្រជុំរួមជាសមាជ តាមរយៈគណៈកម្មការដែលបង្កើតឡើងក្នុងការណីជាក់លាក់នីមួយៗ ។ គណៈកម្មការនេះ មានសិទ្ធិស្តាប់ជនដែលបានស្បថ និងតម្រូវឱ្យជននោះផ្តល់នូវព័ត៌មានដែលបានស្នើសុំ ។

សភាទី១មិនដែលបានប្រើសិទ្ធិបង្កើតគណៈកម្មការស៊ើបអង្កេតទេ ។

២-វិស័យអន្តរជាតិ

ការយល់ព្រមរបស់សភាជាការចាំបាច់ សម្រាប់ការផ្តល់សច្ចាប័ន ឬបដិសេធកិច្ចព្រមព្រៀងលើកលែងតែមានការកំណត់របស់ច្បាប់ ។ បើកិច្ចព្រមព្រៀងណាមានបញ្ហាគ្នីគ្នាជុំវិញនឹងរដ្ឋធម្មនុញ្ញឬបង្ខំឱ្យធ្វើវិសោធនកម្ម ការអនុម័តត្រូវយកតាមសម្លេងភាគច្រើន២/៣នៃសម្លេងដែលបានចោះ ។

V-បទឧបសម្ព្រាន្តដោយឆ្នាក

ក-ការសើរើរដ្ឋធម្មនុញ្ញ

សេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ធម្មនុញ្ញធ្វើតាមនីតិវិធីធម្មតា នៅលើកទី១ ។ បើសភាទាំងពីរអនុម័តយល់ព្រម សភាទី២(រដ្ឋសភា) ត្រូវរលាយ ហើយត្រូវដំណើរការចោះឆ្នោតជាថ្មី ។ ក្រោយការចោះឆ្នោត សមាជិករដ្ឋសភាជាប់ឆ្នោតថ្មី និងសមាជិក ព្រឹទ្ធសភាត្រូវប្រជុំរួមដើម្បីពិភាក្សាលើអត្ថបទដែលបានអនុម័តលើកទី១ ។

ការអនុម័តត្រូវយកតាមសម្លេងភាគច្រើន២/៣នៃសម្លេងដែលបានចោះ ។

ខ-បទឧបសម្ព្រាន្តពាក់ទងនឹងព្រះមហាក្សត្រ

ព្រះមហាក្សត្រ ឬភរិយានុសិទ្ធិ ដើម្បីរៀបអាពាហ៍ពិពាហ៍ ត្រូវមានការអនុញ្ញាតដោយច្បាប់ ដែលអនុម័តដោយសមាជសភាទាំងពីរ ។ ការបដិសេធជនណាម្នាក់ក្នុងការស្នងរាជត្រូវសម្រេចដោយច្បាប់ដែលត្រូវអនុម័តដោយសមាជសភាទាំងពីរ តាមសម្លេងភាគច្រើន២/៣នៃសម្លេងដែលបានចោះ ។

លើសិនជាប្រមើលមើលថាមិនមានអ្នកស្នងរាជ ច្បាប់មួយអាចតែងតាំងអ្នកស្នងនេះបាន ។ បាន ។ សេចក្តីព្រាងច្បាប់ត្រូវស្នើឡើងដោយព្រះមហាក្សត្រ ឬក្នុងព្រះបរមនាម ។

ក្រោយពេលដាក់ស្នើ សភាទាំងពីរត្រូវរលាយ ។ សភាថ្មីត្រូវប្រជុំរួមគ្នាពិភាក្សា និងអនុម័ត តាមសម្លេងភាគច្រើន២/៣នៃសម្លេងដែលបានចោះ ។

បើពេលព្រះមហាក្សត្រចូលទីវង្គតឬដាក់រាជ សភាទាំងពីរត្រូវរលាយ ។

សភាថ្មីត្រូវប្រជុំរួមគ្នា ក្នុងរយៈពេល៤ខែបន្ទាប់ពីចូលទីវង្គត ឬដាក់រាជដើម្បីសម្រេចលើការតែងតាំងព្រះមហាក្សត្រ តាមសម្លេងភាគច្រើន២៣នៃសម្លេងដែលបានបោះ ។

អាណាព្យាបាលរបស់ព្រះមហាក្សត្រ (ឬរាជានុសិទ្ធិ) ជាអនីតិជនត្រូវរៀបចំដោយច្បាប់ដែលអនុម័តដោយសមាជសភា ។

អសមត្ថភាព (ឬការបញ្ចប់អសមត្ថភាព) របស់ព្រះមហាក្សត្រក្នុងការបំពេញមុខងារ ត្រូវប្រកាសដោយសមាជសភា ។ ដូចគ្នានេះដែរ ចំពោះការអាក់ខានបំពេញមុខការមួយរយៈពេល (ឬការចូលមកវិញ) របស់ព្រះមហាក្សត្រ ។

គ-កាលៈទេសៈដោយឡែក

១-ស្ថានភាពសង្គ្រាម

ការប្រកាសសង្គ្រាម ឬបញ្ចប់សង្គ្រាម ត្រូវមានការយល់ព្រមជាមុនពីសមាជសភា លើកលែងតែក្នុងករណីដែលការពិគ្រោះមិនអាចធ្វើទៅបាន ដោយសារស្ថានភាពសង្គ្រាមមានពីមុនមកហើយ ។

២-ស្ថានភាពពិសេស

ក្នុងគ្រប់រយៈពេលនៃស្ថានភាពពិសេស (ការអនុវត្តខុសពីបញ្ញត្តិខ្លះនៃរដ្ឋធម្មនុញ្ញ ដើម្បីរក្សាសន្តិសុខក្នុងឬក្រៅប្រទេស) បើជាការចាំបាច់ សភាទាំងពីរត្រូវប្រជុំជាសមាជ ដើម្បីសម្រេចលើការងារនេះ ។

ហ្វីលីពីន **ព្រឹទ្ធសភា**

PHILIPINE LE SENAT

កំណត់ចំណាំ : ប្រវត្តិនៃរបបសភាពីរនៅហ្វីលីពីនចាប់ផ្តើមក្រោយសង្គ្រាមឆ្នាំ ១៨៩៨ ពេលហ្វីលីពីនចូលក្នុងអធិបតេយ្យរបស់អាមេរិក ។

ក្រោយពេលអន្តរកាល (ដែលផ្តើមពី១៩០២ដល់១៩០៧ ដែលអំណាចនីតិប្បញ្ញត្តិកាន់កាប់ដោយគណៈកម្មការមួយ តែងតាំងដោយប្រធានាធិបតីសហរដ្ឋអាមេរិក) សភាពីរថ្នាក់ត្រូវបានបង្កើតឡើង ដែលមានគណៈកម្មការដែលសមាជិកត្រូវតែងតាំងដោយប្រធានាធិបតីសហរដ្ឋអាមេរិកនិងសភាហ្វីលីពីន (សភាដែលជ្រើសតាំងដោយពលរដ្ឋហ្វីលីពីន) ។ ចាប់ពីឆ្នាំ១៩១៦ គណៈកម្មការនេះត្រូវលុបចោល ហើយជំនួសដោយព្រឹទ្ធសភាជ្រើសតាំង ។ ដំណើរឆ្ពោះទៅរកឯករាជ្យ ដោយការអនុម័តរដ្ឋធម្មនុញ្ញឆ្នាំ១៩៣៥ និងការបង្កើត commonwealth ហ្វីលីពីនបានចោទជាបញ្ហាចំពោះការបង្កើតសភាពីរ ប៉ុន្តែប្រព័ន្ធសភាពីរនេះបានដំណើរការឡើងវិញចាប់ពីឆ្នាំ១៩៤០ដោយវិសោធនកម្មរដ្ឋធម្មនុញ្ញ ។ នៅឆ្នាំ១៩៧២ ក្នុងអាណត្តិទី២ និងតាមគោលការណ៍ជាអាណត្តិចុងក្រោយរបស់ខ្លួន ប្រធានាធិបតីម៉ាកុសបង្កើតនូវចលនាកំមុយនីស្ត ចេញច្បាប់អាជ្ញាសឹក និងត្រប់ត្រងដោយពេញអំណាច ។ រដ្ឋធម្មនុញ្ញថ្មីត្រូវបានអនុម័ត ហើយបានលុបចោលជាពិសេសប្រព័ន្ធសភាពីរ ។ នៅពេលផ្តួលរំលំប្រធានាធិបតីម៉ាកូសឆ្នាំ១៩៨៦ ប្រធានាធិបតីថ្មីលោកស្រី កូរ៉ាហ្យ៉ាន អាគីណូ (Corazon Aquino) គណៈកម្មការធម្មនុញ្ញមួយ ត្រូវបានបង្កើតឡើង ហើយរដ្ឋធម្មនុញ្ញថ្មីត្រូវបានអនុម័តដោយប្រជាមតិនៅឆ្នាំ១៩៨៧ ។ សភាពីរថ្នាក់បានដំណើរការឡើងវិញ តាមបែបអាមេរិកាំង ។

I-សមាសភាព

ព្រឹទ្ធសភាមានសមាជិក២៤រូប ជ្រើសតាំងដោយការបោះឆ្នោតសកល ដោយផ្ទាល់ ។

II-របបឆ្នោះឆ្លោត

សមាជិកព្រឹទ្ធសភាត្រូវបានជ្រើសតាំងក្នុងមណ្ឌលតែមួយ ថ្នាក់ជាតិ មាន២៤ អាសនៈតាមសម្លេងភាគច្រើន ពហុនាម ដោយផ្ទាល់ (scrutin majoritaire plurinominal direct) ។

កំណត់ចំណាំ : សមាជិកព្រឹទ្ធសភាត្រូវបានជ្រើសតាំងក្នុងក្របខ័ណ្ឌជាតិ និងសមាជិករដ្ឋសភាក្នុងក្របខ័ណ្ឌមណ្ឌលហើយសមាជិករដ្ឋសភាបំពេញមុខងារជាតំណាងដែនដី ដែលមានលក្ខណៈផ្ទុយពីសភាផ្សេងៗទៀត ។

អាណត្តិ :៦ឆ្នាំ ផ្លាស់ប្តូរថ្មីចំនួនពាក់កណ្តាល រៀងរាល់ពីឆ្នាំ ។

សមាជិកព្រឹទ្ធសភាម្នាក់ៗមិនអាចបំពេញមុខងារលើសពីពីរអាណត្តិជាប់គ្នាបានឡើយ ។

ការផ្លាស់ប្តូរចុងក្រោយ:១៤ ឧសភា ២០០៧ ។

លក្ខខណ្ឌ: អាយុយ៉ាងតិច៣៥ឆ្នាំ សញ្ជាតិហ្ស៊ីម្ប៉ាប្វេ តាំងពីកំណើត ចេះអាននិងចេះសរសេរ និងស្នាក់នៅក្នុងប្រទេស២ឆ្នាំយ៉ាងតិចមុនពេលបោះឆ្នោត ។

មិនអាចឈរឈ្មោះបាន: អ្នកដែលប្រព្រឹត្តអំពើពុករលួយក្នុងការបោះឆ្នោត អ្នកប្រព្រឹត្តអំពើភេរវកម្ម អ្នកចាយវាយក្នុងការបោះឆ្នោតលើសពីការកំណត់និងអ្នកជួញដូរគ្រាក់ខុសច្បាប់ ។

តុលាការមួយដែលមានសមាជិក៦រូបមកពីសភាណាមួយ និងចៅក្រមពេញបនៃតុលាការកំពូលត្រួតពិនិត្យប្រក្រតីភាពនៃការបោះឆ្នោតជ្រើសរើសសមាជិកសភានោះ ។

សភានីមួយៗអាចដាក់ទណ្ឌកម្មសមាជិកខ្លួនដែលមានចរិយាមិនល្អ ។ទណ្ឌកម្មអាចមានរហូតដល់ព្យួរការងារ៦០ថ្ងៃ ឬបណ្តេញចេញជាស្ថាពរពីសភា ។

អាណត្តិនៃសមាជិកព្រឹទ្ធសភា មានវិសមិតភាពជាមួយការអនុវត្តមុខងារក្នុងរដ្ឋាភិបាលមុខការជាក្រុមប្រឹក្សាច្បាប់ និងជាភាគីកិច្ចសន្យាជាមួយរដ្ឋាភិបាល ។

III -សម័យប្រជុំ

សភាត្រូវកោះប្រជុំជាសាមញ្ញមួយដងក្នុងមួយឆ្នាំ នៅថ្ងៃច័ន្ទទី៤ ខែកក្កដា (quatrième lundi de juillet) លើកលែងតែមានច្បាប់កំណត់ផ្សេងពីនេះ និងអាចបន្តសម័យប្រជុំរហូតដល់ ៣០ថ្ងៃមុនបើកសម័យប្រជុំសាមញ្ញលើកក្រោយបន្ទាប់ ដោយមិនគិតថ្ងៃសៅរ៍ អាទិត្យ និងថ្ងៃបុណ្យ ។

ប្រធានាធិបតីអាចកោះប្រជុំសភាជាវិសាមញ្ញបានគ្រប់ពេល ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-ព័ន្ធិតផ្តួចផ្តើមធ្វើច្បាប់

ព័ន្ធិតផ្តួចផ្តើមធ្វើច្បាប់ជាសិទ្ធិរបស់សមាជិកសមាជ ។

ច្បាប់ដែលទាក់ទងនឹងហិរញ្ញវត្ថុសាធារណៈ (ច្បាប់ហិរញ្ញវត្ថុ ច្បាប់អនុញ្ញាតឱ្យបង្កើនបំណុលសាធារណៈ ។ល ។) ត្រូវតែដាក់ជូនរដ្ឋសភា ។

២-សិទ្ធិវិសោធនកម្ម

សមាជិកព្រឹទ្ធសភាអាចដាក់សេចក្តីស្នើវិសោធនកម្ម (proposition d'amendement) ដោយរាប់ទាំងក្នុងវិស័យច្បាប់ទាក់ទងនឹងហិរញ្ញវត្ថុសាធារណៈផងប៉ុន្តែមិនរាប់វិសោធនកម្មដែលនាំឱ្យបង្កើនចំណាយសាធារណៈឡើយ ។

៣-នីតិវិធីធ្វើច្បាប់

ការពិនិត្យអត្ថបទច្បាប់ចាប់ផ្តើមពីសភាដែលអត្ថបទច្បាប់បានដាក់ ។

ដើម្បីបានទៅជាច្បាប់ អត្ថបទត្រូវតែបានការយល់ព្រមជាបន្តបន្ទាប់ពីសភាទាំងពីរ ។

ការអនុម័តអត្ថបទមួយនៅសភាណាមួយត្រូវធ្វើជាពីការអាន (3 lectures) ។

នៅការអានលើកទី១ (ជាទម្រង់សុទ្ធសាធ) ចំណងជើងច្បាប់ និងសមាជិកសភាដែលជាប្រភពរបស់អត្ថបទត្រូវបង្ហាញជូនសភា ។ បន្ទាប់មក អត្ថបទត្រូវប្រធានសភាបញ្ជូនទៅគណៈកម្មការជំនាញមានសមត្ថកិច្ច ដើម្បីសិក្សាលំអិត ។ បើចាំបាច់ គណៈកម្មការពិសេសអាចត្រូវបានបង្កើតឡើង ។

គណៈកម្មការដំណើរការធ្វើសវនកម្ម និងការប្រជុំពិគ្រោះយោបល់ ។ គណៈកម្មការសម្រេច : អាចបដិសេធទាំងស្រុង (អត្ថបទត្រូវតំកល់ទុក) ឬយល់ព្រមដោយគ្មានការកែប្រែ ឬយល់ព្រមដោយមានវិសោធនកម្ម ។ បើត្រូវបានអនុម័តដោយមាន ឬគ្មានវិសោធនកម្ម អត្ថបទ

ច្បាប់នោះត្រូវចុះក្នុងរបៀបវារៈប្រជុំពេញអង្គសម្រាប់ការអានលើកទី២ ។

ការពិនិត្យក្នុងអង្គប្រជុំ នៅការអានលើកទី២ ចាប់ផ្តើមដំបូងដោយការពិភាក្សាជាទូទៅ ដែលអ្នកផ្តើមគំនិតធ្វើច្បាប់បញ្ជូញយោបល់មុនគេ ។ សមាជិកព្រឹទ្ធសភាដែលគាំទ្រនិងសមាជិកដែលប្រឆាំងបញ្ជូញយោបល់ជាបន្តបន្ទាប់ ។ ពេលចប់ការពិភាក្សាទូទៅ សភាពិភាក្សាលើវិសោធនកម្មដែលគណៈកម្មការជំនាញមានសមត្ថកិច្ចបានស្នើឡើង និងលើវិសោធនកម្មដែលសមាជិកព្រឹទ្ធសភាជាបុគ្គលបានស្នើឡើង ។

ពេលចប់ការពិភាក្សាលំអិត សភាអនុម័តលើអត្ថបទច្បាប់ទាំងមូល ។ បន្ទាប់មក អត្ថបទនោះត្រូវចុះក្នុងរបៀបវារៈសម្រាប់ការអានលើកទី៣ ។ ការអានលើកទី៣ ជាការបោះឆ្នោតលើអត្ថបទដែលអនុម័តនៅការអានលើកទី២ ដោយមានដាក់ឈ្មោះ (vote nominatif) ។

ពេលនេះពុំអាចស្នើវិសោធនកម្មបានទេប៉ុន្តែសមាជិកព្រឹទ្ធសភាអាចមានយោបល់ពន្យល់អំពីការបោះឆ្នោត ។

អត្ថបទដែលត្រូវបានអនុម័តនៅការអានលើកទី៣ត្រូវបញ្ជូនទៅសភាមួយទៀត ដែលប្រើនូវនីតិវិធីដូចគ្នា ។

បើអត្ថបទត្រូវបានអនុម័តដោយឥតកែប្រែ អត្ថបទនោះត្រូវបញ្ជូនទៅប្រធានាធិបតីដើម្បីផ្តល់ការយល់ព្រម ។

បើសភាទាំងពីរមិនអាចរកការព្រមព្រៀងគ្នាបាន គណៈកម្មការសម្របសម្រួលមួយត្រូវរួមប្រជុំ ។ អត្ថបទរបស់គណៈកម្មការ (បើមាន) ត្រូវដាក់ជូនសភាទាំងពីរអនុម័ត ដោយមិនអាចស្នើវិសោធនកម្មណាមួយបានឡើយ ។ បើអត្ថបទរបស់គណៈកម្មការ ត្រូវសភាទាំងពីរអនុម័ត យល់ព្រម ត្រូវបញ្ជូនទៅប្រធានាធិបតី ។

ប្រធានាធិបតីហ្វីលីពីនចុះហត្ថលេខាលើអត្ថបទច្បាប់ឬជំទាស់នឹងច្បាប់ ។

ក្នុងករណីជំទាស់ អត្ថបទត្រូវបញ្ជូនត្រឡប់ ដោយមានការបញ្ជាក់អំពីមូលហេតុនៃការជំទាស់ទៅសមាជដែលត្រូវចាប់ផ្តើមពីសភាដើម ។

ការជំទាស់របស់ប្រធានាធិបតីត្រូវបញ្ជូប់ លើសភាទាំងពីរក្សាជំហររបស់ខ្លួនតាមសម្លេងភាគច្រើន២/៣នៃសមាជិករបស់ខ្លួន ។ប្រធានាធិបតីមានរយៈពេល៣០ថ្ងៃសម្រាប់ចុះហត្ថលេខាប្រកាសឱ្យប្រើ ។ បើហួសរយៈពេលនេះ អត្ថបទច្បាប់ត្រូវទៅជាច្បាប់ដោយស្វ័យប្រវត្តិ ។

ខ-អំណាចត្រួតពិនិត្យ

១-អំណាចស៊ើបអង្កេត(pouvoir d'investigation)

ព្រឹទ្ធសភា រដ្ឋសភា និងគណៈកម្មការរបស់ខ្លួនអាចធ្វើការស៊ើបអង្កេតដើម្បីត្រួតពិនិត្យការអនុវត្តច្បាប់ ។

២-អំណាចឃ្លាំមើល(pouvoirs de surveillance)

សមាជិមានអំណាចឃ្លាំមើលសកម្មភាព កម្មវិធីនយោបាយ និងការងាររបស់អង្គការនីតិប្រតិបត្តិដើម្បីកំណត់ថាច្បាប់នានាត្រូវបានអនុវត្តដោយឬត់ចត់ ។

៣-ការយល់ព្រមលើសន្ធិសញ្ញា

រដ្ឋធម្មនុញ្ញចែងថា " ពុំមានសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិណាមួយមានសុពលភាពដោយពុំមានការយល់ព្រមយ៉ាងតិច២/៣នៃសមាជិកព្រឹទ្ធសភាទាំងមូលឡើយ " ។

គ-ទំនាក់ទំនងជាមួយប្រធានាធិបតី

១-វិស្សមកាល

ករណីវិស្សមកាលនៃមុខងាររបស់អនុប្រធានាធិបតី ប្រធានាធិបតីតែងតាំងពីក្នុងចំណោមសមាជិកសមាជ ។ សភាទាំងពីរអនុម័តដោយឡែកពីគ្នា ផ្តល់ការយល់ព្រមលើការតែងតាំងនេះតាមសម្លេងភាគច្រើននៃសមាជិករបស់ខ្លួន ។

ករណីវិស្សមកាលនៃមុខងាររបស់ប្រធានាធិបតី និងអនុប្រធានាធិបតី ប្រធានព្រឹទ្ធសភាទទួលក្នុងឋានៈស្តីទី ។

២-ការទាក់ទងជាមួយសមាជ

ប្រធានាធិបតីទាក់ទងជាមួយសមាជ តាមសារលិខិត ពេលបើកសម័យប្រជុំវិសាមញ្ញ។

ប្រធានាធិបតីអាចថ្លែងផ្ទាល់ ចំពោះមុខសមាជ តាមការយល់ឃើញរបស់ខ្លួន។

៣-ការត្រួតពិនិត្យ

ប្រធានាធិបតីអាចត្រូវដកពីតំណែង តាមការចោទប្រកាន់របស់រដ្ឋសភា និងតាមការសម្រេចរបស់ព្រឹទ្ធសភា។

៤-ចនម្យញ្ញត្តិផ្សេងៗ

ក-ការសើរើរដ្ឋធម្មនុញ្ញ

ការសើរើរដ្ឋធម្មនុញ្ញអាចស្នើឡើងដោយ:

-ដោយសមាជ តាមសម្លេងភាគច្រើនបីភាគបួននៃសមាជិករបស់ខ្លួន

-ដោយអនុសញ្ញាធម្មនុញ្ញ តាមសំណើរបស់សមាជ(ត្រូវមានសមាជិកសមាជចំនួនពីរភាគបីសម្រេចឱ្យមានការប្រជុំអំពីអនុសញ្ញាឬត្រូវដាក់ធ្វើប្រជាមតិលើសំណើសុំឱ្យមានការប្រជុំ)

-ដោយប្រជាពលរដ្ឋផ្ទាល់(ញត្តិដែលមានការគាំទ្រពីអ្នកចុះឈ្មោះបោះឆ្នោតទាំងអស់យ៉ាងតិច១២% និងមានអ្នកបោះឆ្នោតយ៉ាងតិច៣%ក្នុងមណ្ឌលនីមួយៗ)។

ការសើរើរដ្ឋធម្មនុញ្ញត្រូវអនុម័តដោយប្រជាមតិ ។

ខ-អំណាចតែងតាំង

អំណាចប្រធានាធិបតីក្នុងការតែងតាំងតម្រូវឱ្យមានក្នុងករណីខ្លះ (សមាជិកគណៈកម្ម-ការមុខងារសាធារណៈ សមាជិកក្រុមប្រឹក្សាយុត្តិធម៌ និងគណៈមេធាវី សមាជិកគណៈកម្មការបោះឆ្នោត សមាជិកគណៈកម្មការសវនកម្មហិរញ្ញវត្ថុសាធារណៈ) ការយល់ព្រមពីគណៈកម្មការដឹកនាំដោយប្រធានព្រឹទ្ធសភា និងមានសមាជិកព្រឹទ្ធសភា១២រូប និងសមាជិករដ្ឋសភា១២រូប។

គ-កាលៈទេសៈពិសេស

ក្នុងករណីមានការឈ្លានពាន ឬការបះបោរ ប្រធានាធិបតីអាចប្រកាសច្បាប់អាជ្ញាសឹក ឬព្យួរសើរីភាពបុគ្គលសម្រាប់រយៈ៦០ថ្ងៃ។ ក្នុងករណីនេះ ប្រធានាធិបតីមានរយៈពេល៤៨ម៉ោង

សម្រាប់ធ្វើរបាយការណ៍ជូនសមាជ ។ បើសមាជមិនស្ថិតក្នុងសម័យប្រជុំ សមាជត្រូវប្រជុំដោយពេញច្បាប់ ។ ដោយការអនុម័តរួមរវាងសភាទាំងពីរ តាមសម្លេងភាគច្រើននៃសមាជិករបស់ខ្លួន សមាជអាចវិលត្រឡប់មកច្បាប់អាជ្ញាសឹកវិញបាន ។

ឃ- អំណាចដកហូតមុខតំណែង

ប្រធានាធិបតី អនុប្រធានាធិបតី សមាជិកតុលាការកំពូល និងសមាជិកគណៈកម្មការផ្សេងទៀតដែលមានចែងក្នុងរដ្ឋធម្មនុញ្ញអាចត្រូវដកហូតមុខតំណែង តាមការចោទប្រកាន់របស់រដ្ឋសភា និងការសម្រេចរបស់ព្រឹទ្ធសភា ។

ប៉ូឡូញ ព្រឹទ្ធសភា

POLOGNE LE SENAT

នៅប៉ូឡូញ ប្រព័ន្ធសភាពីរបានរៀបចំឡើងនៅពេលចប់សង្គ្រាមត្រជាក់ឆ្នាំ១៩៨៩ មុន មានការយល់ព្រមពីរដ្ឋធម្មនុញ្ញថ្ងៃទី២ខែ មេសា ឆ្នាំ១៩៩៧ ។

ស្របតាមមាត្រា១០និង៩៩នៃរដ្ឋធម្មនុញ្ញ ព្រឹទ្ធសភាចែករំលែកជាមួយរដ្ឋសភា(la Diète) នូវអំណាចនីតិប្បញ្ញត្តិ ។ទោះជាយ៉ាងនេះក៏ដោយ ព្រឹទ្ធសភាមិនមានអំណាចត្រួតពិនិត្យសកម្មភាពរបស់រដ្ឋាភិបាលឡើយ ។

I.សមាសភាព

ព្រឹទ្ធសភាមានសមាជិក១០០រូប ជ្រើសតាំងឡើងដោយការបោះឆ្នោតសកល ដោយផ្ទាល់ និងជាសម្ងាត់ ។

II.របៀបបោះឆ្នោត

ការបោះឆ្នោតធ្វើក្នុង៤៧មណ្ឌល ផ្ទៃលមាន២អាសនៈ និង២មណ្ឌលមាន ៣អាសនៈ (Varsovie et Katowice) ។

សមាជិកព្រឹទ្ធសភាត្រូវជ្រើសតាំងតាមសម្លេងភាគច្រើន តែមួយជុំ ។ បេក្ខជនម្នាក់ៗត្រូវមានការគាំទ្រពីអ្នកបោះឆ្នោតយ៉ាងតិច៣.000នាក់ ។

លក្ខខណ្ឌអាយុ: ៣០ឆ្នាំ

អាណត្តិ : ៤ឆ្នាំ

ការរំលាយរដ្ឋសភា ផ្ទៃលអាចបណ្តាលពីការសម្រេចចិត្ត តាមសម្លេងភាគច្រើន ២/៣ នៃសមាជិករដ្ឋសភា ឬតាមការសម្រេចរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ដោយមានយោបល់របស់ប្រធានសភាទាំងពីរ នាំឱ្យរលាយព្រឹទ្ធសភា ។

ការផ្លាស់ប្តូរចុងក្រោយ:២១តុលា ២០០៧(បន្ទាប់ពីការរំលាយរដ្ឋសភា) ។

សមាជិកព្រឹទ្ធសភាអាចបំពេញមុខងារជារដ្ឋមន្ត្រី ឬអនុរដ្ឋមន្ត្រី តែមិនអាចបំពេញមុខងារជាប្រធានធនាគារជាតិ ប្រធានសភាត្រួតពិនិត្យជាន់ខ្ពស់ ប្រធានវិទ្យាស្ថានចងចាំជាតិ (Institut de mémoire nationale) មជ្ឈតការ និងមជ្ឈតការសម្រាប់កុមារ (និងអនុប្រធាន) សមាជិកក្រុមប្រឹក្សានយោបាយប្រាក់កាស សមាជិកក្រុមប្រឹក្សាវិទ្យុនិងទូរទស្សន៍ជាតិ អគ្គរដ្ឋទូតភ្នាក់ងារសន្តិសុខរដ្ឋសភាឬព្រឹទ្ធសភាឬប្រធានាធិបតីនៃសាធារណរដ្ឋ ។

សមាជិកព្រឹទ្ធសភាមិនអាចបំពេញមុខងារក្នុងអង្គការប្រតិបត្តិដែនដីនិងមុខងារចៅក្រមអគ្គរដ្ឋអាជ្ញា មន្ត្រី កងទ័ពក្នុងតំណែងសកម្ម នគរបាល ឬមុខងារការពាររដ្ឋ ។

III-សម័យប្រជុំ

សភាទាំងពីរប្រជុំមិនមានអាក់ខាន ។ ប្រតិទិនសម័យប្រជុំរបស់ព្រឹទ្ធសភារៀបចំឡើងស្របតាមប្រតិទិនរបស់រដ្ឋសភា ។

ជាក់ស្តែង ការប្រជុំធ្វើឡើង២ដងក្នុងមួយខែ ម្តង១ពី២ទៅ៣ថ្ងៃ ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភា និងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-ឥនិតផ្តួចផ្តើមធ្វើច្បាប់

ឥនិតផ្តួចផ្តើមធ្វើច្បាប់អនុវត្តដោយព្រឹទ្ធសភា (តាមការដាក់ញត្តិដោយក្រុមសមាជិកព្រឹទ្ធសភាយ៉ាងតិច១០នាក់ ឬដោយគណៈកម្មការអចិន្ត្រៃយ៍ណាមួយ) ក៏ផ្ទួចជាសមាជិករដ្ឋសភា (ក្រុមសមាជិករដ្ឋសភាយ៉ាងតិច១៥នាក់ ឬគណៈកម្មការអចិន្ត្រៃយ៍ណាមួយ) ប្រធានាធិបតីនៃសាធារណរដ្ឋ ក្រុមប្រឹក្សារដ្ឋមន្ត្រី ឬពលរដ្ឋ១០០.០០០នាក់ ។

២-សិទ្ធិវិសោធនកម្ម

ព្រឹទ្ធសភាមានសិទ្ធិវិសោធនកម្ម ។

៣-នីតិវិធីធម្មតា

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវតែពិនិត្យជាលើកទី១ ដោយរដ្ឋសភារាប់ទាំងសេចក្តីស្នើច្បាប់របស់ព្រឹទ្ធសភាផង។

នីតិវិធីធ្វើទៅជាពីរដំណាក់កាល:

-ការអានលើកទី១ ជាការវាយតម្លៃអំពីប្រយោជន៍របស់អត្ថបទនិងអំពីការទទួលយក។

អត្ថបទអាចត្រូវបដិសេធដោយញត្តិ ។ បើទទួលយក អត្ថបទត្រូវបញ្ជូនទៅគណៈកម្មការមានសមត្ថកិច្ចដើម្បីសិក្សាលំអិត

-ការអានលើកទី៣ ជាការពិនិត្យលើវិសោធនកម្មនិងការអនុម័តក្នុងពេលប្រជុំពេញអង្គ។

អត្ថបទដែលបានអនុម័តដោយរដ្ឋសភា ត្រូវបញ្ជូនទៅព្រឹទ្ធសភាដែលត្រូវបញ្ជូនទៅគណៈកម្មការមានសមត្ថកិច្ចណាមួយ ដែលត្រូវបង្ហាញរបាយការណ៍ក្នុងរយៈពេលយ៉ាងយូរ ១៥ ថ្ងៃ ។ អត្ថបទត្រូវពិភាក្សាក្នុងពេលប្រជុំពេញអង្គ។

ព្រឹទ្ធសភាអាចអនុម័តអត្ថបទដោយគ្មានកែប្រែ ដោយមានវិសោធនកម្ម ឬ បដិសេធក្នុងរយៈពេល៣០ថ្ងៃ (លើកលែងតែក្នុងករណីប្រញាប់ : ១៤ថ្ងៃ)។ បើមិនបានអនុម័តដោយសេចក្តីសម្រេចចិត្តក្នុងរយៈពេល៣០ថ្ងៃទេ អត្ថបទនោះត្រូវចាត់ទុកថាបានអនុម័ត។

កាលណាព្រឹទ្ធសភាបដិសេធ ឬវិសោធនកម្ម រដ្ឋសភាត្រូវពិនិត្យឡើងវិញដោយយកតាមសម្លេងភាគច្រើននៃសមាជិកវត្តមានយ៉ាងតិចស្មើនឹងពាក់កណ្តាល(២៣០ ។

បើរដ្ឋសភាមិនបដិសេធវិសោធនកម្មរបស់ព្រឹទ្ធសភា វិសោធនកម្មនេះចាត់ទុកថាបានអនុម័ត។ ដូចគ្នានេះដែរ ចំពោះញត្តិបដិសេធសេចក្តីព្រាងទាំងស្រុង។

អត្ថបទដែលរដ្ឋសភាបានអនុម័ត (គិតទាំងវិសោធនកម្មរបស់ព្រឹទ្ធសភា ដែលយល់ព្រមដោយរដ្ឋសភា) ត្រូវបញ្ជូនទៅប្រធានាធិបតីនៃសាធារណរដ្ឋ ដើម្បីប្រកាសឱ្យប្រើ។

៤-នីតិវិធីចំពោះច្បាប់ថវិកា

ព្រឹទ្ធសភាអាចអនុម័តសេចក្តីសម្រេចចិត្តយល់ព្រម ឬវិសោធនកម្មសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ ដែលអនុម័តដោយរដ្ឋសភាក្នុងរយៈពេល២០ថ្ងៃ ប៉ុន្តែព្រឹទ្ធសភាមិនអាចបដិសេធទាំង

ស្រុងបានឡើយ ។

ខ-អំណាចត្រួតពិនិត្យ

តាមរដ្ឋធម្មនុញ្ញ មានតែរដ្ឋសភាទេដែលមានសិទ្ធិត្រួតពិនិត្យរដ្ឋាភិបាល ។

ត-អំណាចរបស់ព្រឹទ្ធសភាលើប្រធានាធិបតី

១-វិស្សមកាល

សភាជាតិ(ប្រជុំរួមរដ្ឋសភានិងព្រឹទ្ធសភា) កំណត់អំពីអសមត្ថភាពអចិន្ត្រៃយ៍របស់ប្រធានាធិបតីនៃសាធារណរដ្ឋក្នុងការបំពេញមុខងារដោយមូលហេតុសុខភាព តាមសម្លេងភាគច្រើន២/ ៣ នៃចំនួនវត្តមានយ៉ាងតិចស្មើនឹងពាក់កណ្តាលចំនួនសមាជិកសភាជាតិ ។

ក្នុងករណីដែលប្រធានរដ្ឋសភាមិនអាចបំពេញមុខងារស្តីទីប្រធានាធិបតីនៃសាធារណរដ្ឋបាន ប្រធានព្រឹទ្ធសភាអាចទទួលមុខងារនេះបាន ។

២-ការចោទប្រកាន់

ប្រធានាធិបតី ដែលបានស្បថចំពោះមុខសភាទាំងពីរ អាចត្រូវចោទប្រកាន់អំពីការរំលោភរដ្ឋធម្មនុញ្ញ ឬច្បាប់ ឬអំពីបទល្មើស តាមសេចក្តីសម្រេចចិត្តរបស់សភាជាតិ តាមសម្លេងភាគច្រើន ២/ ៣ តាមសំណើរបស់សមាជិកសភាជាតិយ៉ាងតិច១៤០នាក់ ។

V-ចនប្បញ្ញត្តិផ្សេងៗ

ក-វិស័យធម្មនុញ្ញ

១-ការសើរើ

ព្រឹទ្ធសភាមានអំណាចច្រើន ពេលសើរើរដ្ឋធម្មនុញ្ញ ។ ប្រធានាធិបតីនៃសាធារណរដ្ឋ ព្រឹទ្ធសភា ឬសមាជិករដ្ឋសភាយ៉ាងតិច១/៥ អាចស្នើកែប្រែរដ្ឋធម្មនុញ្ញបាន ។

សេចក្តីព្រាងច្បាប់ធម្មនុញ្ញត្រូវអនុម័តដោយរដ្ឋសភា តាមសម្លេងភាគច្រើន២/ ៣(ត្រូវមានវត្តមានសមាជិករដ្ឋសភាពាក់កណ្តាល) និងដោយព្រឹទ្ធសភា តាមសម្លេងភាគច្រើនដាច់ខាត

(ត្រូវមានវត្តមានសមាជិកព្រឹទ្ធសភាចំនួនពាក់កណ្តាល) ។

រយៈពេលសម្រាប់ព្រឹទ្ធសភាពិនិត្យមាន៦០ថ្ងៃ ។

បើការសើរើធ្វើឡើងលើភាគទី១(សាធារណរដ្ឋ) ភាគទី២(សេរីភាពសាធារណៈ) ឬភាគទី១២(ការសើរើរដ្ឋធម្មនុញ្ញ) នៃរដ្ឋធម្មនុញ្ញ ការអនុម័តរបស់សភាត្រូវដាក់ធ្វើប្រជាមតិ ។

២-ការត្រួតពិនិត្យធម្មនុញ្ញភាព

ប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភា៣០នាក់ ប្រធានរដ្ឋសភា ឬសមាជិករដ្ឋសភា ៥០នាក់ និងអាជ្ញាធរឯទៀត អាចស្នើសុំឱ្យតុលាការធម្មនុញ្ញពិនិត្យអំពីភាពស្របនឹងរដ្ឋធម្មនុញ្ញ ស្របនឹងសន្ធិសញ្ញា និងច្បាប់របស់បទដ្ឋានគតិយុត្តនានា ។

ខ-ប្រជាមតិ

សេចក្តីសម្រេចរបស់ប្រធានាធិបតីឱ្យរៀបចំធ្វើប្រជាមតិ ត្រូវតែមានការយល់ព្រមរបស់ព្រឹទ្ធសភា ។

គ-ការតែងតាំង

ត្រូវមានការយល់ព្រមរបស់ព្រឹទ្ធសភា :

-ការតែងតាំង ដោយរដ្ឋសភានូវប្រធានសភាត្រួតពិនិត្យជាន់ខ្ពស់

-ការតែងតាំង ដោយរដ្ឋសភានូវអ្នកការពារសិទ្ធិពលរដ្ឋ

-ការតែងតាំង ដោយរដ្ឋសភានូវអ្នកការពារសិទ្ធិកុមារ

-ការតែងតាំង ដោយរដ្ឋសភានូវប្រធានវិទ្យាស្ថានចងចាំជាតិ ។

ម្យ៉ាងទៀត ព្រឹទ្ធសភា ជាមួយរដ្ឋសភា និងប្រធានាធិបតីនៃសាធារណរដ្ឋ តែងតាំងសមាជិក :

-ក្រុមប្រឹក្សាវិទ្យុ និងទូរទស្សន៍ជាតិ

-ក្រុមប្រឹក្សាយុត្តាធិការជាតិ

-ក្រុមប្រឹក្សានយោបាយប្រាក់កាស ។

ប្រធានព្រឹទ្ធសភាជាសមាជិកពេញច្បាប់ នៃគណៈកម្មការការពារជាតិ ។

ប៉ាគីស្ថាន **ព្រឹទ្ធសភា**

PAKISTAN LE SENAT

នេះគឺជាលើកទី១ហើយតាំងពីពេលព្យូរសភា បន្ទាប់ពីរដ្ឋប្រហារដឹកនាំដោយឧត្តមសេនី Pervez Moucharrraf នាយអត្តសេនាធិការកងទ័ពប៉ាគីស្ថាននៅថ្ងៃទី១២ តុលា១៩៩៩ ដែលការបោះឆ្នោតត្រូវរៀបចំឡើងនៅថ្ងៃ២៤កុម្ភៈ ២០០៣ ដើម្បីរៀបចំព្រឹទ្ធសភាឡើងវិញទាំងស្រុង ។

I-សមាសភាព

សមាជិកព្រឹទ្ធសភាមានចំនួន១០០នាក់ ជ្រើសតាំង:

-២២នាក់ ដោយសភាខេត្តនីមួយ១ ក្នុងចំណោមខេត្តទាំង៤របស់ប្រទេស

-៨នាក់ ដោយសមាជិករដ្ឋសភា នៅកំរិតតំបន់ tribal ក្រោមរដ្ឋបាលសហភាព ២នាក់ ជ្រើសរើសក្នុងរដ្ឋធានីសហភាព ដោយសមាជិករដ្ឋសភា ។

II-រមបៈឆ្នោត

-មិនផ្ទាល់ : ប្រព័ន្ធសមាមាត្រ និងអាចផ្ទេរបាន

-មាន៤មណ្ឌលពហុនាម(ត្រូវនឹងខេត្ត៤របស់ប្រទេស) ១មណ្ឌលពហុនាម(ត្រូវនឹងតំបន់ tribal ក្រោមរដ្ឋបាលសហភាព) និង១មណ្ឌលពហុនាម(ត្រូវនឹងរដ្ឋធានីសហភាព) ។

-អាណត្តិ : ៦ឆ្នាំ ផ្ទាស់ប្តូរថ្មីពាក់កណ្តាលរៀងរាល់៣ឆ្នាំ ។

-ផ្ទាស់ប្តូរថ្មីចុងក្រោយ : ២៤កុម្ភៈ២០០៣

-លក្ខខណ្ឌ: អាយុ ៣០ឆ្នាំ ពលរដ្ឋប៉ាគីស្ថាន ទំនៀមទំលាប់ល្អ ពេញចិត្តនឹងលក្ខខណ្ឌខ្លះទាក់ទងនឹងសាសនាអ៊ីស្លាម ។

-ហាម:សកម្មភាពគូរខ្មាស់អៀន សកម្មភាពខុស ប៉ះពាល់ប្តូរណភាពទឹកដី ក្ស័យធនមិនទាន់មាននីតិសម្បទា ជាប់ពន្ធនាគារលើសពី៥ឆ្នាំ ជាប់កិច្ចសន្យាជាមួយរដ្ឋាភិបាល ។

-វិសមិតភាព : កងកំឡាំងប្រដាប់អាវុធ ជាប់បន្ទុកសាធារណ: មុខងារមានផលប្រយោជន៍ជាប្រាក់កាសក្នុងសេវារដ្ឋ ។

III-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ និងធម្មនុញ្ញ

១-សភាទាំងពីរមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។ សេចក្តីព្រាងវិសោធនកម្មរដ្ឋធម្មនុញ្ញ អាចដាក់ជូនព្រឹទ្ធសភាជាលើកដំបូង ដូចជាច្បាប់ធម្មតាឯទៀតៗ ។ ក្រោយពីបានអនុម័តសេចក្តីព្រាងច្បាប់រួចហើយ ព្រឹទ្ធសភា(រដ្ឋសភា) ត្រូវបញ្ជូនអត្ថបទនោះទៅរដ្ឋសភា(ព្រឹទ្ធសភា) ។

អត្ថបទត្រូវតែមានការយល់ព្រមពីសភាទាំងពីរ តាមសម្លេងភាគច្រើន លើកលែងតែវិសោធនកម្មរដ្ឋធម្មនុញ្ញដែលត្រូវយកតាមសម្លេងភាគច្រើន២ភាគ៣នៃសមាជិកសភាទាំងពីរ ។

បើសភាទាំងពីរខ្វែងគំនិតគ្នាលើអត្ថបទណាមួយ អត្ថបទនោះត្រូវដាក់ជូនសភាទាំងពីរប្រជុំរួមគ្នាជាសមាជ ។ បញ្ញត្តិនេះមិនអនុវត្តចំពោះវិសោធនកម្មរដ្ឋធម្មនុញ្ញទេ ។

សេចក្តីព្រាងដែលអនុម័តដោយសភាទាំងពីរ ត្រូវបញ្ជូនទៅប្រធានាធិបតីដើម្បីប្រកាសឱ្យប្រើ ។ ពេលបានទទួលការយល់ព្រមពីប្រធានាធិបតី សេចក្តីព្រាងនេះមានតម្លៃជាច្បាប់ ។

២-ព្រឹទ្ធសភាមិនមានអំណាចអ្វីចំពោះថវិកាទេ ។ អំណាចនេះជាអំណាចផ្តាច់មុខរបស់រដ្ឋសភា ។

ខ-អំណាចត្រួតពិនិត្យ

ពេលប្រជុំដាក់សំណួរត្រូវត្រៀមបំរុងទុកឱ្យរដ្ឋមន្ត្រីឆ្លើយនឹងសំណួររបស់សមាជិកព្រឹទ្ធ-សភា ។

IV-បទប្បញ្ញត្តិផ្សេងៗ

ប្រធានព្រឹទ្ធសភាជាឥស្សរជនទី២របស់រដ្ឋ ។ ប្រធានព្រឹទ្ធសភាទទួលជាប្រមុខរដ្ឋស្តីទីក្នុងករណីវិស្សមកាលរបស់ប្រមុខរដ្ឋ ។

មុិកសុិក **ព្រឹទ្ធសភា**

MEXIQUE LE SENAT

I-សមាសភាព

ព្រឹទ្ធសភាមុិកសុិកមានសមាជិក១២៨នាក់ ។

រដ្ឋនីមួយៗក្នុងចំណោមរដ្ឋទាំង៣១និងស្រុកសហព័ន្ធ(district fédéral) ដែលមានទីក្រុងមុិកសុិកូនិងទីជិតៗនោះមានពីរអាសនៈ ជ្រើសតាំងតាមសម្លេងភាគច្រើន ជាឯកត្តនាម (scrutin majorité uninominal) ត្រូវជា៦៤នាក់ និង១អាសនៈសំរាប់ជនជាតិភាគតិចទី១ (première minorité) ត្រូវជា៣២នាក់ទៀត ។

អាសនៈ ៣២ ដែលនៅសល់ត្រូវផ្តល់ឱ្យ តាមប្រព័ន្ធសមាមាត្រ ក្នុងកំរិតជាតិ ។

II-របបឆោះឆ្លោត

មណ្ឌលៈ៣២ (៣១រដ្ឋសហព័ន្ធនិង១ស្រុកសហព័ន្ធ)

ប្រព័ន្ធ :

-ឯកត្តនាម សម្លេងភាគច្រើន ចំពោះសមាជិកជ្រើសរើសក្នុងរដ្ឋនីមួយៗ និងតំបន់សហព័ន្ធ

-ពហុនាមលើបញ្ជី កំរិតជាតិ សំរាប់អាសនៈ៣២ ។

អាយុ : ២៥ឆ្នាំ

អាណត្តិ :៦ឆ្នាំ មិនអាចជាប់ជាថ្មីនៅអាណត្តិបន្ទាប់

ការផ្ទាស់ប្តូរចុងក្រោយ : ២កក្កដា ២០០០

សមាជិកបំរុងត្រូវជ្រើសរើសជាមួយសមាជិកពេញសិទ្ធិ ។

III-សម័យប្រជុំ

ក-សម័យប្រជុំសាមញ្ញ

ព្រឹទ្ធសភាមាន២សម័យប្រជុំសាមញ្ញក្នុង១ឆ្នាំ :

-លើកទី១:ថ្ងៃទី១ខែកញ្ញា ដល់ទី១៥ខែធ្នូ

-លើកទី២ៈ ថ្ងៃទី១៥ខែមិនាដល់ទី៣១ខែមេសា ។

ខ-សម័យប្រជុំវិសាមញ្ញ

ព្រឹទ្ធសភាប្រជុំជាវិសាមញ្ញ តាមការកោះរបស់គណៈកម្មការអចិន្ត្រៃយ៍នៃសមាជសហ-ភាព(Congrès de l'Union) ដែលមានសមាជិករដ្ឋសភា១៥នាក់ និងសមាជិកព្រឹទ្ធសភា១៨នាក់ តាមរបៀបវារៈយ៉ាងជាក់លាក់ ដែលបញ្ជាក់ក្នុងការកោះប្រជុំ ។

ព្រឹទ្ធសភា(ឬរដ្ឋសភា) អាចត្រូវកោះប្រជុំតែឯង ឬជាមួយសភាមួយទៀត ។

IV-ឧទាក់ឧទាចជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-ត់និតផ្តួចផ្តើមធ្វើច្បាប់

ត់និតផ្តួចផ្តើមនេះត្រូវអនុវត្តក្នុងក្របខ័ណ្ឌនៃច្បាប់ដែលកំរិតដោយរដ្ឋធម្មនុញ្ញ ។

២-សិទ្ធិវិសោធនកម្ម

ព្រឹទ្ធសភាមានសិទ្ធិធ្វើវិសោធនកម្មអត្ថបទ ដែលដាក់ឱ្យពិនិត្យ ។

៣-នីតិវិធីធ្វើច្បាប់

នីតិវិធីតោរពសមភាពរវាងសភាទាំងពីរ ។ សេចក្តីព្រាងច្បាប់ ត្រូវដាក់ពិភាក្សាជាលើកដំបូងនៅសភាណាមួយ លើកលែងតែច្បាប់ហិរញ្ញវត្ថុដែលរដ្ឋសភាត្រូវតែពិនិត្យជាលើកដំបូង ។

សេចក្តីព្រាងច្បាប់ត្រូវតែពិនិត្យដោយគណៈកម្មការណាមួយជាចាំបាច់ មុនការពិភាក្សានៅសម័យប្រជុំពេញអង្ត ។

ខ-អំណាចត្រួតពិនិត្យ

១-ព្រឹទ្ធសភាអាចបង្កើតគណៈកម្មការអង្កេត

២-ព្រឹទ្ធសភាផ្តល់ ការយល់ ព្រមលើសន្ធិសញ្ញា និងអនុសញ្ញាការទូត ។

ព្រឹទ្ធសភាមានសិទ្ធិផ្តាច់មុខក្នុងៈ

-ការពិភាក្សាលើនយោបាយក្រៅប្រទេស លើមូលដ្ឋាននៃរបាយការណ៍ប្រចាំឆ្នាំរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ និងរបស់រដ្ឋមន្ត្រីការបរទេស

-ផ្តល់ការយល់ព្រមលើសន្ធិសញ្ញាអន្តរជាតិ និងលើអនុសញ្ញាការទូត

-ផ្តល់សច្ចាប៉ន់លើការតែងតាំងអគ្គរដ្ឋអាជ្ញា រដ្ឋមន្ត្រីនានា ភ្នាក់ងារការទូត អគ្គកុងស៊ុល មន្ត្រីជាន់ខ្ពស់នៃក្រសួងហិរញ្ញវត្ថុ នាយទាហានជាន់ខ្ពស់នៃម៉ាតូ្រណើង ម៉ាតូ្រណើងទឹកនិងម៉ាតូ្រអាកាស

-អនុញ្ញាតឱ្យបញ្ជូនម៉ាតូ្រទៅបរទេស ឱ្យកងម៉ាតូ្របរទេសចូលមកក្នុងប្រទេសឬការសំចតនៃកងនាវាចម្បាំងបរទេសលើដែនទឹកយៈពេលលើសពី១ខែ

-អនុញ្ញាតឱ្យប្រធានាធិបតីនៃសាធារណរដ្ឋធ្វើការចល័ត ឆ្នាំជាតិទៅក្រៅរដ្ឋដើមរបស់ខ្លួន

-តែងតាំងអគ្គទេសាភិបាល១នាក់ ឱ្យទទួលបន្ទុករៀបចំការចោះឆ្នោតនៅរដ្ឋណា ដែលអំណាចសាធារណៈចុះថមថយ

-កាត់សេចក្ដីពាក្យបណ្ដឹងតវ៉ាដែលរៀបចំដោយស្ថាប៉ន់មួយ ឬច្រើនរបស់រដ្ឋមួយក្នុងករណីដែលមានការខ្វែងយោបល់ គ្នា ។ ការកាត់សេចក្ដីជាអាជ្ញាកណ្ដាលត្រូវស្របនឹងរដ្ឋធម្មនុញ្ញ សហភាព និងច្បាប់រដ្ឋដែលពាក់ព័ន្ធ

-បង្កើតឱ្យមានការកាត់សេចក្ដីដើម្បីរកកំហុសដែលភ្នាក់ងារសាធារណៈបានប្រព្រឹត្ត

-ផ្តល់ការយល់ព្រមលើការតែងតាំងសមាជិកតុលាការយុត្តិធម៌កំពូល និងទទួលយកឬមិនទទួលយកការសុំលាលែងឬការបណ្ដេញចេញ តាមសំណើរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ។

-បង្កើតនៅឆ្នាំ :១៩៩៣

-តំណាងសម្ព័ន្ធភាពដែនដី

-សភាត្រួតពិនិត្យ ។

I-សមាសភាព

ក្រុមប្រឹក្សាជាតិមានសមាជិក២៦នាក់ (២នាក់ក្នុង១តំបន់ ក្នុងចំណោម១៣តំបន់) ។

II-របបបោះឆ្នោត

មិនចំពោះ ភាគីតំបន់ ។ តំបន់នីមួយ១មានប្រព័ន្ធបោះឆ្នោតរៀងខ្លួន ។

អាណត្តិ : ៦ឆ្នាំ

ការរៀបចំចុងក្រោយ : ២៩ និង៣០វិច្ឆិកា ២០០៤

វិសមិតភាព :សមាជិកជាប់ឆ្នោតនៃអាជ្ញាធរមូលដ្ឋាន មន្ត្រីទទួលប្រាក់ឈ្នួលសិទ្ធ ជនដែលមានទោសពីបទរំលោភណាមីប៊ី តាំងពីបានឯកភាព អ្នកកាន់ឃុយធនដែលមិនមានធានិសម្បទា ។

III-សម័យប្រជុំ

សម័យប្រជុំអាស្រ័យទៅតាមកម្មវិធីសម័យប្រជុំរដ្ឋសភា ដែលមានកំណត់ពេលវេលាជាពីរសម័យប្រជុំប្រចាំឆ្នាំ (កុម្ភៈដល់ វិច្ឆិកា អាក់ខានតែខែកក្កដា និងសីហា) ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិបញ្ញត្តិ

ច្បាប់ដែលរដ្ឋសភាបានអនុម័ត ត្រូវដាក់ស៊ីសង្គមពីក្រុមប្រឹក្សាជាតិ ដោយប្រធានរដ្ឋសភា ។ វិសោធនកម្មអាចត្រូវស្នើឡើង ។

១-ពាក្យផ្តួចផ្តើមធ្វើច្បាប់ : ត្រូវ

២-សិទ្ធិវិសោធនកម្ម : មាន

៣-នីតិវិធីធ្វើច្បាប់

សេចក្តីព្រាងច្បាប់ត្រូវដាក់ជូនរដ្ឋសភា ដែលពេលចប់ការពិនិត្យ៣លើក (3 lectures) ត្រូវបញ្ជូនទៅក្រុមប្រឹក្សាជាតិ ដែលបន្តនីតិវិធីមួយចម្លា ។ ក្រុមប្រឹក្សាជាតិពិនិត្យច្បាប់ដែលបញ្ជូនមក និងធ្វើរបាយការណ៍ដែលមានអនុសាសន៍ ។បើរបាយការណ៍យល់ស្របតាមសេចក្តីព្រាងច្បាប់ អាចប្រកាសឱ្យប្រើ ។

ក្រុមប្រឹក្សាជាតិអាចបដិសេធសេចក្តីព្រាងវិសោធនកម្ម ឬបញ្ជូនត្រឡប់ទៅវិញ ដោយគ្មានវិសោធនកម្ម ។

បើអត្ថបទត្រូវបញ្ជូនទៅវិញដោយគ្មានវិសោធនកម្ម អត្ថបទនោះត្រូវប្រកាសឱ្យប្រើ ។

បើក្រុមប្រឹក្សាស្នើវិសោធនកម្ម សេចក្តីព្រាងច្បាប់ត្រូវបញ្ជូនត្រឡប់ទៅរដ្ឋសភាវិញ ។ រដ្ឋសភាត្រូវពិនិត្យសាជាថ្មីនិងអាចធ្វើវិសោធនកម្មតាមទំនងរបស់ក្រុមប្រឹក្សាឬតាមទំនងផ្សេង ។

អត្ថបទដែលមានវិសោធនកម្មឬគ្មាន មិនបញ្ជូនទៅក្រុមប្រឹក្សាវិញទេ ។អត្ថបទនោះត្រូវបញ្ជូនទៅប្រធានាធិបតី ដើម្បីប្រកាសឱ្យប្រើ ។

សេចក្តីព្រាងអាចត្រូវបានបដិសេធ តាមសម្លេងភាគច្រើន២/ ៣នៃសមាជិកក្រុមប្រឹក្សាជាតិ(មូលហេតុត្រូវបញ្ជាក់ក្នុងរបាយការណ៍) ។ ក្នុងករណីនេះ វិសោធនកម្មក៏ត្រូវបញ្ជាក់ក្នុងរបាយការណ៍ដែរ ។ សេចក្តីព្រាងត្រូវបញ្ជូនទៅរដ្ឋសភាវិញ ដែលអាចតាំទ្រលើសេចក្តីព្រាង តាមសម្លេងភាគច្រើន២/ ៣នៃសមាជិករបស់ខ្លួន និងបញ្ជូនទៅប្រធានាធិបតីដើម្បីប្រកាសឱ្យប្រើ ។ ករណីផ្ទុយពីនេះ បើមិនមានវិសោធនកម្ម អត្ថបទត្រូវបដិសេធ ។

បញ្ញត្តិនេះមិនអនុវត្តចំពោះសេចក្តីព្រាងច្បាប់ទាក់ទងនឹងការលើកលែងពន្ធ និងការប្រើប្រាស់មូលនិធិសាធារណៈទេ ។

ក្រុមប្រឹក្សាជាតិមានពេល៣ខែ ដើម្បីដាក់របាយការណ៍ ។ បើមិនបានធ្វើក្នុងពេលកំណត់នេះទេ ត្រូវចាត់ទុកថាយល់ព្រម ។

ដើម្បីឱ្យក្រុមប្រឹក្សាជាតិអាចអនុវត្តអំណាច និងបំពេញមុខងាររបស់ខ្លួន ចាំបាច់ត្រូវមាន

វត្តមាននៃសមាជិកក្រុមប្រឹក្សាចំនួនភាគច្រើន ។

បញ្ហានានាត្រូវអនុម័តតាមសម្លេងភាគច្រើននៃសមាជិកវត្តមាន ។ ក្នុងករណីសម្លេងបែកជាពីរស្មើ ប្រធានអង្គប្រជុំមានសិទ្ធិអនុម័ត ។

ខ-អំណាចត្រួតពិនិត្យ

ក្រុមប្រឹក្សាជាតិបំពេញមុខងារជូចជាសភាត្រួតពិនិត្យ ។

ក្រុមប្រឹក្សាដឹកនាំការស៊ើបអង្កេតលើបញ្ហាខ្លះក្នុងកំរិតតំបន់ ។

V-ចនប្បញ្ញត្តិដោយឡែក

ក-ការកែប្រែរដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញអាចត្រូវទុកជាមោឃៈ ឬវិសោធនកម្មដោយសភាទាំងពីរជាសមាជ តាមសម្លេងភាគច្រើន២/៣នៃសមាជិកសភានីមួយ១ ។ បើមិនអាចរកសម្លេងភាគច្រើននេះបានទេ ប្រធានាធិបតីអាចដាក់ធ្វើប្រជាមតិ ។

ខ-ប្រធានក្រុមប្រឹក្សាជាតិ

ប្រធានក្រុមប្រឹក្សាជាតិត្រូវជ្រើសរើស សំរាប់រយៈពេល៦ឆ្នាំ ។ ប្រធានក្រុមប្រឹក្សាជាតិជាឥស្សរជនទី៤ ជាអ្នកឃ្លាំមើលធម្មនុញ្ញភាពរបស់ច្បាប់ និងមានសម្លេងនុត្តមានុភាពក្នុងការអនុម័ត ។

សាធារណរដ្ឋដូមីនីកែន	**ព្រឹទ្ធសភា**
LA REPUBLIQUE DOMONICAINE	LE SENAT

I-សមាសភាព

សមាជិកព្រឹទ្ធសភា : ៣០រូប ជ្រើសរើសដោយផ្ទាល់ ដែលមាន១អាសនៈសម្រាប់១ខេត្ត និង១អាសនៈសម្រាប់តំបន់ថ្នាក់ជាតិ ។

II-របបបោះឆ្នោត

ប្រព័ន្ធ : ឯកត្តនាម សម្លេងភាគច្រើន ដោយផ្ទាល់

អាណត្តិ : ៤ឆ្នាំ

ការផ្លាស់ប្តូរចុងក្រោយ:១៦ ឧសភា ២០០២

លក្ខខណ្ឌ: អាយុ ២៥ឆ្នាំ ពលរដ្ឋដូមីនីកែន មានសិទ្ធិស៊ីវិល និងនយោបាយ កើត ឬរស់នៅក្នុងមណ្ឌលជាប់រយៈពេល៥ឆ្នាំ ។

វិសមិតភាព : មុខងារសាធារណៈ

លក្ខខណ្ឌជាតំណាង : តែងតាំងដោយគណបក្សនយោបាយណាមួយដែលមានការទទួលស្គាល់ដោយអង្គការបោះឆ្នោតកណ្តាល ។

III-សម័យប្រជុំ

ក-សម័យប្រជុំសាមញ្ញ

ព្រឹទ្ធសភាមាន២សម័យប្រជុំក្នុង១ឆ្នាំ ដែលបើកនៅថ្ងៃទី២៧ខែកុម្ភៈ និង១៦ ខែសីហា ។ សម័យប្រជុំនីមួយៗមានរយៈពេល៩០ថ្ងៃ ។ រយៈពេលនេះអាចពន្យារ ៦០ ថ្ងៃយ៉ាងច្រើន ។

ខ-សម័យប្រជុំវិសាមញ្ញ

១-សភាទាំងពីរប្រជុំជាវិសាមញ្ញ តាមការកោះប្រជុំរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ។

២-ម្យ៉ាងទៀត ព្រឹទ្ធសភាអាចកោះប្រជុំជាវិសាមញ្ញ តាមការផ្តើមគំនិតរបស់ប្រធាន ឬតាមការស្នើសុំរបស់សមាជិកព្រឹទ្ធសភាមួយចំនួន ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

សមាជនៃសាធារណរដ្ឋមានព្រឹទ្ធសភា និងរដ្ឋសភា ។

ក-អំណាចនីតិប្បញ្ញត្តិ

របបសភាពីរសមភាព(Bicamérisme égalitaire) ។

១-ឥទ្ធិពលផ្តួចផ្តើមធ្វើច្បាប់

ព្រឹទ្ធសភាមានសិទ្ធិផ្តួចផ្តើមឥទ្ធិពលធ្វើច្បាប់ ដូចជាសមាជិករដ្ឋសភា និងប្រធានាធិបតីនៃសាធារណរដ្ឋ ។

មានសិទ្ធិផ្តួចផ្តើមឥទ្ធិពលធ្វើច្បាប់ដែរៈចៅក្រមតុលាការយុត្តិធម៌កំពូល ក្នុងវិស័យតុលាការ និងសមាជិកអង្គការបោះឆ្នោត ក្នុងការងារបោះឆ្នោត ។

២-សិទ្ធិវិសោធនកម្ម

ព្រឹទ្ធសភាមានសិទ្ធិវិសោធនកម្ម ។

៣-នីតិវិធីធ្វើច្បាប់

ក-នីតិវិធីធម្មតា

សេចក្តីព្រាងច្បាប់អាចដាក់ជូនសភាណាមួយក็ได้ ។

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលដាក់ជូនសភាណាមួយត្រូវដាក់ធ្វើការពិភាក្សាពីរពេល ដែលមានចន្លោះពីគ្នាយ៉ាងតិច១ថ្ងៃ លើកលែងតែក្នុងករណីដែលមានការប្រកាសជាមុនថាជាការប្រញាប់(អត្ថបទត្រូវដាក់ពិភាក្សាពីរពេលជាប់គ្នា) ។

ម្ហូសសេចក្តីព្រាងច្បាប់អាចការពារសេចក្តីព្រាងរបស់ខ្លួន ក្នុងសភាមួយទៀត ។

ពេលអនុម័តរួច អត្ថបទត្រូវដាក់ជូនសភាមួយទៀត ដែលប្រើនីតិវិធីដូចគ្នា ។

បើវិសោធនកម្មត្រូវបានអនុម័ត សេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ត្រូវបញ្ជូន ដោយមានទាំងការកែប្រែទៅសភាដែលពិនិត្យនៅលើកដំបូង ។ បើសភា(ពិនិត្យលើកដំបូង) នេះអនុម័តនូវការកែប្រែទាំងនេះ ច្បាប់ត្រូវបញ្ជូនទៅប្រធានាធិបតីនៃសាធារណរដ្ឋដើម្បីប្រកាសឱ្យប្រើ ។ បើត្រូវបដិសេធ អត្ថបទត្រូវច្រានចោល ។

សេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ដែលបដិសេធដោយសភាណាមួយអាចត្រូវបានដាក់ជាថ្មីនៅនីតិកាលបន្ទាប់ ។

សេចក្តីសម្រេចរបស់ព្រឹទ្ធសភាត្រូវយកតាមសម្លេងភាគច្រើននៃអ្នកដែលបានបោះ លើកលែងតែសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ណាប្រកាសជាមុនថាជាការប្រញាប់(សម្លេងភាគច្រើន២/៣នៃអ្នកដែលបានបោះ នៅការអានលើកទី២) ។

ខ-បទប្បញ្ញត្តិសម្រាប់ហិរញ្ញវត្ថុសាធារណៈ

ចំពោះច្បាប់ហិរញ្ញវត្ថុ ឬច្បាប់ដែលទាក់ទងនឹងហិរញ្ញវត្ថុសាធារណៈ ការអនុម័តត្រូវយកយកតាមសម្លេងភាគច្រើន២/៣នៃសមាជិកសភានីមួយៗ ។

គ-សំណើពិភាក្សាជាថ្មី

ប្រធានាធិបតីនៃសាធារណរដ្ឋមានសិទ្ធិស្នើសុំពិភាក្សាជាថ្មីលើសេចក្តីព្រាងច្បាប់នៅសភាដែលពិនិត្យលើកចុងក្រោយ ។

ច្បាប់ត្រូវចាត់ទុកថាជាស្ថាពរ បើសភាទាំងពីរអនុម័តជាថ្មី តាមសម្លេងភាគច្រើន២/៣នៃសមាជិកសភានីមួយៗ ។

សម័យប្រជុំត្រូវពន្យារ បើចាំបាច់ រហូតដល់ចប់ការពិនិត្យ ។

ខ-អំណាចត្រួតពិនិត្យ

-ការសួរដេញដោល

ព្រឹទ្ធសភាមានសិទ្ធិកោះហៅមកសួរដេញដោលនូវរដ្ឋមន្ត្រី (រដ្ឋលេខាធិការ) នាយក ឬអភិបាលនៃអង្គការស្វយ័តរបស់រដ្ឋលើវិស័យជាសមត្ថកិច្ច ដោយការសម្រេច តាមសម្លេងភាគច្រើន២/ ៣នៃសមាជិកវត្តមាន តាមសំណើរបស់សមាជិកណាម្នាក់របស់ខ្លួន ។

២-ការអនុម័តលើការអនុវត្តថវិកា

ពេលចាប់ផ្តើមសម័យប្រជុំនីមួយៗ នៅថ្ងៃទី២៧កុម្ភៈ ប្រធានាធិបតីធ្វើសេចក្តីថ្លែងការណ៍អំពីការគ្រប់គ្រងក្នុងឆ្នាំមុន ។របាយការណ៍នានារបស់រដ្ឋលេខាធិការ និងរបស់តុលាការគណនីត្រូវដាក់សុំការអនុម័តពីសភា ។សភានីមួយអនុម័តលើរបាយការណ៍លំអិតរបស់គណៈកម្មការថវិកា ។

V-បទប្បញ្ញត្តិដោយឡែក

ក-ការសើរើរដ្ឋធម្មនុញ្ញ

ការដាក់សេចក្តីស្នើច្បាប់សើរើរដ្ឋធម្មនុញ្ញអាចធ្វើឡើងដោយសមាជិក១/៣នៃសភាណាមួយ ។

ការសើរើរដ្ឋធម្មនុញ្ញត្រូវអនុម័តតាមសម្លេងភាគច្រើន២/៣ ។

ទម្រង់នៃសាធារណរដ្ឋ ស៊ីវិល ប្រជាធិបតេយ្យ និងភាពជាតំណាងរបស់រដ្ឋមិនអាចធ្វើការសើរើបានឡើយ ។

ខ-ការបង្កើតការិយាល័យ

នៅថ្ងៃទី១៦ សីហា រាល់ឆ្នាំ ព្រឹទ្ធសភាជ្រើសតាំងការិយាល័យ(ប្រធាន អនុប្រធាន១រូប និងលេខាធិការ២រូប) របស់ខ្លួន ។

គ-ការប្រជុំជាសភាជាតិ

រដ្ឋសភា និងព្រឹទ្ធសភាប្រជុំជាសភាជាតិ ក្នុងករណីដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។ ចំនួនពាក់កណ្តាលនៃសមាជិកសភានីមួយៗត្រូវមានវត្តមាន ហើយសេចក្តីសម្រេចត្រូវយកតាមសម្លេងភាគច្រើនដាច់ខាត ។

ប្រធានព្រឹទ្ធសភាជាប្រធានអង្គប្រជុំសភាជាតិ ឬជាការប្រជុំរួម និងប្រធានរដ្ឋសភាជាអនុប្រធានអង្គប្រជុំ ។

ដូចគ្នានេះដែរ ចំពោះអង្គប្រជុំស្តាប់សាររបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ប្រជុំទទួលសម្បថរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ដែលទើបជាប់ឆ្នោតថ្មី ឬទទួលការលាលែងរបស់ប្រធានាធិបតី ។

សភាទាំងពីរអាចប្រជុំរួមដើម្បីស្តាប់សារប្រចាំឆ្នាំរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ។

មុនចូលកាន់តំណែង ប្រធានាធិបតី និងអនុប្រធានាធិបតីធ្វើសច្ចាប្រណិធានចំពោះមុខសភាជាតិ ។

ឃ-អំណាចជុំនំជម្រះ

ព្រឹទ្ធសភាជាចៅក្រមកាត់សេចក្តី តាមការចោទប្រកាន់របស់រដ្ឋសភា (តាមសម្លេងភាគច្រើន៧/៤) ប្រឆាំងមន្ត្រីសាធារណៈដែលមានកិរិយាមារយាទមិនល្អឬដែលមានកំហុសធ្ងន់ធ្ងរក្នុងការបំពេញមុខងារ ។

ទោសតែមួយដែលព្រឹទ្ធសភាអាចដាក់បាន (តាមសម្លេងភាគច្រើន៧/ ៤) គឺការទម្លាក់ពីតំណែង ។

ង-តុលាការកំពូល

ប្រធានព្រឹទ្ធសភា(និងសមាជិកព្រឹទ្ធសភា១រូបនៃគណបក្សប្រឆាំង) ជាសមាជិកតុលាការ

យុត្តិធម៌កំពូល ។

តុលាការកំពូលធ្វើការចោទប្រកាន់អំពីបទព្រហ្មទណ្ឌប្រឆាំងសមាជិកសភា រដ្ឋមន្ត្រី ឬ ប្រធានាធិបតីនៃសាធារណរដ្ឋ ។

ច-ស្ថានភាពសង្គ្រាម និងស្ថានភាពអាសន្ន

សភាមានសិទ្ធិប្រកាសស្ថានភាពសង្គ្រាមឬភ័យន្តរាយសាធារណៈឬស្ថានភាពអាសន្ន ក្នុងករណីគ្រោះថ្នាក់ធ្ងន់ធ្ងរ និងតំរាមកំហែងដល់អធិបតេយ្យជាតិ ។

ឆ-អំណាចតែងតាំង

ព្រឹទ្ធសភា :

-ផ្តល់ការយល់ព្រមលើការតែងតាំងសមាជិកអង្គទូត

-ជ្រើសរើសប្រធាននិងសមាជិកក្រុមប្រឹក្សាបោះឆ្នោតជាតិ និងអ្នកបំរុង

-ជ្រើសរើសសមាជិកតុលាការគណនី ។

របបសភាពីរជាវិបាកនៃជម្រើសធម្មនុញ្ញឆ្នាំ១៩២០ ជាគំរូសម្រាប់តាក់តែងរដ្ឋធម្មនុញ្ញ ថ្មីឆ្នាំ១៩៩២ ។ ប៉ុន្តែមានបញ្ហាជាច្រើន ក្រោយពីអនុម័តរដ្ឋធម្មនុញ្ញរួច អំពីការបង្កើតសភាទី២ ។ រហូតដល់ឆ្នាំ១៩៩៦ គឺ៤ឆ្នាំបន្ទាប់មក ទើបព្រឹទ្ធសភាបានកើតជារូបរាងឡើង ។

I-សមាសភាព

ព្រឹទ្ធសភាឆែកមានសមាជិក៨១រូប ។

II-របបបោះឆ្នោត

ប្រទេសទាំងមូលចែកជា៨១មណ្ឌលបោះឆ្នោត ។ ក្នុងមណ្ឌលនីមួយៗ អ្នកបោះឆ្នោតបោះជ្រើសរើសដោយផ្ទាល់នូវសមាជិកព្រឹទ្ធសភា១រូប ក្នុងចំណោមបេក្ខជនដែលស្នើដោយគណបក្សនយោបាយ ឬបេក្ខជនអព្យាក្រិត្ស ។

ការបោះឆ្នោតធ្វើតាមប្រព័ន្ធឯកត្តនាម សម្លេងភាគច្រើន ជា២ជុំ ។

បេក្ខជនដែលបានទទួលសម្លេងភាគច្រើនដាច់ខាតនៅជុំទី១ ត្រូវបានជាប់ឆ្នោត ។ បើមិនដូច្នេះទេ ត្រូវដំណើរការបោះនៅជុំទី២រវាងបេក្ខជន២រូបដែលបានសម្លេងច្រើនជាងគេ ។ បេក្ខជនដែលបានទទួលសម្លេងភាគច្រើននៅជុំទី២ ត្រូវបានជាប់ឆ្នោត ។

អាណត្តិ : ៦ឆ្នាំ

ព្រឹទ្ធសភាត្រូវធ្វើការផ្លាស់ប្តូរថ្មី១៣ រៀងរាល់២ឆ្នាំ ។

ការផ្លាស់ប្តូរចុងក្រោយ : ២០ តុលា ២០០៦ ។

លក្ខខណ្ឌ : អាយុ ៤០ឆ្នាំ ជាពលរដ្ឋឆែក មានសិទ្ធិបោះឆ្នោត ។

វិសមិតភាព : មុខងារជាប្រធានាធិបតីនៃសាធារណរដ្ឋ សមាជិករដ្ឋសភា នាយកអង្គប្រតិបត្តិមូលដ្ឋាននិងមុខងារជាចៅក្រម រដ្ឋអាជ្ញា និងមជ្ឈត្តករ ។

III-សម័យប្រជុំ

ព្រឹទ្ធសភាប្រជុំជាអចិន្ត្រៃយ៍ ។ សម័យប្រជុំអាចត្រូវព្យួរ តាមការសម្រេចចិត្តរបស់ព្រឹទ្ធសភា ប៉ុន្តែ ក-រយៈពេលសរុបទាំងអស់នៃការព្យួរមិនអាចលើសពី ១២០ថ្ងៃក្នុង១ឆ្នាំ និង ខ-ការព្យួរអាចមាននៅពេលដែលសភាជាន់ទាបរលាយ ។

ប្រធានព្រឹទ្ធសភាអាចបង្ហូញរយៈពេលព្យូរ និងកោះប្រជុំព្រឹទ្ធសភាឡើងវិញ បើមានសំណើពីប្រធានាធិបតីនៃសាធារណរដ្ឋ រដ្ឋាភិបាល ឬសមាជិកព្រឹទ្ធសភាចំនួន១/៥ ។

IV-ឧំនាក់ឧំនងជាមួយរដ្ឋសភា និងអំណាចនីតិប្បញ្ញត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-តំនិតផ្តួចផ្តើមធ្វើច្បាប់

តាមការផ្ទួចផ្តើមរបស់សមាជិកព្រឹទ្ធសភា១ក្រុម ឬរបស់គណៈកម្មការណាមួយ ព្រឹទ្ធសភាអនុម័តសេចក្តីសម្រេចចិត្តដើម្បីដាក់សេចក្តីស្នើច្បាប់ ។ សិទ្ធិនេះអនុវត្តផ្ទួចគ្នានឹងសមាជិករដ្ឋសភាក្រុមនយោបាយនៅរដ្ឋសភា រដ្ឋាភិបាល ឬសភាតំណាងដែនដី ។

តំនិតផ្តួចផ្តើមក្នុងវិស័យច្បាប់ហិរញ្ញវត្ថុ និងច្បាប់នៃបទបញ្ជា (loi de règlement) ជាសិទ្ធិផ្តាច់មុខរបស់រដ្ឋាភិបាល ។

ខ-សិទ្ធីវិសោធនកម្ម

ព្រឹទ្ធសភាអាចធ្វើវិសោធនកម្មអត្ថបទច្បាប់ដែលកំពុងពិភាក្សា ។

ព-នីតិវិធីធ្វើច្បាប់ធម្មតា

ការពិនិត្យអត្ថបទត្រូវចាប់ផ្តើមពីរដ្ឋសភា ទោះបីជាអត្ថបទដែលដាក់ដោយព្រឹទ្ធសភាក៏ដោយ ។

ក្រោយពេលអនុម័តដោយរដ្ឋសភា អត្ថបទត្រូវបញ្ជូនមកព្រឹទ្ធសភា(លើកលែងតែច្បាប់ហិរញ្ញវត្ថុ និងច្បាប់នៃបទបញ្ជាដែលត្រូវពិនិត្យនិងអនុម័តតែនៅរដ្ឋសភា) ។

បើក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីការបញ្ជូនរបស់រដ្ឋសភា ព្រឹទ្ធសភាអនុម័តយល់ព្រមលើអត្ថបទឬសម្រេចមិនពិនិត្យ ឬមិនអនុម័ត ពេលនោះអត្ថបទត្រូវចាត់ទុកថាបានអនុម័តជាស្ថាពរ ។

បើក្នុងរយៈពេល៣០ថ្ងៃ ព្រឹទ្ធសភាបដិសេធអត្ថបទ ឬអនុម័តដោយមានវិសោធនកម្ម អត្ថបទត្រូវបញ្ជូនត្រឡប់ទៅរដ្ឋសភាវិញដើម្បីពិនិត្យជាលើកទី២ ។

ការទទួលយកចំណែកណាមួយនៃវិសោធនកម្ម ឬការដាក់វិសោធនកម្មថ្មីមិនអាចធ្វើបានឡើយក្នុងដំណាក់កាលនេះ ។

សមាជិករដ្ឋសភាអាចត្រឹមតែរក្សាទុកអត្ថបទដែលខ្លួនបានអនុម័តមុនបញ្ជូនទៅព្រឹទ្ធសភា ឬអនុម័តអត្ថបទដែលមានវិសោធនកម្មរបស់ព្រឹទ្ធសភា ។

ដើម្បីបញ្ចប់ការជំទាស់របស់ព្រឹទ្ធសភា និងរក្សាអត្ថបទដើមរបស់ខ្លួន រដ្ឋសភាត្រូវអនុម័ត តាមសម្លេងភាគច្រើន ។

អត្ថបទដែលបានអនុម័តជាស្ថាពរដោយសភា ត្រូវបញ្ជូនទៅប្រធានាធិបតីនៃសាធារណរដ្ឋ ដើម្បីប្រកាសឱ្យប្រើ ។ប្រធានាធិបតីអាចបញ្ជូនអត្ថបទត្រឡប់ទៅសភាវិញ ក្នុងរយៈពេល១៥ថ្ងៃ ដោយមានបង្ហាញមូលហេតុ លើកលែងតែច្បាប់សើរើរដ្ឋធម្មនុញ្ញ ។ រដ្ឋសភាពិនិត្យជាថ្មីឡើងវិញ លើអត្ថបទទាំងមូល ដោយមិនអាចបញ្ជូលវិសោធនកម្មថ្មីទេ ។បើសិនជាអត្ថបទត្រូវបានរក្សាទុក ដោយរដ្ឋសភា តាមសម្លេងភាគច្រើនដាច់ខាត អត្ថបទត្រូវបានប្រកាសឱ្យប្រើ ។

៤-នីតិវិធីដោយឡែក

ការងារដែលទាក់ទងនឹងមាត្រា៤០នៃរដ្ឋធម្មនុញ្ញ (ច្បាប់ចោះឆ្នោត ច្បាប់ទាក់ទងនឹងព្រឹទ្ធសភា ច្បាប់ទាក់ទងនឹងសភាទាំងពីរនិងច្បាប់ទាក់ទងរវាងសភាទាំងពីរនិងស្ថាប័នឯទៀត) ត្រូវតែអនុម័តដោយសភាទាំងពីរ ។

ច្បាប់ស្តីពីហិរញ្ញវត្ថុ និងច្បាប់ស្តីពីបទបញ្ជាត្រូវអនុម័តតែដោយរដ្ឋសភា ។

បើរដ្ឋសភារលាយ ក្នុងករណីប្រញាប់ និងតាមសំណើរបស់រដ្ឋាភិបាល ព្រឹទ្ធសភាអាចអនុម័តច្បាប់ក្នុងវិស័យដែលរដ្ឋសភាត្រូវអនុម័ត លើកលែងតែច្បាប់ដែលទាក់ទងនឹងរដ្ឋធម្មនុញ្ញ ប្រព័ន្ធចោះឆ្នោត គណនី និងហិរញ្ញវត្ថុសាធារណៈ និងច្បាប់ច្បាប់ផ្ទល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិអំពីសិទ្ធិនិងសេរីភាពជាមូលដ្ឋាន ។

បទដ្ឋានគតិយុត្តទាំងនេះត្រូវអនុម័តដោយរដ្ឋសភានៅពេលប្រជុំដ៏ឆាប់ខាងមុខ បើមិនដូច្នេះទេ ត្រូវអស់សុពលភាព ។

៥-អំណាចត្រួតពិនិត្យ

ព្រឹទ្ធសភាមិនអាចបង្កើតគណៈកម្មការស៊ើបអង្កេត និងដាក់សំណូរចំពោះរដ្ឋាភិបាលទេ ។

ក្នុងវិស័យអន្តរជាតិ ការអនុម័តយល់ព្រមពីសភាទាំងពីរជាការចាំបាច់ ចំពោះសន្ធិសញ្ញា:

-អំពីសិទ្ធិនិងករណីកិច្ចបុគ្គល

-អំពីសម្ព័ន្ធភាពអន្តរជាតិ និងកិច្ចព្រមព្រៀងសន្តិភាព

-អំពីការចូលរួមរបស់រដ្ឋក្នុងអង្គការអន្តរជាតិ

-អំពីបទប្បញ្ញត្តិទាក់ទងនឹងច្បាប់

-ដែលមានលក្ខណៈសេដ្ឋកិច្ចទូទៅ ។

ម្យ៉ាងទៀត ការអនុម័តយល់ព្រមតាមសម្លេងភាគច្រើន៣៥នៃសមាជិកព្រឹទ្ធសភា និង និង ៣៥នៃសមាជិករដ្ឋសភា ក៏ជាការចាំបាច់ដែរចំពោះការផ្តល់សច្ចាប័នលើសន្ធិសញ្ញាផ្ទេរអង្គការអន្តរជាតិដែលសមត្ថកិច្ចរបស់ខ្លួនកាន់កាប់ដោយស្ថាប័ននៃសាធារណរដ្ឋនៃក ។

ค-ទំនាក់ទំនងជាមួយប្រធានាធិបតីនៃសាធារណរដ្ឋ

១-ការចូលរួមក្នុងពេលប្រជុំសភា

ប្រធានាធិបតីនៃសាធារណរដ្ឋអាចចូលតាមដានការប្រជុំសភាទាំងពីរ និងការប្រជុំរបស់គណៈកម្មការនានា ។ ប្រធានាធិបតីអាចមានយោបល់ចាន បើលោកស្នើសុំ ។

២-ការជ្រើសរើសប្រធានាធិបតីនៃសាធារណរដ្ឋ

បេក្ខជនប្រធានាធិបតីណាម្នាក់ត្រូវស្នើឡើងដោយសមាជិករដ្ឋសភាយ៉ាងតិច១០រូប ឬសមាជិកព្រឹទ្ធសភាយ៉ាងតិច១០រូប ។

បេក្ខជនដែលទទួលបានសម្លេងឆ្នោតភាគច្រើនដាច់ខាតព្រមគ្នាទាំងនៅរដ្ឋសភា និងនៅព្រឹទ្ធសភាត្រូវបានជាប់ឆ្នោត ។ បើមិនដូច្នេះទេ ការបោះឆ្នោតជាលើកទី២ត្រូវធ្វើ ក្នុងរយៈពេល ២សប្តាហ៍:បេក្ខជនដែលបានទទួលសម្លេងឆ្នោតភាគច្រើនដោយប្រៀប(majorité relative) ព្រមគ្នាទាំងនៅរដ្ឋសភា និងនៅព្រឹទ្ធសភាត្រូវបានជាប់ឆ្នោត ។ បើមិនដូច្នេះទេ ត្រូវបោះជាលើកទី៣ តាមរបៀបដូចគ្នា ក្នុងរយៈពេល២សប្តាហ៍ ។ បើនៅលើកទី៣ នៅតែមិនមានអ្នកជាប់ឆ្នោតទៀត ត្រូវរៀបចំបោះឆ្នោតជ្រើសរើសប្រធានាធិបតីជាថ្មី ។

៣-ការចោទប្រកាន់ប្រធានាធិបតី

ព្រឹទ្ធសភាធ្វើការចោទប្រកាន់ប្រធានាធិបតីអំពីបទល្មើស ។ តុលាការធម្មនុញ្ញជាអ្នកសម្រេចសេចក្តី ។

៤-វិស្សមកាលរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ

ក្នុងករណីវិស្សមកាល បើសភាត្រូវរលាយ ប្រធានព្រឹទ្ធសភាទទួលជាស្តីទីដើម្បីបំពេញមុខងារខ្លួនរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ (តែងតាំង ឬទទួលការលាលែងរបស់រដ្ឋាភិបាល តែងតាំងចៅក្រមតុលាការធម្មនុញ្ញ ឬសមាជិកក្រុមប្រឹក្សាធនាគារជាតិនៃសាធារណរដ្ឋ ពោះប្រជុំរដ្ឋសភា) ។

V-បទប្បញ្ញត្តិផ្សេងៗ

ក-វិស័យធម្មនុញ្ញ

១-ការសើរើរដ្ឋធម្មនុញ្ញ

អត្ថបទសើរើរដ្ឋធម្មនុញ្ញត្រូវតែអនុម័តយល់ព្រមដោយសភាទាំងពីរ តាមសម្លេងភាគច្រើន៧៥នៃសមាជិកសភានីមួយៗ ។

២-ការត្រួតពិនិត្យធម្មនុញ្ញភាព

អនុលោមតាមច្បាប់ធម្មតា ព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភាជាក្រុមអាចស្នើសុំឱ្យតុលាការធម្មនុញ្ញសម្រេចអំពីធម្មនុញ្ញភាពនៃច្បាប់ ។ សមាជិកព្រឹទ្ធសភាចំនួន១០នាក់ក៏អាចស្នើសុំឱ្យត្រួតពិនិត្យធម្មនុញ្ញភាពនៃសន្ធិសញ្ញាមុននឹងផ្តល់សច្ចាប័ន ។

ខ-កាលៈទេសៈពិសេស

ការប្រកាសសង្គ្រាម និងការអនុញ្ញាតឱ្យមានវត្តមានកងទ័ពបរទេសលើទឹកដីជាតិត្រូវមានការយល់ព្រមពីសភាទាំងពីរ តាមសម្លេងភាគច្រើននៃសមាជិកសភានីមួយៗ ។

សភាអាចសម្រេចឱ្យប្រកាសស្ថានភាពសង្គ្រាម ក្នុងករណីមានការវាយលុកឬបើសិនណាការសម្រេចនេះជាការចាំបាច់ដើម្បីបំពេញនូវភាពកិច្ចនៃសន្ធិសញ្ញាការពារទៅវិញទៅមក ។

កងកម្លាំងប្រដាប់អាវុធអាចទៅធ្វើសកម្មភាពក្រៅទឹកដី លុះត្រាតែមានការយល់ព្រមពីសភាទាំងពីរ ។

គ-តុលាការធម្មនុញ្ញ

ការយល់ព្រមរបស់ព្រឹទ្ធសភាជាការចាំបាច់ ចំពោះការតែងតាំងរបស់ប្រធានាធិបតីនៃសាធារណរដ្ឋនូវសមាជិកនានានៃតុលាការធម្មនុញ្ញ ។

សមាជិកម្នាក់ៗនៃតុលាការធម្មនុញ្ញ អាចត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ កាលបើមានការយល់ព្រមពីព្រឹទ្ធសភា ។ បើព្រឹទ្ធសភាមិនយល់ព្រម ការចោទប្រកាន់ត្រូវចាត់ទុកបោះបង់ចោលជាស្ថាពរ ។

សមាជិកម្នាក់ៗនៃតុលាការធម្មនុញ្ញអាចត្រូវបានឃាត់ខ្លួនអំពីបទឧក្រិដ្ឋបានតែក្នុងករណីប្រព្រឹត្តបទល្មើសជាក់ស្តែង (en flagrant délit) ។

អាជ្ញាធរដែលបានឃាត់ខ្លួនត្រូវជូនព័ត៌មានភ្លាមដល់ប្រធានព្រឹទ្ធសភា។ បើក្នុងរយៈពេល ២៤ម៉ោង ប្រធានព្រឹទ្ធសភាមិនបានផ្តល់ការយល់ព្រមឱ្យបន្តនីតិវិធីច្បាប់ ចៅក្រមត្រូវដោះលែងឱ្យមានសេរីភាពឡើងវិញ ។ នៅពេលប្រជុំដំណាប់ចុងក្រោយ ព្រឹទ្ធសភាត្រូវសម្រេច ។

រូម៉ានី **ព្រឹទ្ធសភា**

ROUMANIE LE SENAT

ការសើរើរដ្ឋធម្មនុញ្ញឆ្នាំ២០០៣ បានកែប្រែយ៉ាងជ្រាលជ្រៅនូវនីតិវិធីធ្វើច្បាប់ ។អំណឹះតមក សភាដែលទទួលសេចក្តីព្រាងនៅលើកដំបូង និងសភាដែលសម្រេចជាចុងក្រោយត្រូវកំណត់ដោយអនុលោមទៅតាមកម្មវត្ថុចម្បងរបស់អត្ថបទ ។

ចំណែក៦នីតិវិធីសម្របសម្រួលរវាងសភាទាំងពីរត្រូវលុបចោល ។

I-សមាសភាព

ព្រឹទ្ធសភារូម៉ានីមានសមាជិក១៣៧រូប ជ្រើសតាំងដោយការបោះឆ្នោតសកល ដោយផ្ទាល់ តាមនីតិវិធីដូចការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា ។

II-របបបោះឆ្នោត

ការបោះឆ្នោតធ្វើឡើងក្នុង៤២មណ្ឌល ត្រូវនឹងខេត្ត (départements) ដោយត្រូវមានសមាជិក១រូប សម្រាប់ប្រជាជន១៦០.០០០នាក់ ។

ការបោះឆ្នោតយកតាមប្រព័ន្ធសមាមាត្រ លើបញ្ជី ។

ពលរដ្ឋរូម៉ានី អាយុយ៉ាងតិច៣៣ឆ្នាំ ត្មានជម្ងឺប្រសាទ មានសិទ្ធិបោះឆ្នោត អាចឈរឈ្មោះជាសមាជិកព្រឹទ្ធសភា ។

អាណត្តិ :៤ឆ្នាំ

ការផ្លាស់ប្តូរចុងក្រោយ: វិច្ឆិកា ២០០៤ ។

សមាជិកព្រឹទ្ធសភាអាចបំពេញមុខងារជាសមាជិករដ្ឋាភិបាល ។

III-សម័យប្រជុំ

ព្រឹទ្ធសភាមាន២សម័យប្រជុំ ក្នុង១ឆ្នាំ : លើកទី១ ពីខែកុម្ភ:ដល់មិថុនា លើកទី២ ពីខែកញ្ញាដល់ធ្នូ ។

សភាអាចប្រជុំជាវិសាមញ្ញ តាមសំណើរបស់ប្រធានាធិបតី ការិយាល័យអចិន្ត្រៃយ៍នៃសភានីមួយៗ សមាជិកសភានីមួយៗចំនួន១/៣យ៉ាងតិច ។

ជាបញ្ចប់ សភាអាចប្រជុំដោយពេញច្បាប់ក្នុងរយៈពេល២៤ម៉ោងបន្ទាប់ពីការវាយលុកដោយអាវុធ ក្នុងរយៈពេល២៤ម៉ោងបន្ទាប់ពីការប្រកាសសង្ត្រាម ឬកំណែន ក្នុង៤៨ម៉ោង បន្ទាប់ការប្រកាសស្ថានភាពអាសន្ន ឬស្ថានភាពបន្ទាន់ ។

IV-ឥទាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-ឥនិតផ្ទួចផ្តើមធ្វើច្បាប់

ឥនិតផ្ទួចផ្តើមធ្វើច្បាប់ជាសិទ្ធិរបស់សមាជិកព្រឹទ្ធសភា រដ្ឋាភិបាល សមាជិករដ្ឋសភា និងប្រជាជនយ៉ាងតិច១០០.០០០នាក់ក្នុងចំណោមអ្នកមានសិទ្ធិបោះឆ្នោត និងមកពីខេត្តយ៉ាងតិច ១/៤ក្នុងទូទាំងប្រទេស (ត្រូវមានហត្ថលេខា៥.០០០ក្នុងខេត្តនីមួយ១ និងទីក្រុងប៊ីយការៃស) ។ ឥនិតផ្ទួចផ្តើមរបស់ពលរដ្ឋមិនអាចអនុវត្តបានទេ ក្នុងវិស័យពន្ធដារ អន្តរជាតិ ការលើកលែងទោស និងការបន្ធូរបន្ថយទោស ។

២-សិទ្ធិវិសោធនកម្ម

ព្រឹទ្ធសភាមានសិទ្ធិវិសោធនកម្ម ។

៣-នីតិវិធីធ្វើច្បាប់ធម្មតា

ក-ការដាក់អត្ថបទ

ត្រូវដាក់ជាដំបូងជូនរដ្ឋសភា អត្ថបទស្តីពីការផ្តល់សច្ចាប័នលើសន្ធិសញ្ញាឬកិច្ចព្រមព្រៀងអន្តរជាតិផ្សេង១ និងអត្ថបទសម្រាប់អនុវត្តសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងទាំងនោះ ក៏ដូចជាសេចក្តីព្រាងច្បាប់អង្គការ ស្តីពីសេវាសាធារណៈនៃវិទ្យុ-ទូរទស្សន៍ មេធាវី ក្រុមប្រឹក្សានីតិកម្ម ការបង្កើតអាជ្ញាធររដ្ឋបាល អព្យាក្រិត វិសមិតភាពជាមួយមុខងារ ជាសមាជិករដ្ឋាភិបាល បទប្បញ្ញត្តិខ្ទះពាក់ព័ន្ធនឹងការបោះឆ្នោត ការការពារ យុត្តាធិការ និងកាតព្វកិច្ចយោធា ។

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ផ្សេងទៀតត្រូវដាក់ជូនព្រឹទ្ធសភាជាលើកដំបូង ។

ខ-ការពិនិត្យអត្ថបទ

សភាដែលពិនិត្យលើកដំបូងត្រូវអនុម័តក្នុងរយៈពេល៤៥ថ្ងៃ ។ ចំពោះក្រម(les codes) និងច្បាប់ទាំងឡាយដែលមានលក្ខណៈស្មុគ្រស្មាញខ្លាំង រយៈពេលមាន ដល់ទៅ៦៥ថ្ងៃ ។ បើហួសរយៈពេលទាំងនេះ សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវចាត់ទុកថាបានអនុម័ត ។

ក្រោយពេលសភាទទួលលើកដំបូងបានអនុម័តបដិសេធ ឬយល់ព្រម (មានឬគ្មានវិសោធនកម្ម) សេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ត្រូវបញ្ជូនទៅសភាមួយទៀត ។ សភាក្រោយនេះ អនុម័តជាស្ថាពរដោយអាចទទួលយក ឬបដិសេធជំហររបស់សភាមុន ។

ទន្ទឹមនឹងវិធានទូទៅដែលផ្តល់សិទ្ធិសម្រេចចុងក្រោយឱ្យសភាដែលពិនិត្យនៅលើកទី២ សភាដែលពិនិត្យនៅលើកទី១អាចផ្តល់នូវទស្សនៈលើចំណុចណាមួយដែលរដ្ឋធម្មនុញ្ញផ្តល់ឱ្យ មិនមិនមែននៅលើអត្ថបទទាំងមូលទេ ។

ជូនកាលមានអត្ថបទដែលកម្មវត្ថុទូទៅសំដៅទៅលើវិស័យ ដែលផ្តល់ឱ្យសភាណាមួយមានចែង នូវបទប្បញ្ញត្តិដោយឡែកដែលតាមរដ្ឋធម្មនុញ្ញជាដែនសម្រេចរបស់សភាមួយទៀត ។

បទប្បញ្ញត្តិដោយឡែកទាំងនេះ ត្រូវកាត់ចេញពីអត្ថបទដើម្បីចែងក្នុងបទដ្ឋានពិសេស ។

ហេតុនេះ កាលណាសភាពិនិត្យទី១ អនុម័តបទប្បញ្ញត្តិដែលស្ថិតក្នុងសមត្ថកិច្ចសម្រេចរបស់ខ្លួនស្របតាមរដ្ឋធម្មនុញ្ញ សភាពិនិត្យទី២មិនអាចវិសោធនកម្ម ឬលុបចោលជាស្ថាពរនូវបញ្ញត្តិនេះឡើយ ។ ការកែប្រែដែលអាចមាន ត្រូវដាក់ជូនសភាពិនិត្យទី១ ដែលត្រូវសម្រេចជាស្ថាពរ ដោយប្រើនីតិវិធីប្រញាប់ ។

ដូចគ្នានេះដែរ កាលណាសភាពិនិត្យទី២អនុម័តវិសោធនកម្ម ដើម្បីបញ្ចូលបទប្បញ្ញត្តិមួយដែលសមត្ថកិច្ចសម្រេចជារបស់សភាពិនិត្យទី១ បទប្បញ្ញត្តិនេះត្រូវត្រឡប់ទៅសភាពិនិត្យទី១ ដែលត្រូវសម្រេចរក្សាទុក ឬមិនរក្សាទុក ។

ត-ការប្រកាសឱ្យប្រើ និងការពិភាក្សាជាថ្មី

ប្រធានាធិបតីប្រកាសឱ្យប្រើច្បាប់ក្នុងរយៈពេល២០ថ្ងៃក្រោយពីបានទទួល ។មុនប្រកាសឱ្យប្រើ ប្រធានាធិបតីអាចស្នើសុំបានតែ១ដងឱ្យសភាពិនិត្យច្បាប់ឡើងវិញ ។

រយៈពេលប្រកាសឱ្យប្រើមាន១០ថ្ងៃទៀត ។

ឃ-ក្រុមប្រឹក្សានីតិកម្ម(Conseil législatif)

ក្រុមប្រឹក្សានីតិកម្មជាអង្គការពិគ្រោះយោបល់របស់សភា ។ ក្រុមប្រឹក្សានេះផ្តល់យោបល់លើសេចក្តីព្រាងបទដ្ឋានគតិយុត្តដើម្បីឱ្យមានភាពរលូនមានឯកភាព និងសម្របសម្រួលនីតិកម្ម ។ ក្រុមប្រឹក្សាកាន់កាប់បញ្ជីផ្លូវការនៃនីតិកម្មរបស់រូម៉ានី ។

៤-នីតិវិធីធ្វើច្បាប់ដោយឡែក

ក-នីតិសម្បទា

បទបញ្ជា (les ordonnances) ត្រូវអនុម័តស្របតាមច្បាប់ពិសេសស្តីពីនីតិសម្បទា និងក្នុងក្របខ័ណ្ឌដែលកំណត់ដោយច្បាប់នេះ ។ បទបញ្ជាទាំងនេះនឹងអស់សុពលភាព បើមិនបានទទួលសច្ចាប័នពីសភា ក្នុងរយៈពេលកំណត់ក្នុងករណីដែលច្បាប់ស្តីពីនីតិសម្បទាតម្រូវ ។

រដ្ឋាភិបាលអាចចេញបទបញ្ជាដែលមានលក្ខណៈប្រញាប់ ក្នុងស្ថានភាពវិសាមញ្ញ ។ បទបញ្ជាដែលមានលក្ខណៈប្រញាប់ចូលជាធរមានតែក្រោយពេលដាក់ជូនសភា ។ បើសភាមិនស្ថិតក្នុងសម័យប្រជុំ សភាត្រូវតែកោះប្រជុំជាចាំបាច់ ក្នុងរយៈពេល៤ថ្ងៃក្រោយពេលដាក់ ។ បើសភាដែលបានទទួលមិនបានអនុម័ត ក្នុងរយៈពេលយ៉ាងយូរ៣០ថ្ងៃ ចាប់ពីពេលដាក់ បទបញ្ជាត្រូវចាត់ទុកថាបានអនុម័ត ហើយត្រូវបញ្ជូនទៅសភា១ទៀតដែលត្រូវប្រើនីតិវិធីប្រញាប់ ។បទបញ្ជាដែលមានលក្ខណៈប្រញាប់ដែលមានបទដ្ឋានជាច្បាប់អង្គការ ត្រូវអនុម័តតាម សម្លេងភាគច្រើននៃសមាជិកសភានីមួយៗ ។

បទបញ្ជាដែលមានលក្ខណៈប្រញាប់ មិនអាចអនុម័តបានក្នុងវិស័យច្បាប់ធម្មនុញ្ញ មិនអាចធ្វើឱ្យខូចប្រយោជន៍របស់ស្ថាប័នសំខាន់ៗរបស់រដ្ឋ ចំពោះសិទ្ធិបោះឆ្នោត សិទ្ធិ សេរីភាព និងកាតព្វកិច្ច និងវិធានការ ថែរក្សាទ្រព្យសម្បត្តិជាកម្មសិទ្ធិសាធារណៈ ។

ខ-បទបញ្ជាត្តិដោយឡែកក្នុងវិស័យថវិកា

បើសភាមិនអនុម័តថវិការដ្ឋ និងថវិកាការពារខាងសង្គមកិច្ចយ៉ាងតិចពីរថ្ងៃ មុនចប់ឆ្នាំថវិកា ថវិកាទាំងនេះនៃឆ្នាំចាស់ត្រូវយកមកអនុវត្តរហូតដល់ការអនុម័តថវិកាឆ្នាំថ្មី ។

ខ-អំណាចត្រួតពិនិត្យ

១-ត្រួតពិនិត្យនយោបាយរបស់រដ្ឋាភិបាល

ក-វិធីតាមការផ្តើមគំនិតរបស់សភា

រដ្ឋសភា និងព្រឹទ្ធសភានៅពេលប្រជុំរួម អាចដកសេចក្តីទុកចិត្តពីរដ្ឋាភិបាលដោយការអនុម័តញត្តិបន្ទោស តាមសម្លេងភាគច្រើននៃសមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភា ។

ញត្តិបន្ទោសអាចស្នើឡើងដោយសមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភាចំនួន១ /៤ ។

បើញត្តិត្រូវបានបដិសេធ សមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភាជាហត្ថលេខីមិនអាចផ្តើមញត្តិជាថ្មីក្នុងសម័យប្រជុំដដែលបានឡើយ ។

ខ-វិធីតាមការផ្តើមគំនិតរបស់រដ្ឋាភិបាល

រដ្ឋាភិបាលអាចបញ្ជាក់អំពីការទទួលខុសត្រូវរបស់ខ្លួននៅមុខរដ្ឋសភា និងព្រឹទ្ធសភានៅពេលប្រជុំរួម លើកម្មវិធី ការប្រកាសអំពីនយោបាយទូទៅ ឬសេចក្តីព្រាងច្បាប់ ។

រដ្ឋាភិបាលត្រូវលាលែង បើញត្តិបន្ទោសដែលដាក់ក្នុងរយៈពេលពីរថ្ងៃគិតចាប់ពីការបង្ហាញកម្មវិធី ការប្រកាសនយោបាយទូទៅ ឬសេចក្តីព្រាងច្បាប់ត្រូវបានអនុម័ត ។

បើរដ្ឋាភិបាលមិនបានលាលែង សេចក្តីព្រាងច្បាប់ដែលកែប្រែ ឬបំពេញបន្ថែម ទៅតាមករណីដោយមានវិសោធនកម្មដែលទទួលយកដោយរដ្ឋាភិបាលត្រូវចាត់ទុកថាបានអនុម័ត និងការអនុវត្តនូវកម្មវិធី ឬការប្រកាសនយោបាយទូទៅក្លាយទៅជាការចាំបាច់ចំពោះរដ្ឋាភិបាល ។

ក្នុងករណីដែលប្រធានាធិបតីស្នើសុំឱ្យពិនិត្យអត្ថបទច្បាប់ឡើងវិញ បន្ទាប់ពីការអនុម័ត ផ្តល់ការទុកចិត្ត ការពិភាក្សាត្រូវប្រព្រឹត្តទៅក្នុងពេលប្រជុំរួមរបស់សភាទាំងពីរ ។

២-រូបភាពផ្សេងទៀតនៃការត្រួតពិនិត្យ

ក-គណៈកម្មការស៊ើបអង្កេត

សភានីមួយៗអាចបង្កើតគណៈកម្មការស៊ើបអង្កេត ។ ក៏អាចមានលទ្ធភាពបង្កើតគណៈ-កម្មការរួមរវាងសភាទាំងពីរ ។ គណៈកម្មការទាំងនេះត្រូវបង្កើតឡើងតាមសំណើរបស់សមាជិករដ្ឋសភា ឬសមាជិកព្រឹទ្ធសភាចំនួន១ /៣ ។

ខ-សំណួរ និងសំណួរដេញដោល

សំណួរនិងការសួរដេញដោលអាចធ្វើឡើងដោយសមាជិកព្រឹទ្ធសភា(les sénateurs) ។ រដ្ឋាភិបាលត្រូវឆ្លើយនឹងសំណួរទាំងនោះ ។

ព្រឹទ្ធសភាអាចអនុម័តញត្តិដែលបង្ហាញពីជំហររបស់ខ្លួន អំពីបញ្ហាដែលជាកម្មវត្ថុនៃការសួរដេញដោល ។

គ-ព័ត៌មានរបស់សភា

ប្រធានាធិបតីជូនព័ត៌មានដល់សភាអំពីវិធានការចំពោះការឈ្លានពានដោយអាវុធ ។

រដ្ឋាភិបាល និងអង្គការរដ្ឋបាលសាធារណៈផ្សេងៗត្រូវផ្តល់ព័ត៌មាននិងឯកសារនានាដែលព្រឹទ្ធសភាឬគណៈកម្មការនានាទាមទារ តាមរយៈប្រធានព្រឹទ្ធសភា ឬប្រធានគណៈកម្មការនានា ។

ឃ-ការត្រួតពិនិត្យថវិកា

ព្រឹទ្ធសភាអាចស្នើសុំឱ្យតុលាការគណនីត្រួតពិនិត្យការប្រើប្រាស់ធនធានសាធារណៈ និងឱ្យបង្ហាញ របាយការណ៍អំពីការត្រួតពិនិត្យនោះ ។

តុលាការធម្មនុញ្ញបង្ហាញរបាយការណ៍ប្រចាំឆ្នាំជូនសភាអំពីការអនុវត្តថវិកា។

ង-សេវាស៊ើបការសម្ងាត់(services de renseignements)

សភាទាំងពីរ នៅពេលប្រជុំរួម ត្រួតពិនិត្យសកម្មភាពនៃសេវាស៊ើបការណ៍សម្ងាត់ ។

គ-អំណាចចំពោះមុខងារប្រធានាធិបតី

ប្រធានាធិបតីទាក់ទងជាមួយសភាដោយសារ ។

ប្រធានាធិបតី(ដែលបានធ្វើសម្បថនៅមុខសភាទាំងពីរប្រជុំរួមគ្នាក្រោយការផ្តល់សុពលភាពនៃការបោះឆ្នោត) អាចត្រូវចោទប្រកាន់អំពីអំពើល្មើសក្បត់ធ្ងន់ធ្ងរដោយការបោះឆ្នោត តាមសម្លេងភាគច្រើន២/៣យ៉ាងតិចនៃចំនួនសមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភានៅពេលប្រជុំរួម តាមសំណើរបស់សមាជិកភាគច្រើននៃរដ្ឋសភា និងព្រឹទ្ធសភា។

រដ្ឋសភា និងព្រឹទ្ធសភា នៅពេលប្រជុំរួមគ្នា ក្រោយពីបានពិគ្រោះយោបល់ជាមួយតុលាការធម្មនុញ្ញតាមសំណើរបស់សមាជិករដ្ឋសភា និងព្រឹទ្ធសភាចំនួនយ៉ាងតិច១/៣ សម្រេចព្យួរតំណែងប្រធានាធិបតី បើប្រធានាធិបតីបានរំលោភយ៉ាងធ្ងន់ធ្ងរលើរដ្ឋធម្មនុញ្ញ។

ប្រជាមតិត្រូវរៀបចំឡើង ក្នុងរយៈពេល៣០ថ្ងៃ ដើម្បីទំលាក់ប្រធានាធិបតី។

ប្រធានព្រឹទ្ធសភាទទួលជាប្រធានាធិបតីស្តីទី ក្នុងករណីវិស្សមកាល ព្យួរ ឬមិនអាចបំពេញមុខងារមួយរយៈពេល។

V-**បទប្បញ្ញត្តិផ្សេងៗ**

ក-សមត្ថកិច្ចក្នុងវិស័យធម្មនុញ្ញ

១-ការស្នើរ

គំនិតផ្តួចផ្តើមស្នើរើរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់សមាជិកព្រឹទ្ធសភា (ឬសមាជិករដ្ឋសភា) ចំនួន ១/៤យ៉ាងតិច របស់រដ្ឋាភិបាលឬរបស់ពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតយ៉ាងតិច៥សែននាក់ (៥០០.០០០)និងមកពីខេត្តចំនួនពាក់កណ្តាលក្នុងទូទាំងប្រទេស។

សភានីមួយ១ត្រូវអនុម័តសេចក្តីព្រាង ឬសេចក្តីស្នើសើរើរដ្ឋធម្មនុញ្ញ តាមសម្លេងភាគច្រើន២/៣នៃសមាជិករបស់ខ្លួន ។ក្នុងករណីមិនព្រមព្រៀងគ្នានិងបរាជ័យនៃនីតិវិធីសម្របសម្រួលរដ្ឋសភានិងព្រឹទ្ធសភាប្រជុំរួមគ្នាសម្រេច តាមសម្លេងភាគច្រើន ៣/ ៤នៃចំនួនសមាជិករដ្ឋសភានិងព្រឹទ្ធសភា ។ ការសើរើទៅជាស្ថាពរក្រោយពីមានការយល់ព្រមពីប្រជាមតិ ដែលត្រូវរៀបចំឡើងក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីពេលអនុម័តសេចក្តីព្រាងឬសេចក្តីស្នើសើរើ ។

២-ត្រួតពិនិត្យធម្មនុញ្ញភាព

ប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភាយ៉ាងតិច២៥រូបអាចស្នើសុំឱ្យតុលាការធម្មនុញ្ញពិនិត្យធម្មនុញ្ញភាព:

-ច្បាប់មុនប្រកាសឱ្យប្រើ (ក្នុងករណីអធម្មនុញ្ញ សភាត្រូវពិនិត្យឡើងវិញនូវបញ្ញត្តិដែលមានបញ្ហា)

-សន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ

-បទបញ្ជារបស់សភាទាំងពីរ ។

ប្រធានព្រឹទ្ធសភាអាចស្នើសុំឱ្យតុលាការដោះស្រាយវិវាទខាងច្បាប់មានលក្ខណៈធម្មនុញ្ញរវាងអាជ្ញាធរសាធារណៈ ។

ខ-អំណាចជុំនំជម្រះ

ព្រឹទ្ធសភា(ក៏ដូចជារដ្ឋសភា និងប្រធានាធិបតី) មានសិទ្ធិស្នើសុំឱ្យដំណើរការចោទប្រកាន់សមាជិករដ្ឋាភិបាល ចំពោះអំពើល្មើសក្នុងការបំពេញមុខងារ ។

ត-កាលៈទេសៈពិសេស

ការអនុញ្ញាតរបស់សភាជាការចាំបាច់ចំពោះកំណែនជាផ្នែក ឬទូទៅនៃកម្លាំងប្រដាប់អាវុធ ។ សភាត្រូវអនុម័ត ក្នុងរយៈពេលយ៉ាងយូរ៥ថ្ងៃនូវស្ថានភាពអាសន្ន ឬស្ថានភាពបន្ទាន់ ។

ឃ-អំណាចតែងតាំង

ព្រឹទ្ធសភាតែងតាំង៣/៤ នៃចៅក្រមតុលាការធម្មនុញ្ញ ។

ព្រឹទ្ធសភាតែងតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម២រូប តំណាងសង្គមស៊ីវិលនិងផ្តល់សុពលភាពដល់ការជ្រើសរើសសមាជិក១៤រូបដោយសភាទូទៅនៃចៅក្រម (assemblées générales des magistrats) ។

ព្រឹទ្ធសភាតែងតាំងសមាជិកនានានៃតុលាការគណនី សម្រាប់អាណត្តិ៥ឆ្នាំ មិនផ្ទាស់ប្តូរថ្មី(non renouvelable)។

ព្រឹទ្ធសភាតែងតាំង ក្នុងពេលប្រជុំរួមនូវមេធាវីរបស់ពលរដ្ឋ(avocat du peuple)នាយកសេវាស៊ើបការណ៍សម្ងាត់ តាមសំណើរបស់ប្រធានាធិបតី។

នាសតវត្សទី២០ សភាអភិជនដែលតទៅនេះហៅថាសភាជាន់ខ្ពស់មានការកែទម្រង់ជាច្រើនដែលនាំដល់ការកាត់បន្ថយអំណាចប្រៀបធៀបនឹងរដ្ឋសភា(Chambre des Communes) ។ ប៉ុន្តែពេលថ្មីៗនេះ គឺបញ្ហាសមាសភាពនៃសភាជាន់ខ្ពស់ដែលជាកម្មវត្ថុនៃការពិភាក្សា ។

សភាជាន់ខ្ពស់មានសមាជិកតែងតាំង(membres désignés)និងសមាជិកពេញច្បាប់ (membres de droit) ។ នៅឆ្នាំ១៩៩៩ កំណែទម្រង់របស់លោក ប្លែរ (la réforme de M.Blair) បានលុបបំបាត់សិទ្ធិចំពោះសមាជិកពេញច្បាប់ខ្លះ ពោលគឺសមាជិកតពូជចំនួនជាង៧០០រូប (lesquelques 700pairs héréditaires) ។ ជាបណ្តោះអាសន្ន សមាជិក៩២រូបក្នុងចំនួននេះត្រូវបានរក្សាទុក ។ នាថ្ងៃ៧ មីនា ឆ្នាំ២០០៧ រដ្ឋសភា ដែលមានការពិគ្រោះយោបល់ពីរដ្ឋាភិបាលអំពីការដឹកនាំដែលអាចបន្តទម្រង់នៃសមាសភាពសភាជាន់ខ្ពស់ បានអនុម័តតាមសម្លេងភាគច្រើនដ៏ទូលំទូលាយ(large majorité)ជាគុណប្រយោជន៍ដល់សភាជាន់ខ្ពស់ជ្រើសតាំង១០០ភាគរយ ។ នៅសភាជាន់ខ្ពស់ លទ្ធផលនៃការបោះឆ្នោត១សប្តាហ៍ក្រោយមកជាការផ្ទុយគ្នា ។ ការបោះឆ្នោតទាំងនេះមានតម្លៃត្រឹមតែជាការពិគ្រោះយោបល់ ។

ជំហានទៅរកសភាជ្រើសតាំងជាការកាត់ផ្តាច់យ៉ាងសំខាន់ មិនត្រឹមតែក្នុងប្រវត្តិសាស្ត្រសភាជាន់ខ្ពស់ប៉ុណ្ណោះទេ ប៉ុន្តែទូលំទូលាយជាងទៀតនោះក្នុងសេដ្ឋកិច្ចជារួមនៃរបបសភាពីរក្នុងប្រទេស ។

ពោលការណ៍ពីរសម្រាប់ជាត្រីវិស័យនៃដំណើរកំណែទម្រង់ :

-ជំរុញសភាជាន់ខ្ពស់ឱ្យមានលក្ខណៈជ្រើសតាំងជាផ្នែក ឬទាំងស្រុង ប៉ុន្តែនៅតែបំពេញឱ្យរដ្ឋសភា និងមិនមែនជាគូរប្រជាំង ហើយត្រូវឆ្លើយនឹងសំណួរ : អំណាចអ្វីខ្លះ?គុណភាពអ្វីខ្លះ ? និងភាពជាតំណាងខាងនយោបាយអ្វី?

-ឈានទៅដល់សេចក្តីព្រាងកំណែទម្រង់ ដែលអាចដាក់បញ្ចូលក្នុងកម្មវិធីបោះឆ្នោតរបស់រដ្ឋាភិបាល សម្រាប់ការបោះឆ្នោតសភា(២០១២) ក្រោយពីមានការពិភាក្សាគ្នារវាងភាគីនានា ។ ក្នុងករណីនេះ អភិជននានាមិនអាចជំទាស់បានឡើយ ស្របតាមអនុសញ្ញាសាលីប៊ូរី (la Convention de Salisbury) ។

ការវិភាគខាងក្រោមជាស្ថានភាពបច្ចុប្បន្ននៃបញ្ញត្តិទាក់ទងនឹងសភាជាន់ខ្ពស់ ។

I-សមាសភាព

នៅឆ្នាំ២០០៨ សភាជាន់ខ្ពស់មានសមាជិក៧៣៨រូប :

-សមាជិក១ជីវិត (pairs à vie) :៦២០រូប

-សមាជិកតពូជ(pairs héréditaires) :៩២រូប

-សមាជិកជាបព្វជិតព្រះវិហារ?(archevêques et évêques) :២៦រូប ។

II-របបតែងតាំង

គ្រប់ប្រភេទនៃសមាជិកសភាជាន់ខ្ពស់ ត្រូវមានអាយុយ៉ាងតិច ២១ឆ្នាំ ។

ក-សមាជិកមួយជីវិត(pairs à vie)

សមាជិកមួយជីវិតដែលមានចំនួន៦២០រូប(ដើមឆ្នាំ២០០៨)ជាសមាជិកភាគច្រើន(៨៤%) ។ សមាជិកប្រភេទនេះត្រូវតែងតាំងដោយមហាក្សត្រីយានី តាមសំណើរបស់នាយករដ្ឋមន្ត្រី ។ ប៉ុន្តែចាប់តាំងពីឆ្នាំ២០០១ គណៈកម្មការឯករាជមួយមានតួនាទីយ៉ាងសំខាន់ក្នុងការតែងតាំងទាំងនេះ ។ គណៈកម្មការនេះ ស្នើតែងតាំងសមាជិកដែលមិនជាប់ក្នុងនយោបាយដែលហៅថា crossbenchers (បច្ចុប្បន្នមាន១៦៨ ត្រូវជា២៣ % នៃសមាជិកសភាអភិជន) ។

ខ-សមាជិកតពូជ(pairs héréditaires)

លក្ខន្តិកៈនេះត្រូវបានលុបចោលដោយកំណែទម្រង់ឆ្នាំ១៩៩៩ ។ ទោះជាយ៉ាងនេះ ក្នុងអន្តរកាល សមាជិកប្រភេទនេះ៩២រូប(ក្នុងចំណោម៧៣០រូបពីដើម) ត្រូវបានរក្សាទុក និងជ្រើសតាំងមួយផ្នែកដោយសមាជិកមួយជីវិតទាំងអស់ និងមួយផ្នែកទៀតដោយសមាជិកទាំងអស់នៃសភាអភិជន ។

គ-បព្វជិតព្រះវិហារអង់គ្លីកាន(évêques de l'église Anglicane)

បព្វជិតតំបន់កង់ទ័របេរី និងយ៉ក និងបព្វជិតតំបន់ឡុងដ្រំ ដឺហាំ និងវីនឆេស្ទ័រ ជាសមាជិកពេញច្បាប់ ក៏ដូចជាបព្វជិត២១រូបដែលចាស់ជាងគេ ក្នុងបន្ទុកចំពោះតំបន់ឯទៀត ។

វិធានតែងតាំងប្លែក១នេះ ធ្វើឱ្យសភាជាន់ខ្ពស់មានទិដ្ឋភាពនយោបាយខុសគ្នាយ៉ាងខ្លាំងពីរដ្ឋសភា ។ វត្តមានក្រុមcrossbenchersបញ្ជៀសមិនឱ្យគណបក្សតែមួយត្រួតត្រាសភា ។ លើសពីនេះទៀត ការតែងតាំងមួយជីវិតជាការធានានូវឯករាជភាពរបស់សមាជិកពីគណបក្សនយោបាយ ។

ជាទីបញ្ចប់ ការផ្លាស់ប្តូរថ្មីបានធ្វើឱ្យចុះខ្សោយនូវឥទ្ធិពលរលកនៃការបោះឆ្នោតដែលមានពេញទំហឹងនៅរដ្ឋសភា ។ហេតុនេះហើយក្នុងចំណោមស្ថាប័នអង់គ្លេស សភាជាន់ខ្ពស់ជានិមិត្តរូបនៃការត្រួតពិនិត្យ (expertise) និងមានភាពទម្ងន់ខាងច្បាប់ច្បាស់លាស់ ក្នុងការងារត្រួតពិនិត្យរដ្ឋាភិបាល និងក្នុងការវិភាគបញ្ហាចំ១របស់សង្គម ។

III-សម័យប្រជុំ

សម័យប្រជុំប្រចាំឆ្នាំតែមួយ បើកជាឧទ្យានិកនៅដើមខែវិច្ឆិកា ដោយសុន្ទរកថារបស់ព្រះមហាក្សត្រីយានី ដែលដោយតែអង្គឯង អាចកោះសម័យប្រជុំថ្មី និងបិទសម័យប្រជុំមុន ។

ក្នុងការអនុវត្តជាក់ស្តែង តាមបទប្បញ្ញត្តិទូទៅ សភាជាន់ខ្ពស់លើកពេលប្រជុំជាញឹកញាប់ ។ ជាមធ្យម សភាប្រជុំ៣៥សប្តាហ៍ក្នុង១ឆ្នាំ ប្រហែល១៤០ថ្ងៃ ។

IV-ឧំនាក់ឧំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-ឥនិតផ្តួចផ្តើមធ្វើច្បាប់

សមាជិកសភាជាន់ខ្ពស់ ក៏ដូចជាសមាជិករដ្ឋសភាមានសិទ្ធិផ្តួចផ្តើមឥនិតធ្វើច្បាប់ ។ អត្ថបទដែលផ្តើមឡើងដោយសមាជិកសភា មានឈ្មោះថាសេចក្តីស្នើជាឯកជនរបស់សមាជិក (Private Members'Bills) ។អត្ថបទដែលផ្តើមដោយរដ្ឋាភិបាលមានឈ្មោះថាសេចក្តីព្រាង (Governement Bills) ។ ឥនិតផ្តួចផ្តើមមិនបើកចំហចំពោះសមាជិកសភាទេ ក្នុងវិស័យហិរញ្ញវត្ថុ ។

២-សិទ្ធីវិសោធនកម្ម

សមាជិកសភាជាន់ខ្ពស់មានសិទ្ធីវិសោធនកម្ម ។

៣-នីតិវិធីធ្វើច្បាប់ធម្មតា

អត្ថបទអាចដាក់នៅសភាណាមួយក៏បាន ។ សភាដែលបានទទួល ពិនិត្យអត្ថបទជាច្រើនដំណាក់កាល ។

-ការអានលើកទី១ (Première lecture) ជាទម្រង់មួយយ៉ាងសាមញ្ញ ។ ចំណងជើងអត្ថបទត្រូវអានក្នុងសភា ហើយសភានេះអនុញ្ញាតឱ្យបោះពុម្ព ។ ដំណាក់កាលនេះមិនមានការពិភាក្សាទេ ។

-ការអានលើកទី២ (Deuxième lecture) ផ្តល់លទ្ធភាពឱ្យមានការពិភាក្សាយ៉ាងខ្លាំងលើគោលការណ៍នៃសេចក្តីព្រាង ។ វិសោធនកម្មមិនអាចមានទេក្នុងដំណាក់កាលនេះ ប៉ុន្តែសេចក្តីព្រាងអាចត្រូវបដិសេធទាំងស្រុង ។ បើត្រូវបានទទួលយក អត្ថបទត្រូវបញ្ជូនទៅគណៈកម្មការដើម្បីពិនិត្យយ៉ាងលំអិត ។

ក្នុងដំណាក់កាលគណៈកម្មការ(នៅរដ្ឋសភាឬនៅសភាជាន់ខ្ពស់) អត្ថបទត្រូវលំអិតមួយមាត្រាម្តង១ហើយវិសោធនកម្មទាំងឡាយត្រូវដាក់ស្នើនិងពិភាក្សា ។វិសោធនកម្មដែលគណៈកម្មការបានអនុម័តត្រូវដាក់បញ្ចូលក្នុងអត្ថបទច្បាប់ ។ បន្ទាប់ពីនេះ គណៈកម្មការបោះពុម្ពអត្ថបទដែលមានវិសោធនកម្មដែលអនុម័តដោយគណៈកម្មការ ។

ការពិភាក្សាពេលប្រជុំពេញអង្គខាងមុខធ្វើឡើងលើអត្ថបទរបស់គណៈកម្មការ ។ ដំណើរការជាក់ស្តែងនៅតាមគណៈកម្មការមានការខុសគ្នាពីសភាមួយទៅសភាមួយទៀត ។ ម្យ៉ាង នៅសភាអភិជន ជាញឹកញ្ជាប់ ការពិនិត្យអត្ថបទត្រូវបានប្រគល់ឱ្យគណៈកម្មាធិការសភាទាំងមូល (Comité de Toute la Chambre) ។ម្យ៉ាងទៀត ដំណើរការវិសោធនកម្មមិនដូចគ្នាទេនៅសភាទាំងពីរ ។នៅរដ្ឋសភា ពេលវេលាពិភាក្សាលើវិសោធនកម្មត្រូវចុះក្នុងកម្មវិធី ។ ចំណែកនៅសភាជាន់ខ្ពស់ ការពិភាក្សាប្រព្រឹត្តទៅដោយសេរី ។ នៅរដ្ឋសភា ប្រធានគណៈកម្មការមានអំណាចឆន្ទានុសិទ្ធិក្នុងការជ្រើសរើសយកវិសោធនកម្មដែលត្រូវចុះក្នុងរបៀបវារៈពិភាក្សាក្នុងគណៈកម្មការ ។ ជាអំណាចដែលទទួលស្គាល់ក្នុងបណ្តាឆ្នាំ១៩៣០ ។ នៅសភាជាន់ខ្ពស់ វិសោធនកម្មទាំងអស់ត្រូវដាក់ឱ្យពិភាក្សា ។

ក្រោយដំណាក់កាលគណៈកម្មការ ជាដំណាក់កាលរបាយការណ៍ ។ សភាពិនិត្យក្នុងពេលប្រជុំពេញអង្គលើលទ្ធផលការងាររបស់គណៈកម្មការ ។ នៅដំណាក់កាលនេះ វិសោធនកម្មថ្មីអាចដាក់ជូនបាន ។ អត្ថបទមិនត្រូវបានពិនិត្យមួយមាត្រាម្តងដូចនៅគណៈកម្មការទេ ។ នៅរដ្ឋសភាប្រធានអាចប្រើអំណាចឆន្ទានុសិទ្ធិ រំលងចោលវិសោធនកម្ម កាលបើយល់ថាបានសម្របសម្រួលនៅគណៈកម្មការរួចហើយ(ការអនុវត្តដែលហៅ ថាបែបកង់ហ្ជ្ហ្ជ្ហ) ។

-ការអានលើកទី៣(Troisième lecture)និងការអនុម័តចុងក្រោយ

ដំណាក់កាលនេះ ញត្តិស្នើឱ្យមានការអានអត្ថបទច្បាប់ជាលើកទី៣និងឱ្យមានការអនុម័តសេចក្តីព្រាងច្បាប់ត្រូវដាក់ជូនសភា ។

បើក្រោយការអានលើកទី៣ សេចក្តីព្រាងត្រូវបានអនុម័តដោយសភា សេចក្តីព្រាងនេះត្រូវបញ្ជូនទៅសភាមួយទៀតដើម្បីពិនិត្យ តាមនីតិវិធីដែលរៀបរាប់ខាងលើ ។

គ្រប់សេចក្តីព្រាងច្បាប់ត្រូវអនុម័តយល់ព្រមដោយសភាទាំងពីរ មុនក្លាយទៅជាច្បាប់ ។ កាលណាអត្ថបទមួយត្រូវបានអនុម័តលើកដំបូងដោយសភាណាមួយ ហើយត្រូវសភាមួយទៀតធ្វើវិសោធនកម្ម អត្ថបទនោះត្រូវពិនិត្យឡើងវិញដោយសភាដែលពិនិត្យលើកដំបូង និងជាបន្តបន្ទាប់រហូតដល់មានការព្រមព្រៀងលើអត្ថបទទាំងមូល ។ គឺជាប៉ែងប៉ុង(ping-pong) តាមបែបអង់គ្លេសដែលត្រូវគ្នានឹងការបញ្ជូនទៅបញ្ជូនមក (navette) នៅសភាបារាំង ។

រដ្ឋសភាមានសិទ្ធិបង្ហាញនូវទស្សនៈរបស់ខ្លួន កាលណាសភាជាន់ខ្ពស់បដិសេធអត្ថបទទាំងស្រុង ឬធ្វើវិសោធនកម្មដែលរដ្ឋសភាមិនទទួលយក ។

បើរដ្ឋសភាអនុម័តសេចក្តីព្រាងដដែលនៅ២សម័យប្រជុំ(ជាប់គ្នា) ប្រចាំឆ្នាំ សេចក្តីព្រាងនោះអាចត្រូវព្រះមហាក្សត្រប្រកាសឱ្យប្រើ ទោះជាគ្មានការយល់ព្រមពីសភាជាន់ខ្ពស់ក៏ដោយ ។ ការបន្ថយអំណាចរបស់សភាជាន់ខ្ពស់នេះស្របតាមច្បាប់ស្តីពីសភា (loi sur le Parlement) ឆ្នាំ ១៩៩១និង១៩៤៩ ។ ច្បាប់ឆ្នាំ១៩៩១ បានបន្ថយយ៉ាងខ្លាំងនូវអំណាចរបស់សភាអភិជន ក្នុងការពិនិត្យច្បាប់ថ៉វិកា(Money Bills) ។

ច្បាប់នេះបានអនុញ្ញាតឱ្យរដ្ឋសភាឆ្លងផុតពីការជំទាស់របស់សភាជាន់ខ្ពស់ ហើយកំណត់រយៈពេលobstructionរបស់អភិជនដល់២ឆ្នាំ ។ ច្បាប់ឆ្នាំ១៩៤៩បានបន្ថយរយៈពេលនេះមកត្រឹមតែ១ឆ្នាំ ។

២-នីតិវិធីធ្វើច្បាប់ដោយឡែក

ក-អនុសញ្ញាសាលីប៉ូរី(convention de Salisbury)

អនុលោមតាមអនុសញ្ញាដែលអនុម័តនៅឆ្នាំ១៩៤៦ ពេលអនុម័តអត្ថបទ សមាជិកសភាអភិជនមិនអាចជំទាស់នៅការអានលើកទី២ និងលើកទី៣នឹងសេចក្តីព្រាងច្បាប់ដែលគោលការណ៍មានដាក់បញ្ជូលក្នុងកម្មវិធីបោះឆ្នោតរបស់រដ្ឋាភិបាល ។ មានតែវិសោធនកម្មតិចតួចដែលបញ្ជាក់នូវការបំរុងទុកត្រូវបានទទួលយក និងអនុម័ត(le Marquis de Salisbury ជាប្រធានគណបក្សអភិរក្សនៅសភាជាន់ខ្ពស់ ពេលដែលអនុសញ្ញាត្រូវបានអនុម័ត) ។

ខ-សេចក្តីព្រាងច្បាប់ថវិកា(Money Bills)

Money Bills ជាអត្ថបទដែលមានតែបទប្បញ្ញត្តិទាក់ទងនឹងពន្ធដារ ចំណាយសាធារណៈ និងកំចីសាធារណៈ ។ មានតែប្រធានរដ្ឋសភាទេដែលអាចសម្រេច ថាអត្ថបទណាមួយជាប្រភេទ Money Bills ។ ច្បាប់ប្រភេទនេះមានលក្ខណៈដែលសិទ្ធិជំទាស់របស់សភាជាន់ខ្ពស់ត្រូវបានកាត់បន្ថយយ៉ាងច្រើន បើប្រៀបធៀបនឹងនីតិវិធីធម្មតាៈពិនិត្យលើកទី២ សមាជិកសភាជាន់ខ្ពស់មិនអាចធ្វើវិសោធនកម្មឬបដិសេធ ទោះជាមានអ្វីកើតឡើងត្រូវចាត់ទុកថាបានអនុម័តដោយសភានូវអត្ថបទដែលរដ្ឋសភាបានអនុម័ត យ៉ាងយូរក្នុងរយៈពេល១ខែ ក្រោយពេលបញ្ជូនទៅសភាជាន់ខ្ពស់ ។

អត្ថបទដែលសំខាន់ជាងគេនៃ Money Billsគឺអត្ថបទដែលសម្រេចរៀងរាល់ឆ្នាំ នូវថវិការដ្ឋដែលអាចអនុញ្ញាតឱ្យដកពន្ធដារ និងអនុញ្ញាតឱ្យមានចំណាយរដ្ឋ ។

ឃ-អំណាចត្រួតពិនិត្យ

១-សំណួរ

ពេលប្រជុំដាក់សំណួរផ្ទាល់មាត់រយៈពេល៣០នាទីអាចមានរាល់ថ្ងៃ (នៅម៉ោង១៤:៣០ ថ្ងៃចន្ទ និងអង្គារ នៅម៉ោង១៥:០០ថ្ងៃពុធ និងម៉ោង១១:០០ថ្ងៃព្រហស្បតិ៍) ។

ម្យ៉ាងទៀត ក្នុង១ឆ្នាំ មានសំណួរជាលាយលក្ខណ៍អក្សរប្រហែល៧.០០០សំណួរចំពោះរដ្ឋាភិបាល ។

២-ការពិភាក្សាតូច(mini débats) និងការពិភាក្សាទូទៅ

ការពិភាក្សាតូចចំនួន២ ដែលមួយៗមានរយៈពេលពី១ម៉ោងទៅ១ម៉ោងកន្លះ ធ្វើនៅអំឡុងថ្ងៃព្រហស្បតិ៍ណាមួយក្នុងខែ ។ ការពិភាក្សាផ្តោតទៅលើបញ្ហាបច្ចុប្បន្នភាព លើកឡើងដោយសមាជិកសភា និងជ្រើសរើសតាមការអនុម័ត ។

តំណាង១រូបរបស់រដ្ឋាភិបាលត្រូវបានអនុញ្ញាតឱ្យចូលមកឆ្លើយ ។

ពេលប្រជុំផ្សេងទៀតនាថ្ងៃព្រហស្បតិ៍ជាញឹកញាប់សម្រាប់ការពិភាក្សាទូទៅ ។រយៈពេល២ម៉ោងកន្លះ ប្រធានបទត្រូវបានជ្រើសរើសដោយការព្រមព្រៀងគ្នារវាងអ្នកទទួលខុសត្រូវនៃគណបក្សនយោបាយ និងអ្នកនាំពាក្យនៃសមាជិកដែលមិនមានគណបក្ស ។

៣-សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាល

រដ្ឋាភិបាលអាចធ្វើសេចក្តីថ្លែងការណ៍ចំពោះមុខសភាអំពីបញ្ហាសំខាន់ និងបន្ទាន់ ។

៤-គណៈកម្មការជ្រើសរើស(Select Commitees)

គណៈកម្មការត្រួតពិនិត្យសកម្មភាពរដ្ឋាភិបាល (បង្កើតពីឆ្នាំ១៩៧៩)មានអំណាចយ៉ាងធ្ងន់ធ្ងរណាស់ ។ គណៈកម្មការមានអំណាចកោះហៅជនត្រប់រូប ទទួលត្រប់ឯកសារ ឬសាក្សី(លាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់) រាប់ទាំងសមាជិករដ្ឋាភិបាល មន្ត្រីអង្គការប្រតិបត្តិដើម្បីប៉ះភ្ជាប់លើបញ្ហាណាមួយ ។

គណៈកម្មការមានការកិច្ចត្រួតពិនិត្យចំណាយរដ្ឋបាល និងនយោបាយរបស់ក្រសួងណាមួយ ព្រមទាំងអង្គការដែលស្ថិតនៅក្រោមនិវាទ ។

សភាទាំងពីរមិនមានស្ថាប័នដូចគ្នាក្នុងមុខងារត្រួតពិនិត្យនយោបាយរបស់រដ្ឋាភិបាលឡើយ ដើម្បីចៀសវាងការជាន់ការងារគ្នា ។

គណៈកម្មការត្រួតពិនិត្យតាមវិស័យចំនួន១៨ (មួយគណៈកម្មការសម្រាប់មួយក្រសួង) និងគណៈកម្មការជាច្រើនទៀតត្រូវបានបង្កើតឡើងនៅរដ្ឋសភា(គណៈកម្មការគណនីសាធារណៈ គណៈកម្មការសវនកម្ម បរិដ្ឋាន និងរដ្ឋបាលសាធារណៈ) ។

ចំណែកសភាជាន់ខ្ពស់វិញបានបង្កើតជាអាទិ៍ទូវគណៈកម្មការវិទ្យាសាស្ត្រ និងបច្ចេកទេសដែលមានអ្នកវិទ្យាសាស្ត្រល្បីៗ មានពិសោធន៍ពិតខ្ពស់ គណៈកម្មការកិច្ចការសេដ្ឋកិច្ច ឬគណៈកម្មការទទួលបន្ទុកកិច្ចការធម្មនុញ្ញទៀតផង ។

ម្យ៉ាងវិញទៀត នៅសភាជាន់ខ្ពស់ គណៈកម្មការ២ទទួលបន្ទុកជាពិសេសត្រួតពិនិត្យលក្ខណៈនៃការអនុវត្តច្បាប់ដោយរដ្ឋាភិបាល និងការអនុវត្តអំណាចដែលច្បាប់ខ្ជះផ្តល់ឱ្យរដ្ឋមន្ត្រីក្នុងវិស័យធ្វើច្បាប់បន្ទាប់បន្សំ ។ គឺជាគណៈកម្មការនៃអំណាចប្រគិភូកម្ម (Commission des pouvoirs délégués) និងកំណែទម្រង់បទបញ្ជា និងជាគណៈកម្មការគុណភាពបទបញ្ជា ។

៧-បទឧប្បញ្ញត្តិផ្សេងៗ :មុខងារជំនុំជម្រះ

មុខងារជំនុំជម្រះរបស់សភាជាន់ខ្ពស់ ត្រូវអនុវត្តដោយសមាជិកជាអ្នកច្បាប់ចំនួន១២រូប តែងតាំងអាស្រ័យតាមសមត្ថភាពវិជ្ជាជីវៈក្នុងវិស័យនេះ ។សមាជិកទាំងនេះមិនត្រូវបានតែងតាំងមួយជីវិត ប៉ុន្តែរហូតដល់៧០ឆ្នាំ(អាចដល់៧៥ឆ្នាំ) ។

សភាជាន់ខ្ពស់ជាសាលាឧទ្ធរណ៍ជាន់ខ្ពស់នៃចក្រភពទាំងមូលទាំងកិច្ចការស៊ីវិល ទាំងកិច្ចការព្រហ្មទណ្ឌ(លើកលែងតែត្រប់បទឧក្រិដ្ឋ écossaisesដែលស្ថិតក្រោមយុត្តាធិការពិសេស) ។

សេចក្តីសម្រេចរបស់សភាជាន់ខ្ពស់មានអានុភាពបង្ខំទៅលើយុត្តាធិការថ្នាក់ក្រោម ។ ជាក់ស្តែង សមាជិកជាអ្នកច្បាប់ដែលទទួលការបណ្តុះបណ្តាលមានជាទូទៅ៥រូប ។

មុខងារជំនុំជម្រះនេះកំពុងត្រូវពិចារណាឱ្យលុបបំបាត់ ។

កំណែទម្រង់រដ្ឋធម្មនុញ្ញឆ្នាំ២០០៥ទាក់ទងនឹងការបែងចែកវាងយុត្តិធម៌ សភា និងនីតិ-ប្រតិបត្តិបានចែងអំពីការលុបចោលមុខងារនេះរបស់សភាជាន់ខ្ពស់ និងត្រូវបង្កើតឡើងនូវតុលាការកំពូលដោយឡែកមួយនាខែតុលា ឆ្នាំ២០០៩ ។

គេអាចកត់សំគាល់ថា ក្នុងគំនិតបែងចែកអំណាចនេះ ច្បាប់ឆ្នាំ២០០៥ កែប្រែមុខងាររបស់ Lord Chancelier ដែលរហូតមកជាប្រធានសភាជាន់ខ្ពស់ ប៉ុន្តែក៏ជាប្រធានតុលាការកំពូលទទួលបន្ទុកត្រួតពិនិត្យអំណាចតុលាការ ។ មុខងារជំនុំជម្រះនេះ អំណឹះតទៅត្រូវផ្ទេរទៅឱ្យប្រធានយុត្តិធម៌ ហើយអធិបតីនៃសភាជាន់ខ្ពស់ត្រូវប្រគល់ទៅឱ្យប្រធានដែលជ្រើសរើសដោយសភា ។

(បច្ចុប្បន្នភាពចុងក្រោយ: ខែ ធ្នូ ឆ្នាំ២០០៨) ។

ក្រុមប្រឹក្សាសហព័ន្ធ
LE CONSEIL DE LA FEDERATION

នៅឆ្នាំ២០០០ ក្រុមប្រឹក្សាសហព័ន្ធរុស្សុីជាកម្មវត្ថុនៃកំណែទម្រង់របស់លោកប្រធានាធិបតីពូទីន ។

ក្រៅពីការអនុម័តច្បាប់សហព័ន្ធ លើលទ្ធភាពនៃការរំលាយសភាដែនដីនិងការទំលាក់រដ្ឋាភិបាល ក្នុងករណីអនុម័តបទដ្ឋានផ្ទុយនឹងរដ្ឋធម្មនុញ្ញ និងក្រៅពីការបង្កើតតំបន់សហព័ន្ធដែលប្រមូលផ្ទុំអង្គភាពនៃសហព័ន្ធ និងដឹកនាំដោយតំណាងពេញសិទ្ធិរបស់ប្រធានាធិបតី បទបញ្ញាអំពីសមាសភាពនៃក្រុមប្រឹក្សាសហព័ន្ធត្រូវបានសើរើឡើងវិញ ។ ។

ឥទ្ធិពលនៃកំណែទម្រង់ស្ថាប័ននៅតែស្ថិតក្នុងសភាពលំបាក ។ អំណាចមូលដ្ឋាន (នីតិប្បញ្ញត្តិនិងនីតិប្រតិបត្តិ) នៅតែមានអំណាចត្រួតពិនិត្យខ្លាំងលើសមាជិកក្រុមប្រឹក្សាសហព័ន្ធ ដែលខ្លួនតែងតាំង ដោយអាចដកពីតំណែង និងអាចត្រួតពិនិត្យការចូលកាន់តំណែង ។

ម្យ៉ាងទៀត កំណែទម្រង់ការបោះឆ្នោត តាមច្បាប់ថ្ងៃទី១៤ កុម្ភៈ ២០០៥ ដែលត្រូវអនុវត្តចាប់ពីថ្ងៃទី១ខែមករាឆ្នាំ២០១១ បង្កើតនូវការត្រួតត្នានៃអាណត្តិចាំបាច់ (cumul des mandates obligatoires) ដែលត្រូវកែប្រែយ៉ាងជ្រាលជ្រៅនូវសមាសភាពសភាទី២ ។

I-សមាសភាព

ក្រុមប្រឹក្សាមានសមាជិក១៧៨រូប ។

II-របបបោះឆ្នោត និងតែងតាំង

ក-របបទូទៅ

អង្គភាពនីមួយៗ មានតំណាងនៅសភាជាន់ខ្ពស់ :

-ទីប្រឹក្សា១រូប ជ្រើសតាំងដោយអង្គការនីតិប្បញ្ញត្តិដែនដី

-ទីប្រឹក្សា១រូប តែងតាំងដោយអង្គការនីតិប្រតិបត្តិដែនដី (សភានីតិប្បញ្ញត្តិតំបន់អាចជំទាស់នឹងការតែងតាំងនេះ តាមសម្លេង២/៣) ។

បេកូជនានានៃតំណាងអង្គការនីតិប្បញ្ញត្តិត្រូវស្នើឡើងដោយប្រធានសភាដែលពាក់ព័ន្ធ (ឬប្រធានសភាទាំងពីរប្តូរវេនគ្នា បើអង្គការនីតិប្បញ្ញត្តិតំបន់មានសភាពីរ) ។

សមាជិករដ្ឋសភានៃសាធារណរដ្ឋ ឬតំបន់យ៉ាងតិច១/៣ក៏អាចស្នើបេកូជនដ៏ទៃទៀតបាន ។

ការបោះឆ្នោតធ្វើឡើងជាសម្ងាត់ ហើយត្រូវមានការយល់ព្រម ដោយសេចក្តីសម្រេចចិត្ត ដែលអនុម័តដោយអង្គការនីតិប្បញ្ញត្តិ ។

អាណត្តិនៃទីប្រឹក្សាមិនដូចគ្នាទេ ។

នៅពេលផ្លាស់ប្តូរថ្មីម្តង១ នៃអង្គការនីតិប្បញ្ញត្តិតំបន់ណាមួយ(ការផ្លាស់ប្តូរថ្មីនៅតាមដែនដីផ្សេង១មិនត្រូវពេលគ្នាទេ) ត្រូវដំណើរការបោះឆ្នោតជ្រើសរើសទីប្រឹក្សាថ្មី ដើម្បីតំណាងសភាមូលដ្ឋាននៅក្រុមប្រឹក្សាសហព័ន្ធ ។ ដូចគ្នានេះដែរ ចំពោះទីប្រឹក្សាតែងតាំងដោយអង្គការនីតិប្រ-តិបត្តិតំបន់ អាណត្តិត្រូវចប់កាលណាអាជ្ញាធរដែលតែងតាំងឈប់បំពេញមុខងាររបស់ខ្លួន ។

ម្យ៉ាងទៀត អង្គការដែលរៀបចំការបោះឆ្នោតឬដែលតែងតាំងអាចបញ្ចប់អាណត្តិរបស់ទីប្រឹក្សាដែលខ្លួនបានជ្រើសតាំងឬតែងតាំង នៅពេលណាក៏បាន ។

ទីប្រឹក្សាត្រូវមានអាយុច្រើនជាង៣០ឆ្នាំ និងបំពេញតាមលក្ខខ័ណ្ឌជាអ្នកបោះឆ្នោត និងអ្នកឈរឈ្មោះក្នុងអង្គការសហព័ន្ធ ។

មុខងារជាទីប្រឹក្សាមានវិសមិតភាពជាមួយមុខងារជាសមាជិកសភាឌូម៉ា(Douma) ឬរដ្ឋសភារបស់រដ្ឋ ។

ខ-កំណែទម្រង់ច្បាប់១៤កុម្ភៈ២០០៩

ច្បាប់ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៩(អនុវត្តចាប់ពីថ្ងៃទី១ ខែ មករា ឆ្នាំ២០១១) បង្កើតនូវកាតព្វកិច្ចថ្មីចំពោះសមាជិកក្រុមប្រឹក្សាសហព័ន្ធ គឺកាតព្វកិច្ចមានអាណត្តិបោះឆ្នោតមូលដ្ឋានក្នុងកំរិតសភាតំបន់ ឬកំរិតក្រុមប្រឹក្សាក្រុងនៅពេលធ្វើការតែងតាំង ។

ច្បាប់នេះមិនឱ្យអ្នកមានសញ្ជាតិ២បំពេញមុខងារក្នុងក្រុមប្រឹក្សាសហព័ន្ធទេ ។

លក្ខខណ្ឌថ្មីសម្រាប់ការឈរឈ្មោះទាំងនេះ ចូលជាធរមានជាបណ្តើរ១ ទៅតាមការផ្លាស់ប្តូរថ្មីនានា ទៅតាមអាណត្តិសមាជិកដែលចប់ទៅតាមអាណត្តិរបស់អាជ្ញាធរដែលបានតែងតាំងសមាជិកនោះ ។

ច្បាប់នេះបានធ្វើឱ្យមានការប្រែប្រួលយ៉ាងជ្រាលជ្រៅនូវរូបសណ្ឋានៃក្រុមប្រឹក្សាសហព័ន្ធ ។ បច្ចុប្បន្នមានសមាជិកក្រុមប្រឹក្សាតែ១២រូប/១៧ផ្ទុយទៅដែលមានអាណត្តិបោះឆ្នោតនៅមូលដ្ឋាន (ដែលនៅពេលអនាគតជាការតម្រូវ) ។

III-សម័យប្រជុំ

ក្រុមប្រឹក្សាសហព័ន្ធប្រជុំប្រចាំឆ្នាំពីថ្ងៃទី២៥ខែមករា ដល់ទី១៥ខែកក្កដា និងពីថ្ងៃទី ១៦ ខែកញ្ញា ដល់ទី៣១ខែធ្នូ ។ ក្នុងសម័យប្រជុំ ក្រុមប្រឹក្សាមិនអាចប្រជុំតិចជាងពីរដងក្នុង១ខែបានទេ ។

ម្យ៉ាងវិញទៀត ក្រុមប្រឹក្សាសហព័ន្ធអាចត្រូវកោះប្រជុំតាមតម្រូវការដោយប្រធានតាមតាមការផ្តើមគំនិតផ្ទាល់ ឬតាមសំណើរបស់ប្រធានាធិបតីសហព័ន្ធរបស់អង្គភាពនៃសហព័ន្ធ លើបញ្ហារបស់សហព័ន្ធ ឬតាមសំណើរបស់គណៈកម្មការក្រុមប្រឹក្សាសហព័ន្ធ ឬរបស់សមាជិកក្រុមប្រឹក្សាសហព័ន្ធចំនួនយ៉ាងតិច១/៥ ។

IV-ទំនាក់ទំនង២ជាមួយរដ្ឋសភានិងអំណាចនីតិប្បញ្ញត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-គំនិតផ្តួចផ្តើមធ្វើច្បាប់

គំនិតផ្តួចផ្តើមធ្វើច្បាប់ជាសិទ្ធិរបស់សមាជិកក្រុមប្រឹក្សាសហព័ន្ធ (ក៏ដូចប្រធានាធិបតីសហព័ន្ធ សមាជិករដ្ឋសភាឌូម៉ា រដ្ឋាភិបាលសហព័ន្ធ អង្គការតំណាងអង្គភាពសហព័ន្ធរុស្សុី) ។ តុលាការធម្មនុញ្ញ តុលាការកំពូល និងតុលាការអាជ្ញាកណ្តាលជាន់ខ្ពស់នៃសហព័ន្ធរុស្សុីក៏មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ក្នុងវិស័យដែលជាសមត្ថកិច្ចរៀងៗខ្លួន ។

សេចក្តីព្រាងច្បាប់ស្តីពីការបង្កើត ឬលុបពន្ធដារ ការលើកលែងពន្ធ (exemptions fiscales) ការខ្ចីប្រាក់រដ្ឋ ការកែប្រែការធានាខាងហិរញ្ញវត្ថុរបស់រដ្ឋ ក៏ដូចជាសេចក្តីព្រាងច្បាប់ត្រាងចំណាយថវិកាសហព័ន្ធ អាចដាក់ស្នើបានលុះត្រាតែមានយោបល់យល់ព្រមពីរដ្ឋាភិបាលសហព័ន្ធរុស្សុី ។

២-សិទ្ធិវិសោធនកម្ម

ក្រុមប្រឹក្សាសហព័ន្ធមិនមានសិទ្ធិវិសោធនកម្មផ្ទាល់ខ្លួនទេ ។ ក្រុមប្រឹក្សាមានត្រឹមតែសិទ្ធិស្នើសុំធ្វើវិសោធនកម្មលើអត្ថបទដែលសភាឌូម៉ា (រដ្ឋសភា) បានអនុម័តនាការអានលើកទី១រួចហើយ ។

៣-នីតិវិធីធ្វើច្បាប់ធម្មតា

នីតិវិធីធម្មតាអនុវត្តចំពោះសេចក្តីព្រាងច្បាប់សហព័ន្ធ លើកលែងតែសេចក្តីព្រាងដែល

មានលក្ខណៈធម្មនុញ្ញ (ដែលដូចគ្នានឹងច្បាប់អង្គការនៅបារាំង : គឺជាច្បាប់ដែលចង្ហុរដោយរដ្ឋធម្មនុញ្ញ និងធ្វើតាមនីតិវិធីពិសេសដោយឡែក) ។

ត្រប់អត្ថបទ ទោះជាមកពីប្រភពណាក៏ដោយត្រូវដាក់ជាលើកដំបូងជូនរដ្ឋសភាដែលត្រូវអនុម័ត តាមសម្លេងភាគច្រើននៃសមាជិករដ្ឋសភា ។

អត្ថបទនេះត្រូវបញ្ជូនទៅឱ្យក្រុមប្រឹក្សាសហព័ន្ធ ក្នុងរយៈពេល៥ថ្ងៃដើម្បពិនិត្យ ។

បើសមាជិកក្រុមប្រឹក្សាលើសពីពាក់កណ្តាលអនុម័តគាំទ្រ ច្បាប់សហព័ន្ធត្រូវចាត់ទុកថាបានអនុម័តដោយក្រុមប្រឹក្សាសហព័ន្ធ ។

បើអត្ថបទមិនបានពិនិត្យដោយក្រុមប្រឹក្សាសហព័ន្ធ ក្នុងរយៈពេល១៤ថ្ងៃ ត្រូវចាត់ទុកថាបានការយល់ព្រមពីក្រុមប្រឹក្សាសហព័ន្ធ ។ ប៉ុន្តែ រដ្ឋធម្មនុញ្ញបានចែងថាត្រូវតែមានការពិនិត្យពីក្រុមប្រឹក្សាសហព័ន្ធ ច្បាប់សហព័ន្ធដែលទាក់ទងនឹង :ក-ថវិកាសហព័ន្ធ ខ-ពន្ធដារ និងអាករសហព័ន្ធ គ-បទបញ្ជាហិរញ្ញវត្ថុ ការប្តូរប្រាក់ ឥណទាន គយនិងរដ្ឋាករ ការបោះផ្សាយប្រាក់ ឃ-ការផ្តល់សច្ចាប័ន និងការបដិសេធសន្ធិសញ្ញាអន្តរជាតិរបស់ សហព័ន្ធរុស្សុី ង-លក្ខន្តិកៈ និងការការពារព្រំដែនរដ្ឋសហព័ន្ធ ច-សង្គ្រាម និងសន្តិភាព ។

បើអត្ថបទត្រូវបដិសេធដោយក្រុមប្រឹក្សាសហព័ន្ធ រដ្ឋសភាអាចរក្សាទុកអត្ថបទដែលខ្លួនបានអនុម័តនៅការអានលើកទី១ តាមសម្លេងភាគច្រើន២/៣នៃសមាជិករដ្ឋសភា ។

រដ្ឋសភាក៏មានសិទ្ធិទទួលយកគណៈកម្មការសម្របសម្រួល (commission de conciliation) ។ គណៈកម្មការនេះមានសមាជិកដែលជាតំណាងសភាខ្ពស់និងតំណាងក្រុមប្រឹក្សាសហព័ន្ធហើយបង្កើតឡើងតាមសំណើរបស់ក្រុមប្រឹក្សាសហព័ន្ធសភាខ្ពស់រដ្ឋ ប្រធានាធិបតីសហព័ន្ធ ឬពីម្ចាស់ផ្តួចផ្តើមគំនិត ។

ការបង្កើតគណៈកម្មការសម្របសម្រួល ត្រូវមានសមាជិកសភាខ្ពស់ចំនួនភាគច្រើនដាច់ខាតយល់ព្រម ។

គណៈកម្មការសម្របសម្រួលពិនិត្យដាច់ដោយឡែកពីគ្នានូវចំណុច ដែលក្រុមប្រឹក្សាសហព័ន្ធមិនយល់ព្រម ហើយឈានទៅរកអត្ថបទរួមមួយ ។

សេចក្តីសម្រេចនានាជាលទ្ធផលនៃការអនុម័តដាច់ពីគ្នានៃតំណាងសភាខ្ពស់ និងតំណាងក្រុមប្រឹក្សាសហព័ន្ធ តាមសម្លេងភាគច្រើន ។

គណៈកម្មការរៀបចំពិធីសារបញ្ជាក់នូវសំណើដែលត្រូវធ្វើ ដើម្បីដោះស្រាយការមិនព្រមព្រៀងគ្នារវាងសភាទាំងពីរ ។

ពិធីសារនេះត្រូវពិនិត្យដោយក្រុមប្រឹក្សាសហព័ន្ធដែលត្រូវដាក់បញ្ចូលក្នុងរបៀបវារៈរបស់ខ្លួន ។

នៅការអានថ្មី សភាទូម៉ាពិភាក្សាតែលើសំណើដែលមាននៅក្នុងពិធីសារដែលរៀបចំដោយគណៈកម្មការសម្របសម្រួល ។

សភាទូម៉ាមិនអាចពិភាក្សាលើវិសោធនកម្មដែលចេញផុតពីសំណើទាំងនោះ ។

បើសំណើណាមួយរបស់គណៈកម្មការសម្របសម្រួលត្រូវបដិសេធដោយសភាទូម៉ា សភាទូម៉ាអាចស្នើសុំបន្តការងាររបស់ខ្លួន ដោយគិតផលវិសោធនកម្ម ដែលខ្លួនបានអនុម័តដើម្បីលើកសំណើជាថ្មី ដោយគណៈកម្មការសម្របសម្រួល ក្នុងរយៈពេល១០ថ្ងៃ ។ សភាទូម៉ាអនុម័តសំណើនីមួយៗរបស់គណៈកម្មការសម្របសម្រួលដាច់១ពីគ្នា តាមសម្លេងភាគច្រើននៃសមាជិករបស់ខ្លួន ។

ច្បាប់ដែលចេញពីសំណើរបស់គណៈកម្មការសម្របសម្រួល ដែលទទួលយកដោយសភាទូម៉ាត្រូវបញ្ជូនដោយប្រធានសភាទូម៉ាទៅក្រុមប្រឹក្សាសហព័ន្ធ ។

បើសភាទូម៉ា មិនអនុម័តនូវសំណើរបស់គណៈកម្មការសម្របសម្រួល និងសំដែងនូវការមិនយល់ព្រមចំពោះសេចក្តីសម្រេចបដិសេធរបស់ក្រុមប្រឹក្សាសហព័ន្ធ ការអនុម័តជាថ្មីត្រូវធ្វើឡើង ។ សភាទូម៉ាអនុម័តលើអត្ថបទពីមុនរបស់ខ្លួន ។ អត្ថបទនោះ ត្រូវចាត់ទុកថាជាស្ថាពរបើបានទទួលសម្លេងភាគច្រើន២/៣នៃសមាជិករបស់សភាទូម៉ា ។

ค-សិទ្ធិជំទាស់របស់ប្រធានាធិបតី

ច្បាប់សហព័ន្ធដែលអនុម័តជាស្ថាពរត្រូវបញ្ជូនក្នុងរយៈពេល៥ថ្ងៃទៅប្រធានាធិបតីសហព័ន្ធដើម្បីចុះហត្ថលេខា និងប្រកាសឱ្យប្រើ ។

បើប្រធានាធិបតីសហព័ន្ធបដិសេធច្បាប់សហព័ន្ធក្នុងរយៈពេល១៤ថ្ងៃចាប់ពីទទួល សភាទូម៉ា និងក្រុមប្រឹក្សាសហព័ន្ធពិនិត្យជាថ្មីនូវច្បាប់នេះ ។ បើពេលអនុម័តជាថ្មី ច្បាប់សហព័ន្ធត្រូវបានអនុម័តតាមអត្ថបទដើម (ដែលអនុម័តតាមសម្លេងភាគច្រើន ២/៣នៃសមាជិកក្រុមប្រឹក្សា និងសមាជិកសភាទូម៉ា) ប្រធានាធិបតីសហព័ន្ធត្រូវតែចុះហត្ថលេខាក្នុងរយៈពេល៧ថ្ងៃ និងប្រកាសឱ្យប្រើ ។

៤-នីតិវិធីដោយឡែកៈច្បាប់សហព័ន្ធដែលមានលក្ខណៈធម្មនុញ្ញ

អត្ថបទទាំងនេះ ត្រូវអនុម័តតាមសម្លេងភាគច្រើន៣/៤នៃសមាជិកក្រុមប្រឹក្សាសហព័ន្ធ និងសម្លេងភាគច្រើន២/៣នៃសមាជិកសភាខ្ពស់ៗ ។

ប្រធានាធិបតីមិនអាចជំទាស់បានឡើយ ។

៥-អំណាចត្រួតពិនិត្យ

តំណាងរដ្ឋាភិបាល និងមន្ត្រីឯទ្យៃតត្រូវបានអញ្ជើញយ៉ាងទ្យៃងទាត់ឱ្យចូលរួមក្នុងពេលប្រជុំ(ម៉ោងរដ្ឋាភិបាល)ដើម្បីផ្តល់ព័តិមានដល់សមាជិកសភា និងឆ្លើយនឹងសំណួរនានា ។

សវនកម្មទាំងឡាយអាចរៀបចំឡើងលើបញ្ហាដែលទាក់ទងនឹងសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។

ជាមួយសភាខ្ពស់ៗ ក្រុមប្រឹក្សាសហព័ន្ធអាចបង្កើតសភាគណនី(chambre des comptes) សម្រាប់ត្រួតពិនិត្យការអនុវត្តថវិកាសហព័ន្ធ ។

ត-ទំនាក់ទំនងជាមួយប្រធានាធិបតីសហព័ន្ធ

១-ការទំលាក់ប្រធានាធិបតីសហព័ន្ធ

ប្រធានាធិបតីសហព័ន្ធអាចត្រូវទំលាក់ពីតំណែងដោយក្រុមប្រឹក្សាសហព័ន្ធ លើមូលដ្ឋានដែលសភាខ្ពស់ៗចោទពីបទក្បត់ឬអំពីកំហុសធ្ងន់ដែលបញ្ជាក់ដោយតុលាការកំពូល ក្នុងការបំពេញមុខងារ ។

ប៉ុន្តែតុលាការកំពូលត្រួតពិនិត្យប្រក្រតីភាពនៃនីតិវិធីចោទប្រកាន់ តាមសំណើរបស់ក្រុមប្រឹក្សាសហព័ន្ធ ។

សេចក្តីសម្រេចទំលាក់ត្រូវយកតាមសម្លេងភាគច្រើន២/៣នៃសមាជិកក្រុមប្រឹក្សា និងការអនុម័តត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរពាខែបន្ទាប់ពីពេលចោទប្រកាន់ ។ ផ្ទុយពីនេះ ការចោទប្រកាន់ត្រូវបដិសេធចោល ។

២-សារៈបស់ប្រធានាធិបតីសហព័ន្ធ

ប្រធានាធិបតីអាចផ្ញើសារទៅសភាសហព័ន្ធ (សភាខ្ពស់ៗ និងក្រុមប្រឹក្សាសហព័ន្ធ) ដើម្បីរាយការណ៍អំពីសភាពការណ៍ក្នុងប្រទេស និងអំពីនយោបាយក្នុង និងក្រៅប្រទេស ។

ប្រធានាធិបតីសហព័ន្ធ(ក៏ដូចជាប្រមុខរដ្ឋាភិបាល) ក៏អាចផ្ទែងក្នុងពេលប្រជុំក្រុមប្រឹក្សាសហព័ន្ធ ឬសភាខ្ពស់ៗ ដែលពិភាក្សាលើថវិកាសហព័ន្ធ ឬលើបញ្ហាតន្លឹះនៃនយោបាយរបស់រដ្ឋ ។

V-បទប្បញ្ញត្តិផ្សេងៗ

១-ការសើរើ

លើវិស័យធម្មនុញ្ញក៏ដូចជាវិស័យផ្សេងទៀត ក្រុមប្រឹក្សាសហព័ន្ធអាចស្នើសុំឱ្យសភាទូម៉ា ពិនិត្យសេចក្តីព្រាងច្បាប់ណាមួយ ។

បទប្បញ្ញត្តិរដ្ឋធម្មនុញ្ញទាក់ទងនឹងវិធានធម្មនុញ្ញជាមូលដ្ឋាន (ជំពូក១) សិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ(ជំពូក២ និងនីតិវិធីសើរើរដ្ឋធម្មនុញ្ញ(ជំពូក៩) មិនអាចសើរើបានដោយសភាសហព័ន្ធឡើយ ។ ប៉ុន្តែបើសេចក្តីស្នើសើរើបទប្បញ្ញត្តិទាំងនេះបានទទួលការគាំទ្រពីសម្លេង៣៥នៃសមាជិកក្រុមប្រឹក្សាសហព័ន្ធ និងសមាជិកសភាទូម៉ា សភាធម្មនុញ្ញត្រូវបានកោះប្រជុំ ។

ច្បាប់ធម្មនុញ្ញសហព័ន្ធត្រូវអនុម័ត ស្របតាមនីតិវិធីដែលអនុវត្តចំពោះច្បាប់សហព័ន្ធដែលមានលក្ខណៈធម្មនុញ្ញ ។

២-ការត្រួតពិនិត្យធម្មនុញ្ញភាព និងការបកស្រាយរដ្ឋធម្មនុញ្ញ

តាមសំណើរបស់ក្រុមប្រឹក្សាសហព័ន្ធឬរបស់សមាជិកខ្លួនចំនួន១/៥ (ក៏ដូចជាប្រធានាធិបតីសហព័ន្ធ សភាទូម៉ា រដ្ឋាភិបាលសហព័ន្ធ តុលាការកំពូលសហព័ន្ធ និងតុលាការអាជ្ញាកណ្តាលជាន់ខ្ពស់ អង្គការនានានៃអំណាចនីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិនៃអង្គភាពរបស់សហព័ន្ធ) តុលាការធម្មនុញ្ញសម្រេចអំពីភាពស្របនឹងរដ្ឋធម្មនុញ្ញ : ក-នៃច្បាប់សហព័ន្ធ បទដ្ឋានគតិយុត្តរបស់ប្រធានាធិបតីសហព័ន្ធ សភាទាំងពីរនិងរដ្ឋាភិបាលសហព័ន្ធ ខ-រដ្ឋធម្មនុញ្ញ ច្បាប់និងបទដ្ឋានគតិយុត្តរបស់អង្គភាពសហព័ន្ធអំពីបញ្ហាជាសមត្ថកិច្ចរបស់រដ្ឋឬសមត្ថកិច្ចរួម គ-សន្ធិសញ្ញាចុះដោយសហភាពនិងអង្គភាពរបស់ខ្លួនឬរវាងអង្គភាពនានា ឃ-សន្ធិសញ្ញាអន្តរជាតិមិនចូលជាធរមាន ។

តាមសំណើរបស់ក្រុមប្រឹក្សាសហព័ន្ធ(ក៏ដូចជាប្រធានាធិបតីសហព័ន្ធ សភាទូម៉ា រដ្ឋាភិបាលសហព័ន្ធ អង្គការនៃអំណាចនីតិប្បញ្ញត្តិអង្គភាពរបស់សហព័ន្ធ) តុលាការធម្មនុញ្ញធ្វើការបកស្រាយរដ្ឋធម្មនុញ្ញ ។

សភាទាំងពីរអាចប្រជុំរួមគ្នាដើម្បីស្តាប់សាររបស់តុលាការធម្មនុញ្ញ ។

៣-សមត្ថកិច្ចផ្តាច់មុខ

ក-អំណាចតែងតាំង

ក្រុមប្រឹក្សាសហព័ន្ធដំណើរការតែងតាំងមុខតំណែងចៅក្រមនៅតុលាការធម្មនុញ្ញសហព័ន្ធ នៅតុលាការកំពូលសហព័ន្ធ នៅតុលាការអាជ្ញាកណ្តាលជាន់ខ្ពស់សហព័ន្ធ ។

ក្រុមប្រឹក្សាកំដំណើរការតែងតាំងនិងបញ្ជូនមុខតំណែងអគ្គរដ្ឋអាជ្ញាសហព័ន្ធ ។

ជាបញ្ជប់ ក្រុមប្រឹក្សាតែងតាំង និងបញ្ជូនមុខតំណែងអនុប្រធានាធិបតី និងចំនួនពាក់កណ្តាលនៃសវនការនៃសភាគណនី ។

ខ-សមត្ថកិច្ចផ្តាច់មុខផ្សេងទៀត

ក្រុមប្រឹក្សាសហព័ន្ធផ្តល់ការយល់ព្រមលើការកែប្រែព្រំដែនរវាងអង្គភាពនៃសហព័ន្ធ ។

ក្រុមប្រឹក្សាផ្តល់ការយល់ព្រមលើក្រិត្យរបស់ប្រធានាធិបតីសហព័ន្ធ អំពីស្ថានភាពអាសន្ន ក្រិត្យអំពីស្ថានភាពបន្ទាន់ សេចក្តីសម្រេចទាក់ទងនឹងលទ្ធភាពនៃការប្រើកងកម្លាំងប្រដាប់អាវុធសហព័ន្ធក្រៅទឹកដីសហព័ន្ធ និងជាទីបញ្ជប់ការកំណត់ការបោះឆ្នោតជ្រើសរើសប្រធានាធិបតីសហព័ន្ធរុស្សុី ។

(បច្ចុប្បន្នភាពចុងក្រោយ :២៥ មីនា ២០០៩) ។

រដ្ឋធម្មនុញ្ញថ្មីមានចែងអំពីសភាពីរថ្នាក់ ។ ព្រឹទ្ធសភាមានការកិច្ចជាពិសេសពិនិត្យមើលការការពារឯកភាពជាតិ(l'unité nationale) និងការបែងចែកដោយសមធម៌នៃអំណាច ។

ថ្ងៃទី១២ខែកញ្ញា ឆ្នាំ២០០២ គណៈកម្មការធម្មនុញ្ញបានបោះផ្សាយក្នុងសារព័ត៌មានទូវ សំយោគនៃគំនិតជាមូលដ្ឋាននៃអនាគតរដ្ឋធម្មនុញ្ញ ដែលទទួលបានតាមរយៈបេសកកម្មដែលបានរៀបចំឡើងក្នុងប្រទេស អំឡុងឆមាសទី១ ឆ្នាំ២០០២ ។

សេចក្ដីព្រៀងដើមរបស់គណៈកម្មការនីតិកម្ម និងធម្មនុញ្ញត្រូវបានពិភាក្សាក្នុងសន្ធិសីទជាតិ ថ្ងៃ៨-១០ ខែធ្នូ ឆ្នាំ២០០២ ។

សេចក្ដីព្រាងរដ្ឋធម្មនុញ្ញ អនុម័តដោយសភានៅថ្ងៃទី២៣ ខែមេសា ឆ្នាំ ២០០៣ត្រូវបានដាក់ជូនប្រជាមតិនៅថ្ងៃទី២៦ ខែ ឧសភា ឆ្នាំ២០០៣ ។

៩៣% នៃអ្នកបោះឆ្នោតបានគាំទ្រ ។

I-សមាសភាព

សមាជិកព្រឹទ្ធសភាមាន២៦រូប :

-១២រូប ជ្រើសរើសដោយសមាជិកគណៈកម្មការប្រតិបត្តិនៃវិស័យ និងក្រុមប្រឹក្សាស្រុក (conseils de district) និងទីក្រុង Kigali

-៧រូប តែងតាំងដោយប្រធានាធិបតីនៃសាធារណរដ្ឋ ដែលត្រូវធានានូវភាពជាតំណាងរបស់សហគមន៍ជាតិដែលមិនមានភាពអនុគ្រោះជាងគេក្នុងប្រវត្តិសាស្ត្រ (la communauté nationale historiquement la plus défavorisée) ។

-៤រូប តែងតាំងដោយ forum នៃគណបក្សនយោបាយនានា

-២រូប មានកិរិតយ៉ាងទាបជាសាស្ត្រាចារ្យ ជ្រើសរើសជាបន្តបន្ទាប់ដោយសាស្ត្រាចារ្យនៃសាកលវិទ្យាល័យ និងវិទ្យាស្ថានអប់រំជាន់ខ្ពស់សាធារណៈនិងឯកជន ។

អតីតប្រមុខរដ្ឋទៅជាសមាជិកព្រឹទ្ធសភាដោយពេញច្បាប់ តាមសំណើរបស់សាមីខ្លួន ។

II-បេបបោះឆ្នោតនិងតែងតាំង

មុខងារជាសមាជិកសភាមានវិសមិតភាព(incompatible)ជាមួយមុខងារជាសមាជិករដ្ឋាភិបាល ។

អាយុយ៉ាងតិច : ៤០ឆ្នាំ

ប្រព័ន្ធបោះឆ្នោត : សមាជិកព្រឹទ្ធសភាជ្រើសរើសក្នុងខេត្តនីមួយ១ និងនៅទីក្រុងkigali តាមសម្លេងភាគច្រើនដាច់ខាតនៅជុំទី១(premier tour) និងតាមសម្លេងភាគច្រើនដោយប្រៀបនៅជុំទី២(second tour) ។

អាណត្តិ : ៨ឆ្នាំ គ្មានផ្លាស់ប្តូរថ្មី(non renouvelable) ។

សមាជិកព្រឹទ្ធសភាត្រូវបានតែងតាំងពីក្នុងចំណោមពលរដ្ឋដែលមានលក្ខណសម្បត្តិខ្ពស់ខាងវិទ្យាសាស្ត្រ ច្បាប់ សេដ្ឋកិច្ច នយោបាយសង្គម និងវប្បធម៌ ឬអ្នកដែលធ្លាប់កាន់មុខតំណែងសាធារណៈឬឯកជនជាន់ខ្ពស់ ។ ការតែងតាំងត្រូវគិតដល់ឯកភាពជាតិ និងភេទ៤ ៣០%យ៉ាងតិចជាស្ត្រី ។ព្រឹទ្ធសភាត្រូវឆ្លុះបញ្ចាំងនូវឯកភាពជាតិរ្វាំន់ដា ។

ប្រធានាធិបតីនៃសាធារណរដ្ឋចាត់ចែងចុងក្រោយ ដើម្បីធ្វើឱ្យមានតុល្យភាពជាអាទិ៍ខាងជនជាតិ ។

ការបោះឆ្នោតលើកទី១ : ២៩-៩-២០០៣ ។

ប្រធានាធិបតីនៃសាធារណរដ្ឋបានតែងតាំងសមាជិកព្រឹទ្ធសភា៤រូប នៅខែតុលា ឆ្នាំ២០០៣ ហើយបន្ទាប់មក ៤រូបទៀតនៅខែតុលា ឆ្នាំ២០០៤ ។

Forum នៃគណបក្សនយោបាយនានានឹងតែងតាំងសមាជិកព្រឹទ្ធសភា២រូប ។

II-សម័យប្រជុំ

សម័យប្រជុំសាមញ្ញរបស់រដ្ឋសភា និងព្រឹទ្ធសភាធ្វើឡើងនៅពេលដូចគ្នា ។

ក-សម័យប្រជុំសាមញ្ញ

សភាមានពាសម័យប្រជុំ សម័យប្រជុំនីមួយ១មានរយៈពេល២ខែ:

-លើកទី១ :បើកនៅថ្ងៃទី៥ ខែ កុម្ភៈ

-លើកទី២ : បើកនៅថ្ងៃទី៥ ខែ មិថុនា

-លើកទី៣ : បើកនៅថ្ងៃទី៥ ខែ តុលា ។

ខ-សម័យប្រជុំវិសាមញ្ញ

ព្រឹទ្ធសភាប្រជុំជាវិសាមញ្ញ តាមការកោះប្រជុំរបស់ប្រធាន ក្រោយពីបានពិគ្រោះយោបល់ជាមួយសមាជិកឯទៀតនៃការិយាល័យ ឬតាមសំណើរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ តាមសំណូមពររបស់រដ្ឋាភិបាល ឬតាមសំណើរបស់សមាជិកព្រឹទ្ធសភាចំនួន១/៤ ។

អាចកោះប្រជុំតាមការព្រមព្រៀងគ្នានៃប្រធានសភាទាំងពីរ តាមសំណើរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ឬសមាជិក១/៤នៃសភានីមួយ១ ។

សម័យប្រជុំវិសាមញ្ញត្រូវបញ្ចប់ពេលព្រឹទ្ធសភា ឬសភាអស់របៀបវារៈ ហើយមិនអាចលើសពី១៥ថ្ងៃទេ ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

ព្រឹទ្ធសភាមានអំណាចនីតិប្បញ្ញត្តិពិសេស :អនុម័តអត្ថបទសំខាន់១ ជាអាទិ៍ច្បាប់អង្គការនិងបញ្ហាជាមូលដ្ឋាន ដូចជាបញ្ហាទាក់ទងនឹងសិទ្ធិបុគ្គល ។

១-តំនិតផ្តួចផ្តើមធ្វើច្បាប់

ព្រឹទ្ធសភាមិនមានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់ទេ ។ រដ្ឋសភា និងរដ្ឋាភិបាលមានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់ ។

២-សិទ្ធិវិសោធនកម្ម

ព្រឹទ្ធសភាមានសិទ្ធិវិសោធនកម្ម ។ វិសោធនកម្មណាដែលនាំឱ្យបន្ថយធនធានជាតិ ឬបង្កើត ឬបន្ថែមបន្ទុកសាធារណៈ ត្រូវភ្ជាប់ជាមួយនូវសំណើបន្ថែមចំណូល ឬសេដ្ឋកិច្ចសមមូល ។

៣-នីតិវិធីធ្វើច្បាប់

ក- វិស័យសមត្ថកិច្ចរបស់ព្រឹទ្ធសភា

១-ច្បាប់អង្គការ

២-ច្បាប់ស្តីពីការបង្កើត ការកែប្រែ ការប្រព្រឹត្តទៅ ការលុបស្ថាប័នរដ្ឋនិងការរៀបចំដែនដី

៣-ច្បាប់ទាក់ទងនឹងសេរីភាព សិទ្ធី និងកាតព្វកិច្ចជាមូលដ្ឋានរបស់បុត្តល

៤-ច្បាប់ព្រហ្មទណ្ឌ ច្បាប់រៀបចំនិងសមត្ថកិច្ចតុលាការ និងច្បាប់នីតិវិធីព្រហ្មទណ្ឌ

៥-ច្បាប់ទាក់ទងនឹងការការពារ និងសន្តិសុខ

៦-ច្បាប់ចោះឆ្នោត និងប្រជាមតិ

៧-ច្បាប់ទាក់ទងនឹងសន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ ។

ចំពោះវិស័យថ៉វិកា យោបល់របស់ព្រឹទ្ធសភាត្រូវបានស្នើដោយប្រធានរដ្ឋសភា មុនការអនុម័តជាស្ថាពរនូវច្បាប់ស្តីពីហិរញ្ញវត្ថុ ។

ខ- ការបញ្ជូន

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវពិនិត្យជាលើកដំបូងដោយរដ្ឋសភា ហើយទើបបញ្ជូនទៅព្រឹទ្ធសភា ។

ត- នីតិវិធីប្រញ្ជាប់

ការប្រញ្ជាប់អាចស្នើឡើងដោយ (១) សមាជិកព្រឹទ្ធសភាម្នាក់ ឬសមាជិករដ្ឋសភាម្នាក់ ឬដោយ(២)រដ្ឋាភិបាលទៅសភាដែលពាក់ព័ន្ធ ។ក្នុងករណីទី១ត្រូវអនុម័តដោយសភា ក្នុងករណីទី២ ការប្រញ្ជាប់ត្រូវទទួលដោយពេញច្បាប់ ។

ការប្រញ្ជាប់ផ្តល់អាទិភាពឱ្យចុះមុនក្នុងរបៀបវារៈ ។

ឃ-ការអនុម័ត

ច្បាប់ធម្មតាត្រូវអនុម័តតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកវត្តមាននៅសភានីមួយ១ ច្បាប់អង្គការ តាមសម្លេងភាគច្រើន៣/៥ ។

ង-ការមិនព្រមព្រៀងគ្នា

បើព្រឹទ្ធសភាមិនបានអនុម័តអត្ថបទ ឬបើវិសោធនកម្មរបស់ព្រឹទ្ធសភាមិនយល់ព្រមដោយ

រដ្ឋសភា គណៈកម្មការចំរុះសមភាពី(commission mixte paritaire) ត្រូវស្នើឡើងនូវអត្ថបទមួយ លើចំណុចដែលត្រូវបន្តពិភាក្សាទៅសភាទាំងពីរ ។

បើនៅតែមិនព្រមព្រៀងគ្នា អត្ថបទត្រូវបញ្ជូនត្រឡប់ទៅអ្នកផ្តួចផ្តើមវិញ ។

ច-ការពិភាក្សាឡើងវិញ

មុនពេលប្រកាសឱ្យប្រើ ប្រធានាធិបតីនៃសាធារណរដ្ឋអាចស្នើឱ្យសភាពិនិត្យជាលើកទី២ ។

ក្នុងករណីនេះ បើសភាអនុម័តច្បាប់ដដែលតាមសម្លេងភាគច្រើនចំពោះច្បាប់ធម្មតា និង ២ភាគ៣ចំពោះច្បាប់អង្គការ ប្រធានាធិបតីនៃសាធារណរដ្ឋត្រូវប្រកាសឱ្យប្រើក្នុងរយៈពេលធម្មតា១៥ ថ្ងៃបន្ទាប់ពីបានទទួលអត្ថបទពីរដ្ឋាភិបាល ។

ឆ-អំណាចបកស្រាយ

ការបកស្រាយច្បាប់ជាសិទ្ធិរបស់សភាទាំងពីរប្រជុំរួមគ្នា ដោយមានយោបល់ជាមុនពីតុលាការកំពូល ។

ការបកស្រាយអាចស្នើឡើងដោយរដ្ឋាភិបាល សមាជិកសភា ឬគណៈមេធាវី ។

សមាជិកសភា ឬគណៈមេធាវីអាចទទួលសំណើពីជនគ្រប់រូប ដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍ ។

៤-ក្រឹត្យ-ច្បាប់

បើសភាស្ថិតក្នុងសភាពដាច់ខាតដែលមិនអាចប្រជុំបាន ប្រធានាធិបតីនៃសាធារណរដ្ឋចេញក្រឹត្យ-ច្បាប់ដែលអនុម័តដោយក្រុមប្រឹក្សារដ្ឋមន្ត្រី និងមានតម្លៃជាច្បាប់ធម្មតា ។

បើមិនបានការយល់ព្រមពីសភា នាពេលប្រជុំជិតបំផុតខាងមុខ ក្រឹត្យ-ច្បាប់ទាំងនោះអស់ត្រប់កម្លាំងចាប់បង្ខំ ។

ខ-អំណាចត្រួតពិនិត្យ

១-សំណួរ

សមាជិកព្រឹទ្ធសភាអាចដាក់សំណួរផ្ទាល់មាត់ឬ ជាលាយលក្ខណ៍អក្សរចំពោះនាយករដ្ឋមន្ត្រី

ដែលត្រូវឆ្លើយដោយផ្ទាល់ ឬដោយរដ្ឋមន្ត្រីដែលពាក់ព័ន្ធ។ ក្នុងមួយសប្តាហ៍ មានមួយពេលសំរាប់ឆ្លើយសំណួរ។

២-គណៈកម្មការស៊ើបអង្កេត

ព្រឹទ្ធសភាមានសិទ្ធិបង្កើតគណៈកម្មការស៊ើបអង្កេត។

៣-វិស័យថវិកា

រាល់ឆ្នាំ នៅមុនពេលបើកសម័យប្រជុំពិនិត្យថវិកា ការិយាល័យអគ្គលេខាធិការដ្ឋានសភានូវរបាយការណ៍នៃការអនុវត្តថវិកាកន្លងមក។

សភាអាចឱ្យការិយាល័យត្រួតពិនិត្យក្នុងគ្រប់សេវារបស់រដ្ឋ ឬសេវាដែលទាក់ទងនឹងការប្រើថវិកាដែលរដ្ឋផ្តល់ឱ្យ។

៤-វិស័យអន្តរជាតិ

សន្ធិសញ្ញាអន្តរជាតិស្តីពីសន្តិភាព ពាណិជ្ជកម្ម សន្ធិសញ្ញា ឬកិច្ចព្រមព្រៀងទាក់ទងនឹងអង្គការអន្តរជាតិ សន្ធិសញ្ញា ឬកិច្ចព្រមព្រៀងធានាខាងហិរញ្ញវត្ថុរបស់រដ្ឋកែប្រែបញ្ញត្តិដែលមានលក្ខណៈច្បាប់ សន្ធិសញ្ញាឬកិច្ចព្រមព្រៀងដែលទាក់ទងនឹងស្ថានភាពបុគ្គលអាចត្រូវបានផ្តល់សច្ចាប័នលុះត្រាមានការយល់ព្រមជាមុនពីសភា។

គ-ទំនាក់ទំនងជាមួយប្រធានាធិបតីនៃសាធារណរដ្ឋ

១-ប្រធានាធិបតីទាក់ទងជាមួយសភាដោយសារជូនទៅសភាណាមួយ ឬសភាទាំងពីរប្រជុំរួម ដោយផ្ទាល់ខ្លួន ឬតាមរយៈនាយករដ្ឋមន្ត្រី។

សារទាំងនេះមិនអាចយកទៅពិភាក្សាបានឡើយ។ នៅចន្លោះសម័យប្រជុំសភា សភាណាមួយត្រូវកោះប្រជុំជាពិសេសចំពោះកិច្ចការនេះ។

២-ស្ថិតិ

ក្នុងករណីវិស្សមកាលនៃតំណែងប្រធានាធិបតីនៃសាធារណរដ្ឋដោយអនិច្ចកម្ម លាលែង ឬមិនអាចបំពេញមុខងារជាស្ថាពរ ប្រធានព្រឹទ្ធសភាទទួលជាប្រធានាធិបតីស្ថិតិ។

បើប្រធានព្រឹទ្ធសភាមិនអាចបំពេញការងារបាន ប្រធានរដ្ឋសភា(នាយករដ្ឋមន្ត្រី)ទទួលជាប្រធានាធិបតីស្តីទី ។

៧-បទឧបសម្ព័ន្ធផ្សេងៗ

ក-វិស័យធម្មនុញ្ញ

១-ការសើរើរដ្ឋធម្មនុញ្ញ

គំនិតផ្តួចផ្តើមសើរើរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ និងរបស់សមាជិកមួយ១ ។ ការសើរើរដ្ឋធម្មនុញ្ញ ត្រូវអនុម័តតាមសម្លេងភាគច្រើនបីភាគបួននៃសមាជិកសភាទាំងមួយ១(សំរាប់វិស័យខ្លះ ត្រូវអនុម័តជាបន្ទាប់ដោយប្រជាមតិ) ។

២-ការត្រួតពិនិត្យធម្មនុញ្ញភាព

តុលាការជាន់ខ្ពស់ត្រួតពិនិត្យធម្មនុញ្ញភាពរបស់ច្បាប់ សន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ តាមសំណើរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា សមាជិកព្រឹទ្ធសភា ឬសមាជិករដ្ឋសភាចំនួនមួយភាគប្រាំ ។

ខ-វិស័យតុលាការ

១-ការចោទប្រកាន់នៅតុលាការជាន់ខ្ពស់ (Cour suprême)

ការចោទប្រកាន់ប្រធានាធិបតីនៃសាធារណរដ្ឋអំពីអំពើក្បត់ឬបំពានធ្ងន់ធ្ងរចំពោះរដ្ឋធម្មនុញ្ញ ត្រូវអនុម័តដោយសភាទាំងពីរប្រជុំរួមគ្នា តាមសម្លេងភាគច្រើននៃសមាជិកសភានីមួយ១ ។

បន្ទាប់ទៅ ប្រធានាធិបតីត្រូវវិនិច្ឆ័យដោយតុលាការកំពូល ។

២-តុលាការជាន់ខ្ពស់ (Haute cour)

ការខ្វះខាតធ្ងន់ធ្ងររបស់គណបក្សនយោបាយចំពោះកាតព្វកិច្ច ដែលតម្រូវដោយរដ្ឋធម្មនុញ្ញ តាមគោលការណ៍ប្រជាធិបតេយ្យ គោលការណ៍មិនរើសអើង ត្រូវព្រឹទ្ធសភាដាក់ជូនតុលាការជាន់ខ្ពស់នៃសាធារណរដ្ឋដែលអាចសម្រេចពីព្រមានរហូតដល់រំលាយគណបក្សនយោបាយ ។

ត-អំណាចតែងតាំង(pouvoir de nomination)

១-ព្រឹទ្ធសភាជ្រើសរើសប្រធាន អនុប្រធានព្រឹទ្ធសភា ចៅក្រមតុលាការកំពូល អគ្គរដ្ឋ-អាជ្ញា (procureur général) និងអគ្គរដ្ឋអាជ្ញារងនៃសាធារណរដ្ឋ ។

២-យល់ព្រមលើការតែងតាំងអ្នកដឹកនាំ និងសមាជិកគណៈកម្មការជាតិ (សិទ្ធិ បុគ្គល ឯកភាព និងការបង្រួបបង្រួម ប្រឆាំងនឹងការប្រល័យពូជសាសន៍ ...) អ្នកការពារពលរដ្ឋ អគ្គ-សវនាការរដ្ឋ និងអគ្គសវនាការរង ឯកអគ្គរដ្ឋទូត និងតំណាងអចិន្ត្រៃយ៍ ចៅហ្វាយខេត្ត (des préfets de provinces) នាយកអង្គការរដ្ឋ ។

ប្រធាន អនុប្រធានតុលាការកំពូលសំរាប់អាណត្តិតែមួយ រយៈពេល៨ឆ្នាំ និងចៅក្រមត្រូវជ្រើសរើស តាមសម្លេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភា តាមសំណើរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ដែលមានបេក្ខជន២រូប សំរាប់តំណែងមួយ និងក្រោយពីពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សារដ្ឋមន្ត្រី និងខុត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (conseil supérieur de la magistrature) ។

ប្រធាន និងអនុប្រធានតុលាការអាចត្រូវដកពីមុខតំណែង ពីបទបាត់បង់ភាពថ្ឋៃថ្ឋូរអសមត្ថភាព កំហុសវិជ្ជាជីវៈធ្ងន់ធ្ងរដោយសភា តាមសម្លេងភាគច្រើន២/ ៣នៃសមាជិកសភានីមួយ១ និងតាមការផ្តួចផ្តើមតំនិតរបស់សមាជិករដ្ឋសភាឬព្រឹទ្ធសភាចំនួន៣/៥ ។

ឃ-ការប្រកាសសង្ត្រាម

សង្ត្រាមត្រូវប្រកាសដោយប្រធានាធិបតីនៃសាធារណរដ្ឋ ដែលត្រូវជូនដំណឹងទៅសភាក្នុងរយៈពេល៧ថ្ងៃ ។ សភាត្រូវសម្រេចលើការប្រកាសនេះ តាមសម្លេងភាគច្រើននៃសមាជិកសភានីមួយ១ ។

ង-ស្ថានភាពអាសន្ន និងស្ថានភាពបន្ទាន់

-ប្រកាសដោយប្រធានាធិបតីនៃសាធារណរដ្ឋ ក្រោយការសម្រេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

-ការពន្យារពេលលើសពី១៥ថ្ងៃ អាចត្រូវអនុញ្ញាតតែដោយសភា តាមសម្លេងភាគច្រើននៃសមាជិកសភានីមួយ១ ។ ក្នុងរយៈពេលនៃស្ថានភាពខាងលើ សភាត្រូវកោះប្រជុំជាស្វ័យប្រវត្តិ

បើសិនជានៅចន្លោះសម័យប្រជុំ ។

បើនៅថ្ងៃប្រកាសស្ថានភាពអាសន្ន និងស្ថានភាពបន្ទាន់ រដ្ឋសភាត្រូវវិលាយឬចប់អាណត្តិ សមត្ថកិច្ចរបស់សភាទាក់ទងនឹងស្ថានភាពអាសន្ន និងស្ថានភាពបន្ទាន់ត្រូវប្រគល់ឱ្យព្រឹទ្ធសភា ។

I-សមាសភាព

ព្រឹទ្ធសភាមានសមាជិក១១រូប តែងតាំងដោយអគ្គទេសាភិបាល:

-៦រូប តាមសំណើរបស់នាយករដ្ឋមន្ត្រី

-៣រូប តាមសំណើរបស់ប្រធានគណបក្សជំទាស់

-២រូប ក្រោយបានពីគ្រោះយោបល់ពីតំណាងខាងសាសនា សេដ្ឋកិច្ច សង្គម ឬសមាគមនានា ដែលក្នុងនោះអគ្គទេសាភិបាលយល់ថាសមាជិកព្រឹទ្ធសភាទាំងនេះត្រូវបានតែងតាំង។

I-របបតែងតាំង

អាណត្តិ : ៥ឆ្នាំ

ការផ្លាស់ប្តូរចុងក្រោយ : ៣ ធ្នូ ២០០១

លក្ខខណ្ឌ : អាយុ២១ឆ្នាំ ជាពលរដ្ឋ commonwealth britannique រស់នៅ Sainte-Lucie រយៈពេល៥ឆ្នាំមុនពេលបោះឆ្នោត ។

មិនអាចតែងតាំង : ជាប់កាតព្វកិច្ចជាមួយបរទេស ធនធ្ងន់ធ្ងរមានទីតិសម្បទាសង្ស័យ ទោសប្រហារជីវិត ទោសពន្ធនាគារលើសពី៥ឆ្នាំ ។

រៀងមិតភាព : ឧត្តមមន្ត្រី រដ្ឋមន្ត្រីវប្បធម៌

រ៉ាវ៉ាទអ់ពីសុពលភាពនៃការតែងតាំង ជាសមត្ថកិច្ចរបស់តុលាការកំពូល ។

II-សម័យប្រជុំ

ក- សភាមិនអាចមិនប្រជុំលើសពី១២ខែជាប់គ្នាទេ ។

ខ-សម័យប្រជុំពេញច្បាប់ (session de droit) ។

ព្រឹទ្ធសភាប្រជុំពេញច្បាប់យ៉ាងយូរ១ខែ ក្រោយការបោះឆ្នោតសភា ។

គ-ការលើកពេល (ajournement)

ព្រឹទ្ធសភាត្រូវលើកពេលប្រជុំ បើមិនមានសមាជិក៦នាក់យ៉ាងតិចចូលរួម ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

សភាសាំងត-លូស៊ី មានមហាក្សត្រីយ៍អង់គ្លេស ព្រឹទ្ធសភា និងរដ្ឋសភា ។

ក-អំណាចនីតិប្បញ្ញត្តិ

ព្រឹទ្ធសភាមានអំណាចនីតិប្បញ្ញត្តិមានកំរិត ។

១-ឥទ្ធិពលផ្តួចផ្តើមធ្វើច្បាប់

សមាជិកសភាមានសិទ្ធិផ្តួចផ្តើមឥទ្ធិពលធ្វើច្បាប់ ។ ប៉ុន្តែអំណាចរបស់សភាទាំងពីរមានកំរិតក្នុងវិស័យហិរញ្ញវត្ថុ និងថវិកាចំពោះគ្រប់កំណែទម្រង់ដែលតាមការវាយតម្លៃរបស់ប្រធានអង្គប្រជុំ ឈានទៅកែប្រែពន្ធដារ (បន្ថយពន្ធ) បន្ថែមបន្ទុកសាធារណៈ បន្ថយធនធានសាធារណៈ ឬដែលទាក់ទងនឹងបំណុលសាធារណៈ ។

២-សិទ្ធិវិសោធនកម្ម

សមាជិកសភាមានសិទ្ធិវិសោធនកម្ម ប៉ុន្តែអំណាចនេះមានកំរិតក្នុងវិស័យហិរញ្ញវត្ថុ និងថវិកាចំពោះវិសោធនកម្មដែល តាមការវាយតម្លៃរបស់ប្រធានអង្គប្រជុំ ឈានទៅកែប្រែពន្ធដារ (បន្ថយពន្ធ) បន្ថែមបន្ទុកសាធារណៈ បន្ថយធនធានសាធារណៈ ឬដែលទាក់ទងនឹងបំណុលសាធារណៈ ។

៣-នីតិវិធីធ្វើច្បាប់

សេចក្តីព្រាងច្បាប់អាចដាក់ជូនសភាណាមួយ លើកលែងតែសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុដែលត្រូវដាក់ជូនរដ្ឋសភាជាមុន ។

ប្រធានអង្គប្រជុំមិនចូលរួមអនុម័តទេ លើកលែងតែមានសម្លេងស្មើគ្នា ។

ក-នីតិវិធីធម្មតា

អត្ថបទត្រូវចាត់ទុកថាបដិសេធដោយព្រឹទ្ធសភា ពេលដែលវិសោធនកម្មរបស់ព្រឹទ្ធសភាមិនត្រូវបានរដ្ឋសភាអនុម័ត ។

អត្ថបទត្រូវឆ្លងហួសពីការជំទាស់របស់ព្រឹទ្ធសភា នៅការកែទម្រង់ច្បាប់ បើអត្ថបទនោះត្រូវបានអនុម័តដោយរដ្ឋសភានៅពីរសម័យប្រជុំបន្តបន្ទាប់ និងត្រូវច្រានចោលដោយព្រឹទ្ធសភា

នៅសម័យប្រជុំនីមួយ១នោះក្នុងលក្ខខណ្ឌដែលសេចក្តីព្រាងត្រូវបានបញ្ជូនទៅព្រឹទ្ធសភាយ៉ាងតិច ១ខែមុនចប់សម័យប្រជុំនិងរយៈពេល៦ខែបានកន្លងផុតពីពេលអនុម័ត១ទៅពេលអនុម័ត១ទៀត នៅរដ្ឋសភា (Il est passé outre l'opposition du Sénat à une réforme législative si le texte a été adopté par la chambre de l'Assemblée lors de deux sessions successives et repoussé par le Sénat á chacune de ses sessions , à condition que le projet ait été transmis au Sénat au moins un mois avant la fin de la session , et qu'un délai de six mois se soit écoulé entre chacune des odoptions du texte par la Chambre de l'Assemblée) ។

ក៏ប៉ុន្តែមុនការអានលើកទី២នៅព្រឹទ្ធសភា រដ្ឋសភាអាចស្នើនូវវិសោធនកម្មទៅព្រឹទ្ធសភា ។ កាលបើព្រឹទ្ធសភាអនុម័តនូវវិសោធនកម្មទាំងនោះ ត្រូវចាត់ទុកថាវិសោធនកម្មទាំងនោះជាវិសោធនកម្ម របស់ព្រឹទ្ធសភាដែលយល់ព្រមដោយរដ្ឋសភា ។

ខ-បញ្ញត្តិពិសេសខាងថវិកា

លក្ខខណ្ឌពិសេសអំពីរយៈពេល ត្រូវកំណត់សំរាប់ការអនុម័តច្បាប់បរិញ្ញាវត្ថុដោយព្រឹទ្ធសភា: បើសេចក្តីព្រាងត្រូវបានអនុម័តដោយរដ្ឋសភា ហើយបញ្ជូនទៅព្រឹទ្ធសភា យ៉ាងតិច១ខែ មុនចប់ សម័យប្រជុំមិនត្រូវបានព្រឹទ្ធសភាអនុម័តឆ្នាំវិសោធនកម្មក្នុងរយៈពេល១ខែ ចាប់ពីពេលបញ្ជូន អត្ថបទនោះត្រូវដាក់ជូនអត្ថទេសាភិបាលចុះហត្ថលេខា បើសិនរដ្ឋសភាមិនសម្រេចផ្សេងទៀត ។

ខ-អំណាចត្រួតពិនិត្យ

ខុទ្ទកាល័យ(នាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីនានា) ទទួលខុសត្រូវរួមចំពោះសភា (ប៉ុន្តែមានតែរដ្ឋសភាទេដែលមានសិទ្ធិអនុម័តញ្ញត្តិបន្ទោស) ។

ค-ការរំលាយ និងការពន្យារ

១-ការរំលាយ

អត្ថទេសាភិបាលអាចរំលាយសភាបានគ្រប់ពេល ដោយមានការយល់ព្រមពីនាយករដ្ឋមន្ត្រី ។

២-ការពន្យារ

អត្ថទេសាភិបាលអាចពន្យារអាណត្តិសភាបានគ្រប់ពេល ។ ក្នុងករណីសង្គ្រាម ការពន្យារ អាចធ្វើទៅបានរយៈពេល១២ខែ ហើយអាចបន្តបាន(៥ឆ្នាំយ៉ាងច្រើន) ។

V-បណ្ឌិត្យត្តិ៏ជ័យនៃ្ចក

ក-ការសើរើរដ្ឋធម្មនុញ្ញ

ការអនុម័ត ទៅការអានចុងក្រោយ លើការសើរើរដ្ឋធម្មនុញ្ញ (ក៏ដូចជាច្បាប់ទាក់ទងនឹងតុលាការកំពូល) ត្រូវយកតាមសម្លេងភាគច្រើន៣៥ ឬ២ ៣នៃសមាជិកសភានីមួយៗ ទៅតាមបញ្ញត្តិដែលជាកម្មវត្ថុនៃការសើរើ ។

បើសេចក្តីព្រាងសើរើរដ្ឋធម្មនុញ្ញត្រូវព្រឹទ្ធសភាច្រានចោល២លើក សេចក្តីព្រាងនេះនឹងមានសុពលភាពតែតាមរយៈប្រជាមតិ (សម្រាប់តែបញ្ញត្តិខ្លះនៃរដ្ឋធម្មនុញ្ញ) ។

ខ-ស្ថានភាពបន្ទាន់

ស្ថានភាពបន្ទាន់ត្រូវប្រកាសដោយអគ្គទេសាភិបាល ។

ការប្រកាសស្ថានភាពបន្ទាន់អស់ប្រសិទ្ធភាព បើមិនបានការអនុម័តរបស់ព្រឹទ្ធសភា និងរដ្ឋសភា ក្នុងរយៈពេល៧ថ្ងៃគិតពីពេលចុះផ្សាយពេលសភានៅក្នុងសម័យប្រជុំ ក្នុងរយៈពេល២១ថ្ងៃ ក្នុងករណីផ្សេងទៀត ។

គ-ស្នងការសភា (commissaire parlementaire)

ស្នងការសភាសាំង-ណូស៊ី ជាមន្ត្រីរបស់សភា សម្រាប់តែមុខងារនេះ តែងតាំងដោយអគ្គទេសាភិបាល ក្រោយការពិគ្រោះយោបល់ជាមួយនាយករដ្ឋមន្ត្រី និងប្រធានគណបក្សជំទាស់នៅរដ្ឋសភា ។

ស្នងការសភាទទួលស៊ើបអង្កេតលើរាល់សេចក្តីសម្រេច ឬលើរាល់សកម្មភាពរបស់រដ្ឋាភិបាល ឬអំណាចសាធារណៈ លើពាក្យបណ្តឹងជាបុគ្គលឬរបស់សមាជិកព្រឹទ្ធសភាឬសមាជិករដ្ឋសភាម្នាក់ៗ ។

ស្នងការសភាមានអំណាចកោះហៅសាក្សី ស៊ើបអង្កេតលើឯកសារ ឬនៅនឹងកន្លែងដោយមិនរំខានដល់ការស៊ើបអង្កេតរបស់តុលាការ ។

មិនរាប់បញ្ចូលក្នុងអំណាចរបស់ស្នងការសភា:

-ទំនាក់ទំនងបរទេស

-បើមានការស៊ើបអង្កេតរបស់តុលាការលើប្រធានបទ

-សិទ្ធិសម្រាលទោស (droit de grâce) របស់អគ្គទេសាភិបាល

-កម្លាំងប្រដាប់អាវុធ

-ការតែងតាំង ប្រាក់បំណាច់ និងក្រុមខ័ណ្ឌភ្នាក់ងារសាធារណៈ ។

សេណេហ្គាល **ព្រឹទ្ធសភា**

SENEGAL LE SENAT

រដ្ឋសភាសេណេហ្គាលបានអនុម័តនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ នូវច្បាប់មួយដែលបង្កើតព្រឹទ្ធសភាឡើងវិញ ។

ក្រោមរបបលោកប្រធាន អាប់ឌូ ឌីអ្ហ(Abdou Diouf) ព្រឹទ្ធសភាដែលកើតឡើងលើកទី១នៅខែមករាឆ្នាំ១៩៩៩ បានលប់បំបាត់ដោយមូលហេតុសេដ្ឋកិច្ច តាមប្រជាមតិលើរដ្ឋធម្មនុញ្ញនៅថ្ងៃទី៧ខែមករាឆ្នាំ២០០១ ។

I-សមាសភាព: ៦០នាក់

-៤៥នាក់ តំណាងសមូហភាពដែនដី

-៣នាក់ តំណាងប្រជាជនសេណេហ្គាលនៅក្រៅប្រទេស

-១២នាក់ តែងតាំងដោយប្រធានាធិបតី អាណត្តិ : ៥ឆ្នាំ ។

II-របបបោះឆ្នោត

១-សមាជិកព្រឹទ្ធសភាតំណាងសមូហភាពដែនដី ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាសកល មិនចំពោះ(universel indirect) ក្នុង១០តំបន់(ពី៤ទៅ៧នាក់/មួយតំបន់) ។

អង្គបោះឆ្នោត:សមាជិករដ្ឋសភា សមាជិកក្រុមប្រឹក្សាមូលដ្ឋាន -ក្រុង ឬតំបន់(ប្រហែល ១៣.000នាក់) ។

២-សមាជិកព្រឹទ្ធសភាតំណាងប្រជាជនសេណេហ្គាលនៅក្រៅប្រទេសត្រូវបានជ្រើសរើសពីក្នុងចំណោមប្រតិភូក្រុមប្រឹក្សាជាន់ខ្ពស់នៃប្រជាជនសេណេហ្គាលដោយសមាជិកនៃក្រុមប្រឹក្សា ។

លក្ខខណ្ឌអាយុ : ៣៥ឆ្នាំយ៉ាងតិច

ការបោះឆ្នោតលើកទី១ : ២៤ មករា ១៩៩៩ ។

II-សម័យប្រជុំ

ក-សម័យប្រជុំសាមញ្ញ

ព្រឹទ្ធសភាប្រជុំជាសាមញ្ញ២ដងក្នុងមួយឆ្នាំ ។ សម័យប្រជុំនីមួយៗមានរយៈពេល៣ខែ

យ៉ាងច្រើន ។

សម័យប្រជុំលើកទី១ចាប់ផ្តើមក្នុងអំឡុងត្រីមាសទី២នៃឆ្នាំ សម័យប្រជុំលើកទី២ចាប់ផ្តើមក្នុងពាក់កណ្តាលទី១នៃខែតុលា ។

កាលបរិច្ឆេទនៃការបើកសម័យប្រជុំ និងរយៈពេលត្រូវបានកំណត់ដោយរដ្ឋសភា ក្រោយពីមានយោបល់របស់ប្រធានព្រឹទ្ធសភា ។

ខ-សម័យប្រជុំវិសាមញ្ញ

សម័យប្រជុំវិសាមញ្ញមានរយៈពេល៣០ថ្ងៃយ៉ាងយូរតាមរបៀបវារៈជាក់លាក់ :

-តាមសំណើយ៉ាងតិច៥០%ក្នុង១នៃចំនួនសមាជិករដ្ឋសភា

-តាមការផ្តើមគំនិតរបស់ប្រធានាធិបតី តាមសំណើរបស់រដ្ឋមន្ត្រីទី១ ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងជាមួយអង្គការយុត្តិធម៌

ក-អំណាចនីតិប្បញ្ញត្តិ

១-ការផ្ទេរផ្តើមគំនិតច្បាប់

សមាជិកព្រឹទ្ធសភាមានសិទ្ធិផ្ទេរផ្តើមគំនិតច្បាប់ដូចប្រធានាធិបតី និងសមាជិករដ្ឋសភា ។

សេចក្តីស្នើច្បាប់ដែលផ្ទេរផ្តើមដោយសមាជិកព្រឹទ្ធសភាត្រូវតែដាក់ជូនរដ្ឋសភាអនុម័តជាលើកដំបូង ។សេចក្តីស្នើច្បាប់ដែលផ្ទេរផ្តើមដោយសមាជិកសភាមិនអាចនាំឱ្យមានការបន្ថយធនធានសាធារណៈ ការបង្កើត ឬការបង្កើនបន្ទុកសាធារណៈ លើកលែងតែសេចក្តីស្នើទាំងនោះមានភ្ជាប់ទៅជាមួយនូវសេចក្តីស្នើបង្កើនចំណូលដើម្បីបំពេញឱ្យវិញ ។

២-សិទ្ធិវិសោធនកម្ម

សមាជិកព្រឹទ្ធសភាមានសិទ្ធិធ្វើវិសោធនកម្មច្បាប់ដូចប្រធានាធិបតី និងសមាជិករដ្ឋសភា ។

វិសោធនកម្មរបស់សមាជិកសភាមិនអាចនាំឱ្យមានការបន្ថយធនធានសាធារណៈ ការបង្កើត ឬការបង្កើនបន្ទុកសាធារណៈ លើកលែងតែសេចក្តីស្នើទាំងនោះមានភ្ជាប់មកនូវសំណើបង្កើនចំណូលបំពេញឱ្យវិញ ។

៣-នីតិវិធីធ្វើច្បាប់

ព្រឹទ្ធសភាទទួលពិនិត្យសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់នៅលើកទី២(បន្ទាប់ពីរដ្ឋសភា) ។ សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវតែបញ្ជូនទៅឱ្យគណៈកម្មការណាមួយក្នុងចំណោមគណៈកម្មការជំនាញទាំង៧ មុននឹងបញ្ជូនទៅសម័យប្រជុំពេញអង្គជាសាធារណៈ ។

ប្រធានាធិបតីត្រូវតែបានទទួលព័ត៌មានអំពីរបៀបវារៈរបស់គណៈកម្មការ តាមរយៈតំណាងនៅព្រឹទ្ធភា ។

ព្រឹទ្ធសភាត្រូវពិនិត្យរយៈពេល២០ថ្ងៃរាប់ពីថ្ងៃទទួល ។ រយៈពេលត្រូវបន្ថយមក៧ថ្ងៃក្នុងករណីប្រញាប់ដែលប្រកាសដោយរដ្ឋាភិបាល ។

ក្នុងករណីគ្មានការព្រមព្រៀងគ្នារវាងសភាទាំងពីរ ឬបើសិនព្រឹទ្ធសភាមិនបានពិនិត្យក្នុងរយៈពេលកំណត់ រដ្ឋសភាសម្រេចជាចុងក្រោយ ។

៨-អំណាចត្រួតពិនិត្យ

ព្រឹទ្ធសភាអាចៈ

-ដាក់សំណូរជាលាយលក្ខណ៍អក្សរឬផ្ទាល់មាត់ ដោយមានឬគ្មានសូរដេញដោល

-បង្កើតគណៈកម្មការស៊ើបអង្កេត

-ចេញសេចក្តីសម្រេចចិត្តជូនទៅប្រធានាធិបតី ។

V-**បទប្បញ្ញត្តិពិសេស**

ក-អំណាចទាក់ទងនឹងធម្មនុញ្ញ (pouvoir constituant)

១-ការផ្តួចផ្តើមគំនិត

សមាជិកព្រឹទ្ធសភាមានសិទ្ធិផ្តួចផ្តើមគំនិតសើរើរដ្ឋធម្មនុញ្ញដូចប្រធានាធិបតី និងសមាជិករដ្ឋសភាដែរ ។

២-នីតិវិធី

សេចក្តីស្នើឬសេចក្តីព្រាងសើរើរដ្ឋធម្មនុញ្ញ បើសិនជាមិនមានការធ្វើប្រជាមតិទេត្រូវអនុម័ត

ដោយសមាជិកសភាតាមសម្លេងភាគច្រើន៣/៤នៃឆ្នោតដែលបានបោះ ។

ខ-ក្នុងករណីប្រធានាធិបតីលាលែងពីតំណែងមិនអាចបំពេញការងារឬអនិច្ចកម្ម ប្រធានព្រឹទ្ធសភាទទួលតំណែងស្តីទីប្រធានាធិបតី ។

គ-ជ្រើសរើសចៅក្រមសភា ចំនួនពាក់កណ្តាលនៃតុលាការយុត្តិធម៌ជាន់ខ្ពស់ ។

ក្រុមប្រឹក្សាជាតិជាតំណាងអ្នកមានផលប្រយោជន៍សង្គមសេដ្ឋកិច្ច មុខរបរនិងមូលដ្ឋាន។

ក្រុមប្រឹក្សាជាតិមានសមាជិក៤០រូប ជ្រើសរើស ដោយមិនចំពោះ ។

-៤រូប តំណាងនយោជក

-៤រូប តំណាងនយោជិក

-៤រូប តំណាងកសិករ សិប្បករ និងមុខរបរសេរី

-៦រូប តំណាងវិស័យសកម្មភាពមិនមែនសេដ្ឋកិច្ច (សុខាភិបាល វិទ្យាសាស្ត្រ អប់រំ និងសន្តិសុខ សង្គម)

-២២រូប តំណាងផលប្រយោជន៍មូលដ្ឋាន ។

II-របបបោះឆ្នោត

-មិនចំពោះ(indirect)

-អង្គបោះឆ្នោត អាស្រ័យតាមការណី:

-វិស័យសេដ្ឋកិច្ចនិងសង្គម :ជនបរទេស ប្រកបមុខរបរឬធ្វើការនៅស្លូវេនី អាចចូលរួម ក្នុងការបោះឆ្នោតជ្រើសរើសតំណាងវិស័យសេដ្ឋកិច្ច និងសង្គម ។

-ទីក្រុង : ក្នុងមណ្ឌលនីមួយ១(ក្នុងចំណោម២២) អង្គបោះឆ្នោតមាន :

-សមាជិកសភាមូលដ្ឋានបើសិនមណ្ឌលមានសហគមន៍តែ១

-តំណាងជ្រើសតាំងដោយសភានានានៃសហគមន៍ បើមណ្ឌលមានច្រើនសហគមន៍ ។

អាណត្តិ : ៥ឆ្នាំ

ការផ្ទាស់ប្តូរចុងក្រោយ: ១ ធ្នូ ឆ្នាំ២០០២ ។

III-សម័យប្រជុំ

ក-សម័យប្រជុំសាមញ្ញ

ប្រធានកោះប្រជុំក្រុមប្រឹក្សាជាតិជាសាមញ្ញ តាមការផ្ទូចផ្តើបផ្ទាល់ ឬតាមការសម្រេច

របស់ក្រុមប្រឹក្សា តាមសំណើរបស់គណៈកម្មការណាមួយ ឬរបស់នាយកម្នាក់ ឬច្រើននៃក្រុមដែលមានផលប្រយោជន៍ ឬតាមសំណើរបស់ទីប្រឹក្សាជាតិចំនួន៨រូប ។

ខ-បើអត្ថបទដែលក្រុមប្រឹក្សាជាតិពិភាក្សារុងនឹងជំទាស់ដោយព្យួរ(véto suspensif) ត្រូវបានចុះក្នុងរបៀបវារៈប្រជុំរដ្ឋសភា ប្រធានក្រុមប្រឹក្សាជាតិត្រូវកោះប្រជុំក្រុមប្រឹក្សា ក្នុងរយៈពេល ៦ថ្ងៃ បន្ទាប់ពីការអនុម័តរបស់រដ្ឋសភា ។

គ-ក្រុមប្រឹក្សាជាតិប្រជុំប្រចាំឆ្នាំ២ពាក់កណ្តាលក្នុង១ឆ្នាំ និងយ៉ាងតិច២ ដងក្នុង១ខែ ។

IV-ធ្នាក់ធ្ងន់ទាបមួយរដ្ឋសភានិងអំណាចនីតិប្បញ្ញត្តិ

(របបសភាពីរមិនស្មើភាព (bicamérisme inégalitaire)

ក-អំណាចនីតិប្បញ្ញត្តិ(មានកំរិត)

១-គំនិតផ្តួចផ្តើមធ្វើច្បាប់

តាមការផ្តួចផ្តើមគំនិតរបស់ទីប្រឹក្សានានាឬគណៈកម្មការនានា ក្រុមប្រឹក្សាជាតិអាចស្នើសុំឱ្យរដ្ឋសភាធ្វើការអនុម័តច្បាប់ ។

២- សិទ្ធិវិសោធនកម្ម

តាមការផ្តួចផ្តើមគំនិតរបស់ទីប្រឹក្សានានា ឬគណៈកម្មការនានា ក្រុមប្រឹក្សាជាតិអាចស្នើសុំឱ្យរដ្ឋសភាធ្វើការអនុម័តវិសោធនកម្មច្បាប់ ។

៣-ជំទាស់ដើម្បីព្យួរ(véto suspensif)

ក្រុមប្រឹក្សាជាតិអាចស្នើឱ្យរដ្ឋសភាពិនិត្យច្បាប់ឡើងវិញម្តងទៀត ក្នុងរយៈពេល៧ថ្ងៃពីពេលអនុម័ត និងមុនពេលប្រកាសឱ្យប្រើ ។

ច្បាប់ត្រូវអនុម័តតាមសម្លេងភាគច្រើននៃសមាជិករដ្ឋសភា លើកលែងតែតម្រូវឱ្យមានសម្លេងភាគច្រើនលើសពីនេះ (majorité qualifiée) ។

នៅខែមករាឆ្នាំ២០០០ ចាប់តាំងពីពេលបង្កើតឡើងនាថ្ងៃ២៣ធ្នូឆ្នាំ១៩៩២ ក្រុមប្រឹក្សាជាតិបានជំទាស់៥១ករណី (៣៤ក្នុងអាណត្តិទី១ និង១៧ចាប់ពីដើមអាណត្តិបច្ចុប្បន្ន) ។

៤-ប្រជាមតិលើច្បាប់

តាមសម្លេងភាគច្រើននៃសមាជិករបស់ខ្លួន ក្រុមប្រឹក្សាជាតិអាចស្នើទៅរដ្ឋសភាឲ្យមានការធ្វើប្រជាមតិ ដែលរដ្ឋសភាត្រូវកំណត់ពេល ។

ការស្នើនេះអាចដាក់បានរហូតពេលចាប់ផ្តើមការអានលើកទីពីរ និងជាលើកចុងក្រោយនៅរដ្ឋសភាសំរាប់ប្រជាមតិជាមុន (référendums préalables) និងមិនលើសពីវិធីក្រោយការអនុម័តសំរាប់ប្រជាមតិជាក្រោយ(référendums postérieurs) ។

ខ-អំណាចត្រួតពិនិត្យ

តាមសម្លេងភាគច្រើននៃទីប្រឹក្សាវត្តមាន ក្រុមប្រឹក្សាជាតិអាចស្នើសុំរដ្ឋសភាធ្វើការស៊ើបអង្កេតលើការងារដែលមានលក្ខណៈសាធារណៈ ។

រដ្ឋសភាត្រូវបង្កើតគណៈកម្មការស៊ើបអង្កេត ។ រដ្ឋសភាអាចពង្រីក ឬកែប្រែពាក្យសុំ បើក្រុមប្រឹក្សាជាតិមិនជំទាស់ ។

V-បទឧប្បញ្ញត្តិជំនួយនៃ

ក-អំណាចផ្តល់យោបល់ (pouvoirs d'avis)

ក្រុមប្រឹក្សាជាតិអាចផ្តល់យោបល់ទៅរដ្ឋសភា លើគ្រប់ការងារដែលខ្លួនមានសមត្ថកិច្ច ។ តាមសំណើរបស់រដ្ឋសភា ក្រុមប្រឹក្សាជាតិត្រូវផ្តល់យោបល់លើការងារជាក់លាក់ណាមួយ ។

គឺជាមធ្យោបាយរបស់ក្រុមប្រឹក្សាជាតិក្នុងការបញ្ជូន និងបង្ហាញរដ្ឋសភានូវផលប្រយោជន៍របស់ក្រុម សង្គម មុខរបរ និងមូលដ្ឋានដែលខ្លួនបានទទួល ។

សេចក្តីស្នើនានា ការផ្ទៀងផ្ទើម ឬសំណូរដែលត្រូវបានបញ្ជូនទៅរដ្ឋសភាត្រូវដាក់ដោយទីប្រឹក្សាណាមួយនិងបញ្ជូនទៅគណៈកម្មការមានសមត្ថកិច្ចដែលអនុម័តនូវរបាយការណ៍លើប្រធានបទ មុនការពិភាក្សាក្នុងសម័យប្រជុំ ។ រដ្ឋាភិបាល ឬអង្គការរដ្ឋអាចត្រូវចោទសួរ ។

ប្រធានរដ្ឋសភាបញ្ជូនសំណើ យោបល់ និងពាក្យសុំរបស់ក្រុមប្រឹក្សាជាតិទៅសមាជិករដ្ឋសភាគ្រប់រូប និងរដ្ឋាភិបាល ហើយស្នើឲ្យរដ្ឋាភិបាល ឬអង្គការមានសមត្ថកិច្ចបង្ហាញយោបល់របស់ខ្លួនជូនរដ្ឋសភា ។

តំណាង១រូបរបស់ក្រុមប្រឹក្សាជាតិ អាចត្រូវអញ្ជើញឱ្យចូលរួមក្នុងការប្រជុំអង្គការរបស់រដ្ឋសភាដែលពិនិត្យយោបល់របស់ក្រុមប្រឹក្សា ។ ប្រធានក្រុមប្រឹក្សាត្រូវបានជូនដំណឹងអំពីការអនុម័ត ។

ខ-សំណើចំពោះក្រុមប្រឹក្សាធម្មនុញ្ញ

ក្រុមប្រឹក្សាជាតិអាចស្នើក្រុមប្រឹក្សាធម្មនុញ្ញឱ្យត្រួតពិនិត្យមើលធម្មនុញ្ញភាព និងភាពស្របច្បាប់នៃអត្ថបទដែលមានលក្ខណៈគតិយុត្ត ។

ស៊ូដង់ចេញពីសង្គ្រាមស៊ីវិលជាច្រើនឆ្នាំ ។

គណៈកម្មការចំពោះកិច្ច (commission ad hoc) នៃគណបក្សកាន់អំណាច ទទួលបន្ទុកវិសោធនកម្មរដ្ឋធម្មនុញ្ញ១៩៩៨ បានដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួនជូនសភានៅរដូវ printemps ឆ្នាំ២០០២ ។

គណៈកម្មការបានស្នើជាពិសេសបន្ថែមនៃរដ្ឋធម្មនុញ្ញ ទូវបញ្ញត្តិចែងអំពីការបង្កើតព្រឹទ្ធសភា ។

ស្ថាប័ននេះជាក្រុមប្រឹក្សានៃព្រឹទ្ធាចារ្យ (conseil des sages) ដែលទទួលពិនិត្យជាលើកដំបូងគ្រប់សេចក្តីព្រាងច្បាប់ ។

ថ្ងៃ៥ មករាឆ្នាំ២០០៥ កិច្ចព្រមព្រៀងសន្តិភាពទូទៅនិងជាស្ថាពរត្រូវបានចុះហត្ថលេខា ។

ស្របតាមកិច្ចព្រមព្រៀងនេះ រយៈពេលបណ្តោះអាសន្នចំនួន៦ឆ្នាំចាប់ពីថ្ងៃទី៩ខែកក្កដាឆ្នាំ២០០៥ បានបើកឡើងសំរាប់ការចុះហត្ថលេខាលើរដ្ឋធម្មនុញ្ញថ្មី និងការឡើងកាន់តំណែងរបស់ប្រធានាធិបតីថ្មី ។

រដ្ឋធម្មនុញ្ញបង្កើតស្ថាប័នសភាពីរថ្នាក់ដែលមានរដ្ឋសភា និងសភានៃបណ្តារដ្ឋ ។

I-សមាសភាព

-៥០រូបជ្រើសរើសដោយការបោះឆ្នោតមិនចំពោះដោយអ្នកមានអាណត្តិនៃរដ្ឋនានា ដែលមានតំណាង២រូបសំរាប់រដ្ឋនីមួយៗ ក្នុងចំណោម២៥រដ្ឋ(១៥ភាគខាងជើង និង១០ភាគខាងត្បូង ។

-២រូប ជាអ្នកសង្កេតការណ៍នៃក្រុមប្រឹក្សាតំបន់ Abyei (nord)ដែលមិនមានសិទ្ធិអនុម័ត ។

រហូតដល់ការបោះឆ្នោតដែលប្រព្រឹត្តទៅនៅអំឡុងឆ្នាំទី៣នៃរយៈពេលអន្តរកាល សមាជិកនានានៃក្រុមប្រឹក្សាបណ្តារដ្ឋត្រូវតែងតាំងដោយ ប្រធានាធិបតីនៃសាធារណរដ្ឋ ក្រោយការពិគ្រោះយោបល់ពីគណៈអធិបតី (ប្រធានាធិបតីនៃសាធារណរដ្ឋ អនុប្រធានទាំង២ ដែល១រូបមកពីស៊ូដង់

ខាងត្បូង និង១រូបមកពីស៊ូដង់ខាងជើង) និងចំពោះស៊ូដង់ខាងត្បូង តាមអនុសាសន៍របស់ប្រមុខរដ្ឋាភិបាលស៊ូដង់ខាងត្បូង ក្រោយពីបានពិគ្រោះយោបល់ជាមួយស្ថាប័នរដ្ឋដែលពាក់ព័ន្ធ ។

ការតែងតាំងនេះធ្វើនៅថ្ងៃ៣១ ខែសីហា ឆ្នាំ២០០៥ ។

II-**របបឧោះឆ្លាត**

អាណត្តិ : ៥ឆ្នាំ

អាយុ : ២១ឆ្នាំ

III-**សម័យប្រជុំ**

ក-សម័យប្រជុំសាមញ្ញ

ក្រុមប្រឹក្សា(ក៏ដូចជារដ្ឋសភា) កំណត់អំពីការចាប់ផ្តើម និងការបញ្ចប់នៃសម័យប្រជុំនានារបស់ខ្លួន: ២សម័យប្រជុំក្នុង១ឆ្នាំ (ពីថ្ងៃ ច័ន្ទទី១ខែមេសា ដល់ថ្ងៃពុធចុងក្រោយ ខែមិថុនា និងពីថ្ងៃច័ន្ទ ទី១ ខែតុលាដល់សប្តាហ៍ចុងក្រោយខែធ្នូ) ។

ខ-សម័យប្រជុំវិសាមញ្ញ

ក្រុមប្រឹក្សាបណ្តារដ្ឋ (ដូចជារដ្ឋសភា) អាចរួមប្រជុំជាបន្ទាន់ឬវិសាមញ្ញ តាមសំណើរបស់សមាជិកខ្លួនចំនួនពាក់កណ្តាល ឬរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ។

IV-**ទំនាក់ទំនងជាមួយដ្ឋសតានិងអំណាចនីតិប្រតិបត្តិ**

ក-អំណាចនីតិប្បញ្ញត្តិ

La sharia គឺជាប្រភពមួយរបស់ច្បាប់ដែលអនុវត្តនៅបណ្តារដ្ឋខាងជើងស៊ូដង់ រីឯរដ្ឋខាងត្បូងស៊ូដង់ ត្រូវគិតតាមប្រពៃណី និងទំនៀមទំលាប់សាសនាដែលមានសភាពប្លែកៗត្នានៅភាគខាងត្បូង ។

កាលណាច្បាប់ផ្នែកទៅលើសាសនានិងទំនៀមទំលាប់ រដ្ឋមួយដែលប្រជាជនភាគច្រើនមិនគោរពសាសនា ឬទំនៀមទំលាប់អាច:

-អនុម័តច្បាប់មួយដែលមានការយល់ព្រមពីសាសនា និងទំនៀមទំលាប់ទាំងនោះ

-ឬបញ្ជូនច្បាប់ទៅក្រុមប្រឹក្សាបណ្តារដ្ឋដែលអាច តាមសម្លេងភាគច្រើន២/៣នៃសមាជិក អនុម័តឬបញ្ជូលចំណុចដែលមានការចាំបាច់ ។

១-សិទ្ធិផ្តួចផ្តើមធ្វើច្បាប់

តាមរដ្ឋធម្មនុញ្ញ ក្រុមប្រឹក្សាបណ្តារដ្ឋមានសមត្ថកិច្ចផ្តើមគំនិតធ្វើច្បាប់ទាក់ទងនឹងវិមជ្ឈការ និងការផ្ទេរអំណាច ។ អត្ថបទមួយដែលរដ្ឋសភាបានអនុម័តអាចបញ្ជូនទៅគណៈកម្មការចំរុះ អចិន្ត្រៃយ៍ដើម្បីសម្រេច បើអត្ថបទនេះប៉ះពាល់ដល់ផលប្រយោជន៍នៃបណ្តារដ្ឋ ។ ក្នុងករណីនេះ អត្ថបទត្រូវបញ្ជូនទៅក្រុមប្រឹក្សាបណ្តារដ្ឋ ។

ប្រធានាធិបតីនៃសាធារណរដ្ឋ គណៈអធិបតីក្រុមប្រឹក្សារដ្ឋមន្ត្រីជាតិ ឬគណៈកម្មការណាមួយរបស់សភាអាចដាក់សេចក្តីព្រាងច្បាប់ជូនសភាណាមួយ អាស្រ័យតាមវិស័យនៃសមត្ថកិច្ច ។

សមាជិកសភាអាចដាក់សេចក្តីស្នើច្បាប់ជូនសភា ដែលខ្លួនជាសមាជិក ក្នុងវិស័យនៃសមត្ថកិច្ចរបស់ខ្លួន ។

សេចក្តីព្រាងច្បាប់អាចដាក់ជូនសភាដែលមានសមត្ថកិច្ច ក្រោយពីបានបញ្ជូនទៅគណៈ-កម្មការពាក់ព័ន្ធ បើមានទាក់ទងនឹងផលប្រយោជន៍សាធារណៈសំខាន់ ។

២-នីតិវិធីធ្វើច្បាប់

សេចក្តីព្រាងច្បាប់ត្រូវបញ្ជូនជាដំបូងទៅសភាដែលមានសមត្ថកិច្ចជាធម្មតា ។

ប្រធានសភាបញ្ជូនទៅគណៈកម្មការមានសមត្ថកិច្ចទទួលបន្ទុកវិភាគអត្ថបទ សំរាប់ការអានលើកទី២ ។

ក្នុងសម័យប្រជុំពេញអង្គ ការអានលើកទី២ធ្វើឡើងដោយការពិភាក្សាជាទូទៅ និងការអនុម័តជាគោលការណ៍ ។ ពេលបានអនុម័តហើយអត្ថបទត្រូវធ្វើការពិភាក្សានៅការអានជាលើកទី៣ដោយលំអិត និងការពិភាក្សាលើវិសោធនកម្មទាន់ដែលបានស្នើឡើង ។

គណៈកម្មការមានសមត្ថកិច្ចត្រូវបង្ហាញនូវរបាយការណ៍ លើវិសោធនកម្មទាំងនោះ ។

គណៈកម្មការក៏ត្រូវស្នើដោយប្រធានសភាឲ្យបង្ហាញនូវរបាយការណ៍ លើសេចក្តីព្រាងជា

ស្ថានសំរាប់ធ្វើការពិភាក្សានៅការអានលើកចុងក្រោយ ។

៣-ការយល់ព្រមរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ

ដើម្បីទៅជាច្បាប់ អត្ថបទនានាដែលសភាបានអនុម័តត្រូវទទួលការយល់ព្រមពីប្រធានាធិបតីនៃសាធារណរដ្ឋ ។ បើប្រធានាធិបតីមិនចាត់ការក្នុងរយៈពេល៣០ថ្ងៃ ដោយមិនផ្តល់មូលហេតុ អត្ថបទត្រូវចាត់ទុកថាបានចុះហត្ថលេខា ។បើប្រធានាធិបតីព្យួរការយល់ព្រម ដោយផ្តល់មូលហេតុ អត្ថបទត្រូវបញ្ជូនទៅសភាដើម្បីពិនិត្យយោបល់របស់ប្រធានាធិបតី ។

អត្ថបទក្លាយជាច្បាប់ បើត្រូវបានសភាអនុម័តតាមសម្លេងភាគច្រើន២/៣នៃសមាជិកសភាទាំងពីរ ។ ការយល់ព្រមរបស់ប្រធានាធិបតីលែងជាការតម្រូវដើម្បីឱ្យច្បាប់ចូលជាធរមាន ។

៤-បញ្ញត្តិ(les ordonnances)

ក្នុងចន្លោះសម័យប្រជុំ ប្រធានាធិបតីនៃសាធារណរដ្ឋ ក្នុងករណីប្រញាប់ អាចចេញវិធានបណ្តោះអាសន្នដែលមានកម្លាំងជាច្បាប់ ហើយត្រូវដាក់ជូនសភាមានសមត្ថកិច្ចតាមដែលអាចធ្វើបាន ។ ពេលដែលសភាបានផ្តល់សច្ចាប័ន វិធានទាំងនោះត្រូវប្រកាសឱ្យប្រើជាច្បាប់ ។

បើសភាណាមួយបដិសេធ ឬបើមិនបានការយល់ព្រមមុនចប់សម័យប្រជុំសភា វិធានទាំងនោះត្រូវអស់តម្លៃហើយគ្មានអានុភាពប្រតិសកម្ម (sans effets rétroactifs)ឡើយ ។

វិធានបណ្តោះអាសន្នមិនអាចប្រើបានទេក្នុងករណីខាងក្រោម : កិច្ចព្រមព្រៀងសន្តិភាព ការប្រកាសអំពីសិទ្ធិ អង្គការ វិមជ្ឈការរបស់រដ្ឋ ការបោះឆ្នោតទូទៅ ថវិកា ច្បាប់ព្រហ្មទណ្ឌ អនុសញ្ញាអន្តរជាតិ ឬកិច្ចព្រមព្រៀងអំពីព្រំដែនរដ្ឋ ។

ច្បាប់ដែលត្រូវបានចាត់ជាមោឃៈ ឬកែប្រែដោយវិធានបណ្តោះអាសន្នមានអានុភាពវិញ បន្ទាប់ពីវិធានបណ្តោះអាសន្ននោះអស់អានុភាព ។

៥-ការចេញបញ្ញត្តិដោយការប្រគល់សិទ្ធិ

សភាទាំងពីរ ឬសភាណាមួយ ដោយច្បាប់មួយ អាចប្រគល់សិទ្ធិឱ្យប្រធានាធិបតីនៃសាធារណរដ្ឋ ក្រុមប្រឹក្សាជាតិនៃរដ្ឋមន្ត្រី ឬស្ថាប័នសាធារណៈណាមួយទ្រង់អំណាចចេញបទបញ្ជា

បន្ទាប់បន្សំ (règlements secondaires)ដែលមានកម្ទាំងជាច្បាប់ ក្រោមលក្ខខណ្ឌដែលបទបញ្ញានោះបានដាក់ជូនសភាដែលមានសមត្ថកិច្ច និងត្រូវបានសភាអនុម័ត ឬកែប្រែដោយសេចក្តីសម្រេចចិត្ត ។

ខ-អំណាចត្រួតពិនិត្យ

១-សំណូរ (questions)

នៅក្នុងវិស័យនៃសមត្ថកិច្ចនៃសភានីមួយ១ សមាជិកសភាអាចដាក់សំណូចំពោះរដ្ឋមន្ត្រីលើគ្រប់បញ្ហាដែលទាក់ទងនឹងក្រសួង ។

រដ្ឋមន្ត្រីត្រូវឆ្លើយយ៉ាងប្រញ្ហាប់តាមដែលអាចធ្វើបាន ។

២-សំណើសុំការពន្យល់ (demandes d'explications)

សភានីមួយ១ ឬគណៈកម្មការណាមួយអាចសុំឱ្យរដ្ឋមន្ត្រីពន្យល់អំពីការដែលជាសមត្ថកិច្ចរបស់ខ្លួន ។

គ-ទំនាក់ទំនងជាមួយអំណាចនីតិប្រតិបត្តិ

១-ទំនាក់ទំនងជាមួយប្រធានាធិបតីនៃសាធារណរដ្ឋ

ប្រធានាធិបតីនៃសាធារណរដ្ឋ អាចទាក់ទងនឹងសភាទាំងពីរ ឬសភាណាមួយដោយផ្ទាល់ខ្លួន ឬដោយសារ ។ ប្រធានាធិបតី អាចស្នើសុំយោបល់របស់សភាលើគ្រប់បញ្ហា ។

២-អនុប្រធានាធិបតីម្នាក់១ឬប្រមុខរដ្ឋាភិបាលខាងត្បូងស៊ីដង់អាច ស្នើសុំឱ្យបញ្ចូនពាក្យសុំទៅសភាណាមួយដែលត្រូវឆ្លើយយ៉ាងប្រញ្ហាប់តាមដែលអាចធ្វើបាន ។

៣-រដ្ឋមន្ត្រីម្នាក់១អាចស្នើសុំឱ្យធ្វើសេចក្តីផ្លែងការណ៍នៅមុខសភាណាមួយ ។

៤-អភិបាល(gouverneur)អាចស្នើសុំឱ្យធ្វើសេចក្តីផ្លែងការណ៍នៅក្រុមប្រឹក្សាបណ្តារដ្ឋ ។

V-ចនម្យញ្ញត្តិដោយឡែក

ក-តុលាការធម្មនុញ្ញ(cour constitutionnelle)

១-សមាសភាព

ក្រុមប្រឹក្សាបណ្តារដ្ឋ តាមសម្ទេងភាគច្រើន២៣នៃសមាជិករបស់ខ្លួន អនុម័តលើការតែងតាំងចៅក្រមនៃតុលាការធម្មនុញ្ញ តាមសំណើរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ។

ប្រធានតុលាការធម្មនុញ្ញត្រូវដកពីមុខងារដោយអសមត្ថភាព (incompetence) ឬក្នុងករណីវិសមិតភាព (incompatible) ជាមួយមុខងារដោយសេចក្តីសម្រេចរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ដោយមានការយល់ព្រមពីក្រុមប្រឹក្សាបណ្តារដ្ឋតាមសម្ទេងភាគច្រើន២៣។

២-តុលាការធម្មនុញ្ញបកស្រាយបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ

តាមសំណើរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ រដ្ឋាភិបាលជាតិ រដ្ឋាភិបាលខាងត្បូងសូដង់ រដ្ឋាភិបាលរដ្ឋមួយឬរដ្ឋសភា។

ខ-ស្ថានភាពបន្ទាន់

១-ការប្រកាសស្ថានភាពបន្ទាន់លើដែនដីទាំងមូលឬមួយផ្នែកធ្វើឡើងដោយប្រធានាធិបតីនៃសាធារណរដ្ឋ ដោយមានការយល់ព្រមពីអនុប្រធានាធិបតីទី១ ត្រូវដាក់ជូនសភាក្នុងរយៈពេល១៥ថ្ងៃ។ សភាត្រូវកោះប្រជុំជាវិសាមញ្ញ កាលបើស្ថិតនៅចន្លោះសម័យប្រជុំ។

២- ក្នុងករណីសភាអនុម័តយល់ព្រម ច្បាប់និងវិធានពិសេសទាំងឡាយដែលចេញដោយប្រធានាធិបតីនៃសាធារណរដ្ឋក្នុងក្របខ័ណ្ឌនេះមានអានុភាពចាប់បង្ខំ។

៣-វិធាននានាដែលចាត់ឡើងក្នុងក្របខ័ណ្ឌនៃស្ថានភាពបន្ទាន់ឈប់អនុវត្ត:

-ពេលហួសពី៣០ថ្ងៃ ចាប់រាប់ពីពេលប្រកាស កាលបើសភាមិនបានអនុម័តពន្យារ

-បន្ទាប់ពីរយៈពេលដែលសភាបានអនុម័ត

-ដោយអានុភាពនៃសេចក្តីប្រកាសរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ(យល់ព្រមដោយអនុប្រធានាធិបតីទី១)លើស្ថានភាពបន្ទាន់។

គ-ការប្រកាសសង្គ្រាម

ការប្រកាសសង្គ្រាមត្រូវមានការយល់ព្រមពីសភា។

ឃ-ការសើរើរដ្ឋធម្មនុញ្ញ

វិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវអនុម័តតាមសម្លេងភាគច្រើន៧/៤នៃសមាជិកសភានីមួយ១ ដាច់ដោយឡែកពីគ្នា និងបន្ទាប់ពីរយៈពេល២ខែយ៉ាងតិច ចាប់ពីពេលដាក់សំណើ ។

ង-ក្រុមប្រឹក្សាបណ្តារដ្ឋទាមទារទៅរដ្ឋាភិបាល និងបណ្តារដ្ឋមន្ត្រីដែលមានសមត្ថកិច្ចខាងទំនាក់ទំនងលើការអនុវត្តវិមជ្ឈការ និងការប្រគល់អំណាច ។

ច-ក្រុមប្រឹក្សាបណ្តារដ្ឋត្រួតពិនិត្យមូលនិធិជាតិខាងការស្តាបនាឡើងវិញ និងខាងការអភិវឌ្ឍ ។

ឆ-ក្រុមប្រឹក្សាបណ្តារដ្ឋសម្រេចលើការជំទាស់របស់សមាជិកមិនអចិន្ត្រៃយ៍លើប្រធានបទរបស់គណៈកម្មការជាតិប្រេងកាត ។

ស្វីស ក្រុមប្រឹក្សាបណ្តារដ្ឋ

SUISSE LE CONSEIL DES ETATS

I-សមាសភាព

សមាជិករដ្ឋសភាខេត្ត (cantons)ចំនួន៤៦រូប ។ ខេត្តនីមួយ១ជ្រើសរើសសមាជិករដ្ឋសភា ២រូប ដោយការបោះឆ្នោតសកល ។

II-របបបោះឆ្នោត

ការបោះឆ្នោតនៅក្រុមប្រឹក្សាបណ្តារដ្ឋ ស្ថិតក្រោមច្បាប់ផ្ទៃក្នងរបស់ខេត្ត : ដោយផ្ទាល់ សម្ងេងភាគច្រើនធម្មតាជាទូទៅ ។

-២០មណ្ឌលពហុនាម តំណាងខេត្ត (២អាសន:)

-៦ មណ្ឌលឯកត្តនាម តំណាងពាក់កណ្តាលខេត្ត (representant les ½ cantons) ។

អាណត្តិ (កំណត់ដោយច្បាប់ខេត្ត) : ៤ឆ្នាំ

ការផ្ទាស់ប្តូរចុងក្រោយ: ១៩ តុលា ២០០៣

III-សម័យប្រជុំ

ក-សម័យប្រជុំសាមញ្ញ

៤ សម័យប្រជុំក្នុង១ឆ្នាំ (ការកោះសម័យប្រជុំត្រូវកំណត់ដោយច្បាប់) ។

ខ-សម័យប្រជុំវិសាមញ្ញ

តាមការកោះប្រជុំរបស់ក្រុមប្រឹក្សាសហព័ន្ធ (Conseil fédéral) ឬតាបសំណើរបស់ សមាជិកក្រុមប្រឹក្សាជាតិចំនួន១/៤ ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

ក្រុមប្រឹក្សាបណ្តារដ្ឋមានអំណាចស្មើនឹងក្រុមប្រឹក្សាជាតិ ។

១-សិទ្ធិផ្តួចផ្តើមធ្វើច្បាប់

ក្រុបប្រឹក្សាបណ្តារដ្ឋ និងសមាជិករបស់ខ្លួន(ក៏ផ្ទួចជាក្រុមប្រឹក្សាជាតិ និងសមាជិករបស់

ខ្លួន ត្រប់ក្រុមសមាជិកសភា និងត្រប់គណៈកម្មការរបស់សភាខេត្ត និងក្រុមប្រឹក្សាជាតិ) មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។

២-សិទ្ធិវិសោធនកម្ម

ក្រុមប្រឹក្សាបណ្តារដ្ឋមានសិទ្ធិវិសោធនកម្ម ។

៣-នីតិវិធីធ្វើច្បាប់

អត្ថបទត្រូវពិនិត្យជាបន្តបន្ទាប់ដោយសភាទាំងពីរ ។ ក្នុងករណីខ្វែងគំនិតគ្នា នីតិវិធីត្រូវដំណើរការដើម្បីរកការព្រមព្រៀង (បញ្ជូនទៅ-មកពីរដងយ៉ាងច្រើន បន្ទាប់ទៅមានការប្រជុំសម្របសម្រួល) ។ បន្តទៅទៀតមានការអនុម័តចុងក្រោយក្នុងសភាទាំងពីរ) ។

ខ-អំណាចត្រួតពិនិត្យ

ក្រុមប្រឹក្សាបណ្តារដ្ឋមានអំណាចត្រួតពិនិត្យ ដូចគ្នានឹងក្រុមប្រឹក្សាជាតិ ។

១-ការតែងតាំងក្រុមប្រឹក្សាសហព័ន្ធ(conseil fédéral)

ក-សមាជិកក្រុមប្រឹក្សាសហព័ន្ធ(នីតិប្រតិបត្តិ) ត្រូវចាត់តាំង (nommés) សំរាប់៤ឆ្នាំ ដោយក្រុមប្រឹក្សាប្រជុំរួម និងជ្រើសរើសពីក្នុងចំណោមពលរដ្ឋស្វ៊ីសដែលអាចជ្រើសរើសចូលក្នុងក្រុមប្រឹក្សាជាតិ ។

ខ-ប្រធានសហព័ន្ធ និងអនុប្រធានក្រុមប្រឹក្សា សហព័ន្ធត្រូវចាត់តាំងសំរាប់១ឆ្នាំ ដោយសភាសហព័ន្ធ(ប្រជុំក្រុមប្រឹក្សាជាតិ និងក្រុមប្រឹក្សាបណ្តារដ្ឋ) ក្នុងចំណោមសមាជិកក្រុមប្រឹក្សា ។

ស្វាស៊ីលែន SWAZILAND

ព្រឹទ្ធសភា LE SENAT

ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៥ មហាក្សត្រ មស្វាទី(Mswati)III បានចុះហត្ថលេខាលើ រដ្ឋធម្មនុញ្ញថ្មីដែលអនុម័តដោយសភា ដែលឈានរំលាយប្រពៃណីឆ្គោះទៅគោលការណ៍ ប្រជាធិបតេយ្យ ។ រដ្ឋធម្មនុញ្ញនេះចូលជាធរមាននៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ ២០០៦ ។

ការបោះឆ្នោតនីតិប្បញ្ញត្តិត្រូវបានរៀបចំឡើង ។ សភា(ក៏ដូចជារដ្ឋាភិបាល) ត្រូវរក្សាទុក ក្នុងរយៈពេលអន្តរកាល ដែលអនុញ្ញាតឱ្យរៀបចំស្ថាប័ននានាស្របតាមរដ្ឋធម្មនុញ្ញថ្មី ។

រដ្ឋធម្មនុញ្ញត្រូវបានលុបចោលនៅថ្ងៃទី១២ខែមេសាឆ្នាំ១៩៧៣ ហើយគណបក្សនយោបាយ ត្រូវបានហាមឃាត់ (ប៉ុន្តែត្រូវបានអនុគ្រោះ) ។ ជាប់ពីពេលនេះមក ការគ្រប់គ្រងរដ្ឋធ្វើដោយ ក្រឹត្យរបស់មហាក្សត្រ ។

រដ្ឋធម្មនុញ្ញថ្មីរបស់រាជាណាចក្រផ្តាច់ការនេះ បានផ្តល់សិទ្ធិជាច្រើនដល់ពលរដ្ឋ ពង្រឹង អំណាចមហាក្សត្រ រក្សាសភាពីរផ្ទាក់ និងរក្សាការហាមឃាត់គណបក្សនយោបាយ ។

I-សមាសភាព

ព្រឹទ្ធសភាមានសមាជិក៣០រូប :

-១០ជាសមាជិកជ្រើសរើស

-២០ជាសមាជិកតែងតាំងដោយប្រមុខរដ្ឋ ។

II-មេបបោះឆ្នោត

ប្រព័ន្ធបោះឆ្នោត : មិនផ្ទាល់ដោយរដ្ឋសភា តាមសម្ទេងភាគច្រើននៃសមាជិកវត្តមាន និងជាអ្នកបោះឆ្នោត ។

អាណត្តិ : ៥ឆ្នាំ

ការផ្ទាស់ប្តូរចុងក្រោយ : ៣១ ខែ តុលា ឆ្នាំ ២០០៣

លក្ខខណ្ឌ : អាយុ១៨ឆ្នាំ ពលរដ្ឋស្វាស៊ីលែន រស់នៅយ៉ាងទៀងទាត់ក្នុងប្រទេស

ហាមឃាត់ : ជាប់កាតព្វកិច្ចជាមួយប្រទេសក្រៅ ក្ស័យធនមិនទាន់មានន៊ីតិសម្បទា ទោសប្រហារជីវិត ទោសជាប់ពន្ធនាគារលើសពី៦ខែ ។

វិសមិតភាព : មុខងារសាធារណ: មុខងារពីការបោះឆ្នោត កិច្ចសន្យារដ្ឋបាល កងកម្ទាំង ប្រដាប់អាវុធ ។

III-សម័យប្រជុំ

IV-ឆំនាក់ឆំនងជាមួយរដ្ឋសភា និងអំណាចន៊ីតិប្រតិបត្តិ

ក-អំណាចន៊ីតិប្បញ្ញត្តិ

១-ឥនិតផ្តួចផ្តើមធ្វើច្បាប់

២-សិទ្ធិវិសោធនកម្ម

៣-ន៊ីតិវិធីធ្វើច្បាប់

ខ-អំណាចត្រួតពិនិត្យ

V-បនប្បញ្ញត្តិដោយឡែក

តាស៊ីគីស្ថាន **ម៉ាលីស៊ី មីយី**

TADJIKISTAN MAJLISI MILLIY

ក៏ណែទម្រង់រដ្ឋធម្មនុញ្ញដែលអនុម័តដោយប្រជាមតិ ខែកញ្ញា ឆ្នាំ១៩៩៩បានបង្កើតឡើងវិញនូវប្រព័ន្ធសភា២ ។

I-សមាសភាព

ម៉ាលីស៊ី មីយីមានសមាជិក៣៤រូប :

-២៥រូបជាសមាជិកជ្រើសរើស

-៩នាក់ជាសមាជិកតែងតាំងដោយប្រមុខរដ្ឋ ។

II-របបបោះឆ្នោត

ច្បាប់បោះឆ្នោតថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៩៩ :

សមាជិក២៥រូប ត្រូវជ្រើសរើសដោយការបោះឆ្នោតមិនផ្ទាល់(scrutin indirect)និងសម្ងាត់ក្នុងសម័យប្រជុំម៉ាលីស(majlis)តំបន់(៥អាសនៈក្នុង១តំបន់) ។

ការបោះឆ្នោតលើកទី១:២៤ ខែមីនា ឆ្នាំ២០០៥

អាណត្តិ : ៥ឆ្នាំ

III-សម័យប្រជុំ

ម៉ាលីស៊ី មីយី ប្រជុំ២ដងយ៉ាងតិចក្នុង១ឆ្នាំ តាមការកោះប្រជុំរបស់ប្រធានរបស់ខ្លួន ។

IV-ទំនាក់ទំនងជាមួយវ្នេសភា(សភាទី១)និងអំណាចនីតិប្រតិបត្តិ

អំណាចនីតិប្បញ្ញត្តិ :

សេចក្តីព្រាងច្បាប់ដែលសភាទី១(majlisi Nanoyondago)ត្រូវបញ្ជូនទៅម៉ាលីស៊ី មីយី(សភាទី២)ដែលអាចអនុម័តយល់ព្រម ឬបដិសេធ ។

V-បទប្បញ្ញត្តិផ្សេងៗ

ក-អំណាចតែងតាំង

ម៉ាលីស៊ី មីយ៉ា :

១-ជ្រើសរើសនិងដកហូតតំណែងប្រធាន បណ្តាអនុប្រធាននិងចៅក្រមតុលាការធម្មនុញ្ញ តុលាការកំពូល និងតុលាការកំពូលសេដ្ឋកិច្ច តាមសំណើរបស់ប្រធាន ។

២-យល់ព្រមលើការតែងតាំង ឬការដាក់ជូនសមត្ថរដ្ឋអាជ្ញា(procureur general) និងបណ្តាអត្ថរដ្ឋអាជ្ញារង ។

៣-សមត្ថកិច្ចក្នុងការរៀបចំមូលដ្ឋាន

ម៉ាលីស៊ី មីយ៉ាបង្កើត លុប និងកែប្រែសម្ព័ន្ធភាពរដ្ឋបាលដែនដី ។

ត្រីនីតេនិងតូបាកូ TRINITE-ET-TOBAGO

ព្រឹទ្ធសភា LE SENAT

I-សមាសភាព

ព្រឹទ្ធសភាមានសមាជិកពា១រូប តែងតាំងដោយប្រមុខរដ្ឋ:

-១៦រូបតាមសំណើរបស់នាយករដ្ឋមន្ត្រី

-៦រូបតាមសំណើរបស់ប្រធានគណបក្សជំទាស់

-៥រូបអាស្រ័យលើសមត្ថកិច្ចក្នុងវិស័យសេដ្ឋកិច្ច សង្គម ...។

II-របបតែងតាំង

អាណត្តិ : ៥ឆ្នាំ

ការបោះឆ្នោតចុងក្រោយ : ១០ធ្នូ ២០០១

លក្ខខណ្ឌ : អាយុ២៥ឆ្នាំ ពលរដ្ឋ ទ្រីនីតេនិងតូបាកូ

ហាម :ជាប់កាតព្វកិច្ចជាមួយប្រទេសក្រៅ ក្ស័យធនមិនទាន់មានន៊ីតិសម្បទា សរសៃប្រសាទ បទល្មើសបោះឆ្នោត ទោសប្រហារជីវិត ឬជាប់ពន្ធនាគារលើសពី១២ខែ ។

វិសមិតភាព : មុខងារសាធារណ:ខ្លះ និងការងារជាបន្ទុកទាំងអស់អំពីការរៀបចំការបោះឆ្នោត ។

ប្រធាន និងអនុប្រធានព្រឹទ្ធសភា (ជ្រើសរើសនៅដើមនីតិកាលនីមួយ១) មិនមានសិទ្ធិទទួលជារដ្ឋមន្ត្រី ឬជាលេខាធិការសភា (secretaire parlementaire) ។

គេអាចដំណើរការតែងតាំងសមាជិកព្រឹទ្ធសភាជាបណ្តោះអាសន្ន(senateurs temporaires) ក្នុងករណីមានអាសន:នៅទំនេរដោយជម្ងឺ អវត្តមានពីទ្រីនីតេនិងតូបាកូ ឬព្យូរមុខងារ (ក្នុងរយ:ពេលដែលពាក់ព័ន្ធនឹងការជ្តន្ទាទោស) ។

III-សម័យប្រជុំ

ក-សម័យប្រជុំសាមញ្ញ

ការលបរិច្ឆេទបើក និងបិទសម័យប្រជុំ ត្រូវកំណត់ដោយប្រកាសរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ។

សភាប្រជុំយ៉ាងតិច១ដងក្នុង១ឆ្នាំ និងមិនអាចមិនប្រជុំលើសពី៦ខែបានទេ ។

ខ-សម័យប្រជុំពេញច្បាប់ (session de droit)

ព្រឹទ្ធសភាប្រជុំដោយពេញច្បាប់យ៉ាងយូរ១ខែក្រោយការបោះឆ្នោតសភា ។

ត-ការលើកពេល(ajournement)

ការប្រជុំត្រូវលើកពេលបើមិនមានកូរ៉ុមចំនួន១០ ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

សភាទ្រីនីតេនិងតូបាកូមានប្រធាន(ប្រមុខរដ្ឋ) ព្រឹទ្ធសភា និងរដ្ឋសភា ។

ក-អំណាចនីតិប្បញ្ញត្តិ

ព្រឹទ្ធសភាមានអំណាចនីតិប្បញ្ញត្តិមានកំរិត ។

១-តំនិតផ្តួចផ្តើមធ្វើច្បាប់

សមាជិកព្រឹទ្ធសភា(ឬសមាជិករដ្ឋសភា) មានសិទ្ធិផ្តួចផ្តើមតំនិតធ្វើច្បាប់ ។ សិទ្ធិនេះមានកំរិត ក្នុងករណីទាក់ទងនឹងសេចក្តីស្នើធានាខាងហិរញ្ញវត្ថុសាធារណៈ បង្កើត ឬបន្ថែមពន្ធដារ ឬបន្ទុកឯទៀត (តាមការវាយតម្លៃរបស់ប្រធានអង្គប្រជុំ) បើសិនជារដ្ឋាភិបាលមិនយល់ព្រម ។

២-សិទ្ធិវិសោធនកម្ម

សមាជិកព្រឹទ្ធសភា(ឬសមាជិករដ្ឋសភា) មានសិទ្ធិវិសោធនកម្ម ។ សិទ្ធិនេះមានកំរិតក្នុងករណីទាក់ទងនឹងសេចក្តីស្នើធានាខាងហិរញ្ញវត្ថុសាធារណៈ បង្កើតឬបន្ថែមពន្ធដារឬបន្ទុកឯទៀត (តាមការវាយតម្លៃរបស់ប្រធានអង្គប្រជុំ) បើសិនជារដ្ឋាភិបាលមិនយល់ព្រម ។

រដ្ឋមន្ត្រីក្រសួងយុត្តិធមិ(le Garde des Sceaux) ចូលរួមក្នុងការងាររបស់សភា និងមានសិទ្ធិវិសោធនកម្ម ក្នុងនោះមានការងារដែលទាក់ទងនឹងក្រសួងផ្សេងទៀត ។សិទ្ធិនេះត្រូវផ្តល់ដល់ដល់រដ្ឋមន្ត្រីឯទៀត ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

៣-នីតិវិធីធ្វើច្បាប់

សេចក្តីព្រាងច្បាប់អាចបញ្ជូនមកសភាណាមួយ លើកលែងតែសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ ដែលត្រូវតែបញ្ជូនមករដ្ឋសភាជាមុន ។

សេចក្តីព្រាងច្បាប់ត្រូវតែពិនិត្យដោយសភាទាំងពីរ ហើយត្រូវអនុម័តតាមសម្លេងភាគច្រើននៃសមាជិកសភានីមួយៗដែលវត្តមាន និងដែលបានចោះ ។

ប្រធានអង្គប្រជុំអាចអនុម័តបានពេលសម្លេងបែកជាពីរស្មើ(vote decisif) ។

ក-នីតិវិធីធម្មតា

ការជំទាស់របស់ព្រឹទ្ធសភាត្រូវឆ្លងផុត តាមកំណែទម្រង់ច្បាប់ ក្រោមលក្ខខ័ណ្ឌដូចតទៅ: អត្ថបទត្រូវតែអនុម័តដោយរដ្ឋសភា នៅពីរសម័យប្រជុំបន្តបន្ទាប់ និងត្រូវច្រានចោលដោយព្រឹទ្ធសភានាសម័យប្រជុំនីមួយៗ (អត្ថបទត្រូវបញ្ជូនទៅព្រឹទ្ធសភាយ៉ាងតិច១ខែមុនចប់សម័យប្រជុំ)រយៈពេល៦ខែត្រូវឆ្លងផុតរវាងការអនុម័តនីមួយៗដោយរដ្ឋសភា ។

ប៉ុន្តែ មុនការអានលើកទី២ ដោយព្រឹទ្ធសភា រដ្ឋសភាមានសិទ្ធិលើកសំណើវិសោធនកម្ម ដែលបើបានអនុម័តដោយព្រឹទ្ធសភា ត្រូវចាត់ទុកជាវិសោធនកម្មរបស់ព្រឹទ្ធសភា ដែលយល់ព្រមដោយរដ្ឋសភា ។

អត្ថបទត្រូវចាត់ទុកថាច្រានចោលដោយព្រឹទ្ធសភា កាលណាមិនត្រូវបានអនុម័តដោយព្រឹទ្ធសភា ឬកាលបើមានវិសោធនកម្មរបស់ព្រឹទ្ធសភាដែលរដ្ឋសភាបដិសេធ ។

អត្ថបទច្បាប់ត្រូវប្រកាសឱ្យប្រើដោយប្រធានាធិបតីនៃសាធារណរដ្ឋ ។

ខ-បទប្បញ្ញត្តិដោយឡែកខាងថវិកា

រយៈពេលសំរាប់ការអនុម័តច្បាប់ហិរញ្ញវត្ថុត្រូវកំណត់ដោយព្រឹទ្ធសភា:កាលណាអត្ថបទដែលត្រូវបានរដ្ឋសភាអនុម័តបានបញ្ជូនទៅព្រឹទ្ធសភាយ៉ាងតិច១ខែ មុនចប់សម័យប្រជុំ និងដែលព្រឹទ្ធសភាមិនបានអនុម័ត ដោយគ្មានការកែប្រែ យ៉ាងយូរ១ខែ ក្រោយពេលបញ្ជូនមកអត្ថបទត្រូវដាក់ជូនប្រធានាធិបតីចុះហត្ថលេខា បើសិនជារដ្ឋសភាមិនសម្រេចអ្វីផ្សេង ។

ខ-អំណាចត្រួតពិនិត្យ

សិទ្ធិទទួលព័ត៌មាន:

រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការដែលជាសមាជិកព្រឹទ្ធសភា ឬសមាជិករដ្ឋសភាបន្តចូលរួមក្នុងការងាររបស់សភាដែលខ្លួនជាសមាជិក។ វត្តមានរបស់រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការដែលជាសមាជិកព្រឹទ្ធសភាឬសមាជិករដ្ឋសភាជាការចាំបាច់បើសិនជាត្រូវបញ្ជាក់(ក្នុងនាមជាសមាជិករដ្ឋាភិបាល) លើវិស័យដែលជាសមត្ថកិច្ចរបស់ខ្លួនដែលកំពុងពិភាក្សា។

រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការទាំងនេះមិនអាចកោះអញ្ជើញដោយសភាមួយទៀតបានទេ បើសភាក្រោយនេះអនុម័តញត្តិ ចំពោះការងារនេះ ។

ค-ការរំលាយ និងពន្យារ

១-ការរំលាយ

ប្រធានាធិបតីនៃសាធារណរដ្ឋមានអំណាចរំលាយសភា។ព្រឹទ្ធសភារលាយស្របពេលនឹងរដ្ឋសភា ។

២-ការពន្យារ

ប្រធានាធិបតីនៃសាធារណរដ្ឋមានអំណាចពន្យារអាណត្តិរបស់សភា។ ក្នុងពេលសង្គ្រាមសភាអាចបន្ត១២ខែ(ទាំងអស់៥ឆ្នាំយ៉ាងច្រើន) ។

V-បទឧបសម្ព្ធន្ធ៏ដោយឡែក

ก-ការសើរើរដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញតម្រូវឲ្យយកតាមសម្លេងភាគច្រើនពិសេសសម្រាប់ការសើរើរដ្ឋធម្មនុញ្ញ: ពីរភាគបី(២/៣) ឬបីភាគបួន(៣/៤) នៃសមាជិកសភានីមួយៗ ទៅតាមមាត្រាដែលពាក់ព័ន្ធ។

ข-ការជ្រើសរើសប្រធានាធិបតីនៃសាធារណរដ្ឋ

ការបោះឆ្នោតជ្រើសរើសប្រធានាធិបតី ប្រព្រឹត្តទៅក្រោមការទទួលខុសត្រូវរបស់ប្រធានរដ្ឋសភា(chambre des représentants) ។ប្រធានាធិបតីត្រូវជ្រើសរើសដោយសមាជិកព្រឹទ្ធសភានិងសមាជិករដ្ឋសភាដែលប្រជុំរួមគ្នា ។

ค-អំណាចតុលាការ

ចំពោះការប្រាសចាកសិទ្ធិរបស់ប្រធានាធិបតី នីតិវិធីតម្រូវឱ្យមានញត្តិដែលផ្តើមដោយរដ្ឋសភាដែលដាក់ឱ្យស៊ើបអង្កេតដោយតុលាការដែលមានប្រធានតុលាការកំពូល(cour suprême) និងចៅក្រម៤រូប(តែងតាំងដោយប្រធានតុលាការកំពូល) ។

ញត្តិនេះបញ្ជាក់អំពីមូលហេតុដែលនាំឱ្យមានការប្រាសចាកសិទ្ធិ ហើយត្រូវអនុម័តតាមសម្លេងភាគច្រើនពីរភាគបី(២/៣) នៃចំនួនសមាជិកព្រឹទ្ធសភា និងសមាជិករដ្ឋសភាដែលប្រជុំរួមគ្នា ។

ប្រធានាធិបតីនៃសាធារណរដ្ឋត្រូវបានតម្កល់ចំណែង តាមសេចក្តីសម្រេចចិត្ត (លើមូលដ្ឋាននៃការសន្និដ្ឋានរបស់តុលាការ) តាមសម្លេងភាគច្រើន(២ / ៣) នៃចំនួនសមាជិកព្រឹទ្ធសភា និងសមាជិករដ្ឋសភាដែលប្រជុំរួមគ្នា ។

ក្នុងករណីនេះ ប្រធានព្រឹទ្ធសភាទទួលជាប្រធានាធិបតីបណ្តោះអាសន្ន ។

ក្នុងឱកាសខួបលើកទី១៤ នៃការឡើងកាន់តំណែងប្រធានាធិបតី ថ្ងៃ៧ ខែធ្នូ ឆ្នាំ២០០១ លោកប្រធានាធិបតី ស៊ីនអែល អាប៊ីឌីន បេន អាលី (Zine El Abidine Ben Ali) បានប្រកាសនូវកំណែទម្រង់រដ្ឋធម្មនុញ្ញ ជាពិសេសឱ្យមានសភាទី២ ដើម្បីពង្រីកភាពជាតំណាងតំបន់ និងសមាសភាពផ្សេងៗក្នុងសង្គម ដោយលើកកំពស់មុខងារនីតិប្បញ្ញត្តិ និងជីវភាពនយោបាយជាទូទៅ ។

ការសើរើរដ្ឋធម្មនុញ្ញត្រូវបានអនុម័តដោយប្រជាមតិថ្ងៃ២៦ខែឧសភាឆ្នាំ២០០២ ។

ការបោះឆ្នោតលើកទី១ ប្រព្រឹត្តទៅនៅថ្ងៃ៣ ខែ កក្កដា ឆ្នាំ ២០០៤ ។

ការតែងតាំងលើកទី១ ដោយប្រធានាធិបតីនៃសាធារណរដ្ឋ ថ្ងៃទី ០១ខែសីហា ឆ្នាំ២០០៤ ។

I-សមាសភាព

សភាទីប្រឹក្សាមានសមាជិក១២៦រូប ។

ចំនួនសមាជិកសភាទីប្រឹក្សាមិនត្រូវលើសពីពីរភាគបីនៃចំនួនសមាជិករដ្ឋសភា (បច្ចុប្បន្នមាន ១៨៤) ។

ការបោះឆ្នោតមិនផ្ទាល់ដោយសមាជិកជាប់ឆ្នោតនៃសម្ព័ន្ធភាពមូលដ្ឋាន ជ្រើសរើសសមាជិកសភាក្រុមប្រឹក្សាចំនួនពីរភាគបី (២៣) ។

II-របបបោះឆ្នោត

-៤៣ អាសនៈ ត្រូវជ្រើសរើសតាមតំបន់ ក្នុងចំណោមសមាជិកជាប់ឆ្នោតនៃសម្ព័ន្ធភាពមូលដ្ឋាន (មួយឬពីរអាសនៈក្នុង១មណ្ឌល)

-៤២ អាសនៈ (មួយភាគបី) ត្រូវជ្រើសរើស កំរិតជាតិក្នុងចំណោមនិយោជក កសិករ និងកម្មករ ។ បេក្ខជនត្រូវស្នើឡើងដោយអង្គការវិជ្ជាជីវៈ លើបញ្ជីដែលមានឈ្មោះយ៉ាងតិចពីរដងនៃចំនួនអាសនៈបំរុង សម្រាប់ប្រភេទនីមួយៗ ។

អាសនៈត្រូវបែងចែកដោយស្មើភាពរវាងវិស័យដែលមានការទាក់ទង ។

-៤១ អាសនៈទៀតត្រូវតែងតាំង(designés) ដោយប្រធានាធិបតីនៃសាធារណរដ្ឋក្នុងចំណោមឥស្សរជនជាតិ និងមានសមត្ថភាព ។

អាណត្តិ: ៦ឆ្នាំ ផ្លាស់ប្តូរថ្មីចំនួនពាក់កណ្តាលរាល់ពីឆ្នាំ ។

អាយុ : ៤០ឆ្នាំ

ការបោះឆ្នោតលើកទី១ :៣ កក្កដា ២០០៥(ត្រានការចូលរួមពីអង្គការវិជ្ជាជីវៈ កម្មករ-១៤អាសនៈ)

ការតែងតាំងលើកទី១ : ១ សីហា ២០០៥ ។

III-**សម័យប្រជុំ**

ក-សម័យប្រជុំសាមញ្ញ

សភាទីប្រឹក្សាប្រជុំជាសាមញ្ញ១ដងក្នុង១ឆ្នាំ ដោយចាប់ផ្តើមក្នុងអំឡុងខែតុលា និងបញ្ចប់ក្នុងអំឡុងខែកក្កដា(ពេលផ្លាស់ប្តូរថ្មី សម័យប្រជុំចាប់ផ្តើមក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីការបោះឆ្នោត) ។

ខ-សម័យប្រជុំវិសាមញ្ញ

សភាទីប្រឹក្សាប្រជុំជាវិសាមញ្ញ តាមសំណើរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ឬរបស់សមាជិករដ្ឋសភាភាគច្រើន លើរបៀបវារៈមួយជាក់លាក់ ។

IV-**ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ**

ក-អំណាចនីតិប្បញ្ញត្តិ

សមត្ថកិច្ចនីតិប្បញ្ញត្តិរបស់សភាទីប្រឹក្សាមានជាទូទៅ លើកលែងតែការអនុញ្ញាតឱ្យផ្តល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិ ។

១-ព័ន្ធិតផ្តួចផ្តើមធ្វើច្បាប់

សភាទីប្រឹក្សាគ្មានសិទ្ធិផ្តួចផ្តើមព័ន្ធិតធ្វើច្បាប់ទេ ។ សិទ្ធិនេះសម្រាប់តែប្រធានាធិបតីនៃសាធារណរដ្ឋ និងសមាជិករដ្ឋសភា ។

២-សិទ្ធិវិសោធនកម្ម

សភាទីប្រឹក្សាមានសិទ្ធិវិសោធនកម្ម ។ ប៉ុន្តែវិសោធនកម្មនេះមិនអាចទទួលយកបានទេ កាលបើនាំឱ្យមានការកាត់បន្ថយធនធានសាធារណៈ ឬបង្កើនបន្ទុកឬចំណាយថ្មី ។

៣-និតិវិធីធ្វើច្បាប់

ក-និតិវិធីធម្មតា

វិស័យនៃច្បាប់ត្រូវបានរាប់ ដោយមានការកំណត់ ។ ប្រធានាធិបតីនៃសាធារណរដ្ឋអាចជំទាស់ទាំងការមិនទទួលយកគ្រប់សេចក្តីព្រាងច្បាប់ ឬវិសោធនកម្មដែលមានក្នុងវិស័យបទប្បញ្ញត្តិ (domaine reglementaire) ។

ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចលើបញ្ហាក្នុងរយៈពេលយ៉ាងយូរបំផុត១០ថ្ងៃ ចាប់ពីពេលទទួល ។

អត្ថបទត្រូវសម្រេចក្នុងសភាទីមួយ១តាមសម្លេងភាគច្រើននៃចំនួនវត្តមាន(សម្លេងភាគច្រើននេះមិនអាចតិចជាងមួយភាគបីនៃសមាជិកសភា) ។

សេចក្តីព្រាងដែលដាក់ដោយប្រធានាធិបតីជាសេចក្តីព្រាងដែលមានអាទិភាព ។

សភាទីប្រឹក្សាមានពេល១៥ថ្ងៃ សម្រាប់ពិនិត្យសេចក្តីព្រាងដែលរដ្ឋសភាបានអនុម័ត ។

បើអត្ថបទមិនត្រូវបានអនុម័តក្នុងរយៈពេលនេះ ប្រធានរដ្ឋសភាបញ្ជូនអត្ថបទនោះទៅប្រធានាធិបតីនៃសាធារណរដ្ឋដើម្បីប្រកាសឱ្យប្រើ ។

បើសភាទីប្រឹក្សាអនុម័តដោយគ្មានការកែប្រែ ប្រធានសភាទីប្រឹក្សាបញ្ជូនទៅប្រធានាធិបតីដើម្បីប្រកាសឱ្យប្រើ ហើយជូនដំណឹងនេះទៅប្រធានរដ្ឋសភា ។

បើសភាទីប្រឹក្សាធ្វើវិសោធនកម្ម ប្រធានសភាទីប្រឹក្សាបញ្ជូនអត្ថបទទៅប្រធានាធិបតី ហើយជូនដំណឹងនេះទៅប្រធានរដ្ឋសភា ។

គណៈកម្មការចម្រុះសមភាគី (commission mixte paritaire) ដែលបង្កើតឡើងតាមសំណើរបស់រដ្ឋាភិបាល ទទួលបន្ទុកតាក់តែងក្នុងរយៈពេល១សប្តាហ៍នូវអត្ថបទរួមមួយ អនុម័តដោយរដ្ឋាភិបាល លើចំណុចខ្វែងគ្នារវាងសភាទាំងពីរ ។

ក្នុងករណីយល់ព្រម អត្ថបទត្រូវបញ្ជូនទៅរដ្ឋសភាដែលត្រូវអនុម័តជាលើកចុងក្រោយ ក្នុងរយៈពេល១សប្តាហ៍ ។ អត្ថបទនេះអាចធ្វើវិសោធនកម្មបាន បើមានការយល់ព្រមពីរដ្ឋាភិបាល ។ បន្ទាប់មក អត្ថបទត្រូវបញ្ជូនទៅប្រធានាធិបតីនៃសាធារណរដ្ឋដើម្បីប្រកាសឱ្យប្រើ ។

ក្នុងករណីបរាជ័យក្នុងរយៈពេលដែលបានកំណត់ ប្រធានរដ្ឋសភាបញ្ជូនទៅប្រធានាធិបតីនៃសាធារណរដ្ឋដើម្បីប្រកាសឱ្យប្រើអត្ថបទដែលខ្លួនបានអនុម័តពីមុនរួចហើយ ។

បើអត្ថបទត្រូវបានផ្តើមដោយសភា ពុំមានការកំណត់ពេលសម្រាប់សភាទីប្រឹក្សាពិនិត្យនៅការអានលើកទី១ឡើយ ។

វិស្សមកាលនៃសភាទាំងពីរត្រូវរយៈពេលខាងលើ ។

ខ-នីតិវិធីសំរាប់ច្បាប់ថវិកា

សេចក្តីព្រាងច្បាប់ថវិកាត្រូវបញ្ជូនទៅសភាទាំងពីរ ។

បើនៅថ្ងៃទី៣១ ខែធ្នូ សភាទីប្រឹក្សាមិនបានពិនិត្យសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ ឬអនុម័ត ផ្ទុយពីរដ្ឋសភា សេចក្តីព្រាងត្រូវបញ្ជូនទៅប្រធានាធិបតីនៃសាធារណរដ្ឋដើម្បីប្រកាសឱ្យប្រើ ។

បើនៅពេលវេលាតែមួយ សភាទាំងពីរមិនបានអនុម័ត បទប្បញ្ញត្តិនៃសេចក្តីព្រាងអាចត្រូវចូលជាធរមានដោយក្រឹត្យ ម្តងមួយត្រីមាស ហើយអាចបន្តបាន ។

គ-បទប្បញ្ញត្តិដោយឡែកចំពោះច្បាប់អង្គការ

សមាជិករដ្ឋសភា និងសមាជិកសភាទីប្រឹក្សាអនុម័តសេចក្តីព្រាងច្បាប់អង្គការតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកសភាទាំងពីរ ។

ឃ-នីតិសម្បទា

សភាទាំងពីរ អាចផ្តល់នីតិសម្បទាឱ្យប្រធានាធិបតីនៃសាធារណរដ្ឋមួយរយៈពេលមានកំណត់ សម្រាប់ការងារមួយជាក់លាក់ ចេញក្រឹត្យ-ច្បាប់ដែលហួសពេលនេះនឹងបញ្ជូនមកសុំការអនុម័ត ពីរដ្ឋសភា ឬពីសភាទាំងពីរទៅតាមករណី ។

ក្នុងវិស្សមកាលរបស់រដ្ឋសភា និងរបស់សភាទីប្រឹក្សា ប្រធានាធិបតីនៃសាធារណរដ្ឋ អាចចេញក្រឹត្យ- ច្បាប់ដែលក្រោយមកដាក់សុំការអនុម័តពីរដ្ឋសភា ឬពីសភាទាំងពីរនៅសម័យ ប្រជុំបន្ទាប់ពីវិស្សមកាល ទៅតាមករណី ។

ក្នុងករណីរំលាយរដ្ឋសភា ក្រោយពេលអនុម័តញត្តិបន្ទោសរដ្ឋាភិបាល ប្រធានាធិបតីនៃ សាធារណរដ្ឋអាចចេញក្រឹត្យ-ច្បាប់ដែលក្រោយមកដាក់សុំសច្ចាប័នពីរដ្ឋសភា និងពីសភាទីប្រឹក្សា ទៅតាមករណី ។

ខ-អំណាចត្រួតពិនិត្យ

សភាទីប្រឹក្សាគ្មានអំណាចត្រួតពិនិត្យទេ ។

 គ-ទំនាក់ទំនងជាមួយប្រធានាធិបតីនៃសាធារណរដ្ឋ

ក-សម្បថ

ប្រធានាធិបតីជាប់ឆ្នោតធ្វើសម្បថនៅមុខរដ្ឋសភា និងសភាទីប្រឹក្សាដែលប្រជុំរួមគ្នា ។

ខ-ទំនាក់ទំនង

ប្រធានាធិបតីនៃសាធារណរដ្ឋទាក់ទងជាមួយសភាដោយផ្ទាល់ ឬដោយសារ ។

គ-វិធានការពិសេស

ក្នុងករណីមានការគំរាមកំហែងដល់ស្ថាប័ននៃសាធារណរដ្ឋ ដល់សន្តិសុខ ឯករាជជាតិនិង ដល់ប្រក្រតីភាពនៃដំណើរការនៃអំណាចសាធារណៈ ប្រធានាធិបតីអាចប្រើវិធានការពិសេសដែល កាលៈទេសៈតម្រូវ ក្រោយពីបានពិគ្រោះយោបល់ជាមួយនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និង ប្រធានសភាទីប្រឹក្សា ។

វិធានការទាំងនេះត្រូវអស់ប្រសិទ្ធភាព ពេលចប់កាលៈទេសៈនេះ ។

ប្រធានាធិបតីត្រូវផ្ញើសារជូន រដ្ឋសភា និងសភាទីប្រឹក្សា ។

ឃ-ការអាក់ខានធ្វើការងារបណ្តោះអាសន្ន (empêchement provisoire)

ក្នុងករណីមិនអាចបំពេញការងារជាបណ្តោះអាសន្ន ប្រធានាធិបតីនៃសាធារណរដ្ឋអាចប្រគល់ភារកិច្ច (លើកលែងតែអំណាចរំលាយ) ឱ្យនាយករដ្ឋមន្ត្រី ដោយជូនដំណឹងទៅប្រធានសភាទាំងពីរ ។

V-បទប្បញ្ញត្តិផ្សេងៗ

ក-ត្រួតពិនិត្យធម្មនុញ្ញភាព

១-បទបញ្ជាផ្ទៃក្នុងសភាទាំងពីរត្រូវបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុនប្រកាសឱ្យប្រើ ។

២-សេចក្តីស្នើរបស់ប្រធានាធិបតីនៃសាធារណរដ្ឋត្រូវបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុនបញ្ជូនទៅរដ្ឋសភា ។

ខ-វិស្សមកាលរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ

ក្នុងករណីវិស្សមកាលរបស់ប្រធានាធិបតីនៃសាធារណរដ្ឋដោយអនិច្ចកម្ម លាលែងឬមិនមិនអាចបំពេញមុខងារជាស្ថាពរ ក្រុមប្រឹក្សាធម្មនុញ្ញរួមប្រជុំជាបន្ទាន់ និងសម្រេចពីវិស្សមកាលនេះ តាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិករបស់ខ្លួន ។ក្រុមប្រឹក្សាធម្មនុញ្ញចេញសេចក្តីប្រកាសអំពីបញ្ជានេះដល់ប្រធានសភាទីប្រឹក្សានិងប្រធានរដ្ឋសភា ដែលទទួលភ្លាមនូវមុខងារប្រមុខរដ្ឋស្តីទី (President de l' Etat par interim) សំរាប់រយៈពេលពី៤៥ថ្ងៃយ៉ាងតិច ដល់៦០ថ្ងៃយ៉ាងច្រើន ។

បើវិស្សមកាលជាស្ថាពរជាន់ត្នានឹងការរំលាយរដ្ឋសភា ប្រធានសភាទីប្រឹក្សាទទួលនូវមុខងារប្រមុខរដ្ឋស្តីទី សម្រាប់រយៈពេលដូចត្នា ។ប្រមុខរដ្ឋស្តីទី (President de l' Etat par interim) ធ្វើសម្បថស្របតាមរដ្ឋធម្មនុញ្ញ នៅមុខរដ្ឋសភា និងសភាទីប្រឹក្សា នាសម័យប្រជុំរួមត្នា និងក្នុងករណីដ៏គួរខ្លះ នៅមុខការិយាល័យនៃសភាទាំងពីរ ។ បើវិស្សមកាលជាស្ថាពរជាន់ត្នានឹងការរំលាយរដ្ឋសភា ប្រធានាធិបតីនៃសាធារណរដ្ឋស្តីទីធ្វើសម្បថនៅមុខសភាទីប្រឹក្សា និងក្នុងករណីដ៏គួរខ្លះ នៅមុខការិយាល័យរបស់ខ្លួន ។

អ៊ូរូហ្គាយ	**ព្រឹទ្ធសភា**
URUGUAY	LE SENAT

I-សមាសភាព

ព្រឹទ្ធសភាមានសមាជិក៣០រូប ជ្រើសតាំងដោយការបោះឆ្នោតដោយផ្ទាល់ ។

អនុប្រធានាធិបតីនៃសាធារណរដ្ឋជាប្រធានព្រឹទ្ធសភា ដោយពេញច្បាប់ ។

II-របបបោះឆ្នោត

មណ្ឌលបោះឆ្នោតមានតែមួយ ពហុនាម ភ្ជាប់ជាតិ តំណាងឱ្យដែនដីជាតិ មាន៣០អាសនៈ ។

ការបោះឆ្នោតប្រព្រឹត្តទៅនៅថ្ងៃអាទិត្យចុងក្រោយនៃខែតុលា ។

ប្រព័ន្ធបោះឆ្នោត : លើបញ្ជី តាមប្រព័ន្ធសមាមាត្រទាំងស្រុង (scrutin de liste à la représentation proportionnelle intégrale) ។

អាណត្តិ : ៥ឆ្នាំ

ការផ្លាស់ប្តូរចុងក្រោយ : ៣១ តុលា ២០០៤

អាយុ : ៣០ ឆ្នាំ (សម្រាប់អ្នកចូលសញ្ជាតិត្រូវចូលសញ្ជាតិបាន៧ឆ្នាំ)

វិសមិតភាព : ជាមួយមុខងារជាសមាជិករដ្ឋាភិបាល ។

III-សម័យប្រជុំ

សម័យប្រជុំរបស់ព្រឹទ្ធសភាដូចគ្នានឹងសម័យប្រជុំរបស់រដ្ឋសភា : សភាទាំងពីរបើក និងបិទសម័យប្រជុំព្រមពេលគ្នា(សមាជិកចំនួនលើសពីពាក់កណ្តាលត្រូវវត្តមាន) ។

ក-សម័យប្រជុំសាមញ្ញ

ព្រឹទ្ធសភាប្រជុំមួយដងក្នុងមួយឆ្នាំ ពីថ្ងៃទី១ ខែមីនា ដល់ទី១៥ ខែធ្នូ ។

ក្នុងករណីមានការបោះឆ្នោតទូទៅ សម័យប្រជុំត្រូវចប់នៅថ្ងៃទី១៥ ខែកញ្ញា និងសភាថ្មីរួមប្រជុំនៅថ្ងៃទី១៥ ខែកុម្ភៈបន្ទាប់ ។

ខ-សម័យប្រជុំវិសាមញ្ញ

ប្រធានាធិបតីនៃសាធារណរដ្ឋ អាចកោះប្រជុំមហាសន្និបាត (Assemblée Générale - ប្រជុំសភាទាំងពីរ) ឬសភានីមួយ១ជាវិសាមញ្ញ លើប្រធានបទជាក់លាក់ដែលមានលក្ខណៈបន្ទាន់ និងធ្ងន់ធ្ងរ (caractère d'urgence et de gravité) ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

គណៈកម្មការអចិន្ត្រៃយ៍មួយ (សមាជិក១១រូប : សមាជិកព្រឹទ្ធសភា៤រូប និងសមាជិករដ្ឋសភា៧រូប) ត្រូវបានបង្កើតឡើងក្នុងមួយឆ្នាំ១ ដោយសភាទាំងពីរ តាមរូបមន្តសមាមាត្រ។

សមាជិកព្រឹទ្ធសភានៃគណបក្សសម្លេងភាគច្រើនទទួលជាប្រធានគណៈកម្មការ ។

រដ្ឋាភិបាលអាចទទួលយោបល់របស់គណៈកម្មការគ្រប់ពេលលើគ្រប់ការងារ ។

ក-អំណាចនីតិប្បញ្ញត្តិ

អំណាចនីតិប្បញ្ញត្តិរ៉ាប់រងដោយមហាសន្និបាត (Assembée Générale - រដ្ឋសភា និងព្រឹទ្ធសភាប្រជុំរួមគ្នា) ដែលអនុម័តជារួម ឬដាច់ពីគ្នាទៅតាមករណី ។

១-ឥទ្ធិពលផ្ទួចផ្តើមច្បាប់

សមាជិកព្រឹទ្ធសភាមានសិទ្ធិផ្ទួចផ្តើមច្បាប់ (ដូចសមាជិករដ្ឋសភា និងរដ្ឋាភិបាល) លើកលែងតែករណីដូចខាងក្រោម :

-រដ្ឋាភិបាលបញ្ជូនសេចក្តីព្រាងច្បាប់ថវិកាជាតិជូនរដ្ឋសភា ។

-រដ្ឋាភិបាលមានសិទ្ធិផ្ទួចផ្តើមឥទ្ធិពលច្បាប់កំណត់ការលើកលែងពន្ធ (exonération fiscale) ប្រាក់ឈ្នួលអប្បបរមា និងតម្លៃ (salaire minimum et les prix) ។

២-សិទ្ធិវិសោធនកម្ម

សមាជិកព្រឹទ្ធសភាមានសិទ្ធិវិសោធនកម្ម លើកលែងតែវិសោធនកម្មនោះនាំឱ្យបង្កើនចំណាយ ។

៣-នីតិវិធីច្បាប់

អត្ថបទអាចបញ្ជូនមកសភាណាមួយ ។

ក-នីតិវិធីធម្មតា

សេចក្តីព្រាងដែលសភាណាមួយបានអនុម័តត្រូវបញ្ជូនទៅសភាមួយទៀតអនុម័ត ហើយបញ្ជូនត្រឡប់ទៅវិញ ក្នុងករណីមានការកែប្រែ ។ បើសភាទាំងពីរព្រមព្រៀងគ្នាសភាដែលពិនិត្យចុងក្រោយបញ្ជូនអត្ថបទទៅប្រធានាធិបតីនៃសាធារណរដ្ឋដែលត្រូវចុះផ្សាយ ដោយគ្មានកំណត់ពេល ។

ក្នុងករណីមិនព្រមព្រៀងគ្នា សភាទាំងពីរប្រជុំរួមជាមហាសន្និបាតដែលអាចកែប្រែ ឬអនុម័តយល់ព្រមលើសេចក្តីព្រាងច្បាប់ តាមសម្លេងភាគច្រើន(២/៣) ។

បើមិនមានការព្រមព្រៀងគ្នាទេ សេចក្តីព្រាងនេះមិនអាចដាក់ឡើងវិញក្នុងសម័យប្រជុំប្រចាំឆ្នាំដដែលបានឡើយ ។

ខ-នីតិវិធីប្រញាប់

ប្រធានាធិបតីនៃសាធារណរដ្ឋអាចប្រើប្រាស់វិធានការប្រញាប់ ដើម្បីដាក់សេចក្តីព្រាងច្បាប់ឬវិសោធនកម្មជូនមហាសន្និបាតសភា ។

សភាដែលបានទទួលសេចក្តីព្រាងជាលើកដំបូង ត្រូវពិនិត្យក្នុងរយៈពេល៤៥ថ្ងៃ ។ បើមិនបានពិនិត្យក្នុងរយៈពេល៣០ថ្ងៃ សភានោះត្រូវប្រជុំជាវិសាមញ្ញនិងជាអចិន្ត្រៃយ៍ ។ នៅចុងបញ្ចប់នៃរយៈពេល៤៥ថ្ងៃ បើសេចក្តីព្រាងមិនត្រូវបានបដិសេធដោយច្បាស់លាស់ទេ សេចក្តីព្រាងនោះត្រូវចាត់ទុកថាយល់ព្រម ហើយត្រូវបញ្ជូនទៅសភាមួយទៀតដែលមានរយៈពេល៣០ថ្ងៃ សម្រាប់អនុម័ត ។ បើសភាចុងក្រោយនេះមិនបានបដិសេធដោយច្បាស់លាស់ទេ សេចក្តីព្រាងនោះត្រូវចាត់ទុកថាបានអនុម័តយល់ព្រម ។ បើអនុម័ត ដោយវិសោធនកម្មត្រូវបញ្ជូនត្រឡប់ទៅសភាដើមវិញ ដែលមានរយៈពេល១៥ថ្ងៃសម្រាប់អនុម័ត ។ បើហួសរយៈពេលនេះ សភាដើមមិនបានអនុម័ត សភាទាំងពីរត្រូវរួមប្រជុំមហាសន្និបាតដើម្បីអនុម័តក្នុងរយៈពេល១០ថ្ងៃ ។ ហួសរយៈពេលនេះ បើមហាសន្និបាតមិនបានអនុម័ត សេចក្តីព្រាងនោះត្រូវចាត់ទុកថាបានអនុម័តយល់

ព្រម ហើយត្រូវបញ្ជូនទៅរដ្ឋាភិបាលដើម្បីចុះផ្សាយ ។ បើសភាណាមួយឬមហាសន្ធិបាតបដិសេធ សេចក្តីព្រាងនោះមិនអាចដាក់ឡើងវិញក្នុងសម័យប្រជុំប្រចាំឆ្នាំដដែលបានឡើយ ។

តាមនីតិវិធីនេះ ប្រធានាធិបតីមិនអាចដាក់សេចក្តីព្រាងច្បាប់លើសពីមួយបានទេ ហើយមិនអាចប្រើសម្រាប់ច្បាប់ថវិកាឡើយ ។

សភានីមួយៗអាចបដិសេធនីតិវិធីប្រញ្ជាប់ដោយការអនុម័ត តាមសម្លេងភាគច្រើនបីភាគប្រាំ(៣/៥) នៃសមាជិក ។

ដូច្នេះ សេចក្តីព្រាងត្រូវដំណើរការតាមនីតិវិធីធម្មតា ។

ត-វិស័យថវិកា

រដ្ឋាភិបាលដាក់សេចក្តីព្រាងច្បាប់ថវិការដ្ឋ និងសេចក្តីព្រាងថវិកាខេត្ត (budget départementaux) ជូនសភាទាំងពីរក្នុងអំឡុងរមាសទី១ឯប្រតិបត្តិការថវិកា (dans les 6 premiers mois de l'exercice budgétaire) និងដាក់ជូននូវច្បាប់ស្តីពីការអនុវត្តគណនីក្នុងរយៈពេល៦ខែកន្លងមក ។

សភាមិនអាចអនុម័តការកែប្រែដែលបណ្តាលឱ្យបង្កើនចំណាយ ។

សភានីមួយៗមានរយៈពេល ៤៥ថ្ងៃសម្រាប់អនុម័ត ។ ហួសរយៈពេលនេះ បើសភាទាំងពីរមិនបានអនុម័ត សេចក្តីព្រាងត្រូវចាត់ទុកថាបានបដិសេធ ។

បើសេចក្តីព្រាងត្រូវបានអនុម័តដោយសភាណាមួយ ហើយត្រូវសភាមួយទៀតកែប្រែ សភាដើម (សភាពិនិត្យលើកដំបូង) មានរយៈពេល១៥ថ្ងៃសម្រាប់ពិនិត្យការកែប្រែនោះ ។ បើហួសរយៈពេលនេះ សភាដើមមិនបានអនុម័ត ឬបដិសេធវិសោធនកម្ម (ការកែប្រែ) សភាទាំងពីររួមប្រជុំមហាសន្ធិបាតដើម្បីអនុម័តក្នុងរយៈពេល១៥ថ្ងៃ ។បើហួសរយៈពេលនេះ មហាសន្ធិបាតមិនបានអនុម័ត សេចក្តីព្រាងត្រូវចាត់ទុកថាបានបដិសេធ ។

ឃ-សិទ្ធិជំទាស់របស់ប្រធានាធិបតី

បើប្រធានាធិបតីជំទាស់ទាំងស្រុង ឬផ្នែកណាមួយនៃអត្ថបទ ដែលសភាបានបញ្ជូនមក ប្រធានាធិបតីបញ្ជូនត្រឡប់ទៅមហាសន្ធិបាតវិញ បន្ទាប់ពីធ្វើវិសោធនកម្មក្នុងរយៈពេល១០ថ្ងៃ ។

បើប្រធានាធិបតីមិនបានបញ្ជាក់ការមិនយល់ព្រមនៅហួសពេលនេះទេ សេចក្តីព្រាងដែលអនុម័តដោយសភាទាំងពីរមានឥទ្ធិពលជាច្បាប់ ។

សន្និបាតអនុម័តអត្ថបទរបស់ប្រធានាធិបតី តាមសម្លេងភាគច្រើនបីភាគប្រាំ(៣/៥) ។

បើអត្ថបទរបស់ប្រធានាធិបតីមិនត្រូវបានបដិសេធដោយច្បាស់លាស់ ក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីការបញ្ជូនទៅមហាសន្និបាតវិញទេ អត្ថបទនោះត្រូវចាត់ទុកថាបានអនុម័ត ។

បើមហាសន្និបាតបដិសេធ អត្ថបទនោះមិនអាចដាក់ឡើងវិញក្នុងសម័យប្រជុំប្រចាំឆ្នាំដដែលបានឡើយ ។

ង-បទប្បញ្ញត្តិដោយឡែក

ច្បាប់ស្តីពីការបោះឆ្នោត (គិតទាំងការបោះឆ្នោតផ្ទៃក្នុងគណបក្សនយោបាយផង) ត្រូវ

ត្រូវមានសម្លេងគាំទ្រពីរភាគបី(២/៣) នៃសមាជិកសភានីមួយៗ ។

ខ-អំណាចត្រួតពិនិត្យ

១-ការបន្ទោស

សភានីមួយៗអាចស្នើសុំធ្វើការបន្ទោសរដ្ឋមន្ត្រីមួយរូប ច្រើនរូបឬទាំងអស់ ។ កាលណាញត្តិបន្ទោសបានដាក់នៅសភាណាមួយ សភានោះត្រូវប្រជុំក្នុងរយៈពេល៤៨ម៉ោង និងអនុម័តញត្តិ តាមសម្លេងភាគច្រើននៃសមាជិកវត្តមាន ។

ញត្តិដែលបានអនុម័តនោះត្រូវដាក់ជូនមហាសន្និបាតដែលត្រូវប្រជុំក្នុងរយៈពេល៤៨ម៉ោង ។

មហាសន្និបាតអនុម័តញត្តិតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកមហាសន្និបាត ក្នុងពេលប្រជុំពិសេសជាសាធារណៈ ។ បើញត្តិត្រូវបានអនុម័ត រដ្ឋមន្ត្រី(មួយរូបឬច្រើនរូប)នោះត្រូវដាក់ពាក្យលាលែង ។ បើមហាសន្និបាតបានសម្លេងតិចជាងពីរភាគបី(២/៣) ប្រធានាធិបតីនៃសាធារណរដ្ឋ អាចស្នើឱ្យមានការអនុម័តជាថ្មីរបស់មហាសន្និបាត ដែលត្រូវប្រជុំក្នុងរយៈពេល១០ថ្ងៃ ។

បើមហាសន្និបាតមិនប្រមូលបានសម្លេងលើសពីពាក់កណ្តាលនៃសមាជិករបស់ខ្លួន សម័យប្រជុំបន្ទាប់នឹងត្រូវកោះយ៉ាងតិច២៤ម៉ោងក្រោយការប្រជុំលើកមុន ឬយ៉ាងយូរបំផុត៧២ម៉ោងក្រោយ ។ បើខ្វះកូរ៉ុមនៅពេលប្រជុំលើកទី២នេះ ញត្តិត្រូវបានចាត់ទុកថាបដិសេធ ។

បើញត្តិទទួលបានតិចជាងបីភាគប្រាំ(៣/៥) នៃសមាជិកមហាសន្និបាត ប្រធានាធិបតីអាចសម្រេចរក្សាទុកញត្តិ ឬរដ្ឋមន្ត្រីនានាដែលពាក់ព័ន្ធ ឬរំលាយព្រឹទ្ធសភានិងរដ្ឋសភា ។

សេចក្តីសម្រេចរក្សាទុករដ្ឋមន្ត្រី រំលាយរដ្ឋសភា និងរៀបចំការបោះឆ្នោតមានចែងនៅក្នុងក្រឹត្យតែមួយ ។ សភាទាំងពីរលែងអាចប្រជុំបាន ប៉ុន្តែសមាជិកសភានៅរក្សាលក្ខន្តិកៈរបស់ខ្លួនដដែល ។

ប្រធានាធិបតីនៃសាធារណរដ្ឋមិនអាចរំលាយសភា នៅឆ្នាំចុងក្រោយនៃអាណត្តិ ។ ក្នុងរយៈពេលនេះ សភាទាំងពីរអាចអនុម័តញត្តិបន្ទោស ប៉ុន្តែញត្តិត្រូវអនុម័តតែតាមសម្លេងភាគច្រើនលើសពីពីរភាគបី(២/៣) នៃសមាជិកមហាសន្និបាតទាំងមូល ។

បើញត្តិបន្ទោសមិនសំដៅទៅលើរដ្ឋមន្ត្រី(ទាំងអស់)ទេ ប្រធានាធិបតីនៃសាធារណរដ្ឋអាចប្រើអំណាចរបស់ខ្លួនតែម្តងគត់ ក្នុងការរំលាយសភានៃអាណត្តិនីមួយៗ ។

ក្នុងករណីរំលាយសភា បើរដ្ឋាភិបាលមិនរៀបចំការបោះឆ្នោត ឬបើរយៈពេល៩០ថ្ងៃក្រោយការបោះឆ្នោតនេះ តុលាការបោះឆ្នោត(Cour électorale) មិនបានប្រកាសលទ្ធផល ការរំលាយសភាត្រូវចាត់ទុកជាមោឃៈ ហើយសភាចាស់ត្រូវបន្តការងាររបស់ខ្លួនទៅទៀត ។

នៅពេលលទ្ធផលត្រូវបានប្រកាស មហាសន្និបាតថ្មី (nouvelle Assemblée Générale) រួមប្រជុំដោយពេញច្បាប់ ក្នុងរយៈពេល៣ថ្ងៃបន្ទាប់ពីការប្រកាសលទ្ធផល ដោយមិនចាំបាច់មានការកោះប្រជុំរបស់ប្រធានាធិបតីនៃសាធារណរដ្ឋឡើយ ។

ក្នុងរយៈពេល១៥ថ្ងៃ មហាសន្និបាតថ្មីសម្រេចលើញត្តិបន្ទោសតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិករបស់ខ្លួន ។ បើញត្តិត្រូវបានអនុម័ត រដ្ឋមន្ត្រី(ឬរដ្ឋមន្ត្រីនានា)នោះត្រូវដាក់ពាក្យលាលែង ។ សភាថ្មីបញ្ចប់អាណត្តិរបស់សភាចាស់ ។

២-ការកោះអញ្ជើញរដ្ឋមន្ត្រី(Interpellation des ministres)

សភានីមួយៗមានសិទ្ធិកោះហៅរដ្ឋមន្ត្រី (ឬរដ្ឋមន្ត្រីនានា) លើសមាជិកយ៉ាងតិចមួយភាគបី (១/៣) ស្នើសុំ។ សមាជិករដ្ឋាភិបាលអាចស្នើសុំចូលរួមប្រជុំមហាសន្និបាត ឬប្រជុំសភាណាមួយ ប្រជុំគណៈកម្មការអចិន្ត្រៃយ៍ និងគណៈកម្មការនីមួយៗនៃសភាទាំងពីរ។

រដ្ឋមន្ត្រីអាចចូលរួមយោបល់ ប៉ុន្តែមិនអាចអនុម័តបានឡើយ។

៣-ការងារព័ត៌មាន

នៅដើមដំបូងនៃការប្រជុំប្រចាំឆ្នាំ ប្រធានាធិបតីនៃសាធារណរដ្ឋជូនព័ត៌មានដល់មហាសន្និបាតអំពីស្ថានភាពរបស់ប្រជាជាតិ និងអំពីកម្មវិធីសំខាន់ៗរបស់រដ្ឋាភិបាល។

ប្រធានាធិបតីនៃសាធារណរដ្ឋ អាចស្នើសុំមហាសន្និបាតឱ្យអនុម័តផ្តល់ការទុកចិត្តចំពោះរដ្ឋាភិបាល ។

ការអនុម័តត្រូវយកតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិក ពុំមានការពិភាក្សាក្នុងរយៈពេល៧២ម៉ោង។

បើហួសរយៈពេលនេះ មហាសន្និបាតមិនបានប្រជុំឬមិនបានអនុម័ត ការទុកចិត្តត្រូវចាត់ទុកថាបានអនុម័ត។

សភានីមួយៗអាចដាក់សំណូរ ជាលាយលក្ខណ៍អក្សរ ឬតាមរយៈប្រធានសភាចំពោះរដ្ឋមន្ត្រី តុលាការកំពូល តុលាការបោះឆ្នោត តុលាការវិវាទរដ្ឋបាល និងតុលាការគណនី។

៤-សភានីមួយៗអាចបង្កើតគណៈកម្មការស៊ើបអង្កេត ។

៥-ការផ្តល់សច្ចាប័នលើសន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ ។

V-បទប្បញ្ញត្តិដោយឡែក

ក-កំណែទម្រង់រដ្ឋធម្មនុញ្ញ

១-គំនិតផ្ទួចផ្តើមរបស់ប្រជាជន(initiative populaire)

សេចក្តីព្រាងនៃកំណែទម្រង់ត្រូវតែតំណាងដោយ១0% នៃអង្គបោះឆ្នោត(corp électoral) ។ សេចក្តីព្រាងត្រូវបញ្ជូនទៅប្រធានមហាសន្និបាត (Président de Assemblée Générale :vice-

Président de la République) ដែលត្រូវដាក់ឱ្យប្រជាជនអនុម័តនៅពេលបោះឆ្នោតដ៏ឆាប់ខាងមុខ ។

សភាទាំងពីរដែលប្រជុំជាមហាសន្និបាតអាចស្នើសេចក្តីព្រាងជាជម្រើស (Projet alternatif) ឱ្យអនុម័តនៅពេលជាមួយគ្នានឹងសេចក្តីព្រាងដំបូងរបស់ប្រជាជន ។

២-គំនិតផ្តួចផ្តើមរបស់មហាសន្និបាត

សមាជិកមហាសន្និបាតចំនួនពីរភាគប្រាំអាចស្នើសេចក្តីព្រាងនៃកំណែទម្រង់ដែលត្រូវដាក់ឱ្យប្រជាជនអនុម័ត និងត្រូវទទួលសម្លេងភាគច្រើនដាច់ខាត និងយ៉ាងតិចពាក់ភាគបួននៃចំនួនអ្នកចុះឈ្មោះទាំងអស់ ។

៣-គំនិតផ្តួចផ្តើមរបស់សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងរបស់អំណាចនីតិប្រតិបត្តិ

គំនិតផ្តួចផ្តើមនៃកំណែទម្រង់រដ្ឋធម្មនុញ្ញ អាចផ្តើមឡើងដោយសមាជិកព្រឹទ្ធសភាម្នាក់ៗ សមាជិករដ្ឋសភាម្នាក់ៗនិងដោយអំណាចនីតិប្រតិបត្តិ ។ សេចក្តីព្រាងត្រូវទទួលការគាំទ្រពីភាគច្រើនដាច់ខាតនៃសមាជិកមហាសន្និបាត ។ រដ្ឋាភិបាលរៀបចំការបោះឆ្នោត ដើម្បីតែងតាំងសមាជិកអនុសញ្ញាជាតិនៃធម្មនុញ្ញ (Convention nationale constituante) ដែលមានចំនួន២ដងច្រើនជាងសមាជិកមហាសន្និបាត ។

៤-កំណែទម្រង់ដោយច្បាប់ធម្មនុញ្ញ

រដ្ឋធម្មនុញ្ញអាចកែទម្រង់ដោយច្បាប់ធម្មនុញ្ញ ដែលត្រូវអនុម័តតាមសម្លេងភាគច្រើនពីរភាគបី (២៣) នៃសមាជិកសភានីមួយៗ នៅក្នុងសម័យប្រជុំដូចគ្នា ។ អង្គបោះឆ្នោតត្រូវធ្វើការអនុម័តផ្តល់ការគាំទ្រច្បាប់ធម្មនុញ្ញ ។ បើទទួលបានសម្លេងភាគច្រើនដាច់ខាត សេចក្តីព្រាងត្រូវប្រកាសឱ្យប្រើដោយប្រធានមហាសន្និបាត ។

រដ្ឋាភិបាលមិនអាចប្រើសិទ្ធិវីតូបានឡើយ ។

ខ-ប្រធានព្រឹទ្ធសភា

ប្រធានព្រឹទ្ធសភាដឹកនាំការប្រជុំរួមនៃសភាទាំងពីរក្នុងការពិភាក្សានិងអនុម័ត ។

គ-ការតែងតាំង និងការដកហូតតំណែង

១-ព្រឹទ្ធសភា រួមជាមួយរដ្ឋសភា ក្នុងមហាសន្និបាត :

ក-កំណត់ចំនួនកងកម្លាំងប្រដាប់អាវុធ

ខ-សម្រេចបង្កើត ឬលុបការងារសាធារណៈ

ត-តែងតាំងសមាជិក:

-តុលាការកំពូលយុត្តិធម៌(Cour supreme de justice)

-តុលាការវិវាទរដ្ឋបាល(Tribunal du contentieux administratif)

-តុលាការបោះឆ្នោត(tribunal électoral)

-តុលាការគណនី(Tribunal des Comptes) ។

ព្រឹទ្ធសភាផ្តល់ការអនុញ្ញាត :

-ការតម្លើងថ្នាក់នាយទាហានជាន់ខ្ពស់ចាប់ពីវរសេនីឯកឡើង

-ការតែងតាំងរដ្ឋអាជ្ញានៃតុលាការកំពូល និងរដ្ឋអាជ្ញានៃសាធារណរដ្ឋ

-ការតែងតាំងសមាជិកសាលាឧទ្ធរណ៍(tribunal d'appel)

-ការតែងតាំងអគ្គនាយក (directeurs généraux) និងសមាជិកក្រុមប្រឹក្សានាយក (conseil de direction) នៃសហគ្រាសសាធារណៈ(តាមសម្លេងភាគច្រើនបីភាគប្រាំ(៣/៥) ក្នុងការអនុម័តលើកទី១ ។ បើក្រោយការបដិសេធ រដ្ឋាភិបាលនៅតែរក្សាបេក្ខភាពដដែល សម្លេងភាគច្រើនដាច់ខាតត្រូវយកមកប្រើ) ។

ការតែងតាំងដោយប្រធានាធិបតីនៃសាធារណរដ្ឋ នូវប្រមុខបេសកកម្មការទូតត្រូវមានការយល់ព្រមពីព្រឹទ្ធសភាឬពីគណៈកម្មការអចិន្ត្រៃយ៍ ។ បើពុំមានការសម្រេចណាពីព្រឹទ្ធសភាក្នុងរយៈពេល៦០ថ្ងៃ ប្រធានាធិបតីដំណើរការតែងតាំង ។

២-ប្រធានាធិបតីនៃសាធារណរដ្ឋអាចដកហូតមុខតំណែងមន្ត្រីការទូត និងភារធារីដោយមានការអនុញ្ញាតពីព្រឹទ្ធសភាដែលត្រូវសម្រេចក្នុងរយៈពេល៩០ថ្ងៃ ។ ហួសរយៈពេលនេះ បើព្រឹទ្ធសភាមិនបានអនុម័ត ប្រធានាធិបតីនៃសាធារណរដ្ឋអាចដំណើរការដកហូត ដោយមិនមានការអនុញ្ញាតពីព្រឹទ្ធសភា ។

ព្រឹទ្ធសភាតែឯកឯងអនុញ្ញាតឱ្យដកហូតមុខតំណែងមន្ត្រីដោយអសមត្ថភាព ឬមានកំហុស ។

ឃ-ការត្រួតពិនិត្យការបោះឆ្នោត

តុលាការបោះឆ្នោតវិនិច្ឆ័យការបោះឆ្នោត ។ សមាជិកទាំង៥រូបត្រូវតែងតាំង ដោយមហាសន្ទិបាត: ៥រូប តាមសម្លេងភាគច្រើនពីរភាគបី(២/៣) នៃសមាជិកមហាសន្ទិបាត និង៤រូបទៀត ដោយការអនុម័តពីរលើកជាបន្តបន្ទាប់ តាមប្រព័ន្ធសមាមាត្រ ។

សភានីមួយ១អាចស្នើសុំឱ្យតុលាការបោះឆ្នោតចាត់ការពិន័យចៅក្រម សមាជិកតុលាការ Cuentas តុលាការវិវាទរដ្ឋបាល នាយកសហត្រាសសាធារណ: សេវាវិមជ្ឈការ យោធាសកម្ម និងមន្ត្រីនគរបាលដែលមិនគោរពកាតព្វកិច្ចស្របច្បាប់(មិនពាក់ព័ន្ធនឹងសកម្មភាពនយោបាយ) ។

ង-ការត្រួតពិនិត្យធម្មនុញ្ញភាព

សភាទាំងពីរអាចបកស្រាយរដ្ឋធម្មនុញ្ញ ។ គណ:កម្មការអចិន្ត្រៃយ៍តាមដាន ត្រួតពិនិត្យការគោរពរដ្ឋធម្មនុញ្ញ និងច្បាប់ និងមានអំណាចផ្តល់ការវំលឹកដល់រដ្ឋាភិបាលក្នុងការងារនេះ ។ ក្រោយការវំលឹកលើកទី២ គណ:កម្មការអចិន្ត្រៃយ៍អាចសម្រេចកោះប្រជុំមហាសន្ទិបាត ។

តុលាការកំពូលយុត្តិធម៌ដែលអនុវត្តអំណាចតុលាការ វិនិច្ឆ័យអំពីធម្មនុញ្ញភាពរបស់ច្បាប់ ។ សមាជិក៥រូបនៃតុលាការនេះត្រូវចាត់តាំងដោយមហាសន្ទិបាត តាមសម្លេងភាគច្រើន២/៣ ។

ច-វិធានការបន្ទាន់

ប្រធានាធិបតីនៃសាធារណរដ្ឋអាចចាត់វិធានការបន្ទាន់នានាក្នុងករណីមានការឈ្លានពានពីខាងក្រៅឬភាពវឹកវរខាងក្នុង ។ ប្រធានាធិបតីជូនដំណឹងដល់សភាទាំងពីរ ដែលប្រជុំរួមជាមហាសន្ទិ-បាត ក្នុងរយ:ពេល២៤ម៉ោង និងបញ្ជាក់អំពីមូលហេតុ ។

វិធានការបន្ទាន់នីមួយ១ ត្រូវដាក់ជូនមហាសន្ទិបាត ក្នុងរយ:ពេល២៤ម៉ោង បន្ទាប់ពីការសម្រេច ។

ឆ-ការទទួលខុសត្រូវរបស់មន្ត្រី

មន្ត្រីនានា(នាយកប្រតិបត្តិខេត្ត-chefs de l'exécutif départemental និងមេឃុំជាប់

ឆ្នោត-maires élus) និងសមាជិកក្រុមប្រឹក្សាខេត្តអាចត្រូវចោទប្រកាន់នៅមុខព្រឹទ្ធសភា ដោយសមាជិកក្រុមប្រឹក្សាខេត្តចំនួនមួយភាគបី(១/៣) ពីបទរំលោភរដ្ឋធម្មនុញ្ញ ឬកំហុសធ្ងន់ធ្ងរ ។

ព្រឹទ្ធសភាអាចបញ្ចប់មុខងារមន្ត្រីទាំងនោះ តាមសម្លេងភាគច្រើនពីរភាគបី(២/៣) ។

ជ-អំណាចតុលាការ

អំណាចតុលាការជារបស់ព្រឹទ្ធសភាតែឯកឯង តាមសំណើរបស់រដ្ឋសភា ក្នុងការវិនិច្ឆ័យប្រធានាធិបតីនៃសាធារណរដ្ឋ អនុប្រធានាធិបតី រដ្ឋមន្ត្រី សមាជិកសភា សមាជិកតុលាការកំពូល យុត្តិធម៌ តុលាការវិវាទរដ្ឋបាល តុលាការបោះឆ្នោត និងតុលាការ Cuentas ពីបទរំលោភរដ្ឋធម្មនុញ្ញ ឬកំហុសធ្ងន់ធ្ងរក្នុងការបំពេញមុខងារ ។

ការសម្រេចត្រូវយកតាមសម្លេងភាគច្រើន២/៣នៃសមាជិកព្រឹទ្ធសភា ។ ក្នុងករណីនេះ ប្រធានាធិបតីនៃសាធារណរដ្ឋត្រូវស្នូរ ។

ឈ-វិស័យអន្តរជាតិ

១-មហាសន្និបាតអនុម័តសេចក្ដីសម្រេចចិត្តប្រកាសសង្គ្រាម និងអនុញ្ញាតឱ្យប្រធានាធិបតីនៃសាធារណរដ្ឋចេញសេចក្ដីប្រកាស ។

២-មហាសន្និបាតអនុញ្ញាត ឬបដិសេធការផ្ទេរកាត់ឬការលាបន់ចាតជាបណ្ដោះអាសន្នទ្រព្យកងទ័ពបរទេសលើទឹកដី និងកំណត់រយៈពេលស្នាក់នៅ ។

៣-មហាសន្និបាតយល់ព្រម ឬបដិសេធការបញ្ជូនកងទ័ពទៅបរទេស និងកំណត់រយៈពេលស្នាក់នៅ ។

៤-សន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ ដែលចុះហត្ថលេខាដោយប្រធានាធិបតីនៃសាធារណរដ្ឋត្រូវតែផ្ដល់សច្ចាប័នដោយមហាសន្និបាត ។

ញ-ការអនុញ្ញាតឱ្យប្រធានាធិបតីអវត្តមាន

ព្រឹទ្ធសភាមានសមត្ថកិច្ចផ្ដាច់មុខក្នុងការអនុញ្ញាតឱ្យប្រធានាធិបតីនៃសាធារណរដ្ឋអវត្តមានពីប្រទេសលើសពី៤៨ម៉ោង ។

ក្នុងករណីមានការចោទប្រកាន់លើប្រធានាធិបតីនៃសាធារណរដ្ឋ ការអនុញ្ញាតឱ្យចេញពីប្រទេសត្រូវសម្រេចដោយមហាសន្និបាត តាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិករបស់ខ្លួន ។

ថ្ងៃទី១៥ខែវិច្ឆិកាឆ្នាំ២000 សភាយ៉ែម៉ែន-រដ្ឋសភាបានអនុម័តវិសោធនកម្មយ៉ាងច្រើន នៃរដ្ឋធម្មនុញ្ញ ដែលស្នើឡើងដោយប្រធានាធិបតីនៃសាធារណរដ្ឋ និងរៀបចំតាមសំណើរបស់ខ្លួនដោយក្រុមប្រឹក្សាពិគ្រោះយោបល់(Conseil de la Choura) ។

វិសោធនកម្មមួយចែងអំពីការពង្រីកក្រុមប្រឹក្សាពិគ្រោះយោបល់បច្ចុប្បន្ន (បង្កើតនៅឆ្នាំ ១៩៩៤) និងមានសមាជិក៥៩រូបតែងតាំងដោយប្រធានាធិបតីនៃសាធារណរដ្ឋ និងការពង្រឹងអំណាចនីតិប្បញ្ញត្តិ ។

សេចក្តីព្រាងវិសោធនកម្មត្រូវបានអនុម័តដោយប្រជាមតិ នៅថ្ងៃទី២0ខែកុម្ភៈឆ្នាំ២00១ ។

I-សមាសភាព

ក្រុមប្រឹក្សាមានសមាជិក១១១រូប តែងតាំងដោយក្រឹត្យរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ។ សមាជិកនេះមិនអាចតែងតាំងជាសមាជិករដ្ឋសភា ឬជាសមាជិកសភាមូលដ្ឋានទេ ។ សមាជិកក្រុមប្រឹក្សាត្រូវមានអាយុយ៉ាងតិច៤0ឆ្នាំ ។

II-សមត្ថកិច្ច

ក្រៅពីអំណាចពិគ្រោះយោបល់និងអន្តរាគមន៍របស់ការិយាល័យ(រួមជាមួយការិយាល័យរបស់រដ្ឋសភា) ដើម្បីអនុម័តបញ្ជីបេក្ខជនបោះឆ្នោតប្រធានាធិបតី អំណះតទៅការយល់ព្រមរបស់ក្រុមប្រឹក្សាជាការតម្រូវឱ្យមានក្នុងការប្រជុំរួមជាមួយរដ្ឋសភាដែលកោះដោយប្រធានាធិបតីនៃសាធារណរដ្ឋ ដើម្បីអនុម័តច្បាប់ទាំងអស់ទាក់ទងនឹងការអនុវត្តផែនការសង្គម សេដ្ឋកិច្ច ឬដែលទាក់ទងនឹងការការពារព្រំដែន សម្ព័ន្ធភាព និងសន្តិភាព ក៏ដូចជាគ្រប់វិស័យ ដែលដាក់ជូនអង្គប្រជុំរួមដោយប្រធាន ។

ហ្ស៊ីមបាវេ ព្រឹទ្ធសភា

ZIMBABWE LE SENAT

I-សេចក្តីព្រាងរដ្ឋធម្មនុញ្ញដែលដាក់ធ្វើប្រជាមតិនៅថ្ងៃទី១២និង១៣ ខែកុម្ភៈឆ្នាំ២០០០ ចែងអំពីការបង្កើតឡើងវិញនូវសភាទី២ ដែលហៅថាព្រឹទ្ធសភា (លុបនៅឆ្នាំ ១៩៩០) ដែលមានសមាជិក៦០រូប (អាយុយ៉ាងតិច៤០ឆ្នាំ) ដែល:

-៥រូបជ្រើសតាំង តាមប្រព័ន្ធសមាមាត្រ ក្នុងខេត្តនីមួយៗនៃខេត្តទាំង១០

-១០រូបជ្រើសរើសក្នុងចំណោមប្រធានប្រពៃណី(chefs traditionnels)

សេចក្តីព្រាងរដ្ឋធម្មនុញ្ញនេះត្រូវបានច្រានចោលដោយសម្លេង៥៥% ។

II- នៅសម័យប្រជុំលើកទី៨១នៃការិយាល័យនយោបាយ (ZANU-PF) ខែមិថុនាឆ្នាំ២០០៥ ប្រធានាធិបតី Mugabe បានដាក់សេចក្តីព្រាងនៃកំណែទម្រង់រដ្ឋធម្មនុញ្ញ ដែលបង្កើតឡើងវិញនូវប្រព័ន្ធសភាពីរ ។

វិសោធនកម្មរដ្ឋធម្មនុញ្ញនេះត្រូវបានអនុម័តដោយសភា នៅថ្ងៃ៣០ ខែសីហា ឆ្នាំ២០០៥ ហើយប្រកាសឱ្យប្រើ និងបោះផ្សាយនៅថ្ងៃទី១៤ខែកញ្ញាឆ្នាំ២០០៥ ។

ការបោះឆ្នោតព្រឹទ្ធសភាលើកទី១ប្រព្រឹត្តទៅនៅថ្ងៃទី២៦ខែវិច្ឆិកា ឆ្នាំ២០០៥ ។

I-សមាសភាព

ព្រឹទ្ធសភាមានសមាជិក៦៦រូប :

-៥០រូបជ្រើសតាំងដោយការបោះឆ្នោតដោយផ្ទាល់(៥អាសនៈក្នុង១ខេត្តនៃខេត្តទាំង១០)

-ប្រធាន និងអនុប្រធានក្រុមប្រឹក្សាប្រធានប្រពៃណី

-ប្រធានប្រពៃណី៨រូបជ្រើសរើសក្នុងខេត្តនីមួយៗនៃខេត្តទាំង៨(មិនមែនក្រុង)

-៦រូបតែងតាំងដោយប្រមុខរដ្ឋ ។

II-របបបោះឆ្នោត

ប្រព័ន្ធ :ឯកត្តនាម សម្លេងភាគច្រើនសាមញ្ញ តែ១ជុំ

មណ្ឌល : ៥០

អាយុ : ៤០ឆ្នាំ

សមាជិកព្រឹទ្ធសភាអាចជារដ្ឋមន្ត្រី ឬអនុរដ្ឋមន្ត្រី ។

ហ្វីជហ្ជ៊ី(គោះ) ព្រឹទ្ធសភា

FIDJI (Iles) LE SENAT

ក្រោយរដ្ឋប្រហារយោធា ថ្ងៃទី៥ ខែ ធ្នូ ឆ្នាំ២០០៦ សភាត្រូវរលាយ ។

I-សមាសភាព

ព្រឹទ្ធសភាមានសមាជិក៣២រូប តែងតាំងដោយប្រមុខរដ្ឋ:

-១៤រូប ស្នើដោយខុត្តមក្រុមប្រឹក្សាប្រធាន(Grand conseil des Chefs)

-៥រូប ស្នើដោយនាយករដ្ឋមន្ត្រី

-៨រូប ស្នើដោយប្រមុខគណបក្សជំទាស់

-១រូបស្នើដោយក្រុមប្រឹក្សាRotuma ។

II-របបតែងតាំង

អាណត្តិ : ៥ឆ្នាំ(ដូចគ្នានឹងរដ្ឋសភា លើកលែងតែក្នុងករណីត្រូវរំលាយ)

ការផ្ទាស់ប្តូរថ្មីចុងក្រោយ : ៦ មិថុនា ឆ្នាំ ២០០៦

អាយុអប្បបរមា : ២១ឆ្នាំ ។

III-សម័យប្រជុំ

ក-សម័យប្រជុំសាមញ្ញ

សភាត្រូវកោះប្រជុំដោយប្រធានាធិបតីនៃសាធារណរដ្ឋ តាមសំណើរបស់នាយករដ្ឋមន្ត្រី ប៉ុន្តែចន្លោះពីសម័យប្រជុំមួយទៅសម័យប្រជុំមួយទៀតមិនត្រូវលើសពី៦ខែឡើយ ។

ខ-សម័យប្រជុំវិសាមញ្ញ

ប្រធានាធិបតីនៃសាធារណរដ្ឋអាចកោះប្រជុំសភាជាវិសាមញ្ញ តាមសំណើជាលាយលក្ខណ៍អក្សរពីសមាជិករដ្ឋសភាយ៉ាងតិច១៨រូប ។

គ-ពេលប្រជុំ(séances)

កាលណាសភាស្ថិតក្នុងសម័យប្រជុំ ប៉ុន្តែបើរដ្ឋសភាមិនប្រជុំតាំងពីលើសពី២ខែ តាមសំណើជាលាយលក្ខណ៍អក្សរពីសមាជិករដ្ឋសភាយ៉ាងតិច១៨រូប ប្រធានរដ្ឋសភាអាចកំណត់ពេលប្រជុំយ៉ាងយូរបំផុត២សប្តាហ៍ ក្រោយពេលស្នើ ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

អំណាចនីតិប្បញ្ញត្តិត្រូវបានផ្តល់ឱ្យសភាដែលមានប្រធានរដ្ឋសភា និងព្រឹទ្ធសភា ។

១-ឥទ្ធិពលផ្ទាល់ក្នុងការធ្វើច្បាប់ : គ្មាន

២-សិទ្ធិវិសោធនកម្ម : មាន លើកលែងតែវិស័យពន្ធដារ ឬការប្រមូលចំណូល ។ ព្រឹទ្ធសភាមិនអាចបង្កើនបន្ទុកទៅលើពលរដ្ឋទេ ។

៣-នីតិវិធីធ្វើច្បាប់

ក-នីតិវិធីធម្មតា

ក្រោយពីបានពិនិត្យនៅរដ្ឋសភា សេចក្តីព្រាងច្បាប់ត្រូវបញ្ជូនទៅព្រឹទ្ធសភា ។ បើព្រឹទ្ធសភាធ្វើវិសោធនកម្ម រដ្ឋសភាអាចយល់ព្រម បដិសេធ ឬអនុម័តដោយមានការកែប្រែ ។

បើរដ្ឋសភាបដិសេធវិសោធនកម្មណាមួយរបស់ព្រឹទ្ធសភា សេចក្តីព្រាងត្រូវបញ្ជូនទៅព្រឹទ្ធសភាវិញ ។

បើរដ្ឋសភាអនុម័តសេចក្តីព្រាងច្បាប់ក្នុងអំឡុងពីរសម័យប្រជុំជាបន្តបន្ទាប់ និងដោយមានចន្លោះពេលយ៉ាងតិច៦ខែ និងក្នុងករណីទាំងពីរ ព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬអនុម័តដោយមានការកែប្រែ ដែលមិនមានការយល់ព្រមពីរដ្ឋសភា សេចក្តីព្រាងអាចដាក់ជូនប្រធានាធិបតីនៃសាធារណរដ្ឋដើម្បីផ្តល់ការយល់ព្រម ។

បើរដ្ឋសភាយល់ថាត្រឹមត្រូវល្អ រដ្ឋសភាអាចដាក់បញ្ចូលក្នុងសេចក្តីព្រាង ដែលបដិសេធ ឬអនុម័តដោយព្រឹទ្ធសភាដោយមានការកែប្រែដែលរដ្ឋសភាមិនបានយល់ព្រម ទូវិសោធនកម្ម ដែល(បើសិនជាយល់ព្រមដោយព្រឹទ្ធសភា)រដ្ឋសភាអាចទទួលយកបាន ។

បើព្រឹទ្ធសភាអនុម័តសេចក្តីព្រាងច្បាប់ក្នុងលក្ខខណ្ឌទាំងនេះ វិសោធនកម្មនានាត្រូវចាត់ទុកថាជាវិសោធនកម្មរបស់ព្រឹទ្ធសភា ដែលយល់ព្រមដោយរដ្ឋសភា ។

ខ-នីតិវិធីប្រញាប់

បើនាយករដ្ឋមន្ត្រីបញ្ជាក់ជាលាយលក្ខណ៍អក្សរទៅប្រធានព្រឹទ្ធសភាថា សេចក្តីព្រាងដែលអនុម័តដោយរដ្ឋសភាមានលក្ខណៈប្រញាប់នោះ អត្ថបទត្រូវបញ្ជូនទៅព្រឹទ្ធសភាយ៉ាងតិចៗថ្ងៃប្រជុំមុនដំណាច់សម័យប្រជុំ ។

បើព្រឹទ្ធសភាមិនអនុម័តសេចក្តីព្រាងច្បាប់ក្នុងរយៈពេលៗថ្ងៃនេះទេ(គិតពីថ្ងៃបញ្ជូនមក) ឬអនុម័តដោយមានការកែប្រែ ដែលមិនទទួលយកដោយរដ្ឋសភាក្នុងរយៈពេលនេះ អត្ថបទត្រូវបញ្ជូនទៅប្រធានាធិបតីដើម្បីផ្តល់ការយល់ព្រម ។

ត-នីតិវិធីសម្រាប់វិស័យហិរញ្ញវត្ថុ

បើសេចក្តីព្រាងច្បាប់(អនុម័តដោយរដ្ឋសភា ហើយប្រធានបានបញ្ជាក់ថាមានប្រភេទជាច្បាប់ឥណទាន) មិនត្រូវបានអនុម័តយល់ព្រមដោយព្រឹទ្ធសភា នៅដំណាច់ពេលប្រជុំបន្ទាប់ពីថ្ងៃបញ្ជូនមកទេ អត្ថបទនោះត្រូវបញ្ជូនទៅប្រធានាធិបតីដើម្បីផ្តល់ការយល់ព្រម លើកលែងតែរដ្ឋសភាសម្រេចផ្សេងពីនេះ ។

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ(ក្រៅពីច្បាប់ខាងលើ) អនុម័តដោយរដ្ឋសភា ហើយប្រធានបានបញ្ជាក់អំពីប្រភេទច្បាប់ហិរញ្ញវត្ថុ ត្រូវបញ្ជូនទៅព្រឹទ្ធសភាយ៉ាងតិច២១ថ្ងៃប្រជុំមុនដំណាច់សម័យប្រជុំ ។

បើព្រឹទ្ធសភាមិនបានអនុម័តយល់ព្រម ក្នុងរយៈពេល២១ថ្ងៃបន្ទាប់ពីថ្ងៃបញ្ជូនមកទេ អត្ថបទត្រូវបញ្ជូនទៅប្រធានាធិបតីដើម្បីផ្តល់ការយល់ព្រម លើកលែងតែរដ្ឋសភាសម្រេចផ្សេងពីនេះ ។

ឃ-នីតិវិធីដោយឡែកសម្រាប់អត្ថបទកំណត់សិទ្ធិសមូហភាព(droits collectifs)

១-ការកែប្រែអត្ថបទខ្លះទាក់ទងនឹងការអភិវឌ្ឍន៍ប្រទេស និងដែនដីមិនអាចដាក់ជូន

ប្រធានាធិបតី ដើម្បីផ្តល់ការយល់ព្រមមុនការអានលើកទី៣នៅសភានីមួយ១ និងបើគ្មានការបដិសេធពីព្រឹទ្ធសភា លើកលែងតែនៅការអានលើកទី៣អត្ថបទត្រូវបានអនុម័តយ៉ាងតិចដោយសម្លេងជ្រាំបួនភាគដប់បួន (៥/១៤) នៃសមាជិកដែលស្នើឡើងដោយ ឧត្តមក្រុមប្រឹក្សាប្រធាន (Grand Conseil des Chefs)។

២ -ការកែប្រែអត្ថបទទាក់ទងនឹងកម្មសិទ្ធិ និងអ្នកទទួលជួលដីធ្លីកសិកម្ម (locataires de terres agricoles) មិនអាចដាក់ជូនប្រធានាធិបតីដើម្បីផ្តល់ការយល់ព្រមមុនការអានលើកទី៣នៅសភានីមួយ១ និងដោយមានលក្ខខណ្ឌថានៅការអានលើកទី៣ អត្ថបទត្រូវបានអនុម័តតាមសម្លេងភាគច្រើនពីរភាគបី(២/៣) នៃសមាជិកសភានីមួយ១ និងនៅព្រឹទ្ធសភាត្រូវបានអនុ-ម័តយ៉ាងតិចដោយសម្លេងជ្រាំបួនភាគដប់បួន(៥/១៤) នៃសមាជិកដែលស្នើឡើងដោយឧត្តមក្រុមប្រឹក្សាប្រធាន។

ខ-ថវិកាប្រចាំឆ្នាំ

រាល់ឆ្នាំ រដ្ឋមន្ត្រីមានសមត្ថកិច្ចដាក់ជូនព្រឹទ្ធសភា (និងរដ្ឋសភា) នូវថវិកាប្រចាំឆ្នាំដែលបង្ហាញពីការប៉ាន់ប្រមាណចំណូលនិងចំណាយជាធម្មតា និងជាមូលធនដោយយោលទៅលើសេវាធម្មការបស់រដ្ឋាភិបាល និងរបស់សភា ។

គ-អំណាចត្រួតពិនិត្យ :គ្មាន

V-បទឧប្បញ្ញត្តិផ្សេងៗ

ក-ការកែប្រែរដ្ឋធម្មនុញ្ញ

សេចក្តីព្រាងកែប្រែរដ្ឋធម្មនុញ្ញត្រូវឬមិនត្រូវបានកែប្រែរហូតការអានលើកទី៣នៅសភានីមួយ១។

នៅការអានលើកទី២ និងលើកទី៣ អត្ថបទត្រូវអនុម័តតាមសម្លេងភាគច្រើនពីរភាគបី (២/៣) នៃសមាជិកសភានីមួយ១ ។

ដូចបទប្បញ្ញត្តិខ្លះដែលទាក់ទងនឹងរដ្ឋសភា ការកែប្រែបទប្បញ្ញត្តិអំពីសិទ្ធិសហគមន៍ (droits des communautés) ឬបទប្បញ្ញត្តិក្នុងកថាខ័ណ្ឌនេះ ត្រូវអនុម័តនៅការអានលើកទី៣យ៉ាងតិចដោយសម្លេង(៥/១៤) នៃសមាជិកដែលស្នើឡើងដោយឧត្តមក្រុមប្រឹក្សាប្រធាន។

8-OMDUDSMAN

១-តាមសំណើរបស់សមាជិកព្រឹទ្ធសភា១រូប(ឬរដ្ឋសភា១រូប គណៈកម្មការរបស់សភា ឬតាមគំនិតផ្តួចផ្តើមរបស់ខ្លួន)ombudsmanធ្វើការស៊ើបអង្កេតលើសកម្មភាព ក្នុងវិស័យរដ្ឋបាលដោយសេវា ឬអាជ្ញាធរមួយដែលបង្កើតឡើង ។

២-បើក្នុងរយៈពេលសមរម្យមួយ បទប្បញ្ញត្តិដែលចេញដោយombudsmanដើម្បីដោះស្រាយបញ្ហា មិនត្រូវបានចាត់ការ ombudsmanអាចដាក់ជូនព្រឹទ្ធសភា(និងរដ្ឋសភា)នូវរបាយការណ៍មួយដែលមានការអត្ថាធិប្បាយរបស់សេវា ឬអាជ្ញាធរដែលពាក់ព័ន្ធ ។

 គ-អគ្គត្រួតពិនិត្យហិរញ្ញវត្ថុសាធារណៈ Contrôleur général des finances publiques)

យ៉ាងតិច១ដងក្នុង១ឆ្នាំ អគ្គត្រួតពិនិត្យដាក់ជូនសភានូវរបាយការណ៍អំពីការត្រួតពិនិត្យដែលខ្លួនបានធ្វើ ។

សភាអាចផ្តល់ឱ្យអគ្គត្រួតពិនិត្យនូវមុខងារ និងអំណាច ។

ក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីពេលបញ្ជូនមក ឬបើសភាទាំងពីរមិនបានប្រជុំនៅថ្ងៃទី១ ក្រោយចប់រយៈពេលនេះ ប្រធានរដ្ឋសភាអាចសុំឱ្យប្រមុខគណបក្សជំទាស់នៃសភាទាំងពីរជូនរបាយការណ៍របស់អគ្គត្រួតពិនិត្យទៅសភាទាំងពីរ ។

ប៊ូគីណាហ្វាសូ សភាតំណាង
BURKINA FASO LA CHAMBRE DES REPRESENTANTS

<u>គំណត់ចំណាំ</u> : សភាតំណាងដែលមុខងារត្រូវបានពង្រីងខ្លះ ដោយការសើរើរដ្ឋធម្មនុញ្ញ អនុម័តនៅថ្ងៃទី១១ខែមេសាឆ្នាំ២០០០ ត្រូវបានលុបចោលនៅខែមករាឆ្នាំ២០០២ ។

សភាតំណាងនេះត្រូវបានជំនួសដោយសន្និសីទទូទៅរបស់ប្រជាជាតិ (Conférence générale de la Nation) ដែលលក្ខណៈ សមាសភាព សមត្ថកិច្ច មិនទាន់មានការបញ្ជាក់ ។

I-សមាសភាព

សភាតំណាងមានសមាជិក១៦២រូប :

-៩០រូបជ្រើសរើសដោយក្រុមប្រឹក្សាខេត្ត (conseils provinciaux)

-៦រូប តំណាងសហគមន៍ប្រូតេស្តង់ (២) កាតូលីក (២) និងមុលស៊ុយម៉ង់ (២)

-១រូប តំណាងសហគមន៍ tidjania

-១រូប តំណាងសហគមន៍ sunnite

-៨រូប តំណាងសហគមន៍ប្រពៃណី

-៥រូប តំណាងសហជីពកម្មករ

-១រូប តំណាងសមាគមមាតាបិតាសិស្សបឋមសិក្សា

-១រូប តំណាងសមាគមមាតាបិតាសិស្សមធ្យមសិក្សា

-២រូប តំណាងសមាគមយុវជន

-២រូប តំណាងបុគ្គលិកអប់រំជាតិ (មធ្យមនិងបឋម)

-២រូប តំណាងបុគ្គលិកសាកលវិទ្យាល័យ និង ស្រាវជ្រាវវិទ្យាសាស្ត្រ

-១រូប តំណាងសមាគមអ្នកប្រើប្រាស់

-៣រូប តំណាងវិស័យមិនផ្លូវការ (secteur informel)

-១រូប តំណាងសមាគមនិវត្តជន

-២រូប តំណាងសមាគមការពារសិទ្ធិមនុស្ស

-៨រូប តំណាងសមាគមនារី

-១រូប តំណាងពាណិជ្ជករ

-២រូប តំណាងសមាគមនិយោជក

-១រូប តំណាងអ្នកដឹកជញ្ជូន

-៥រូប តំណាងជនបទ(កសិករ ចិញ្ចឹមសត្ត និងប្រហាក់ប្រហែល)

-៣រូប តំណាងកងទ័ព

-៣រូប តំណាងអាវុធហត្ថ

-២រូប តំណាងសមាគមសិល្បករ

-២រូប តំណាងសមាគមកីឡាករ

-១រូប តំណាងសមាគមការពារបរិដ្ឋាន

-១រូប តំណាងសមាគមជនពិការ

-៣រូប តំណាងពលរដ្ឋ(Burkinabés) រស់នៅឯបរទេស

-៤រូប តំណាងដែលតែងតាំងដោយប្រធានាធិបតី(Président du Faso) ។

II-របបឆោះឆ្លោត

ប្រព័ន្ធ : ដោយមិនផ្ទាល់(scrutiny indirect) ។

តំណាងនានានៃអង្គការ ឬរចនាសម្ព័ន្ធខាងលើត្រូវជ្រើសតាំង ឬតែងតាំង ។

អាណត្តិ : ៣ឆ្នាំ

ការផ្ទាស់ប្តូរចុងក្រោយ: ខែ មេសា ឆ្នាំ១៩៩៩

III-សម័យប្រជុំ

ក-សម័យប្រជុំសាមញ្ញ

សភាតំណាងប្រជុំសាមញ្ញដោយពេញច្បាប់២លើក ក្នុង១ឆ្នាំ ព្រមជាមួយនឹងរដ្ឋ- សភា (Assemblée nationale) :

-លើកទី១ បើកនៅថ្ងៃពុធទី១ខែមីនា

-លើកទី២ បើកនៅថ្ងៃពុធចុងក្រោយខែកញ្ញាឬនៅថ្ងៃធ្វើការទី១បន្ទាប់បើចំលើថ្ងៃបុណ្យ ។

សម័យប្រជុំនីមួយៗមិនត្រូវលើសពី៩០ថ្ងៃឡើយ ។

ខ-សម័យប្រជុំវិសាមញ្ញ

សភាតំណាងប្រជុំជាវិសាមញ្ញ តាមការកោះអញ្ជើញរបស់ប្រធាន តាមសំណើរបស់ប្រធានាធិបតី នាយករដ្ឋមន្ត្រី ឬសមាជិកចំនួនពីរភាគបី(២/៣)លើរបៀបវារៈមួយជាក់លាក់ ។

សម័យប្រជុំវិសាមញ្ញចប់នៅពេលអស់របៀបវារៈ ហើយមិនត្រូវលើសពី១៥ថ្ងៃ ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

សភាតំណាងជាសភាពិគ្រោះយោបល់(chamber consultative) និងមិនមានអំណាចនីតិប្បញ្ញត្តិទេ ។ សភាតំណាងផ្តល់យោបល់ដែលចាំបាច់ ពេលមានការស្នើសុំ ។

ការផ្តើមគំនិតស្នើសុំឱ្យសភាតំណាងផ្តល់យោបល់លើសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ដែលមានសារៈសំខាន់ ចេញពីរដ្ឋាភិបាល រដ្ឋសភា ឬគណៈកម្មការអចិន្ត្រៃយ៍សភាតំណាង ។

យោបល់របស់សភាតំណាងជាការតម្រូវឱ្យមាន ចំពោះបញ្ហាដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

ចាប់តាំងពីការសើរើរដ្ឋធម្មនុញ្ញ ដែលអនុម័តនៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០០០ ដោយសមាជិករដ្ឋសភា សភាតំណាងត្រូវតែផ្តល់យោបល់ដើម្បីឱ្យរដ្ឋសភាអនុម័តនូវច្បាប់ដែលទាក់ទងនឹង :

-ភាពជាពលរដ្ឋ (citoyenneté) សិទ្ធិពលរដ្ឋ (droits civiques) និងការអនុវត្តសេរីភាពសាធារណៈ

-សញ្ជាតិ របបអាពាហ៍ពិពាហ៍(régimes matrimoniaux) ការស្នងមរតក (successions) និងសន្ធានាន(libéralités)

-នីតិវិធីស្របតាមទំនៀមទំលាប់ និងតាមគោលការណ៍ជាមូលដ្ឋាននៃរដ្ឋធម្មនុញ្ញ

-ការការពារសេរីភាពសារព័ត៌មាន និងការទទួលបានព័ត៌មាន

-សមាហរណកម្មតម្លៃវប្បធម៌ជាតិ ។

សភាតំណាងអាច :

-ត្រូវបានស្នើចំពោះសេចក្ដីព្រាង ឬសេចក្ដីស្នើច្បាប់

-ត្រូវបានស្នើ ឬផ្ដើមដោយខ្លួនឯង ចំពោះបញ្ហាសំខាន់ៗរបស់ជាតិ

-ដើរតួជាមជ្ឈត្តករ(médiateur)

- ដាក់បញ្ហាជាមុន (questions préalables) ញត្តិព្យួរសេចក្ដីសម្រេច (motion préjudicielles)

យោបល់ទាំងនេះមិនចាប់បង្ខំឱ្យរដ្ឋសភាទទួលយកទេ (តែសមាជិករដ្ឋសភាអាចទទួលយក) ។

ខ-អំណាចត្រួតពិនិត្យ

សភាតំណាងអាចបង្កើតគណៈកម្មការស៊ើបអង្កេត ។

គ-ទំនាក់ទំនងជាមួយអំណាចនីតិប្រតិបត្តិ

ប្រធានាធិបតីទាក់ទងជាមួយសភាតំណាងដោយផ្ទាល់ ឬតាមសារដែលអានដោយប្រធានសភាតំណាង ។

សមាជិករដ្ឋាភិបាលអាចចូលរួមប្រជុំសភាតំណាង និងគណៈកម្មការនានា ហើយអាចនាំអ្នកជំនាញទៅជាមួយ ។

ច្បាប់ចម្លងគ្រប់សេចក្ដីព្រាងច្បាប់ និងសារនានារបស់ប្រធានាធិបតី ឬនាយករដ្ឋមន្ត្រី ត្រូវផ្ញើជូនសភាតំណាង ដោយរដ្ឋសភា ។

សភាតំណាងអាចស្នើសុំការពន្យល់ ឬការអត្ថាធិប្បាយលើគ្រប់សេចក្ដីព្រាងច្បាប់ ឬបញ្ហាទាំងអស់ ។

ឃ-ទំនាក់ទំនងជាមួយរដ្ឋសភា

ប្រធានរដ្ឋសភាទាក់ទងជាមួយសភាតំណាងដោយផ្ទាល់ ឬតាមសារដែលអានដោយសភាតំណាង ។

ប្រធានគណៈកម្មការនានារបស់រដ្ឋសភាអាចចូលរួមប្រជុំសភាតំណាង ឬគណៈកម្មការនានារបស់សភាតំណាង ។

ច្បាប់ចម្លងគ្រប់សេចក្តីស្នើច្បាប់ ដែលដាក់ជូនរដ្ឋសភាត្រូវជូនដំណឹងទៅសភាតំណាង ។

សភាតំណាងអាចស្នើសុំការពន្យល់ ឬការអត្ថាធិប្បាយលើសេចក្តីស្នើទាំងអស់ដែលដាក់ជូនរដ្ឋសភា ។

រដ្ឋសភាបញ្ជាក់ក្នុងអង្គសន្ទិសីទប្រធាន(conference des Présidents)នូវសេចក្តីព្រាង និងសេចក្តីស្នើច្បាប់ដែលត្រូវសុំយោបល់ ។

យោបល់ត្រូវធ្វើជារបាយការណ៍ដែលផ្ញើជូនគណៈកម្មការអចិន្ត្រៃយ៍រដ្ឋសភា ។

V-**បនប្បញ្ញត្តិដោយឡែក**

ក-ប្រធានាធិបតីអាចប្រកាសរំលាយរដ្ឋសភា ក្រោយពីបានពិគ្រោះយោបល់ជាមួយនាយករដ្ឋមន្ត្រី និងប្រធានសភាតំណាង ។

ខ-កាលណាស្ថាប័នជាតិរងការគំរាមកំហែងប្រធានាធិបតីចាត់វិធានការដែលកាលៈទេសៈតម្រូវក្រោយពីបានការសម្រេចពីក្រុមប្រឹក្សារដ្ឋមន្ត្រី និងក្រោយពីបានពិគ្រោះយោបល់ជាមួយប្រធានរដ្ឋសភា ប្រធានសភាតំណាង និងប្រធានតុលាការកំពូល ។

គ-ប្រធានសភាតំណាងជាឥស្សរជនទី៤របស់រដ្ឋ ។

<u>កំណត់ចំណាំ</u> : រដ្ឋសភាបានអនុម័តលុបចោលសភាបណ្តាស្រុក ដែលគណបក្សជំទាស់មានសម្លេងភាគច្រើនស្នើ នៅខែមីនា ឆ្នាំ២០០១ ។

I-**សមាសភាព** : ៦៧រូប

តំណាងដែនដី :

-ពាអាសនៈសម្រាប់ស្រុកនីមួយៗនៃស្រុកទាំង២១ (Zupanijas) ក្នុងប្រទេសត្រូវជា ៦ពារូប

-៥រូប តែងតាំងដោយប្រមុខរដ្ឋ ។

ប្រធានាធិបតីនៃសាធារណរដ្ឋ ក្រោយចប់អាណត្តិត្រូវជាសមាជិកអស់មួយជីវិតនៃសភាស្រុក (Zupanijas) លើកលែងតែសាមីខ្លួនប្រកាសបោះបង់ចោលមុខងារនេះ ។

II-**របបបោះឆ្នោត**

ប្រព័ន្ធ : សកល ដោយផ្ទាល់ សមាមាត្រ

បញ្ជីស្រុកដែលទទួលបានសម្លេងតិចជាង៥% ត្រូវផាត់ចេញពីការបែងចែកអាសនៈ ។

អាណត្តិ : ៤ឆ្នាំ

ការផ្លាស់ប្តូរចុងក្រោយ : ១៣ មេសា ឆ្នាំ១៩៩៧

អាយុ : ១៨ឆ្នាំ

II-**សម័យប្រជុំ**

ក-សម័យប្រជុំសាមញ្ញ

សភាបណ្តាស្រុកប្រជុំ២លើកក្នុង១ឆ្នាំ :

-លើកទី១ ពីថ្ងៃទី១៥ ខែមករាដល់ទី៣០ខែមិថុនា

-លើកទី២ ពីថ្ងៃទី១៥ ខែកញ្ញាដល់ទី១៥ខែធ្នូ ។

ខ-សម័យប្រជុំវិសាមញ្ញ

សភាបណ្តាស្រុកប្រជុំជាវិសាមញ្ញ តាមសំណើរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ រដ្ឋាភិបាល ឬពីសមាជិកភាគច្រើន ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្បញ្ញត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-ឥទ្ធិពលផ្ទួចផ្តើមធ្វើច្បាប់

សភាបណ្តាស្រុកមានសិទ្ធិផ្ទួចផ្តើមឥទ្ធិពលធ្វើច្បាប់ ដូចជាសមាជិក និងគណៈកម្មការនានារបស់រដ្ឋសភា និងរដ្ឋាភិបាល ។

២-សិទ្ធិវិសោធនកម្ម

សភាបណ្តាស្រុកមានសិទ្ធិធ្វើវិសោធនកម្មច្បាប់ ។

៣-នីតិវិធីធ្វើច្បាប់

ច្បាប់ត្រូវបានអនុម័តដោយរដ្ឋសភា ។

ក-នីតិវិធីធម្មតា

ក្នុងរយៈពេល១៥ថ្ងៃបន្ទាប់ពីការអនុម័តរបស់រដ្ឋសភា សភាបណ្តាស្រុកអាចបញ្ជូនសេចក្តីព្រាងច្បាប់ទៅរដ្ឋសភាវិញដើម្បីពិនិត្យជាលើកទី២ ដោយមានភ្ជាប់ទៅជាមួយនូវយោបល់របស់ខ្លួនដោយបញ្ជាក់ពីមូលហេតុផង ។ ក្នុងករណីនេះ រដ្ឋសភាអនុម័តច្បាប់តាមសម្លេងភាគច្រើននៃសមាជិករបស់ខ្លួន លើកលែងតែច្បាប់ណាដែលត្រូវយកតាមសម្លេងភាគច្រើនពីរភាគបី ។

ខ-បទប្បញ្ញត្តិដោយឡែក

ចំពោះច្បាប់កំណត់សិទ្ធិជាតិ សិទ្ធិ និងសេរីភាពរបស់មនុស្ស និងពលរដ្ឋ ដែលផ្តល់ដោយរដ្ឋធម្មនុញ្ញ របបបោះឆ្នោត ការរៀបចំការកិច្ច និងប្រភេទសកម្មភាពអង្គការរដ្ឋ ការរៀបចំការគ្រប់គ្រងដោយសេរី និងការគ្រប់គ្រងនៅមូលដ្ឋាន សភាបណ្តារដ្ឋផ្តល់យោបល់ជាមុនដល់រដ្ឋសភា ។

ខ-អំណាចត្រួតពិនិត្យ

១-សមាជិកសភាបណ្តាស្រុកមានសិទ្ធិដាក់សំណួរចំពោះរដ្ឋាភិបាលនិងរដ្ឋមន្ត្រី ។

២-សភាបណ្ណាស្រុកមានសិទ្ធិបង្កើតគណៈកម្មការស៊ើបអង្កេតលើរាល់បញ្ហាដែលទាក់ទងនឹងផលប្រយោជន៍សាធារណៈ ។

៣-ប្រធានាធិបតីនៃសាធារណរដ្ឋរាយការណ៍ជូនសភា១ដងក្នុងឆ្នាំ អំពីស្ថានភាពរបស់ប្រទេស ។

ត-អំណាចផ្តល់យោបល់

សភាបណ្ណាស្រុកមានសិទ្ធិពិភាក្សា និងផ្តល់យោបល់របស់ខ្លួនលើរាល់បញ្ហា ដែលជាសមត្ថកិច្ចរបស់រដ្ឋសភា ។

V-មនប្បញ្ញត្តិដោយឡែក

ក-ការរំលាយសភាបណ្ណាស្រុក

សភាបណ្ណាស្រុកអាចត្រូវរំលាយតាមការសម្រេចរបស់សមាជិកភាគច្រើន ។

ខ-ការសើរើរដ្ឋធមនុញ្ញ

រដ្ឋសភាត្រូវទទួលយោបល់របស់សភាបណ្ណារដ្ឋ មុននឹងសម្រេចដំណើរការសើរើ ។ យោបល់ជាមុនរបស់សភាបណ្ណាស្រុកតម្រូវឱ្យមានដែរ មុនការអនុម័តលើសេចក្តីព្រាងសើរើដោយរដ្ឋសភា ។

ត-សិទ្ធិសុំឱ្យធ្វើប្រជាមតិ

ឃ-ការរួមបញ្ចូលជាមួយរដ្ឋដ៏ទៃ

១-ការផ្តួចផ្តើមតំនិតស្នើនូវនីតិវិធីរួមបញ្ចូលក្រូអាស៊ីជាមួយរដ្ឋដ៏ទៃ អាចចេញពីសមាជិកជិកសភាយ៉ាងតិច១/៣ ។

ការសម្រេចជាមុនអំពីការរួមបញ្ចូល ត្រូវអនុម័តដោយសភា តាមសម្លេងភាគច្រើនពីរភាគបី(២/៣) នៃសមាជិកទាំងអស់ ។ សេចក្តីសម្រេចនេះត្រូវដាក់ធ្វើប្រជាមតិ ។

២-នីតិវិធីដែលនេះប្រើសម្រាប់ការបំបែក? (désassociation) លើកលែងតែករណីដែលសភាត្រូវសម្រេចបំបែក ដើម្បីការពារអធិបតេយ្យនៃសាធារណរដ្ឋ តាមសម្លេងភាគច្រើន ២/៣) នៃសមាជិកវត្តមាន អាស្រ័យលើសភាពការណ៍ពិសេស និងតាមសំណើពីសមាជិករបស់ខ្លួនចំនួន១/៣) ឬរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ឬរបស់រដ្ឋាភិបាល ។

ង-ការៈទេសៈពិសេស

១-ការប្រកាសសង្គ្រាម ក៏ដូចជាការកំណត់សន្តិភាពជាសិទ្ធិរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ តាមការសម្រេចជាមុនរបស់សភា ។

២-ការកំបិតសិទ្ធិ និងសេរីភាពខ្លះដែលរដ្ឋធម្មនុញ្ញធានាដោយសភា តាមសម្តេងភាគច្រើន ២៣នៃសមាជិកទាំងអស់ ក្នុងពេលសង្គ្រាម មហន្តរាយពីធម្មជាតិ ឬបើឯកភាពជាតិ និងឯកភាពជាតិត្រូវគំរាមកំហែងដោយផ្ទាល់ ។

បើសភាមិនអាចប្រជុំបាន សេចក្តីសម្រេចត្រូវធ្វើដោយប្រធានាធិបតីនៃសាធារណរដ្ឋ ។

ច-ការទទួលខុសត្រូវរបស់ធនាគារជាតិនៅមុខសភា

ឆ-ការការពារចៅក្រម

ចៅក្រម ដែលបញ្ចប់មុខងារ មានសិទ្ធិស្នើសុំឱ្យសភាបណ្តាស្រុកការពារ ។

ជ-ការតែងតាំង

១-សភាបណ្តារដ្ឋតែងតាំងប្រធាននិងសមាជិកនៃក្រុមប្រឹក្សានៃអង្គចៅក្រម ។

២-រដ្ឋសភាតែងតាំងចៅក្រមតុលាការធម្មនុញ្ញតាមសំណើរបស់សភាបណ្តាស្រុក ។

ឃ្យ៉ហ្ស៊ីស្ថាន សភាតំណាងពលរដ្ឋ

KIRGHIZSTAN L'ASSEMBLEE DES REPRESENTANTS DU PEUPLE

ដោយសារប្រជាមតិថ្ងៃទី២ ខែកុម្ភ: ឆ្នាំ២០០៣ រដ្ឋធម្មនុញ្ញត្រូវបានសើរើ ដើម្បីចែងជាពិសេសអំពីការលុបសភាតំណាងពលរដ្ឋដែលជាតំណាងផលប្រយោជន៍ដែនដី ។

កំណែទម្រង់នេះបានចូលជាធរមាននៅពេលសភាផ្ទាស់ប្តូរថ្មី ។ ការបោះឆ្នោតសភាថ្ងៃទី ២៧ ខែកុម្ភ:ឆ្នាំ ២០០៥បានកំណត់អំពីការការបង្កើតរបបសភាតែមួយ : ក្រុមប្រឹក្សាជាន់ខ្ពស់ (conseil suprême)ដែលមានសមាជិក៧៥រូប ជំនួសសភាតំណាងពលរដ្ឋ(៤៥អាសន:) និងរដ្ឋសភា(៦០អាសន:) ។

I-សមាសភាព

សភាតំណាងពលរដ្ឋមានសមាជិក៤៥រូប ជ្រើសរើសដោយការបោះឆ្នោតដោយផ្ទាល់ ។

II-របបបោះឆ្នោត

ប្រព័ន្ធ : សម្ងេងភាគច្រើន ឯកត្តនាម ២ជុំ

អាណត្តិ :៥ឆ្នាំ

ការផ្ទាស់ប្តូរចុងក្រោយ:២០ កម្ភ: ២០០០(ជុំទី១) ៥មីនា ២០០០(ជុំទី២)

ការផ្ទាស់ប្តូរថ្មីរបស់សភាតំណាងពលរដ្ឋប្រព្រឹត្តទៅជាបន្តបន្ទាប់នឹងរដ្ឋសភា ។

លក្ខខណ្ឌ: មានសញ្ជាតិឃ្យ៉ហ្ស៊ី អាយុលើសពី២៥ឆ្នាំ និងស្នាក់នៅ៥ឆ្នាំយ៉ាងតិចនៅ ឃ្យ៉ហ្ស៊ីស្ថាន ក្នុងនោះពាឆ្នាំនៅមណ្ឌលឈរឈ្មោះ ។

III-សម័យប្រជុំ

ក-សម័យប្រជុំសាមញ្ញ

សភាតំណាងពលរដ្ឋប្រជុំយ៉ាងតិចពីរលើកក្នុង១ឆ្នាំ ។

ខ-សម័យប្រជុំវិសាមញ្ញ

សភាតំណាងពលរដ្ឋប្រជុំវិសាមញ្ញ ក្នុងករណីធ្វើសម្បថរបស់ចៅក្រមតុលាការធម្មនុញ្ញ

និងសារៈរបស់ប្រមុខរដ្ឋជូនប្រជាជាតិ ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-គំនិតផ្តួចផ្តើមធ្វើច្បាប់

សមាជិកសភាតំណាងពលរដ្ឋអាចដាក់សេចក្តីស្នើច្បាប់ថវិកា និងការរៀបចំដែនដី និងរដ្ឋបាល ។

២-សិទ្ធិវិសោធនកម្ម : ត្រាន

៣-នីតិវិធីធ្វើច្បាប់

ក-នីតិវិធីធម្មតា

ច្បាប់ដែលអនុម័តដោយរដ្ឋសភាត្រូវតែមានការយល់ព្រមពីសភាតំណាងពលរដ្ឋ តាមសម្លេងភាគភាគច្រើន ។ ក្នុងករណីដែលសភាតំណាងពលរដ្ឋបដិសេធ សេចក្តីព្រាងច្បាប់អាចត្រូវអនុម័តជាលើកចុងក្រោយនៅការអានលើកទី២ដោយរដ្ឋសភា តាមសម្លេងភាគច្រើន២/៣ ។

ខ-ច្បាប់ដែលស្ថិតក្នុងសមត្ថកិច្ចពិសេសរបស់សភាតំណាងពលរដ្ឋ

ច្បាប់ដែលស្ថិតក្នុងសមត្ថកិច្ចពិសេសរបស់សភាតំណាងពលរដ្ឋ(ថវិកា ការរៀបចំរដ្ឋបាល និងដែនដី) ត្រូវមានការយល់ព្រមពីរដ្ឋសភា តាមសម្លេងភាគច្រើន (majorité simple) ។ ក្នុងករណីបដិសេធត្រូវអនុម័តជាលើកចុងក្រោយនៅការអានលើកទី២ ប៉ុន្តែតាមសម្លេងភាគច្រើន ២/៣ ។

ខ-អំណាចត្រួតពិនិត្យ

១-ការអនុម័តញត្តិបន្ទោស(motion de censure)

សភាតំណាងពលរដ្ឋអាចអនុម័តញត្តិបន្ទោសនាយករដ្ឋមន្ត្រី ។

២-ការប្រគល់តំណែង(investiture) នាយករដ្ឋមន្ត្រី

សភាតំណាងពលរដ្ឋត្រូវផ្តល់ការយល់ព្រមលើបេក្ខភាពនាយករដ្ឋមន្ត្រី ។

៣-វិស័យថវិកា

សភាតំណាងពលរដ្ឋបង្ហាញរបាយការណ៍អំពីការអនុវត្តថវិកាជាតិ ។

៤-សភាតំណាងពលរដ្ឋស្តាប់របាយការណ៍ប្រចាំឆ្នាំរបស់នាយករដ្ឋមន្ត្រី អគ្គរដ្ឋអាជ្ញា និងប្រធានធនាគារជាតិ ។

ឃ-ទំនាក់ទំនងជាមួយប្រធានាធិបតីនៃសាធារណរដ្ឋ

១-សភាតំណាងពលរដ្ឋមានសមត្ថកិច្ចកំណត់ពេលចោះឆ្នោតប្រធានាធិបតី ។

២-សភាតំណាងពលរដ្ឋត្រូវបានផ្តល់អំណាចទាក់ទងនឹងការលាលែងរបស់ប្រធានាធិបតី នៃសាធារណរដ្ឋ ។

ការលាលែងរបស់ប្រធានាធិបតីនៃសាធារណរដ្ឋត្រូវបញ្ជូនទៅសភាទាំងពីរប្រជុំជារួម ។

ប្រធានាធិបតីអាចត្រូវដកហូតតំណែងដោយសភាតំណាងពលរដ្ឋ តាមសម្លេងភាគច្រើនពីរភាគបី ក្នុងរយៈពេល២ខែបន្ទាប់ពីរដ្ឋសភាស្នើសុំ(រដ្ឋសភាខ្លួនឯងអនុម័ត តាមសម្លេងភាគច្រើន ២ពន្ធវាស្ថិតក្នុងដកហូតតំណែង ដែលស្នើឡើងដោយគណៈកម្មការពិសេសដែលខ្លួនបានបង្កើតឡើង) ។

V-បណ្ណាល្ងាស្ថិតនៅឯក

ក-ការកែប្រែរដ្ឋធម្មនុញ្ញ

សភាតំណាងពលរដ្ឋបញ្ជូលវិសោធនកម្មទៅក្នុងរដ្ឋធម្មនុញ្ញ ។ ជាបន្ទាប់ទៅវិសោធនកម្មទាំងនេះត្រូវបានអនុម័តដោយសភានីមួយៗតាមសម្លេងភាគច្រើន២ភាគ ។

អាចមានលទ្ធភាពដាក់ធ្វើប្រជាមតិ ហើយដែលធ្លាប់បានធ្វើកាលពីខែតុលា ឆ្នាំ១៩៩៨ ។

ខ-ការបកស្រាយរដ្ឋធម្មនុញ្ញ

សភាតំណាងពលរដ្ឋមានសមត្ថកិច្ចបកស្រាយជាផ្លូវការនូវរដ្ឋធម្មនុញ្ញ ។

គ-ការងារដែនដី

សភាតំណាងពលរដ្ឋមានសមត្ថកិច្ច :

-កែប្រែព្រំដែនសាធារណរដ្ឋ

-សម្រេចអំពីការរៀបចំដែនដី និងរដ្ឋបាលនៃសាធារណរដ្ឋ ។

ឃ-អំណាចតែងតាំង

សភាតំណាងពលរដ្ឋមានសមត្ថកិច្ចក្នុង :

-ការអនុម័តបេក្ខភាពអគ្គរដ្ឋអាជ្ញា(procureur général)

-ការអនុម័តបេក្ខភាពប្រធានធនាគារជាតិ

-ការជ្រើសរើស និងដកហូតតំណែងប្រធាន ឬមន្ត្រីជាន់ខ្ពស់នៃតុលាការធម្មនុញ្ញ

-ការជ្រើសរើស និងដកហូតតំណែងប្រធាន ឬមន្ត្រីជាន់ខ្ពស់នៃតុលាការកំពូល និងតុលាការអាជ្ញាកណ្តាលជាន់ខ្ពស់(cour suprême d'abitrage)

-ការជ្រើសរើសសមាជិកគណៈកម្មការកណ្តាលនៃការបោះឆ្នោត និងប្រជាមតិចំនួនមួយភាគបី

-ការដកហូតតំណែងចៅក្រម

-ជ្រើសរើសសមាជិកតុលាការគណនីចំនួនមួយភាគបី ។

ម៉ាឡាវី **ព្រឹទ្ធសភា**

MALAWI LE SENAT

សភាម៉ាឡាវីបានអនុម័ត នៅថ្ងៃ១១ ខែមករា ឆ្នាំ២០០១ លុបព្រឹទ្ធសភាជំទាស់នឹងយោបល់របស់ប្រធានប្រពៃណី និងវិសយ័របស់ប្រធានប្រពៃណីនិងវិស័យខ្លះនៃសង្គម(ព្រះវិហារ អង្គការ សហជីព និងអង្គការ ការពារសិទ្ធិមនុស្ស) ។

សភានេះមានចែងនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៤ ប៉ុន្តែមិនដែលបានកើតឡើងទេ ។

I-សមាសភាពព្រឹទ្ធសភា

ចំនួនសមាជិក :៨០រូប :

-៤៨រូប ជ្រើសរើសក្នុងស្រុក(districts)

-៣២រូប ជ្រើសរើសដោយអ្នកមានមុខរបរដូចគ្នា(pairs)

II-របបឆោះឆ្នោត

ក-ប្រព័ន្ធ

១-ក្នុងស្រុកនីមួយៗនៃស្រុកទាំង២៤

ក-សមាជិក១រូប ជ្រើសរើសជាសម្ងាត់ក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីការបោះឆ្នោតមូលដ្ឋាន(élections locales) ក្នុងចំណោមជនចុះឈ្មោះលើបញ្ជីបោះឆ្នោតស្រុក ដោយក្រុមប្រឹក្សាស្រុក

ខ-សមាជិក១រូប ជ្រើសរើសជាសម្ងាត់ ក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីការបោះឆ្នោតមូលដ្ឋាន ក្នុងចំណោមប្រធាន(chefs) ចុះឈ្មោះលើបញ្ជីបោះឆ្នោតស្រុក ដោយអង្គបោះឆ្នោតដែលមានប្រធានទាំងអស់នៅស្រុក(tous les chefs de district) ។

២- ៣២រូប ជ្រើសរើសតាមសម្លេងភាគច្រើន២/៣ ដោយសមាជិកព្រឹទ្ធសភាទាំងអស់លើមូលដ្ឋាននៃសំណើរបស់គណៈកម្មការតែងតាំង(commission de Nomination) ដោយត្រូវមានតំណាងនៃក្រុមផ្សេងៗ(នារី ជនពិការ សុខាភិបាល អប់រំ កសិកម្ម ពាណិជ្ជកម្ម សហជីព) តំណាងសង្គម(ចំពោះសមត្ថភាពខាងសង្គម វប្បធម៌ ឬការអភិវឌ្ឍបច្ចេកវិទ្យាជាតិ) តំណាងតំបន់សំខាន់ៗរបស់រដ្ឋ ។

គណៈកម្មការតែងតាំងរបស់ព្រឹទ្ធសភាត្រូវបង្កើតក្នុងរយៈពេល៤៥ថ្ងៃ បន្ទាប់ពីការបោះឆ្នោតមូលដ្ឋាន ។ គណៈកម្មការនេះមានប្រធានរដ្ឋសភា ombudsman សមាជិកព្រឹទ្ធសភាពីរូបជ្រើសតាំងក្នុងស្រុក តែងតាំងដោយរដ្ឋសភា ។

៩-អាយុអប្បបរមា : ៣៥ ឆ្នាំ ។

កិច្ចព្រមព្រៀងនយោបាយត្រូវបានចុះហត្ថលេខានៅ ខែវិច្ឆិកា ឆ្នាំ ២០០៦ រវាងពួកម៉ៅនិយម(les maoïstes)និងគណបក្សនយោបាយចំនួន៧ ។ សមាសភាពនៃសភាពីរថ្នាក់ ជ្រើសរើសនៅឆ្នាំ១៩៩៨ និងព្យួរដោយព្រះមហាក្សត្រ នៅខែមេសា ។ កិច្ចព្រមព្រៀងនេះបានបើកផ្លូវឱ្យចេញពីសង្គ្រាមស៊ីវិលដែលចាប់ផ្តើមតាំងពីឆ្នាំ១៩៩៦និងបណ្តាលឱ្យស្លាប់ជិត១៣.000នាក់ ។

កិច្ចព្រមព្រៀងនេះបានចែងអំពី:

-ការរៀបចំការបោះឆ្នោតដើម្បីបង្កើតសភាធម្មនុញ្ញ យ៉ាងយូរបំផុតនៅពាក់កណ្តាលខែមិថុនា ឆ្នាំ២០០៧

-ការបង្កើតស្ថាប័នបណ្តោះអាសន្នដើម្បីគ្រប់គ្រងក្នុងអន្តរកាល ។

ក្រោយការចរចាដ៏លំបាក កិច្ចព្រមព្រៀងបានចេញរួចនៅខែធ្នូ ឆ្នាំ២០០៦ លើការតាក់តែងសេចក្តីព្រាងរដ្ឋធម្មនុញ្ញបណ្តោះអាសន្ន ។ អត្ថបទមានបញ្ញត្តិ២យ៉ាងសំខាន់ :ការបង្កើតសភាបណ្តោះអាសន្នដែលក្នុងនោះមានពួកម៉ៅនិយម និងការតែងតាំងដោយសភាបណ្តោះអាសន្ននេះនូវរដ្ឋាភិបាលបណ្តោះអាសន្ន ឱ្យទទួលបន្ទុករៀបចំការបោះឆ្នោតធម្មនុញ្ញ នៅខែមិថុនា ឆ្នាំ២០០៧ ។

នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៧ សភាទាំងពីរដែលជ្រើសតាំងនៅឆ្នាំ១៩៩៨ បានអនុម័តរដ្ឋធម្មនុញ្ញបណ្តោះអាសន្ន ហើយបន្ទាប់មកត្រូវលាយដោយឯកឯង ។

សភាពីរថ្នាក់របស់ណេប៉ាល់លែងមានទៀតហើយ : បច្ចុប្បន្ន ត្រូវជំនួសដោយសភាតែមួយជាបណ្តោះអាសន្ន ក្នុងនោះពួកម៉ៅនិយមកាន់កាប់៨៣អាសនៈ ក្នុងចំណោម៣៣០អាសនៈ ។

តំណាក់កាលក្រោយមកទៀតគឺការតែងតាំងរដ្ឋាភិបាលបណ្តោះអាសន្ន ។

<u>កំណត់ចំណាំ</u> : រដ្ឋធម្មនុញ្ញថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៩០បានដាក់បញ្ចូលនូវរបបរាជានិយមអាស្រ័យសភាពីរថ្នាក់ (monarchie parlementaire bicamérale) ដែលបន្តពីរបបផ្តាច់ការនៃ Panchayat ។

តាមន័យនៃរដ្ឋធម្មនុញ្ញនេះ សភាមានព្រះមហាក្សត្រ និងសភាទាំងពីរ : រដ្ឋសភា និងក្រុមប្រឹក្សាជាតិ ។

I-សមាសភាព

ក្រុមប្រឹក្សាជាតិមានសមាជិក៦០រូប :

-១០រូប តែងតាំងដោយព្រះមហាក្សត្រ ក្នុងចំណោមឥស្សរជនដែលមានឈ្មោះល្បីល្បាញដែលមានគុណបំណាច់ច្រើនក្នុងវិស័យនានានៃសង្គមជាតិ

-ពាក្យរូប ជ្រើសតាំង(នារីពារូប យ៉ាងតិច)ដោយរដ្ឋសភា

-១៥រូប ដោយការបោះឆ្នោតមិនផ្ទាល់ ។

II-របបបោះឆ្នោត

ប្រព័ន្ធ : ប្រព័ន្ធតំណាងសមាមាត្រ និងឆ្នោតតែមួយ អាចផ្ទាស់ប្តូរបាន (système de représentation proportionnelle et de vote unique transferable) ចំពោះសមាជិកពាក្យរូបដែលជ្រើសតាំងដោយរដ្ឋសភា និងសមាជិក១៥រូបដែលជ្រើសតាំង ក្នុងតំបន់ចំនួន៥(ពារូប ក្នុង ១តំបន់)ក្នុងកំរិតភូមិ ទីក្រុង និងស្រុក ។

អាណត្តិ : ៦ឆ្នាំ ផ្ទាស់ប្តូរ១/ពារៀងរាល់២ឆ្នាំ (renouvelable par tiers tous les deux ans) ។

ការផ្ទាស់ប្តូរចុងក្រោយ : ២៧ មិថុនា ឆ្នាំ ២០០១ ។

លក្ខខណ្ឌ : អាយុ ពាក្យ ឆ្នាំ ពលរដ្ឋណេបាំល់ ។

វិសមិតភាព : អ្នកប្រកបមុខរបររកចំណេញ សមាជិករដ្ឋសភា ។

III-សម័យប្រជុំ

ព្រះមហាក្សត្រកោះសភាជាសម័យប្រជុំក្នុងខែបន្ទាប់ពីការបោះឆ្នោតរដ្ឋសភា ។

ព្រះមហាក្សត្រកោះសភាជាសម័យប្រជុំផ្សេងទៀត ។

ចន្លោះពីសម័យប្រជុំមួយទៅសម័យប្រជុំមួយទៀតមិនអាចលើសពី៦ខែទេ ។

ព្រះមហាក្សត្រអាចពន្យារសម័យប្រជុំសភាណាមួយបាន ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

១-ព័ន្ធិតផ្តួចផ្តើមធ្វើច្បាប់

ក្រុមប្រឹក្សាជាតិមានសិទ្ធិផ្តួចផ្តើមព័ន្ធិតធ្វើច្បាប់ ។

២-សិទ្ធិវិសោធនកម្ម

ក្រុមប្រឹក្សាជាតិមានសិទ្ធិធ្វើវិសោធនកម្មច្បាប់ ។

៣-និតិវិធីធ្វើច្បាប់

ក-និតិវិធីពិនិត្យ

សេចក្តីព្រាងច្បាប់អាចដាក់ជូនសភាណាមួយក៏បាន លើកលែងតែច្បាប់ហិរញ្ញវត្ថុ ដែលត្រូវតែដាក់នៅការិយាល័យរដ្ឋសភា ។

សេចក្តីព្រាងច្បាប់ដែលបានពិនិត្យនៅសភាណាមួយ ត្រូវតែបញ្ជូនជាប្រញាប់តាមដែលអាចធ្វើបានទៅសភាមួយទៀត ។ បើច្បាប់ត្រូវបានអនុម័ត ច្បាប់នោះត្រូវបញ្ជូនទៅព្រះមហាក្សត្រដើម្បីផ្តល់ការយល់ព្រម ។

ក្រោយពីការពិភាក្សានៅរដ្ឋសភា សេចក្តីព្រាងស្តីពីបញ្ញត្តិហិរញ្ញវត្ថុត្រូវតែត្រូវបញ្ជូនទៅក្រុមប្រឹក្សាជាតិ ដែលត្រូវបញ្ជូនត្រឡប់ទៅរដ្ឋសភាវិញ ក្នុងរយៈពេល១៥ថ្ងៃដោយមានអនុសាសន៍ជាយថាហេតុ ។ បើរដ្ឋសភាយល់ព្រមលើអនុសាសន៍ សេចក្តីព្រាងត្រូវបញ្ជូនទៅព្រះមហាក្សត្រដើម្បីផ្តល់ការយល់ព្រម ។

បើក្រុមប្រឹក្សាជាតិមិនបញ្ជូនអត្ថបទត្រឡប់ទៅវិញក្នុងរយៈពេល១៥ថ្ងៃ រដ្ឋសភាអាចបញ្ជូនសេចក្តីព្រាងទៅព្រះមហាក្សត្រ ។

សេចក្តីព្រាងច្បាប់ទាំងអស់ លើកលែងតែបញ្ញត្តិស្តីពីហិរញ្ញវត្ថុ ត្រូវតែបញ្ជូនត្រឡប់ក្រោយការអនុម័តលើអនុសាសន៍ ក្នុងរយៈពេល២ខែ បន្ទាប់ពីពេលទទួល ។

បើក្រុមប្រឹក្សាជាតិមិនបញ្ជូនត្រឡប់វិញ រដ្ឋសភាអាចបញ្ជូនទៅព្រះមហាក្សត្រ តាមសម្លេងភាគច្រើននៃសមាជិកវត្តមាន ។

បើសេចក្តីព្រាងច្បាប់ត្រូវបដិសេធ ឬវិសោធនកម្មដោយសភាមួយទៀត សេចក្តីព្រាងត្រូវបញ្ជូនទៅសភាដើម(assemblée originaire) ។

បើរដ្ឋសភាអនុម័តអត្ថបទដែលបដិសេធ ឬវិសោធនកម្មដោយក្រុមប្រឹក្សាជាតិ រដ្ឋសភាអាចបញ្ជូនអត្ថបទទៅព្រះមហាក្សត្រ តាមសម្លេងភាគច្រើននៃសមាជិកវត្តមាន ។

សេចក្តីព្រាងច្បាប់ដែលវិសោធនកម្មត្រូវបានលើកឡើង និងត្រូវបានបញ្ជូនទៅក្រុមប្រឹក្សាជាតិដោយរដ្ឋសភា ត្រូវបានបញ្ជូនទៅព្រះមហាក្សត្រដើម្បីផ្តល់ការយល់ព្រមបើក្រុមប្រឹក្សាជាតិដាក់នូវសេចក្តីសម្រេចចិត្ត ដើម្បីអនុម័តអត្ថបទដែលបានវិសោធនកម្មនោះ ។ បើអត្ថបទមិនត្រូវបានអនុម័ត សភាទាំងពីរត្រូវប្រជុំរួម ។ ក្នុងករណីយល់ព្រម អត្ថបទត្រូវបញ្ជូនទៅព្រះមហាក្សត្រ ។

សេចក្តីព្រាងច្បាប់ដូចខាងក្រោមត្រូវបញ្ជូនទៅគណៈកម្មការចំរុះរបស់សភាទាំងពីរ :

-សេចក្តីព្រាងច្បាប់ដែលអនុម័តដោយក្រុមប្រឹក្សាជាតិ លើយត្រូវបដិសេធដោយរដ្ឋសភា ឬ

-សេចក្តីព្រាងច្បាប់ដែលត្រូវបានបញ្ជូនត្រឡប់ដោយក្រុមប្រឹក្សាជាតិ វិសោធនកម្មដោយរដ្ឋសភា ប៉ុន្តែត្រូវក្រុមប្រឹក្សាជាតិបដិសេធវិសោធនកម្ម ។

បើគណៈកម្មការចំរុះអនុម័តអត្ថបទ សភាដើមត្រូវបញ្ជូនអត្ថបទទៅព្រះមហាក្សត្រ ។

សេចក្តីព្រាងច្បាប់ ដែលការពិភាក្សាមិនទាន់ចប់នៅដំណាច់សម័យប្រជុំ ត្រូវបន្តការពិភាក្សានៅសម័យប្រជុំបន្ទាប់

ក្នុងករណីរំលាយរដ្ឋសភា ឬបើត្រូវបញ្ចប់នីតិកាល សេចក្តីព្រាងត្រូវទុកជាមោឃៈ ។

សេចក្តីស្នើច្បាប់អាចត្រូចដកវិញដោយម្ចាស់សេចក្តីស្នើ ដោយមានការយល់ព្រមពីសភា ។

ខ-សេចក្តីស្នើសុំឱ្យពិភាក្សាជាថ្មី

លើកលែងតែចំពោះសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ បើព្រះមហាក្សត្រយល់ថាការពិភាក្សាគួរតែបន្ត ព្រះអង្គបញ្ជូនអត្ថបទត្រឡប់ទៅសភាដើម ដោយភ្ជាប់ជាមួយនូវរាជសារ ក្នុងរយៈពេលជាអតិបរមា១ខែ ។

ក្នុងករណីនេះ គណៈកម្មការរួមនៃសភាទាំងពីរត្រូវរួមប្រជុំ ហើយព្រះមហាក្សត្រមានរយៈពេល៣០ថ្ងៃ ដើម្បីផ្តល់ការយល់ព្រម ។

ค-បញ្ញត្តិ(ordonnances)

បើយល់ថាចាំបាច់ ព្រះមហាក្សត្រអាចប្រកាសឱ្យប្រើបញ្ញត្តិ នៅក្រៅសម័យប្រជុំ ។ បញ្ញត្តិទាំងនេះមានកម្លាំងជាច្បាប់ ។ បញ្ញត្តិទាំងនេះត្រូវដាក់ជូនសភាទាំងពីរនាសម័យប្រជុំបន្ទាប់ ។ បើពុំដូច្នេះទេ បញ្ញត្តិទាំងនេះត្រូវអស់តម្លៃ ក្នុងរយៈពេល៦ខែបន្ទាប់ពីពេលប្រកាសឱ្យប្រើ ឬ៦០ថ្ងៃក្រោយចាប់ផ្តើមសម័យប្រជុំ ។

ខ-អំណាចត្រួតពិនិត្យ

១-ចំណាយដែលជាបន្ទុកមូលនីធិសម្រាប់ត្រួសារភាជវង្ស សភា និងអង្គការនានាត្រូវអនុម័តរៀងរាល់ឆ្នាំដោយសភា ។

២-អនុសញ្ញានានាត្រូវតែផ្តល់សច្ចាប័ន តាមសម្លេង២ភាគនៃសមាជិកវត្តមានរបស់សភាទាំងពីរដែលប្រជុំជាសមាជ ។

គ-ទំនាក់ទំនងជាមួយព្រះមហាក្សត្រ

ព្រះមហាក្សត្រអាចថ្លែងទៅកាន់សភាណាមួយ ឬសភាទាំងពីរ(ប្រជុំរួម) និងអាចកោះប្រជុំសមាជិកសភាសភាក្នុងគោលបំណងនេះ ។

ព្រះមហាក្សត្រថ្លែងសុន្ទរកថានៅសម័យប្រជុំលើកទី១ បន្ទាប់ពីការបោះឆ្នោតរដ្ឋសភា និងនៅពេលប្រជុំរួមនៃសភាទាំងពីរនៅពេលចាប់ផ្តើមសម័យប្រជុំប្រចាំឆ្នាំ ។

ព្រះមហាក្សត្រអាចផ្ញើព្រះរាជសារទៅសភាណាមួយ(ឬទាំងពីរ)ដែលត្រូវថ្វាយយោបល់ទៅវិញ ។ ពុំមានការពិភាក្សាណាមួយអាចធ្វើបានលើត្រួសារភាជវង្សឡើយ ។

ឃ-ក្រុមប្រឹក្សាជាតិអាចត្រូវរំលាយ ។

V -បទឧបសម្ព្ធន្ធ្ងន់ដោយឯកត

ប្រធានក្រុមប្រឹក្សាជាតិ:

-ត្រូវជ្រើសតាំងដោយសមាជិកទាំងអស់នៃក្រុមប្រឹក្សា សម្រាប់រយៈពេល៦ឆ្នាំ

-ជាឥស្សរជនទី៥របស់រដ្ឋ

-ជាតំណាងរបស់ក្រុមប្រឹក្សាជាតិនៅក្នុងអង្គការអំណាចសាធារណៈ ជាសមាជិកពេញច្បាប់នៃស្ថាប័នធម្មនុញ្ញខ្លះដទៃពីសភា

-ជាតំណាងក្រុមប្រឹក្សាជាតិក្នុងអង្គការអន្តរជាតិនានា

-ចូលរួមអនុម័តតែក្នុងករណីបែកសម្លេងជាពីរស្មើ ---

-និងចូលរួមក្នុងនីតិវិធីត្រួតពិនិត្យរបស់សភា

-ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។

ហុលឡង់ សភាទី១នៃសភាជាតិ

PAYS-BAS LA PREMIERE CHAMBRE DES ETATS GENERAUX

I-សមាសភាព

សភាទី១មានសមាជិក៧៥រូប ជ្រើសរើសដោយសមាជិកក្រុមប្រឹក្សាខេត្ត ។

II-របបបោះឆ្នោត

សមាជិកព្រឹទ្ធសភាត្រូវជ្រើសដោយការបោះឆ្នោតដោយប្រយោលឬមិនផ្ទាល់ (indirect) តាមប្រព័ន្ធសមាមាត្រ ។ មណ្ឌលបោះឆ្នោតជាក្រុមប្រឹក្សាខេត្តទាំង១២ ។ អង្គបោះឆ្នោតមានសមាសភាពជាសមាជិកក្រុមប្រឹក្សាខេត្ត ។

ការបោះឆ្នោតជ្រើសរើសសមាជិកសភាទី១ប្រព្រឹត្តទៅក្នុងរយៈពេលពាខែ បន្ទាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត ។

អាណត្តិ : ៤ឆ្នាំ

សភាទី១(ក៏ដូចជាសភាទី២) អាចរំលាយដោយព្រះរាជក្រឹត្យ(décret royal) ។

ការផ្លាស់ប្តូរចុងក្រោយ : ២៩ ឧសភា ២០០៧ ។

អាចឈរឈ្មោះ : មានឈ្មោះបោះឆ្នោត អាយុយ៉ាងតិច១៨ឆ្នាំ មានសញ្ជាតិនៀទ្យង់ (néerlandaise) ។

សភាទី១ កាត់សេចក្តីលើការបោះឆ្នោតជ្រើសរើសសមាជិករបស់ខ្លួន ។

មិនមានជនណាអាចជាសមាជិករដ្ឋសភាផង ជាសមាជិកសភាទី១ផងបានទេ ។

III-សម័យប្រជុំ

សភាទី១មាន១សម័យប្រជុំក្នុង១ឆ្នាំ ដែលបើកនៅថ្ងៃអង្គារ ទី៣ ខែកញ្ញា ជាថ្ងៃថ្ងៃងសាររបស់ព្រះមហាក្សត្រ(le Jour du Discours du Trône) ។

IV-ទំនាក់ទំនងជាមួយរដ្ឋសភានិងអំណាចនីតិប្រតិបត្តិ

សភាទី១មានអំណាចនីតិប្បញ្ញត្តិ និងអំណាចត្រួតពិនិត្យមានកំរិត ។

ក-អំណាចនីតិប្បញ្ញត្តិ

១-ព័ន្ធិតផ្ទួចផ្តើមធ្វើច្បាប់

សភាទី១មិនមានសិទ្ធិផ្ទួចផ្តើមព័ន្ធិតធ្វើច្បាប់ទេ ។ សិទ្ធិនេះជារបស់សភាទី២ (រដ្ឋសភា) និងរដ្ឋាភិបាល ។

២-សិទ្ធិវិសោធនកម្ម

សភាទី១មិនអាចធ្វើវិសោធនកម្មអត្ថបទបានឡើយ ។ សភាទី១បានត្រឹមតែផ្តល់ការយល់ព្រម ឬបដិសេធអត្ថបទទាំងមូល ។

៣-នីតិវិធីធ្វើច្បាប់

សេចក្តីព្រាងច្បាប់របស់រដ្ឋាភិបាលត្រូវដាក់នៅសភាទី២(រដ្ឋសភា)ដូចជាសេចក្តីស្នើរបស់សមាជិករដ្ឋសភា ។ ក្រោយពេលដែលសភាទី២បានអនុម័តរួច អត្ថបទត្រូវបញ្ជូនទៅសភាទី១ ដែលត្រូវអនុម័តនាពេលប្រជុំពេញអង្គ ក្រោយពេលដែលគណៈកម្មការជំនាញពិនិត្យរួចជាមុន ។

សភាទី១អាចផ្តល់ការយល់ព្រម ឬបដិសេធអត្ថបទទាំងមូល ដោយមិនអាចធ្វើវិសោធនកម្មបានឡើយ ។ បើយល់ព្រមទាំងស្រុង អត្ថបទត្រូវអនុម័តជាស្ថាពរ ។ បើមិនដូច្នេះទេ អត្ថបទត្រូវបដិសេធជាស្ថាពរ(មិនមានក្នុងការជាក់ស្តែង ។

ខ-អំណាចត្រួតពិនិត្យ

១-នយោបាយក្នុងប្រទេស

រៀងរាល់ឆ្នាំ នៅថ្ងៃអង្គារទី៣ ខែកញ្ញា នយោបាយទូទៅរបស់រដ្ឋាភិបាល ត្រូវបង្ហាញដោយព្រះមហាក្សត្រ(ឬព្រះរាជតំណាង) ចំពោះសភាជាតិដែលប្រជុំរួមគ្នា ។

សមាជិកសភាទី១អាចដាក់សំណួរជាលាយលក្ខណ៍អក្សរចំពោះរដ្ឋាភិបាល ប៉ុន្តែមិនមានពេលសម្រាប់សំណួរផ្ទាល់មាត់ឡើយ ។

សភាទី១មានសិទ្ធិស៊ើបអង្កេត ដូចសភាទី២ និងសភាជាតិប្រជុំរួមជាសមាជ តាមរយៈគណៈកម្មការដែលបង្កើតឡើងក្នុងករណីជាក់លាក់នីមួយ១ ។ គណៈកម្មការនេះមានសិទ្ធិស្តាប់ជនដែលបានស្បថ និងតម្រូវឱ្យជននោះផ្តល់នូវព័តិមានដែលបានស្នើសុំ ។

សភាទី១មិនដែលបានប្រើសិទ្ធិបង្កើតគណៈកម្មការស៊ើបអង្កេតទេ ។

២-វិស័យអន្តរជាតិ

ការយល់ព្រមរបស់សភាជាការចាំបាច់សម្រាប់ការផ្តល់សច្ចាប័ន ឬបដិសេធកិច្ចព្រមព្រៀងលើកលែងតែមានការកំណត់របស់ច្បាប់ ។

បើកិច្ចព្រមព្រៀងណាមានបញ្ញត្តិផ្ទុយនឹងរដ្ឋធម្មនុញ្ញឬបង្ខំឱ្យធ្វើផ្ទុយ ការអនុម័តត្រូវយកតាមសម្លេងភាគច្រើនពីរភាគបី(២/៣) នៃសម្លេងដែលបានបោះ ។

V-បទប្បញ្ញត្តិដោយឡែក

ក-ការសើរើរដ្ឋធម្មនុញ្ញ

សេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ធម្មនុញ្ញធ្វើតាមនីតីវិធីធម្មតា នៅពេលទី១ ។

បើសភាទាំងពីរអនុម័តយល់ព្រម សភាទី២(រដ្ឋសភា) ត្រូវរលាយ ហើយត្រូវដំណើរការបោះឆ្នោតជាថ្មី ។ ក្រោយការបោះឆ្នោត សមាជិករដ្ឋសភាជាប់ឆ្នោតថ្មីនិងសមាជិកសភាទី១ត្រូវប្រជុំរួម ដើម្បីពិភាក្សាលើអត្ថបទដែលបានអនុម័តលើកទី១ ។

ការអនុម័តត្រូវយកតាមសម្លេង ភាគច្រើនពីរភាគបី(២/៣) នៃសម្លេងដែលបានបោះ ។

ខ-បទប្បញ្ញត្តិទាក់ទងនឹងព្រះមហាក្សត្រ

ព្រះមហាក្សត្រ ឬរាជានុសិទ្ធិដើម្បីរៀបអាពាហ៍ពិពាហ៍ត្រូវមានការអនុញ្ញាតដោយច្បាប់ដែលអនុម័តដោយសមាជសភាទាំងពីរ ។ ការបដិសេធជនណាម្នាក់ក្នុងការស្នងរាជ ត្រូវសម្រេចដោយច្បាប់ដែលត្រូវអនុម័តដោយសមាជសភាទាំងពីរ តាមសម្លេងភាគច្រើនពីរភាគបី(២/៣) នៃសម្លេងដែលបានបោះ ។

បើសិនជាប្រមើលមើលថាមិនមានអ្នកស្នងរាជ ច្បាប់មួយអាចតែងតាំងអ្នកស្នងនេះបាន ។ សេចក្តីព្រាងច្បាប់ត្រូវស្នើឡើងដោយព្រះមហាក្សត្រ ឬក្នុងព្រះបរមនាម ។

ក្រោយពេលដាក់ស្នើ សភាទាំងពីរត្រូវរំលាយ។ សភាថ្មីត្រូវប្រជុំរួមគ្នាពិភាក្សានិងអនុម័ត តាមសម្លេងភាគច្រើនពីរភាគបី(២/៣) នៃសម្លេងដែលបានបោះ។

បើពេលព្រះមហាក្សត្រចូលទីវង្គត ឬដាក់រាជ សភាទាំងពីរត្រូវរំលាយ ។ សភាថ្មីត្រូវប្រជុំរួមគ្នា ក្នុងរយៈពេល៤ខែបន្ទាប់ពីចូលទីវង្គត ឬដាក់រាជ ដើម្បីសម្រេចលើការតែងតាំងព្រះមហាក្សត្រ តាមសម្លេងភាគច្រើន២/៣នៃសម្លេងដែលបានបោះ។

អាណាព្យាបាលរបស់ព្រះមហាក្សត្រ (ឬភាជានុសិទ្ធិ) ជាអនីតិជនត្រូវរៀបចំដោយច្បាប់ ដែលអនុម័តដោយសមាជិកសភា។

អសមត្ថភាព (ឬការបញ្ចប់អសមត្ថភាព)របស់ព្រះមហាក្សត្រក្នុងការបំពេញមុខងារ ត្រូវប្រកាសដោយសមាជិកសភា ។ ដូចគ្នានេះដែរ ចំពោះការអាក់ខានបំពេញមុខការមួយរយៈពេល (ឬការចូលមកវិញ) របស់ព្រះមហាក្សត្រ។

គ-កាលៈទេសៈដោយឡែក

១-ស្ថានភាពសង្គ្រាម

ការប្រកាសសង្គ្រាម ឬបញ្ចប់សង្គ្រាម ត្រូវមានការយល់ព្រមជាមុនពីសមាជិកសភា លើកលែងតែក្នុងករណីដែលការពិគ្រោះមិនអាចធ្វើទៅបាន ដោយសារស្ថានភាពសង្គ្រាមមានពីមុនមកហើយ។

២-ស្ថានភាពពិសេស

ក្នុងគ្រប់រយៈពេលនៃស្ថានភាពពិសេស (ការអនុវត្តខុសពីបញ្ញត្តិខ្លះនៃរដ្ឋធម្មនុញ្ញ ដើម្បីការពារសន្តិសុខក្នុង ឬក្រៅប្រទេស) បើជាការចាំបាច់ សភាទាំងពីរត្រូវប្រជុំជាសមាជដើម្បីសម្រេចលើការងារនេះ។

រដ្ឋធម្មនុញ្ញថ្ងៃ១៤ ខែមេសា ឆ្នាំ១៩៩៦បានបង្កើតសភាពីរថ្នាក់ ។

ព្រឹទ្ធសភាតំណាងសម្ព័ន្ធភាពដែនដីវិមជ្ឈការ(collectivités territoriales décentralisées) ។ អង្គការវិមជ្ឈការមិនដែលត្រូវបានបង្កើតឡើងទេ ព្រឹទ្ធសភាក៏មិនដែលត្រូវបានបង្កើតឡើងដែរ

សេចក្តីព្រាងសៀវភៅរដ្ឋធម្មនុញ្ញបានលុបព្រឹទ្ធសភា។ សេចក្តីព្រាងត្រូវបានអនុម័ត នៅថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០០៤ ដោយរដ្ឋសភា និងដាក់ធ្វើប្រជាមតិនៅថ្ងៃទី៦ ខែ មិថុនា ឆ្នាំ២០០៥ (៦៧,៥0%) ។

I-សមាសភាព

សមាជិកព្រឹទ្ធសភាជ្រើសតាំង ។

-ចោះឆ្នោតសកល (universel) មិនផ្ទាល់ (indirect) ដោយអង្គចោះឆ្នោតដែលមានទីប្រឹក្សាតំបន់(conseillés régionaux) ខេត្ត(départementaux) និងក្រុង(municipaux) ។

-អាណត្តិ : ៦ឆ្នាំ ផ្លាស់ប្តូរមួយភាគបី(១/៣) រៀងរាល់២ឆ្នាំ(renouvelable par tiers tous les deux ans) ។ សមាជិក១/៣ ទី១ដែលត្រូវផ្លាស់ប្តូរធ្វើឡើងតាមការចាប់ឆ្នោត(tirage au sort) ។

-អាយុ : ៤0ឆ្នាំ

ច្បាប់អង្គការមួយនឹងកំណត់ប្រាក់បំណាច់ និងរបបដែលមិនអាចឈរឈ្មោះបាន និងវិសមិតភាព។ ច្បាប់នេះនឹងកំណត់ដែរនូវលក្ខខណ្ឌជ្រើសរើសសមាជិកសភាមកបំពេញវិញ្ញរហូតដល់ការផ្លាស់ប្តូរថ្មីខាងមុខ ក្នុងករណីមានអាសនៈនៅទំនេរ ។

II-សម័យប្រជុំ

ក-សម័យប្រជុំសាមញ្ញ

សភាប្រជុំដោយពេញច្បាប់ជាពីរសម័យប្រជុំធម្មតាក្នុងមួយឆ្នាំ ។ សម័យប្រជុំលើកទី១ ចាប់ផ្តើមនៅថ្ងៃទី៥ ខែមេសា លើកទី២ចាប់ផ្តើមនៅថ្ងៃទី៥ ខែតុលា។ បើថ្ងៃទី៥ ខែមេសា ឬ

ថ្ងៃទី៥ ខែតុលាជាថ្ងៃបុណ្យ ការបើកសម័យប្រជុំត្រូវប្រព្រឹត្តទៅនៅថ្ងៃធ្វើការទី១បន្ទាប់ ។

រយៈពេលនៃសម័យប្រជុំនីមួយ ៗមិនអាចលើសពី៥០ថ្ងៃទេ ។

ខ-សម័យប្រជុំវិសាមញ្ញ

សភាប្រជុំជាវិសាមញ្ញតាមសំណើរបស់នាយករដ្ឋមន្ត្រី ឬរបស់សមាជិកភាគច្រើននៃរដ្ឋសភា លើរបៀបវារៈមួយជាក់លាក់ ។ សម័យប្រជុំវិសាមញ្ញត្រូវបើក និងបិទដោយក្រឹត្យរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ។

ត-កូរ៉ុម(quorum)

នៅពេលបើកសម័យប្រជុំ បើមិនមានកូរ៉ុមពីរភាគបី(២/៣) ពេលប្រជុំត្រូវលើកទៅថ្ងៃធ្វើការទីពាបន្ទាប់ ។ ក្នុងករណីនេះការពិភាក្សាអាចយកជាការបានទេ លុះត្រាតែមានវត្តមានសមាជិកព្រឹទ្ធសភាយ៉ាងតិចពាក់កណ្តាល ។

III-ឧំនាក់ឧំនងជាមួយរដ្ឋសភា និងអំណាចនីតិប្រតិបត្តិ

ក-អំណាចនីតិប្បញ្ញត្តិ

រដ្ឋធម្មនុញ្ញបានចែងរៀបរាប់វិស័យដែលត្រូវចែងដោយច្បាប់ ។ ដទៃពីនោះ វិស័យនានាត្រូវចែងដោយបទបញ្ជា(règlement) ។

១-តំនិតផ្តួចផ្តើមធ្វើច្បាប់

តំនិតផ្ទួចផ្តើមធ្វើច្បាប់ជាសិទ្ធិរបស់រដ្ឋាភិបាល និងរបស់សមាជិកសភា ។

២-សិទ្ធិវិសោធនកម្ម

សមាជិកសភា និងរដ្ឋាភិបាលមានសិទ្ធិធ្វើវិសោធនកម្ម ។ សេចក្តីស្នើ ឬវិសោធនកម្មរបស់សមាជិកសភាមិនអាចទទួលយកបានទេ បើសិនជានាំឱ្យមានការកាត់បន្ថយធនធានសាធារណៈ ឬការបង្កើត ឬការបន្ថែមបន្ទុកសាធារណៈ លើកលែងតែមានភ្ជាប់ទៅជាមួយនូវសេចក្តីស្នើបន្ថែមចំណូល ឬសេដ្ឋកិច្ចសមមូល ។

ញ-និតិវិធីធ្វើច្បាប់

សេចក្តីព្រាងច្បាប់ត្រូវដាក់ជូនសភាណាមួយក៏បាន។ សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុត្រូវតែដាក់ជូនរដ្ឋសភាពិនិត្យជាលើកដំបូង ។

ក-និតិវិធីធម្មតា

ការពិភាក្សាត្រូវធ្វើនៅសភាដែលបានទទួល លើអត្ថបទរបស់រដ្ឋាភិបាល។ សភាមួយទៀតដែលទទួលអត្ថបទដែលសភាមុនបានអនុម័តរួច ពិភាក្សាលើអត្ថបទដែលសភាមុនបានធ្វើមក ។

សេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ ត្រូវបញ្ជូនទៅគណៈកម្មការអចិន្ត្រៃយ៍ណាមួយ។ សេចក្តីព្រាងឬសេចក្តីស្នើអាចត្រូវបញ្ជូនទៅគណៈកម្មការពិសេស (ដែលត្រូវបង្កើតឡើង) កាលបើមានសំណើពីរដ្ឋាភិបាល ឬពីសភាសាមី។

ពេលសភាប្រគល់អត្ថបទឱ្យគណៈកម្មការណាមួយរបស់ខ្លួនពិនិត្យ រដ្ឋាភិបាលអាច ក្រោយបើកការពិភាក្សា ជំទាស់នឹងការពិនិត្យវិសោធនកម្មទាំងអស់ដែលមិនបានដាក់ឱ្យគណៈកម្មការពិនិត្យជាមុន ។

សេចក្តីព្រាងច្បាប់ទាំងអស់ត្រូវពិនិត្យជាបន្តបន្ទាប់នៅសភាទាំងពីរ ដើម្បីឱ្យបានអត្ថបទតែមួយ ។

បើរដ្ឋាភិបាលស្នើសុំ សភាសាមីអនុម័តតែម្តងលើអត្ថបទទាំងមូល ឬផ្ទែកណាមួយដោយរក្សាទុកតែវិសោធនកម្មដែលស្នើឬដែលខ្លួនយល់ព្រម ។

បើបន្ទាប់ពីមានការមិនយល់ព្រមរវាងសភាទាំងពីរសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់មិនអាចអនុម័តក្រោយការអានលើកទី២នៅសភានីមួយ១ ឬបើរដ្ឋាភិបាលបានប្រកាសការប្រញ្ញាប់ក្រោយការអានលើកទី១នៅសភានីមួយ១ រដ្ឋាភិបាលអាចបង្កើតឱ្យមានការប្រជុំគណៈកម្មការចំរុះសមភាគី(commission mixte paritaire)ដែលត្រូវតាក់តែងអត្ថបទមួយលើបញ្ញត្តិដែលនៅសេសសល់ ។

អត្ថបទដែលតាក់តែងឡើងដោយគណៈកម្មការចំរុះ អាចដាក់ជូនដោយរដ្ឋាភិបាលទៅសភាទាំងពីរដើម្បីអនុម័ត ។ ពុំមានវិសោធនកម្មណាមួយអាចទទួលយកឡើយលើកលែងតែមាន

ការយល់ព្រមពីរដ្ឋាភិបាល ។ បើគណៈកម្មការចំរុះមិនអាចរកអត្ថបទរួមបាន រដ្ឋាភិបាលអាច (ក្រោយការអានជាថ្មីនៅរដ្ឋសភានិងនៅព្រឹទ្ធសភា) សុំឱ្យរដ្ឋសភាអនុម័តជាចុងក្រោយ ។ ក្នុងករណីនេះ រដ្ឋសភាអាចយកអត្ថបទរបស់គណៈកម្មការចំរុះ ឬអត្ថបទចុងក្រោយរបស់ខ្លួន ដោយមានវិសោធនកម្មមួយឬច្រើនរបស់ព្រឹទ្ធសភា(បើសិនជាមាន) ។

ខ-បញ្ញត្តិដោយឡែកចំពោះច្បាប់ថវិកា

សេចក្តីព្រាងច្បាប់ថវិកាត្រូវដាក់ជូនសភាទាំងពីរយ៉ាងយូរ នៅពេលបើកសម័យប្រជុំសាមញ្ញប្រចាំឆ្នាំលើកទី២ ។ សភាមានពេល៨០ថ្ងៃ យ៉ាងច្រើនសម្រាប់អនុម័ត ។

ក្នុងករណីប្រធានសក្តិ (force majeure) ដែលមិនអាចដាក់សេចក្តីព្រាងបាន សភាត្រូវប្រជុំជាវិសាមញ្ញមួយរយៈពេលចាំបាច់សម្រាប់ការអនុម័ត ។

បើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុមិនបានអនុម័តក្នុងរយៈពេលនេះទេ សេចក្តីព្រាងអាចទទួលជាធរមានដោយបទបញ្ជា(ordonnance) ។ បទបញ្ជានេះត្រូវរាប់បញ្ចូលវិសោធនកម្មដែលអនុម័តដោយសភា និងដែលរដ្ឋាភិបាលយល់ព្រម ។

បើច្បាប់មិនអាចប្រកាសឱ្យប្រើមុនចាប់ផ្តើមឆ្នាំថវិកា(année budgétaire)រដ្ឋាភិបាលទទួលការអនុញ្ញាឱ្យចេញក្រឹត្យដើម្បីបន្តការងារសេវានានា ។

-និតិសម្បទា

ដើម្បីអនុវត្តកម្មវិធីរបស់ខ្លួន រដ្ឋាភិបាលអាចស្នើសុំសភានូវការអនុញ្ញាតឱ្យចេញបទបញ្ជា (ដែលមានលក្ខណៈជាច្បាប់)សម្រាប់រយៈពេលមួយមានកំណត់ ។

ខ-អំណាចត្រួតពិនិត្យ

១-សិទ្ធិទទួលព័ត៌មាន(droit d'information)

រដ្ឋាភិបាលមានកាតព្វកិច្ចផ្តល់ជូនសភានូវគ្រប់ការពន្យល់ដែលសភាស្នើសុំ លើការគ្រប់គ្រង និងសកម្មភាពរបស់រដ្ឋាភិបាល ។

២-មធ្យោបាយព័ត៌មាន និងត្រួតពិនិត្យ

-ការកោះអញ្ជើញ

-សំណួរជាលាយលក្ខណ์អក្សរ

-សំណួរផ្ទាល់មាត់

-គណៈកម្មការស៊ើបអង្កេត

-ញត្តិបន្ទោស

-សវនកម្មនៅតាមគណៈកម្មការ ។

៣-ការត្រួតពិនិត្យថវិកា

សភាគណនីនៃតុលាការកំពូលជួយរដ្ឋាភិបាលនិងសភាលើការងារត្រួតពិនិត្យច្បាប់ហិរញ្ញវត្ថុ ។

៤-នាយករដ្ឋមន្ត្រីមានសិទ្ធិស្នើសុំឱ្យព្រឹទ្ធសភាផ្តល់ការយល់ព្រម លើសេចក្តីថ្លែងការណ៍នយោបាយទូទៅ ។

ត-រប្យៀបវារៈ

រប្យៀបវារៈរបស់សភាទាំងពីរមានតាមអាទិភាព និងតាមលំដាប់ដែលរដ្ឋាភិបាលបានកំណត់នូវការពិភាក្សាលើសេចក្តីព្រាងច្បាប់នានាដែលរដ្ឋាភិបាលបានបញ្ជូនមក ។

ក្នុងមួយសប្តាហ៍មានមួយពេលត្រៀមសម្រាប់ការពិនិត្យ និងអនុម័តសេចក្តីស្នើច្បាប់ ។

ក្នុង១៥ថ្ងៃ មានមួយពេលត្រៀមសម្រាប់សមាជិកសភាតាំងសំណួរ និងសម្រាប់រដ្ឋាភិបាលឆ្លើយ ។

ឃ-ទំនាក់ទំនងជាមួយប្រធានាធិបតីនៃសាធារណរដ្ឋ

ប្រធានាធិបតីនៃសាធារណរដ្ឋទាក់ទងជាមួយសភាទាំងពីរដោយសារដែលត្រូវអាន និងមិនអាចពិភាក្សាបានឡើយ ។ នៅក្រៅសម័យប្រជុំ សភាត្រូវរួមប្រជុំជាពិសេសសម្រាប់ស្តាប់សារនេះ ។

V-**បទឃ្យញ្ញត្តិដោយឡែក**

ក-ការសើរើរដ្ឋធម្មនុញ្ញ

តំនិតផ្តួចផ្តើមសើរើរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ក្រោយការសម្រេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី និងជាសិទ្ធិរបស់សមាជិកសភា ។

ដើម្បីយកជាការបានសេចក្តីព្រាង ឬសេចក្តីស្នើសើរើត្រូវតែអនុម័ត ដោយព្រមព្រៀងគ្នារវាងសភាទាំងពីរតាមសម្លេងភាគច្រើនពីរភាគបី(២/៣) នៃសមាជិកសភានីមួយ១ ។

ការសើរើរដ្ឋធម្មនុញ្ញត្រូវអនុម័តដោយប្រជាមតិ ។ ចំពោះការសើរើដែលមានលក្ខណៈបច្ចេកទេស អាចយកតាមសម្លេងភាគច្រើនបីភាគប្រាំ(៣/៥) នៃសមាជិករដ្ឋសភា និងព្រឹទ្ធសភាប្រជុំជាសមាជ ។

ខ-ប្រធានព្រឹទ្ធសភា

១-ប្រធានព្រឹទ្ធសភា (និងការិយាល័យ) ត្រូវជ្រើសតាំងក្រោយការផ្លាស់ប្តូរថ្មីជាផ្នែក។

២-ស្ថិតិប្រធានាធិបតីនៃសាធារណរដ្ឋ

ក្នុងករណីវិស្សមកាលរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ភារកិច្ចរបស់ប្រធានាធិបតីត្រូវអនុវត្តជាបណ្តោះអាសន្នដោយប្រធានព្រឹទ្ធសភា និងក្នុងករណីដែលប្រធានមិនអាចបំពេញភារកិច្ចនេះបាន អនុប្រធានព្រឹទ្ធសភាជាអ្នករ៉ាប់រង ។

ក្នុងរយៈពេលស្ថិតិនេះ ប្រធានព្រឹទ្ធសភាមិនអាចដកហូតតំណែងនាយករដ្ឋមន្ត្រី និងរដ្ឋាភិបាលព្រមទាំងមិនអាចដំណើរការសើរើរដ្ឋធម្មនុញ្ញ និងមិនអាចរំលាយរដ្ឋសភាបានឡើយ ។

៣-ក្នុងករណីរំលាយរដ្ឋសភាឬករណីមានវិធានការជាតិសេស ប្រធានាធិបតីនៃសាធារណរដ្ឋត្រូវតែជូនព័ត៌មាននោះទៅប្រធានព្រឹទ្ធសភា ។

គ-ការត្រួតពិនិត្យធម្មនុញ្ញភាព

១-ច្បាប់

តាមសំណើរបស់ប្រធានព្រឹទ្ធសភា ឬរបស់សមាជិកព្រឹទ្ធសភាយ៉ាងតិចមួយភាគដប់(ឬប្រធានាធិបតីនៃសាធារណរដ្ឋ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា ឬសមាជិករដ្ឋសភាយ៉ាងតិចមួយភាគដប់) ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចអំពីធម្មនុញ្ញភាពនៃច្បាប់មុនប្រកាសឱ្យប្រើ ។

២-ការសន្យាជាអន្តរជាតិ

ប្រធានព្រឹទ្ធសភាក៏ដូចជាប្រធានាធិបតីនៃសាធារណរដ្ឋ ឬប្រធានរដ្ឋសភាអាចស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃការសន្យាជាអន្តរជាតិ ។

បើក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាការសន្យានោះមានខ្ទះផ្ទុយនឹងរដ្ឋធម្មនុញ្ញ ការផ្តល់សច្ចាប៉ន់អាចធ្វើបានតែនៅក្រោយការសើរើរដ្ឋធម្មនុញ្ញ ។

ឃ-ការតែងតាំង

ប្រធានព្រឹទ្ធសភាតែងតាំង :

-សមាជិកតុលាការកំពូល៤រូប ក្នុងចំណោម១៦រូប(ប្រធានតុលាការកំពូលត្រូវតែងតាំងដោយប្រធានាធិបតីនៃសាធារណរដ្ឋ ក្រោយពីបានយោបល់ពីប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា)

-សមាជិកក្រុមប្រឹក្សាធម្មនុញ្ញពារូបក្នុងចំណោម៩រូប

-សមាជិកក្រុមប្រឹក្សាជាន់ខ្ពស់ខាងតមនាតមន៍

ង-តុលាការយុត្តិធម៌ជាន់ខ្ពស់មានសមាជិក១៥រូប ក្នុងនោះ៤រូបជាសមាជិកព្រឹទ្ធសភា

ច-ការប្រកាសសង្គ្រាមត្រូវមានការអនុញ្ញាតពីសភា

ឆ-ស្ថានភាពអាសន្ន និងស្ថានភាពបន្ទាន់ត្រូវប្រកាសដោយក្រុមប្រឹក្សារដ្ឋមន្ត្រី ។ រដ្ឋាភិ-បាលត្រូវជូនដំណឹងនេះទៅការិយាល័យសភាទាំងពីរ ។ ការពន្យាររយៈពេលលើសពី១២ ថ្ងៃត្រូវមានការអនុញ្ញាតពីសភាទាំងពីរប្រជុំរួមគ្នា ។

រដ្ឋធម្មនុញ្ញរបស់រដ្ឋសេ៊ីប៊ី និងម៉ុងតេណេក្រូថ្មីត្រូវបានប្រកាសដោយសភាយូហ្គោស្លាវី ថ្ងៃទី៤ខែកុម្ភៈ ។ក្នុងចំណោមស្ថាប័នរួម រដ្ឋធម្មនុញ្ញបង្កើតសភាតែមួយ(Parlement monocaméral) ។

ការបោះឆ្នោតមិនផ្ទាល់នានា(élections indirectes) ដោយសភាសេ៊ីប៊ី និងម៉ុងតេណេក្រូ បានធ្វើឡើងនៅថ្ងៃទី២៥ខែកុម្ភៈ ដើម្បីជ្រើសរើសសមាជិកសភាថ្មីចំនួន១២៦រូប (សេ៊ីប៊ី:៥១រូប និងម៉ុងតេណេក្រូ :៣៥រូប) ។

សភាថ្មីត្រូវបានបង្កើតរួចជាស្រេចការនៅថ្ងៃទី៣ខែមីនា ឆ្នាំ២០០៣ ។

I-សមាសភាព

សមាជិករដ្ឋសភា៤០រូប ជ្រើសរើសដោយការបោះឆ្នោតសកលដោយផ្ទាល់ (ចាប់តាំងពីការសើរើរដ្ឋធម្មនុញ្ញខែកក្កដាឆ្នាំ២០០០ កាលមុនការបោះឆ្នោតធ្វើឡើងដោយមិនផ្ទាល់ : សមាជិកសភាបណ្តាសាធារណរដ្ឋត្រូវបានជ្រើសតាំងដោយសភាសាធារណរដ្ឋសេ៊ីប៊ី និងម៉ុងតេណេក្រូ លើមូលដ្ឋានៃតំណាងគណបក្សក្នុងអង្គការទាំងនេះ ក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីការបោះឆ្នោតសភាពលរដ្ឋ(chambre des citoyens) ។

សមាជិកទាំងនេះជាតំណាងសាធារណរដ្ឋសមាជិកយូហ្គោស្លាវី ដែលបានជ្រើសតាំងខ្លួន (សេ៊ីប៊ី :២០រូប និងម៉ុងតេណេក្រូ:២០រូប) ។

II-របបបោះឆ្នោត

មណ្ឌល :១០(៥នៅសេ៊ីប៊ី និង១នៅម៉ុងតេណេក្រូ)

អាណត្តិ :៤ឆ្នាំ ។ អាណត្តិសភាសហព័ន្ធ(សភាពលរដ្ឋ និងសភាបណ្តាសាធារណរដ្ឋ) ត្រូវបញ្ចប់បើ៣ខែក្រោយការកំណត់ដែលមានក្នុងនីតិវិធី រដ្ឋាភិបាលសហព័ន្ធមិនត្រូវបានជ្រើសតាំង ឬបើក្នុងរយៈពេលនេះ ថវិកាសហព័ន្ធមិនត្រូវបានអនុម័ត ។

ការបោះឆ្នោតត្រូវបានរៀបចំធ្វើក្នុងរយៈពេល៦០ថ្ងៃ ។

ការផ្ទាស់ប្តូរចុងក្រោយ: ២០ និង២៤ ខែកញ្ញា ឆ្នាំ២០០០

លក្ខខណ្ឌ : អាយុ១៨ឆ្នាំ ពលរដ្ឋយូហ្គូស្លាវី រស់នៅក្នុងប្រទេស

វិសមិតភាព: មុខងារក្នុងរដ្ឋាភិបាលសហព័ន្ធ ។

<u>កំណត់សំគាល់</u> :ប្រព័ន្ធបោះឆ្នោតនៅឆ្នាំ១៩៩៨ សភាម៉ុងតេណេហ្គ្រូបានអនុម័តច្បាប់មួយចែងពីប្រព័ន្ធសម្លេងភាគច្រើន ដែលត្រូវបានប្រកាសថាផ្ទុយនឹងរដ្ឋធម្មនុញ្ញដោយសេចក្តីសម្រេចរបស់តុលាការធម្មនុញ្ញ ធ្វើឡើងតាមនីតិវិធីប្រញាប់ ។

ថ្ងៃទី១១ ខែមេសា ឆ្នាំ២០០០ សភាស៊ើបអនុម័តច្បាប់បោះឆ្នោតថ្មីមួយ ដែលរក្សាទុកនូវប្រព័ន្ធសមាមាត្រ តាមរបៀប២យ៉ាង :

១-ប្រធានសភាស៊ើបមានអំណាចឆន្ទានុសិទ្ធិ (pouvoir discrétionnaire) ក្នុងការសម្រេចអំពីចំនួនសមាជិករដ្ឋសភាជាប់ឆ្នោតនៅក្នុងក្រុមសមាជិកសភា ។

២- គណបក្សណាមួយដែលមិនបានចូលរួមក្នុងការបោះឆ្នោត មិនអាចជ្រើសរើសតំណាងនៅក្នុងសភាសហព័ន្ធឡើយ ។

III-សម័យប្រជុំ

ក-សម័យប្រជុំសាមញ្ញ

សភាបណ្តាសាធារណរដ្ឋប្រជុំដោយឯកានការកោះ២ដងក្នុងមួយឆ្នាំ ស្របតាមបទបញ្ញត្តិផ្ទៃក្នុងរបស់ខ្លួន ។ សម័យប្រជុំលើកទី១ចាប់ផ្តើមពីថ្ងៃធ្វើការទី១ ខែកុម្ភៈ និងលើកទី២ ពីថ្ងៃធ្វើការទី១ ខែកញ្ញា ។

ខ-សម័យប្រជុំវិសាមញ្ញ

សម័យប្រជុំវិសាមញ្ញអាចកោះតាមសំណើរបស់សមាជិកសភាយ៉ាងតិចមួយភាគបី ឬតាមសំណើរបស់រដ្ឋាភិបាលសហព័ន្ធ តាមរបៀបវារៈមួយយ៉ាងជាក់លាក់ ។

IV-ទំនាក់ទំនងជាមួយសភារដ្ឋសភា និងអំណាចនីតិប្រតិបត្តិ

ក-អំណាចនិតិប្បញ្ញត្តិ

១-ការផ្តួចផ្តើមធ្វើច្បាប់

សភាបណ្តាសាធារណរដ្ឋមានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់(ផ្តួចជាសមាជិកសភា រដ្ឋាភិបាលសហព័ន្ធ និងអ្នកបោះឆ្នោតចំនួន៣០.០០០នាក់យ៉ាងតិច ។

ធនាគារជាតិយូរ៉ូ ស្ថាប័ន ក៏អាចដាក់សេចក្តីព្រាងច្បាប់សហព័ន្ធ អំពីប្រាក់ការ ប្រព័ន្ធប្តូរប្រាក់ និងឥណទាន ។

២-សិទ្ធិវិសោធនកម្ម

សភាបណ្តាសាធារណរដ្ឋមានសិទ្ធិវិសោធនកម្ម ។

៣-នីតិវិធីធ្វើច្បាប់

ក-នីតិវិធីធម្មតា

ការណាសេចក្តីព្រាងច្បាប់លើបញ្ហារបស់សហព័ន្ធ ច្បាប់ឯទៀត ឬអត្ថបទដែលមានលក្ខណៈច្បាប់មិនត្រូវបានអនុម័តដោយព្រមព្រៀងគ្នារវាងសភាទាំងពីរ សភាទាំងពីរប្រជុំគណៈកម្មការដែលមានសមាជិក១៥រូប មកពីសភានីមួយៗដើម្បីសម្រួលអត្ថបទ ។

សភាទាំងពីរអនុម័តលើសេចក្តីព្រាងដើម(avant projet) របស់គណៈកម្មការ ។

បើគណៈកម្មការរកការព្រមព្រៀងគ្នាមិនបានក្នុងរយៈពេល១ខែ ឬបើសភាទាំងពីរមិនទទួលយកសេចក្តីព្រាងច្បាប់ អត្ថបទដែលអនុម័តដោយសភាពេលវេលា ត្រូវចុះជាការអនុម័ត បណ្តោះអាសន្ន ។ បើជាអត្ថបទទាក់ទងនឹងសេដ្ឋកិច្ច ពន្ធដារ បច្ចេកវិទ្យា ឬ បរិស្ថានអត្ថបទដែលអនុម័តដោយសភាបណ្តាសាធារណរដ្ឋត្រូវដាក់ឱ្យអនុវត្តជាបណ្តោះអាសន្ន ។

ច្បាប់សហព័ន្ធដែលដាក់ឱ្យអនុវត្តជាបណ្តោះអាសន្នចូលជាធរមាន តែនៅពេលដែលត្រូវបានអនុម័ត ដោយសភាទាំងពីរយ៉ាងយូរ១ឆ្នាំក្រោយការចាប់ផ្តើមអនុវត្ត ។

បើច្បាប់នោះមិនត្រូវបានអនុម័តក្នុងរយៈពេលអនុវត្តជាបណ្តោះអាសន្ន អាណត្តិរបស់សភាសហព័ន្ធត្រូវបញ្ចប់ ។

ខ-បទបញ្ញត្តិដោយឡែកចំពោះថវិកា

បើថវិកាសហព័ន្ធមិនត្រូវបានអនុម័តនៅដើមឆ្នាំសារពើពន្ធ ចំណាយនានាត្រូវអនុញ្ញាតឱ្យប្រើដូចថវិកាឆ្នាំមុន រហូតដល់មានការអនុម័ត ។

ខ-អំណាចត្រួតពិនិត្យ

១-ការបង្កើតរដ្ឋាភិបាល

លេខាធិការដ្ឋមន្ត្រីដែលប្រធានាធិបតីបានស្នើឡើងត្រូវបង្ហាញកម្មវិធី និងសមាសភាពរដ្ឋាភិបាលចំពោះសភាសហព័ន្ធ ។ រដ្ឋាភិបាលត្រូវចាត់ទុកថាបានបង្កើតកាលណាសភាយល់ព្រមលើនាយករដ្ឋមន្ត្រី តាមសម្លេងភាគច្រើននៃសមាជិកសភាទាំងអស់ ក្នុងសភានីមួយៗ ។

២-ការទទួលខុសត្រូវរបស់នាយករដ្ឋមន្ត្រីចំពោះសភាសហព័ន្ធ

នាយករដ្ឋមន្ត្រីអាចស្នើសុំឱ្យសភាសហព័ន្ធអនុម័តផ្តល់ការទុកចិត្ត ។ បើការអនុម័តមានលក្ខណៈអវិជ្ជមាន រដ្ឋាភិបាលត្រូវសុំលាលែង ។

៣-ញត្តិបន្ទោស

សភាសហព័ន្ធអាចបន្ទោសរដ្ឋាភិបាល ។ ញត្តិបន្ទោសអាចដាក់ដោយសមាជិក៣០រូបយ៉ាងតិចនៃសភាណាមួយ ។ ការអនុម័តត្រូវធ្វើនៅ៣ថ្ងៃយ៉ាងតិច ក្រោយពេលដាក់ញត្តិ ។

ការអនុម័តត្រូវយកតាមសម្លេងភាគច្រើននៃសមាជិកទាំងអស់នៃសភានីមួយៗ ។

ការអនុម័តញត្តិបន្ទោសនាំឱ្យរដ្ឋាភិបាលលាលែង ។

ត-ការរំលាយ និងការពន្យារ

១-ការរំលាយ

សភាសហព័ន្ធ អាចត្រូវរំលាយដោយក្រឹត្យរបស់ប្រធានាធិបតីនៃសាធារណរដ្ឋតាម សំណើរបស់រដ្ឋាភិបាលសហព័ន្ធ ។ ការបោះឆ្នោតត្រូវរៀបចំឡើង ក្នុងរយៈពេល៦០ថ្ងៃពីពេលរំលាយ ។

មុខងាររបស់រដ្ឋាភិបាលសហព័ន្ធត្រូវបញ្ឈប់ក្នុងករណីរំលាយ (ឬការបំព្រួញអាណត្តិ) សភាសហព័ន្ធ ។

សភាសហព័ន្ធមិនអាចត្រូវរំលាយក្នុងខែទី១ និង៦ខែចុងក្រោយនៃអាណត្តិស្ថានភាពសង្គ្រាម ករណីគំរាមកំហែងធ្ងន់ធ្ងរនៃសង្គ្រាម ឬស្ថានភាពបន្ទាន់ ។

២-ការពន្យារ

ក្នុងករណីសង្គ្រាម ការគំរាមកំហែងធ្ងន់ធ្ងរនៃសង្គ្រាម ឬស្ថានភាពបន្ទាន់ សភាសហព័ន្ធ អាចសម្រេចបន្តអាណត្តិសមាជិកសភាសហព័ន្ធ ទៅតាមសភាពការណ៍ជាក់ស្តែង ឬរហូតដល់មានលក្ខណៈសម្បត្តិរៀបចំការបោះឆ្នោតបាន ។

៧-**បទប្បញ្ញត្តិដោយឡែក**

ក-ការកែប្រែរដ្ឋធម្មនុញ្ញ

១- គំនិតផ្តួចផ្តើម

គំនិតផ្តួចផ្តើមធ្វើឡើង ដោយសេចក្តីស្នើរបស់សមាជិកសភាបណ្តារដ្ឋចំនួន២០រូបយ៉ាងតិច (ឬសមាជិកសភាពលរដ្ឋ៣០យ៉ាងតិច ឬរដ្ឋាភិបាលសហព័ន្ធ ឬអ្នកបោះឆ្នោត១០០.០០០នាក់យ៉ាងតិច) ចំពោះការកែប្រែផ្សេងពីការកែប្រែទាក់ទងនឹងគោលការណ៍ និងរចនាសម្ព័ន្ធសហព័ន្ធ សមត្ថកិច្ចសហព័ន្ធ និងបទប្បញ្ញត្តិទាំងឡាយទាក់ទងនឹងនីតិវិធីនៃការកែប្រែរដ្ឋធម្មនុញ្ញ (ចំពោះការកែប្រែបទប្បញ្ញត្តិទាំងនេះ សភាបណ្តាសាធរណរដ្ឋត្រូវដកចេញពីនីតិវិធី) ។

២-នីតិវិធី

នីតិវិធីនៃការកែប្រែត្រូវបានសម្រេច និងសេចក្ដីស្នើត្រូវអនុម័តដោយសភាសហព័ន្ធតាមសម្លេងភាគច្រើនពីរភាគបីនៃសមាជិកសភានីមួយៗ។

ក្នុងករណីបដិសេធសេចក្ដីស្នើ មិនអាចដាក់មកវិញក្នុងរយៈពេល១ឆ្នាំបានទេ។

ខ-ប្រធានសភាបណ្ដារដ្ឋ

១-ប្រធានសភាបណ្ដារដ្ឋត្រូវជ្រើសតាំងសម្រាប់រយៈពេល៤ឆ្នាំ ក្នុងចំណោមសមាជិកសភា។

២-ស្ថិតិប្រមុខរដ្ឋ

ក្នុងករណីដែលប្រធានាធិបតីមិនអាចបំពេញមុខងារបាន មុខងារនេះត្រូវកាន់កាប់ដោយប្រធានសភាបណ្ដារដ្ឋ រហូតដល់មានការបោះឆ្នោតជ្រើសរើសប្រធានាធិបតីថ្មី ។

គ-ប្រធានសភាទាំងពីរដឹកនាំអង្គប្រជុំរួមដោយប្តូរវេនគ្នា។

ឃ-ចំពោះប្រធានាធិបតីនៃសាធារណរដ្ឋ

១-ប្រធានាធិបតីនៃសាធារណរដ្ឋត្រូវជ្រើសតាំងដោយសភាសហព័ន្ធ សម្រាប់រយៈពេល ៤ឆ្នាំ។

២-ប្រធានាធិបតីនៃសាធារណរដ្ឋអាចត្រូវដកហូតពីតំណែង តែក្នុងករណីរំលោភរដ្ឋធម្មនុញ្ញធ្ងន់ធ្ងរដែលរៀបចំដោយសភាសហព័ន្ធ។

ង-ការតែងតាំង

សភាសហព័ន្ធតែងតាំង និងដកហូត ចៅក្រមតុលាការសហព័ន្ធ(អាណត្តិ៩ឆ្នាំ) រដ្ឋអាជ្ញាសហព័ន្ធ(អាណត្តិ៤ឆ្នាំ) ។

-ចប់-

វិមានរដ្ឋធំការមន, មហាវិថីព្រះនរោត្តម,ភ្នំពេញ
ទូរស័ព្ទ :(៨៥៥-២៣) ២១១ ៤៤១,២,៣ ទូរសារ: (៨៥៥-២៣) ២១១ ៤៤៦
Email : oum_sarith@camnet.com.kh
Website : www.senate.gov.kh